ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
# ២០១៩-២០២៣

ដើម្បីកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព
ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០

# ព្រះរាជក្រម

នស/រកម/០៧១៩/ ០១១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣

**មាត្រា១.—**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.—**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ នេះ។

**មាត្រា៣.—**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

នស/រកម.០៧១៩.០១៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានបន្តប្រកាន់ខ្ជាប់នូវគោលនយោបាយសាមគ្គីជាតិ ក្នុងការប្រមូលកម្លាំងប្រជាជាតិទាំងមូលជាធ្លុងមួយពីគ្រប់មជ្ឈដ្ឋាន និន្នាការនយោបាយទាំងក្នុងនិងក្រៅប្រទេស និងគ្រប់ស្រទាប់វណ្ណៈ ក្រោមបាវចនា *"ជាតិ សាសនា ព្រះមហាក្សត្រ"* ដើម្បីធ្វើឱ្យប្រទេសមានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សុខសន្តិភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពថ្កើងថ្កាន។ កម្ពុជាបាននិងកំពុងបន្តទទួលបាននូវ *"ផលចំណេញពីសន្តិភាពពេញលេញ"* ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស និងបានចូលរួមវិភាគទានយ៉ាងថ្លៃថ្លាក្នុងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងលើពិភពលោក។ កត្តាស្ថិរភាពនយោបាយពេញលេញដែលកម្ពុជាទទួលបាន បានអនុញ្ញាតឱ្យកម្ពុជាមានលទ្ធភាពអនុវត្តនូវកិច្ចការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ សំដៅពង្រឹងសមត្ថភាពមនុស្សនិងស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងបង្កើតបរិយាកាសរឹងមាំ ដើម្បីបន្តទាក់ទាញវិនិយោគទុនទាំងក្នុងនិងក្រៅប្រទេស ក្នុងគោលដៅធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័សបន្ថែមទៀត។

ក្នុងអាណត្តិ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** កម្ពុជាមានការផ្លាស់ប្តូរយ៉ាងច្រើន មិនត្រឹមតែក្នុងទិដ្ឋភាពនយោបាយនិងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការប្រែប្រួលក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមផងដែរ។ ស្ថិរភាពនយោបាយ សុខសន្តិភាព និងសុវត្ថិភាពបែបនេះ គឺជាបុព្វលក្ខខណ្ឌសម្រាប់កម្ពុជាប្រើប្រាស់បានពេញលេញនូវសក្តានុពលសង្គម សេដ្ឋកិច្ចរបស់ខ្លួន។ ការបោះឆ្នោតសកលឆ្នាំ១៩៩៣ បាននាំមកនូវការអនុវត្តគោលការណ៍នៃ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស សេដ្ឋកិច្ចទីផ្សារ និងការគោរពសិទ្ធិសេរីភាពនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវ ***កម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នាឆ្នាំ១៩៩៤ និង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី១ (១៩៩៦-២០០០)*** សម្រាប់កំណត់ចក្ខុវិស័យនៃការកសាងនិងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ដោយផ្តោតជាសំខាន់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ។

លើសពីនេះទៀត ដំណាក់កាលនៃការផ្លាស់ប្តូរមុខមាត់របស់កម្ពុជាដ៏គួរឱ្យកត់សម្គាល់ គឺនៅក្នុងឆ្នាំ១៩៩៨-២០០៣ ដែលជារយៈពេលប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដោយមិនត្រឹមតែមានការផ្លាស់ប្តូរទិដ្ឋភាពសង្គម និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្លាស់ប្តូរនូវទិដ្ឋភាពនយោបាយថែមទៀតផង។ ជាក់ស្តែង ការបោះឆ្នោតសកលឆ្នាំ១៩៩៨ ការអនុវត្តដោយជោគជ័យនូវនយោបាយ "***ឈ្នះ ឈ្នះ***" ដែល

បានរំលាយអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហម និងការធ្វើសមាហរណកម្មនៃអតីតកងទ័ពខ្មែរក្រហម និងបងប្អូនខ្មែរដែលរស់នៅក្នុងតំបន់អតីតខ្មែរក្រហមកាន់កាប់ ឱ្យចូលមកក្នុងសង្គមកម្ពុជាតែមួយ ដែលបាននាំមកនូវសុខសន្តិភាពពេញផ្ទៃប្រទេស។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវ*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ (២០០១-២០០៥)* ដើម្បីផ្តល់ការតម្រង់ទិសដល់ការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ព្រមទាំងបានអនុវត្តប្រកបដោយជោគជ័យនូវ "*យុទ្ធសាស្ត្រត្រីកោណ*" ដែលបានផ្តោតលើគោលដៅសំខាន់ៗចំនួនបីគឺៈ (១) ការធានាឱ្យមានសន្តិភាព ស្ថិរភាព និងសន្តិសុខ (២) ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងការធ្វើឱ្យមានទំនាក់ទំនងល្អឡើងវិញជាមួយនឹងសហគមន៍អន្តរជាតិ និង (៣) ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច។ ប្រការនេះ បានប្រែក្លាយកម្ពុជាពីប្រទេសមួយដែលធ្លាប់មានអស្ថិរភាព សង្គ្រាម ជម្លោះផ្ទៃក្នុង និងភាពអន់ថយ ឱ្យក្លាយទៅជាចំណុចកណ្តាលមួយនៃសន្តិភាពដ៏រឹងមាំ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការគោរពលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស កិច្ចសហប្រតិបត្តិការនិងកិច្ចអភិវឌ្ឍ ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ។ ទិដ្ឋភាពមួយទៀតនៃការវិវឌ្ឍដ៏វិជ្ជមាននិងគួរឱ្យកត់សម្គាល់ ដែលកើតមានឡើងចាប់តាំងពីឆ្នាំ២០០៣ រហូតមកដល់បច្ចុប្បន្ន រួមមានការបោះឆ្នោតសកល នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ និងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨(ប្រជាជនចេញទៅបោះឆ្នោតលើសពី ៨៣%) ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ដែលត្រូវបានទទួលស្គាល់ថាជា "*អច្ឆរិយហេតុនៃទន្លេមេគង្គ*" ម្តងទៀត និងសមិទ្ធផលជាច្រើនដែលសម្រេចបានតាមរយៈការអនុវត្តដោយជោគជ័យនូវ*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ (២០០១-២០០៥)* និង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ ទី២ និងទី៣ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* តាមរយៈ*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០, ២០០៩-២០១៣,* និង*២០១៤-២០១៨*។ តាមរយៈនេះ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនភាព សេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ក្នុងនោះកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានកម្រិត ៨,៤% ក្នុងរវាងឆ្នាំ១៩៩៤-២០០៦ ពីឆ្នាំ១៩៩៩-២០០៦ កំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានកម្រិតដល់ទៅ ៩% និងពីឆ្នាំ២០០៦-បច្ចុប្បន្ន រក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងកម្រិត ៧%។ ជាការពិត សមិទ្ធផលទាំងអស់នេះមិនអាចកាត់ផ្តាច់ពីការចូលរួមវិភាគទានដ៏ថ្លៃថ្លារបស់ដៃគូអភិវឌ្ឍទាំងអស់របស់កម្ពុជា។ វាក៏បានឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ដែលត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងការប្រើប្រាស់នូវហិរញ្ញប្បទានសហប្រតិបត្តិការគ្រប់ប្រភេទ ដែលកម្ពុជាទទួលបានពីដៃគូសហប្រតិបត្តិការក្រៅប្រទេសរបស់ខ្លួនក្នុងរយៈពេលកន្លងមកនេះ។ ជារួម ការដាក់ចេញនិងការអនុវត្តប្រកបដោយជោគជ័យនូវផែនការជាតិនិងយុទ្ធសាស្ត្រអភិវឌ្ឍនានា កន្លងមក បានផ្តល់នូវផែនទីតម្រង់ទិសសម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើដំណើរឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការកាត់បន្ថយភាពក្រីក្រ។ ការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ*គឺជាការបន្តពង្រឹងនូវសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងរយៈពេលកន្លងមក ដើម្បីធ្វើឱ្យសម្រេចបាននូវ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* កែលម្អ

និងបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ចនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ក្នុងទិសដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងការពារសម្បត្តិធម្មជាតិនិងសម្បត្តិវប្បធម៌ជាតិ ដែលទាំងអស់នេះគឺសុទ្ធតែជាកត្តាគន្លឹះដ៏សំខាន់បំផុត សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ការធ្វើឱ្យការអភិវឌ្ឍជាតិសម្រេចទៅបានដោយជោគជ័យក្នុងក្របខណ្ឌនៃទស្សនៈនេះ តម្រូវឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង កែលម្អ និងពង្រឹងនូវអាទិភាពគោលនយោបាយ បន្តកែលម្អនូវយុទ្ធសាស្ត្រតាមផ្នែកដើម្បីឆ្លុះបញ្ចាំងនូវសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា ដោយឈរលើបទពិសោធន៍ជាក់ស្តែងនៃការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* សម្រាប់នីតិកាលទី៣ នៃរដ្ឋសភាក្នុងពេលកន្លងមក។

ដើម្បីបន្តពង្រីកបន្ថែមនូវវឌ្ឍនភាពដែលសម្រេចបានក្នុងនីតិកាលទី៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ដែលជាមូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនិងសង្គម នៃ***កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល*** សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានរៀបចំ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០០៦-២០១០*** ដែលជាផែនការថ្មី និងត្រូវបានរៀបចំឡើងដោយប្រើទម្រង់របស់*យុទ្ធសាស្ត្រចតុកោណ*។ ក្នុងការរៀបចំ *ផ.យ.អ.ជ. ២០០៦-២០១០* រាជរដ្ឋាភិបាលបានប្រើប្រាស់ភាពជាម្ចាស់ពេញលេញក្នុងការគ្រប់គ្រងដំណើរការរៀបចំ ដោយធានាឱ្យមានការចូលរួមពិគ្រោះយោបល់ និងការផ្តល់អនុសាសន៍ពីគ្រប់ ចំណែកពាក់ព័ន្ធទាំងអស់។ ស្ថិតក្នុងជំហរម៉ឺងម៉ាត់ និងឥតងាករេក្នុងការអនុវត្ត*យុទ្ធសាស្ត្រចតុកោណ* និង *ផ.យ.អ.ជ. ២០០៦-២០១០* រាជរដ្ឋាភិបាលបានបង្កើតឡើងនូវបរិស្ថានអំណោយផល និងលក្ខខណ្ឌចាំបាច់ជាច្រើនដែលអាចនាំកម្ពុជាបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍស្របគ្នាជាមួយនឹងគោលបំណង ឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពុះពារបម្រើជាតិ និងប្រជាជននៅគ្រប់កាលៈទេសៈ ស្របតាមឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជន។

ជាក់ស្តែងយើងមាន*យុទ្ធសាស្ត្រចតុកោណ* ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** និង ***យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ*** ព្រមទាំងឯកសារជាច្រើនទៀតដែលមានលក្ខណៈជាផែនការ គោលនយោបាយ កម្មវិធីវិនិយោគ និងថវិកាជាតិ។ *ផ.យ.អ.ជ.* គឺជាឯកសារគោលនយោបាយសំខាន់ទី២ របស់រាជរដ្ឋាភិបាលកម្ពុជានិងជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្ត***កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល*** ក៏ដូចជា*យុទ្ធសាស្ត្រចតុកោណ*។ ដើម្បីធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារនិងលំដាប់លំដោយនៃការអនុវត្តរវាងឯកសារទាំងអស់នេះ រាជរដ្ឋាភិបាលបានបន្សុំអាណត្តិរបស់ *ផ.យ.អ.ជ.* ជាមួយនឹងអាណត្តិរបស់***កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល*** និង *យុទ្ធសាស្ត្រចតុកោណ*។

ក្នុងបរិការណ៍នេះ *ផ.យ.អ.ជ. ២០០៦-២០១០* ត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាពចំនួនពីរ គឺ*គោលដៅទី១* បន្ស៊ីអាណត្តិកាលរបស់ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម* ជាមួយនឹងអាណត្តិរបស់រាជរដ្ឋាភិបាលសំដៅធានាថាសកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ក្រសួង ស្ថាប័នទាំងអស់ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់ក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* និង *គោលដៅទី២* គឺដើម្បីធានាថាការងារដែលត្រូវលើកឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះត្រូវបានរៀបចំឡើង ដោយមានការគិតគូរដល់ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកដែលអាចកើតមានមកលើសេដ្ឋកិច្ចរបស់កម្ពុជា។

*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រដែលមានលក្ខណៈប្រសើរជាងមុន ព្រោះថាវិធីសាស្ត្រនេះបានផ្តោតលើ *ទី១ បញ្ជាក់ច្បាស់ពីក្រសួង ស្ថាប័ន* ទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងឡាយក្នុងមុំនីមួយៗនៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* *ទី២ បញ្ជាក់ពីសកម្មភាពជាក់លាក់* ដែលក្រសួង ស្ថាប័នបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ និង*ទី៣ កំណត់តម្លៃ* ដែលក្រសួង ស្ថាប័ន ត្រូវប៉ាន់ស្មានឱ្យបានត្រឹមត្រូវបំផុត ដើម្បីអនុវត្តសកម្មភាពទាំងឡាយដែលបានគ្រោង សម្រាប់ឆ្នាំ២០០៩ ដល់២០១៣។ ការរៀបចំ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* មានការចូលរួមនិងពិគ្រោះយោបល់ទូលំទូលាយ ទាំងក្នុងរង្វង់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ដើម្បីគ្រប់គ្រងនូវដំណើរការពង្រឹងសុខដុមនីយកម្មរវាងការរៀបចំផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងធនធានពីគ្រប់ប្រភពសម្រាប់អនុវត្តវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការកំណត់គម្រោងវិនិយោគសាធារណៈនានា ដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រថវិកា សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។

ជាលទ្ធផល តាមរយៈកិច្ចខិតខំប្រឹងប្រែងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្ត *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* នៅក្នុងដំណាក់កាលនៃផែនការនេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនមធ្យមប្រចាំឆ្នាំប្រមាណ៧%។ ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗ មានកម្រិតលើសពី ១ ០០០ ដុល្លារអាមេរិក ហើយអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយឱ្យមកត្រឹមប្រមាណ១៩% ក្នុងឆ្នាំ២០១១។ ជាពិសេស កម្ពុជាសម្រេចបានជោគជ័យគួរជាទីមោទនៈក្នុងការសម្រេចបានគោលដៅភាគច្រើននៃ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលបានធ្វើឱ្យកម្ពុជាត្រូវបានអង្គការសហប្រជាជាតិជ្រើសជាប្រទេសគំរូក្នុងការសម្រេចបាន*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*។

ដោយផ្អែកលើបទពិសោធន៍ លទ្ធផលដែលសម្រេចបានមហាសាលក្នុងនីតិកាលទី៣ ទី៤ និងទី៥ នៃរដ្ឋសភា សម្រាប់នីតិកាលទី៦នេះ រាជរដ្ឋាភិបាលយល់ឃើញថា*យុទ្ធសាស្ត្រចតុកោណ* ពិសេស

គោលដៅសម្រាប់ *កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* នៅតែចាំបាច់ និងសមស្របសម្រាប់កម្ពុជា បន្តអនុវត្តដោយរក្សាទុកនូវចតុកោណទាំងបួនឱ្យនៅដដែល ដោយពង្រីកវិសាលភាព និងសម្រិតសម្រាំង ធ្វើអាទិភាវូបនីយកម្មមុំនីមួយៗ នៃចតុកោណយុទ្ធសាស្ត្រទាំងបួន ព្រមទាំងកែលម្អរបៀបវារៈគោលនយោបាយ និងយន្តការអនុវត្តឱ្យកាន់តែល្អប្រសើរថែមទៀតឱ្យទៅជា *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* ដែលជានាទីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងបរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ និងអន្តរជាតិ។

*ផ.យ.អ.ជ. ២០១៩-២០២៣* គឺត្រូវបានបន្តរៀបចំឡើងសម្រាប់អនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* ដោយមានកំណត់អាទិភាពសូចនាករនានា និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងមានកំណត់ពីយន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃផ្អែកលើក្របខណ្ឌលទ្ធផល ជាពិសេស កំណត់ពីការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទៅតាមមុំនីមួយៗ ដើម្បីបន្តទទួលបានផលចំណេញខ្ពស់ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងឈានឡើងពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បន្តឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងរួមចំណែកសម្រេចឱ្យបានក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។ ការរៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣* គឺរាជរដ្ឋាភិបាលបានប្រើប្រាស់នីតិវិធី និងយន្តការដែលមានស្រាប់ដូចជាការរៀបចំ *ផ.យ.អ.ជ. ២០១៤-២០១៨* និងបានពិនិត្យនិងពិភាក្សាកាន់តែច្បាស់លាស់ជាងមុន ក្នុងការសម្រួចខ្លឹមសារផែនការជាតិនេះ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍទាំងឡាយ ដែលបានជួយគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់រួមចំណែកធ្វើឱ្យកម្ពុជាមានវឌ្ឍនភាពគួរជាទីមោទនៈ។ ប្រាកដណាស់ថា បច្ចុប្បន្នយើងកំពុងបន្តស្ថិតក្នុងយុគសម័យថ្មីមួយទៀត ដែលរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នរបស់ខ្លួនត្រូវតែធ្វើជាម្ចាស់លើដំណើរការអភិវឌ្ឍនានា និងទទួលខុសត្រូវលើវាសនារបស់ខ្លួនឯង។ ក្នុងខណៈពេលដែលយើងកំពុងបន្តបោះជំហានឆ្ពោះទៅមុខ រាជរដ្ឋាភិបាលនឹងទទួលខុសត្រូវពេញលេញក្នុងដំណើរការអភិវឌ្ឍទាំងមូល ដើម្បីធានាថាធនធានទាំងអស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនឹងត្រូវបានផ្តល់ដោយមានទិសដៅច្បាស់លាស់ទៅដល់អាទិភាពនិងវិស័យនានា ដែលត្រូវបានជ្រើសឡើង។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ក្នុងការសម្រេចឱ្យបាន *ការផ្ទេរពិត* នៃធនធានអភិវឌ្ឍ ដើម្បីឱ្យបានទៅដល់អ្នកត្រូវទទួលផលប្រយោជន៍ទាំងឡាយ ជាពិសេស នៅតំបន់ជនបទ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា ដើម្បីភាពជោគជ័យនៃការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដូចបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ខ្ញុំសូមជំរុញនិងសង្ឃឹមជឿជាក់ថា

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់នឹងប្រកាន់ខ្ជាប់នូវបណ្តាអាទិភាពនានា ដែលបានកំណត់នៅក្នុង *ផ.យ.អ.ជ. ២០១៩-២០២៣* ដែលជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៩

**ហ៊ុន សែន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# កម្ពុជា: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

## ព័ត៌មានទូទៅ

| | |
|---|---|
| ផ្ទៃដីសរុបៈ គម$^២$ | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៤ |
| ចំនួនក្រុង | ២៧ |
| ចំនួនខណ្ឌ | ១៤ |
| ចំនួនស្រុក | ១៦២ |
| ចំនួនសង្កាត់ | ២៤១ |
| ចំនួនឃុំ | ១ ៤០៥ |
| ចំនួនភូមិ | ១៤ ៣៨៣ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (៛) |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| ១.០០ | **អត្រានៃភាពក្រីក្រ** | | | | | | | |
| ១.០១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | ១៣,៥ (២០១៤) | ៩,៥ | | ៧,៥ | | ៥,៥ |
| | | | | | | | | |
| ២.០០ | **ប្រជាជន[1]** | | | | | | | |
| ២.០១ | ប្រជាជនសរុប | លាននាក់ | ១៦,០ | ១៦,២ | ១៦,៥ | ១៦,៧ | ១៧,០ | ១៧,៣ |
| ២.០២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម$^២$ | ៨៨ | ៩០ | ៩១ | ៩២ | ៩៣ | ៩៥ |
| ២.០៣ | បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | ៩៦,៧ | ៩៦,៩ | ៩៧,០ | ៩៧,២ | ៩៧,៣ | ៩៧,៥ |
| ២.០៤ | អាយុ០-១៤ | % នៃប្រជាជន | ៣៤,១ | ៣៣,៨ | ៣៣,៦ | ៣៣,៣ | ៣៣,១ | ៣២,៨ |
| ២.០៥ | អាយុ១៥-៦៤ | % នៃប្រជាជន | ៦៦,៣ | ៦៦,៤ | ៦៦,៤ | ៦៦,៤ | ៦៦,៤ | ៦៦,៣ |
| ២.០៦ | អាយុ៦៥ឆ្នាំឡើង | % នៃប្រជាជន | ៥,៣ | ៥,៤ | ៥,៥ | ៥,៦ | ៥,៧ | ៥,៩ |
| ២.០៧ | ជនបទ | % នៃប្រជាជន | ៧៥,៥ | ៧៥,១ | ៧៤,៦ | ៧៤,១ | ៧៣,៧ | ៧៣,៣ |
| ២.០៨ | ទីប្រជុំជន | % នៃប្រជាជន | ២៤,៥ | ២៤,៩ | ២៥,៤ | ២៥,៩ | ២៦,៣ | ២៦,៧ |
| ២.០៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១,៤ | ១,៤ | ១,៣ | ១,៣ | ១,៣ | ១,២ |
| ២.១០ | អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ២,៥ | ២,៥ | ២,៤ | ២,៤ | ២,៤ | ២,៣ |
| ២.១១ | អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត ប្រុស | ឆ្នាំ | ៦៧,១ | ៦៧,៣ | ៦៧,៥ | ៦៧,៧ | ៦៧,៩ | ៦៨,១ |
| | ស្ត្រី | ឆ្នាំ | ៧០,៦ | ៧១,៣ | ៧២,០ | ៧២,៧ | ៧៣,៣ | ៧៣,៩ |
| | | | | | | | | |

[1] ចំណោលប្រជាជនឆ្នាំ២០១៣-២០២៣ ដោយផ្អែកតាមអង្កេតចន្លោះជំរឿនឆ្នាំ២០១៣ និងអង្កេតប្រជាសាស្រ្តនិងសុខភាពឆ្នាំ២០១៤

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| ៣.00 | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | | | |
| ៣.0១ | ផ.ស.ស. ថ្លៃបច្ចុប្បន្ន | ប៊ីលានរៀល | ៩៨ ៧៨៦ | ១0៨ ៥៩0 | ១១៩ 0៣៤ | ១៣0 ៩១៥ | ១៤៤ ១៧0 | |
| ៣.0២ | ផ.ស.ស. ថ្លៃបច្ចុប្បន្ន | លានដុល្លារ | ២៤ ៣៧៤ | ២៦ ៧៨៦ | ២៩ ៣៦២ | ៣២ ២៩៣ | ៣៥ ៥៦២ | |
| ៣.0៣ | អត្រាកំណើន ផ.ស.ស. ពិត | % | ៧,៥ | ៧,១ | ៦,៥ | ៧,0 | ៧,0 | |
| ៣.0៤ | កសិកម្ម | % | ១,៦ | ១,៦ | ១,៧ | ១,៨ | ១,៨ | |
| ៣.0៥ | ឧស្សាហកម្ម | % | ១២,៣ | ១0,៧ | ៨,៩ | ១0,២ | ១0,១ | |
| ៣.0៦ | សេវា | % | ៦,៥ | ៦,៧ | ៦,៤ | ៦,៣ | ៦,២ | |
| ៣.0៧ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗ | ពាន់រៀល | ៦ ២៦៩ | ៦ ៧៩៩ | ៧ ៣៥៤ | ៧ ៩៨៦ | ៨ ៦៨៣ | |
| ៣.0៨ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗ | ដុល្លារ | ១ ៥៤៨ | ១ ៦៧៩ | ១ ៨១៦ | ១ ៩៧២ | ២ ១៤៤ | |
| ៣.0៩ | អតិផរណា (ការប្រែប្រួលមធ្យមប្រចាំឆ្នាំ) | % | ២,៥ | ២,៨ | ២,៩ | ៣,0 | ៣,0 | |
| ៣.១0 | ប្រាក់រៀលធៀបនឹងដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ 0៥៣ | ៤ 0៥៤ | ៤ 0៥៤ | ៤ 0៥៤ | ៤ 0៥៤ | |
| ៣.១១ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំចូល | ៥,៥ | ៥,៨ | ៦,១ | ៦,២ | ៦,២ | |
| ៣.១២ | ទុនបម្រុងបរទេសដុល | លានដុល្លារ | ១0 0៥២ | ១១ ៥0៥ | ១៣ 00៧ | ១៤ ៤៨៤ | ១៥ ៩៧៣ | |
| ៣.១៣ | ការវិនិយោគផ្ទាល់បរទេស | លានដុល្លារ | ២ ៩៧៩ | ៣ ៦៦៦ | ៤ ៣២៨ | ៥ ១១៩ | ៦ 0៥៥ | |
| | | | | | | | | |
| ៤.00 | **សារពើពន្ធ** | | | | | | | |
| ៤.0១ | ចំណូលថវិកាសរុប | %នៃ ផ.ស.ស. | ២២,២ | ២២,៦ | ២២,៥ | ២២,៥ | ២២,៨ | |
| ៤.0២ | ចំណាយថវិកាសរុប | %នៃ ផ.ស.ស. | ២៤,៤ | ២៥,0 | ២៨,៤ | ២៧,៦ | ២៧,៦ | |
| ៤.0៣ | អតិរេកចរន្ត | %នៃ ផ.ស.ស. | ៥,៨ | ៦,0 | ៥,៦ | ៥,៣ | ៥,៦ | |
| | | | | | | | | |
| ៥.00 | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | | |
| ៥.0១ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | ៣,៣៣ | ៣,៣៥ | ៣,៣៧ | ៣,៣៩ | ៣,៤១ | ៣,៤៤ |
| ៥.0២ | ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | ៣,៣៤ | ៣,១ | ៣,១ | ៣,២ | ៣,២ | ៣,៣ |
| ៥.0៣ | បរិមាណផលស្រូវ | លានតោន | ១0,៨៩ | ៩,៧ | ១0,0 | ១0,២ | ១0,៥ | ១0,៨ |
| ៥.0៤ | ផលិតផលស្រូវផលិតលើស | លានតោន | ៥,៨៣ | ៥,២៤ | ៥,៤១ | ៥,៦0 | ៥,៧៩ | ៦,00 |
| ៥.0៥ | ផ្ទៃដីដាំដុះដំណាំគ្រប់មុខ (រួមមានដំណាំអចិន្ត្រៃយ៍និងដំណាំចម្ការ) | លាន ហ.ត. | ៥ ១៦៤ | ៤ ៨១៤ | ៥ 0២៤ | ៥ ២៣៤ | ៥ ៤៤៤ | ៥ ៦៥៤ |
| ៥.0៦ | សហគមន៍កសិកម្ម | ចំនួន | ១ ១១៦ | ៤៧៥ | ៥៧៥ | ៦៧៥ | ៧៧៥ | ៨៧៥ |
| ៥.0៧ | ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | ៣៤,៣ | ៣៥,៨ | ៣៦,៩ | ៣៨,0 | ៣៩,១ | ៤0,៣ |
| ៥.0៨ | សត្វដែលទទួលបានវ៉ាក់សាំង | ភាគរយ | ១0 | ១0 | ១២ | ១៥ | ១៧ | ២0 |
| ៥.0៩ | ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាមស្តង់ដាបច្ចេកទេស | ចំនួនកន្លែង | ២៥ | ២៥ | ៥0 | ៧៥ | ១00 | ១២៥ |
| ៥.១0 | ផ្ទៃដីដាំដុះកៅស៊ូ | ហ.ត. | ៤៣៦ ៧00 | ៤៣៧ 000 | ៤៣៨ 000 | ៤៣៨ 000 | ៤៣៨ 000 | ៤៣៩ 000 |
| ៥.១១ | ទិន្នផលជ័រ | គ.ក្រ/ហ.ត/ឆ្នាំ | ១ ២៥៧ | ១ ១៤៨ | ១ ១៥៤ | ១ ១៦២ | ១ ១៦៨ | ១ ១៧៥ |
| ៥.១២ | ផលិតកម្មកៅស៊ូ | ពាន់តោន | ២0៧,00 | ២៩២,00 | ៣៥៣,00 | ៣៩៥,00 | ៤១២,00 | ៤១៧,00 |
| ៥.១៣ | ផលិតកម្មវារីវប្បកម្មកើន ១៥% | តោន | ២៥៤ 0៤៨ | ៩៧ ៨00 | ១១២ ៥00 | ១២៩ ៤00 | ១៤៨ ៨00 | ១៧១ ១៧0 |
| ៥.១៤ | បរិមាណផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៨៤៨,0 | ៨៩៨,៧ | ៩៥៨,៥ | ១ 0៣0,១ | ១ ១១៦,២ | ១ ២១៩,៤ |
| ៥.១៥ | ចំនួនសហគមន៍នេសាទ | សហគមន៍ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| ៥.១៦ | ការបោះបង្គោលព្រំព្រៃឈើ (គ.ម) | ហ.ត. | | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ |
| ៥.១៧ | ផ្ទៃដីដាំព្រៃឡើងវិញ | ហ.ត. | ២៥១ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ |
| ៥.១៨ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត | ចំនួន | ៦១៤ | ៣២ | ៣២ | ៣២ | ៣២ | ៣២ |
| | | | | | | | | |
| **៦.០០** | **ការអភិវឌ្ឍជនបទ** | | | | | | | |
| ៦.០១ | ការស្តារនិងសាងសង់ផ្លូវជនបទ (លើប្រវែងសរុប ៤០.០០០ គ.ម) | គ.ម. | ២៩១៧២ | ៣០ ៧៤០ | ៣២ ៩៣៥ | ៣៦ ០០៨ | ៣៩ ៦០៩ | ៤៣ ៥៧០ |
| ៦.០២ | ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ (DBST) ឬបេតុង | គ.ម. | ៦៩,៩៥ | ១២០ | ១៤៤ | ១៧២ | ២០៧ | ២៤៨ |
| ៦.០៣ | ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៦០ | ៧០ | ៧៥ | ៨០ | ៨៥ | ៩០ |
| ៦.០៤ | ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៦០ | ៦៥ | ៧២ | ៧៩ | ៨៤ | ៩១ |
| ៦.០៥ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | ក្រុម | ១៤១ | ១៤៦ | ១៥១ | ១៥៦ | ១៦១ | ១៦៥ |
| ៦.០៦ | ចំនួនភូមិដែលបានបណ្តុះបណ្តាល គ.អ.ភ. ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ១៦៨ | ២០០ | ២១០ | ២២០ | ២៣០ | ២៤០ |
| ៦.០៧ | សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គ.ម.ដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ១០០% | គ.ម. | ៣១០ | ៣៣០ | ៣៥៤ | ៣៨២ | ៤១៧ | ៤៥៨ |
| ៦.០៨ | កសាងសមត្ថភាព គ.អ.ភ. ស្តីពីជម្រើសនៃបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | ២៥ | ៣០ | ៣៥ | ៤០ | ៤៥ | ៥០ |
| | | | | | | | | |
| **៧.០០** | **ដឹកជញ្ជូន** | | | | | | | |
| ៧.០១ | ផ្លូវជាតិនិងផ្លូវខេត្ត : សរុប | គ.ម. | ១៦ ២៩២ | ១៦ ២៩២ | ១៦ ២៩២ | ១៦ ២៩២ | ១៦ ៤៨២ | ១៦ ៤៨២ |
| ៧.០២ | ក្នុងនោះ -- ផ្លូវកៅស៊ូ | គ.ម. | ៨ ៦២០ | ៨ ៩២០ | ៩ ២២០ | ៩ ៥២០ | ១០ ០១០ | ១០ ៣១០ |
| ៧.០៣ | ផ្លូវដែក | គ.ម. | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ៨០២ |
| ៧.០៤ | កំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ២ | ៤ | ៤ |
| | | | | | | | | |
| **៨.០០** | **សុខាភិបាល** | | | | | | | |
| | **១- កម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ និងអាហារូបត្ថម្ភ** | | | | | | | |
| ៨.០១ | អត្រាមរណភាពមាតា | ក្នុង១០០ ០០០ កំណើតរស់ | ១៧០ | | ១០០ | | | ៥៥ |
| ៨.០២ | អត្រាស្លាប់ទារក | ក្នុង១០០០ កំណើតរស់ | | | ១៤ | | | |
| ៨.០៣ | អត្រាស្លាប់កុមារអាយុក្រោម៥ឆ្នាំ | ក្នុង១០០០ | | | ៣០ | | | |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | | កំណើតរស់ | | | | | | |
| ៨.០៤ | អត្រាស្គមស្គាំងលើកុមារអាយុក្រោម៥ឆ្នាំ | % | | | ៩ | | | |
| ៨.០៥ | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្តនឹងមធ្យោបាយពន្យារកំណើតទំនើប | % | | | ៦២ | | | |
| ៨.០៦ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ២១,៩២ | ៤៤,៥ | ៤៦ | ៤៧ | ៤៨ | ៤៩ |
| ៨.០៧ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល | % | ៧៧,២១ | ៨៨ | ៨៩ | ៨៩,៥ | ៩០ | >៩០ |
| ៨.០៨ | ស្ត្រីមានគភ៌បានទទួលជីវជាតិដែក-ហ្វូលីកអាស៊ីត៩០គ្រាប់ | % | ៧៩,៩៩ | ៨២ | ៨៥ | ៨៧ | ៨៩ | ៩០ |
| ៨.០៩ | ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១ (មុន៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល | % | ៦៨,៤៦ | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ |
| ៨.១០ | សមាមាត្រនៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៨៤,០៥ | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ |
| ៨.១១ | ការសម្រាលដោយវះកាត់ | % | ៦,៧៧ | ៩ | ១០ | ១០,២ | ១០,៤ | ១០,៦ |
| ៨.១២ | ភាគរយនៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងកំឡុងមួយម៉ោងដំបូងនៃកំណើត | % | ៦៧ | ៦៧,៥ | ៦៨ | ៦៨,៥ | ៦៩ | ៦៩,៥ |
| ៨.១៣ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូចដូសទី១ | % | ១០៣ | ៩៥ | ៩៥ | ៩៥ | ៩៥ | >៩៥ |
| ៨.១៤ | ការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ១,៦០ | ១,៥៨ | ១,៦០ | ១,៦២ | ១,៦៥ | ១,៦៧ |
| ៨.១៥ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកស្លួត | % | ៩៨ | ៩៥ | ៩៥ | ៩៥ | >៩៥ | >៩៥ |
| ៨.១៦ | ភាគរយនៃកុមារអាយុ១២-៥៩ខែ បានទទួលថ្នាំទម្លាក់ព្រូនមេបង់ជាហូរលក្នុងអំឡុងពេល៦ខែ ចុងក្រោយនៃឆ្នាំ | % | ៧៨,០៩ | ៨២ | ៨៥ | ៨៨ | ៩០ | ៩០ |
| | **២- បង្ការនិងគ្រប់គ្រងជំងឺឆ្លង** | | | | | | | |
| ៨.១៧ | ករណីឆ្លងថ្មីនៃមេរោគអេសដ៍ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍១ ០០០នាក់ | ក្នុង ១០០០នាក់ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ |
| ៨.១៨ | ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressedក្នុងរយៈពេល១២ខែកន្លងមក | % | ៨៤,៦៣ | ៩០ | ៩០ | ៩០ | ៩០ | ៩០ |
| ៨.១៩ | អាំងស៊ីដងនៃជំងឺរបេងគ្រប់សណ្ឋានលើប្រជាជន | ១០០ ០០០ នាក់ | ៣៣៦ | ៣២៣ | ៣១០ | ២៦១ | ២៤៣ | ២២៦ |
| ៨.២០ | អត្រាស្លាប់ដោយជំងឺរបេងក្នុងចំណោមប្រជាជន | ១០០ ០០០ នាក់ | ១៨ | ១៧ | ១៦ | ១៥ | ១៤ | ១៣ |
| ៨.២១ | អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | % | ៩៣ | >៩០ | >៩០ | >៩០ | >៩០ | >៩០ |
| ៨.២២ | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជន ១០០ ០០០នាក់ | ១០០ ០០០ នាក់ | ០,០០ | ០,១៥ | ០,០០ | ០,០០ | ០,០០ | ០,០០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| ៨.២៣ | អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ (ករណីថ្មី) លើប្រជាជន | ១០០០នាក់ | ៤ | ១,២៥ | ១,០៥ | ០,៨៥ | ០,៦៥ | ០,៤០ |
| ៨.២៤ | អត្រាស្លាប់ដោយជំងឺគ្រុនឈាម | % | ០,០៩ | ០,២៥ | ០,២ | ០,២ | <០,២ | <០,២ |
| | **៣- បង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ** | | | | | | | |
| ៨.២៥ | ភាគរយនៃប្រជាជនអាយុពី១៨-៦៩ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល | % | | ៣២ | ៣៥ | ៤០ | ៤៥ | ៥០ |
| ៨.២៦ | ភាគរយនៃប្រជាជនអាយុពី១៨-៦៩ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | % | | ១៩ | ២០ | ២២ | ២៤ | ២៦ |
| ៨.២៧ | ភាគរយនៃស្ត្រីអាយុ៣០ទៅ៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិចមួយលើក | % | ១,១៨ | ៤ | ៦ | ៨ | ១០ | ១២ |
| ៨.២៨ | អត្រារះកាត់ជំងឺភ្នែកឡើងបាយក្នុងចំណោមប្រជាជន១លាននាក់ | ១លាននាក់ | ២ ២៨៦ | ២.៥០០ | ៣.០០០ | ៣.១០០ | ៣.២០០ | ៣.៣០០ |
| ៨.២៩ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់៖<br>- អាយុលើសពី១៥ឆ្នាំ<br>- អាយុពី ១៣-១៥ឆ្នាំ | % | ២១,៨<br>២,៤ | ២០,៨<br>២,៣ | ១៩,៨<br>២,២ | ១៨,៨<br>២,១ | ១៧,៨<br>២,០ | ១៦,៨<br>១,៩ |
| ៨.៣០ | ប្រេវ៉ាឡង់នៃការប្រើប្រាស់សារជាតិអាល់កុលក្នុងចំណោមមនុស្សពេញវ័យចាប់ពីអាយុ១៨ឆ្នាំ | % | ៤៥,៥ | ៤៥,៤ | ៤៥,៣ | ៤៥,២ | ៤៥,១ | ៤៥,០ |
| ៨.៣១ | ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល | % | ១,៧១ | ១៥ | ២០ | ២២ | ២៤ | ២៥ |
| ៨.៣២ | ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | % | ៨ ០៩៦ នាក់ ១០០% | ៧០ | ៨០ | ៨០ | ៨០ | >៨០ |
| | **៤- ពង្រឹងប្រព័ន្ធសុខាភិបាល** | | | | | | | |
| ៨.៣៣ | ភាគរយនៃមូលដ្ឋានសុខាភិបាលដែលមានស្តុកឱសថសារវន្តនិងឧបករណ៍បរិក្ខារពេទ្យចាំបាច់ដែលបានកំណត់១៥មុខ | % | | ៨០ | ៨៥ | ៨៦ | ៨៧ | ៨៨ |
| ៨.៣៤ | ភាគរយនៃការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្ត | % | ២៣ | ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ |
| ៨.៣៥ | ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីរបស់ប្រជាជនមួយនាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ០,៧២ | ០,៨០ | ០,៨៥ | ០,៨៦ | ០,៨៧ | ០,៨៩ |
| ៨.៣៦ | អត្រាស្លាប់នៅមន្ទីរពេទ្យ | % | ០,៧២ | <១ | <១ | <១ | <១ | <១ |
| ៨.៣៧ | ភាគរយនៃប្រជាជនដែលគ្រប់ដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិសមធម៌និងធានារ៉ាប់រងសុខភាព) | % | ៣៥,៧ | ៤៥ | ៥០ | ៥៥ | ៦០ | ៦៥ |
| ៨.៣៨ | ចំណាយចរន្តនៃថវិកាជាតិលើសុខភាពគិតជា%នៃផលិតផលសរុបក្នុងស្រុក | % | ១,៤៣ | ២ | ២ | ២,១ | ២,២ | ២,៣ |
| ៨.៣៩ | សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | % | ៩៤ | >៩៧ | >៩៧ | >៩៧ | ៩៨ | >៩៧ |
| ៨.៤០ | ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការពេញលេញ | % | ៧៦ | ៨៥ | >៨៥ | >៨៥ | >៨៥ | ៩០ |
| | | | | | | | | |
| **៩.០០** | **អប់រំ** | | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ |
| ៩.០១ | ភាគរយកុមារអាយុ៥ឆ្នាំ ទទួលបានការអប់រំ | % | ៥៨,០ | ៥៩,៣ | ៦០,៦ | ៦១,៩ | ៦៣,២ | ៦៤,៥ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | កុមារតូចគ្រប់រូបភាព (មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | | | | | | | |
| | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| ៩.០៣ | សរុប | % | ៩៧,៨ | ៩៧,៩ | ៩៨,១ | ៩៨,២ | ៩៨,៤ | ៩៨,៥ |
| ៩.០៤ | ប្រុស | % | ៩៧,៦ | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,៣ | ៩៨,៥ |
| ៩.០៥ | ស្រី | % | ៩៨,១ | ៩៨,៣ | ៩៨,៥ | ៩៨,៦ | ៩៨,៨ | ៩៩,០ |
| ៩.០៦ | ទីប្រជុំជន | % | ១០២,៨ | ១០២,១ | ១០១,៦ | ៩៥,២ | ៩៧,៩ | ១០០ |
| ៩.០៧ | ជនបទ | % | ៩៦,៧ | ៩៧,០ | ៩៧,៣ | ៩៧,៥ | ៩៧,៦ | ៩៨,០ |
| | អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| ៩.០៨ | សរុប | % | ១១៣,៧ | ១១២,៣ | ១១១,២ | ១១០,៤ | ១០៩,៨ | ១០៨,០ |
| ៩.០៩ | ប្រុស | % | ១១៤,៦ | ១១៣,២ | ១១២,២ | ១១១,៤ | ១១០,៨ | ១០៩,០ |
| ៩.១០ | ស្រី | % | ១១២,៩ | ១១១,៤ | ១១០,៣ | ១០៩,៥ | ១០៨,៩ | ១០៧,០ |
| | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | |
| ៩.១១ | សរុប | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ |
| ៩.១២ | ប្រុស | % | ៧៩,១ | ៨០,៣ | ៨១,៥ | ៨២,៦ | ៨៣,៨ | ៨៥,០ |
| ៩.១៣ | ស្រី | % | ៨៦,៤ | ៨៧,៣ | ៨៨,២ | ៨៩,២ | ៩០,១ | ៩១,០ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| ៩.១៥ | សរុប | % | ៥៩,២ | ៦០,៧ | ៦២,២ | ៦៣,៧ | ៦៥,២ | ៦៦,៧ |
| ៩.១៦ | ប្រុស | % | ៥៥,២ | ៥៧,២ | ៥៩,១ | ៦១,១ | ៦៣,០ | ៦៥,០ |
| ៩.១៧ | ស្រី | % | ៦៣,៤ | ៦៥,១ | ៦៦,៨ | ៦៨,៦ | ៧០,៣ | ៧២,០ |
| ៩.១៨ | ទីប្រជុំជន | % | ៦៧,០ | ៦៨,៤ | ៦៩,៨ | ៧១,២ | ៧២,៦ | ៧៤,០ |
| ៩.១៩ | ជនបទ | % | ៥៧,៤ | ៥៩,០ | ៦០,៦ | ៦២,២ | ៦៣,៨ | ៦៥,៤ |
| | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | |
| ៩.២០ | សរុប | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ |
| ៩.២១ | ប្រុស | % | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ |
| ៩.២២ | ស្រី | % | ៥១,១ | ៥២,៥ | ៥៣,៤ | ៥៤,៣ | ៥៥,៣ | ៥៦,៣ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| ៩.២៤ | សរុប | % | ២៨,៥ | ៣០,៤ | ៣២,៣ | ៣៤,២ | ៣៦,១ | ៣៨,០ |
| ៩.២៥ | ប្រុស | % | ២៦,៣ | ២៨,៣ | ៣០,២ | ៣២,២ | ៣៤,១ | ៣៦,១ |
| ៩.២៦ | ស្រី | % | ៣០,៩ | ៣២,៧ | ៣៤,៥ | ៣៦,៤ | ៣៨,២ | ៤០,០ |
| ៩.២៧ | ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ៩ | ១១ | ១៣ | ១៥ | ១៦ | ១៩ |
| ៩.២៨ | ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ១ ៤៧១ | ១ ៧៧៧ | ២ ០៨៣ | ២ ៣៨៨ | ២ ៦៩៤ | ៣ ០០០ |
| ៩.២៩ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ |
| ៩.៣០ | អត្រាអក្ខរជនពេញវ័យ (១៥ឆ្នាំឡើង) | % | ៨២,៥ | ៨៣,៦ | ៨៤,៧ | ៨៥,៨ | ៨៦,៩ | ៨៨,០ |
| | | | | | | | | |
| ១០.០០ | **កម្មវិធីសម្អាតមីន** | | | | | | | |
| ១០.០១ | ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ៥៨ | ៥២ | ៤៧ | ៤២ | ៣៨ | ៣០ |
| ១០.០២ | ចំនួនជនរងគ្រោះដោយសារការលេងនិងច្នៃគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ | នាក់ | ៤១ | ៣៧ | ៣៣ | ៣០ | ២៧ | ២០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | (ស្លាប់/របួស) | | | | | | | |
| ១០.០៣ | ផ្ទៃដីសរុបបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម(ផ្អែកលើលទ្ធផលពីការស្រាវជ្រាវមូលដ្ឋាន) | ហ.ត. | ១៣ ១៦៧ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ |
| | ផ្ទៃដីបោសសម្អាតមីន | ហ.ត. | | ១១ ០០០ | ១១ ០០០ | ១១ ០០០ | ១១ ០០០ | ១១ ០០០ |
| | ផ្ទៃដីបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | | ១០ ៤០០ | ១០ ៤០០ | ១០ ៤០០ | ១០ ៤០០ | ១០ ៤០០ |
| | | | | | | | | |

# មាតិកា

ទំព័រ

**អារម្ភកថា** ............ i

**សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា** ............ vii

**កម្ពុជា: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ** ............ viii

**មាតិកា** ............ xv

**បញ្ជីនៃតារាង រូបភាព និងឧបសម្ព័ន្ធ** ............ xix

**ជំពូកទី១ សេចក្តីផ្តើម** ............ ១

១- ប្រវត្តិដើម ............ ១

២- ការពិនិត្យឡើងវិញពីផែនការអភិវឌ្ឍន៍នៅកម្ពុជា ............ ២

៣- យុទ្ធសាស្ត្រចតុកោណ ............ ៤

៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ............ ៦

៥- ទម្រង់នៃផ.យ.អ.ជ. ២០១៩-២០២៣ ............ ៨

**ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តផ.យ.អ.ជ. ២០១៤-២០១៨** ............ ១០

១. សេចក្តីផ្តើម ............ ១០

**២- អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ** ............ **១០**

២.១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ............ ១០

២.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ............ ១៣

២.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ ............ ១៥

២.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ............ ២៣

**៣- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល** ............ **២៤**

៣.១- សុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ............ ២៤

៣.២- បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និង ចីរភាពបរិស្ថាន ............ ៣១

៣.៣- ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ ............ ៣៨

៣.៤- សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅនៅក្នុងតំបន់និងពិភពលោក ............ ៤១

**៤- ការលើកស្ទួយវិស័យកសិកម្ម ........ ៤៦**

៤.១- លើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម........ ៤៧

៤.២- ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ........ ៥០

៤.៣- កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម........ ៥២

៤.៤- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព........ ៥៦

**៥- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត........ ៧៤**

៥.១- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន........ ៧៤

៥.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ........ ៨៣

៥.៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី........ ៨៨

៥.៤- ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន........ ៨៨

**៦- ការអភិវឌ្ឍវិស័យឯកជននិងការងារ........ ៩៣**

៦.១- ការពង្រឹងវិស័យឯកជននិងការជំរុញវិនិយោគ និង ធុរកិច្ច........ ៩៣

៦.២- ការអភិវឌ្ឍឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យម........ ១០៧

៦.៣- ការអភិវឌ្ឍទីផ្សារការងារ........ ១១២

៦.៤- ការអភិវឌ្ឍវិស័យធនាគារ និង ហិរញ្ញវត្ថុ........ ១១៦

**៧- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស........ ១២០**

៧.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាល ១២០

៧.២- ការលើកកម្ពស់សុខភាព និង អាហារូបត្ថម្ភ........ ១២៦

៧.៣- ការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម........ ១៣៦

៧.៤- ពង្រឹងការអនុវត្តគោលនយោបាយប្រជាជននិងសមភាពយេនឌ័រ........ ១៤៩

**ជំពូកទី៣ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ........ ១៥៥**

៣.១ - សេចក្តីផ្តើម........ ១៥៥

៣.២- សមិទ្ធផល ឆ្នាំ២០១៤-២០១៨........ ១៥៦

៣.៣- គោលដៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ឆ្នាំ២០១៩-២០២៣........ ១៧០

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និង ការធ្វើសមាហរណកម្មទៅក្នុង ផ.យ.អ.ជ. ២០១៩-២០២៣........ ១៧០

ទិសដៅទូទៅនៃគោលនយោបាយ ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤........................ ១៧២

ក្របខ័ណ្ឌលទ្ធផល.................................................................................................. ១៧៣

គោលដៅ គោលនយោបាយ និង សកម្មភាពម៉ាក្រូសេដ្ឋកិច្ច................................................ ១៧៦

គោលនយោបាយរូបិយវត្ថុ និង វិស័យហិរញ្ញវត្ថុ............................................................... ១៨០

៣.៤- ទស្សនវិស័យសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣............................................................ ១៨៥

ការប៉ាន់ស្មានតម្រូវការវិនិយោគ សម្រាប់ ផ.យ.អ.ជ. ២០១៩-២០២៣.................................. ១៨៨

តួនាទីរបស់សារពើពន្ធនាពេលអនាគត.......................................................................... ១៨៨

**ជំពូកទី៤ គោលនយោបាយនិងសកម្មភាពអាទិភាព ២០១៩-២០២៣.................................. ១៩១**

**១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ............................... ១៩៤**

១.១- ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន............................................................ ១៩៤

១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ........................................................ ២០១

១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ.......................................................................... ២០៥

១.៤- ការពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន...................................................................... ២១១

**២- បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល..................................................... ២១២**

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ................................ ២១២

២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍ............................ ២១៨

២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ............. ២២៦

២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក...................................................................................................... ២២៨

**៣- ការអភិវឌ្ឍធនធានមនុស្ស..................................................................................... ២៣៣**

៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា............................................ ២៣៤

៣.២- ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស........................................................................ ២៤២

៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ.......................................... ២៤៤

៣.៤- ការពង្រឹងសមភាពយេនឌ័រ និង ការគាំទ្រសង្គម....................................................... ២៥៧

**៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច......................................................................................... ២៦៩**

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល ២៦៩

៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ........ ២៨៥

៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤........ ២៩៥

៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ........ ៣០៤

**៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ........ ៣០៨**

៥.១- ការអភិវឌ្ឍទីផ្សារការងារ........ ៣០៩

៥.២- ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព........ ៣១២

៥.៣- ការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន........ ៣១៦

៥.៤- ការពង្រឹងការប្រកួតប្រជែង........ ៣១៨

**៦- ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន........ ៣២១**

៦.១- ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ........ ៣២១

៦.២- ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ ប្រកបដោយចីរភាព........ ៣៤២

៦.៣ - ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម........ ៣៥១

៦.៤- ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ........ ៣៥៦

**ជំពូកទី៥ តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ........ ៣៦១**

១-តម្រូវការវិនិយោគរុប........ ៣៦២

២-តម្រូវការវិនិយោគសាធារណៈ........ ៣៦៥

៣. ប្រភពហិរញ្ញប្បទានសក្តានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ ........ ៣៦៦

៤. ការអភិវឌ្ឍនូវសំយោគថ្មី សម្រាប់ការវិនិយោគមូលធន រវាងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និង ថវិកា........ ៣៧១

**ជំពូកទី៦ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**........ ៣៧៣

១-សេចក្តីផ្តើម........ ៣៧៣

២- តួនាទីនិងសារៈសំខាន់នៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងរៀបចំគោលនយោបាយ និងការរៀបចំផែនការ........ ៣៧៤

៣- ក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនិងការរៀបចំសម្រាប់ ផ.យ.អ.ជ. ២០១៩-២០២៣.. ៣៧៦

៤- ការរៀបចំផែនការនិងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅតាមកម្រិត........ ៣៨១

៥- បញ្ហាប្រឈមទាក់ទងនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ........ ៣៨៣

**ជំពូកទី៧ សេចក្តីសន្និដ្ឋាន**........ ៤០៥

# បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ

## តារាង


| | | |
|---|---|---|
| តារាងទី២.១ | ចំនួនមន្ត្រីរាជការនិងមន្ត្រីប្រភេទផ្សេងទៀតក្នុងតារាងបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា...... | ១៨ |
| តារាងទី២.២ | បៀវត្សអប្បបរមាមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ.................................. | ១៩ |
| តារាងទី២.៣ | សូចនាករសំខាន់ៗក្នុងវិស័យធម្មនិ័យ........................................................................ | ២៩ |
| តារាងទី២.៤ | សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកបឋមសិក្សា........................................................ | ២៩ |
| តារាងទី២.៥ | សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកមធ្យមសិក្សាបឋមភូមិ.......................................... | ២៩ |
| តារាងទី២.៦ | សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកមធ្យមសិក្សាទុតិយភូមិ.......................................... | ៣០ |
| តារាងទី២.៧ | សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកឧត្តមសិក្សា........................................................ | ៣០ |
| តារាងទី២.៨ | វិស័យនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម.............................................. | ៤០ |
| តារាងទី២.៩ | វឌ្ឍនភាពនៃការអនុវត្តចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ.................... | ៤១ |
| តារាងទី២.១០ | ផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៤-២០១៨............................................................ | ៤៨ |
| តារាងទី២.១១ | ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៤-២០១៨............................................................ | ៥០ |
| តារាងទី២.១២ | ការចិញ្ចឹមសត្វសរុបពីឆ្នាំ២០១៤-២០១៨............................................................ | ៥១ |
| តារាងទី២.១៣ | លទ្ធផលសម្រេចបាន លើការងារកំណែទម្រង់វិស័យដីធ្លី............................................ | ៥៤ |
| តារាងទី២.១៤ | សមិទ្ធផលក្នុងវិស័យសកម្មភាពមីន ឆ្នាំ២០១៤-២០១៨............................................ | ៥៥ |
| តារាងទី២.១៥ | លទ្ធផលសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិស័យព្រៃឈើ............................................ | ៥៦ |
| តារាងទី២.១៦ | ស្ថានភាពផលនេសាទពីឆ្នាំ២០១៤-២០១៨............................................................ | ៥៩ |
| តារាងទី២.១៧ | សូចនាករវាស់វែងវិស័យរ៉ែ........................................................................ | ៦០ |
| តារាងទី២.១៨ | សូចនាករសំខាន់ៗទាក់ទងនឹងបរិស្ថាន................................................................ | ៦៤ |
| តារាងទី២.១៩ | សូចនាករវាស់វែងវឌ្ឍនភាពពីឆ្នាំ ២០១៤-២០១៨.................................................. | ៦៩ |
| តារាងទី២.២០ | លទ្ធផលការងារដឹកជញ្ជូនតាមផ្លូវអាកាសពីឆ្នាំ២០១៤-២០១៨.................................. | ៨២ |
| តារាងទី២.២១ | ការផ្គត់ផ្គង់ទឹកស្អាត........................................................................ | ៨៧ |
| តារាងទី២.២២ | សូចនាករស្តីពីអត្រាអ្នកប្រើប្រាស់................................................................ | ៨៩ |
| តារាងទី២.២៣ | ចំនួនអ្នកប្រើប្រាស់សេវាទូរស័ព្ទសរុប................................................................ | ៩០ |
| តារាងទី២.២៤ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធឺណិត........................................................ | ៩០ |
| តារាងទី២.២៥ | ការទទួលបានព័ត៌មានសាធារណៈ........................................................................ | ៩១ |
| តារាងទី២.២៦ | សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៤-២០១៨.................................... | ៩៧ |

តារាងទី២.២៧ សូចនាករនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ ..... ១០១
តារាងទី២.២៨ ចំនួនភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិចូលទស្សនាសារមន្ទីរ ..... ១០២
តារាងទី២.២៩ ការចុះបញ្ជីបេតិកភណ្ឌពិភពលោក ..... ១០៣
តារាងទី២.៣០ ការងារអភិរក្សនិងជួសជុល ..... ១០៤
តារាងទី២.៣១ ការផ្តល់សេវាសាធារណៈ ..... ១០៥
តារាងទី២.៣២ សូចនាកររបស់វិស័យឧស្សាហកម្ម ..... ១០៩
តារាងទី២.៣៣ ចំនួនសហគ្រាសនិងកម្លាំងពលកម្ម ..... ១១០
តារាងទី២.៣៤ ចំនួនគំរូផលិតផលពីឆ្នាំ២០១៤-២០១៨ ..... ១១១
តារាងទី២.៣៥ សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា ..... ១២៣
តារាងទី២.៣៦ និន្នាការនៃការកាត់បន្ថយមរណភាពមាតា ទារក កុមារ និងកង្វះអាហារូបត្ថម្ភ ២០០៥-២០១៥ ..... ១២៦
តារាងទី២.៣៧ និន្នាការនៃការកាត់បន្ថយអត្រាឈឺនិងស្លាប់ និងបន្ថយកត្តាហានិភ័យនៃជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ ២០១៤-២០១៨ ..... ១២៦
តារាងទី២.៣៨ និន្នាការសូចនាករនៃការប្រើប្រាស់សេវាសុខាភិបាល ២០១៤-២០១៨ ..... ១២៨
តារាងទី២.៣៩ ស្ថិតិមូលដ្ឋានសុខាភិបាលពី ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ ..... ១៣០
តារាងទី២.៤០ ស្ថិតិបុគ្គលិកសុខាភិបាលសាធារណៈពី ២០១៤ ដល់ ឆ្នាំ២០១៨ ..... ១៣០
តារាងទី២.៤១ និន្នាការនៃការចំណាយថវិកាជាតិក្នុងវិស័យសុខាភិបាល ២០១៤ ដល់ ឆ្នាំ២០១៨ ..... ១៣១
តារាងទី២.៤២ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ ..... ១៣៧
តារាងទី២.៤៣ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា ..... ១៤០
តារាងទី២.៤៤ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ ..... ១៤១
តារាងទី២.៤៥ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពមនុស្សចាស់ ..... ១៤៣
តារាងទី២.៤៦ សមិទ្ធផលស្តីពីការលើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល ..... ១៤៥
តារាងទី២.៤៧ សមិទ្ធផលស្តីពីការលើកកម្ពស់វិស័យអតីតយុទ្ធជន ..... ១៤៦
តារាងទី២.៤៨ សមិទ្ធផលស្តីពីការពង្រឹងសមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូ ..... ១៤៨
តារាងទី៣.១ អនុបាតកម្រិតស្ថិរភាពបំណុល ..... ១៦១
តារាងទី៣.២ ទិន្នន័យទីផ្សារការងារពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ..... ១៦៦
តារាងទី៣.៣ សង្ខេបពីលទ្ធផលនៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ..... ១៦៩
តារាងទី៣.៤ ក្របខ័ណ្ឌលទ្ធផល ដែលបានស្នើឡើង ..... ១៧៤
តារាងទី៣.៥ សង្ខេប ចំហាក ម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅឆ្នាំ២០២៣ ..... ១៨៦
តារាងទី៣.៦ ការព្យាករអត្រាកំណើនតាមវិស័យ ឆ្នាំ២០១៩-២០២៣ ..... ១៨៧

| | | |
|---|---|---|
| តារាងទី៤.១ | សូចនាករសំខាន់ៗ និងចំណុចដៅ ឆ្នាំ២០១៩-២០២៣ | ២០២ |
| តារាងទី៤.២ | សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៩-២០២៣ | ២៣១ |
| តារាងទី៤.៣ | សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា | ២៤០ |
| តារាងទី៤.៤ | សូចនាករពិនិត្យតាមដានវឌ្ឍនភាព ២០១៩-២០២៣ | ២៤៧ |
| តារាងទី៤.៥ | សូចនាករសំខាន់ៗតាមវិស័យ និងកំណត់ចំណុចដៅសម្រាប់ឆ្នាំ២០១៩-២០២៣ | ២៥៣ |
| តារាងទី៤.៦ | ការប៉ាន់ស្មានអត្រា ប្រជាជនទីប្រជុំជនទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត តាមបំពង់ ឆ្នាំ ២០១៩-២០២៣ | ២៥៧ |
| តារាងទី៤.៧ | សូចនាករសំខាន់ៗសម្រាប់វាស់វែងក្នុងវិស័យយេនឌ័រ ២០១៩-២០២៣ | ២៦១ |
| តារាងទី៤.៨ | សូចនាករសំខាន់ៗ សម្រាប់វាស់វែង វិស័យសង្គមកិច្ច ឆ្នា២០១៩-២០២៣ | ២៦៤ |
| តារាងទី៤.៩ | សូចនាករសំខាន់ៗនៃវិស័យថាមពល | ២៨៤ |
| តារាងទី៤.១០ | សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន | ៣០២ |
| តារាងទី៤.១១ | សូចនាករសំខាន់ៗនៃវិស័យកសិកម្ម | ៣២៨ |
| តារាងទី៤.១២ | សូចនាករក្នុងវិស័យសកម្មភាពមីន ឆ្នាំ២០១៩-២០២៣ | ៣៣០ |
| តារាងទី៤.១៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក រួមទាំងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ | ៣៣៣ |
| តារាងទី៤.១៤ | ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត | ៣៣៤ |
| តារាងទី៤.១៥ | ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម | ៣៣៥ |
| តារាងទី៤.១៦ | សូចនាករសម្រាប់វាស់វែងចលនាភូមិមួយ ផលិតផលមួយ | ៣៤២ |
| តារាងទី៤.១៧ | សូចនាករ ផែនការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២០១៩-២០២៣ | ៣៥៦ |
| តារាងទី៤.១៨ | សូចនាករសំខាន់ៗ ការងារប្រែប្រួលអាកាសធាតុ ២០១៩-២០២៣ | ៣៦០ |
| តារាងទី៥.១ | វិនិយោគមូលធនដែលត្រូវការចាំបាច់ដើម្បីសម្រេចបានកំណើន ដែលបានគ្រោងទុក និង ធនធានដែលអាចមានសម្រាប់ហិរញ្ញប្បទានឆ្នាំ២០១៩-២០២៣ | ៣៦៣ |
| តារាងទី៥.២ | ចំណុចដៅក្នុងការកៀរគរធនធានសម្រាប់វិនិយោគវិស័យសាធារណៈ ២០១៩-២០២៣ | ៣៦៦ |
| តារាងទី៥.៣ | ការវិភាជតាមវិស័យនិងអនុវិស័យនៃវិនិយោគវិស័យសាធារណៈក្នុង ផ.យ.អ.ជ. ២០១៩-២០២៣ | ៣៧២ |
| តារាងទី៦.១ | ក្របខ័ណ្ឌលទ្ធផលសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ.យ.អ.ជ | ៣៧៧ |
| តារាងទី៦.២ | សូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនៃផ.យ.អ.ជ. ២០១៩-២០២៣ | ៣៨៨ |
| តារាងទី៦.៣ | សូចនាករបន្ថែម | ៣៩៩ |


## រូបភាព


| | | |
|---|---|---|
| រូបភាពទី១.១ | គំនូសបំប្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ | ៥ |
| រូបភាពទី២.១ | និន្នាការហិរញ្ញប្បទានតាមវិស័យ និងដៃគូអភិវឌ្ឍសំខាន់ៗ | ៣៩ |
| រូបភាពទី២.២ | ការតម្រឹមហិរញ្ញប្បទានជាមួយអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤- | ៣៩ |

| | | |
|---|---|---|
| | ២០១៨.................................................................................................... | |
| រូបភាពទី២.៣ | ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ.................................... | ១១៦ |
| រូបភាពទី២.៤ | ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ............................ | ១១៨ |
| រូបភាពទី២.៥ | សមាមាត្រប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប................................................ | ១៤៣ |
| រូបភាពទី២.៦ | ថវិការដ្ឋដែលបានវិភាជរយៈពេល ៥ឆ្នាំ២០១៤-២០១៨............................................ | ១៤៩ |
| រូបភាពទី៣.១ | កំណើន ផ.ស.ស. ២០១៤-២០១៨............................................................................ | ១៥៧ |
| រូបភាពទី៣.២ | ការវិនិយោគធៀបនឹង ផ.ស.ស. តាមប្រភេទនៃការវិនិយោគ.................................... | ១៥៨ |
| រូបភាពទី៣.៣ | តុល្យភាពថវិកាឆ្នាំ ២០១៤-២០១៨........................................................................ | ១៥៩ |
| រូបភាពទី៣.៤ | ចំណាយចរន្ត និងចំណាយមូលធន.......................................................................... | ១៦០ |
| រូបភាពទី៣.៥ | សម្ពាធអតិផរណា ២០១៤-២០១៨............................................................................ | ១៦១ |
| រូបភាពទី៣.៦ | សមាសធាតុនៃរូបិយវត្ថុទូទៅ និង កំណើន.............................................................. | ១៦៣ |
| រូបភាពទី៣.៧ | តម្លៃបន្ថែមតាមវិស័យ គិតជា % នៃផលិតផលក្នុងស្រុកសរុបនិងការព្យាករណ៍ដល់ឆ្នាំ២០១៨........................................................................................................ | ១៦៥ |
| រូបភាពទី៣.៨ | របាយពលកម្មតាមវិស័យ...................................................................................... | ១៦៦ |
| រូបភាពទី៣.៩ | ការប្រើប្រាស់របស់គ្រួសារក្នុងមនុស្សម្នាក់ តាមតម្លៃបច្ចុប្បន្ន ២០១៣-២០១៦............. | ១៦៧ |
| រូបភាពទី៣.១០ | ការបែងចែកទិន្នន័យភាពក្រីក្រ ឆ្នាំ២០១៥............................................................ | ១៦៨ |
| រូបភាពទី៥.១ | សមាសភាគនៃវិនិយោគវិស័យឯកជន...................................................................... | ៣៦៤ |
| រូបភាពទី៥.២ | សមាសភាគនៃវិនិយោគវិស័យសាធារណៈ.................................................................. | ៣៦៥ |
| រូបភាពទី៥.៣ | ការព្យាករលំហូរនៃហិរញ្ញប្បទាននាពេលអនាគត ឆ្នាំ២០២៥...................................... | ៣៦៧ |
| រូបភាពទី៦.១ | ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងវដ្តគោលនយោបាយ.................................. | ៣៧៤ |
| រូបភាពទី៦.២ | ទ្រឹស្តីបទនៃការផ្លាស់ប្តូរនិងចង្វាក់លទ្ធផល.............................................................. | ៣៧៥ |
| រូបភាពទី៦.៣ | សូចនាករ ផ.យ.អ.ជ.តាមអាទិភាពគោលនយោបាយ.................................................. | ៣៧៨ |
| រូបភាពទី៦.៤ | សូចនាករ ផ.យ.អ.ជ.តាមប្រភព............................................................................ | ៣៧៩ |
| រូបភាពទី៦.៥ | ទំនាក់ទំនងរវាងរចនាសម្ព័ន្ធកម្មវិធី ថវិកា និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ... | ៣៨២ |


## ឧបសម្ព័ន្ធ


| | | |
|---|---|---|
| ឧបសម្ព័ន្ធទី១ | ពាក្យបំប្រួញ.......................................................................................... | ៤០៩ |
| ឧបសម្ព័ន្ធទី២ | គេហទំព័រ ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល........................................................ | ៤១១ |

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១. ប្រវត្តិដើម

១.១ ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ពីប្រទេសជាតិមួយដែលត្រូវបានបំផ្លិចបំផ្លាញ ដោយសាររបបខ្មែរក្រហមនិងជម្លោះក្នុងរយៈពេលបីទសវត្សរ៍កន្លងទៅនេះ។ បច្ចុប្បន្ននេះ សេដ្ឋកិច្ចកម្ពុជាមានទំហំ៣ដង បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩០ ហើយមូលដ្ឋាននៃសេដ្ឋកិច្ចបានផ្លាស់ប្តូរពីវិស័យកសិកម្មទៅឧស្សាហកម្មនិងសេវាកម្ម ដែលបានធ្វើឲ្យមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់នៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដោយបានស្តែងឡើងតាមរយៈការធ្លាក់ចុះយ៉ាងលឿននៃអត្រាភាពក្រីក្រ គឺបានធ្លាក់ចុះមកក្នុងរង្វង់១៣,៥%នៅឆ្នាំ២០១៤ ដែលស្មើនឹងប្រហែលមួយភាគបួននៃអត្រាភាពក្រីក្រក្នុងឆ្នាំ១៩៩៤។ សមិទ្ធផលដ៏ធំធេងនោះគឺ ប្រទេសកម្ពុជាសម្រេចបាននូវគោលដៅភាគច្រើនដែលបានកំណត់ដោយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដោយចំណុចដៅមួយចំនួនសម្រេចបានមុនកាលកំណត់ ហើយអត្រានៃភាពរីកចម្រើននៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស បានធ្វើឲ្យប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍល្អទាំង១០នៅទូទាំងពិភពលោក។

១.២ មូលដ្ឋានគ្រឹះនៃជោគជ័យទាំងនេះ គឺការប្តេជ្ញាចិត្តនិងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរក្សាសន្តិភាព និងស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន ដោយបានផ្តល់អាទិភាពដល់ការវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យសុខាភិបាល និងវិស័យអប់រំ ទន្ទឹមនឹងការធានាឲ្យមានការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រុងប្រយ័ត្នផងដែរ។ ការលើកកម្ពស់វិនិយោគសាធារណៈ និងឯកជន គួបផ្សំនឹងលំហូរចូលខ្ពស់នៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍បានធ្វើឲ្យវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេសបន្តមានការកើនឡើងជាលំដាប់។

១.៣ នៅឆ្នាំ២០១៥ ប្រទេសកម្ពុជាបានចាកចេញពីប្រទេសដែលមានប្រាក់ចំណូលទាបទៅប្រទេសមានចំណូលមធ្យមកម្រិតទាប។ រាជរដ្ឋាភិបាលបាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងនេះដើម្បីជំរុញឲ្យកម្ពុជាអាចចាកចេញពីស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួច នៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ។ ជាមួយនឹងមហិច្ឆតាក្នុងការជំរុញដំណើរការអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានរៀបចំ

ដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យមនិងវែងរបស់ខ្លួន មានជាអាទិ៍៖ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ កម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ ដំណាក់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ សំដៅប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និង ជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០ ក៏ដូចជា ដើម្បីចូលរួមចំណែកក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍសាកល ក្នុងនោះរួមមាន របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព និង គោលដៅអភិវឌ្ឍប្រកបដោយចីរភាពសកលនៅឆ្នាំ២០១៥។

## ២. ការពិនិត្យឡើងវិញ ពីផែនការអភិវឌ្ឍន៍នៅកម្ពុជា

**១.៤** ក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់នូវទស្សនវិស័យរយៈពេលវែងមួយ គឺ *កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* សម្រាប់ការផ្តួចផ្តើមដំណើរការស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សង្គម រូបវន្ត និងស្ថាប័ន។ ផ្អែកលើទស្សនវិស័យនេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច(ផ.អ.ស.ស.) ៥ឆ្នាំលើកទី១ ១៩៩៦-២០០០* និង *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច (ផ.អ.ស.ស.) ៥ឆ្នាំលើកទី២ ២០០១-២០០៥* ត្រូវបានរៀបចំឡើង។ ផែនការនេះបានផ្តោតជាសំខាន់លើ កំណើនម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ហើយផែនការទី២ បានជំរុញឲ្យមានការអភិវឌ្ឍវិស័យឯកជន ដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងពេលជាមួយគ្នានោះដែរ *កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.) បីឆ្នាំរំកិល* ត្រូវបានរៀបចំឡើង ដើម្បីឲ្យធនធានក្នុងស្រុក និងធនធានបានមកពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្រៅប្រទេស អាចត្រូវបានយកទៅប្រើប្រាស់ទៅតាមវិស័យអាទិភាពនានា ដើម្បីសម្រេចឲ្យបាននូវគោលដៅដែលបានកំណត់នៅក្នុងផែនការ។ *ក.វ.ស. បីឆ្នាំរំកិល* ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ក្នុងអាណត្តិនៃ*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច* ឆ្នាំ២០០២/២០០៣ មានឯកសារសំខាន់ៗចំនួន២ផ្សេងទៀត ដែលផ្តោតសំខាន់លើការកាត់បន្ថយភាពក្រីក្រ គឺ (១) គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង(២) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។

**១.៥** ក្នុងឆ្នាំ២០០៦ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច* ត្រូវបានប្តូរឈ្មោះជា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០០៦-២០១០* ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរទៅរករបៀបធ្វើផែនការដោយចង្អុលបង្ហាញ និងបន្សុីជាមួយសេដ្ឋកិច្ចទីផ្សារដែលកំពុងកើនឡើង

យ៉ាងឆាប់រហ័ស។ ផែនការនេះគឺជាផែនការជាតិតែមួយគត់ដែលគ្របដណ្តប់គ្រប់វិស័យ សម្រាប់អនុវត្ត *គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល* និងកំណត់គោលនយោបាយក្នុងការសម្របសម្រួលកំណើនដែលដឹកនាំដោយវិស័យឯកជនក្រោមបរិស្ថានអនុគ្រោះ។ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាន់ខ្ជាប់នូវគោលការណ៍ឯកភាពជាតិ ប្រមូលផ្តុំនូវប្រជារាស្ត្រពីគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្រោម បាវចនា *"ជាតិ សាសនា ព្រះមហាក្សត្រ"* ដើម្បីកសាងជាតិ និងធានានូវ ឯករាជ្យភាពជាតិ បូរណភាព អធិបតេយ្យភាព សន្តិភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាព។

**១.៦** បន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីកម្មវិធីគោលនយោបាយសង្គម សេដ្ឋកិច្ចរបស់ខ្លួន សម្រាប់នីតិកាលទី៤នៃរដ្ឋសភា។ ផែនការថ្មីនេះមានឈ្មោះថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានអនុម័ត និងដាក់ចេញនូវវិធានការឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះសេដ្ឋកិច្ចនៃបណ្តាប្រទេសជឿនលឿនដែលធ្វើឲ្យតម្រូវការផលិតផលសម្រាប់នាំចេញពីកម្ពុជា មានការថយចុះម៉្យាងទៀត ក៏បានធ្វើឲ្យហានិភ័យក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានការកើនឡើងផងដែរ។ បញ្ហានេះ ក៏បានបង្កើតឲ្យមានផងដែរនូវបញ្ហាមួយចំនួនដែលមិនរំពឹងទុកសម្រាប់កម្ពុជា ដែលក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងការថយចុះនៃសេដ្ឋកិច្ចពិភពលោក។ វិធីសាស្ត្ររៀបចំផែនការបង្ហាញនៅក្នុង *ផ.យ.អ.ជ.* ត្រូវបានរៀបចំកំណត់ច្បាស់ដើម្បីធ្វើការអភិវឌ្ឍប្រទេសជាតិចាប់ពីពេលនោះមក។

**១.៧** ក្នុងការឆ្លើយតបថ្មីៗបំផុត ផ.យ.អ.ជ. ២០១៤-២០១៨ ដែលជាទិសដៅជាយុទ្ធសាស្ត្រវិវឌ្ឍបន្ថែមដោយសង្កត់ធ្ងន់លើការរីកចម្រើនផ្នែកឯកជន ដែលបានចាក់ឫសនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរីព្រមទាំងទទួលស្គាល់ការផ្លាស់ប្តូរប្រភពវិនិយោគ ពីជំនួយអភិវឌ្ឍន៍ផ្លូវការទៅជាវិនិយោគផ្ទាល់បរទេស និងកំណើនចំណូលសាធារណៈក្នុងស្រុក។ របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត *ផ.យ.អ.ជ.* បានលើកឡើងនូវការងារអាទិភាពសំខាន់ចំនួន៧ ដែលត្រូវអនុវត្តនៅពេលខាងមុខ៖ (១) ការលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រនិងកំណើនប្រកបដោយបរិយាប័ន្ន (២) ការពង្រីកវិស័យកសិកម្ម (៣) ការធានានូវភាពប្រកួតប្រជែងកាន់តែខ្លាំង (៤) ការគ្រប់គ្រងការធ្វើចំណាកស្រុកនិងនគរូបនីយកម្ម (៥) ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនិងការកាប់ព្រៃឈើ (៦) ការធានានូវអភិបាលកិច្ចល្អប្រសើរ និង (៧) កែលម្អមូលដ្ឋានធនធានមនុស្ស។ ការអភិវឌ្ឍស្របគ្នាដ៏សំខាន់មួយគឺការអនុម័តលើគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសកល ក្នុងខែកញ្ញាឆ្នាំ២០១៥ និងការអភិវឌ្ឍនានាស្របទៅ នឹងគោលដៅអភិវឌ្ឍន៍

សហស្សវត្សរ៍កម្ពុជា ជាបន្តបន្ទាប់។ ***ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០*** មានចំនួន១៨គោលដៅ (សកលមានចំនួន១៧គោលដៅ បូកបន្ថែមគោលដៅចំនួន១ទៀតទាក់ទងនឹងការបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម)។ ចំណុចដៅចំនួន៨៨ ដែលត្រូវបានជ្រើសរើសពីសំណុំសកលដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជានិងសូចនាករចំនួន១៤៨ ដោយផ្អែកលើសមាមាត្រមួយដែលត្រូវបានទទួលយកដោយផ្ទាល់ពីក្របខ័ណ្ឌសកល សូចនាករប្រុកស៊ីដើម្បីជំនួសសូចនាករដែលបាត់និងវិធានការដែលទទួលបានទូទាំងប្រទេស។

## ៣. យុទ្ធសាស្ត្រចតុកោណ

១.៨ ចាប់តាំងពីឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំកម្មវិធីនយោបាយរបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ បន្ទាប់ពីការបន្សុីគ្នារបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងឆ្នាំ២០០៨ យុទ្ធសាស្ត្រចតុកោណបានផ្តល់ជាការតម្រង់ទិសសម្រាប់ការរៀបចំផែនការជាតិ។ ***ផ.យ.អ.ជ. ២០១៩-២០២៣*** នឹងអនុវត្តរបៀបវារៈនានាដែលមានចែងក្នុង ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*** ដែលផ្សព្វផ្សាយនៅក្នុងខែកញ្ញា ឆ្នាំ២០១៨។

១.៩ យុទ្ធសាស្ត្រចតុកោណ មាន **អភិបាលកិច្ចល្អជាស្នូល** និងជាឯកសារជេរភាពមួយដែលឆ្លើយតបនឹងបញ្ហាប្រឈម ដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងវដ្តនៃការរៀបចំផែនការ។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ មានមុំចំនួន៤ គឺ (១) ការអភិវឌ្ឍធនធានមនុស្ស (២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣) ការអភិវឌ្ឍវិស័យឯកជននិងការងារ និង (៤) ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន ដូចមានបង្ហាញក្នុងរូបភាពទី ១.១ ខាងក្រោម។

## រូបភាពទី ១.១ : គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤




**១.១០** យុទ្ធសាស្ត្រចតុកោណ បានផ្តោតការយកចិត្តទុកដាក់ជាថ្មីទៅលើការបង្កើនផលិតភាពនិងការប្រកួតប្រជែងដើម្បីឈានទៅប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។ ស្នូលនៃយុទ្ធ-សាស្ត្រចតុកោណគឺ ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច ការពង្រឹងស្ថាប័នសាធារណៈ ការបង្កើតឲ្យមានសេវាសាធារណៈដែលមានភាពស្អាតស្អំ ដំណើរការប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ខ្លឹមសារចំនួន៣ដែលគាំទ្រដល់ស្នូលនៃយុទ្ធសាស្ត្រនេះគឺ *គណនេយ្យភាព* ប្រព័ន្ធនៃការឆ្លើយតប ការផ្សារភ្ជាប់ទៅនឹងអាណត្តិ និងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវបានគួបផ្សំជាមួយនឹង*ប្រសិទ្ធភាព* ការពង្រឹងធនធានមនុស្ស ការសម្រួលដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និង *ការប្រើប្រាស់បច្ចេកវិទ្យាឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤* បានផ្តល់ឲ្យនូវកាលានុវត្តភាពប្រសើរឡើងសម្រាប់មនុស្សគ្រប់រូប ជាពិសេសក្រុមងាយរងគ្រោះ ការកែលម្អសេវាកម្មសាធារណៈ រួមជាមួយការការពារធនធានធម្មជាតិនិងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

**១.១១ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ មានគោលដៅយុទ្ធសាស្ត្រចំនួន៤ គឺ៖**

ទី១ ធានាឲ្យបានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាព និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ឲ្យទូលំទូលាយ និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឲ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់។

ទី២ បង្កើតការងារឲ្យបានកាន់តែច្រើន ទាំងបរិមាណនិងគុណភាព ជូនដល់ប្រជាជនកម្ពុជាពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញ ព័ត៌មានទីផ្សារការងារ ការកែលម្អលក្ខខណ្ឌការងារ ការលើកកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគទាំងក្នុងប្រទេសនិងក្រៅប្រទេស។

ទី៣ សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឲ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% ការពារមិនឲ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម។

ទី៤ បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យបានកាន់តែប្រសើរឡើងក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និង បរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។

**១.១២** ភាគច្រើននៃសមាសភាពរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ មានភាពប្រទាក់ក្រឡាជាមួយគ្នា សម្រាប់ធ្វើឲ្យសម្រេចបានអាទិភាពនៅក្នុង ផ.យ.អ.ជ. និងការសម្រេចបានក្របខ័ណ្ឌ គ.អ.ច.ក. និងរួមបញ្ចូលទាំងគោលដៅនិងចំណុចដៅនៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ ផ.យ.អ.ជ. និងការរៀបចំអភិបាលកិច្ចនិងហិរញ្ញវត្ថុ។

## ៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣

**១.១៣** ក្នុងការរៀបចំ*ផ.យ.អ.ជ.* ដោយពិនិត្យលើការវិភាគលើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែងដែលគាំទ្រដល់ការរៀបចំយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់នូវបរិស្ថានតំបន់និងសកល ជាពិសេស និន្នាការធំៗចំនួន

៤ ដូចខាងក្រោម ដែលនឹងជះឥទ្ធិពលលើកម្ពុជា ក្នុងរយៈពេលនៃការរៀបចំ ***ផ.យ.អ.ជ. ២០១៩-២០២៣***៖

- ពិភពលោកកំពុងវិវត្តទៅរកក្របខ័ណ្ឌពហុប៉ូលថ្មីដោយសារការប្រែប្រួលកម្លាំងនិងការកែតម្រូវតុល្យការនៃអំណាចសកល ដូចជាជម្លោះពាណិជ្ជកម្ម និងភាពតានតឹងផ្នែកជាតិនិយម
- សេដ្ឋកិច្ចពិភពលោកដែលកំពុងនាំមុខដោយអាស៊ី និងសេដ្ឋកិច្ចរបស់ប្រទេសចិន
- ចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលគេហៅថាបដិវត្តន៍ឧស្សាហកម្មទី៤ ដែលតម្រូវឲ្យកំណត់ឡើងវិញនូវកត្តាផលិតកម្ម និងផលប្រយោជន៍ប្រកួតប្រជែងដាច់ខាតរបស់ជាតិ
- ការប្រែប្រួលអាកាសធាតុ ដោយមានអាកាសធាតុមិនទៀងទាត់ ដូចជាភាពរាំងស្ងួត រលកកំដៅ និងទឹកជំនន់។

១.១៤ ដោយផ្អែកលើនិន្នាការទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់នូវកាលានុវត្តភាពនិងបញ្ហាប្រឈមជាច្រើនសម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានដាក់បញ្ចូលជាក្រុម តែបញ្ហាណាដែលពាក់ព័ន្ធខ្លាំងក្នុងការរៀបចំ***ផ.យ.អ.ជ. ២០១៩-២០២៣***៖

១. ការបង្កើននិងរក្សាសន្ទុះកំណើននៅក្នុងសេដ្ឋកិច្ចកម្ពុជា (ការរីកចម្រើននៃសកម្មភាពអាជីវកម្មនិងការវិនិយោគក្នុងស្រុក និងលំហូរខ្ពស់នៃវិនិយោគផ្ទាល់បរទេស ដែលជាការឆ្លើយតបទៅនឹងកំណើនតម្រូវការនិងពាណិជ្ជកម្ម) ដោយដោះស្រាយបញ្ហាផលិតភាពនិងការប្រកួតប្រជែង។ នេះត្រូវផ្តោតលើការងារអាទិភាពជាច្រើន រួមមាន៖ ការកសាងធនធានមនុស្សនិងជំនាញ ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការជំរុញតម្លៃបន្ថែមនៅក្នុងវិស័យឧស្សាហកម្មនិងសេវាកម្ម និងការបន្សាំនៃបច្ចេកវិទ្យាថ្មី (បដិវត្តន៍ឧស្សាហកម្មទី៤) និងការផ្តោតការយកចិត្តទុកដាក់លើផលិតភាពនៅតាមតំបន់ជនបទ (រួមបញ្ចូលទាំងផលិតកម្មកសិដ្ឋាននិងមិនមែនកសិកម្ម)។

២. ប្រើប្រាស់នូវគុណសម្បត្តិផ្នែកភូមិសាស្ត្ររបស់កម្ពុជាក្នុងតំបន់អាស៊ីអាគ្នេយ៍ និងភាពនៅជិត នឹងចំណុចកណ្តាលនៃពាណិជ្ជកម្មពិភពលោក ដោយការទាញយកកាលានុវត្តភាពពាណិជ្ជកម្មសេរី(រួមទាំងការធ្វើសមាហរណកម្មអាស៊ាន និងពាណិជ្ជកម្មរបស់ប្រទេសមានការអភិវឌ្ឍតិចតួច) ដើម្បីស្រូបយកការវិនិយោគនិងពង្រីកទីផ្សារនាំចេញ។ ប៉ុន្តែដោយឈរលើគោលការណ៍ស្មើភាពគ្នា ត្រូវការពារទប់ទល់ភាពមិនច្បាស់លាស់នៃសេដ្ឋ-

កិច្ចក្នុងតំបន់និងពិភពលោក រួមទាំងវិបត្តិពាណិជ្ជកម្ម និងរៀបចំមូលដ្ឋានគ្រឹះដើម្បីដោះស្រាយការបាត់បង់ការអនុគ្រោះក្នុងលក្ខខណ្ឌប្រទេសដែលមានការអភិវឌ្ឍតិចតួច និងការរៀបចំឲ្យបានមុនការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៣. ពង្រឹងសមត្ថភាពនៃវិស័យហិរញ្ញវត្ថុរួមទាំងការសម្រួលនិងពង្រឹងការផ្គត់ផ្គង់ឥណទានដូច្នេះបន្ថយនូវឧបសគ្គសំខាន់សម្រាប់សហគ្រាសគ្រប់ទំហំទាំងអស់។ ទាំងនេះរួមបញ្ចូលទាំងការអភិវឌ្ឍទីផ្សារជានារ៉ាប់រងក្នុងស្រុកនិងទីផ្សារមូលប័ត្រ ការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃអន្តរការីហិរញ្ញវត្ថុ និងជំរុញការសន្សំក្នុងស្រុកនិងកាត់បន្ថយបំណុលគ្រួសារ។ ដោយកត់សម្គាល់ថាជាមួយនឹងការបាត់បង់ប្រាក់កម្ចីសម្បទានប្រាក់សន្សំក្នុងស្រុកនិងទីផ្សារមូលធនមានភាពចាំបាច់ក្នុងការរក្សាកម្រិតវិនិយោគនិងកំណើន។ នេះក៏មានទំនាក់ទំនងជាមួយនឹងការមិនប្រើដុល្លារអាមេរិករយៈពេលវែងនៃសេដ្ឋកិច្ចនិងការចេញនូវឧបករណ៍ហិរញ្ញវត្ថុ និងពាណិជ្ជកម្មប្រាក់រៀល។

៤. ទាញយកផលប្រយោជន៍ពេញលេញនៃភាគលាភប្រជាសាស្ត្រនិងអនុបាតតិចតួច ដើម្បីពង្រឹងសន្តិសុខសង្គមនិងប្រព័ន្ធថែរក្សាសុខភាព។ នេះជាមធ្យោបាយមួយដើម្បីកាត់បន្ថយភាពងាយរងគ្រោះផ្ទាល់ខ្លួននិងសេដ្ឋកិច្ចទាំងមូលនិងហានិភ័យ និងរួមចំណែកក្នុងការបង្កើនផលិតភាពនិងកំណើនសេដ្ឋកិច្ច។

៥. រក្សាសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ការដោះស្រាយបញ្ហាប្រឈមខាងក្នុងនិងផ្ទៃក្នុង តាមរយៈការកែទម្រង់សន្តិសុខសាធារណៈនិងសេវាយុត្តិធម៌ដើម្បីផ្តល់ទំនុកចិត្តដល់សាធារណជនទូទៅ និងការធានាគណនេយ្យភាពផ្នែកនយោបាយនិងរដ្ឋបាល តាមរយៈកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់សេវាសាធារណៈកាន់តែទូលំទូលាយ។

៦. ដោះស្រាយភាពទន់ខ្សោយនៃបរិស្ថានដែលធ្លាប់មានពីអតីតកាល និងការពារធនធានធម្មជាតិ តាមរយៈការជំរុញការផលិតនិងការប្រើប្រាស់របស់បរិស្ថាន។ ស្របគ្នានេះដែរក៏មានការឆ្លើយតបនឹងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសកម្មភាពប្រែប្រួលអាកាសធាតុដែលរួមមានការមិនបញ្ចេញកាបូននៃសេដ្ឋកិច្ចនិងជាមួយវិធានការនានា។

## ៥. ទម្រង់នៃ ផ.យ.អ.ជ. ២០១៩-២០២៣

**១.១៥** ឯកសារ *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានរៀបចំឡើងជា៧ជំពូក។ បន្ទាប់ពីសេចក្តីផ្តើម នៅក្នុងជំពូកនេះ ផែនការនេះនឹងបង្ហាញដោយសង្ខេបពី សមិទ្ធផលសំខាន់ៗ និង

បញ្ហាប្រឈម នៅក្នុងអំឡុងពេលនៃការអនុវត្ត*ផ.យ.អ.ជ. ២០១៤-២០១៨* នៅក្នុងជំពូកទី២។ ជំពូកទី៣ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់*ផ.យ.អ.ជ. ២០១៩-២០២៣*។ ជំពូកទី៤ បង្ហាញពីគោលនយោបាយនិងសកម្មភាពអាទិភាព ២០១៩-២០២៣ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធ (ដោយមានកិច្ចសហការពីរដ្ឋបាលមូលដ្ឋាននៅថ្នាក់ក្រោមជាតិ) ត្រូវអនុវត្ត។ ជំពូកទី៥ បង្ហាញការប៉ាន់ស្មានតម្លៃ ដែលរួមទាំងចំណាយ ប្រភពធនធាន និងការកំណត់កម្មវិធីចំណាយ។ ក្របខ័ណ្ឌលទ្ធ-ផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ដំណាក់កាលពីឆ្នាំ២០១៩-២០២៣ នឹងមានបង្ហាញជូននៅក្នុងជំពូកទី៦។ នៅចុងបញ្ចប់ គឺជំពូកទី៧ ដែលបង្ហាញពីសេចក្តីសន្និដ្ឋានយ៉ាងទូលំទូលាយ។

# ជំពូកទី២

# សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

# ជំពូកទី២

## សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

## ១. សេចក្តីផ្តើម

២.១- ជំពូកនេះនឹងបង្ហាញអំពី*វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨* ដោយផ្តោតតាមមុំនីមួយៗនៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* គឺអភិបាលកិច្ចល្អ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យឯកជន និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស។ ការវាយតម្លៃនេះផ្តោតលើការកំណត់សមិទ្ធផលសំខាន់ៗ រួមទាំងភាពប្រឈមនានាដែលជួបប្រទះក្នុងការអនុវត្តរហូតដល់ឆ្នាំ២០១៨។ សូចនាករបរិមាណមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់វិស័យមួយចំនួនហើយពុំមានសូចនាករសម្រាប់វាស់វែងគ្រប់គ្រាន់ ប៉ុន្តែសូចនាករគុណភាពនឹងត្រូវយកមកវាស់វែងវឌ្ឍនភាព។

## ២- អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

### ២.១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

២.២- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់ចំពោះការងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងបានពង្រីក និងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង៣ រួមមាន៖ (១) ការពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ (២) ការបង្ការទប់ស្កាត់កុំឲ្យអាចប្រព្រឹត្តអំពើពុករលួយ និង(៣) ការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការចំពោះជនដែលនៅតែហ៊ានប្រព្រឹត្តអំពើពុករលួយ ដែលសម្រេចបានសមិទ្ធផលដូចខាងក្រោម៖

#### ទី១- ការពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ

- បានអនុវត្ត និងបញ្ជ្រាបការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយដល់គ្រប់គោលដៅ តាមរយៈ ១.ការដាក់បញ្ចូលក្នុងកម្មវិធីអប់រំចំណេះទូទៅចាប់ពីកម្រិតបឋមសិក្សាដល់កម្រិតវិទ្យាល័យ (ថ្នាក់ទី៤ដល់ថ្នាក់ទី១២) ២.ការចុះផ្សព្វផ្សាយផ្ទាល់នៅតាមស្ថាប័នសាធារណៈ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នឯកជន គ្រឹះស្ថានសិក្សា និងអង្គសារព័ត៌មាននានា ផ្សារភ្ជាប់នឹងការចែកជូននូវសម្ភារៈអប់រំផ្សព្វផ្សាយផ្សេងៗដែលបានរៀបចំនិងផលិត ដោយ អ.ប.ព. និង ៣. ការរៀបចំពិធីអបអរសាទរទិវា ជាតិ អន្តរជាតិប្រឆាំងអំពើពុករលួយ និងបង្កើតកម្មវិធី ប្រឡងតាក់តែងកំណាព្យ សូត្រកំណាព្យ សរសេរអត្ថបទខ្លី បទចម្រៀង ចម្រៀងចាប៉ី គូរគំនូរ សម្តែងរឿងកំប្លែងអប់រំ។ល។ មានខ្លឹមសារពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ។
- ជំរុញឲ្យវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល ធ្វើការ អប់រំ ផ្សព្វផ្សាយ មិនឲ្យប្រព្រឹត្តអំពើពុករលួយ។

### ទី២- ការបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ

- ១.ចូលរួមរៀបចំប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ កំណត់ច្បាស់ពីតម្លៃ រយៈពេលផ្តល់ និងយន្តការជាក់លាក់នៃការផ្តល់សេវា ២.ចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយជាមួយវិស័យឯកជន និងរួមគ្នាដាក់ចេញនូវ "សៀវភៅណែនាំអំពីកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជា" និង ៣.ធ្វើការព្រមានជាលាយលក្ខណ៍អក្សរលើមន្ត្រីរាជការដែលក្នុងដំណាក់កាលដំបូងខកខានមិនបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- ចូលរួមសង្កេតការណ៍ក្នុងការប្រឡងក្របខ័ណ្ឌមន្ត្រីរាជការតាមក្រសួង ស្ថាប័ន ប្រឡងជ្រើសរើសសិស្សចូលសិក្សាតាមសាលាវិជ្ជាជីវៈ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងសង្កេតការណ៍ ការដេញថ្លៃវត្ថុតាងបទល្មើសផលអនុផលព្រៃឈើ ដាយត្រី និងក្នុងកិច្ចលទ្ធកម្មសាធារណៈសំដៅពង្រឹងតម្លាភាពនៃការប្រមូលចំណូល និងប្រសិទ្ធភាពនៃការអនុវត្តចំណាយ របស់ ក្រសួង ស្ថាប័ន។
- ប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប០២ឆ្នាំ ទទួលតំណែងថ្មី លាឈប់ ចប់អាណត្តិ បញ្ឈប់ ឬចូលនិវត្តន៍ ទទួលបានលទ្ធផលជោគជ័យដ៏ត្រចះត្រចង់ អាស្រ័យដោយមានការចូលរួមសហការល្អពីក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំនៅគ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវរក្សាទុកទៅតាមបទដ្ឋានបច្ចេកទេស និងរក្សាបាននូវសុវត្ថិភាព និងការសម្ងាត់ខ្ពស់។

### ទី៣- ការអនុវត្តច្បាប់បង្ក្រាប

- ដាក់ចេញ និងអនុវត្តនូវយន្តការទទួលពាក្យប្តឹងប្រកបដោយភាពងាយស្រួល តាមគ្រប់មធ្យោបាយ និងបានដោះស្រាយពាក្យប្តឹងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។
- បង្កើត និងអនុវត្តយន្តការត្រួតពិនិត្យ និងវិភាគពាក្យប្តឹងក្រោមរូបភាពជាកិច្ចប្រជុំវិភាគពាក្យប្តឹង ដើម្បីសិក្សា វិភាគ ផ្តល់យោបល់ និងសម្រេចចំណាត់ការលើពាក្យប្តឹង ជារៀងរាល់ព្រឹកនៃថ្ងៃធ្វើការ ដោយអនុញ្ញាតឲ្យម្ចាស់បណ្តឹងចូលរួមស្តាប់ និងផ្តល់ព័ត៌មានបន្ថែមក្នុងកិច្ចប្រជុំវិភាគពាក្យប្តឹងនេះផងដែរ។
- ចាត់វិធានការដ៏មានប្រសិទ្ធភាពមួយចំនួន ដូចជាស្នើឲ្យអ្នកពាក់ព័ន្ធឆ្លើយបំភ្លឺពីការចោទប្រកាន់ក្នុងករណីមានតម្រុយតិចតួច ការផ្ទេរសមត្ថកិច្ច ប្រសិនបើពាក្យប្តឹងមិនពាក់ព័ន្ធ និងធ្វើការព្រមានចំពោះមុខសញ្ញាដែលក្នុងដំណាក់កាលដំបូង មានការខកខានមិនបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

- ស៊ើបអង្កេត ប្រមូលភស្តុតាងរឹងមាំ និងកសាងសំណុំរឿង ដើម្បីបញ្ជូនជនល្មើសដែលប្រព្រឹត្តអំពើពុករលួយទៅតុលាការ។
- កម្ពុជា ដើម្បីពង្រឹង ពង្រីក និងធ្វើឲ្យប្រសើរឡើងនូវកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងតំបន់ និងអន្តរជាតិ បានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន សកម្ម និងបានចូលរួមក្នុងដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាUNCAC នៅជុំទី១(២០១៣-២០១៥) ប្រកបដោយជោគជ័យដោយមានការចូលរួមពីស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័នតុលាការ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ស្ថាប័នសិក្សាធិការ ស្ថាប័នសារព័ត៌មាន និងវិស័យឯកជន ត្រូវបានវាយតម្លៃខ្ពស់ពីអង្គការសហប្រជាជាតិ និងក្លាយជាគំរូ និងការអនុវត្តល្អសម្រាប់ប្រទេសជាច្រើន។

## បញ្ហាប្រឈម

- **ការផ្លាស់ប្តូរផ្នត់គំនិត និងរួមគ្នាប្រយុទ្ធប្រឆាំងអំពើពុករលួយ:** ទាមទារពេលវេលា ការអត់ធ្មត់ និងការគាំទ្រមិនងាករេ ពីភាគីពាក់ព័ន្ធក្នុងការផ្លាស់ប្តូរ ផ្នត់គំនិត ទស្សនៈ និងទម្លាប់ឲ្យស្អប់ខ្ពើមអំពើពុករលួយ។
- **ភាពព្រមគ្នានៃការអនុវត្ត រៀនសូត្រ កសាងកម្លាំង និងសមត្ថភាព:** ធនធាន និងសមត្ថភាពមន្ត្រី នៅមានកម្រិត ត្រូវការចាំបាច់ រៀនសូត្របណ្តើរ កសាងកម្លាំង និងពង្រឹងសមត្ថភាពបណ្តើរ។
- **ការលំបាកក្នុងការស្វែងរកភស្តុតាង:** ជនល្មើសនៃអំពើពុករលួយកាន់តែមានការវិវឌ្ឍដោយបន្ថែមការប្រុងប្រយ័ត្ន និងព្យាយាមបិទបាំងនូវអំពើល្មើសរបស់ខ្លួន។
- **កង្វះនីតិវិធី និងយន្តការសំខាន់ៗ** ពាក់ព័ន្ធនឹងការការពារសាក្សី និងបុគ្គលរាយការណ៍ ការរឹបអូសផលនៃបទល្មើសមុន និងក្រោយការកាត់ទោសជាដើម។

២.៣- ចាប់តាំងឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ននេះ ក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និង អធិការកិច្ច សម្រេចបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

### ១- ការងារនីតិកម្ម

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារសាក្សី អ្នកជំនាញ និង ជនរងគ្រោះ និងសេចក្តីព្រាងច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍
- រៀបចំគម្រោងកម្មវិធីនៃតម្រូវការសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ការកសាងសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីអធិការកិច្ច និងកសាងសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រី អធិការកិច្ច សម្រាប់អនុវត្តឆ្នាំ២០១៧

### ២- ការងារអប់រំផ្សព្វផ្សាយច្បាប់

- ផ្សព្វផ្សាយច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌ និងវប្បធម៌ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។

### ៣-ការងារអធិការកិច្ច

- ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងកាលបរិច្ឆេទ ២០១៣-២០១៤-២០១៥-២០១៧ នៅក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលនូវបាតុភាពមិនប្រក្រតីមួយចំនួន ហើយបានលើកសំណូមពរ កែលម្អ និងបានធ្វើសេចក្តីជូនដំណឹង ឲ្យជំរុញការកែលម្អចំណុចខ្វះខាតនៅតាមបណ្តារដ្ឋបាលសាលាខេត្ត ក្រុង ស្រុក មន្ទីរ អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

## បញ្ហាប្រឈម

២.៤- ទន្ទឹមនឹងសមិទ្ធផលខាងលើ ក្រសួងក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនដូចខាងក្រោម៖

**១- ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា៖** មិនទាន់បានបញ្ចប់ការកសាងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច អនុក្រឹត្យស្តីពីនីតិវិធីធ្វើអធិការកិច្ច នីតិវិធីតាមដានការអនុវត្តច្បាប់ នីតិវិធីអង្កេតស្រាវជ្រាវពាក្យបណ្តឹង នីតិវិធីផ្សព្វផ្សាយច្បាប់ វិធីសាស្ត្រ សិក្សាស្រាវជ្រាវ និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក៏មិនទាន់ត្រូវបានរៀបចំបង្កើតឡើងផងដែរ ។

**២-ការងារអធិការកិច្ច៖** មិនទាន់មានច្បាប់ស្តីពីអធិការកិច្ច អនុក្រឹត្យ ស្តីពីនីតិវិធីអធិការកិច្ច និងអង្កេតស្រាវជ្រាវបណ្តឹង។ ភាពខ្វះចន្លោះនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បានធ្វើឲ្យក្រសួងពុំទាន់មានមូលដ្ឋានរឹងមាំសម្រាប់អនុវត្តឲ្យមានប្រសិទ្ធភាព ប្រសិទ្ធផលនិងវិធានការពេលអនុវត្តការងារជាក់ស្តែង។

## ២.២- អំណែនទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
### ការកែទម្រង់រចនាសម្ព័ន្ធ លើប្រព័ន្ធយុត្តិធម៌

២.៥- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា ក្រសួងយុត្តិធម៌ បានខិតខំប្រឹងប្រែងបំពេញការងារលើការងារវិស័យច្បាប់ និងបម្រើសេវាកម្មយុត្តិធម៌ ជូនប្រជាពលរដ្ឋ។ បានបំពេញភារកិច្ច និងតួនាទីតាមមុខសញ្ញារៀងៗខ្លួន ក្នុងរយៈពេល៥ ឆ្នាំ កន្លងមក ហើយបើគិតពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ វិស័យយុត្តិធម៌សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

### ក. ការងារនីតិកម្ម

- ក្នុងទិសដៅពង្រឹងនីតិរដ្ឋឲ្យកាន់តែរឹងមាំថែមទៀត ក្រសួងយុត្តិធម៌បានសហការជាមួយអង្គការនានានៃប្រទេសដែលជាដៃគូអភិវឌ្ឍ ដើម្បីតាក់តែង និងកសាងសេចក្តីព្រាងច្បាប់មូលដ្ឋានសំខាន់ៗជាច្រើន ដែលប្រទេសកម្ពុជាយើងកំពុងត្រូវការជាចាំបាច់បំផុត។ បន្ថែមលើច្បាប់ជាច្រើនដែលមានកន្លងមករួចទៅហើយ ចាប់ពីឆ្នាំ២០១៤មក ក្រសួងយុត្តិធម៌បានបង្កើតច្បាប់គ្រឹះចំនួន៣បន្ថែម គឺ ១.ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ២.ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និង ៣.ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងលិខិតបទដ្ឋានគតិយុត្តចំនួន៨ ដែលបានអនុម័ត និងចូលជាធរមានរួចហើយ ព្រមទាំងមានលិខិតុបករណ៍អន្តរជាតិចំនួន២ ដែលបានរៀបចំរួចហើយគឺ ១.ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម និង ២.កិច្ចព្រមព្រៀងជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ បន្ថែមពីនេះ ក្រសួងយុត្តិធម៌បាន និងកំពុងពិនិត្យរៀបចំសេចក្តីព្រាងច្បាប់ចំនួន៨ គឺ៖ ១.សេចក្តីព្រាងច្បាប់ស្តីពីសារការី ២.សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ៣.សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ៤.សេចក្តីព្រាងច្បាប់ស្តីពីអ្នកជំនាញក្នុងវិស័យយុត្តិធម៌ ៥.សេចក្តីព្រាងច្បាប់ស្តីពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ៦.សេចក្តីព្រាងច្បាប់ស្តីពីតម្កល់ ៧.សេចក្តីព្រាងច្បាប់ស្តីពីអគ្រានុកូលដ្ឋាន និង ៨.សេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស។ ក្រៅតែពីសេចក្តីព្រាងច្បាប់ ក្រសួងយុត្តិធម៌ក៏កំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងរដ្ឋប្បវេណីមួយចំនួន ព្រមទាំងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។ ក្រសួងយុត្តិធម៌ក៏បានដើរតួយ៉ាងសំខាន់នៅក្នុងការចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់នានាជាច្រើនទៀតដែលរៀបចំឡើងដោយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលជាពិសេសការផ្តល់យោបល់ពាក់ព័ន្ធនឹងការកំណត់ទោសប្បញ្ញត្តិ។

### ខ. ការងារបណ្តុះបណ្តាលធនធានមនុស្ស

#### ១. ការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងស្រាវជ្រាវនៅកម្រិតក្រសួង

- ក្រសួងបានធ្វើការផ្សព្វផ្សាយចែកជូនសៀវភៅច្បាប់ ជាពិសេសច្បាប់គោលទាំង៤ (ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ) ដល់គ្រប់ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ គណៈមេធាវី និងគ្រប់សាកលវិទ្យាល័យ វិទ្យាស្ថានរដ្ឋ ព្រមទាំងមន្ត្រីនគរបាលយុត្តិធម៌ នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ដើម្បីបានឯកសារច្បាប់គោលនេះទុកជាមូលដ្ឋាន សម្រាប់អនុវត្តការងារ និងសម្រាប់ជាឯកសារសិក្សាស្រាវជ្រាវផ្សេងៗ។
- គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ (គ.ប.ច.) ចំណុះក្រសួងយុត្តិធម៌ ត្រូវបានរៀបចំបង្កើតឡើងកាលពីឆ្នាំ២០១៤។

### គ. កិច្ចការរដ្ឋបាលសាលាជម្រះក្តី និងអភិវឌ្ឍន៍វិស័យយុត្តិធម៌

- ក្រសួងយុត្តិធម៌បានដាក់ឲ្យសាកល្បងប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមប្រព័ន្ធកុំព្យូទ័រនៅតាមសាលាដំបូង ខេត្តមួយចំនួន និងនៅឆ្នាំ២០១៦ បានបំពាក់បន្ថែមនូវប្រព័ន្ធគ្រប់-គ្រងព័ត៌មានចាំបាច់ និងគេហទំព័រកិច្ចការរដ្ឋបាលតុលាការ នៅឆ្នាំ២០១៧ បានពង្រីកការបំពាក់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមប្រព័ន្ធកុំព្យូទ័រតាមសាលាដំបូងខេត្តមួយចំនួនបន្ថែមទៀត នៅឆ្នាំ២០១៨ ក្រសួងយុត្តិធម៌បានពង្រីកប្រព័ន្ធអេឡិចត្រូនិកសម្រាប់ចុះបញ្ជី និងណែនាំបច្ចេកទេសដល់សាលាដំបូងខេត្តមួយចំនួន។
- ក្នុងគោលបំណងបង្កិតសិទ្ធិទទួលបានយុត្តិធម៌ឲ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋានតំបន់ខេត្តឆ្ងាយៗ សំដៅធ្វើឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋ ក្រសួងយុត្តិធម៌បាន និងកំពុងរៀបចំសាងសង់អគារសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ និងសាលាឧទ្ធរណ៍ខេត្តបាត់ដំបង ហើយកំពុងពិនិត្យលទ្ធភាពសាងសង់អគារសាលាឧទ្ធរណ៍បន្ថែមទៀត នៅខេត្តព្រះសីហនុ។

### ង. សេវាកម្មយុត្តិធម៌ក្រៅពីការជំនុំជម្រះ

- ក្រសួងយុត្តិធម៌បានធ្វើការសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រៀបចំមេធាវីការពារក្តីដល់ជនក្រីក្រ។

### បញ្ហាប្រឈម

២.៦- ការអនុវត្តការងារនៅកម្រិតក្រសួងយុត្តិធម៌ បញ្ហាប្រឈមដែលបានកើតមានរួមមាន៖

- ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់មន្ត្រីរាជ-ការ និងសាធារណជន នៅមានកម្រិត
- មធ្យោបាយបម្រើការងារ និងការអនុវត្តការងារនៅតាមសាលាជម្រះក្តី នៅមានកម្រិត
- ចំនួនចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី និងមន្ត្រីជាប់កិច្ចសន្យាមិនទាន់ឆ្លើយតបតម្រូវការ។

## ២.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ

២.៧- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំកែសម្រួលរចនាសម្ព័ន្ធនៅក្នុងការគ្រប់គ្រងតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅកែលម្អ និងពង្រឹងគុណភាព និងផលិតភាពការងារក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។ ជាក់ស្តែងនៅក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រសួងមុខងារសាធារណៈ ដែលមានតួនាទីភារកិច្ចនៅក្នុងការអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈ។ ទន្ទឹមនេះ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ត្រូវបានរៀបចំឡើងដោយផ្តោតជាសំខាន់លើគោលបំណងចំនួនបី៖ ១.សេវាសាធារណៈ ប្រកបដោយគុណភាព ភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា ២.ការគ្រប់គ្រងនិងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ ដោយប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ ៣.ប្រព័ន្ធបៀវត្សត្រូវធានាបាននូវសមធម៌ បង្កើនផលិតភាពនិងប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌកងកម្លាំងប្រដាប់អាវុធ។ ជាមួយគ្នានេះដែរ ក្រសួង បានសម្រេចនូវសមិទ្ធផលសំខាន់ៗគួរឲ្យកត់សម្គាល់ ដូចខាងក្រោម៖

### ការកែលម្អគុណភាពសេវាសាធារណៈ

- ធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈនៅក្រសួង ស្ថាប័នចំនួន២៦ ជាទៀងទាត់ និងដាក់ឲ្យដំណើរការកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈ តាមរយៈទូរស័ព្ទស្មាតហ្វូន។
- ដាក់ឲ្យអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេសចំនួន៤បន្ថែមទៀត នៅក្នុងក្រសួងសុខាភិបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពត ព្រៃវែង ក្រចេះ និងកំពង់ធំ។
- សហការជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ពង្រីកការដាក់ឲ្យដំណើរការយន្តការច្រកចេញចូលតែមួយ នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បង្កើតក្រុមការងារអន្តរក្រសួង និងសហការជាមួយវិទ្យាស្ថានបច្ចេកវិទ្យាទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងអង្គការតម្លាភាពកម្ពុជា ដើម្បីរៀបចំនិងដាក់ឲ្យដំណើរការកម្មវិធីទូរស័ព្ទផ្តល់ព័ត៌មានសេវាសាធារណៈ និងច្រកទ្វារអេឡិចត្រូនិកផ្តល់សេវាសាធារណៈជំហានទី១។
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ ដើម្បីបង្កើតជាក្របខ័ណ្ឌគតិយុត្តិសម្រាប់ជំរុញការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។
- រៀបចំនិងដាក់ឲ្យអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីជំរុញចលនាប្រឡងប្រជែងការ

កែលម្អការផ្តល់សេវាសាធារណៈនៅគ្រឹះស្ថានអប់រំនិងសុខាភិបាលរបស់រដ្ឋ។

- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការ នៅតាមអង្គភាពផ្តល់សេវាសាធារណៈអំពីគោលនយោបាយ ទស្សនទាន យន្តការ និងវិធីសាស្ត្រនៃការផ្តល់និងការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។
- សហការជាមួយលេខាធិការដ្ឋានអាស៊ាន ដើម្បីអនុវត្តគម្រោងរៀបចំសេចក្តីណែនាំស្តីពីស្តង់ដាសេវាសាធារណៈសម្រាប់ប្រទេសអាស៊ានទាំង១០។
- ជំរុញឲ្យក្រសួង ស្ថាប័នប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ក្នុងការផ្តល់សេវាដូចជា៖ ពន្ធដារ ពន្ធគយ រដ្ឋាករទឹក អគ្គិសនី ការបង់ពន្ធផ្លូវ ការធ្វើស្លាកលេខម៉ូតូ រថយន្ត បណ្ណបើកបរ ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណពាណិជ្ជកម្ម ជាដើម។
- ជំរុញដល់ក្រសួងស្ថាប័នក្នុងការកែសម្រួលរចនាសម្ព័ន្ធ ដើម្បីបង្កើតការិយាល័យ ឬយន្តការច្រកចេញចូលតែមួយក្នុងការផ្តល់សេវាសាធារណៈ ដូចជា៖ តំបន់សេដ្ឋកិច្ចពិសេស រដ្ឋបាល ស្រុក និងខេត្តជាដើម។

## ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន

- រៀបចំនិងដាក់ឲ្យអនុវត្តគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ និងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួនទៀតដើម្បីពង្រឹង ការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ការគ្រប់គ្រងរចនាសម្ព័ន្ធនិងចំនួនមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន ការត្រួតពិនិត្យការគ្រប់គ្រងវត្តមានរបស់មន្ត្រី ការគ្រប់គ្រងនិងការវាយតម្លៃគុណផលរបស់មន្ត្រីរាជការស៊ីវិល និងការធ្វើប្រតិភូកម្មអំណាចក្នុងការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សដោយគិតចាប់តាំងពីការជ្រើសរើសរហូតដល់ការដាក់ឲ្យចូលនិវត្តន៍។
- ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី
- រៀបចំនិងដាក់ឲ្យអនុវត្តគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ និងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួនទៀតដែលពាក់ព័ន្ធនឹង៖ ការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ការគ្រប់គ្រងរចនាសម្ព័ន្ធនិងចំនួនមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ការត្រួតពិនិត្យការគ្រប់គ្រងវត្តមានរបស់មន្ត្រី ការគ្រប់គ្រងនិងការវាយតម្លៃគុណផលរបស់មន្ត្រីរាជការស៊ីវិល និងការធ្វើប្រតិភូកម្មអំណាចក្នុងការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងប្រព័ន្ធមុខងារសាធារណៈថ្មី
- កែសម្រួលនិងដាក់ឲ្យអនុវត្តការពន្លឿននីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍

- កែលម្អការរៀបចំផែនការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីធានាឲ្យការជ្រើសរើស និងការប្រើប្រាស់ចំគោលដៅ។ មន្ត្រីត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់ ដើម្បីកុំឲ្យប៉ះពាល់ដល់កញ្ចប់ថវិកាខ្លាំងពេក។
- ត្រួតពិនិត្យការប្រើប្រាស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យានៅតាមក្រសួងស្ថាប័ន។
- កំពុងធ្វើវិមជ្ឈការប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា តាមប្រព័ន្ធព័ត៌មានវិទ្យា នឹងឈានទៅអនុវត្តសម្រាប់ក្រសួង ស្ថាប័នដទៃទៀត បន្ទាប់ពីការអនុវត្តគម្រោង នេះទទួលបានជោគជ័យ
- បណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព តាមរយៈការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល ដោយផ្តោតទៅលើវគ្គបណ្តុះបណ្តាលដំបូង វគ្គបណ្តុះបណ្តាលបន្ត និងវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ ដើម្បីពង្រឹងនិងអភិវឌ្ឍន៍សមត្ថភាពដល់ សិស្ស និស្សិត និងមន្ត្រីរាជការសម្រាប់បម្រើការងារក្នុងវិស័យមុខងារសាធារណៈ។
- សម្រាប់ការគ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា ក្រសួងបានរៀបចំផែនការប្រើប្រាស់ក្របខ័ណ្ឌប្រចាំឆ្នាំ ផ្អែកលើគោលការណ៍ក្របខ័ណ្ឌដែលបាត់បង់ដោយការចូលនិវត្តន៍ មរណភាព ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបោះបង់ការងារ និង សេចក្តីត្រូវការពិតប្រាកដនិងចាំបាច់បំផុត និងត្រូវផ្អែកលើមុខតំណែង អង្គភាព និងទីកន្លែងបំពេញការងារច្បាស់លាស់ ក្នុងគោលដៅបំពេញមុខតំណែងទំនេរតែប៉ុណ្ណោះ។ ជាលទ្ធផលអត្រាកំណើនមន្ត្រីរាជការស៊ីវិលអនុវត្តតាមផែនការស្ថិតក្នុងរង្វង់០,៨៥%ក្នុងមួយឆ្នាំ។ ការជ្រើសរើសត្រូវបានគិតគូរផ្តល់អាទិភាពដល់បេក្ខជនជាស្ត្រីដោយត្រូវជ្រើសរើសពី២០% ទៅ ៥០% ក្នុងចំនួនក្របខ័ណ្ឌដែលទទួលបានប្រចាំឆ្នាំ និង តម្រូវឲ្យជ្រើសរើសជនពិការដែលមានសមត្ថភាពសមស្របចូលក្របខ័ណ្ឌក្នុងអត្រា២% នៃក្របខ័ណ្ឌសរុបរបស់ក្រសួងស្ថាប័ននីមួយៗ។

**តារាងទី ២.១ ចំនួនមន្ត្រីរាជការនិងមន្ត្រីប្រភេទផ្សេងទៀតក្នុងតារាងបៀវត្ស តាមប្រព័ន្ធព័ត៌មានវិទ្យា គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ (ឯកតាគិតជា នាក់)**

| បរិយាយ | ប្រុស | | ស្ត្រី | | សរុប | |
|---|---|---|---|---|---|---|
| ថ្នាក់ជាតិ | ២៩ ៧៩១ | ១៤% | ១១ ៥០១ | ៦% | ៤១ ២៩២ | ២០% |
| ថ្នាក់ក្រោមជាតិ | ៩៥ ៩៣៣ | ៤៦% | ៧១ ៥០០ | ៣៤% | ១៦៧ ៤៣៣ | ៨០% |
| សរុប | ១២៥ ៧២៤ | ៦០% | ៨៣ ០០១ | ៤០% | ២០៨ ៧២៥ | ១០០% |

*ប្រភព:* ក្រសួងមុខងារសាធារណៈ

## ការកែទម្រង់បៀវត្ស និងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត

- ផ្តល់ប្រាក់វិភាជន៍គ្រួសារសម្រាប់កូនមន្ត្រីរាជការរហូតដល់អាយុ២១ឆ្នាំ ដោយស្វ័យប្រវត្តិ ព្រមទាំងដំឡើងប្រាក់វិភាជន៍គ្រួសារ និង ផ្តល់ភាពអនុគ្រោះលើមូលដ្ឋានគិតពន្ធលើ

ប្រាក់បៀវត្ស។

- ពិនិត្យនិងតាមដានការអនុវត្តការងារ របស់គណៈកម្មការសិក្សានិងត្រួតពិនិត្យលើការប្រើប្រាស់ថ្នាក់ពីរវេន ថ្នាក់គួប និងការកំណត់ប្រាក់តំបន់នៃក្រសួងអប់រំ យុវជន និង កីឡា។
- រៀបចំផ្តល់ប្រាក់តំបន់សម្រាប់វិស័យសុខាភិបាល និងវិស័យអប់រំ និង រៀបចំដំឡើងរបបសន្តិសុខសង្គមជូនមន្ត្រីរាជការជាស្ត្រី(ប្រាក់ឧបត្ថម្ភមាតុភាព) និង ដំឡើងរបបសោធននិវត្តន៍ជូនអតីតមន្ត្រីរាជការនិងអតីតយុទ្ធជន។

**តារាងទី ២.២ បៀវត្សអប្បបរមាមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ (គិតជារៀល)**

| ឆ្នាំ / សូចនាករ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| រដ្ឋបាល ការទូតនិងបច្ចេកទេស | ៣៤៤ ០០០ | ៤២៤ ០០០ | ៥៥២ ៨០០ | ៧០០ ៥០០ | ៨៥៣ ៥០០ | ១ ០១៤ ៤៥០ |
| អប់រំ | ៤០២ ៨០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ | ៩៥៣ ៥០០ | ១ ១១៤ ៤៥០ |
| សុខាភិបាល | ៣៦០ ០០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ | ៩៥៣ ៥០០ | ១ ១១៤ ៤៥០ |
| នគរបាលជាតិ | ៣៧៩ ៩៣០ | ៤៦០ ៩៣០ | ៦២៨ ២៧០ | ៧៨៤ ៧៣០ | ៩៣៧ ៩៧៧ | ១ ០៩៨ ៩២៧ |
| យោធិន | ៣១៥ ៩៩០ | ៣៩៦ ៩៩០ | ៥៨២ ៤៣០ | ៧៣៣ ៧៣០ | ៨៨០ ៩៧៧ | ១ ០៣៥ ០២៧ |

*ប្រភព :* ក្រសួងមុខងារសាធារណៈ

## បញ្ហាប្រឈម

២.៨- នៅក្នុងអនុវត្តការងារគោលនយោបាយ និងកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងរយៈពេលកន្លងមកនេះ មានបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ការផ្សព្វផ្សាយកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត នៅថ្នាក់ក្រោមជាតិ ហើយក៏នៅមានកង្វះខាតនូវការលើកទឹកចិត្តសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ មានកង្វះខាតនូវបទដ្ឋានគតិយុត្តសម្រាប់ជំរុញ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ដោយឡែកការចូលរួមនិងការសហការរវាងអង្គភាពនិងអង្គភាព ស្ថាប័ននិងស្ថាប័ន និងដៃគូអភិវឌ្ឍនៅជាបញ្ហានៅឡើយ។
- សមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ក្រសួង ស្ថាប័ន នៅមិនទាន់អាចឆ្លើយតបបានពេញលេញទៅនឹងសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលទន្ទឹមនឹងនេះ ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មុខតំណែងវិជ្ជាជីវៈ ក៏នៅមានកង្វះខាតសមត្ថភាពនៅក្នុងការរៀបចំអនុវត្តផងដែរ។
- ការកសាងសមត្ថភាពមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលមិនទាន់មានលក្ខណៈជាប្រព័ន្ធ និងមិនទាន់មានប្រសិទ្ធភាពឆ្លើយតបទៅនឹងការវិវឌ្ឍរបស់រដ្ឋបាលសាធារណៈ។
- ការវិភាគមុខងាររបស់ក្រសួងស្ថាប័ន អង្គភាព និងការងារក្នុងក្រសួង ស្ថាប័ន និងអន្តរក្រសួង

សម្រាប់ប្រភេទសេវានីមួយៗមិនទាន់កំណត់បានច្បាស់លាស់ និងកែលម្អឲ្យមានប្រសិទ្ធភាពខ្ពស់នៅឡើយ។ ដោយឡែក នីតិវិធីនៃការប្រើប្រាស់ថវិកាមិនទាន់ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនៃការអនុវត្តសកម្មភាពក្នុងផែនការដែលបានកំណត់។

- ការផ្សារភ្ជាប់ផ្នែកស្ថាប័ន និងសកម្មភាពកែទម្រង់ទាំងឡាយក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលនៅមិនទាន់អនុវត្តឲ្យបានពេញលេញនិងមានប្រសិទ្ធភាព។
- ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនិងការលើកកម្ពស់គុណភាពសេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះ ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យានៅតែមិនទាន់បានធ្វើវិមជ្ឈការវិសហមជ្ឈការក្នុងការគ្រប់គ្រង។

## កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

២.៩- ក្នុងអំឡុងពេលពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការបានបន្តផ្តោតជាសំខាន់ៗលើកិច្ចការអាទិភាពពាក់ព័ន្ធនឹង ១.ការគ្រប់គ្រងការងារកំណែទម្រង់ ២.អភិបាលកិច្ចល្អ ៣.ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤.ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង ៥.វិមជ្ឈការហិរញ្ញវត្ថុ។

២.១០- ក្រោមការដឹកនាំសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ដោយមានកិច្ចសហការជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់តាមវិស័យនានាបានជំរុញឲ្យការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសម្រេចនូវសមិទ្ធផលធំៗជាច្រើន ដូចខាងក្រោម៖

**១.ការគ្រប់គ្រងការងារកំណែទម្រង់៖** សមិទ្ធផលសំខាន់ៗរួមមាន ១.លិខិតបទដ្ឋានគតិយុត្តប្រមាណ៣០០ត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ២.ដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ៣.រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យនិងកែសម្រួលជាបន្តបន្ទាប់ ដើម្បីធានាដល់ការឆ្លើយតបទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និង ៤.សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិរួមមានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សារដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានបង្កើតដើម្បីគាំទ្រ និងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**២. អភិបាលកិច្ចល្អ៖** គឺជាកិច្ចដំណើរការនៃការអនុវត្តសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងការងាររបស់ស្ថាប័នរដ្ឋ ឬស្ថាប័នឯកជន ឬ

អង្គការសង្គមស៊ីវិលនានា សមិទ្ធផលសំខាន់ៗរួមមាន៖ ១.ផែនការយុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការងារគណនេយ្យភាពសង្គម ត្រូវបានរៀបចំ និងអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានាដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តការងារ ការប្រើប្រាស់ថវិកា ការផ្តល់សេវា និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ២.គោលការណ៍នានាសម្រាប់ការលើកកម្ពស់យេនឌ័រ បរិយាប័ន្នសមធម៌សង្គម និងយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងត្រូវបានបញ្ជ្រាបទៅក្នុងនីតិវិធីអនុវត្តការងារ និងប្រព័ន្ធគ្រប់គ្រងនានា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣.យន្តការសម្រុះសម្រួល និងដោះស្រាយពាក្យបណ្តឹងត៌វ៉ារបស់ប្រជាពលរដ្ឋពាក់ព័ន្ធការផ្តល់សេវាសាធារណៈនិងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិងដាក់ឲ្យដំណើរការ ៤.គណនេយ្យភាពរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ រវាងក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលរបស់ខ្លួននិងរវាងក្រុមប្រឹក្សា និងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ត្រូវបានពង្រឹងជាបណ្តើរៗ។

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖** សមិទ្ធផលសំខាន់ៗរួមមាន៖ ១.លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្ទេរសិទ្ធិអំណាចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត ២.ផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងដាក់ឲ្យអនុវត្ត ៣.ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងអំពីក្របខ័ណ្ឌនៃការអនុវត្តតាមប្រព័ន្ធ និងនីតិវិធីអនុវត្តការងារនានាត្រូវបានផ្តល់ជាប្រចាំ និង ៤.សាលាជាតិរដ្ឋបាលមូលដ្ឋានសម្រាប់ផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត និងកំពុងចាប់ផ្តើមដំណើរការ។

**៤. ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន៖** សមិទ្ធផលសំខាន់ៗរួមមាន៖ ១.ក្រសួងស្ថាប័នចំនួន១៤ បានរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះមានក្រសួងចំនួន៤ បានផ្ទេរមុខងារចំនួន១៦ ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺក្រសួងបរិស្ថានបានផ្ទេរមុខងារចំនួន០៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្ទេរមុខងារចំនួន០៣ ក្រសួងអភិវឌ្ឍន៍ជនបទ បានផ្ទេរមុខងារចំនួន០៣ ក្រសួងអប់រំ យុវជន និងកីឡា បានផ្ទេរមុខងារចំនួន០៤ ២.ជាមួយគ្នានេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា **ក្រសួងមហាផ្ទៃ** បានស្នើសុំទៅរាជរដ្ឋាភិបាលដាក់ចេញអនុក្រឹត្យ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងពាក់ព័ន្ធចំនួន១៤ បានធ្វើប្រតិភូកម្មនូវមុខងារ ផ្តល់សេវារដ្ឋបាលចំនួនប្រមាណជាង៦០០ប្រភេទ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមរយៈយន្តការច្រក

ចេញចូលតែមួយ។ ចំពោះការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ បានបង្កើតឡើងនិងកំពុងដំណើរការ។

**៥. វិមជ្ឈការហិរញ្ញវត្ថុ៖** សមិទ្ធផលសំខាន់ៗរួមមាន៖ ១.ការបង្កើតប្រព័ន្ធផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌ (មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់) ២.ការបង្កើតយន្តការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌភ្ជាប់ជាមួយនឹងមុខងារដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៣.ការបង្កើតយន្តការផ្ទេរធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាការផ្តល់ហិរញ្ញប្បទានបន្ថែមទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងលក្ខណៈប្រកួតប្រជែងសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈនានា ៤.ការបង្កើតប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការចែករំលែកចំណូលពន្ធ និងមិនមែនសារពើពន្ធរវាងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយកំណត់ឲ្យរដ្ឋបាលរាជធានី ខេត្ត ចែករំលែកចំណូលសារពើពន្ធទាំងនោះក្នុងអត្រា ៣% ឲ្យទៅរដ្ឋបាលក្រុង ស្រុក និង ១% ឲ្យទៅរដ្ឋបាលឃុំ សង្កាត់។

### បញ្ហាប្រឈម

២.១១- ទោះបីសម្រេចបានសមិទ្ធផលគួរឲ្យកត់សម្គាល់ក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ រួមមាន៖

- កិច្ចដំណើរការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពយឺតយ៉ាវជាងការរំពឹងទុក។ រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលទ្ធភាព និងសមត្ថភាពពេញលេញក្នុងការចាប់ផ្តើមអនុវត្តមុខងារទាំងនោះនៅឡើយ ដោយសារភាពយឺតយ៉ាវនៃការផ្ទេរធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។
- ការរៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវជាងការរំពឹងទុក ដែលនាំឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានសិទ្ធិអំណាចពេញលេញក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមក ផ្តោតតែទៅលើក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋានគតិយុត្តដោយពុំទាន់បានផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពជំនាញជាក់-លាក់ដែលត្រូវការចាំបាច់សម្រាប់ការផ្តួចផ្តើមគំនិតប្រកបដោយភាពច្នៃប្រឌិតក្នុងការដឹកនាំការគ្រប់គ្រង និងការចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាក់ស្តែងនៅឡើយ។
- រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនៅពុំទាន់ឆ្លើយតបទៅនឹងគោលការណ៍គ្រប់គ្រងតាមបែបរដ្ឋបាលឯកភាព ដែលធានាដល់ការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ក្នុងការអនុវត្តរាល់សកម្មភាពសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលមូលដ្ឋាននីមួយៗ។

- ចំពោះនីតិវិធីបែបបទនៃការផ្តល់សេវារបស់មន្ទីរ អង្គភាពនៅមានភាពស្មុគ្រស្មាញ ដែលតម្រូវឲ្យសិក្សាលម្អិត និងឯកភាពរវាងរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពសាមី ដើម្បីធ្វើការកែសម្រួលឲ្យមានលក្ខណៈសាមញ្ញជូនប្រជាពលរដ្ឋ។

## ២.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

២.១២- ឆ្លើយតបទៅនឹងការគំរាមកំហែងទាំងឡាយ កងយោធពលខេមរភូមិន្ទបានអនុវត្តសិទ្ធិស្វ័យការពារយ៉ាងប្តូរផ្តាច់ ក្នុងការទប់ស្កាត់និងវាយបកទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព រក្សាបាននូវបូរណភាពទឹកដីគ្រប់កាលៈទេសៈ និងរក្សាបាននូវភាពអត់ធ្មត់ខ្ពស់បំផុតដោយគោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់អន្តរជាតិក៏ដូចជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងផ្នែកការទូតនិងផ្លូវច្បាប់។ សមិទ្ធផល នានាដែលកងយោធពលខេមរភូមិន្ទ សម្រេចបាន៖

- កំពុងអនុវត្តចក្ខុវិស័យប្រែក្លាយអតីតតំបន់ប្រយុទ្ធមកជាតំបន់អភិវឌ្ឍ ពីទីលានសមរភូមិទៅជាទីផ្សារសេដ្ឋកិច្ច ពីតំបន់គ្រោះថ្នាក់ ទៅជាតំបន់ទេសចរណ៍ ពីតំបន់ភ័យខ្លាចទៅជាតំបន់ សន្តិភាព មានមនុស្សរស់នៅកុះករ ។
- កំពុងបំពេញកិច្ចការពារព្រំដែន សន្តិសុខលម្ហសមុទ្រ ការហ្វឹកហ្វឺន និងការបណ្តុះបណ្តាល ប្រតិបត្តិការរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ការប្រឆាំងភេរវកម្ម ជំនួយមនុស្សធម៌ និងការឆ្លើយតបគ្រោះមហន្តរាយ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគ្រប់គ្រងធនធានការពារជាតិ។
- បង្កើតវិទ្យាស្ថានជាតិគ្រប់គ្រងកម្លាំងរក្សាសន្តិភាព និងកាកសំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងបានបង្កើតសមាគមអតីតយុទ្ធជនកម្ពុជាផងដែរ ដើម្បីបម្រើសេវាកម្មសុខុមាលភាពក្នុងសហគមន៍កងទ័ព ដោយផ្តោតទៅលើគោលនយោបាយ សម្បទានដី សង្គមកិច្ចរបស់រាជរដ្ឋាភិបាល ។
- ទទួលសិទ្ធិក្នុងការធ្វើធុរកិច្ច ដើម្បីស្វែងរកប្រភពចំណូល ពង្រីកកិត្យានុភាពកងទ័ព និងបង្កើនកម្រិតជីវភាពរស់នៅរបស់សហគមន៍កងទ័ព។

២.១៣- បច្ចុប្បន្នក្រសួងការពារជាតិ ក្នុងនាមសេនាធិការឲ្យរាជរដ្ឋាភិបាលកម្ពុជា បានកសាងឡើងនូវសមិទ្ធផលជាប្រវត្តិសាស្ត្រទិវាចងចាំដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជ-សាសន៍ ប៉ុល ពត ថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៧ មួយទៀតនោះគឺ ***វិមាននយោបាយឈ្នះឈ្នះ*** ដែលបានចាប់ផ្តើមកសាងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ហើយនិងដាក់សម្ពោធជាផ្លូវការ នៅថ្ងៃទី២៩-៣១ ខែធ្នូ ឆ្នាំ២០១៨។ ការកសាងសមិទ្ធផលជាប្រវត្តិសាស្ត្រនេះក្នុងគោលបំណងបង្ហាញពីតម្លៃសន្តិភាពនិងការផ្សះផ្សារជាតិ ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**បញ្ហាប្រឈម**

២.១៤- ទោះជាសម្រេចបាននូវសមិទ្ធផលដូចខាងលើ ក៏កងយោធពលខេមរភូមិន្ទ នៅជួបបញ្ហាប្រឈមដូចខាងក្រោម៖

- ពុំមានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈសមស្រប ដើម្បីពង្រឹងសមត្ថភាពកងទ័ពលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិជ្ជាជីវៈ ។
- ការគ្រប់គ្រងនឹងប្រើប្រាស់ធនធានរូបវន្តរបស់កងទ័ព នៅមិនទាន់អស់សក្ដានុពលប្រកបដោយប្រសិទ្ធភាពដើម្បីទាញយកប្រយោជន៍ឲ្យបានជាអតិបរមា សម្រាប់បង្កើនកម្រិតជីវភាពរស់នៅនិងការអភិវឌ្ឍអង្គភាព។
- ការបង្កើតដៃគូអភិវឌ្ឍយុទ្ធសាស្ត្រ សម្រាប់ធ្វើកិច្ចសហប្រតិបត្តិការ និងការវិនិយោគធុរកិច្ចរយៈពេលវែង នៅពុំទាន់បានឆ្លើយតប។

## ៣- បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

## ៣.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

២.១៥- សភាពការណ៍ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៃព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈល្អប្រសើរ បង្កបរិយាកាសអំណោយផលបន្តទៀតដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ សន្តិភាពបន្តគ្របដណ្ដប់លើផ្ទៃប្រទេស បូរណភាពទឹកដីនិងអធិបតេយ្យជាតិត្រូវបានការពារយ៉ាងគត់មត់។ តំបន់ព្រំដែនទាំងសងខាងមានសភាពស្ងប់ស្ងាត់ល្អទោះបីមានការរំលោភខ្លះៗចំពោះការសន្យារក្សាស្ថានភាពដដែលនៃព្រំដែនដែលមិនទាន់ឯកភាពគ្នា តែរាជរដ្ឋាភិបាលបានរួសរាន់ពិគ្រោះដោះស្រាយដោយសន្តិវិធី ទទួលបានលទ្ធផលជាវិជ្ជមាន ពុំមានការប្រឈមដោយអាវុធឡើយ។

**សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ**

២.១៦- សភាពការណ៍សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ត្រូវបានធានាការពារយ៉ាងគត់មត់ បង្កើតនូវបរិយាកាសសន្តិសុខល្អប្រសើរដែលជាបុព្វបទបម្រើដល់ការវិនិយោគ ការធ្វើធុរកិច្ចទេសចរណ៍ និងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។ អំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ត្រូវបានបង្ការ ទប់ស្កាត់ ព្រមទាំងបញ្ចៀសបាននូវការប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំងនឹងប្រទេសជិតខាង។ តំបន់ព្រំដែនរក្សាបាននូវសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការល្អ និងការអភិវឌ្ឍ។ ព្រឹត្តិការណ៍ជាតិ អន្តរជាតិប្រព្រឹត្តទៅប្រកបដោយជោគជ័យក្រោមកិច្ចការពារសុវត្ថិភាពយ៉ាងហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់។ សកម្មភាពបាតុកម្ម កូដកម្មត្រូវបានរៀបចំសណ្ដាប់ធ្នាប់ឲ្យមានរបៀបរៀបរយ និងបានបង្ការ ទប់ស្កាត់ មិនឲ្យកើតជាអំពើហិង្សា ការដង្ហែក្បួនបង្កចលាចលដល់សង្គម។

២.១៧- **ក្រសួងមហាផ្ទៃ** បានអនុវត្តកិច្ចការបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទប្រកបដោយជោគជ័យក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាជនពិសេសតាមរយៈការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** និងពង្រឹងការបណ្តុះបណ្តាលមន្ត្រីនគរបាលក្រោមប្រធានបទ **"នគរបាល និងសហគមន៍"** ក្នុងគោលបំណងផ្លាស់ប្តូរឥរិយាបទមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលក្នុងការផ្តល់សេវាសន្តិសុខសេវាតម្រូវការនានាប្រកបដោយប្រសិទ្ធភាព មានភាពរាក់ទាក់ និងភាពស្និទ្ធស្នាល ធ្វើប្រជាពលរដ្ឋមានជំនឿជឿជាក់ និងស្ម័គ្រចិត្តចូលរួមជាមួយនគរបាលក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៅមូលដ្ឋានផងដែរ។

២.១៨- ក្រសួងមហាផ្ទៃ បានធ្វើការកែទម្រង់ការងារគ្រប់គ្រងពន្ធនាគារ ធានាបានសន្តិសុខ សុវត្ថិ-ភាព សុខភាព និងមនុស្សធម៌ ដោយផ្តោតលើការអប់រំកែប្រែ ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈនិងមុខរបរ ស្របតាមគោលការណ៍អន្តរជាតិ និងវិធានសហប្រជាជាតិ។ បានរៀបចំជួសជុលកែលម្អ ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារចាស់ៗឲ្យស្របតាមបទដ្ឋានស្តង់ដាថ្មី ។

២.១៩- ការងារសុខភាពពន្ធនាគារទាំងផ្នែកបច្ចេកទេស ឱសថ សម្ភារបរិក្ខារពេទ្យ និងការពិនិត្យព្យាបាល ទទួលបានកិច្ចសហការ ឧបត្ថម្ភ គាំទ្រ និងកិច្ចអន្តរាគមន៍ពីក្រសួងសុខាភិបាលនិងផ្នែកពាក់ព័ន្ធ។ ប៉ុស្តិ៍សុខភាពពន្ធនាគារ ត្រូវបានទទួលស្គាល់និងដាក់ឲ្យស្ថិតនៅក្រោមការគ្រប់ដណ្តប់របស់ក្រសួងសុខាភិបាល។

### បញ្ហាប្រឈម

២.២០- ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានខាងលើក៏ក្រសួងនៅប្រឈមនឹងបញ្ហាមួយចំនួន៖

- ការងារគ្រប់គ្រងអត្តសញ្ញាណកម្មតាមរបៀបមជ្ឈការ (ដូចជាអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ) ដោយដៃមិនប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលបង្កឲ្យមានការលំបាកក្នុងការគ្រប់គ្រង និងធ្វើឲ្យទិន្នន័យមិនដូចគ្នាសម្រាប់ប្រជាពលរដ្ឋម្នាក់ៗ
- ឧក្រិដ្ឋឆ្លងដែនដែលមាននិន្នាការរីករាលដាលស្មុគស្មាញ និងការក្លាយជាវិញ្ញាសារប្រឈមរួមរបស់ពិភពលោក និងតំបន់ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទទួលរងឥទ្ធិពលអវិជ្ជមានផងដែរ។ ទន្ទឹមនោះនៅតាមតំបន់ព្រំដែន អាចប្រឈមនឹងបញ្ហាមួយចំនួនដែលកើតឡើងដោយភាពមិនច្បាស់លាស់នៃព្រំដែនដែលមិនទាន់ឯកភាពគ្នា។
- សណ្តាប់ធ្នាប់សាធារណៈ ក៏ជាបញ្ហាស្មុគស្មាញថ្មីដែលត្រូវយកចិត្តទុកដាក់ ស្របពេលដែលប្រទេសជាតិកំពុងមានការរីកចម្រើន។
- នយោបាយបើកចំហជើងមេឃដើម្បីទាក់ទាញទេសចរ ពាណិជ្ជករ និងវិនិយោគ ក៏មានលាយឡំនូវសមាសភាពជនទុច្ចរិត ជនរត់គេចពីសំណាញ់ច្បាប់នៅក្រៅប្រទេស និងជនសម្លឹងរកការងារធ្វើជ្រៀតចូលមកក្នុងប្រទេស បង្កសកម្មភាពស្មុគស្មាញប៉ះពាល់ដល់

សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងការស្នាក់នៅខុសច្បាប់ ឬហួសរយៈពេលកំណត់ផងដែរ។

- លក្ខណៈភូមិសាស្ត្រព្រំដែនគោក នៃព្រះរាជាណាចក្រកម្ពុជាលាតសន្ធឹងវែងឆ្ងាយប្រកបដោយព្រៃភ្នំ ដងអូរដែលធ្វើឲ្យសមត្ថកិច្ចមានការលំបាកក្នុងការបង្ការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ទាំងការជ្រៀតចូលរបស់ជនបរទេស និងការលបលួចចាកចេញរបស់ពលរដ្ឋខ្មែរទៅកាន់ប្រទេសជិតខាង។
- វិបត្តិនៃបញ្ហាជនភៀសខ្លួនអន្តរជាតិដែលកំពុងកើតឡើងគួបផ្សំនឹងស្ថានភាពរីកចម្រើនរបស់ប្រទេសកម្ពុជា អាចនឹងធ្វើឲ្យមានវត្តមានជនសុំសិទ្ធិជ្រកកោន និងការសុំឋានៈជាជនភៀសខ្លួនមានការកើនឡើង ដែលតម្រូវឲ្យមានការគិតគូរប្រកបដោយការទទួលខុសត្រូវបំផុត។

## ការងារគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

២.២១- នៅឆ្នាំ២០១៨ សមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃមានចំនួនសរុប៥ ២៣៤ ក្នុងនោះ សមាគមមានចំនួន២ ១១៧ និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួន៣ ១១៧។ នៅក្នុងឆ្នាំ២០១៧ ក្រសួងមហាផ្ទៃ បានចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន២៥៨ ក្នុងនោះសមាគមមានចំនួន១២៨ និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួន១៣០ និងបានចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចចំនួន០៨ និងលុបឈ្មោះចេញពីបញ្ជីចំនួន២០ ក្នុងនោះមាន សមាគមចំនួន០៦ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៤។

២.២២- គិតមកចុងឆ្នាំ២០១៧ គណបក្សនយោបាយមានចំនួនសរុប៣៦គណបក្ស ក្នុងនោះគណបក្សបានបង្កើតតែមិនទាន់បានសុំចុះបញ្ជីមានចំនួន០១គណបក្ស។ នៅក្នុងឆ្នាំ២០១៧ នេះ ក្រសួងបានសម្រេចអនុញ្ញាតឲ្យបង្កើតគណបក្សនយោបាយចំនួន០៣គណបក្ស ចុះក្នុងបញ្ជីគណបក្សនយោបាយចំនួន០៤គណបក្ស និងលុបឈ្មោះគណបក្សនយោបាយចេញពីបញ្ជីគណ-បក្សចំនួន៣៦គណបក្ស។

## ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន

២.២៣- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង ស្ថាប័នចំនួន២៧ ជាសមាជិក និងមានអគ្គលេខាធិការដ្ឋានមួយធ្វើជាសេនាធិការ បានទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយក្នុងការត្រួតពិនិត្យគ្រឿងញៀន។ ទន្ទឹមនោះដែរ ខ្លឹមសារនៃអនុសញ្ញានានារបស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន បានភ្ជាប់ទៅនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលត្រូវបានអនុម័ត និងប្រកាសឲ្យប្រើកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១២។

## ការកាត់បន្ថយតម្រូវការគ្រឿងញៀន៖

២.២៤- ***អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*** បានបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជាមួយដៃគូអភិវឌ្ឍផ្សេងទៀត ហើយបានខិតខំប្រឹងប្រែងធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងការកាត់បន្ថយតម្រូវការគ្រឿងញៀន ដែលក្នុងនោះផ្តោតទៅលើការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ បដិសេធគ្រឿងញៀន ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន។ល។

## ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន៖

២.២៥- *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បានសម្របសម្រួល និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពអនុវត្តច្បាប់នានាដើម្បីចាត់វិធានការបង្ក្រាបបទល្មើសគ្រឿងញៀនឲ្យបានទាន់ពេលវេលាដែលក្នុងនោះ មានទាំងក្នុងករណីប៉ុនប៉ង និងករណីដាំដុះ ផលិត ដឹកជញ្ជូន ចរាចរឆ្លងកាត់ ជួញដូរគ្រឿងញៀន ព្រមទាំងករណីបង្វែរសារធាតុគីមីផ្សំសម្រាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

## ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម៖

២.២៦- *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បានខិតខំប្រឹងប្រែងធ្វើឲ្យសម្រេចបាននូវកិច្ចការមួយចំនួនគួរជាទីមោទនៈ ដូចខាងក្រោម ៖

- រៀបចំបង្កើតសៀវភៅគោលការណ៍ណែនាំស្តីពីការបន្សាប និងព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមបណ្តារាជធានី ខេត្ត។
- ដាក់ឲ្យដំណើរការមណ្ឌលសុខុមាលភាពសង្គមរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបានសម្រេចផ្តល់នូវរបបជីវភាពជូនដល់ជនរងគ្រោះដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នសម្រាប់ការអប់រំនិងព្យាបាលអ្នកញៀនគ្រឿងញៀន និងនៅក្នុងមណ្ឌលស្តារនីតិសម្បទា និងបានជំរុញកម្មវិធីបន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀននិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមនិយាមវេជ្ជសាស្ត្រនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និងមណ្ឌលឯកជន ។
- រៀបចំឲ្យមានជាផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ ដោយបានកំណត់នូវក្រុមគោលដៅ និងបែងចែកការទទួលខុសត្រូវច្បាស់លាស់ដល់ក្រសួង ស្ថាប័នអង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ដើម្បីធានាថាគ្រប់ក្រុមគោលដៅជាពិសេសក្រុមគោលដៅប្រឈមនានាបានទទួលសារ ឬ ការផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន។

- រៀបចំគោលការណ៍ណែនាំ ស្តីពីការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំងនៅកម្ពុជា ដើម្បីជួយទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន និងរៀបចំនិយាមប្រតិបត្តិដើម្បីដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។
- ដាក់ឲ្យអនុវត្តនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ស្របតាមសេចក្តីសម្រេចស្តីពីការងារពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

២.២៧- *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* បានបន្តពង្រឹង និងពង្រីកឥតឈប់ឈរនូវកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិតាមច្រើនរូបភាពដែលក្នុងនោះ រួមមាន៖

- ចូលរួម និងសហការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយនឹងប្រទេស ថៃ ឡាវ និងវៀតណាម។
- បង្កើតយន្តការអចិន្ត្រៃយ៍សម្រាប់ផ្លាស់ប្តូរព័ត៌មាននៅថ្នាក់មូលដ្ឋាន តាមការិយាល័យទំនាក់ទំនងព្រំដែន ដែលមាននៅតាមច្រកទ្វារព្រំដែនអន្តរជាតិ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសនានាក្នុងតំបន់ តាមរយៈយន្តការរបស់អាស៊ាន និងប្រទេសនានាក្រៅតំបន់អាស៊ាន និងនៅលើសកលលោក។
- ទទួលនូវការគាំទ្រផ្នែកបច្ចេកទេសយ៉ាងច្រើនពីអង្គការដៃគូ និងប្រទេសផ្តល់ជំនួយនានា ពិសេស ការគាំទ្រផ្នែកបច្ចេកទេសលើការងារពង្រឹងស្ថាប័ន និងការបណ្តុះបណ្តាលធនធានមនុស្ស។ល។

## ធម្មការនិងសាសនា

២.២៨- ***ក្រសួងធម្មការ និងសាសនា*** ដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយ “**លើកកម្ពស់ សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា**” ស្របតាមកំណែទម្រង់នានា របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥ ដើម្បីជំរុញ កំណើនសេដ្ឋកិច្ច បង្កើតការងារជានាបានសមធម៌ និងប្រសិទ្ធភាព ឲ្យស្របតាមនិន្នាការរីកចម្រើនក្នុងតំបន់ និងសាកលលោក។

២.២៩- ក្នុងរយៈពេល០៥ឆ្នាំកន្លងមក ក្រសួងបានអនុវត្តគោលនយោបាយរបស់ខ្លួនដោយសម្រេចបាននូវសមិទ្ធផលធំៗ គួរឲ្យកត់សម្គាល់ដូចជា៖

### ១. វិស័យពុទ្ធិកសិក្សា

ក្រសួងធម្មការ និងសាសនា បាននិងកំពុងដំណើរការយ៉ាងរលូន ក្នុងទិសដៅផ្តល់សេវាអប់រំប្រកបដោយសមធម៌ ការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាអប់រំលើវិស័យពុទ្ធិកសិក្សា ដោយបានបណ្តុះបណ្តាលធនធានទាំងព្រះសង្ឃ និងគ្រហស្ថ ពីធម្មវិន័យ រហូតដល់ពុទ្ធិកឧត្តមសិក្សា និងពុទ្ធិកក្រោយឧត្តមសិក្សា។

## តារាងទី ២.៣ សូចនាករសំខាន់ៗក្នុងវិស័យធម្មវិន័យ

| សូចនាករ | | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| ចំនួនសាលា | | ៥២៣ | ៥៨៥ | ៥២០ | ៥៤៣ | ៤៩១ |
| ចំនួនសមណសិស្ស | | ៨ ២២៩ | ៩ ៩៨៩ | ១០ ៨៦៩ | ១១ ០៩៣ | ៩ ៨៥០ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ១៦ | ៣៨ | ៣៨ | ៤៧ | ៤១ |
| | កិច្ចសន្យា | ៤៣៣ | ៥៨០ | ៤០៧ | ៣៩០ | ៨០ |
| | ជួល | ១៤ | ១៣៩ | ២១៧ | ៣៤៥ | ៥៣ |

*ប្រភព*: ក្រសួងធម្មការនិងសាសនា

## តារាងទី ២.៤ សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកបឋមសិក្សា

| សូចនាករ | | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| ចំនួនសាលា | | ៧៤៣ | ៧២២ | ៧៦៥ | ៧២៣ | ៧៩៦ |
| ចំនួនសមណសិស្ស | | ១៦ ២២៧ | ១៦ ៧៣៤ | ១៩ ៥១៦ | ២១ ០៧៦ | ២២ ៩៣០ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ២០៩ | ១៦១ | ១៦៩ | ១៦៩ | ១៦៥ |
| | កិច្ចសន្យា | ១ ១៧៩ | ១ ១៨៩ | ១ ១៦៩ | ១ ១៦៥ | ១ ២៧០ |
| | ជួល | ២៥៣ | ២០៩ | ៣៥៥ | ៥៣៧ | ៥៥៣ |

*ប្រភព*: ក្រសួងធម្មការនិងសាសនា

## តារាងទី ២.៥ សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកមធ្យមសិក្សាបឋមភូមិ

| សូចនាករ | | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| ចំនួនសាលា | | ៣៧ | ៣៨ | ៣៧ | ៤១ | ៤០ |
| ចំនួនសមណសិស្ស | | ៤ ៨១៩ | ៤ ៦៥៣ | ៥ ០៤៣ | ៥ ២៧១ | ៥ ៥៤១ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ១០៦ | ១៤០ | ១៤០ | ១៣២ | ១០៦ |
| | កិច្ចសន្យា | ៣៦ | ១១៩ | ១១៣ | ១៣៤ | ៣៦ |
| | ជួល | ៤៩៧ | ៤០៣ | ៤៦៨ | ៥១៣ | ៤៩៧ |

*ប្រភព*: ក្រសួងធម្មការនិងសាសនា

## តារាងទី ២.៦ សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

| សូចនាករ | | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| ចំនួនសាលា | | ១៥ | ១៤ | ១៤ | ១៤ | ១៤ |
| ចំនួនសមណសិស្ស | | ១ ៥២៦ | ១ ៥៩៦ | ១ ៦៤៤ | ១ ៨២១ | ១ ៥២៦ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ៣៤ | ៤៩ | ៤១ | ៣៣ | ៣៤ |
| | កិច្ចសន្យា | ៣៤ | ២១ | ១៨ | ២៧ | ៣៤ |
| | ជួល | ២៣៨ | ២១៨ | ២២៤ | ២៤០ | ២៣៨ |

*ប្រភព :* ក្រសួងធម្មការនិងសាសនា

## តារាងទី ២.៧ សូចនាករសំខាន់ៗក្នុងវិស័យពុទ្ធិកឧត្តមសិក្សា

| សូចនាករ | | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | ២០១៨-២០១៩ |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង |
| *១-ចំនួនពុទ្ធិកស.ស.ព.* | | ០១ | ០១ | ០១ | ០១ | ០១ |
| ចំនួនសមណនិស្សិត | | ៥២៤ | ៦១៨ | ២៧៤ | ៤៤៥ | ៤២០ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ២៤ | ៣១ | ៤៦ | ៤៨ | ៣៧ |
| | ជួល | ២០៦ | ៩៣ | ១៤៤ | ១៥៧ | ៧៦ |
| បញ្ចប់បរិញ្ញាបត្រ | | ២៣០ | ១៧០ | ១៦៩ | ១២៤ | ២៣០ |
| *២-ចំនួនពុទ្ធិកឆ.ក.ស.ព.ស.* | | ០១ | ០១ | ០១ | ០១ | ០១ |
| ចំនួនសមណនិស្សិត | | | ៣៦១ | ៥១០ | ៤១៩ | ៤០៣ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ០១ | ០១ | ០២ | ០១ | ០១ |
| | ជួល | ៥៣ | ៥៤ | ៥២ | ៥៥ | ៦១ |
| បានបញ្ចប់បរិញ្ញាបត្រ | | ១១៦ | ៩៦ | ៩២ | ៧២ | ២៣៥ |
| *៣-ចំនួនពុទ្ធិកប.ប.ស.ស.ព.* | | ០១ | ០១ | ០១ | ០១ | ០១ |
| ចំនួនសមណនិស្សិត | | ៣៥៦ | ២២៨ | ២០១ | ៣៣៨ | ២៦២ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ០៦ | ០៣ | ០៥ | ០៥ | ០៦ |
| | ជួល | ៥៣ | ៥២ | ៤៣ | ៣០ | ៤១ |
| បានបញ្ចប់បរិញ្ញាបត្រ | | ១២៦ | ៩០ | ៨៨ | ៣៦ | ៨៩ |
| *៤-ចំនួនពុទ្ធិករ.ស.ព.ព.* | | ០១ | ០១ | ០១ | ០១ | ០១ |
| ចំនួនសមណនិស្សិត | | ១ ១៧៦ | ៨០៦ | ៧៥៨ | ៨៩៧ | ៨៣០ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ០៦ | ៣១ | ០៨ | ០ | ០ |
| | ជួល | ១១០ | ៩៣ | ១២៦ | ៩១ | ៩១ |
| បានបញ្ចប់បរិញ្ញាបត្រ | | ៥០ | ១០០ | ១០០ | ១២០ | ២១០ |
| *៥-ចំនួនពុទ្ធិកស.ហ.ស.ព.* | | ០១ | ០១ | ០១ | ០១ | ០១ |
| ចំនួនសមណនិស្សិត | | ៣១៩ | ២១៧ | ២៤៩ | ៤៤៥ | ៦១៧ |
| ចំនួនគ្រូ | ក្របខ័ណ្ឌ | ៧ | ១០ | ១២ | ១៩ | ០៥ |
| | ជួល | ៣២ | ២៧ | ២០ | ២៣ | ៤៥ |
| បានបញ្ចប់បរិញ្ញាបត្រ | | ៤៥ | ៩០ | ១០០ | ១១១ | ៣០០ |
| *ក្រោយឧត្តមសិក្សា* | | ១១៤ | ៤៩៣ | ៤៣២ | ១៥៤ | ២៧២ |

*ប្រភព :* ក្រសួងធម្មការនិងសាសនា

## ២. ការគ្រប់គ្រងផ្សព្វផ្សាយព្រះពុទ្ធសាសនា និងរក្សាសុខដុមនីយកម្ម ខាងជំនឿសាសនា

ក្រសួងបាននឹងកំពុងរៀបចំការសម្តែងព្រះធម៌ទេសនាអប់រំដោយផ្ទាល់តាមរយៈការផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម កម្មវិធីទស្សនាទានព្រះពុទ្ធសាសនា បើកវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ និងបានចងក្រងសមាគមអាចារ្យខ្មែរប្រចាំរាជធានី ខេត្ត ។

២.៣០- ក្រៅពីនេះ ក្រសួង បានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានផលិតកម្រងឯកសារស្តីពីតួនាទីភារកិច្ចអាចារ្យក្នុងទម្រង់អាពាហ៍ពិពាហ៍ខ្មែរមួយចប់ ហើយបានចាក់ផ្សាយតាមវិទ្យុ ទូរទស្សន៍រដ្ឋ និងឯកជន បានចងក្រងបោះពុម្ពសៀវភៅស្តីពីតួនាទី ភារកិច្ចអាចារ្យក្នុងទម្រង់អាពាហ៍ពិពាហ៍ខ្មែរក្នុងពិធីបុណ្យផ្សេងៗចំនួនរាប់ម៉ឺនក្បាល។ លើសពីនេះទៀត ក្រសួងបានរៀបចំការងារស្រាវជ្រាវ ចងក្រង អភិរក្ស និងផ្សព្វផ្សាយឯកសារប្រពៃណីវប្បធម៌ និងសាសនា។

### បញ្ហាប្រឈម

២.៣១- ទន្ទឹមនឹងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រខាងលើ ក្រសួងក៏មានបញ្ហាប្រឈមមួយចំនួនដូចជា៖

- ខ្វះលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការគ្រប់គ្រងវត្តអារាម និងជួបការលំបាកដោយសារចំណេះដឹងរបស់ព្រះសង្ឃ អាចារ្យ គណៈកម្មការ អ្នកគ្រប់គ្រងវត្តនៅមានកម្រិត ការអប់រំបញ្ជ្រាបសីលធម៌ ចរិយាធម៌ព្រះពុទ្ធសាសនាតាមរយៈការសម្តែងព្រះធម៌ទេសនាឲ្យជ្រាបដល់ស្រទាប់មហាជនទូទៅគឺនៅជួបការលំបាក ដោយសារការហូរចូលនូវឥទ្ធិពលវប្បធម៌បរទេស ។

## ៣.២- បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និងចីរភាពបរិស្ថាន

### កំណើនប្រកបដោយចីរភាព

២.៣២- សេដ្ឋកិច្ចកម្ពុជា មានកំណើនជាមធ្យម៧% រវាងឆ្នាំ២០១៤ និងឆ្នាំ២០១៧ ដែលគាំទ្រដោយកំណើននៃវិស័យកាត់ដេរ វិស័យសំណង់ អចលនទ្រព្យ និងដឹកជញ្ជូននិងគមនាគមន៍ ព្រមទាំងឧស្សាហកម្មមិនមែនកាត់ដេរ ដូចជា វិស័យកសិកម្ម សណ្ឋាគារនិងភោជនីយដ្ឋាន និង វិស័យលក់ដុំ-រាយ។ ជាលទ្ធផល កម្ពុជាស្ថិតលើគន្លងក្នុងការសម្រេចបានចំណុចដៅកំណើនរយៈពេលមធ្យមដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។ ទោះបីវិស័យកសិកម្មមានកំណើនយឺតក្តី ដោយសារកត្តាអាកាសធាតុ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជារក្សាបានកំណើនល្អ ដែលប៉ះប៉ូវ

ដោយកំណើនខ្ពស់នៃវិស័យផ្សេងទៀត។ ទោះបីបរិស្ថានខាងក្រៅអាចជះឥទ្ធិពលមួយចំនួនដល់កំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេសការនាំចេញ វិស័យទេសចរណ៍ វិនិយោគផ្ទាល់ពីបរទេស និងវិស័យពាក់ព័ន្ធចំណូលប្រជាពលរដ្ឋ ប៉ុន្តែកំណើនសេដ្ឋកិច្ចកម្ពុជាបានបន្តភាពរឹងមាំ ដោយសារការត្រៀមខ្លួនល្អ តាមរយៈការដាក់ចេញវិធានការចាំបាច់បានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ ទន្ទឹមនេះ អតិផរណាប្រចាំឆ្នាំ ត្រូវបានគ្រប់គ្រងក្នុងអត្រាទាបជាង ៣,០% ឬចំណុចដៅ (៣,៥%)ក្នុង **ផ.យ.អ.ជ. ២០១៤-២០១៨** ទោះបីកម្ពុជាបានទទួលផលប៉ះពាល់ពីតម្លៃប្រេងអន្តរជាតិ និង តម្លៃម្ហូបអាហារនៅក្នុងស្រុកក្តី។

## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

២.៣៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានវឌ្ឍនភាពល្អក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គោលបំណងនៃកម្មវិធីកំណែទម្រង់នេះគឺកែលម្អប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាអនុលោមតាមស្តង់ដាអន្តរជាតិ។ សមាសធាតុសំខាន់នៃកម្មវិធីកំណែទម្រង់នេះរួមមានការពង្រឹងជំនឿទុកចិត្តថវិកា ការពង្រឹងការគ្រប់គ្រងនិងការប្រមូលចំណូល ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុតាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ និងការពង្រីកការអនុវត្តថវិកាកម្មវិធីនិងការកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា។

### សមិទ្ធផល

### ១. ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាចលករ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ

- រាជរដ្ឋាភិបាលសម្រេចបានសូចនាករសំខាន់ៗនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច រួមមានកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% រក្សាបាននូវអតិផរណាទាបក្នុងរង្វង់៣% អត្រាប្តូរប្រាក់ក្នុងរង្វង់៤ ០០០រៀល/ដុល្លារអាមេរិក និងឱនភាពថវិកានៅក្នុងកម្រិតទាប។
- ចំណូលមានការកើនឡើងក្នុងចន្លោះ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ហើយចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ១៥,០៦% នៃផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់ ១៩,៦៤% ក្នុងឆ្នាំ២០១៧ ពោលគឺកើនឡើងជិតពីរដង ឬប្រមាណជា៤,៥៨ ពិន្ទុភាគរយនៃផ.ស.ស.។ ជាមួយគ្នានេះ ការអនុវត្តចំណូលកាន់តែខិតជិតគោលដៅ +/-៥% នៃឥណទានកំណត់ក្នុងច្បាប់។
- ថវិកាចំណាយបានកើនឡើងប្រមាណ១,៨ដង ចាប់ពីឆ្នាំ២០១៣-២០១៧ ហើយការវិភាជត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ។ ជាមួយគ្នានេះ ការអនុវត្តចំណាយ គឺកាន់តែខិតជិតគោលដៅ +/-៥% នៃឥណទានកំណត់ក្នុងច្បាប់។

- អតិរេកថវិកាចរន្តសម្រេចបានក្នុងចន្លោះ៣,៦%នៃផ.ស.ស. ក្នុង១ឆ្នាំ និងបានកាត់បន្ថយឱនភាពថវិកាសរុប ពី-៧,០១% ក្នុងឆ្នាំ ២០១៣ នៃផ.ស.ស. មកត្រឹម -៥,៨៤% នៃផ.ស.ស.ក្នុងឆ្នាំ ២០១៨។
- ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធភាព ដោយគ្មានបំណុលកកស្ទះ ក្នុងនោះ បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ និងបុគ្គលិករដ្ឋ ត្រូវផ្ទេរផ្ទាល់ចូលក្នុងគណនីធនាគារ នៅក្នុងសប្តាហ៍ទី៤នៃខែ។ បន្ថែមពីនេះ និវត្តជនក៏បានទទួលនូវការបង្កើនប្រាក់សោធន និងរបបតាវលិកផ្សេងទៀត ជាបន្តបន្ទាប់ផងដែរ។
- បំណុលសាធារណៈត្រូវបានគ្រប់គ្រងត្រឹមត្រូវ និងអនុវត្តខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះទាំង៤ចំណុច រួមមាន៖ ១.ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន ២.ត្រូវខ្ចីឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣.ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង ៤.ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។ ទន្ទឹមនេះ រាជរដ្ឋាភិបាលរក្សាបានកម្រិតអនុបាតបំណុលធៀបផ.ស.ស. ត្រឹម២០,៦%(មិនរួមបញ្ចូលបំណុលមរតក) និង២២,៨%(រួមបញ្ចូលបំណុលមរតក) តាមគោលដៅកំណត់ក្នុងឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុល ២០១៥-២០១៨(ទាបជាង៤០%)។

២.៣៤- បន្ថែមពីនេះ ការកើនឡើងនៃទំហំចំណូល បានផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលបង្កើនចំណាយយ៉ាងច្រើន ទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃសេវាសាធារណៈ ទាំងតាមរយៈចំណាយចរន្តថវិកាជាតិ និងទាំងតាមរយៈចំណាយវិនិយោគសាធារណៈ ដើម្បីធ្វើឲ្យការផ្តល់សេវាសាធារណៈមានភាពកាន់តែប្រសើរឡើង និងកាន់តែខិតជិតនឹងប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់។ លើមូលដ្ឋាននេះ ក្នុងរយៈពេល៥ ឆ្នាំចុងក្រោយ ចំណាយសរុបថវិការដ្ឋ ត្រូវបានកើនឡើងជិតពីរដង ក្នុងនោះ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាងបីដងចំណាយសរុបរបស់ក្រសួងសុខាភិបាល ត្រូវបានបង្កើនជិតពីរដងកន្លះ ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើនជិតបីដង ហើយចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្កើនជិតពីរដងកន្លះ។ មួយវិញទៀតសមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេសក្នុងចំណែកថវិកាជាតិបាន ថយចុះពីប្រមាណជិត៧០% នៅក្នុងឆ្នាំ១៩៩៥ មកនៅត្រឹមតែប្រមាណ២១,៤% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៧ ហើយនឹងបន្តថយចុះថែមទៀតនៅមិនដល់២០% នៅឆ្នាំ២០១៨។ ប្រការនេះគឺជាការសបញ្ជាក់ឲ្យឃើញថា កម្ពុជាកាន់តែមានឯករាជ្យភាពខាងថវិកាជាងមុន និងកាន់តែមានភាពជាម្ចាស់ជាងមុន។

## ២. បុរេលក្ខណៈសំខាន់ៗ ត្រូវបានកសាង និងពង្រឹងបន្ថែមដើម្បីធានានូវគណនេយ្យភាពហិរញ្ញវត្ថុ

- ប្លង់គណនេយ្យថ្មីសម្រាប់រដ្ឋាភិបាល និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានកែសម្រួលឲ្យស្របតាមស្តង់ដាអន្តរជាតិ និងដាក់ឲ្យអនុវត្ត។
- លុបបំបាត់មុខងារបេឡានៅរតនាគារទាំងស្រុង ដោយបង្វែរមកប្រើប្រាស់សេវារបស់ធនាគារជាតិនៃកម្ពុជា។
- ប្រព័ន្ធFMIS ដំណាក់កាលទី១ ត្រូវបានកសាងនិងដាក់ឲ្យអនុវត្តនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគាររាជធានី ខេត្ត អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិ និងបានបញ្ឈប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខ្មែរទាំងស្រុង និងចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធFMIS ពេញលេញ។
- មុខងារចំនួន៦ រួមមាន៖ ១.មុខងារវិភាជន៍ថវិកា ២.មុខងារគណនីត្រូវសង ៣.មុខងារគណនីត្រូវទារ ៤.មុខងារគ្រប់គ្រងសាច់ប្រាក់ ៥.មុខងារទិញ និង ៦.មុខងារសៀវភៅធំនៃប្រព័ន្ធFMIS ត្រូវបានដាក់ឲ្យអនុវត្ត។ បន្ថែមពីនេះ ចំណាត់ថ្នាក់ទាំង៧ នៃមាតិកាថវិកាត្រូវបានកែសម្រួល រៀបចំថ្មី និងដាក់ឲ្យអនុវត្ត។
- អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបាននៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងមុខងារសវនកម្មផ្ទៃក្នុង ត្រូវបានពង្រឹងជាលំដាប់។
- តម្លាភាពថវិកា ត្រូវបានបង្កើនជាលំដាប់តាមរយៈការផ្សព្វផ្សាយនូវឯកសារសំខាន់ៗ រួមមាន៖ ១.សង្ខេបសំណើថវិកា ដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រី ២.ថវិកាសង្ខេបដែលងាយស្រួលយល់ក្រោយច្បាប់ថវិកាត្រូវបានអនុម័ត ៣.របាយការណ៍លទ្ធផលនៃការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ៤.ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ៥.របាយការណ៍សវនកម្ម លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ៦.របាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ៧.ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង ៨.ផែនការលទ្ធកម្ម,សេចក្តីជូនដំណឹងការដេញថ្លៃ ការប្រគល់កិច្ចសន្យាលទ្ធកម្មនិងរបាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតនៅក្រោមសិទ្ធិសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាប្រចាំឆ្នាំ២០១៦ លើកាលបរិច្ឆេទឆ្នាំ២០១៥។ តាមរយៈការផ្តល់ព័ត៌មានស្តីពីថវិកានៅគ្រប់វដ្តនៃថវិកាជាសាធារណៈ គឺដើម្បីពង្រឹងប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពថវិកា ផងដែរ។
- ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រងថវិកា លទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងមូលបត្ររដ្ឋ ត្រូវបានប្រកាសឲ្យប្រើនិងដាក់ឲ្យអនុវត្ត។

២.៣៥- របហូតមកដល់ពេលនេះ ប្រព័ន្ធFMIS ត្រូវបានបញ្ចប់អនុវត្តសាកល្បងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ ហើយកំពុងតែពង្រីកការអនុវត្តសាកល្បងទៅដល់ក្រសួង ស្ថាប័នជាបន្តបន្ទាប់។ ក្នុងពេលអនាគត ប្រព័ន្ធនេះនឹងក្លាយជាយន្តការស្នូល ក្នុងការពង្រឹងប្រសិទ្ធភាពថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុនៅគ្រប់កម្រិត ទាំងកម្រិតនៃការត្រួតពិនិត្យហិរញ្ញវត្ថុ កម្រិតនៃការគ្រប់គ្រងសាច់ប្រាក់ និងកម្រិតនៃការអនុវត្តកម្មវិធី។

## ៣. ក្របខ័ណ្ឌថវិកាកម្មវិធីត្រូវបានរៀបចំ ពង្រឹង និងពង្រីកជាឧបករណ៍ផ្សារភ្ជាប់ថវិកានឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល

- ថវិកាកម្មវិធីសាកល្បងពេញលេញត្រូវបានអនុវត្តនិងពង្រីកទៅគ្រប់ក្រសួង ស្ថាប័ន ក្នុងនោះ ក្រសួង ស្ថាប័នចំនួន១០ អនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ២០១៥ ក្រសួង ស្ថាប័នចំនួន១៥ បន្ថែមសម្រាប់ឆ្នាំ២០១៦ និងក្រសួង ស្ថាប័នចំនួន១១ បន្ថែមសម្រាប់ឆ្នាំ២០១៧ និងក្រសួង ស្ថាប័នចំនួន៣ បន្ថែមសម្រាប់ឆ្នាំ២០១៨ ដែលសរុបចំនួន៣៩ ហើយគ្រប់ក្រសួង ស្ថាប័ន បានរៀបចំរចនាសម្ព័ន្ធគោលនយោបាយ និងផែនការយុទ្ធសាស្ត្រថវិកាស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ រីឯគ្រប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឲ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧-២០២០។
- ក្របខ័ណ្ឌគតិយុត្តនៃការរៀបចំនិងអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំនិងដាក់ឲ្យអនុវត្ត។
- យន្តការអង្គភាពថវិកា បានជំរុញឲ្យមានតម្លាភាព គណនេយ្យភាព ការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវនិងការចូលរួមខ្ពស់ពីអង្គភាពជំនាញ ក្នុងដំណើរការនៃវដ្តថវិកា។
- តាមរយៈការអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង ស្ថាប័ន ចាប់ពីឆ្នាំ២០១៨ ត ទៅនឹងជួយដល់ក្រសួង ស្ថាប័នធ្វើការរៀបចំថវិកាកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការរៀបចំថវិកា និងការចរចាថវិកា ត្រូវបានពង្រឹង និងកែលម្អមួយកម្រិតខ្ពស់ថែមទៀត តាមរយៈការឆ្លុះបញ្ចាំងបានកាន់តែល្អប្រសើរឡើងនូវអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត។

## ៤. សមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង

- កំណើនប្រសិទ្ធភាពនៃការអនុវត្តថវិកា៖ ការអនុវត្តខិតជិតគោលដៅនៃឥណទានច្បាប់។
- ការបណ្តុះបណ្តាលត្រូវបានរៀបចំជាបន្តបន្ទាប់ និងមានលក្ខណៈប្រមូលផ្តុំ(ជំនាញថវិកា កិច្ចបញ្ជិការគណនេយ្យ រជ្ជទេយ្យ លទ្ធកម្ម ។ល។)។
- គុណភាពនៃផែនការយុទ្ធសាស្ត្រថវិកាកើនឡើង និងសំណើគម្រោងថវិកាប្រចាំឆ្នាំ រៀបចំកាន់តែមានគុណភាព។

២.៣៦- តាមរយៈលទ្ធផលនៃការវាយតម្លៃឆ្នាំ២០១៧ ដោយប្រើប្រាស់ទិន្នន័យនិងព័ត៌មានឆ្នាំ ២០១៤-២០១៦ ធៀបជាមួយនឹងលទ្ធផលនៃការវាយតម្លៃឆ្នាំ២០១៥ ដែលប្រើប្រាស់ទិន្នន័យឆ្នាំ ២០១១-២០១៣ ដោយប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាព ឆ្នាំ២០១១ បង្ហាញថាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាមានភាពប្រសើរឡើងលើការគ្រប់គ្រងចំណូល-ចំណាយ ការពង្រឹងរដ្ឋបាលប្រមូលចំណូល តម្លាភាពថវិកា និងលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងបៀវត្ស។

## បញ្ហាប្រឈម

២.៣៧- ទន្ទឹមនឹងសមិទ្ធផលសម្រេចបានខាងលើ ការអនុវត្តកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ តែងជួបឧបសគ្គ និងបញ្ហាប្រឈមនានា រួមមាន៖ បញ្ហាស្ថាប័ន បច្ចេកទេស និងធនធានហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាមោះមុត និងបានប្រកាន់យកអភិក្រម "**រៀនផងធ្វើផង**" ឬ "**ឆ្លងស្ទឹងស្ទាបថ្ម**" ដែលមកដល់ពេលនេះទទួលបានលទ្ធផលនិងបទពិសោធន៍ជាច្រើនគួរឲ្យកត់សម្គាល់ សម្រាប់ជាទុនបន្តដំណើរទៅមុខទៀត។ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានជួបប្រទះបញ្ហាសំខាន់រួមមាន៖

### ១. កត្តាស្ថាប័ន

- យន្តការសម្របសម្រួលរួម រវាងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយក្រសួង ស្ថាប័ន ជាពិសេសក្នុងការអនុវត្តថវិកានៅពុំទាន់ប្រមូលផ្តុំ។
- ឆន្ទៈ ការយល់ដឹង និងការចូលរួមរបស់ក្រសួង ស្ថាប័ន កើនឡើងជាលំដាប់ ប៉ុន្តែនៅពុំទាន់គ្រប់គ្រាន់ ក្នុងការជំរុញការងារកែទម្រង់ឲ្យកាន់តែមានសន្ទុះ ជាពិសេស កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់។
- ពុំទាន់មានផែនការសកម្មភាពសម្រាប់ផ្សារភ្ជាប់ការងារកែទម្រង់ប្រទាក់ក្រឡាទាំង៣។

### ២. កត្តាបច្ចេកទេសនិងធនធានមនុស្ស

- ការរៀបចំផែនការសកម្មភាពលម្អិតរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន នៅពុំទាន់ឆ្លើយតបនឹងផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់។
- ការបណ្តុះបណ្តាលត្រូវបានរៀបចំជាច្រើនលើក ប៉ុន្តែភាគច្រើនជាការបញ្ជ្រាបការយល់ដឹងដោយនៅពុំទាន់បានរៀបចំរយៈពេលមធ្យម និងវែង ដែលសំដៅបង្កើនសមត្ថភាពជំនាញរបស់មន្ត្រី។

### ៣. កត្តាហិរញ្ញវត្ថុ

- ថវិការដ្ឋសម្រាប់គាំទ្រកម្មវិធីកែទម្រង់នៅមានកម្រិត ដោយនៅមានសេចក្តីត្រូវការគាំទ្រពីហិរញ្ញប្បទានដៃគូអភិវឌ្ឍ។

- ការរៀបចំការឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង ស្ថាប័ន នៅកំពុងរៀបចំវិធាន និងនីតិវិធីនៅឡើយ ដើម្បីអាចអនុវត្តក្នុងឆ្នាំ ២០១៨ នេះ។

## ចីរភាពបរិស្ថាន

២.៣៨- ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ រួមទាំងការប្រែប្រួលអាកាសធាតុកំពុងតែជាបញ្ហាសំខាន់ដែលទាក់ទងនឹងចីរភាព និងស្ថិរភាពនៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមរបស់កម្ពុជា។ បញ្ហាបរិស្ថានជាបញ្ហាអន្តរវិស័យនិងតម្រូវឲ្យមានការសម្របសម្រួលក្នុងរដ្ឋាភិបាលទាំងមូលទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយមានកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ។

២.៣៩- ***ក្រសួងបរិស្ថាន***មានតួនាទីដឹកនាំការងារដើម្បីសម្រេចបានចីរភាពបរិស្ថាន។ ក្រសួងសម្រេចបានវឌ្ឍនភាពល្អក្នុងផ្នែកជាច្រើនដូចជា៖ ១.ព័ត៌មាននិងចំណេះដឹងបរិស្ថាន ២.ការគ្រប់គ្រងតំបន់អភិរក្ស ៣.កិច្ចគាំពារបរិស្ថាន និង ៤.ការអភិវឌ្ឍដោយចីរភាព/ការប្រែប្រួលអាកាសធាតុ។

២.៤០- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គោលដៅទី៧ បានបង្ហាញថាកិច្ចការពារព្រៃឈើ ធនធានទឹក និងបរិស្ថានគឺជាស្នូលនៃការអភិវឌ្ឍដោយចីរភាព។ ប៉ុន្តែ កិច្ចប្រឹងប្រែងដោយចីរភាពរបស់រាជរដ្ឋាភិបាលមិនទាន់សម្រេចបាននៅឡើយទេ។ ឧទាហរណ៍ គម្របព្រៃឈើមានចំនួន ៦១,១៥%ក្នុងឆ្នាំ២០០២ ប៉ុន្តែបានធ្លាក់ចុះមក៤៩,៨%ក្នុងឆ្នាំ២០១៥ ដោយសារសកម្មភាពកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ ដែលស្ថិតនៅក្រោមចំណុចដៅ(៦០%) របស់ផ.យ.អ.ជ.។ ប្រសិនបើមិនមានការត្រួតពិនិត្យទេ និន្នាការនេះអាចបណ្តាលឲ្យមានឥទ្ធិពលអេកូឡូស៊ីអវិជ្ជមានទៅគុណភាពដីនិងទឹកព្រមទាំងការបាត់បង់ជីវៈចម្រុះ និង ត្រី។

២.៤១- រាជរដ្ឋាភិបាលកំពុងធ្វើការងារជាមួយសហគមន៍ ដើម្បីស្តារការបាត់បង់ផ្នែកបរិស្ថានឡើងវិញតាមរយៈការលើកកម្ពស់ការការពារនិងគ្រប់គ្រងធនធានតាមសហគមន៍ដោយចីរភាព។ ឧទាហរណ៍ រាជរដ្ឋាភិបាលបានបង្កើតសហគមន៍ព្រៃឈើចំនួន៤៩៩ ដែលគ្របដណ្តប់ផ្ទៃដីចំនួន ៥១៤លានហ.ត.។ ចំនួនសហគមន៍នេសាទបានកើនឡើងពី៤៤០ក្នុងឆ្នាំ២០០៥ទៅ៥១៦ក្នុងឆ្នាំ ២០១៥ ដែលគ្របដណ្តប់ផ្ទៃដីចំនួន៦៤៧ ០០០ហ.ត. ហើយបច្ចុប្បន្នមានតំបន់អភិរក្សនេសាទចំនួន៥៦១(សហគមន៍ចំនួន៤៦៧កន្លែង)។

២.៤២- ទឹកស្អាតនិងអនាម័យ គឺជាចំណុចដៅសំខាន់មួយផ្សេងទៀតក្នុងគោលដៅទី៧នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនមានចំនួន៨៨,០១%ក្នុងឆ្នាំ២០១៥ ដែលលើសចំណុចដៅ (>៨០%) ចំណែកការផ្គត់ផ្គង់ទឹកស្អាតជនបទសម្រេចបាន៥០%ដូចចំណុចដៅ។ អនាម័យនៅទីប្រជុំជនសម្រេចបាន៨៩%ក្នុងឆ្នាំ២០១៥លើសចំណុចដៅ(៧៤%)។

២.៤៣- ទោះបីការប្រើប្រាស់ធ្យូងសម្រាប់ចម្អិនត្រូវបានកាត់បន្ថយពី៨៤%ក្នុងឆ្នាំ២០០៥មក ៧៤,៨% ក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជានឹងមិនអាចសម្រេចបានចំណុចដៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងឆ្នាំ២០១៥ទេ។ ការចុះបញ្ជីដីបានកើនឡើងពី១៥%ក្នុងឆ្នាំ២០០០ ទៅ២៨% ក្នុងឆ្នាំ២០១១និងកើនដល់៥៨%ក្នុងឆ្នាំ២០១៥ លើសចំណុចដៅ( ៥៧%)។ រាជរដ្ឋាភិបាលកម្ពុជានឹងប្រឹងប្រែងបន្ថែមទៀតដើម្បីសម្រេចបានចំណុចដៅ( ៧០%)ក្នុងឆ្នាំ២០១៨។

### បញ្ហាប្រឈម

២.៤៤- បញ្ហាប្រឈមសំខាន់គឺការបន្តពង្រឹងសមត្ថភាពសម្រាប់កិច្ចសម្របសម្រួល និងសហប្រតិបត្តិការអន្តរវិស័យលើបញ្ហាមួយចំនួនដូចជា៖ ទឹក ដីធ្លី ព្រៃឈើ និងគុណភាពខ្យល់នៅ តំបន់ទីប្រជុំជននិងជនបទ។ រាជរដ្ឋាភិបាលនឹងត្រូវបន្តបង្កើនការដាំកូនឈើឡើងវិញ ដើម្បីស្តារព្រៃឈើឡើងវិញ។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ នគរូបនីយកម្ម និងកំណើនឧស្សាហូបនីយកម្មនឹងដាក់បន្ទុកបន្ថែមលើធនធានធម្មជាតិនិងអេកូឡូស៊ីរបស់កម្ពុជា។

## ៣.៣- ភាពជាដៃគូក្នុងការអភិវឌ្ឍ

២.៤៥- រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើន ក្នុងការពង្រឹងភាពជាដៃគូជាមួយគូអង្គអភិវឌ្ឍទាំងអស់តាមរយៈការដាក់ឲ្យអនុវត្ត និងកែលម្អជាបន្តបន្ទាប់នូវក្របខ័ណ្ឌគោលនយោបាយ យន្តការស្ថាប័ន និងលិខិតបទដ្ឋានចាំបាច់ជាច្រើន ពិសេសការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការកៀរគរធនធានសម្រាប់ការអភិវឌ្ឍជាតិ ហើយចាត់ទុកហិរញ្ញប្បទានសហប្រតិបត្តិការនៅបន្តតួនាទីសំខាន់សម្រាប់អភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជាក្នុងបរិការណ៍ដែលកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៦។

### ១. ការពង្រឹងប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ក្នុងរយៈពេល០៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពសំខាន់ៗក្នុងការពង្រឹងប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ ដែលរួមមាន ៖

## រូបភាពទី ២.១ និន្នាការហិរញ្ញប្បទានតាមវិស័យ និងដៃគូអភិវឌ្ឍសំខាន់ៗ

| ការបើកផ្ដល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ (ជាលានដុល្លារអាមេរិក) | ការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ (ជាលានដុល្លារអាមេរិក) |
|---|---|
| | |








*ប្រភព៖* ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០១៨

២.៤៦- ការបើកផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការបានរក្សាទំហំក្នុងរង្វង់១ ៤០០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤-២០១៨។ ទោះជាការបើកផ្ដល់មានការធ្លាក់ចុះបន្តិចក្នុងឆ្នាំ២០១៥ និង ២០១៦ បន្ទាប់ពីកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហិរញ្ញប្បទានសរុបបានកើនឡើងវិញក្នុងឆ្នាំ២០១៧ ហើយក៏រំពឹងថានឹងរក្សាកំណើនល្អក្នុងឆ្នាំ២០១៨ ដោយសារការបន្តគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច និងវិស័យហេដ្ឋារចនាសម្ព័ន្ធ។

## រូបភាពទី ២.២ ការតម្រឹមហិរញ្ញប្បទានជាមួយអាទិភាពនៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨




*ប្រភព៖* ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០១៨

២.៤៧- ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងរយៈពេល៥ឆ្នាំចុងក្រោយបានតម្រឹមយ៉ាងល្អប្រសើរជាមួយអាទិភាពជាតិ ពោលគឺមានទំហំសរុប៦ ៨៧៧លានដុល្លារអាមេរិក ស្មើនឹង៩១% នៃតម្រូវការធនធានសរុបរបស់ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨***។ ការបើកផ្តល់ក៏ត្រូវបានតម្រឹមផ្អែកតាមបរិការណ៍នៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ដោយក្នុងនោះ វិស័យកសិកម្ម ថាមពល និងដឹកជញ្ជូន ទទួលបានហិរញ្ញប្បទានខ្ពស់ជាងតម្រូវការព្រោះជាវិស័យជំរុញកំណើនសេដ្ឋកិច្ច។

**ហិរញ្ញប្បទានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥**

២.៤៨- ក្នុងឆ្នាំ២០១៥-២០១៨ ហិរញ្ញប្បទានសហប្រតិបត្តិការសរុប៦០៤លានដុល្លារអាមេរិក បានគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា និងជាមធ្យមមានទំហំ ១៥១លានដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់គាំទ្រវិស័យអាទិភាព និងវិធានការគន្លឹះនៃគោលនយោបាយនេះ។ ក្នុងនោះ ហិរញ្ញប្បទានទំហំ៤២១លានដុល្លារអាមេរិក បានគាំទ្រដល់ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី និងវិស័យដឹកជញ្ជូន។ ដៃគូអភិវឌ្ឍសំខាន់ៗដែលគាំទ្រ រួមមាន សាធារណរដ្ឋប្រជាមានិតចិន ធនាគារអភិវឌ្ឍន៍អាស៊ី ជប៉ុន បារាំង និងអូស្ត្រាលី។

**តារាងទី ២.៨ វិស័យនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**

*(ជាលានដុល្លារអាមេរិក)*

| វិស័យនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ ប៉ាន់ស្មាន |
|---|---|---|---|---|
| វិធានការគន្លឹះ៤ ជាក់ស្តែង | ៥៧,៦ | ១៦៨,៥ | ១០៣,០ | ៩២,១ |
| ការពង្រឹកសហគ្រាសធុនតូច និងមធ្យម | ៣,៩ | ១,៦ | ៣,៧ | ២,៧ |
| ការជំរុញវិនិយោគ | ០,៤ | ៣,៦ | ១,៧ | ៥,៨ |
| ការកែលម្អបរិយាកាសនិយតកម្ម | ៩,៧ | ៩,៦ | ២៥,៣ | ៧,៦ |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | ២៩,៥ | ២២,២ | ២៦,០ | ២៩,០ |
| **សរុប** | **១០១,១** | **២០៥,៦** | **១៥៩,៧** | **១៣៧,២** |

***ប្រភព៖*** ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០១៨

**ការសម្របសម្រួលយន្តការពិគ្រោះយោបល់ភាពជាដៃគូ**

២.៤៩- រាជរដ្ឋាភិបាល បានបន្តដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគី និងពហុភាគីជាមួយដៃគូអភិវឌ្ឍសំខាន់ៗ ដូចជា ជប៉ុន កូរ៉េ អូស្ត្រាលី អឺរ៉ុប និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីពិនិត្យ និងតម្រង់ទិសការគាំទ្ររបស់ដៃគូទាំងនោះឲ្យស្របតាមអាទិភាពអភិវឌ្ឍជាតិ។ លើសពីនេះ រាជរដ្ឋាភិបាលបានអនុវត្តយន្តការក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីជំរុញប្រសិទ្ធភាពនៃ

ភាពជាដៃគូនៅកម្រិតវិស័យ។ នាឆ្នាំ២០១៨ គ.ជ.នា បានរៀបចំការពិនិត្យអំពីសមិទ្ធកម្មនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពង្រឹងប្រសិទ្ធភាព និងអាទិភាពការងារតាមវិស័យ។

## ២. ការអនុវត្តចំណុចដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨

២.៥០- ដោយឈរលើគោលការណ៍ភាពជាម្ចាស់ដ៏មឹងម៉ាត់ និងមានទស្សនវិស័យច្បាស់លាស់ក្នុងការដឹកនាំកិច្ចសហប្រតិបត្តិការអភិវឌ្ឍជាមួយតួអង្គអភិវឌ្ឍទាំងអស់ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អប្រសើរ សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ពិសេសលើការប្រើប្រាស់ប្រព័ន្ធជាតិ។

### តារាងទី ២.៩ វឌ្ឍនភាពនៃការអនុវត្តចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

| សូចនាករ | ទិន្នន័យឆ្នាំ ២០១៤ | ទិន្នន័យឆ្នាំ ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|
| ១. វឌ្ឍនភាពនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ | ១ ២៤២លានដុល្លារអាមេរិក | ១ ៣៦៩ លានដុល្លារអាមេរិក |
| ២. ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | ២៥% | ៣២% |
| ៣. ការប្រើប្រាស់ប្រព័ន្ធជាតិ | ៣២% | ៦១% |

*ប្រភព៖* ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០១៨

### បញ្ហាប្រឈម

២.៥១- ក្នុងបរិការណ៍ដែលកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ទំហំ និងទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូបានប្រែប្រួលដោយសារដៃគូអភិវឌ្ឍមួយចំនួនបានកែសម្រួលយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការ និងបង្វែរការគាំទ្រពីការផ្តល់ហិរញ្ញប្បទានឥតសំណងទៅជាកម្ចីសម្បទានវិញ។ ទន្ទឹមនឹងនេះ ទាមទារឲ្យដៃគូអភិវឌ្ឍបន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធជាតិ និងសមត្ថភាពជាតិ ពិសេសបង្កើនការរួមបញ្ចូលហិរញ្ញប្បទានសហប្រតិបត្តិការជាមួយថវិកាជាតិ ក្នុងការរៀបចំនិងអនុវត្តកម្មវិធីសម្រាប់គាំទ្រគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវិស័យ ព្រមទាំងគាំទ្រកម្ពុជាចាកផុតពីប្រទេសមានការអភិវឌ្ឍតិចតួច។

## ៣.៤- សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅនៅក្នុងតំបន់និងពិភពលោក

២.៥២- កម្ពុជាបន្តអនុវត្តកិច្ចព្រមព្រៀងជាមួយអាស៊ាន ដែលត្រូវធ្វើសមាហរណកម្មចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងនាមជាដៃគូស្មើភាពគ្នា។ កម្ពុជាបានចូលរួមក្នុងធនាគារអភិវឌ្ឍន៍វិនិយោគហេដ្ឋារចនាសម្ព័ន្ធក្នុងពេលថ្មីៗនេះ។

២.៥៣- តាមរយៈនៃកិច្ចខិតខំនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផល ដូចមានខាងក្រោម៖

**ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ និងអធិបតេយ្យភាព**

- កម្ពុជាបានធ្វើការបកស្រាយ ពន្យល់ តាមរយៈជំនួបរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជាជាមួយ ឥស្សរជនបរទេស ស្ថាប័នអន្តរជាតិ ក៏ដូចជាសហគមន៍ខ្មែរនៅក្រៅប្រទេស ក៏ដូចជាចេញផ្សាយឯកសារផ្លូវការរបស់ក្រសួង អំពីវិធានការផ្លូវច្បាប់របស់កម្ពុជាក្នុងការការពារអធិបតេយ្យភាពរបស់ខ្លួន។
- កម្ពុជាបានធ្វើការចរចាជាមួយប្រទេសជិតខាង ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាព្រំដែនដែលនៅសេសសល់ដោយសន្តិវិធី ឈរលើមូលដ្ឋានការមិនកែប្រែខ្សែបន្ទាត់ព្រំដែនក្រោយទទួលឯករាជ្យពីអាណានិគម និងប្រែក្លាយតំបន់ព្រំដែនជា មួយប្រទេសជិតខាងទាំងអស់ឲ្យទៅជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ ក្នុងន័យនេះក្រសួងបានសម្រេចដោយជោគជ័យក្នុងការស្នើសុំខ្ចីផែនទីUTM ខ្នាត១/១០០ ០០០ ចំនួន១៨ផ្ទាំងពីអង្គការសហប្រជាជាតិ(អ.ស.ប.) ដែលជាផែនទីតម្កល់ទុកដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៦៤ មកធ្វើការផ្ទៀងផ្ទាត់បង្ហាញឲ្យឃើញភាពត្រឹមត្រូវ ស្របច្បាប់នៃផែនទីBonne ខ្នាត១/១០០ ០០០ ចំនួន២៦ផ្ទាំងបោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ច្រើនទស្សវត្សរ៍មកហើយ។
- កម្ពុជាបានខិតខំសហការជាមួយស្ថានតំណាងរបស់ខ្លួននៅក្រៅប្រទេស ក៏ដូចជាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរួមទាំងប្រទេសម្ចាស់ផ្ទះជួយសង្គ្រោះ អន្តរាគមន៍ និងធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋខ្មែរ ជាពិសេសពលករ ពលការីនីខ្មែរដែលរងគ្រោះនៅបរទេស។

**ការអនុវត្តនូវគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ តបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានា**

- សហការជាមួយក្រសួងមហាផ្ទៃកម្ពុជា និងសហរដ្ឋអាមេរិក ក្នុងការទទួលយកពលរដ្ឋខ្មែរដែលត្រូវបានបណ្ដេញចេញពីសហរដ្ឋអាមេរិក។
- ធ្វើការយ៉ាងសកម្មជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ដើម្បីសម្រេចបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយដែលផ្អែកលើវិធានការច្បាប់ ដោយយកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូល និងស្របតាម "**ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ**" ព្រមទាំងជំរុញលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូរបស់អាស៊ានជាមួយបណ្ដាប្រទេស និងអង្គការតំបន់ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អព្យាក្រឹត្យ ការមិនរើសអើង ការបើកចំហ តម្លាភាព បរិយាប័ន្ន ការសម្លឹងឆ្ពោះទៅខាងក្រៅ និងការដោះស្រាយជម្លោះដោយសន្តិវិធី។
- កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការរក្សាតួនាទីស្នូល និងមជ្ឈភាពរបស់អាស៊ានក្នុងគំនិតផ្ដួចផ្ដើមស្ដីពី និម្មាបនកម្មតំបន់ និងការដោះស្រាយបញ្ហាប្រឈមនានា ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ដើម្បីធានាថា ប្រជាជនអាស៊াននឹងបន្តរស់នៅក្នុងតំបន់តែមួយដែលប្រកបដោយការឯកភាពគ្នា សន្តិភាព ស្ថិរភាព និងភាពស្និតរមួតនឹងគ្នា។

- កម្ពុជាតែងតែផ្តល់គំនិតនិងរិះរកវិធីសាស្ត្រដោះស្រាយបញ្ហាតំបន់ និងសាកល ជាពិសេសភាពតានតឹងក្នុងបញ្ហាសមុទ្រចិនខាងត្បូង។ កម្ពុជាគាំទ្រ និងជំរុញដល់កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាននិងចិន ក្នុងការបង្កើនទំនុកចិត្តនិងភាពជឿជាក់គ្នាដោយឈរលើមូលដ្ឋាននៃទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ដើម្បីអនុវត្តឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិនៅសមុទ្រចិនខាងត្បូង និងដំណើរការតាក់តែងក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង។

**ការអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិ**

ក្នុងឆ្នាំ២០១៨ នេះ ក្រសួងបានសម្រេចបើកស្ថានឯកអគ្គរាជទូតកម្ពុជាថ្មីចំនួន៣ នៅតំបន់អឺរ៉ុបគឺៈ តួកគី សែប៊ី និងប៊ុលហ្គារី ក្នុងគោលដៅពង្រឹងចំណងមិត្តភាព បង្កើនទំនុកចិត្តផ្នែកនយោបាយ និងបើកទីផ្សារថ្មី។

- កម្ពុជាបាននិងកំពុងចរចាជាមួយសហភាពអឺរ៉ុប ក្នុងការទប់ស្កាត់នូវវិធានការនានា ដែលសហភាពអឺរ៉ុបគ្រោងនឹងដាក់មកលើកម្ពុជា ជាពិសេសការគម្រាមដកភាពអនុគ្រោះពន្ធលើកម្មវិធី "គ្រប់មុខទំនិញ លើកលែងតែសព្វាវុធ"។
- គិតត្រឹមឆ្នាំ២០១៨នេះ កម្ពុជាបានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការជាមួយប្រទេសសរុបចំនួន៣៤ ។
- កម្ពុជាបានបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសក្នុងតំបន់ និងសកលលោកដោយជំរុញការចូលទៅកាន់ទីផ្សារ និងមូលដ្ឋានផលិតកម្មធំជាងមុន និងការកសាងសមត្ថភាពនិងការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សព្រមទាំងការលើកកម្ពស់ការតភ្ជាប់ (ការតភ្ជាប់ផ្នែករូបវន្ត ការតភ្ជាប់ស្ថាប័ន និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន) រវាងកម្ពុជាទៅក្នុងតំបន់ទាំងនោះ ព្រមទាំងការទទួលបាននូវអត្ថប្រយោជន៍ពីគម្រោងកាត់បន្ថយគម្លាតអភិវឌ្ឍក្នុងតំបន់ ការតភ្ជាប់អាស៊ាន ឱកាសការងារកាន់តែច្រើននិងវិបុលភាពកាន់តែប្រសើរឡើង។
- កម្ពុជាបានចូលជាសមាជិកធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីក្នុងឆ្នាំ២០១៦។
- បានអនុវត្តកាតព្វកិច្ច និងចូលរួមគំនិតផ្តួចផ្តើមនានាក្នុងនាមជាសមាជិកដ៏សកម្មមួយរបស់អាស៊ាន ដែលត្រូវបន្តធ្វើសមាហរណកម្មស៊ីជម្រៅនិងពេញលេញ សំដៅសម្រេចទស្សនវិស័យសហគមន៍អាស៊ាន២០២៥។
- កម្ពុជាបានចុះអនុស្សារណៈនៃការយោគយល់ ជាមួយប្រធានក្រុមប្រឹក្សាភិបាលនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដើម្បីជំរុញការអភិវឌ្ឍនៃទំនាក់ទំនងរវាងកម្ពុជា និងប្រទេសជាសមាជិករបស់EEC កាលពីខែឧសភា ឆ្នាំ២០១៦ នៅទីក្រុងស៊ូជី ប្រទេសរុស្ស៊ី និងចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ ចូលជាដៃគូចរចាជាមួយអង្គការសហ

ប្រតិបត្តិការសៀងហៃ កាលពីខែកញ្ញា ឆ្នាំ២០១៥ ព្រមទាំងបានសម្រេចជាគោលការណ៍ស្នើសុំចូលជាអ្នកសង្កេតការណ៍ របស់អង្គការនេះនៅក្នុងឆ្នាំ២០១៧។

- ធ្វើជាប្រទេសម្ចាស់ផ្ទះនៃវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន កាលពីខែឧសភា ឆ្នាំ ២០១៧។

**ការចូលរួមកាន់តែសកម្មថែមទៀតដល់បុព្វហេតុ សន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក**

- កម្ពុជាបានប្រែក្លាយខ្លួនពីប្រទេស ដែលទទួលយកកងកម្លាំងបេសកកម្មថែរក្សាសន្តិភាពពី អ.ស.ប. ទៅជាប្រទេសដែលបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពទៅចូលរួមក្នុងបេសកកម្មរបស់ អ.ស.ប. វិញ។ ចាប់តាំងពីឆ្នាំ២០០៦ មកដល់ឆ្នាំ២០១៨ កម្ពុជាបានបញ្ជូនកងកម្លាំងចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប.នៅក្នុង០៨ប្រទេសរួមមាន ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិក កណ្តាល លីបង់ ស៊ីប ស៊ីរី និងម៉ាលី។
- ដល់ឆ្នាំ២០១៨ មានអង្គការអន្តរជាតិ ទីភ្នាក់ងាររអ.ស.ប និងអង្គការមិនមែនរដ្ឋាភិបាលបរទេសជាច្រើនតាំងនៅ និងធ្វើសកម្មភាពសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា ដែលក្នុងនោះ អង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សារណៈនៃការយោគយល់ជាមួយក្រសួង មានចំនួន៣៩៥ និងទីភ្នាក់ងាររអ.ស.ប. ចំនួន២៦ កំពុងប្រតិបត្តិការនៅកម្ពុជា។
- ក្នុងឆ្នាំ២០១៦-២០១៨នេះ កម្ពុជាបានជាប់ឆ្នោត/ជ្រើសតាំងជា៖ ១.ប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍតិចតួចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ពីខែកុម្ភៈ ឆ្នាំ ២០១៧ ដល់ខែកុម្ភៈ ឆ្នាំ២០១៨ ២.សមាជិកនៃក្រុមប្រឹក្សាភិបាលនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/មូលនិធិដើម្បីប្រជាជនរបស់អ.ស.ប. និងការិយាល័យរបស់អ.ស.ប. សម្រាប់គម្រោងសេវាកម្ម (២០១៨-២០២០) ៣.សមាជិកនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលនៃពិធីសារទីពីរឆ្នាំ១៩៩៩ របស់អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ សម្រាប់អាណត្តិឆ្នាំ២០១៧-២០២១ និងបានទទួលការគាំទ្រជាឯកច្ឆន្ទធ្វើជាប្រធានគណៈកម្មាធិការនេះពីរឆ្នាំជាប់គ្នាគឺ ២០១៧ និង ២០១៨ ៤.អនុប្រធានសម័យប្រជុំមហាសន្និបាតអ.ស.ប លើកទី៧៣ សម្រាប់ឆ្នាំ២០១៨-២០១៩ និង ៥.សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អ.ស.ប សម្រាប់អាណត្តិឆ្នាំ២០១៩។
- អង្គការយូណេស្កូបានសម្រេចដាក់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុករបស់កម្ពុជា ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ និងដាក់ល្ខោនខោលចូលជាបេតិកភណ្ឌមនុស្សជាតិ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចុះអនុស្សារណៈនៃការយោគយល់ជាមួយលោក Tigran Sargsy ប្រធានក្រុមប្រឹក្សាភិបាល

នៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដើម្បីជំរុញការអភិវឌ្ឍនៃទំនាក់ទំនងរវាងកម្ពុជានិងប្រទេសជាសមាជិករបស់EEC។

- ពង្រឹងនិងពង្រីកទំនាក់ទំនងទ្វេភាគីជាមួយប្រទេសជាមិត្ត អង្គការអន្តរជាតិនិងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីស្វែងរកជំនួយសម្រាប់អភិវឌ្ឍប្រទេសលើគ្រប់វិស័យ។

២.៥៤- ការដាក់ចេញគោលនយោបាយស្តីពីការលើកកម្ពស់ផលិតកម្មកសិកម្មនិងការនាំចេញស្រូវអង្ករនិងយុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិកម្ពុជា ២០១១-២០២០ បានបង្ហាញសញ្ញាច្បាស់លាស់ថាកម្ពុជាមានបំណងប្រកួតប្រជែងក្នុងទីផ្សារអង្ករ និង កៅស៊ូសាកល។

២.៥៥- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានបញ្ជាក់ថាកម្ពុជាមានបំណងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួននិងបង្កើនផលិតភាព ដើម្បីប្រកួតប្រជែងក្នុងទីផ្សារតំបន់និងសកលប្រកបដោយប្រសិទ្ធភាព។ វឌ្ឍនភាពជាច្រើនសម្រេចបានក្នុងការកែលម្អក្របខ័ណ្ឌគតិយុត្តដើម្បីពង្រឹងបរិស្ថានវិនិយោគនិងពាណិជ្ជកម្ម។

២.៥៦- កម្ពុជាកំពុងដើរតួនាទីសំខាន់ជាប្រជាពលរដ្ឋសាកល តាមរយៈការចូលរួមក្នុងការរក្សាសន្តិភាពនិងសកម្មភាពបោសសម្អាតគ្រាប់មីនអន្តរជាតិ។ គោលនយោបាយបើកចំហជើងមេឃរបស់កម្ពុជាដើរតួនាទីសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ភាគច្រើនមកពីប្រទេសក្នុងតំបន់។ ការផ្សព្វផ្សាយទេសចរណ៍របស់កម្ពុជាកំពុងកើនឡើងក្នុងកម្រិតសាកល។ ការសម្តែងរបស់អត្តពលិកអូឡាំពិករបស់កម្ពុជាក្នុងរីយ៉ូនិងផែនការរបស់កម្ពុជា ក្នុងការទទួលរៀបចំកីឡាស៊ីហ្គេម ២០២៣ បង្ហាញថាកីឡានិងអត្តពលិកគឺជាចំណុចចូលរួមផ្សេងទៀតសម្រាប់សមាហរណកម្មទៅក្នុងកិច្ចការតំបន់និងសាកល។

## បញ្ហាប្រឈម

២.៥៧- សមាហរណកម្មរបស់កម្ពុជាជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ានរួមទាំងទំនាក់ទំនងពាណិជ្ជកម្មសកលនឹងតម្រូវឲ្យមានសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលរវាងរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍផ្សេងទៀតក្នុងការពង្រឹងសមត្ថភាពនិងប្រព័ន្ធជាតិដើម្បីកែលម្អការផ្តល់សេវានិងពង្រឹងភាពប្រកួតប្រជែងពាណិជ្ជកម្មសេដ្ឋកិច្ច និងបន្តកសាងសមត្ថភាពសម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។ ភាពប្រកួតប្រជែងរបស់កម្ពុជាគឺតម្លៃពលកម្មទាប ដោយសារកម្លាំងពលកម្មអត់ជំនាញ។ ដើម្បីរក្សាបានភាពប្រកួតប្រជែងនេះ ត្រូវបង្កើនជំនាញដល់កម្លាំងពលកម្មដើម្បីពង្រឹងផលិតភាព។

២.៥៨- ការបំពុលបរិយាកាសនយោបាយទាំងក្នុងប្រទេសនិងនៅក្រៅប្រទេសគួបផ្សំនឹងនិន្នាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាក្រោមរូបភាព “សិទ្ធិមនុស្ស” និង “លទ្ធិប្រជាធិបតេយ្យ” របស់អង្គការចាត់តាំងនិងប្រទេសមួយចំនួនបានបង្កឡើងនូវបញ្ហាប្រឈមសម្រាប់

ប្រទេសកម្ពុជា។ បញ្ហាការកំណត់ខណ្ឌសីមាព្រំដែនជាមួយប្រទេសជិតខាងរួមមាន៖ កម្ពុជា-វៀតណាម កម្ពុជា-ថៃ និង កម្ពុជា-ឡាវ និង បញ្ហាពលករកម្ពុជាដែលធ្វើការនៅបរទេសទទួលរងការធ្វើបាប និង ធ្វើការហួសកម្លាំងដែលផ្ទុយនឹងគោលការណ៍របស់អង្គការពលកម្មអន្តរជាតិ ក៏ជាការប្រឈម។

## ៤- ការលើកស្ទួយវិស័យកសិកម្ម

២.៥៩- វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៣,៥%(គិតតាមថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៨។ ដោយឡែកវិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣៤,៤% និងវិស័យសេវាកម្មប្រមាណ៤២,១%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច(វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី៣០,៧% ដល់២៣,៥% ក្នុងចន្លោះឆ្នាំ២០១៤-២០១៨ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងសេវាកម្មផ្សេងទៀតមានការកើនឡើង។

២.៦០- នៅឆ្នាំ២០១៨នេះ អត្រានៃការចូលរួមចំណែករបស់អនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបនៃវិស័យកសិកម្ម រួមមាន៖ ផ្នែកដំណាំ ៥៨,១% ផ្នែកផលិតកម្មសត្វ ១១,១% ផ្នែកជលផល ២៤,១% និងផ្នែកព្រៃឈើ៦,៧%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។

២.៦១- ក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជា កម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺ៖ ១.ពលកម្មក្នុងវិស័យកសិកម្ម ២.ពលកម្មក្នុងវិស័យឧស្សាហកម្ម និង ៣.ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេតពលកម្មក្នុងវិស័យកសិកម្មបាននិងកំពុងធ្លាក់ចុះគួរឲ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០១០ មានចំនួន៥៤,២%នៃពលកម្មសរុប ហើយបន្តថយចុះមកត្រឹមតែ៤៨,៧%នៅឆ្នាំ២០១៣ និង៤៥,៣%នៅឆ្នាំ២០១៤។ ឆ្នាំ២០១៧ កម្លាំងពលកម្មមានចំនួនត្រឹមតែ៣៧%ប៉ុណ្ណោះ។ ចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។

២.៦២- សារសំខាន់របស់វិស័យកសិកម្ម ត្រូវបានស្តែងឲ្យឃើញតាមរយៈក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ដែលបានផ្តោតជាសំខាន់លើការជំរុញ និងលើកស្ទួយវិស័យកសិកម្មជាមួយនឹងរបត់ថ្មី ដើម្បីឈានឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលមានគោលដៅ

សំខាន់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឲ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។ ក្នុងន័យនេះ ការធ្វើឲ្យប្រាកដនូវរាល់គោលដៅក្នុងការងារអភិវឌ្ឍន៍វិស័យកសិកម្ម កម្ពុជាត្រូវចាប់ច្បាមនូវកាលានុវត្តភាពនេះឲ្យបាន ជាពិសេសត្រូវធ្វើឲ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងទីផ្សារក្នុងស្រុក និងការនាំចេញកសិផលទាំងក្នុងតំបន់និងពិភពលោក និងកាត់បន្ថយការនាំចូល។

២.៦៣- ក្រសួងក៏បានទទួលស្គាល់ផងដែរថា ប្រព័ន្ធកសិកម្មនៅកម្ពុជាភាគច្រើនជាកសិកម្មផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង ដែលតែងតែទទួលរងនូវផលប៉ះពាល់ពីបាតុភូតធម្មជាតិជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដោយសារការដាំដុះរបស់កសិករភាគច្រើននៅមានការពឹងពាក់នឹងទឹកភ្លៀង និងការសាងសង់ប្រព័ន្ធស្រោចស្រពពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ។ ទាំងអស់នេះ ជាមូលហេតុមួយដែលធ្វើឲ្យផលិតកម្មកសិកម្មមានការប្រែប្រួលជារៀងរាល់ឆ្នាំ។

២.៦៤- ក្នុងគោលបំណងធ្វើឲ្យសម្រេចបាននូវការធ្វើទំនើបកម្មកសិកម្ម ដែលអាចចូលរួមជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ និងសហគមន៍កសិកម្ម រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការប្រទាក់ក្រឡាចាំបាច់មួយចំនួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពទៅលើការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ទាក់ទងទៅនឹងខ្សែច្រវាក់ផលិតកម្មកសិកម្ម និងការបង្កើនឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារដូចជា ផ្លូវថ្នល់ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក ការចែកចាយថាមពលអគ្គិសនី ការផ្តល់សេវាបច្ចេកទេស និងកែលម្អធាតុចូលកសិកម្ម ការកែទម្រង់ការគ្រប់គ្រងដីធ្លី និងហិរញ្ញវត្ថុក្នុងការវិនិយោគ ការរៀបចំយន្តការនានាឆ្ពោះទៅដណ្តើមទីផ្សារ ការរៀបចំនិងអភិវឌ្ឍសហគមន៍កសិកម្ម និងពង្រឹងយន្តការសម្របសម្រួលស្ថាប័ន។

## ៤.១- លើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម

២.៦៥- នាពេលកន្លងទៅនេះ ក្រសួងបានប្រកាសដាក់ឲ្យប្រើប្រាស់នូវឯកសារ **“គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា”** ដើម្បីឲ្យកសិករនិងសហគមន៍កសិករទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។ បន្ថែមលើនេះក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី **"ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ"** បរិមាណអង្ករនាំចេញទៅកាន់ទីផ្សារអន្តរជាតិ បានកើនឡើងប្រមាណ៦៧%ក្នុងរយៈពេល៥ឆ្នាំ ចាប់ពី២០១៤ ដល់២០១៨និងអង្ករពូជស្រូវផ្កាម្លិះត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

២.៦៦- ការបង្វែរទិសពីការអភិវឌ្ឍតាមបែបទូលាយ ឬតាមបែបវិបុលកម្មទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬតាមបែបប្រពលវប្បកម្ម បានក្លាយជារបៀបវារៈអាទិភាពមួយដ៏សំខាន់។ ជាកត្តាសក្យានុម័ត ការពង្រីកនិងការពង្រឹងសេវាកម្មគាំទ្រដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើបទៅតាមអនុវិស័យអាស្រ័យទៅតាមសក្តានុពលនៃភូមិសាស្ត្រ ការ

បែងចែកពូជ ជី សម្ភារកសិកម្ម និងការផ្តល់ឥណទានជនបទ ត្រូវបានយកចិត្តទុកដាក់ និងជាអាទិភាពរបស់រាជរដ្ឋាភិបាលសំដៅលើកកម្ពស់ផលិតភាពកសិកម្ម ឆ្លើយតបទៅតាមតម្រូវការទីផ្សារ ទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារអន្តរជាតិ។

### ក-ផលិតកម្មដំណាំស្រូវ

២.៦៧- ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដីប្រមាណ៣,០៥លានហ.ត. នៅឆ្នាំ២០១៤ និងបានកើនដល់៣,៣៤លានហ.ត. នៅឆ្នាំ២០១៨ ក្នុងនោះស្រូវវស្សាមាន២,៧៤លានហ.ត. និងស្រូវរដូវប្រាំងមាន០,៥៩៦ លានហ.ត។ ផ្ទៃដីប្រមូលផលមានចំនួន៣,២៥លានហ.ត. ក្នុងនោះស្រូវវស្សាមាន២,៦៥លានហ.ត. និងស្រូវរដូវប្រាំងមានប្រមាណ០,៥៩លានហ.ត.។

២.៦៨- ទិន្នផលស្រូវគិតជាមធ្យមទាំងប្រាំងនិងវស្សាបានកើនពី៣,០៧៩តោន/ហ.ត. ពីឆ្នាំ២០១៤ ដល់៣,៣៥៣តោន/ហ.ត. នៅឆ្នាំ២០១៨ ក្នុងនោះទិន្នផលស្រូវវស្សាទទួលបានប្រមាណ៣,០៩៤ តោន/ហ.ត. និងទិន្នផលស្រូវរដូវប្រាំងទទួលបាន៤,៥១២តោន/ហ.ត.។ បរិមាណផលស្រូវបានកើនឡើងពី៩,៣២លានតោននៅឆ្នាំ២០១៤ ដល់ប្រមាណ១០,៨៩លានតោន នៅឆ្នាំ២០១៨ ក្នុងនោះបរិមាណផលស្រូវវស្សាទទួលបានប្រមាណជាង៨,២១២លានតោន និងបរិមាណផលស្រូវរដូវប្រាំងទទួលបានប្រមាណ២,៦៧៨លានតោន។ នៅឆ្នាំ២០១៨នេះ អតិរេកស្រូវមានចំនួនជាង ៥,៨៣៦លានតោន គិតជាអង្ករស្មើនឹង៣,៧៣៥លានតោន។

**តារាងទី ២.១០ ផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៤-២០១៨**

| ផលិតកម្មដំណាំស្រូវ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (លាន ហ.ត.) | ៣,០៥ | ៣,០៥ | ៣,១២ | ៣,១៨ | ៣,៣៤ |
| ផ្ទៃដីប្រមូលផល(លាន ហ.ត) | ៣,០៣ | ៣,០២ | ៣,០៩ | ៣,១៨ | ៣,២៥ |
| បរិមាណផល (តោន) | ៩,៣២ | ៩,៣៣ | ៩,៩៥ | ១០,៥២ | ១០,៨៩ |
| ទិន្នផលមធ្យម(តោន/ហ.ត.) | ៣,០៧ | ៣,០៨ | ៣,២១ | ៣,២៩ | ៣,៣៥ |

*ប្រភព:* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ខ-ផលិតកម្មដំណាំសាកវប្បកម្មនិងឧស្សាហកម្ម

២.៦៩- ផលិតកម្មដំណាំសាកវប្បកម្មនិងឧស្សាហកម្ម ត្រូវបានកត់សម្គាល់ឃើញថា ផ្ទៃដីដាំដុះបានកើនពី៩៥៣ ៥៩៧ហ.ត នៅឆ្នាំ២០១៤ ដល់១,០៩១លានហ.ត នៅឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានប្រមាណ៣,០៣% និងកើន៣,៤២%បើធៀបនឹងឆ្នាំ២០១៧)។ ចំពោះបរិមាណផលផលិតកម្មនៃដំណាំសាកវប្បកម្មនិងឧស្សាហកម្មរយៈពេលខ្លី បានកើនពី១៤,៧លានតោននាឆ្នាំ២០១៤ ដល់ប្រមាណ១៦,៦លានតោននាឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានប្រមាណ១០,៥២% និងកើន១,៤១%ធៀបនឹងឆ្នាំមុន)។

### គ. ការនាំចេញផលិតផលកសិកម្ម (ការធ្វើពាណិជ្ជូបនីយកម្ម)

២.៧០- ការនាំចេញផលិតផលកសិកម្មផ្លូវការ មាននិន្នាការកើនឡើងជាលំដាប់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដែលបានកើនពី៣ ៨៤៥ ១៣២តោន នៅឆ្នាំ២០១៤ កើនដល់ចំនួន៤ ២៣៣ ៥៣២តោននៅឆ្នាំ២០១៨។ កំណើននៃការនាំចេញបានកើនឡើង២២,៨% បើធៀបនឹងឆ្នាំ ២០១៤ តែថយចុះបន្តិចនៅក្នុងឆ្នាំ២០១៨ បើធៀបនឹងការនាំចេញក្នុងឆ្នាំ២០១៧។ ការនាំចេញផលិតផលកសិកម្មសំខាន់ៗមានដូចជាអង្ករចំនួន៦២៦ ២២៥តោន ផលិតផលដំឡូងមី (ចំណិតដំឡូងមី ដំឡូងមីស្រស់ ម្សៅដំឡូងមី) សរុបប្រមាណជាង២,៦លានតោន គ្រាប់ស្វាយចន្ទីមាន ១០១ ៩៧៣តោន ពោតក្រហមចំនួន២០៤ ១៨៤តោន ផ្លែស្វាយស្រស់ចំនួន១០២ ៤៥៧តោន ផ្លែចេក៣២ ៨២១តោន។ ការនាំចេញអង្ករកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែងការនាំចេញអង្ករនៅឆ្នាំ២០១៨ មានចំនួន៦២៦ ២២៥តោន គឺកើនឡើង ៦១,៧% ធៀបនឹងឆ្នាំ២០១៤(៣៨៧ ០៦១តោន) ប៉ុន្តែមានការថយចុះបន្តិចប្រមាណ១,៥% បើធៀបនឹងឆ្នាំ២០១៧(៦៣៥ ២៦៧តោន)។ ការនាំចេញអង្ករនៅក្នុងឆ្នាំ២០១៨ មានប្រភេទអង្ករក្រអូប៧៨,៨២% អង្ករសគ្រាប់វែង១៦,៩៣% និងអង្ករចំហុយគ្រាប់វែង៤,២៥% ទៅកាន់ទិសដៅ ៦១ប្រទេស និងមានក្រុមហ៊ុននាំចេញចំនួន៨៧ក្រុមហ៊ុន។

### ឃ. សហគមន៍កសិកម្ម

២.៧១- ការចងក្រងបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម បានចាប់ផ្តើមតាំងពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០១៨ មានសហគមន៍កសិកម្មសរុបចំនួន១ ១១៦សហគមន៍ ដែលមានសមាជិកសរុបចំនួន១៣០ ០៥៩នាក់(ស្ត្រីមានចំនួន៨០ ៤៣៩នាក់ ស្មើនឹង៦២%) ដែលមានតម្លៃភាគហ៊ុនសរុបចំនួន៣៧ ២៩៧លានរៀល និងដើមទុនសរុបចំនួន៦៩ ០៧៧លានរៀល។ ក្រៅពីសហគមន៍កសិកម្ម ក្រសួងបានជំរុញនិងចុះបញ្ជីសហភាពសហគមន៍កសិកម្មទូទាំងប្រទេសសរុបបានចំនួន៨ ដែលមានសមាជិកជាសហគមន៍កសិកម្មចំនួន៩៧ និងដើមទុនសរុបចំនួនជាង៤១៣លានរៀល។

### ង. ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

២.៧២- រយៈពេល៥ឆ្នាំកន្លងមកនេះ ក្នុងមួយឆ្នាំៗវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានធ្វើពិសោធន៍ជាមធ្យមចំនួន៩០ប្រភេទ នៅ៥៣៦កន្លែង និងអង្កេតចំនួន៩ប្រភេទ លើកសិករប្រមាណចំនួន៣ ៧៥៥នាក់ ព្រមទាំងការងារស្រាវជ្រាវផ្សេងៗទៀតជាច្រើន។

### ច. ការអភិវឌ្ឍដំណាំកៅស៊ូ

២.៧៣- ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានកើនពី៣៥៧,៨ពាន់ហ.ត នៅឆ្នាំ២០១៤ដល់៤៣៦,៧ពាន់ហ.ត. នៅឆ្នាំ២០១៨ (កើនប្រមាណ៣២,៧%) ដែលក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្ម (ផ្ទៃដីរបស់អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដី

សេដ្ឋកិច្ច) មានចំនួន៦៤,២២% និងកៅស៊ូគ្រួសារមានចំនួន៣៥,៧៨%។ ផ្ទៃដីកៅស៊ូគ្រួសារបាន កើនឡើងពី១៤០,៣៥ពាន់ហ.ត. នៅឆ្នាំ២០១៤ ដល់១៦១,១០៣ពាន់ហ.ត.នៅឆ្នាំ២០១៨ (គឺ កើនប្រមាណជា១៣% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)។ រីឯផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មក៏ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ពោលគឺបានកើនពី២១៧,៤៦៣ពាន់ហ.ត. នៅឆ្នាំ ២០១៤ ដល់២៧៥,៥៧៩ពាន់ហ.ត. នៅឆ្នាំ២០១៨ (គឺកើនប្រមាណ២១% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)។

### តារាងទី ២.១១ ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨

| ផលិតកម្មកៅស៊ូ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ផ្ទៃដីដាំកៅស៊ូសរុប | ពាន់ហិកតា | ៣៥៧,៨ | ៣៨៩ | ៤៣២,៧ | ៤៣៦,៣ | ៤៣៦,៧ |
| ២.ផ្ទៃដីចៀរជ័រ | ពាន់ហិកតា | ៩០,៥ | ១១១,២ | ១២៧ | ១៧០,២ | ២៣៤,៧ |
| ៣.ផលិតផលកៅស៊ូ | ពាន់តោន | ៩៧,១ | ១២៦,៩ | ១៤៥,២ | ១៩៣,៣ | ២២០ |

*ប្រភព :* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២.៧៤- ការនាំចេញផលិតផលកៅស៊ូក្នុងរយៈ ពេល៥ឆ្នាំកន្លងមកនេះ បានកើនជាងពីរដង គឺពី ១០០ពាន់តោន មានចំនួនទឹកប្រាក់សរុប១៥៤ ១៣២ ៣៨៩ដុល្លារអាមេរិកនៅឆ្នាំ២០១៤ ដល់ ២១៧ពាន់តោន ស្មើនឹងទឹកប្រាក់២៨៦ ៩៤៤ ៥២៩ដុល្លារអាមេរិក នៅឆ្នាំ២០១៨។

## ៤.២. ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ

២.៧៥- ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ផលិតកម្មសត្វ(ជ្រូកនិងសត្វស្លាប) ជាលក្ខណៈគ្រួសារនិងកសិដ្ឋាន ក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៤-២០១៨ មាននិន្នាការកើនឡើងគួរឲ្យកត់សម្គាល់។ ដោយឡែក ការចិញ្ចឹមគោមានការប្រែប្រួលថយចុះប្រមាណពី៣,០៥៣លានក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ២,៩១៧លានក្បាលនាឆ្នាំ២០១៨។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណពី៥៤២ពាន់ក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ៥០១ពាន់ក្បាលនាឆ្នាំ២០១៨។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីនេះ គឺបណ្តាលមកពីកំណើននៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម (ជាង៩៧%នៃផ្ទៃដីដាំដុះដំណាំស្រូវ) កង្វះកម្លាំងពលកម្មនៅជនបទ(ចំណាកស្រុក) ហើយកសិករបានងាកមកចិញ្ចឹមគោ ក្របី ជាលក្ខណៈពាណិជ្ជកម្ម(គោសាច់)។

២.៧៦- ការចិញ្ចឹមសត្វស្លាប(មាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៤-២០១៨) ទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារនិងកសិដ្ឋាន ពោលគឺបានកើនពីជាង៣១,៥៨លានក្បាលនៅឆ្នាំ២០១៤ ដល់ជិត៣៨,១៦លានក្បាលនាឆ្នាំ២០១៨។ ជាមួយនិងការអភិវឌ្ឍផលិត

កម្មសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអប់រំណែនាំផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ បាននិងកំពុងអនុវត្តយ៉ាងសកម្មផុសផុល ដែលមកទល់ឆ្នាំ២០១៨ ឡជីវឧស្ម័នសរុបចំនួន ២៦ ៥៨៧ឡ ត្រូវបានសាងសង់នៅតាមបណ្តាខេត្តគោលដៅចំនួន១៣។

**តារាងទី ២.១២ ការចិញ្ចឹមសត្វសរុបពីឆ្នាំ២០១៤-២០១៨**

| ប្រភេទសត្វ (ពាន់ក្បាល) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| សត្វគោ | ៣ ០៦០ | ២ ៩១៧ | ២ ៩២០ | ២ ៩៧២ | ២ ៩៨៨ |
| សត្វក្របី | ៥៤២ | ៥០៦ | ៥២៤ | ៥០៩ | ៥០០ |
| សត្វជ្រូក | ២ ៧៣៦ | ២ ៧៧៦ | ២ ៩៧១ | ៣ ០៧៤ | ២ ៧៤៨ |
| សត្វស្លាប | ៣១ ៥៨៤ | ៣៤ ៥១៩ | ៣៥ ៧៣៤ | ៣៦ ២៤៥ | ៣៨ ១៦០ |

*ប្រភព :* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២.៧៧- ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ការនាំចេញគោក្របី ជ្រូក មាន់ ស្វាក្ដាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសមានកើនឡើង ក្នុងនោះគោក្របីចំនួន ៤៣ ៧៥៧ក្បាល ជ្រូកពូជ(មេ បា កូន) ចំនួន១០៩ ៨៣៨ក្បាល កូនមាន់ពូជចំនួន៥៦ ០០០ក្បាល ស្វាក្ដាមចំនួន៧៧ ៦៤៦ក្បាល ចំណីផ្អែចំនួន៧ ០៦៣តោន ស្បែកគោក្របីប្រឡាក់អំបិលចំនួន១៨ ៦០៤តោន និងទឹកដោះគោចំនួន៨ ០០៩តោន។ ដោយឡែកនៅក្នុងឆ្នាំ២០១៨ បាននាំចេញគោក្របីចំនួន៦ ៧៨៦ក្បាល ជ្រូកពូជចំនួន៥ ៥០៥ក្បាល ស្វាក្ដាមចំនួន១០ ៤៧២ក្បាល ស្បែកគោក្របីប្រឡាក់អំបិលចំនួន១ ២៧៥តោន និងទឹកដោះគោចំនួន៧ ៥៥៨តោន។

២.៧៨- ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តបទដ្ឋានអនាម័យសម្រាប់ផលិតផលសត្វជាមួយនឹងការពង្រឹងការអនុវត្តវិធានការអនាម័យសត្វ ដើម្បីការពារនិងប្រយុទ្ធប្រឆាំងជំងឺឆ្លងការពារសុខភាពសាធារណៈ តាមរយៈការការពារជំងឺឆ្លងពីសត្វទៅមនុស្សនិងពីមនុស្សទៅសត្វ និងការបង្កើតសត្តឃាតដ្ឋានទំនើប ដើម្បីការពារសុខភាពសាធារណៈ និងជួយសម្រួលពាណិជ្ជកម្មព្រមទាំងឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ។

## បញ្ហាប្រឈម

២.៧៩- និយាយរួមកសិកម្មកម្ពុជានៅមានសក្តានុពលច្រើនណាស់ដែលយើងពុំទាន់បានប្រើប្រាស់ឲ្យអស់លទ្ធភាពនៅឡើយ។ ការអនុវត្តកន្លងមក គឺត្រូវបានវាយតម្លៃថា សម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ ទោះបីជាយ៉ាងនេះក្តីក៏យើងនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមាន៖

(១) **ផ្នែកផលិតភាពកសិកម្ម និងទីផ្សារ៖** ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វ នៅមានកម្រិតទាបនៅឡើយ ដែលប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារ ពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ ម៉្យាងវិញទៀត ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ គុណភាពនៃធាតុចូលកសិកម្ម និងសេវាផ្នែកកសិកម្មនៅថ្នាក់មូលដ្ឋាន ពិសេសថ្នាក់ស្រុកនៅមានកម្រិត។ ការបន្ស៊ាំរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេសតាមផ្នែកនីមួយៗ និងការផ្តល់សេវាព័ត៌មានទីផ្សារកសិផលទៅដល់កសិករ គឺនៅមិនទាន់មានភាពទូលំទូលាយ។

(២) **ផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងភស្តុភារកម្ម៖** ប្រព័ន្ធស្រោចស្រពកសិកម្មនៅពុំទាន់បានគ្របដណ្តប់លើផ្ទៃដីដាំដុះឲ្យបានទូលំទូលាយ ជាពិសេស ការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិ ពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ។ បញ្ហាតម្លៃដឹកជញ្ជូន អគ្គិសនី និងប្រព័ន្ធសេវាភស្តុភារ គឺជាបញ្ហាមួយដែលរួមចំណែកធ្វើឲ្យថ្លៃដើមផលិតកម្មខ្ពស់។

(៣) **ផ្នែកស្រាវជ្រាវបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្ម៖** ការងារស្រាវជ្រាវ និងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកម្រិត ហើយសមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការប្រើប្រាស់ធាតុចូលកសិកម្មសមស្របតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិតដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ពិបាកប្រជែងនៅលើទីផ្សារ។ ការវិនិយោគក្នុងផ្នែកអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៅមានទំហំតូច ដែលត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់។

(៤) **ការបង្ក្រាបបទល្មើស៖** បទល្មើសព្រៃឈើ ជលផល ការលួចនាំចូលនិងនាំចេញសត្វ សម្ភារកសិកម្មដោយខុសច្បាប់នៅតែកើតមាន ជាពិសេសបណ្តាខេត្តជាប់ព្រំដែន។ សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើ ការរានដីព្រៃលិចទឹកដោយខុសច្បាប់ គឺនៅតែកើតមានពុំចេះចប់រហូតមកទល់បច្ចុប្បន្ននេះ។

## ៤.៣- កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម រដ្ឋបាលដីធ្លី

២.៨០- សមិទ្ធផល ដែលសម្រេចបានក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ រួមមាន៖

- គិតពីការចាប់ផ្តើមអនុវត្តរហូតចុងឆ្នាំ២០១៨ លទ្ធផលសម្រេចបានគឺ ចេញបណ្ណកម្មសិទ្ធិដីបាន ៧៣,២៥ % នៃក្បាលដីប៉ាន់ស្មានសរុប៧លានក្បាលដី លើសផែនការ៣,២៥% ក្នុងនោះបានចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសម្រេចបាន២៤សហគមន៍ ស្មើនឹង ៦៨៤បណ្ណ

- ដោះស្រាយវិវាទដីធ្លីមានពាក្យបណ្ដឹងចំនួន៨ ៣៥៣ករណី បានដោះស្រាយបញ្ចប់ចំនួន ៣ ៩៦៧ករណី ដែលមាន ២១ ០០២គ្រួសារ លើផ្ទៃដីចំនួន ៦ ៣២០ហ.ត
- ដាក់ឱ្យដំណើរការកម្មវិធីបោះពុម្ព QR Code នៅលើសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុគំរូថ្មី និងអាចទាញយកព័ត៌មានបានតាមទូរស័ព្ទទំនើប
- កសាងបង្គោលប្រឹថពីវិភាគលំដាប់សូន្យចំនួន៧បង្គោល បង្គោលប្រឹថពីវិភាគលំដាប់ទី១ ចំនួន១៥៥បង្គោល បង្គោលប្រឹថពីវិភាគលំដាប់ទី២ ចំនួន៤៩៦បង្គោល បង្គោលប្រឹថពីវិភាគលំដាប់ទី៣ ចំនួន១ ៣៨៣បង្គោល បង្គោលរយៈកំពស់ចំនួន៨៣៥បង្គោល
- ផលិតផែនទីអ័រតូហ្វូតូដើម្បីគាំទ្រការចុះបញ្ជីអចលនវត្ថុបានចំនួន១៣ ០០៤សន្លឹក

## ២.៨១-ការរៀបចំដែនដីនិងនគរូបនីយកម្ម

- រៀបចំផែនទីឧទ្យានជាតិ ផែនទីគម្របព្រៃឈើ ផែនទីតំបន់ទីក្រុង និងផែនទីដីកសិកម្ម សម្រាប់ការងារកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ
- ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានអនុម័តនិងបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ
- ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រុងតាខ្មៅ ខេត្តកណ្ដាល ក្រុងសៀមរាប ខេត្តសៀមរាប ក្រុងកំពត ខេត្តកំពត ក្រុងកែប ខេត្តកែប ទីប្រជុំជនស្រុកជ្រៃធំ ខេត្តកណ្ដាល និងទីប្រជុំជនស្វាយអន្ទរ ខេត្តព្រៃវែង ត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ផ្លូវការ
- ផែនការប្រើប្រាស់ដី នៅក្នុងឃុំ សង្កាត់ បានអនុម័តចំនួន៨០ ឃុំសង្កាត់ទូទាំងប្រទេស និង ប្លង់គោលហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍកោះរ៉ុង

## ២.៨២-ការបែងចែកដី

- សរុបគិតចាប់ពីការអនុវត្តរហូតដល់ឆ្នាំ២០១៨ កម្មវិធីសម្បទានដីសង្គមកិច្ចគ្រប់ប្រភេទ បានផ្តល់ដីជូនប្រជាពលរដ្ឋសរុប៧៨ ៥៤៥ គ្រួសារ ស្មើនឹង១៤០ ៧៦៥,៤៧ហ.ត. និង សាងសង់ផ្ទះជូនប្រជាពលរដ្ឋសរុបចំនួន៦ ៦៩៩ ខ្នង និងសម្រេចផ្តល់ដីសរុបជាង ១ លាន ២សែនហ.ត. ស្មើនឹងជាង ៧១ម៉ឺនក្បាលដី ជូនគ្រួសារទទួលដីប្រមាណ៤សែនគ្រួសារ តាមរយៈការអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី ។

### បញ្ហាប្រឈម

- ដីបម្រុងទុកសម្រាប់គោលដៅសម្បទានដីសង្គមកិច្ចត្រូវបានទន្ទ្រាន និងកាន់កាប់ដោយខុសច្បាប់

- ការប្រើប្រាស់ដីមិនទាន់អស់លទ្ធភាព ទាមទារឲ្យមានការជួយជ្រោមជ្រែង និងបណ្តុះបណ្តាលបន្ថែមលើបច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងជាពិសេសជួយស្វែងរកទីផ្សារសម្រាប់លក់ផលិតផលដែលប្រមូលបាន
- ការទទួលយកបច្ចេកទេសសមស្របរបស់ស្ត្រីដើម្បីអនុវត្ត នៅតាមគ្រួសារទាមទារការជំរុញ និងផ្សព្វផ្សាយច្រើនដង និងអនុវត្តបង្ហាញជាក់ស្តែង
- ទីតាំងគម្រោងដីសម្បទានសង្គមកិច្ចជាទីតាំងថ្មីហេតុនេះទីតាំងនេះត្រូវការការងារអភិវឌ្ឍជាច្រើនបន្ថែមទៀត

## ២.៨៣- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់

- សំណង់នៅទូទាំងប្រទេសគិតចាប់ពីឆ្នាំ២០០០ ដល់ខែវិច្ឆិកា ឆ្នាំ២០១៨ បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន៤៣ ៥៥៩គម្រោង ដែលមានផ្ទៃក្រឡាសំណង់សរុបចំនួន១១៥ ២៤៨ ៥៥១ម$^{២}$ និងតម្លៃប៉ាន់ស្មានទុនវិនិយោគសរុបប្រមាណ៤៣ ៨៩៦ ៥០០ ៩៧៦ដុល្លារអាមេរិក

### បញ្ហាប្រឈម

- ការសាងសង់រំលោភលើដីសាធារណៈរបស់រដ្ឋ
- ការសាងសង់គ្មានលិខិតអនុញ្ញាត និងសាងសង់ខុសលិខិតអនុញ្ញាត
- លិខិតបទដ្ឋានគតិយុត្ត លិខិតបទដ្ឋានបច្ចេកទេស មិនទាន់គ្រប់គ្រាន់

### តារាងទី ២.១៣ លទ្ធផលសម្រេចបាន លើការងារកំណែទម្រង់វិស័យដីធ្លី

| ល.រ | សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១ | អត្រាបណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនប្រជាពលរដ្ឋទូទៅ | % | ៥៥ | ៥៩ | ៦៣,៦ | ៦៦,៤ | ៧៣,២៥ |
| ២ | បញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | ចំនួន | ៨ | ១១ | ១៤ | ១៩ | ២៤ |
| ៣ | ដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី | ករណី | ៥ ៨០៨ | ៦ ៤៤៥ | ៦ ៨៩២ | ៧ ០៥៥ | ៧ ៨៣៨ |
| ៤ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំសង្កាត់ | ចំនួន | ៧៦ | ៧៦ | ៨០ | ៨០ | ៨០ |
| ៥ | ប្លង់គោលថ្នាក់ ស្រុក ខណ្ឌ | ចំនួន | ០ | ០ | ០ | ០ | ០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | ប្លង់គោលនិងផែនការប្រើប្រាស់ដីធ្លី ថ្នាក់ក្រុង | ចំនួន | ១ | ៣ | ៣ | ៤ | ៩ |
| ៧ | ផែនការប្រើប្រាស់ដីថ្នាក់ខេត្ត | ចំនួន | ០ | ០ | ០ | ១ | ៣ |
| ៨ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | គ្រួសារ | ៥ ០៩៦ | ៥ ៤៤៣ | ៥ ៤៤៣ | ៥ ៥៦២ | ៧៨ ៥៤៥ |

## ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.)

២.៨៤- ការងារលើវិស័យសកម្មភាពមីនឈរលើ សសរស្តម្ភចំនួន៥ គឺ ការអប់រំយល់ដឹងពី និង ស.ផ.ស. ការបោសសម្អាតមីននិងស.ផ.ស. កិច្ចសង្គ្រោះជនពិការ ការគាំទ្រមតិប្រឆាំងទៅនឹងការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និងការបំផ្លាញចោលឃ្លាំងគ្រាប់មីនប្រឆាំងមនុស្ស មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់៖

### តារាងទី ២.១៤ សមិទ្ធផលក្នុងវិស័យសកម្មភាពមីន ឆ្នាំ២០១៤-២០១៨

| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ជនរងគ្រោះដោយសារមីននិងស.ផ.ស. ប្រចាំឆ្នាំ(ស្លាប់/របួស) | នាក់ (ចំណុចដៅ) | ១៥១* | ១៣៦* | ១២២* | ១១០* | ៩៩* |
| | នាក់ (គ្រោះថ្នាក់ពិត) | ១៥៤ | ១១១ | ៨៣ | ៥៨ | ៥៨ |
| ចំនួនជនរងគ្រោះដោយសារការលេង និងច្នៃគ្រាប់មីន និងស.ផ.ស. ប្រចាំឆ្នាំ(ស្លាប់/ របួស) | នាក់ (ចំណុចដៅ) | ៩៩* | ៨៦* | ៧៣* | ៦០* | ៤៨* |
| | នាក់ (គ្រោះថ្នាក់ពិត) | ៧៧ | ៧៣ | ៣៧ | ៣៦ | ៤១ |
| ផ្ទៃដីសរុបបោសសម្អាតមីន និងស.ផ.ស. | ហ.ត (ចំណុចដៅ) | ៩ ១៤៣* | ៩ ៦០០* | ១០ ០៨០* | ១០ ៥៨៤* | ១១ ១១៣* |
| | ហ.ត (សម្រេចបាន) | ១៨ ៤១៧ | ១៨ ៥៣០ | ១៣ ២២៨ | ១៤ ៦៧៣ | ១៣ ១៦៧ |

**សម្គាល់៖**

- (*) ការប៉ាន់ស្មាន និង (ស.ផ.ស.) សំណល់ជាតិផ្ទុះពីសង្គ្រាម

### បញ្ហាប្រឈម

- ផ្ទៃដីសង្ស័យមានមីននិងស.ផ.ស.មានចំនួន១ ៧២៩គ.ម² ត្រឹមដំណាច់ឆ្នាំ២០១៨ ។
- ជំនួយវិស័យសកម្មភាពមីនពីប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍមានការធ្លាក់ចុះដោយសារកម្ពុជាបានក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតទាប ។

## ៤.៤- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

### កំណែទម្រង់ព្រៃឈើ

២.៨៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តកម្មវិធីកែទម្រង់វិស័យព្រៃឈើជាច្រើនរួមមាន៖ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការបង្កើតនិងពង្រឹងសហគមន៍ព្រៃឈើ ការអនុវត្តវិធានការយ៉ាងម៉ឺងមាត់ក្នុងការគ្រប់គ្រង និងទប់ស្កាត់បទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក ការបង្កើតតំបន់ព្រៃសម្រាប់អភិរក្សធនធានពន្ធុរុក្ខជាតិ និងសត្វព្រៃ ព្រមទាំងបោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ ការដាំកូនឈើនៅតំបន់ស្តារព្រៃឈើឡើងវិញនិងទីតាំងផ្សេងៗ ដែលការងារទាំងអស់នេះ ពិតជាបានឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់វិស័យព្រៃឈើ។

**តារាងទី ២.១៥ លទ្ធផលសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិស័យព្រៃឈើ**

| បរិយាយ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| ការដាំដើមឈើ (ហ.ត.) | ១៧ ៩៣២ | ៥ ៨៩៣ | ៥៣ ៩៩២ | ២៥១ ០៨៤ | ២៦ ៧៩៩ |
| ការនាំចេញឈើ (ម³) | ៣៩ ៧៤៣ | ៧៥ ២៩២ | ២១ ៦៥៥ | ១៥ ៨៦៨ | ៩ ១៤៩ |
| ការនាំចូលឈើ (ម³) | ៥០០ | ១ ៣០០ | ១ ៥៧៤ | ១ ៤២៩ | ៥ ៥១៩ |
| ការបង្ក្រាបបទល្មើសព្រៃឈើ (ករណី) | ១ ៥២៣ | ២ ៤០០ | ២ ១៨៩ | ១ ៤៩០ | ១ ៤២៨ |

*ប្រភព :* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២.៨៦- ផ្អែកតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ដាំឈើលើដីព្រៃរេចរិល ដោយសហការដៃគូជាមួយវិស័យឯកជន។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីវិធានព្រៃឯកជនឆ្នាំ២០១៧ ដែលប្រកាសនេះមានគោលបំណងកំណត់នូវវិធានព្រៃឯកជនសម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើតនិងអភិវឌ្ឍព្រៃឯកជន។

### វិស័យជលផល

២.៨៧- ត្រីជាអាហារប្រចាំថ្ងៃយ៉ាងសំខាន់របស់ប្រជាជនកម្ពុជាតាំងពីដើមរៀងមក ព្រោះត្រីផ្តល់នូវសារជាតិប្រូតេអ៊ីនប្រមាណជាង៨១% នៃប្រូតេអ៊ីនសាច់ដែលប្រជាជនកម្ពុជាបរិភោគ។ វិស័យ

ជលផលក៏បានចូលរួមចំណែកផ្តល់មុខរបរដល់ប្រជាពលរដ្ឋប្រមាណ៦លាននាក់ បង្កើតប្រាក់ចំណូលដល់ប្រជាជនដើម្បីជួយកាត់បន្ថយភាពក្រីក្រនិងជួយអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

ជាក់ស្តែងមកទល់ពេលនេះ សមិទ្ធផលធំៗដែលសម្រេចបានមានដូចខាងក្រោម៖

**(១) ការអភិវឌ្ឍសហគមន៍នេសាទ៖**

រដ្ឋបាលជលផលបានរៀបចំសហគមន៍នេសាទសរុបចំនួន៥១៦ នៅតាមបណ្តាខេត្តនានា ដោយមានសមាជិកចូលរួមសរុប១៤៧ ៥១៨គ្រួសារ ស្មើនឹង៣៣២ ១៦៨នាក់ ដែលមានទីតាំងក្នុងដែននេសាទទឹកសាបចំនួន៤៧៥សហគមន៍ និងតំបន់ឆ្នេរសមុទ្រចំនួន៤១សហគមន៍ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានប្រកបដោយចីរភាព។ នៅក្នុងដែននេសាទសហគមន៍មកដល់បច្ចុប្បន្ននេះ បានបង្កើតតំបន់អភិរក្សបានចំនួន៤៩៦កន្លែង ដោយមានការបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សបានចំនួន៤ ៩៨៨ដើម និងស្លាកសញ្ញាកន្លែងអភិរក្សបានចំនួន២៤២ស្លាក សម្រាប់សម្គាល់ទីតាំងកន្លែងអភិរក្សនៃកន្លែងនេសាទសហគមន៍នីមួយៗ ដែលត្រូវការពារនិងគ្រប់គ្រង។

**(២) ការងារអភិរក្សជលផល៖**

ការងារអភិរក្សត្រូវបានយកចិត្តទុកដាក់បំផុត ដើម្បីចូលរួមចំណែកធានាផលចាប់ប្រកបដោយនិរន្តរភាព។ បើគិតរួមទាំងកន្លែងអភិរក្សជលផលនៅតាមដែនសហគមន៍នេសាទ និងកន្លែងអភិរក្សសម្រាប់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ និងកន្លែងអភិរក្សនៅតាមតំបន់ឆ្នេរ គឺមានរហូតដល់៦៤៤កន្លែង។ ជារួម គិតចាប់ពីឆ្នាំ២០១៣មក បានសាងសង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផលកម្ពស់៨ម៉ែត្រ បានចំនួន១៦១បង្គោល និងកម្ពស់១២ម៉ែត្របានចំនួន៧២បង្គោល ស្នាក់ការល្បាតបណ្តែតទឹកចំនួន២៥ខ្នង ស្នាក់ការបេតុងចំនួន៨ខ្នង និងស្នាក់ការធំ(ស្រឡង់) ចំនួន០៤។

**(៣) ការងារបង្ក្រាបបទល្មើសជលផល៖**

រដ្ឋបាលជលផលបានអនុវត្តតាមគ្រប់រូបភាព ដោយអនុវត្តតាមច្បាប់ស្តីពីជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសបទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាលទទួលបានលទ្ធផលគួរជាទីមោទនៈ ព្រមទាំងធានាបាននិរន្តរភាពធនធានជលផល និងសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ។ លទ្ធផលដែលសម្រេចបានខាងលើនេះ គឺដោយសារមានកិច្ចសហការអំពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសសហគមន៍មូលដ្ឋាន។ នៅឆ្នាំ២០១៤ ករណីបទល្មើសជលផលមានចំនួន៣ ៦៨៦ករណី ចំនួនត្រូវបានថយចុះមកត្រឹម២ ៦៥០ករណីនៅឆ្នាំ២០១៨។

(៤) ការអភិវឌ្ឍវារីវប្បកម្ម៖

ជាគោលនយោបាយដ៏ចម្បងរបស់រដ្ឋាភិបាល ក្នុងការធានាសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ និងកាត់បន្ថយការដាក់សំពាធលើធនធានជលផលក្នុងដែនទឹកធម្មជាតិ ការអភិវឌ្ឍវារីវប្បកម្មក៏ត្រូវអនុវត្តតាមគ្រប់រូបភាព និងគ្រប់ទីកន្លែង រួមទាំងការបង្កើតស្រះជម្រកត្រីសហគមន៍ផងដែរ ដើម្បីធ្វើឲ្យផលវារីវប្បកម្មមានការកើនឡើងប្រមាណ២០%ជារៀងរាល់ឆ្នាំ។ ការអភិវឌ្ឍវារីវប្បកម្មសំខាន់រួមមាន ការចិញ្ចឹមត្រី បង្គា ដែលនៅឆ្នាំ២០១៨ អនុវត្តបានចំនួន២៥០ ២០៦តោន គឺបានកើនឡើងជាង២ដងធៀបនឹងឆ្នាំ២០១៤(១២០ ០៥៥តោន)។ ការចិញ្ចឹមក្រពើក៏មានសន្ទុះកើនឡើងផងដែរ គឺបានកើនប្រមាណ២ដង ពី២១៥ពាន់ក្បាលនាឆ្នាំ២០១៤ ដល់៤២០ពាន់ក្បាលនាឆ្នាំ២០១៨ និងការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន១២០លានក្បាលនាឆ្នាំ២០១៤ និងកើនដល់២១៥លានក្បាល នាឆ្នាំ២០១៨។

(៥) ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃនិងគុណភាព៖

ផ្នែកកែច្នៃជលផលគឺជាផ្នែកដែលមានសក្តានុពលមួយយ៉ាងសំខាន់សម្រាប់វិស័យជលផល ក្នុងការចូលរួមចំណែកផ្គត់ផ្គង់សន្តិសុខស្បៀង អាហារូបត្ថម្ភ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

២.៨៨- ចំពោះការតាមដាននិងត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល រដ្ឋបាលជលផលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយបានបញ្ជូនមន្ត្រីជំនាញសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់លើការប្រើសារធាតុគីមីដែលហាមឃាត់ ជាពិសេសលើផល ផលិតផលជលផលនាំចូលពីក្រៅប្រទេស។

(៦) ការសិក្សាស្រាវជ្រាវជលផល៖

ការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អប្រសើរ ដោយបានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានា ដែលមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវសៀវភៅ ជាច្រើនពាន់ក្បាល និងផូស្ទ័រជាច្រើនម៉ឺនសន្លឹក ត្រូវបានបោះពុម្ពផ្សាយ។

២.៨៩- ជាក់ស្តែង បរិមាណផលនេសាទសរុប(ទឹកសាប សមុទ្រ និងវារីវប្បកម្ម) បានកើនឡើងគួរឲ្យកត់សម្គាល់ គឺបានកើនពី៧៤៥ពាន់តោនក្នុងឆ្នាំ២០១៤ ដល់៩១១ពាន់តោនក្នុងឆ្នាំ២០១៨ ក្នុងនោះបរិមាណផលនេសាទទឹកសាបបានកើនឡើងពី៥០៥ពាន់តោន ដល់៥៣៨ពាន់តោន ផលនេសាទសមុទ្របានកើនឡើងពី១២០ពាន់តោន ដល់១២៣ពាន់តោន និងវារីវប្បកម្មក៏មានសន្ទុះកើនឡើងដូចគ្នា គឺបានកើនពី១២០ពាន់តោន ដល់២៥០ពាន់តោន ក្នុងចន្លោះឆ្នាំ២០១៤ និង២០១៨នេះ។

### តារាងទី ២.១៦ ស្ថានភាពផលនេសាទពីឆ្នាំ២០១៤-២០១៨

| ល.រ | បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១ | ផលវារីវប្បកម្ម | ពាន់តោន | ១២០,០៥ | ១៤៣,១៤ | ១៧២,៥០ | ២០៧,៤៤ | ២៥០,២០ |
| ២ | ផលនេសាទទឹកសាប | ពាន់តោន | ៥០៥,០១ | ៤៨៧,៩០ | ៥០៩,៣៥ | ៥២៧,៨០ | ៥៣៧,៨៥ |
| ៣ | ផលនេសាទសមុទ្រ | ពាន់តោន | ១២០,២៥ | ១២០,៥០ | ១២០,៦០ | ១២១,០៣ | ១២២,៨៥ |

*ប្រភព :* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ទិស័យរ៉ែនិងថាមពល

២.៩០- ក្រសួងរ៉ែនិងថាមពលបានអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

### វិស័យរ៉ែ

- រៀបចំតាក់តែងគោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨
- រៀបចំច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និង
- រៀបចំអនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករករ៉ែ និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ និង អនុក្រឹត្យស្តីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- លុបបំបាត់ភាពអនាធិបតេយ្យនៃអាជីវកម្មបូមខ្សាច់នៃសមុទ្រ ទន្លេ និងស្ទឹង និង ធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំឧត្តមមន្ត្រីរ៉ែអាស៊ាន។
- កសាងមន្ទីរពិសោធន៍ភូគព្ភសាស្ត្រជាតិ
- ជំរុញការកសាងគម្រោងអភិវឌ្ឍរោងចក្រស៊ីម៉ង់ត៍បានចំនួន០៥ រោងចក្រ ដែលកំពុងធ្វើការផលិតស៊ីម៉ងត៍ ហើយមានលទ្ធភាពផលិតនិងផ្គត់ផ្គង់ផលិតផលបានសរុបជិត០៧លានតោនក្នុងមួយឆ្នាំ សម្រាប់បម្រើតម្រូវការក្នុងស្រុក
- អភិវឌ្ឍគម្រោងក្នុងសហគមន៍ដែលអាជីវកម្មរ៉ែស្ថិតនៅ។

### តារាងទី ២.១៧ សូចនាករវាស់វែងវិស័យរ៉ែ

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ | ដុល្លារ | ២ ៨១៣ ៧៨១ | ៩ ៩៩៤ ៥៨៦ | ១៣ ០៩៧ ៣៩៥ | ១៤ ៥៦២ ៧៤៥ | ១៨ ២១៣ ៤៣៣ |
| អាជ្ញាបណ្ណស្វែងរុករករ៉ែ | ចំនួន | ១៣១ | ១០៣ | ៦១ | ៥៤ | ៥៦ |
| អាជ្ញាបណ្ណអាជីវកម្មរ៉ែ | ចំនួន | ២០ | ២៣ | ២៣ | ២៧ | ២៦ |
| អាជ្ញាបណ្ណរ៉ែសំណង់ | ចំនួន | ៣២០ | ៣១៦ | ៤០១ | ៣១៩ | ៣១៤ |

### វិស័យប្រេងកាត

- ប្រកាសអន្តរក្រសួងស្តីពី ការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជានិងនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពបង្កើតស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
- អនុវត្តសារាចរស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយ បូមប្រេង និងឧស្ម័នឥន្ធនៈ
- រៀបចំគោលនយោបាយជាតិស្តីពីប្រេងកាត ឆ្នាំ២០២០-២០៣០ និងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- រៀបចំការគ្រប់គ្រងប្រតិបត្តិការប្រេងកាតផ្នែកអាប់ស្ទ្រីម និង ដោនស្ទ្រីម
- ចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយក្រុមហ៊ុនKrisEnergy សម្រាប់ការងារអភិវឌ្ឍអណ្តូងផលិតកម្មប្រេងកាតប្លុក A ។

### បញ្ហាប្រឈម

២.៩១- នៅក្នុងអាណត្តិទី៥នេះ ការអនុវត្តការងារនៅក្នុងវិស័យរ៉ែនិងថាមពល ជួបប្រទះនូវបញ្ហាប្រឈមធំមួយចំនួនដូចខាងក្រោម៖

- ខ្វះមន្ត្រីសម្រាប់ប្រតិបត្តិការទូទៅ និងខ្វះទុនថវិកាសម្រាប់ប្រតិបត្តិការគ្រប់គ្រង និងអភិវឌ្ឍវិស័យរ៉ែ ប្រេងកាត និងថាមពល។

## កិច្ចគាំពារបរិស្ថាននិងការអភិរក្សជីវៈចម្រុះ

### ១. ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

២.៩២- ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និង មានកិច្ចសហការជិតស្និទ្ធ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ យើងសម្រេចបានសមិទ្ធផល ដូចខាងក្រោម៖

#### ១.១ សេដ្ឋកិច្ចបៃតង

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំ របាយការណ៍ជាតិ និងយន្តការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានជីវៈចម្រុះនិងជីវសុវត្ថិភាព ការអភិវឌ្ឍបៃតង និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប។
- បង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងអគ្គលេខាធិការដ្ឋាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅធានានូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- សម្របសម្រួលសហការរៀបចំ និងអនុវត្តកម្មវិធីការប្រើប្រាស់ថាមពលនុយក្លេអ៊ែបម្រើឲ្យគោលបំណងសន្តិសភាព ថាមពលកកើតឡើងវិញ ថាមពលស្អាត ជីវៈម៉ាស ប្រសិទ្ធភាពថាមពល និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- សហការជាមួយដៃគូអភិវឌ្ឍក្នុងការរៀបចំគម្រោងស្នើសុំសម្រាប់កៀរគរថវិកាអនុវត្តកម្មវិធីការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានជីវៈចម្រុះនិងជីវសុវត្ថិភាព ទីក្រុងនិរន្តរភាពថាមពលនិរន្តរភាព និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

## ២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការវិភាជថវិកាជាតិសម្រាប់អនុវត្តកម្មវិធី គម្រោង និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។
- រៀបចំគោលនយោបាយនិងជំហររបស់កម្ពុជាសម្រាប់ចរចា និងអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនិងស្តីពីជីវៈចម្រុះ ព្រមទាំងកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីនានានៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

## ៣. ជីវៈចម្រុះនិងជីវសុវត្ថិភាព

- សិក្សាស្រាវជ្រាវ វាយតម្លៃគុណតម្លៃជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងប្រភេទរុក្ខជាតិ សត្វកម្រ ងាយរងគ្រោះ និងជិតផុតពូជ ព្រមទាំងសិក្សាលទ្ធភាពក្នុងការបង្កើតរុក្ខឧទ្យាន និងតិណាល័យថ្នាក់ជាតិ។

## ៤. ការត្រួតពិនិត្យ និងអធិការកិច្ចប្រភពបំពុល

- ចុះត្រួតពិនិត្យប្រភពបំពុលបរិស្ថាន នៅតាមបណ្តារោងចក្រសហគ្រាសជាប្រចាំនៅទូទាំងប្រទេស។
- ចុះណែនាំការដាក់ឲ្យអនុវត្តសាកល្បងប្រព័ន្ធរាយការណ៍ពីការសាយភាយ និងបំលាស់ទីសារធាតុបំពុលចូលក្នុងបរិស្ថាន នៅតាមប្រភពបំពុលសំខាន់ៗ។
- ចុះធ្វើអធិការកិច្ចលើបទល្មើសបំពុលបរិស្ថាន។

## ៥. ការអង្កេតតាមដានគុណភាពបរិស្ថាន

- ធ្វើការតាមដានគុណភាពទឹកសាធារណៈចំនួន៣១ចំណុចដៅ នៅតាមបណ្តារាជធានីខេត្ត និងយកសំណាកវិភាគ និងបានដាក់ឲ្យដំណើរការស្ថានីយតាមដានគុណភាពទឹកទន្លេចតុមុខ
- ធ្វើការតាមដានគុណភាពខ្យល់សាធារណៈ អាស៊ីតបរិយាកាសចំនួន៧ គោលដៅនៅតាមរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ។

- ប្រកាសនិងដាក់ឲ្យអនុវត្តអនុក្រឹត្យចំនួន៥៖ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- រៀបចំ និងដាក់ឲ្យអនុវត្តប្រកាស សារាចរណែនាំ សេចក្តីសម្រេច អនុស្សារណៈនៃការយោគយល់ គោលការណ៍ណែនាំបច្ចេកទេស ដើម្បីគាំទ្រការអនុវត្តអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន។

### ៦. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- តាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន។
- រៀបចំ និងដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ៧. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

ធ្វើការវាយតម្លៃធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៦ ដោយលទ្ធផលបានបង្ហាញថា កម្ពុជានៅមានផ្ទៃដីគម្របព្រៃឈើ សរុបទូទាំងប្រទេសប្រមាណ៨ ៧៤២ ៤០១ហ.ត. ស្មើនឹង៤៨,១៤% ដោយមានអត្រាប្រែប្រួលគិតជាមធ្យមប្រចាំឆ្នាំគឺ0,៦៧%។ តាមការព្យាករក្នុងរយៈពេល២ឆ្នាំខាងមុខ អត្រាបាត់បង់គម្របព្រៃឈើនេះនឹងមានការកាត់បន្ថយជាបន្ថែមទៀត។

២.៩៣- តាមរយៈផ្ទៃដីធនធានគម្របព្រៃឈើនេះ តំបន់ការពារធម្មជាតិត្រូវបានបង្កើនជាបន្តបន្ទាប់ពីចំនួន២៣តំបន់ ដល់ចំនួន៥៣តំបន់ រួមទាំងរបៀងអភិរក្សជីវៈចម្រុះ (របៀងអភិរក្សជីវៈចម្រុះ ព្សសាន្ត របៀងអភិរក្សជីវៈចម្រុះឧត្តរ និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ) នាពេលបច្ចុប្បន្ន ធ្វើឱ្យផ្ទៃដីប្រព័ន្ធតំបន់ការពារធម្មជាតិ ទូទាំងប្រទេសសរុបមានប្រមាណជាង៧,៤លានហ.ត. ឬស្មើនឹង៤១% នៃផ្ទៃដីប្រទេសទាំងមូល។ បន្ថែមលើនេះ ក្រសួងបរិស្ថានបានរៀបចំនូវឯកសារចាំបាច់មួយចំនួន ជាពិសេសគឺផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ឆ្នាំ២០១៧-២០៣១ និងយុទ្ធសាស្ត្ររេដបូកជាតិឆ្នាំ២០១៧-២០២៦ ដែលជាឯកសារ សំខាន់ក្នុងការកៀរគរថវិកាពីប្រភពផ្សេងៗដើម្បីគ្រប់គ្រង ថែរក្សាការពារ និងអភិរក្សធនធានព្រៃឈើកម្ពុជាប្រកបដោយចីរភាព។ ជាក់ស្តែងគម្រោងរេដបូកចំនួន៣គឺ នៅដែនជម្រកសត្វព្រៃ «កែវសីមា» ដែនជម្រកសត្វព្រៃ«ព្រៃឡង់» និងដែនជម្រកសត្វព្រៃ «តាតៃ» និងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង បាននឹងកំពុងសហការរៀបចំនីតិវិធីបច្ចេកទេសវាយតម្លៃសុពលភាពរវាងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និង អង្គការដៃគូស្នូលមួយចំនួន។

២.៩៤- ទន្ទឹមជាមួយគ្នានេះ ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងបរិស្ថាន នៃរាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងធ្វើប្រតិភូកម្មមុខងាររដ្ឋបាល

ការពារនិងអភិរក្សធម្មជាតិជូនទៅមន្ទីរបរិស្ថានរាជធានី ខេត្ត លើការងារអនុវត្តការគ្រប់គ្រងតំបន់ការពារធម្មជាតិនិងការអនុវត្តសកម្មភាពរេដបូកនៅថ្នាក់ក្រោមជាតិដែលជាកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងបរិស្ថានលើការការពារ គ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះដោយនិរន្តរភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងអនុសញ្ញានិងកិច្ចព្រមព្រៀងនានា។

### ៩. ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគ្រប់គ្រង តំបន់បេតិកភណ្ឌ

២.៩៥- សមិទ្ធផលសំខាន់ៗ ដែលក្រសួងបរិស្ថានសម្រេចបានលើការងារគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ មូលដ្ឋានរួមមាន៖

- ក្រសួងបរិស្ថានបានរៀបចំកែសម្រួល និងបោះពុម្ពគោលការណ៍ណែនាំស្តីពីនីតិវិធីក្នុងការរៀបចំសហគមន៍ តំបន់ការពារធម្មជាតិដើម្បីចែកជូនដល់មន្ទីរបរិស្ថាន គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងអង្គការដៃគូពាក់ពន្ធ័ក្នុងការប្រើប្រាស់ ដើម្បីរៀបចំនិង ពង្រឹងសមត្ថភាពសហគមន៍នៅតាមតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំលក្ខន្តិកៈ និងយន្តការសម្របសម្រួលសហគមន៍ជាមួយស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បីចងក្រងសហគមន៍តំបន់ការពារធម្មជាតិឲ្យមានរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងទិសដៅចូលរួមពង្រឹងប្រសិទ្ធភាពនៃការការពារនិងគ្រប់គ្រងតំបន់ការពារធម្មជាតិ។
- ធ្វើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីនីតិវិធីក្នុងការរៀបចំសហគមន៍ទេសចរណ៍ធម្ម-ជាតិនៅតាមសហគមន៍តំបន់ការពារធម្មជាតិ និងបានរៀបចំលិខិតណែនាំដល់ម្ចាស់គម្រោងវិនិយោគទេសចរណ៍ធម្មជាតិឲ្យបំពេញបន្តនីតិវិធីច្បាប់។
- អប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងស្តីពីទេសចរណ៍ធម្មជាតិ និងការអភិរក្សធនធានធម្មជាតិ។
- សិក្សាស្រាវជ្រាវដើម្បីរៀបចំសំណើ និងបង្កើតផែនទីក្នុងការបង្កើតបានតំបន់បេតិកភណ្ឌធម្មជាតិ«ភ្នំត្បែង» ខេត្តព្រះវិហារ និងតំបន់បេតិកភណ្ឌធម្មជាតិ«ភ្នំយ៉ាត» ខេត្តប៉ៃលិន។
- សិក្សាស្រាវជ្រាវ និងរៀបចំទិន្នន័យបុរាណស្ថានចំនួន១៥៥កន្លែង និងបានបោះបង្គោលចំនួន៣៥០ ដើម្បីកំណត់ព្រំតំបន់ការពារបុរាណស្ថានចំនួន៣ នៅឧទ្យានជាតិ «ភ្នំគូលែន» និងសិក្សាបុរាណស្ថាននៅដែនជម្រកសត្វព្រៃ«គូលែនព្រហ្មទេព» ខេត្តព្រះវិហារ ចំនួន៨៦កន្លែង និងរកឃើញផូស៊ីលនៅទីនោះ។
- ចូលរួមការពារនិងអភិរក្សប្រសាទ«យ៉ាក់ណាំង» នៅឧទ្យានជាតិវីរៈជ័យ ខេត្តរតនគិរី និងតំបន់ប្រវត្តិសាស្ត្រ ភូមិមូល «ជើងឯក» ឲ្យមាននិរន្តរភាព ដោយសហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ។

# តារាងទី ២.១៨ សូចនាករសំខាន់ៗទាក់ទងនឹងបរិស្ថាន

| ល.រ. | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| ១.ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | | | | | | | | | | | | |
| ១.១. ការអភិវឌ្ឍបៃតង | | | | | | | | | | | | |
| ១ | ចំនួនបុគ្គលិកសហគ្រាសធុនតូច និងមធ្យម និងមន្ត្រីរដ្ឋាភិបាលទទួលបានការបណ្តុះបណ្តាលទាក់ទងនឹងនវានុវត្តន៍បៃតង ស្លាកសញ្ញាបរិស្ថាន (អេកូ) និងវិញ្ញាបនបត្រកម្មស្លាកសញ្ញាបរិស្ថាន និងសេដ្ឋកិច្ចបៃតង | នាក់ | 0 | 0 | 0 | 0 | 0 | 0 | ១១0 | ១៤៥ | ១១0 | ១២0 |
| ២ | ការសិក្សាស្រាវជ្រាវទាក់ទងនឹងថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ) និង/ឬប្រសិទ្ធផលថាមពលសម្រាប់វិស័យឧស្សាហកម្មបានរៀបចំ | បរិមាណ/លើក | 0 | 0 | 0 | 0 | 0 | 0 | ១ | ១ | ២ | ២ |
| ៣ | អាទិភាពគោលនយោបាយសម្រាប់ការអភិវឌ្ឍបៃតងបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ | បរិមាណ/វិស័យ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ៤ | ៤ |
| ១.២ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | | | | | | | | | | | | |
| ១ | របៀបវារៈជាតិស្តីពីការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ គោលនយោបាយ បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | បរិមាណ | 0 | 0 | ១ | ១ | ២ | ២ | ២ | ២ | ២ | ២ |

| ល.រ. | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| ២ | សេវាកម្មនិងបច្ចេកវិទ្យាធានាការអភិវឌ្ឍ និងការទទួលយកបច្ចេកវិទ្យា និងសេវាកម្មបៃតង និងប្រកបដោយការបញ្ចេញកាបូនតិច (អនុវត្តគម្រោងផ្ទេរបច្ចេកវិទ្យា និងការស្រាវជ្រាវ) | ចំនួនគម្រោង | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ១ | ១ |
| ៣ | ចំនួនវគ្គបណ្ដុះបណ្ដាលពង្រឹងចំណេះដឹង និងការយល់ដឹងអំពីវិទ្យាសាស្រ្តបច្ចេកវិទ្យា និងការសិក្សាស្រាវជ្រាវសំដៅធានាការអភិវឌ្ឍដោយនិរន្តរភាព | ចំនួន | ០ | ០ | ០ | ០ | ២ | ២ | ២ | ២ | ៤ | ៣ |
| **២. ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | |
| ១ | ការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹង ផ.ស.ស | % | ១,០៧ | ១,៣ | ១,១ | ១,២ | ១,១៣ | ០,៩ | ១,១៦ | | ១,១៨ | |
| ២ | បញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិនិងក្រោមជាតិ | ក្រសួង/ស្ថាប័ន | ១៣ | ៩ | ១៤ | ១៣ | ១៧ | ១៤ | ១៩ | ១៤ | ២១ | ១៤ |
| ៣ | ចំនួនឃុំងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ | ឃុំ | ៦០០ | ៧៩១ | ៥៥០ | N/A | ៥០០ | ៦៩៥ | ៤៥០ | N/A | ៤០០ | N/A |
| ៤ | ឥណទានកាបូនពីយន្តការអភិវឌ្ឍស្អាត និងយន្តការដទៃទៀត (REDD+ និងទីផ្សារស្ម័គ្រចិត្ត | ($tCO_2e$/yr) | ២ ២៨០ ៣៧៧ | ២ ២២៦ ០៦១ | ២ ៣៣៤ ៦៥០ | ២ ២២៦ ០៦១ | ២ ៣៨៨ ៨១៤ | ៧ ៣៥០ ៩៣៤ | ២ ៤៤៣ ០៤០ | N/A | ២ ៤៩៧ ២៧៥ | N/A |
| **៣. ជីវៈចម្រុះនិងជីវសុវត្ថិភាព** | | | | | | | | | | | | |
| ១ | ចំនួនក្រសួង ស្ថាប័ន បានទទួលការផ្សព្វផ្សាយ ពីបញ្ហាជីវៈចម្រុះ | ក្រសួង/ស្ថាប័ន | ១០ | ១៥ | ១៦ | ២០ | ១៦ | ២២ | ១៨ | ២១ | ១៥ | ១៦ |
| ២ | ចំនួន នៃការសិក្សាស្រាវជ្រាវគោលនយោបាយ ច្បាប់ គោលការណ៍ណែនាំ របាយការណ៍ជាតិ និង | ចំនួន | ៣ | ៦ | ៥ | ៦ | ៧ | ១០ | ១៥ | ២៩ | ២ | ៣ |

| ល.រ. | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| | ប្រព័ន្ធព័ត៌មាន ទាក់ទងនឹងជីវៈចម្រុះ ជីវសុវត្ថិភាព និងការបែងចែកផលប្រយោជន៍ពីធនធានជីវៈចម្រុះ | | | | | | | | | | | |
| ៣ | ចំនួននៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធ | ស្ថាប័ន | ១ | ២ | ២ | ២ | ៣ | ៤ | ៣ | ៦ | ២ | ១៥ |
| ៤ | ចំនួនវគ្គកសាងសមត្ថភាព និងផ្សព្វផ្សាយ | ចំនួនវគ្គ | ៣ | ៥ | ៨ | ១២ | ៩ | ១៣ | ៨ | ៧ | ៤ | ៨ |
| **៥. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ** | | | | | | | | | | | | |
| ១ | តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ជីវៈចម្រុះ | កន្លែង | ២៣ | ២៣ | ៤១ | ៤១ | ៤៥ | ៤៥ | ៤៩ | ៤៩ | ៥៣ | ៥៣ |
| ២ | មន្ត្រីឧទ្យានុរក្ស | នាក់ | ៩៦០ | ៩៦០ | ៩៦០ | ៩៦០ | ៩៦០ | ៩៦០ | ៩៦០ | ៩៦០ | ១ ២២១ | ១ ២២១ |
| ៣ | ការកំណត់ព្រំប្រទល់ និងផែនទី សម្រាប់តំបន់ការពារធម្មជាតិ | បង្គោល | ១ ០៥០ | ១ ០៥០ | ១០៥០ | ១ ០៥០ | ១ ៦៥០ | ១ ៦៥០ | ១ ៧០៤ | ១ ៧០៤ | ២ ១៥៩ | ២ ១៥៩ |
| ៤ | តំបន់រាមសារ | កន្លែង | ៣ | ៣ | ៣ | ៣ | ៤ | ៤ | ៤ | ៤ | ៤ | ៤ |

*ប្រភព :* ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## បញ្ហាប្រឈម

- គោលនយោបាយ និងច្បាប់ដែលចាំបាច់នានា ក្នុងការធានានិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន មិនទាន់មានគ្រប់គ្រាន់តាមតម្រូវការបច្ចុប្បន្ន និងអនាគត។
- សមត្ថភាពស្ថាប័ន និងជំនាញក្នុងការសម្របសម្រួល និងបន្ស៊ីការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព មិនទាន់មានប្រសិទ្ធភាពនិងប្រសិទ្ធផល។
- ការយល់ដឹង និងការចូលរួមពីវិស័យសាធារណៈ និងឯកជន នៅក្នុងការអភិវឌ្ឍដោយចីរភាពពុំទាន់មានភាពទូលំទូលាយ
- កិច្ចសហប្រតិបត្តិការ និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍមិនទាន់ឆ្លើយតបតាមសេចក្តីត្រូវការគោលនយោបាយនិងផែនការយុទ្ធសាស្ត្រដែលបានដាក់ឲ្យអនុវត្ត។

- ការបញ្ជ្រាបគោលការណ៍គ្រឹះនៃការអភិវឌ្ឍដោយចីរភាព ជាអាទិ៍ បញ្ហាប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចបៃតង ជីវៈចម្រុះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ទៅក្នុងផែនការសកម្មភាពតាមវិស័យ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ។
- លិខិតបទដ្ឋានគតិយុត្តលើកិច្ចគាំពារបរិស្ថាននៅមិនទាន់គ្រប់គ្រាន់
- ខ្វះឧបករណ៍សម្ភារបច្ចេកទេស និងមធ្យោបាយធ្វើប្រព្រឹត្តកម្មសំណល់ ប្រកបដោយសុវត្ថិភាពបរិស្ថាន
- សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងសំណល់ទីប្រជុំជនក្រុងស្រុក នៅមានកម្រិត
- ការយល់ដឹង និងការចូលរួមរបស់សាធារណជន និងអ្នកពាក់ព័ន្ធ លើកិច្ចគាំពារបរិស្ថាន នៅមានកម្រិត។
- ការដោះស្រាយទំនាស់ការប្រើប្រាស់ដីនៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ នៅមិនទាន់ដោះស្រាយបានទាំងស្រុង
- កង្វះខាតព័ត៌មាន និងទិន្នន័យអំពីជីវៈចម្រុះ និងធនធានធម្មជាតិ
- មិនទាន់មានផែនការគ្រប់គ្រង និងការបែងចែក និងកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារ ធម្មជាតិឲ្យបានគ្រប់តំបន់ការពារធម្មជាតិ ដើម្បីប្រសិទ្ធភាពការពារ ការគ្រប់គ្រង និងអភិរក្ស ធនធានធម្មជាតិ និងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ។
- ពុំទាន់មានមជ្ឈមណ្ឌលធនធានសម្រាប់ធ្វើជាមជ្ឈមណ្ឌលមូលដ្ឋានក្នុងការផ្តល់ចំណេះដឹងនិងព័ត៌មានបរិស្ថាន
- ដៃគូគាំទ្រនិងសហការលើការងារអប់រំបរិស្ថាន ផ្សព្វផ្សាយព័ត៌មាន និងរៀបចំរបាយការណ៍ស្ថានភាពបរិស្ថាន នៅមានកម្រិត
- ការដោះស្រាយផលប៉ះពាល់ដីធ្លីវិនិយោគជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- ក្រុមហ៊ុនមួយចំនួននៅមិនទាន់មានកិច្ចសហការបានល្អជាមួយក្រសួងបរិស្ថាន
- ក្រុមហ៊ុនមួយចំនួនមិនទាន់បានបំពេញនីតិវិធីច្បាប់ពេញលេញនិងចប់សព្វគ្រប់នៅឡើយ
- ការអនុវត្តសកម្មភាពវិនិយោគមួយចំនួនមានការយឺតយ៉ាវ
- ហេដ្ឋារចនាសម្ព័ន្ធមិនទាន់ត្រូវបានតភ្ជាប់ទៅតំបន់ទេសចរណ៍មួយចំនួន
- ខ្វះការតភ្ជាប់គម្រោងវិនិយោគទេសចរណ៍ធម្មជាតិ និងសហគមន៍ទេសចរណ៍
- ការអនុវត្តច្បាប់នៅមានកម្រិត

## ការគ្រប់គ្រងគ្រោះមហន្តរាយ

២.៩៦- **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- រៀបចំបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការផ្សព្វផ្សាយ និងការអនុវត្តច្បាប់គ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា។
- វិភាគ និងរៀបចំទិន្នន័យបំបែកលើការបាត់បង់និងការខូចខាត ដោយគ្រោះមហន្តរាយក្នុងអំឡុងឆ្នាំ(២០០៥-២០១៧)។
- រៀបចំបង្កើតវេទិកាប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ ជាយន្តការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យ ការរាយការណ៍ លំហូរ និងការវិភាគព័ត៌មានសម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដើម្បីធ្វើសេចក្ដីសម្រេចចិត្ត ផ្អែកតាមព័ត៌មានពេលវេលាពិតនិងទាន់ពេល។
- រៀបចំច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយ និង រៀបចំបង្កើតនិងអនុវត្តប្រព័ន្ធប្រកាសឲ្យដឹងមុននៃព្រឹត្តិការណ៍គ្រោះមហន្តរាយ “EWS ១២៩៤” ។
- ធ្វើបច្ចុប្បន្នភាព និងប្រកាសឲ្យប្រើប្រាស់ ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨។
- ទិន្នន័យនៃការបាត់បង់ និងខូចខាតដោយគ្រោះមហន្តរាយនៅកម្ពុជាត្រូវបានបង្កើតឡើង។
- បង្កើតក្រុមការងារសម្របសម្រួលសម្រាប់ការត្រៀមរៀបចំការឆ្លើយតបសង្គ្រោះបន្ទាន់និងការស្ដារឡើងវិញ។
- រៀបចំផែនការសកម្មភាពស្ដីពីការប្រែប្រួលអាកាសធាតុសម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយ ២០១៤-២០១៨។

## បញ្ហាប្រឈម

- សមត្ថភាពនៅមានកម្រិត(ព័ត៌មាន និងការតាមដានត្រួតពិនិត្យគ្រោះមហន្តរាយ ការប៉ាន់ប្រមាណហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ)។
- មានក្រសួង ស្ថាប័ន មួយចំនួនតូចប៉ុណ្ណោះ បានរៀបចំបង្កើតអង្គភាព/យន្តការគ្រប់គ្រងគ្រោះមហន្តរាយ និងជ្រើសតាំងមន្ត្រីបង្គោលសម្រាប់កិច្ចសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនិងផលិតភាព។
- ការផ្ដល់ហិរញ្ញប្បទាន និងការវិនិយោគ(គ្មានការវិភាជថវិកាជាក់លាក់សម្រាប់ការអនុវត្តសកម្មភាពកម្មវិធី កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការទប់ស្កាត់និងការត្រៀមរៀបចំគ្រោះមហន្តរាយ និងការស្ដារឡើងវិញប្រកបដោយប្រសិទ្ធភាព ការវិនិយោគរបស់សាធារណៈនិងវិស័យឯកជន ការធានារ៉ាប់រងហានិភ័យ)។
- បញ្ហាប្រឈមលើអភិបាលកិច្ច និងការធ្វើមូលដ្ឋាននីយកម្ម(រួមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមមូលដ្ឋានសហគមន៍)។
- ការប្រែប្រួលនៃទម្រង់ហានិភ័យ(ដោយសារការអភិវឌ្ឍយ៉ាងឆាប់រហ័ស)។

- ខ្វះខាតទិន្នន័យ និងបច្ចេកវិទ្យា ក្នុងការប្រកាសឲ្យដឹងមុនប្រកបដោយប្រសិទ្ធភាព និងការធ្វើវិភាគនិងបកស្រាយឲ្យទៅជាសកម្មភាពមុនហេតុការណ៍។
- ខ្វះខាតលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលការណ៍ណែនាំ សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយឲ្យស្របទៅនឹងនិន្នាការអភិវឌ្ឍក្នុងតំបន់និងពិភពលោក។

## ការអភិវឌ្ឍជនបទ

### ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

២.៩៧- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទបានអនុវត្តសម្រេចបាននូវសមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

**តារាងទី ២.១៩ សូចនាករវាស់វែងវឌ្ឍនភាពពីឆ្នាំ ២០១៤-២០១៨**

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ១ | ការស្តារ និងសាងសង់ផ្លូវជនបទ( លើប្រវែងផ្លូវសរុប ៤0 000 គ.ម.) | ២៨ ៦00 | ២៨ 0៣0 | ២៩ ៤៥0 | ២៨ ២៨៤,៥ | ៣0 ៣00 | ២៨ ៥៧៨,៧ | ៣១ ១៥0 | ២៨ ៩៦១,៦ | ៣២ 000 | ២៩ ១៧២,៤ |
| ២ | ផ្លូវជនបទដែលបានក្រាលកៅស៊ូពីជាន់ ឬបេតុង | ៥៥0 | ២0,៥៨ | ៩៨0 | ៦៩,២៣ | ១ ៤៣0 | ៤៧,៨ | ១ ៨៨0 | ៨៦,៦៨ | ២ ៣៣0 | ៦៥,៩៥ |
| ៣ | ថែទាំផ្លូវជាលក្ខណខួប និងប្រចាំ | ២ ៩00 | ៨១៨,៦៥ | ២ ៩00 | ៨២0,៦៦ | ២ ៩00 | ១ ២៨១,៤៣ | ២ ៩00 | ១ ៦៧៤,៩៥ | ២ ៩00 | ១ ៧១៥,៣៤ |
| ៤ | ការរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ ផែនទីផ្លូវជនបទ និងការដាក់ស្លាកចរាចរ | ៤0 ៦៩២,៨ | ៣៣ ៩៦២,១ | ៤0 ៦៩២,៨ | ៤៨ ២៩៦,៣ | ៤0 ៦៩២,៨ | ៤២ ៨៤៨ | ៤0 ៦៩២,៨ | ៤៥ ១១២,៨ | ៤0 ៦៩២,៨ | ៤៥ ៣១៤,៧ |

### ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត

ការងារទឹកស្អាតបានអនុវត្តសម្រេចបាននូវសមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

| សូចនាករ | ផែនការ/អនុវត្តបាន | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ភាគរយនៃប្រជាពលរដ្ឋជនបទ ទទួលបានការផ្គត់ផ្គង់ទឹកជនបទ ដែលមានការកែលម្អ | ផែនការ (%) | ៤៦ | ៥០ | ៥៣ | ៥៦ | ៦០ |
| | អនុវត្តបាន (%) | ៤៦,៦ | ៥០,៣ | ៥៣,៩ | ៥៨ | ៦២ |

## ការងារអនាម័យជនបទ

ការងារអនាម័យជនបទ បានសម្រេច សមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ១ | ភាគរយប្រជាជនជនបទ ទទួលបានសេវាអនាម័យ ដែលមានការ កែលម្អប្រកបដោយនិរន្តរភាព | ៤២ | ៤៦,២ | ៤៦ | ៥៣,៧ | ៥០ | ៥៦,៧ | ៥៥ | ៥៨,៨ | ៦០ | ៦០ |

## ការអភិវឌ្ឍសហគមន៍

ការអភិវឌ្ឍសហគមន៍បានអនុវត្តសម្រេចបាននូវសមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ១ | រៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាព គ.អ.ភ (លើក) | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ០ |
| ២ | បណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គអភ)(វគ្គ) | ០ | ២២៦ | ០ | ២២២ | ២១៥ | ១៨០ | ២៦០ | ១០១ | ១៦៨ | ២៨ |
| ៣ | ការគាំទ្រដល់ការអភិវឌ្ឍភូមិចម្រុះ(ភូមិ) | ៧ | ៧ | ៥ | ៥ | ៦ | ៦ | ៥ | ៥ | ៥ | ០ |

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ៤ | ការបញ្ជ្រាបការយល់ដឹងស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមន្តរាយក្នុងសហគមន៍(នាក់) | 0 | ១០៥ | 0 | ៤២០ | 0 | ៤៩0 | 0 | ៥២៥ | 0 | |
| ៥ | ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ(គ្រួសារ) | 0 | ២២០ | 0 | ២០០ | 0 | ២ ៨៣០ | 0 | ៣២០ | 0 | |
| ៦ | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍជនបទខេត្តតាកែវ (នាក់) | 0 | ៥៤៩ | 0 | ៧១២ | 0 | ៥៣០ | 0 | ៧០០ | 0 | |
| ៧ | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍជនបទខេត្តកំពង់ស្ពឺ (នាក់) | 0 | ៥១៨ | 0 | ៥៦៨ | 0 | ៧២៧ | 0 | ៧២៧ | | |
| ៨ | ពង្រឹងមជ្ឈមណ្ឌអភិវឌ្ឍជនបទកម្ពុជា-កូរ៉េ (វគ្គ) | | | | | | | | | ៨ | 0 |

## ការងារសេដ្ឋកិច្ចជនបទ

ការងារសេដ្ឋកិច្ចជនបទបានអនុវត្តសម្រេចបាននូវសមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ១ | ប្រជាពលរដ្ឋដែលបានបណ្តុះបណ្តាលបច្ចេកទេសឡជីវឧស្ម័ន និង បង្កើតមុខរបរអាជីវកម្មខ្នាតតូច(នាក់) | ២៣៤ | ២៣៤ | ៨០ | ៨០ | ១១០ | ១១០ | ៧៥ | ៧៥ | ៦៦ | 0 |
| ២ | ប្រជាពលរដ្ឋសហគមន៍ទទួលប្រឹក្សាពីទីផ្សារការងារ និងផ្តត់គំនិត អាជីវកម្មខ្នាតតូច(នាក់) | ២១០ | ២១០ | ៤០១ | ៤០១ | ៣១១ | ៣៣១ | ១ ៤១៩ | ១ ៤១៩ | ១០០ | 0 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣ | ប្រជាពលរដ្ឋ/សហគមន៍ ទទួលសេវាឥណទាន ជនបទ (នាក់) | ៥ ៩២៣ | ៥ ៩២៣ | ៥ ៤៣៨ | ៥ ៤៣៨ | ៥ ៧២៩ | ៥ ៧២៩ | ៥ ៩៣៣ | ៥ ៩៣៣ | ១២ | ០ |

## ការអភិវឌ្ឍជនជាតិដើមភាគតិច

ការអភិវឌ្ឍជនជាតិដើមភាគតិចបានអនុវត្តសម្រេចបាននូវសមិទ្ធផលជាច្រើនដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សូចនាករ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង |
| ១ | វាយតម្លៃកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច (៤៥០) សហគមន៍ | | ១០០ | ២០ | ១០ | ២០ | ១០ | ២៥ | ១០ | ២០ | ១១ |
| ២ | សិក្ខាសាលាផ្សព្វផ្សាយ និងពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៤ | ២ | ៤ | ២ | ៤ | ២ | ៤ | ២ | ៤ | ២ |
| ៣ | ប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ |
| ៤ | រៀបចំបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច (៤៥០)សហគមន៍ | ១០ | ៥ | ១០ | ៥ | ១០ | ៥ | ១០ | ៥ | ១០ | ៥ |

## បញ្ហាប្រឈម

២.៩៨- ការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យប៉ះពាល់ដល់ចីរភាពរបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ហើយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជនបទបានធ្វើឲ្យមានការខ្វះកម្លាំងពលកម្មនៅតំបន់ជនបទ។ កំណើនយានយន្ត ការដឹកលើសទម្ងន់កំណត់ និងបើកលើសល្បឿនកំណត់ធ្វើឲ្យផ្លូវជនបទឆាប់ខូច និងមានគ្រោះថ្នាក់ចរាចរណ៍កើនឡើងជាញឹកញាប់ និងមិនទាន់

មានការចូលរួមថែទាំផ្លូវជនបទពីថ្នាក់សហគមន៍និងអ្នកប្រើប្រាស់ផ្លូវឲ្យបានពេញលេញ។ ការយល់ដឹងពីអនាម័យនៅតាមជនបទនៅមានកម្រិត និងការចូលរួមថែទាំអណ្តូងទឹក ស្រះទឹកពីសហគមន៍នៅមានកម្រិត។

### ភូមិមួយ ផលិតផលមួយ

២.៩៩- ក្នុងនីតិកាលទី៥នៃរដ្ឋសភា **ចលនាភូមិមួយផលិតផលមួយ** ដែលដឹកនាំដោយគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានធ្វើសមាហរណកម្មចូលមកក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងសម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- គោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ ត្រូវបានអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ និងបានប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កាលពីឆ្នាំ២០១៧។
- បង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ឆ្នាំ២០១៧។
- រៀបចំសមាសភាពគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ។
- រៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានភ១.ផ១. និងនាយកដ្ឋានចំណុះចំនួន៤។
- កំណត់យកថ្ងៃទី៩ ខែមេសា ជារៀងរាល់ឆ្នាំ ដើម្បីរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ ក្នុងគោលបំណងឲ្យប្រជាជនកម្ពុជាបានយល់ដឹងនិងទិញទំនិញប្រើប្រាស់ជាផលិតផលខ្មែរនៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់យើង។

### បញ្ហាប្រឈម

- ការគាំទ្រពីអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ការងារជំរុញចលនាភូមិមួយផលិតផលមួយនៅមានកម្រិត។
- កិច្ចសហការនិងការសម្របសម្រួលរវាងអគ្គលេខាធិការដ្ឋានភ១.ផ១. និងក្រសួងពាក់ព័ន្ធជា សមាជិកនៃ គ.ជ.ភ១.ផ១. នៅមានកម្រិត។
- ខ្វះហិរញ្ញប្បទានសម្បទាន ឬឥណទានដែលមានអត្រាការប្រាក់ទាបដល់សមាគម សហគមន៍អ្នកផលិត និងផលិតករ។
- ការយល់ដឹងរបស់ប្រជាជនខ្មែរនៅលើការប្រើប្រាស់ផលិតផលខ្មែរនៅមានកម្រិត។
- ខ្វះកិច្ចសហការគ្នារវាងស្ថាប័ន សហគ្រាសខ្នាតតូចនិងមធ្យមជាមួយនឹងអគ្គលេខាធិការដ្ឋានភ១.ផ១. លើការងារជំរុញ និងលើកកម្ពស់ផលិតផលខ្មែរ ភូមិមួយផលិតផលមួយ។
- មានគម្លាតធំនៃការប្រកួតប្រជែងរវាងផលិតផលខ្មែរ និងផលិតផលបរទេសនៅក្នុងការតាំងពិព័រណ៍លក់ផលិតផលតាមរាជធានី ខេត្ត ក្រុង ស្រុក។

## ៥- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## ៥.១- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

២.១០០- ដោយមានកិច្ចខំប្រឹងប្រែង និង មានការចូលរួមសហការពីគ្រប់ក្រសួង ស្ថាប័ន យើងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

### ១- ការងារច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកំណែទម្រង់

- ច្បាប់ស្តីពីផ្លូវថ្នល់ ត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ២០១៤ និង ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ២០១៥។
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមក្នុងឆ្នាំ២០១៧។
- ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្មក្នុងឆ្នាំ២០១៧។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងឆ្នាំ២០១៦។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងឆ្នាំ២០១៧។
- ប្រកាសរៀបចំបែបបទ និងនីតិវិធីសម្រាប់ការចូលរបស់នាវានៅតាមកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១៧។
- ប្រកាសក្នុងឆ្នាំ២០១៧ស្តីពី ១.សន្តិសុខបបនីយភណ្ឌផែនៃព្រះរាជាណាចក្រកម្ពុជា ២. បែបបទនិងនីតិវិធីនៃការចេញបណ្ណបើកបរនិងបណ្ណពិន្ទុ ៣. បែបបទនិងនីតិវិធីនៃការផ្តល់ស្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះគ្រប់ប្រភេទ ៤.លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ៥.លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស និង ៦.ធ្វើនិយ័តកម្មប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានជំនាញ អង្គភាពជំនាញ និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត។

### ២- ការងារកំណែទម្រង់

- ធ្វើការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងដោយបន្ថែមអគ្គនាយកដ្ឋានមួយចំនួន ដើម្បីបំពេញតាមតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។

- បន្តប្រកាន់ខ្ជាប់នូវការផ្តល់អាទិភាពដល់ការលើកកម្ពស់ប្រសិទ្ធភាពទាំងការអនុវត្តគោលនយោបាយ ទាំងការបង្កើតយន្តការចាំបាច់ ដើម្បីផ្តល់សេវាជូនប្រជាជនកាន់តែមានភាពស័ក្តិសិទ្ធិជាងមុន។
- កំពុងបន្តអនុវត្តកំណែទម្រង់ទាំងបី របស់រាជរដ្ឋាភិបាល រួមមាន៖ ១. កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ២.កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ៣.កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- កំពុងបន្តអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីផ្តល់សេវាសាធារណៈលើការងារដឹកជញ្ជូន ដើម្បីលុបបំបាត់ចំណាយក្រៅផ្លូវការ នីតិវិធីស្មុគស្មាញ តម្លាភាព ឆាប់រហ័ស និងជឿទុកចិត្ត បង្កិតសេវាទៅជិតប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព

### ៣-រៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤

កំពុងត្រៀមការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃ៖

- បន្តចុះបញ្ជីតាមអនឡាញឲ្យកាន់តែមានប្រសិទ្ធភាព
- អនុញ្ញាតឲ្យមានការដឹកជញ្ជូនតាមវិធីការដឹកជញ្ជូនចែករំលែក ដូចជា Grab និង Pass App ជាដើម
- កំពុងរៀបចំ និងដាក់ប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ
- រៀបចំដាក់ឲ្យដំណើរការកម្មវិធីអេប(App) សម្រាប់ការចូលរួមកម្មវិធីថែទាំផ្លូវថ្នល់
- កំពុងសិក្សារៀបចំដាក់ឲ្យដំណើរការកម្មវិធីអេប សម្រាប់ដីចំណីផ្លូវ(ជប៉ុន)
- កំពុងសិក្សាលទ្ធភាពសាងសង់ប្រព័ន្ធរថភ្លើងស្វ័យប្រវត្តិកម្ម នៅរាជធានីភ្នំពេញ

### ៤. ការងារស្ពាន និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

- ស្ពាន និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដូចជាផ្លូវជាតិកម្រិត១ ផ្លូវជាតិកម្រិត២ ផ្លូវខេត្ត ផ្លូវជាតិ៤គន្លង ស្ពានធំៗ ។
- ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងត្រូវបញ្ចប់ក្នុងអាណត្តិទី៥(២០១៤-២០១៨)។
- បញ្ចប់ការសិក្សាផែនការមេអភិវឌ្ឍផ្លូវល្បឿនលឿននិងផែនការបណ្តាញផ្លូវថ្នល់នៅព្រះ-រាជាណាចក្រកម្ពុជា
- ដំណើរការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុប្រវែង១៩០គ.ម. និងបានបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាព កំពុងស្វែងរកប្រភពថវិកាផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-បាវិត និងភ្នំពេញ-សៀមរាប

### ៥- ការងារផ្លូវដែក

- ខ្សែផ្លូវភាគខាងត្បូង(រាជធានីភ្នំពេញ-ក្រុងព្រះសីហនុ) បានស្តារនិងសាងសង់រួច(ដោយហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី ហិរញ្ញប្បទានឥតសំណងអូស្ត្រាលី អង្គការអូហ្វិត ម៉ាឡេស៊ី និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល) បច្ចុប្បន្ន កំពុងដំណើរការចរាចរណ៍ដឹកទំនិញ និងអ្នកដំណើរទេសចរណ៍។
- ខ្សែផ្លូវភាគខាងជើង(រាជធានីភ្នំពេញ-ប៉ោយប៉ែត) បានស្តារនិងសាងសង់រួច(ថវិកាជាតិ) បច្ចុប្បន្នបាន កំពុងដំណើរការចរាចរណ៍ ដឹកជញ្ជូនអ្នកដំណើរ និងបានតភ្ជាប់ផ្លូវដែកកម្ពុជាថៃ។
- សាងសង់និងបើកឱ្យប្រើប្រាស់ផ្លូវដែកពីស្ថានីយធំ រាជធានីភ្នំពេញទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញសម្រាប់អ្នកដំណើរ។
- ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់តាមព្រំដែនតាមផ្លូវដែកកម្ពុជា ថៃ។
- កំពុងសិក្សាលទ្ធភាពសាងសង់ប្រព័ន្ធរថភ្លើងស្វ័យប្រវត្តិកម្ម និងសិក្សាលទ្ធភាពសាងសង់ត្រាំវ៉េ នៅរាជធានីភ្នំពេញ។
- បញ្ចប់ការសិក្សា ផែនការមេអភិវឌ្ឍផ្លូវដែកនៅព្រះរាជាណាចក្រកម្ពុជាដែលជាជំនួយបច្ចេកទេសពីសាធារណរដ្ឋកូរ៉េ។

## ៦. ការងារភស្តុភារកម្ម(ឡូជីស្ទីក)

- កម្ពុជាទទួលបានចំណាត់ថ្នាក់កាន់តែប្រសើរលើផ្នែកភស្តុភារកម្មពីលេខ១២៩ ក្នុងឆ្នាំ ២០១០ មកត្រឹមលេខ៧៣ នៅឆ្នាំ២០១៦ នឹងអាចឡើងដល់ចំណាត់ថ្នាក់ទី៥៣ ក្នុងឆ្នាំ ២០២៥ (សន្ទស្សន៍នៃការវាយតម្លៃរបស់ធនាគារពិភពលោក)។
- រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥ ដែលក្នុងនោះមានផែនការ និងការអនុវត្តផែនការមេដឹកជញ្ជូន និងភស្តុភារកម្មផ្សារភ្ជាប់នៅតំបន់ច្រកសេដ្ឋកិច្ចសំខាន់ៗ។
- បង្កើតនូវអគ្គនាយកដ្ឋានភស្តុភារកម្ម ដែលជាអង្គភាពផ្តួចផ្តើមរៀបចំជំរុញឱ្យមានរចនាសម្ព័ន្ធជាក់លាក់ក្នុងការរៀបចំ គ្រប់គ្រង តាមដាន និងអភិវឌ្ឍភស្តុភារកម្មនៅកម្ពុជា។
- សិក្សារៀបចំផែនការមេភស្តុភារកម្ម ត្រូវបានបញ្ចប់នាដំណាច់ខែមីនា ឆ្នាំ២០១៨ ដោយគោលបំណងគន្លឹះក្នុងការរៀបចំផែនការមេគឺៈ ១.បង្កើតកាលានុវត្តអភិវឌ្ឍនិងការវិនិយោគក្នុងវិស័យកំណើនថ្មី ២.ទាក់ទាញវិនិយោគទុននិងបង្កើតការងារថ្មី ៣.កាត់បន្ថយការកកស្ទះចរាចរណ៍នៅជាយក្រុង និងក្នុងរាជធានីភ្នំពេញជាពិសេសការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវាងក្រៅក្រុង ៤. កាត់បន្ថយការចំណាយភស្តុភារកម្ម។
- កំពុងរៀបចំផែនការមេដឹកជញ្ជូននិងភស្តុភារកម្មថ្នាក់ជាតិ។
- អនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេស “គម្រោងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធភស្តុភារកម្ម” ដែលគាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ២០១៨-២០២២

## ៧. ការខារដឹកជញ្ជូនផ្លូវគោក ដឹកជញ្ជូនសាធារណៈក្រុង និងសុវត្ថិភាពចរាចរណ៍

- មានមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចំនួន១៤មណ្ឌល និងរថយន្តត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័តចំនួន៣គ្រឿង។
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម និងរៀបចំប្រព័ន្ធQR Code ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារសេវាដឹកជញ្ជូនផ្លូវគោក។
- កំពុងធ្វើសមាហរណកម្មការចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងស្លាកលេខយានយន្តជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។
- ធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្ម ផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋអាចជ្រើសរើសលេខ និងដាក់ពាក្យចុះបញ្ជីយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមប្រព័ន្ធអនឡាញ
- សហការបច្ចេកទេសរៀបចំកម្មវិធីម៉ូបាលអេប(Mobile App) យល់ដឹងពីទ្រឹស្តីនៃការបើកបរនិងច្បាប់ចរាចរណ៍ផ្លូវគោក និងត្រួតពិនិត្យព័ត៌មានយានយន្ត និងបណ្ណបើកបរសម្រាប់មន្ត្រីសមត្ថកិច្ចជំនាញជាអ្នកប្រើប្រាស់។
- កាត់បន្ថយថ្លៃឈ្នួលដឹកជញ្ជូន ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ សម្រាប់៖
  - កំពង់ផែស្វយ័តក្រុងព្រះសីហនុបញ្ចុះតម្លៃ១០% និងកំពង់ផែស្វយ័តភ្នំពេញបញ្ចុះតម្លៃ៥% នៃតម្លៃសេវាលើកដាក់កុងតឺន័រនៅទីលានកុងតឺន័រ
  - ភ្នាក់ងារកម្ពុជានាវាចរ “កាំសាប” បញ្ចុះតម្លៃ ១០% នៃតម្លៃសេវាកត់ត្រាកុងតឺន័រលើសម៉ោង និង ១០% ទៀត នៃតម្លៃត្រួតពិនិត្យកុងតឺន័រនៅពេលលើកដាក់នៅនាវា
  - សមាគមរថយន្តដឹកជញ្ជូនទំនិញកម្ពុជា បានកាត់បន្ថយកម្រៃសេវា១០ដុល្លារអាមេរិកក្នុងមួយកុងតឺន័រ សម្រាប់បណ្តោយ ៤០ហ្វីត និង ៥ដុល្លារអាមេរិក ក្នុងមួយកុងតឺន័រសម្រាប់បណ្តោយ ២០ហ្វីត។

### ការតភ្ជាប់ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

- មានភាពជឿនលឿនក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជាមួយប្រទេសក្នុងតំបន់ ក្នុងនោះបាននឹងកំពុងពង្រឹង និង ពង្រីកការលើកកម្ពស់កម្រិតគុណភាពស្តង់ដាផ្លូវថ្នល់។
- ស្តារ សាងសង់ និងតភ្ជាប់ទាំងស្រុងជាមួយប្រទេសជិតខាង និងសមាហរណកម្មតំបន់(សម្រាប់ស្តង់ដាអាស៊ានកម្ពុជាមិនមានផ្លូវក្រោមកម្រិត៣ ទៀតទេ)។
- កំពុងសាងសង់លើកកម្រិតខ្សែផ្លូវអាស៊ានមួយចំនួនជាស្តង់ដាកម្រិត១ (៤គន្លងផ្លូវ ប្រភេទ AC) ដូចជាផ្លូវជាតិលេខ៥ ត្រៀមបញ្ចប់ឆ្នាំ២០២០។
- ចូលរួមអនុវត្តគំនិតផ្តួចផ្តើមនានាក្នុងវិស័យដឹកជញ្ជូន ដូចជា ខ្សែក្រវាត់មួយ ផ្លូវមួយ ជាដើម។
- ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ស្តីពីការតភ្ជាប់ផ្លូវល្បឿនលឿន និង កិច្ចសហការជាយុទ្ធសាស្ត្រលើវិស័យដឹកជញ្ជូនឆ្នាំ២០១៨-២០២៥ និងចក្ខុវិស័យឆ្នាំ២០៣០ជាមួយវៀតណាម។

- បញ្ចប់ការសិក្សាលទ្ធភាពសម្រាប់គម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេពៅ (ខេត្តព្រះវិហារ) /សេឡាំផាវ(ខេត្តចម្ប៉ាសាក់ប្រទេសឡាវ) និងផ្លូវតភ្ជាប់ កំពុងចរចារសាងសង់។
- ក្នុងក្របខ័ណ្ឌអនុស្សារណៈ នៃការយោគយល់ស្តីពីការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ដឹកជញ្ជូនឆ្លងកាត់ព្រំដែនជាមួយប្រទេសឡាវអនុវត្តកូតាយានយន្ត៤០គ្រឿង ជាមួយប្រទេសវៀតណាមអនុវត្ត៥០០គ្រឿង ជាមួយប្រទេសថៃ១៥០គ្រឿង និងក្នុងក្របខ័ណ្ឌបីប្រទេសរវាងកម្ពុជា ឡាវ វៀតណាម អនុវត្តកូតាយានយន្តចំនួន១៥០គ្រឿង។
- កំពុងអនុវត្តគម្រោងសាកល្បងប្រព័ន្ធឆ្លងកាត់គយអាស៊ាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ដែលជាច្រករបៀងខាងកើត-លិចនៃអាស៊ាន បន្ទាប់ពីការអនុវត្តគម្រោងសាកល្បងនៅប្រទេសសឹង្ហបូរី ថៃ និងម៉ាឡេស៊ី ដែលជាច្រករបៀងខាងជើង-ត្បូងនៃអាស៊ាន ក្រោមជំនួយបច្ចេកទេសពីសហគមន៍អឺរ៉ុប ស្តីពីការរៀបចំប្រព័ន្ធឆ្លងកាត់គយ។
- ក្នុងក្របខ័ណ្ឌអាស៊ានកិច្ចព្រមព្រៀងស្តីពីការសម្របសម្រួលការដឹកជញ្ជូនអ្នកដំណើរតាមរថយន្ត។
- ក្របខ័ណ្ឌមហាអនុតំបន់មេគង្គ បានចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវគោកបណ្តោះអាសន្ន សម្រាប់រថយន្តពាណិជ្ជកម្ម ចំនួន៥០០គ្រឿង
- ជារួមផ្នែករឹងនៃបណ្តាញផ្លូវថ្នល់កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការតភ្ជាប់ ដោយឡែកនៅមានបញ្ហាផ្នែកទន់ដែលជាបញ្ហារួមរបស់អាស៊ានទាំងមូលដែលត្រូវការពេលវេលា។

## ៨. ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

### ការផ្តល់សេវាសាធារណៈ

**នាវាជំនួញសមុទ្រ**

- ធ្វើកិច្ចសហប្រតិបត្តិការត្រីភាគី ដើម្បីអភិវឌ្ឍនាវាតំបន់ឆ្នេរ កម្ពុជា ថៃ និងវៀតណាម
- ចូលរួមសហប្រតិបត្តិការថ្នាក់តំបន់ប្រយុទ្ធប្រឆាំងអំពើប្លន់នៅតាមសមុទ្រ និងការប្លន់ប្រដាប់អាវុធលើនាវានៅតំបន់អាស៊ី និងបណ្តាប្រទេសជាសមាជិក
- ចូលរួមសហការជាមួយមជ្ឈមណ្ឌលសម្របសម្រួលបច្ចេកវិទ្យាដឹកជញ្ជូន តាមផ្លូវសមុទ្រដើម្បីទទួលចំណេះដឹងក្នុងការបង្កើតបទប្បញ្ញត្តិ និងគ្រប់គ្រងនាវា និងនាវិក។

**ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ**

- សិក្សាទិន្នន័យផលិតផែនទីជលមាគ៌ានាវាចរណ៍ផ្លូវទន្លេ និងតំបន់សមុទ្រ។
- សិក្សាគម្រោងសម្រាប់សាងសង់កំពង់ផែ ស្រុកសំបូរ ខេត្តក្រចេះ កំពង់ផែស្អាង ឃុំព្រែកគយ ស្រុកស្អាង និងផែឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល និងកំពង់ផែ ក្រុងបានលុង ខេត្តរតនគិរី។
- សិក្សាគម្រោងសាងសង់ផែពហុបំណងត្បូងឃ្មុំ(ទន្លេបិទ)។
- សិក្សាវាស់ស្ទង់ជម្រៅទឹក និងបោះបង្គោលពោងស្លាកសញ្ញានាវាចរណ៍តាមដងទន្លេបាសាក់ ពីភ្នំពេញទៅជ្រៃធំ ព្រំដែនកម្ពុជា វៀតណាម។

- សិក្សាប្រមូលទិន្នន័យបម្រែបម្រួលលក្ខណៈរូបសាស្ត្រសងខាងទន្លេពីភ្នំពេញដល់ខេត្តក្រចេះ។

## ៩. អន្តរភាពសហគ្រាសសាធារណៈ

### មន្ទីរពិសោធន៍សំណង់ និងសាធារណការ

- មន្ទីរពិសោធន៍សំណង់ និងសាធារណការ គឺអនុវត្តភារកិច្ចពិសោធន៍សំណង់ និងសាធារណការស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាឲ្យបាននូវរាល់សំណង់ហេដ្ឋារចនាសម្ព័ន្ធ-រូបវន្តទទួលបានគុណភាព និងប្រើប្រាស់បានយូរអង្វែង។

### កំពង់ផែស្វយ័តក្រុងព្រះសីហនុ

- បញ្ចប់គម្រោងចំណតផែកុងតឺន័រប្រវែង២៤០ម៉ែត្រ ជម្រៅ១១,៥ម៉ែត្រ និងពង្រីកចំណតផែកុងតឺន័របន្ថែមប្រវែង១៦០ម៉ែត្រ។
- បញ្ចប់គម្រោងអភិវឌ្ឍចំណតផែពហុបំណង ប្រវែង៣៣០ម៉ែត្រ ជម្រៅ ១៣,៥ម៉ែត្រ និងចំណតមូលដ្ឋានផ្គត់ផ្គង់ភស្តុភារសម្រាប់ការរុករកប្រេងមានបណ្តោយប្រវែង២០០ម៉ែត្រ ជម្រៅទឹក ៧,៥ម៉ែត្រ ព្រមទាំងបូមស្តារអាងនាវា និងឃ្លងនាវាជម្រៅ១២ម៉ែត្រ ។
- ចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជានៅឆ្នាំ២០១៧ដោយបានប្រែក្លាយជាសហគ្រាសសាធារណៈមានទម្រង់ជាក្រុមហ៊ុនរដ្ឋដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។

### កំពង់ផែស្វយ័តភ្នំពេញ

- សាងសង់ចំណតផែកុងតឺន័រថ្មីLM១៧ ចម្ងាយ២៥គ.ម. ពីរាជធានីភ្នំពេញ មានសមត្ថភាពអាចទទួលកុងតឺន័របានចំនួន ៣០០ ០០០ TEUs ក្នុងមួយឆ្នាំ។
- កំពង់ផែស្វយ័តភ្នំពេញ បានចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រកម្ពុជា ខែធ្នូ ឆ្នាំ២០១៥។

## ១០. ការអភិវឌ្ឍវិស័យដឹកជញ្ជូនប្រកបដោយចីរភាព

- ផ្សព្វផ្សាយជំរុញការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីការធ្វើដំណើរដោយយានយន្ត តាមរយៈការលើកទឹកចិត្តប្រជាជនឲ្យប្រើប្រាស់រថយន្តក្រុង រថភ្លើង ការប្រើប្រាស់កង់ ថ្មើរជើង
- រៀបចំគោលការណ៍ណែនាំស្តីពី "ការអភិវឌ្ឍផ្លូវថ្នល់" ដោយផ្តោតលើការគិតគូរពីបញ្ហាបរិស្ថាននិងបង្កើននូវសមត្ថភាពការងារក្នុងការពិនិត្យរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងវិស័យសាធារណការ
- រៀបចំឯកសារមគ្គុទ្ទេសក៍ ស្តីពីហេដ្ឋារចនាសម្ព័ន្ធបៃតងជាមួយនឹងគម្រោងភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។
- រៀបចំជំរុញប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាសូឡា LED សម្រាប់ផ្គត់ផ្គង់ភ្លើងបំភ្លឺតាមដងវិថីក្នុងក្រុង

- ជំរុញរៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈគ្រប់ប្រភេទក្នុងក្រុងរួមមាន៖ រថភ្លើង រថយន្តក្រុង កាណូតដឹកអ្នកដំណើរ និងការសិក្សាសាងសង់ AGT
- រៀបចំផែនការមេឡូជីស្ទីក ដែលគិតគូរពីឡូជីស្ទីកបៃតង សន្សំសំចៃប្រេង កំពុងសហការជាមួយជីអាយហ្សិក លើគម្រោងស្តីពីប្រសិទ្ធភាពថាមពល និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុវិស័យដឹកជញ្ជូន
- កំពុងអភិវឌ្ឍប្រព័ន្ធចម្រោះទឹកកខ្វក់ក្នុងទីក្រុង

## ១១-ភាពជាដៃគូក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- ក្នុងនាមសហប្រធានក្រុមការងារបច្ចេកទេសសម្ព័ន្ធដឹកជញ្ជូនរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន និងក្រុមការងារបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ បានរៀបចំក្របខ័ណ្ឌគតិយុត្តនានា និងរៀបចំវេទិកាសម្រាប់គាំទ្រការអភិវឌ្ឍនិងដោះស្រាយបញ្ហាបានល្អប្រសើរ។
- ផ្តល់គោលការណ៍មួយចំនួនជូនក្រុមហ៊ុនឯកជន ក្នុងការសិក្សាអំពីលទ្ធភាពវិនិយោគលើគម្រោងខ្សែផ្លូវល្បឿនលឿនដែលជាគម្រោងអាទិភាពដូចមានចែងក្នុងផែនការមេ។
- ជំរុញការអនុវត្តគម្រោងផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ
- កំពុងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍនានា ដើម្បីជួយជាជំនួយបច្ចេកទេសក្នុងការរៀបចំជានីតិវិធី បទដ្ឋាននានា ដែលទាក់ទងដល់ការងារវិនិយោគគម្រោងសាងសង់ផ្លូវថ្នល់។
- ក្នុងក្របខ័ណ្ឌអាស៊ាន និងរវាងដៃគូសន្ទនារបស់អាស៊ាន លើវិស័យដឹកជញ្ជូនត្រូវបានជំរុញ និងលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូមានការរីកចម្រើនគួរកត់សំគាល់។
- ចូលរួមសហការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដឹកជញ្ជូននានា ដូចជាគំនិតផ្តួចផ្តើម ខ្សែក្រវាត់មួយ ផ្លូវមួយ ផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ និងផែនការយុទ្ធសាស្ត្រដឹកជញ្ជូនអាស៊ាន ២០១៦-២០២៥ និងផែនការដ៏ទៃទៀត។

### បញ្ហាប្រឈម

២.១០១- ទោះបីជារាជរដ្ឋាភិបាល សម្រេចបានសមិទ្ធផលចម្បងៗ គួរជាទីមោទនៈក្នុងវិស័យសាធារណការ និងដឹកជញ្ជូនយ៉ាងណាក្តី ក៏នៅមានបញ្ហាប្រឈមមួយចំនួន៖

- ការផ្តល់សេវាសាធារណៈនៅមិនទាន់មានភាពរលូន និងជំនឿទុកចិត្តពីមហាជន។
- សមត្ថភាពទទួលមុខងាររបស់ស្ថាប័នថ្នាក់ក្រោមជាតិ នៅមិនទាន់អាចឆ្លើយតបបានទាំងស្រុង។
- ខ្វះធនធានមនុស្ស អ្នកបច្ចេកទេស ប្រកបដោយគុណភាព និងសមត្ថភាព តាមមុខជំនាញនីមួយៗ ដើម្បីទាញយកផល ពីភាពរីកចម្រើននៃបច្ចេកវិទ្យា និងការធ្វើនវានុវត្តភាព។
- ខ្វះគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូននៅមិនទាន់គ្រប់ជ្រុងជ្រោយ និងការយល់ដឹង និងសមត្ថភាពក្នុងការអនុវត្តច្បាប់នៅមានកម្រិត។
- ខ្វះបទដ្ឋានបច្ចេកទេសមួយចំនួន និងមួយចំនួនពុំឆ្លើយតបការអនុវត្តជាក់ស្តែងតម្រូវឲ្យធ្វើការកែសម្រួលតាមបច្ចេកវិទ្យាថ្មីៗជាប្រចាំ។

- ខ្វះប្រព័ន្ធដឹកជញ្ជូនពហុរូបភាព ព្រមទាំងជំនាញ និងវិជ្ជាជីវៈក្នុងវិស័យភស្តុភារកម្មនៅមានកម្រិត
- សមត្ថភាពយល់ដឹងក្នុងការបញ្ហាបបច្ចេកវិទ្យាដែលធន់ និងការចូលរួមទប់ស្កាត់អំពីការប្រែប្រួលអាកាសធាតុនៅមានកម្រិត។
- ការអភិវឌ្ឍទីក្រុង នៅជួបប្រទះការលំបាកនៅឡើយអំពីការរៀបចំលំនៅដ្ឋាន ការដឹកជញ្ជូនសាធារណៈ ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍។
- ខ្វះការចូលរួម និងយល់ដឹងឲ្យទូលំទូលាយលើបញ្ហាបញ្ចេញចោលកាកសំណល់រាវរឹង និងប្រព័ន្ធចម្រោះសម្អាតទឹកកខ្វក់ និងស្ថានីយប្រព្រឹត្តកម្ម
- ខ្វះការគិតគូរប្រទាក់ក្រឡាគ្នារវាងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាមួយនឹងការអភិវឌ្ឍដែនដីនគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី
- មិនទាន់មានយន្តការត្រួតពិនិត្យ តាមដាន វាយតម្លៃជាក់លាក់។

## អាកាសចរស៊ីវិល

២.១០២- ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ឆ្នាំ២០១៤-២០១៨ នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនតាមតួនាទីភារកិច្ចយ៉ាងសកម្ម និងសម្រេចបានលទ្ធផលជាផ្លែផ្កាដែលឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលសមិទ្ធផលទាំងនោះរួមមាន៖

### ផ្នែកហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន

**អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

- សាងសង់ពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ4E ជួសជុល និងពង្រីកស្ថានីយអ្នកដំណើរ សាងសង់ពង្រីកស្ថានីយទំនិញ

**អាកាសយានដ្ឋានអន្តរជាតិសៀមរាប**

- ចាក់ពង្រឹងកម្រាលផ្លូវរត់ និងចាក់ពង្រឹង ចុងផ្លូវសុវត្ថិភាព RESA 05 និង RESA 23 កំពុងសាងសង់ផ្លូវបរថ្មីចំនួន២ គឺ Taxiway C និង Taxiway D សាងសង់ពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ 4D និងបំពាក់ពោងខ្យល់ថ្មី១កន្លែង និងបន្តថែទាំ ។

**អាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ**

- សាងសង់ផ្លូវបរថ្មី ចំនួន១ ជួសជុលពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ4C
- សាងសង់ពង្រីកស្ថានីយអ្នកដំណើរមកដល់ ដែលអាចទទួលអ្នកដំណើរបានជាង៥០ម៉ឺននាក់ ក្នុង១ឆ្នាំ និងបំពាក់ពោងខ្យល់ថ្មី កន្លែង និងបន្តថែទាំ ។

**អាកាសយានដ្ឋានផ្សេងៗ៖** បាត់ដំបង ស្ទឹងត្រែង កោះកុង បានជួសជុលពង្រឹងកម្រាលផ្លូវរត់។ សម្រាប់ខេត្ត រតនគិរី មណ្ឌលគិរី និងព្រះវិហារ បានប្រគល់ដីទីតាំងជូនរដ្ឋបាលខេត្តធ្វើការអភិវឌ្ឍតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

## សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

២.១០៣- ការដឹកជញ្ជូនតាមផ្លូវអាកាសសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

### តារាងទី ២.២០ លទ្ធផលការងារដឹកជញ្ជូនតាមផ្លូវអាកាសពីឆ្នាំ២០១៤-២០១៨

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ក្រុមហ៊ុនអាកាសចរណ៍ | ចំនួន | ២៧ | ៣០ | ៣៨ | ៤៦ | ៤៨ |
| ជើងហោះហើរ | ចំនួន | ៦០ ៩៣៥ | ៦៥ ៦២២ | ៦៩ ០៤១ | ៨៤ ៦៧១ | ៩៩ ១៩៧ |
| អ្នកដំណើរតាមផ្លូវអាកាស | ចំនួន | ៥ ៤៦៧ ៥៩១ | ៦ ០៤២ ៤៨៤ | ៦ ៦២៤ ៨១៦ | ៨ ២៣៧ ៤០៥ | ១០ ០១៣ ១១៨ |
| ទំនិញ | តោន | ៣២ ៨៤៩ | ៣៧ ១៥០ | ៤៦ ៤៦២ | ៦៣ ៩៤៩ | ៧៣ ៥៩២ |
| ជើងហោះហើរឆ្លងកាត់ | ចំនួន | ៤១ ៦០០ | ៤៦ ៩៣៣ | ៥៥ ០៧៥ | ៥៨ ៧៣៧ | ៦៧ ១៥១ |

*ប្រភព :* រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## ប្រព័ន្ធត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាស

២.១០៤- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានធ្វើទំនើបកម្មការនាំផ្លូវហោះហើរដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណបចំពោះអាកាសយានដ្ឋានអន្តរជាតិទាំងបី ដោយកាត់បន្ថយបាននៅពេលវេលា រយៈចម្ងាយហោះហើរ និងថ្លៃដើមនៃការហោះហើរ តាមរយៈជំនួយបច្ចេកទេស កសាងសមត្ថភាពរបស់រដ្ឋាភិបាលជប៉ុនតាមរយៈទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន។ ក្រុមហ៊ុនអាកាសចរណ៍ដែលបានកំពុងប្រតិបត្តិការអាជីវកម្មមានចំនួន៤៨ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកមានចំនួន៩ក្រុមហ៊ុន និងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិមានចំនួន៣៩ក្រុមហ៊ុន។

## អភិវឌ្ឍធនធានមនុស្ស

២.១០៥- ការពង្រឹងសមត្ថភាពមន្ត្រី តាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការដោយផ្តោតជាសំខាន់លើ៣ជំនាញគឺ៖ ការត្រួតពិនិត្យសុវត្ថិភាព ការត្រួតពិនិត្យសន្តិសុខអាកាសចរណ៍ និងជំនាញទូទៅដល់មន្ត្រីត្រួតពិនិត្យសុវត្ថិភាព សន្តិសុខ និងមន្ត្រីរៀបចំចងក្រងបទប្បញ្ញត្តិ ព្រមទាំងមន្ត្រីផ្តល់សេវាសាធារណៈលើវិស័យអាកាសចរស៊ីវិលផងដែរ។

## ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត

២.១០៦- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រ.ល.អ.ស.) បានចងក្រងនិងដាក់ចេញនូវបទ-ប្បញ្ញត្តិសុវត្ថិភាពដែលទាក់ទងដល់ការបញ្ញត្តិ និងបានធ្វើកិច្ចកែសម្រួលបន្ថែមជាបន្តបន្ទាប់ទៅលើបទប្បញ្ញត្តិ នីតិវិធី សេចក្តីណែនាំ ព្រមទាំបទដ្ឋានគតិយុត្តមួយចំនួនទៀតដើម្បីឲ្យស្របតាម

តម្រូវការនិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។ បានរៀបចំសេចក្តីព្រាងស្តីពីកម្មវិធីសន្តិសុខអាកាសចរជាតិ កម្មវិធីសុវត្ថិភាពជាតិ កម្មវិធីសុវត្ថិភាពនាំផ្លូវអាកាស កម្មវិធីត្រួតពិនិត្យសុវត្ថិភាព ហើយក៏កំពុងគិតគូរៀបចំបទប្បញ្ញត្តិសេដ្ឋកិច្ច និងបទប្បញ្ញត្តិបច្ចេកទេសមួយចំនួនទៀតដើម្បីធានាបាននូវបរិការណ៍ធុរកិច្ច ក្នុងវិស័យដឹកជញ្ជូនផ្លូវអាកាសប្រកបដោយនិរន្តរភាព។

២.១០៧- ចំពោះសេវាកម្មនាំផ្លូវអាកាស ត្រូវបានរាជរដ្ឋាភិបាលប្រគល់សិទ្ធិវិនិយោគជូនក្រុមហ៊ុនសេវាកម្មចរាចរណ៍ដែនអាកាសកម្ពុជា ក្រោមរូបភាព សាងសង់-អាជីវកម្ម-ផ្ទេរ ដែលមានរយៈពេល២២ឆ្នាំ (ពីឆ្នាំ២០០២ដល់ឆ្នាំ២០២៣) ដែលគ្រប់គ្រង និងធ្វើទំនើបកម្មបច្ចេកវិទ្យាឧបករណ៍នាំផ្លូវអាកាស ដោយក្រុមហ៊ុនសេវាកម្មចរាចរណ៍ដែនអាកាសកម្ពុជា។

### សន្តិសុខអាកាសចរស៊ីវិល

២.១០៨- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំនូវក្របខ័ណ្ឌច្បាប់ បទដ្ឋានបច្ចេកទេសសន្តិសុខ និងប្រព័ន្ធជាតិត្រួតពិនិត្យសន្តិសុខអាកាសចរស៊ីវិលមួយចំនួនដូចជា៖ បទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការកម្មវិធី សៀវភៅណែនាំមួយចំនួនដែលទាក់ទងនឹងវិធានការសន្តិសុខ និងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលនៅកម្ពុជា។

### បញ្ហាប្រឈម

២.១០៩- ជាមួយសមិទ្ធផល គួរជាទីមោទនខាងលើ ក៏យើងនៅជួបប្រទះនូវបញ្ហាប្រឈម ដូចខាងក្រោម៖

- លិខិតបទដ្ឋានគតិយុត្ត លិខិតបទដ្ឋានបច្ចេកទេស លិខិតបទដ្ឋានសេដ្ឋកិច្ចនៅមានការខ្វះចន្លោះនៅឡើយដែលចាំបាច់ត្រូវរៀបចំ និងកែសម្រួលឡើងវិញដើម្បីឆ្លើយតបនឹងអនុសាសន៍អង្គការអាកាសចរអន្តរជាតិ
- ការចូលរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិដោយក្រុមហ៊ុន SCA នៅមានកម្រិត ដោយក្រុមហ៊ុនយល់ថាកម្ពុជាជាប្រទេសតូច។
- ខ្វះជំនាញការ ដើម្បីជួយរៀបចំបទដ្ឋានគតិយុត្តដើម្បីឲ្យស្របតាមអនុសាសន៍របស់អង្គការអាកាសចរអន្តរជាតិ

## ៥.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

២.១១០- ក្រសួងធនធានទឹកនិងឧតុនិយមមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការតាមដាននិងគ្រប់គ្រងនូវរាល់សកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ព្រមទាំងកាត់បន្ថយគ្រោះមហន្តរាយពីធម្មជាតិ។ ក្នុងការធ្វើឲ្យកើនឡើងនូវលទ្ធភាព និងសក្តានុពល

ស្រោចស្រពបន្ថែមលើលទ្ធភាពដែលមានកន្លងមក ដើម្បីបង្កើនផលិតផលកសិកម្ម ព្រមទាំងការកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងការពារទឹកប្រៃនោះ ក្រសួងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។

**គ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក**

- សម្រេចបានលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុបចំនួន៣១៦ ៦៨៩ហ.ត.ក្នុងនោះ រួមមាន(ស្រូវរដូវវស្សាចំនួន២២៥ ៨៩៥ហ.ត. និងស្រូវរដូវប្រាំងចំនួន៩០ ៧៩៤ហ.ត.) ដំណាំរួមផ្សំចំនួន៤ ៤១៣ហ.ត.
- ក្រៅពីការបង្កើនលទ្ធភាពស្រោចស្រព ក៏មានការរក្សានិរន្តរភាពនៃការស្រោចស្រពស្រូវបានចំនួន ៤៨៥ ៦៩៨ហ.ត. ក្នុងនោះ (ស្រូវវស្សាចំនួន ៣៩៥ ២៣៩ហ.ត. ស្រូវប្រាំងចំនួន ៩០ ៤៥៩ហ.ត.) និងដំណាំរួមផ្សំចំនួន១ ៥៥៦ហ.ត. តាមរយៈការជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួប។

**ការពារនិងការអភិរក្សធនធានទឹក**

- រៀបចំ និង អនុម័ត អនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើត ការរំសាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក
- រៀបចំ និង អនុម័ត អនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ

**គ្រប់គ្រងព័ត៌មាន ស្តីពីធនធានទឹក និងឧតុនិយម**

**ការងារជលសាស្ត្រ**

- ដំឡើងស្ថានីយជលសាស្ត្រចំនួន២៥កន្លែង នៅតាមបណ្តាដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់។
- ជួសជុលស្ថានីយជលសាស្ត្រ
- ដំឡើងក្តារវាស់កម្ពស់ទឹកចំនួន៤២កន្លែង និងជួសជុលក្តារវាស់កម្ពស់ទឹកចំនួន១០កន្លែង នៅតាមចំណុចត្រួតពិនិត្យតាមបណ្តោយទន្លេ និងស្ទឹង។
- ដំឡើងឧបករណ៍ស្វ័យប្រវត្តិបាន៨កន្លែង នៅតាមស្ទឹងក្នុងខេត្តកំពង់ស្ពឺ។

**ការងារឧតុនិយម**

- ដំឡើងស្ថានីយឧតុនិយមសរុបបានចំនួន៤៨កន្លែងនិងជួសជុលកែលម្អស្ថានីយឧតុនិយមបានចំនួន១៤កន្លែង នៅតាមបណ្តាលខេត្ត។
- ដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀងសរុបចំនួន៤៦កន្លែង និងជួសជុលបានចំនួន២៣កន្លែង។
- បំពាក់ឧបករណ៍ស្វ័យប្រវត្តិតាមស្ថានីយសរុបចំនួន១៣កន្លែង។

**បញ្ហាប្រឈម**

២.១១១- ក្នុងកិច្ចដំណើរការអនុវត្ត ក្រសួងធនធានទឹកនិងឧតុនិយម បានជួបប្រទះការប្រឈមមួយចំនួន ដូចជា៖

- ផ្តល់ទុនវិនិយោគប្រចាំឆ្នាំលើការគ្រប់គ្រងនិងអភិវឌ្ឍន៍លើវិស័យធនធានទឹកនិងឧតុនិយម នៅកម្ពុជានៅមានកម្រិត។
- ការចូលរួមរបស់កសិករលើការងារប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់ មានកម្រិតទាបនៅឡើយ។
- តម្រូវការក្នុងការអនុវត្តបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុទៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រ។
- ការគ្រប់គ្រងធនធានទឹកចម្រុះអន្តរវិស័យរួមទាំងការគ្រប់គ្រងអាងទន្លេត្រូវពង្រឹងបន្ថែមទៀត ដោយសារកំណើនសម្ពាធលើធនធានទឹក ដែលបណ្តាលមកពីការអភិវឌ្ឍដូចជា៖ កំណើនវិស័យកសិកម្ម នគរូបនីយកម្ម និងឧស្សាហកម្មហូបនីយកម្មនិងការផលិតថាមពល។

## ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ

២.១១២- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

- អនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ឆ្នាំ២០១៦-២០២០ និងផែនការយុទ្ធសាស្ត្រគណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១៦-២០២០។
- ធ្វើកំណែទម្រង់ស្ថាប័នគណៈកម្មការទន្លេមេគង្គ និងរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តែងតាំងនាយកប្រតិបត្តិដែលមកពីប្រទេសជាសមាជិក និងការសម្រេចឲ្យមានទីស្នាក់ការលេខាធិការដ្ឋាន នៅទីក្រុងវៀងច័ន្ទ និងមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់នៅរាជធានីភ្នំពេញ។
- បញ្ចប់ការសិក្សាស្តីពីការអភិវឌ្ឍ និងការគ្រប់គ្រងប្រកបដោយចីរភាពនៃទន្លេមេគង្គដោយរាប់បញ្ចូលទាំងផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គិសនីនៅលើទន្លេមេ។
- បន្តអនុវត្តនីតិវិធី ស្តីពីការប្រើប្រាស់របស់គណៈកម្មការទន្លេមេគង្គ សម្រាប់ការចែករំលែកទិន្នន័យ និងព័ត៌មាន ការតាមដានការប្រើប្រាស់ទឹក ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ការថែរក្សាធារទឹកនៅលើទន្លេមេ និងគុណភាពទឹក។
- អនុម័តយុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងអាងទន្លេមេគង្គ និងយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផលក្នុងអាងទន្លេមេគង្គ។
- រៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន រៀបចំសកម្មភាពតាមដានបរិស្ថានរួមគ្នាសម្រាប់ទំនប់វារីអគ្គិសនីលើទន្លេមេ និងយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត និងការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំគ្រោងប្លង់សម្រាប់ទំនប់វារីអគ្គិសនីលើទន្លេមេ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយចីរភាព ។

- អនុម័តរូបមន្តបង់វិភាគទានហិរញ្ញវត្ថុ ក្នុងសមាមាត្រស្មើគ្នាត្រឹមឆ្នាំ២០៣០ ដែលបង្ហាញឲ្យឃើញ នូវការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋាភិបាលនៃប្រទេសទាំង៤ ចំពោះគណៈកម្មការទន្លេមេគង្គ។
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនាចិន និងមីយ៉ាន់ម៉ា និងការចែករំលែកទិន្នន័យ និងព័ត៌មាន ការរៀបចំសន្និសីទបច្ចេកទេស និងការផ្លាស់ប្តូរទស្សនកិច្ចរួមគ្នា និងការស្រាវជ្រាវរួមគ្នាលើបញ្ហាសំខាន់ៗ និងកិច្ចសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង។
- កៀរគរការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍនានា និងប្រទេសជាច្រើន។

### បញ្ហាប្រឈម

២.១១៣- ទោះបីជាសមិទ្ធផលចម្បងៗ ក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា៖

- ប្រសិទ្ធភាព នៃការសម្របសម្រួលថ្នាក់តំបន់ជាមួយប្រទេសជាសមាជិកនៅមានកម្រិត។
- ការយល់ដឹងចំពោះកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ព្រមទាំងបណ្តានីតិវិធីប្រើប្រាស់ទឹករបស់គណៈកម្មការទន្លេមេគង្គ នៅកម្រិត។
- តួនាទីរបស់គណៈកម្មការទន្លេមេគង្គ ក្នុងកិច្ចសហប្រតិបត្តិការតំបន់នៅមានកម្រិត ដែលចាំបាច់ត្រូវបន្ត និងជំរុញកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងក្នុងតំបន់ជាមួយយន្តការថ្នាក់តំបន់ដែលមានស្រាប់ និងយន្តការថ្មីៗពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ។

### ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

២.១១៤- អនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ឲ្យបានគ្រប់ទីប្រជុំជនប្រជាជនរស់នៅតំបន់ទីប្រជុំជនយ៉ាងតិច៨០% នៅឆ្នាំ២០១៥ បានទទួលសេវាទឹកស្អាត៨៥% នៅឆ្នាំ២០១៨ និង១០០% នៅឆ្នាំ២០២៥។ ប្រជាជនរស់នៅទីប្រជុំជនទទួលបានទឹកស្អាតប្រើប្រាស់ដោយឈរលើលក្ខខណ្ឌ៤យ៉ាងគឺ៖ ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ (ដោយមានការគិតគូរគ្រប់ជ្រុងជ្រោយអំពីកត្តាថ្លៃដើមផលិតទឹក)។

- ចេញប្រកាសស្តីពី នីតិវិធីនៃការកំណត់ថ្លៃទឹក និងប្រកាសពាក់ព័ន្ធការធ្វើអាជីវកម្មផ្សេងទៀត
- ដាក់ឲ្យដំណើរការរោងចក្រផលិតទឹកស្អាតថ្មីនៅខេត្តមណ្ឌលគិរី បាត់ដំបង និងកំពង់ចាម
- បើកការដ្ឋានឲ្យដំណើរការសាងសង់រោងចក្រផលិតទឹកស្អាតថ្មីនៅខេត្តកំពត
- គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពត(កំពុងដំណើការអនុវត្តដោយមានក្រុមហ៊ុនជប៉ុន ទីប្រឹក្សាបច្ចេកទេសនិងម៉ៅការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងមូល)

- គម្រោងកម្ចីហិរញ្ញប្បទានរបស់ធានាគារអាស៊ី ត្រូវអនុវត្តតាមបណ្តារដ្ឋាករទឹកសាធារណៈ
- បញ្ចប់ការដេញថ្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តស្ទឹងត្រែង
- អនុវត្តការងារបំពង់ទឹកស្អាតនៅតាមបណ្តាខេត្ត០៦
- ក្រសួងកំពុងធ្វើការវាយតម្លៃឯកសារគុណភាពដំបូង សាងសង់ នៅខេត្តមួយចំនួន០២
- ស្តង់ដាបច្ចេកទេសប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត គាំទ្រដោយដៃគូអភិវឌ្ឍ
- គម្រោងវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ៣៖
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងសេវាកម្មទឹកស្អាត និង ប្រកាសស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ និង ធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន
- អភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកឲ្យមានប្រសិទ្ធភាពនិងបានបង្កើតប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការ ទឹកស្អាតឯកជន និងសាធារណៈនៅកម្ពុជា តាមរយៈការបញ្ចូលទិន្នន័យ
- បង្កើត "សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា"
- កំពុងបន្តការងារបណ្តុះបណ្តាល និងអនុវត្តគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតដើម្បីឈានទៅស្វយ័តភាពជាសហគ្រាសមានលក្ខណៈសេដ្ឋកិច្ច
- ផ្ទេរភារកិច្ចចំនួន០៦ មុខងារ ដល់ថ្នាក់ក្រោមជាតិ

### តារាងទី ២.២១ ការផ្គត់ផ្គង់ទឹកស្អាត

| សូចនាករ | ២០១៤ (ម៣) | ២០១៥ (ម៣) | ២០១៦ (ម៣) | ២០១៧ (ម៣) | ២០១៨ (ម៣) |
|---|---|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ១៤៩ ៥៥៧ ៥០៧ | ១៦១ ៦២៣ ៦៣៧ | ១៧៩ ៦៣៩ ១៩១ | ១៩៤ ៦០១ ៣០៦ | ១៥៦ ៤៤០ ៤៤៣ |
| រដ្ឋាករទឹកស្វយ័តសៀមរាប | ៤ ៣៤២ ១៦៤ | ៤ ៧៩៤ ៥១៣ | ៥ ៣៨៥ ៥៩៣ | ៥ ៩១១ ៧៩៤ | ៤ ៧៦២ ៣០៤ |
| រដ្ឋាករទឹកសាធារណៈ | ១៧ ៦៥៣ ៨០៨ | ១៩ ៩៥៦ ៦២៣ | ២៣ ២៣០ ១៦០ | ២៦ ៧៤៩ ០៧២ | ៦៩ ៦៣៨ ០៦០ |
| ក្រុមហ៊ុនទឹកស្អាតឯកជន | ២៥ ៤៥០ ០៥០ | ៣៤ ០២៧ ៤៤៨ | ៤១ ៩២១ ៣២៨ | ៥៣ ៥៥០ ៩៦៥ | ៥៣ ៥៥០ ៩៦៥ |
| អត្រា % ចំនួនប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកស្អាត | ៨១,២៨% | ៨៨,០១% | ៧៥,០៧% | ៨៥,៨៤% | ៨៥,៨៤% |
| **សរុប** | **១៩៧ ០០៣ ៥២៩** | **២២០ ៤០២ ២២១** | **២៥០ ១៧៦ ២៧២** | **២៨០ ៨១៣ ១៣៧** | **២៨០ ៨១៣ ១៣៧** |

*ប្រភព:* ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

### បញ្ហាប្រឈម

- ខ្វះច្បាប់បទដ្ឋានគតិយុត្ត ឯកសារផ្លូវច្បាប់នានាសម្រាប់ការងារគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត
- ថវិកាបដិភាគមានកម្រិតតិចតួចសម្រាប់ការអភិវឌ្ឍវិស័យទឹកស្អាត
- ធនធានមនុស្សមានកម្រិតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានតម្រូវការក្នុងការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញបច្ចេកទេសទឹកស្អាតនៅពេលអនាគត
- ទិន្នន័យដែលផ្តល់ដោយសេវាករផ្គត់ផ្គង់ទឹកស្អាតពុំមានភាពជាក់លាក់
- សមត្ថភាពម្ចាស់ការគ្រប់គ្រងដោយខ្លួនឯងរបស់រដ្ឋាករទឹកសាធារណៈមួយចំនួននៅមានកម្រិត

## ៥.៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

២.១១៥- ក្រសួងរ៉ែនិងថាមពលបានអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- អភិវឌ្ឍប្រភពអគ្គិសនីបានកើនពី១ ០៨៨មេហ្គាវ៉ាត់ នៅឆ្នាំ២០១៣ ដល់២ ៦៥០ មេហ្គាវ៉ាត់ នៅឆ្នាំ២០១៨ ក្នុងនោះប្រភពក្នុងស្រុកកើនពី៦៨៥មេហ្គាវ៉ាត់ ដល់ ២ ២០៧មេហ្គាវ៉ាត់ ធ្វើឲ្យការនាំចូលអគ្គិសនីថយចុះពី ៥៦,៣% មកត្រឹម១៤,៥៥%។ ឆ្នាំ២០១៨ ប្រភពថាមពលពីធ្យូងថ្មមាន៣៥% វារីអគ្គិសនី៤៩% និងនាំចូលប្រហែល១៥% និងអនុស្ថានីយចំនួន ៣៣កន្លែង គ្របដណ្តប់២០រាជធានី ខេត្ត។
- បច្ចុប្បន្នតំបន់ចំនួន៣៤៩ ទូទាំងប្រទេសកំពុងទទួលអគ្គិសនីប្រកបដោយគុណភាពសុវត្ថិភាព និងអាចទុកចិត្តនិងសល់តែតំបន់ចំនួន១០ ទៀតនៅមិនទាន់បានភ្ជាប់ជាមួយបណ្តាញជាតិ
- រាជរដ្ឋាភិបាលបានអនុវត្តផែនការបន្ថយថ្លៃ និងគម្លាតថ្លៃអគ្គិសនីដែលផ្គត់ផ្គង់ដោយបណ្តាញជាតិសម្រាប់ ឆ្នាំ២០១៥-២០២០ និងអនុវត្តផែនការបន្ថែមការអនុគ្រោះថ្លៃសម្រាប់លំនៅដ្ឋានព្រមទាំងបានបង្កើតអត្រាថ្លៃប្រើប្រាស់អគ្គិសនីផ្សេងគ្នាសម្រាប់ពេលថ្ងៃនិងពេលយប់
- ក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ និងជាមួយវៀតណាម បានដោយផ្តោតលើការងារច្បាប់ និងបទប្បញ្ញត្តិសុវត្ថិភាពសារធាតុបរមាណូ និងប្រភពវិទ្យុសកម្មលើវិស័យសុខាភិបាល កសិកម្ម ធនធានទឹក ផែនការអភិវឌ្ឍថាមពល បរិស្ថាន ឧស្សាហកម្ម ការអភិរក្សបេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍធនធានមនុស្ស និងការបង្កើតរចនាសម្ព័ន្ធបញ្ញត្តិករបរមាណូ និងវិទ្យុសកម្ម។

### បញ្ហាប្រឈម

២.១១៦- នៅក្នុងអាណត្តិទី៥នេះ ការអនុវត្តការងារនៅក្នុងវិស័យរ៉ែនិងថាមពល ជួបប្រទះនូវបញ្ហាប្រឈមធំមួយចំនួនដូចខាងក្រោម៖

- ខ្វះមន្ត្រីសម្រាប់ប្រតិបត្តិការទូទៅ និងទុនថវិកាសម្រាប់ប្រតិបត្តិការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យរ៉ែ ប្រេងកាត និងថាមពល។

## ៥.៤- ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### វិស័យប្រៃសណីយ៍

២.១១៧- គិតមកដល់ចុងឆ្នាំ២០១៨ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគន៍ បានផ្តល់អាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិដល់ ក្រុមហ៊ុនចំនួន៣៤ (ឆ្នាំ២០១៣ មានតែ២១ក្រុមហ៊ុន) ដើម្បីបង្កើនភាពងាយស្រួលដល់អតិថិជនក្នុងការទទួលយកសេវា ក៏ដូចជាការចូលរួមអនុវត្តគោលនយោបាយបើកទូលាយវិស័យប្រៃសណីយ៍។ ជាក់ស្តែងផ្អែកតាមលទ្ធផលរបស់សហគ្រាសស្វយ័តប្រៃសណីយ៍កម្ពុជា អត្រារួមនៃការប្រើប្រាស់សេវា ប្រៃសណីយ៍សម្រេចបានតែ

០,០៩០៣% ទាបជាងចំណុចដៅ(០,១២%) ក្នុងប្រជារាស្ត្រ ០១នាក់ ក្នុង០១ឆ្នាំ ។ ក្នុងនោះ សេវាទទួលនិងបញ្ជូនបញ្ញើ ទៅក្រៅប្រទេសស្រូបយក ប្រមាណ ៩៥% នៃសេវាទូទាំងប្រទេស។

**តារាងទី ២.២២ សូចនាករស្ដីពីអត្រាអ្នកប្រើប្រាស់**

| ល.រ. | បរិយាយ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១ | អត្រាអ្នកប្រើសេវា នាក់/ឆ្នាំ | ០,០៩២៦ | ០,០៩០៣ | ០,១០០៧ | ០,០៩១៥ | ០,០៩០៣ |
| ២ | អាត្រាបម្រើសេវា០១ការិយាល័យ/ផ្ទៃដីគម² | ៣ ៣៥២ | ៣ ៣៥២ | ៣ ៣៥២ | ៣ ៣៥២,៥ | ៣ ៣៥២,៥ |

*ប្រភព :* ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**វិស័យទូរគមនាគមន៍**

២.១១៨- អត្រារួមអ្នកប្រើប្រាស់ទូរស័ព្ទចល័តនិងអចល័តមិនទាន់សម្រេចបានតាមចំណុចដៅទេ។ បើគិតត្រឹមចុងឆ្នាំ២០១៨នេះ ចំនួនអតិថិជនប្រើប្រាស់ទូរស័ព្ទចល័ត មានចំនួន ១៩ ៣១៥ ៨៩២ នាក់ ស្មើអត្រា ១១៨,៩០ ក្នុងប្រជារាស្ត្រ១០០នាក់ ដែលក្នុងចំនួននេះមានភ្ជាប់បណ្ដាញអ៊ិនធឺណិតចល័ត ប្រមាណ ១១ ៥៥៩ ៣០០នាក់ សមមូលអត្រា ៧១,១៥ ក្នុងប្រជារាស្ត្រ១០០នាក់ និងទូរស័ព្ទអចល័ត មានចំនួន ១៣១ ៥៨២នាក់ សមមូលអត្រា ០,៨១ ក្នុងប្រជារាស្ត្រ១០០នាក់ ដែលក្នុងចំនួននេះមានភ្ជាប់បណ្ដាញអ៊ិនធឺណិតអចល័តត្រឹមតែ ១៧១ ៩៥៣បណ្ដាញ ត្រូវនឹង ១,០៦បណ្ដាញ ក្នុងប្រជាជន ១០០នាក់ គឺមានកម្រិត ទាបនៅឡើយ។ ដោយឡែកការតភ្ជាប់បណ្ដាញអ៊ិនធឺណិតល្បឿនលឿន ឬប្រដប់ប៊ែន នៅមានកម្រិតទាបបំផុត គឺប្រមាណ១៥០ ៧៣០បណ្ដាញ ត្រូវនឹង ០,៩៣៨ បណ្ដាញ ក្នុង ប្រជាជន ១០០នាក់ និងល្បឿនយឺត ឬ ណេរ៉ូប៊ែន មានត្រឹមតែ ២ ៦១៨បណ្ដាញ ត្រូវនឹង ០,០១៦ បណ្ដាញ ក្នុងប្រជាជន ១០០នាក់ នៅទូទាំង ប្រទេស បើធៀបជាមួយបណ្ដាប្រទេសក្នុងអាស៊ាន និង ក្នុងសកលលោក។

២.១១៩- គិតមកដល់ឆមាសទី១ឆ្នាំ២០១៨ ការអភិវឌ្ឍនិងវិនិយោគហេដ្ឋារចនាសម្ព័ន្ធកាប្លិ៍អុបទិកមានប្រវែងសរុប ៤៣ ៤១០គ.ម.។ រចនាសម្ព័ន្ធឆ្អឹងខ្នងទាំងនេះ ត្រូវបានតភ្ជាប់ទៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃឡង់។ ជាមួយគ្នានេះក៏បានដាក់ឲ្យដំណើរការនូវបណ្ដាញខ្សែកាប្លិ៍អុបទិក ដែលតភ្ជាប់ទៅអន្តរជាតិតាមរយៈខ្សែកាប្លិ៍ អុបទិកក្រោមបាតសមុទ្រផងដែរ។ បន្ថែមពីលើនេះដើម្បីពង្រឹងគុណភាពសេវាទំនាក់ទំនង ក្រសួងបានជំរុញឲ្យក្រុមហ៊ុនទូរស័ព្ទចល័តខិតខំពង្រីកបណ្ដាញរបស់ខ្លួនទៅកាន់តំបន់ជនបទតាមរយៈការដំឡើងស្ថានីយអង់តែនទូរស័ព្ទនិងម៉ៃក្រូវ៉េវបានចំនួន១១ ០៩១បង្គោល។

## តារាងទី ២.២៣ ចំនួនអ្នកប្រើប្រាស់សេវាទូរស័ព្ទសរុប

| ល.រ. | វាយមុខសញ្ញា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១ | ចំនួនទូរស័ព្ទសរុប | | | | | |
| | -ទូរស័ព្ទចល័ត | ២០ ៤៥១ ៩៨២ | ២០ ៨៥០ ៥៤៣ | ១៩ ៩១៥ ៥០៣ | ១៨ ៥៧២ ៩៧៣ | ១៩ ៣១៥៨៩២ |
| | -ទូរស័ព្ទអចល័ត | ៣៦១ ០៥៦ | ២៦៥ ៣៨៧ | ២២៧ ២៦១ | ១៣២ ៩១១ | ១៣១ ៥៨២ |
| ២ | ចំនួនអ្នកប្រើប្រាស់សេវាអ៊ិនធឺណិតសរុប | | | | | |
| | - អ៊ិនធឺណិតចល័ត | ៤ ៩៥៧ ៤៤៩ | ៦ ៧១០ ៦២៤ | ៨ ០០០ ៨៣៤ | ១០ ៧០៣ ០៥៦ | ១១ ៥៥៩ ៣០០ |
| | - អ៊ិនធឺណិតអចល័ត | ៦៨ ៤៩៦ | ៨៥ ៣៨៤ | ៩៨ ២៩៨ | ១៣៨ ៦៧២ | ១៧១ ៩៥៣ |

*ប្រភព :* ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## តារាងទី ២.២៤ អត្រាអ្នកប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធឺណិត

| ល.រ. | វាយមុខសញ្ញា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទសរុប | | | | | | |
| | ទូរស័ព្ទចល័ត | ក្នុង១០០ នាក់ | ១៣៤,៦៩ | ១៣៥,៣៥ | ១២៧,៤៥ | ១១៧,១៩ | ១១៨,៩០ |
| | ទូរស័ព្ទអចល័ត | ក្នុង១០០ នាក់ | ២,៣៨ | ១,៦៦ | ១,៤៥ | ០,៨៤ | ០,៨១ |
| ២ | អត្រាអ្នកប្រើប្រាស់អ៊ិនធឺណិតសរុប | | | | | | |
| | អ៊ិនធឺណិតអចល័ត | ក្នុង១០០ នាក់ | ៣២,៦៥ | ៤៣,៥៦ | ៥១,២០ | ៦៧,៥៣ | ៧១,១៥ |
| | អ៊ិនធឺណិតចល័ត | ក្នុង១០០ នាក់ | ០,៤៥ | ០,៥៥ | ០,៦៣ | ០,៨៧ | ១,០៦ |

*ប្រភព :* ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

### ២.១២០- វិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន

- ធ្វើសមាហរណកម្មអតីតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា(NiDA) ឲ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគន៍។
- បញ្ជ្រាបការយល់ដឹងនិងជំរុញការប្រើប្រាស់ ប.គ.ព. សម្រាប់ការអភិវឌ្ឍសហគមន៍នៅតាមជនបទ ជាពិសេសសម្រាប់ជនងាយរងគ្រោះ ដូចជា ជនពិការ ស្ត្រី កុមារ មនុស្សចាស់ជាដើម។
- រៀបចំពានរង្វាន់ស្ត្រីកម្ពុជាឆ្នើមក្នុងវិស័យបច្ចេកវិទ្យាលើ៣ប្រធានបទ៖ ១.សហគ្រិនស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា ២.វិស្វករស្ត្រីជោគជ័យក្នុងជំនាញ ប.គ.ព ៣.ស្ត្រីដែលបានចូលរួមជំរុញនូវការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍសង្គមឬសហគមន៍។
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរៀបចំគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០។

- សហការជាមួយក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ រៀបចំផែនការមេវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០។

២.១២១- ការកសាងសមត្ថភាពក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន៖

- ផ្តល់ការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រលើជំនាញប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេក វិទ្យាគមនាគមន៍ និងព័ត៌មាន និងមន្ត្រីរាជការ មកពី២៤ខេត្ត/ក្រុង និង ២៥ក្រសួងស្ថាប័ន។
- រៀបចំពានរង្វាន់ស្ត្រីកម្ពុជាឆ្នើមក្នុងវិស័យបច្ចេកវិទ្យាលើ៣ប្រធានបទ៖ ១.សហគ្រិនឆ្នើមស្ត្រីក្នុងវិស័យបច្ចេកវិទ្យា, ២.វិស្វករស្ត្រីជោគជ័យក្នុងជំនាញប.គ.ព., ៣.ស្ត្រីដែលបានចូលរួមជំរុញនូវការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍសង្គមឬសហគមន៍។
- បញ្ជ្រាបការយល់ដឹងអំពីសារប្រយោជន៍នៃការប្រើប្រាស់ប.គ.ព. និងមូលដ្ឋានគ្រឹះព័ត៌មាន វិទ្យាដូចជាការរៀនប្រើប្រាស់ កុំព្យូទ័រ ផ្ញើអ៊ីម៉ែល ទូរស័ព្ទឆ្លាតវៃ និងបណ្តាញទំនាក់ទំនងសង្គម ជាពិសេសសម្រាប់ជនងាយរងគ្រោះ ដូចជាជនក្រីក្រ ជនពិការ ស្ត្រីមនុស្សចាស់ និងជនជាតិភាគតិច។ល។ តាមរយៈអ្នកស្ម័គ្រចិត្ត សិស្ស និស្សិត និងអាជ្ញាធរមូលដ្ឋាន។

## ២.១២២ - **បញ្ហាប្រឈម**

- ខ្វះគ្រឿងបរិក្ខាបច្ចេកទេស និងយន្តការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរួមមួយ
- គុណភាពនៃសូហ្វវែរកម្មវិធីនៅមានកម្រិតបង្កើតជាន់គ្នានិងមិនមានលក្ខណៈរួមបញ្ចូលគ្នា
- ការកៀរគរធនធាន និងសម្របសម្រួល សម្រាប់ការលើកកម្ពស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅតែជាបញ្ហាប្រឈម ។

## ប្រព័ន្ធផ្សព្វផ្សាយ

២.១២៣- ប្រជាជនប្រមាណ៨៨%នៃប្រជាជនសរុបទូទាំងប្រទេសអាចទទួលបានព័ត៌មានកម្មវិធីអប់រំនិងកម្មវិធីកំសាន្ត ជាដើម ដែលផ្សាយតាមវិទ្យុនិងទូរទស្សន៍ និងបណ្តាញព័ត៌មានសង្គម។

**តារាងទី ២.២៥ ការទទួលបានព័ត៌មានសាធារណៈ**

| សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនអ្នកស្តាប់វិទ្យុ មើលទូរទស្សន៍ | % | ៨៥ | ៨៦ | ៨៧ | ៨៨ | - | - |
| ២. ទស្សនាវដ្តី ព្រឹត្តិប័ត្រ និង កាសែត | % | ៤២ | ៤៦ | ៥០ | ៥២ | - | - |

*ប្រភព :* ក្រសួងព័ត៌មាន

## វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២.១២៤- ក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (ក.ជ.វ.ប.) ត្រូវបានបង្កើតឡើង និងមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(អ.ក.ជ.វ.ប.) នៅក្រសួងផែនការក្នុងឆ្នាំ២០១៥ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចដែលមានលក្ខណៈពិពិធកម្មជាងមុន តាមរយៈការជំរុញនវានុវត្តន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៅតាមក្រសួង ស្ថាប័ននិងក្នុងវិស័យឯកជន។ ក្នុងដំណាក់កាលដំបូងនេះ លេខាធិការដ្ឋានបានរៀបចំផែនការមេជាតិស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសម្រាប់តម្រង់ទិសការងារនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សមិទ្ធផលដែលសម្រេចបានមាន៖

- ផ្សព្វផ្សាយផែនការមេជាតិ ស្តីពី វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ២០១៤-២០២០។
- កសាងក្របខ័ណ្ឌគតិយុត្តបឋម សម្រាប់ជាមូលដ្ឋាននៃការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលមាន។
- ឯកភាពលើតួលេខសម្រាប់សូចនាករទាំងពីរសម្រាប់គ្រាគោលនៃគោលដៅទី៩ នៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- កសាងមូលដ្ឋានទិន្នន័យនៃការស្រាវជ្រាវនិងអភិវឌ្ឍសម្រាប់គ្រាគោល ឆ្នាំ២០១៥ ដើម្បីរៀបចំគោលនយោបាយ ផែនការ និងសេចក្តីសម្រេចចិត្តសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិង បច្ចេកវិទ្យាសំដៅរក្សា និរន្តរភាពនៃកំណើនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។
- រៀបចំចំណាត់ថ្នាក់ជាតិផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០១៧ ដើម្បីមានការឯកភាពក្នុងការកត់ត្រា ការរៀបចំសូចនាករ សម្រាប់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រង ការរៀបចំគោលនយោបាយ និងការរៀបចំផែនការអនុវត្តន៍ ។

២.១២៥- **បញ្ហាប្រឈម**

- មិនអាចអនុវត្តទាំងស្រុងនូវ៖ ១.ការកំណត់យកបច្ចេកវិទ្យាអាទិភាពជាតិ៦ សម្រាប់ឆ្នាំ ២០១៧-២០២០ ២.បង្កើនការវិនិយោគរបស់រដ្ឋលើការស្រាវជ្រាវនិងអភិវឌ្ឍដោយមានការបង្កើតមូលនិធិជាតិ ការស្រាវជ្រាវនិងអភិវឌ្ឍ និង ៣.ផ្តល់អាទិភាពក្នុងការទទួលជំនួយ និងការទទួលកិច្ចសហប្រតិបត្តិការអន្តរជាតិ។
- មិនអាចអនុវត្តទាំងស្រុងនូវ ការឯកភាពលើរបាយការណ៍សង្ខេប និងសំណូមពរនៃការប្រជុំក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា លើកទី៣ ឆ្នាំ២០១៨។
- បញ្ហាប្រឈមចម្បងគឺ កង្វះការយល់ដឹង ឈានដល់ការមិនគាំទ្រ ការមិនឯកភាពសម្រាប់ការអនុវត្តនៅកម្រិតបច្ចេកទេស។

**ការកសាងសមត្ថភាពក្នុងវិស័យប្រៃសណីយ៍ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

- រៀបចំការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានថ្នាក់ជាតិ បាន៣លើក
- បញ្ជ្រាបការយល់ដឹងអំពីសារប្រយោជន៍នៃការប្រើប្រាស់ប.គ.ព. និងមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាដូចជាការរៀនប្រើប្រាស់ កុំព្យូទ័រ ផ្ញើអ៊ីម៉ែល ទូរស័ព្ទឆ្លាតវៃ និងបណ្តាញទំនាក់ទំនងសង្គម សម្រាប់ជនងាយរងគ្រោះ ដូចជា ជនក្រីក្រ ជនពិការ ស្ត្រី មនុស្សចាស់ និងជនជាតិភាគតិច ។ល។ តាមរយៈអ្នកស្ម័គ្រចិត្ត សិស្ស និស្សិត និងអាជ្ញាធរមូលដ្ឋាន។

## ៦- ការអភិវឌ្ឍវិស័យឯកជននិងការងារ

២.១២៦- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថាវិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ វិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច ជាពិសេសការធ្វើឲ្យសម្រេចនូវគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ការបញ្ចូលបច្ចេកវិទ្យាទំនើប និងគំនិតច្នៃប្រឌិតសំដៅបង្កើនប្រសិទ្ធភាព និងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការបង្កើតការងារ។

## ៦.១- ការពង្រឹងវិស័យឯកជននិងការជំរុញការវិនិយោគ និងធុរកិច្ច

២.១២៧- ចាប់ពីឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមរបៀបវារៈកំណែទម្រង់ស៊ីជម្រៅ ដើម្បីកែលម្អបរិយាកាសធុរកិច្ចនិងវិនិយោគ ជាពិសេស ពន្លឿនការផ្តល់សេវាពាណិជ្ជកម្ម និងការចរចាបើកទីផ្សារថ្មីៗ បន្ថែមទៀតសម្រាប់ផលិតផលទំនិញរបស់កម្ពុជា។ តាមរយៈកំណែទម្រង់ស៊ីជម្រៅនេះ ក្រសួងពាណិជ្ជកម្ម សម្រេចបាននូវវឌ្ឍនភាពដូចខាងក្រោម៖

**ការងារកំណែទម្រង់**

- ជំរុញធ្វើប្រតិភូកម្មមុខងារសាធារណៈទៅថ្នាក់ក្រោមជាតិ តាមអនុក្រឹត្យគោលនយោបាយកំណែទម្រង់លទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ
- ធ្វើប្រតិភូកម្ម ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នូវ៖ ១.តួនាទីជាអាណាប័កផ្ទេរសិទ្ធិ ២.ការអនុញ្ញាតឲ្យចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី លើទំនិញកសិផលនៅមន្ទីរពាណិជ្ជកម្មតាមបណ្តាខេត្តជាប់ព្រំដែន និងនៅតាមតំបន់សេដ្ឋកិច្ចពិសេស ៣.បិតស្លាកថ្លៃទំនិញ ៤.ស្រង់ថ្លៃទំនិញ និង ៥.អាជីវកម្មលោហៈធាតុត្បូងថ្មមានតម្លៃ គ្រឿងអលង្ការគ្រប់ប្រភេទ
- អភិវឌ្ឍធនធានមនុស្សនិងរចនាសម្ព័ន្ធ ការគ្រប់គ្រងហិរញ្ញវត្ថុ និងវិមជ្ឈការនិងវិសហមជ្ឈការសេវានាំចេញ-នាំចូល និងសេវាពាក់ព័ន្ធនឹងការជំរុញពាណិជ្ជកម្មដើម្បីធានាបាននូវប្រសិទ្ធ

ភាពការងារប្រសើរ និងរហ័សជូនសាធារណៈជន និងតម្រូវការចាំបាច់ស្របតាមស្ថានភាពនៃការអភិវឌ្ឍក្នុងតំបន់ និងសកលលោក។

## កិច្ចការផ្តល់សេវាពាណិជ្ជកម្ម

- **ការចុះបញ្ជីពាណិជ្ជកម្ម៖** ១.អនុវត្តការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ២.ចេញប្រកាសស្តីពីការគ្រប់គ្រង និងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មសេវាកម្មពាណិជ្ជកម្ម ទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្មនិងការបង្កើតគណៈកម្មាការគ្រប់គ្រង និងវាយតម្លៃអ្នកតំណាងស្របច្បាប់។ ការចុះបញ្ជីពាណិជ្ជកម្ម ធ្វើឡើងតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីបង្កភាពងាយស្រួលឆាប់រហ័សនិងកាត់បន្ថយចំណាយផ្សេងៗ។ ពាណិជ្ជករ និងក្រុមហ៊ុន អាចធ្វើការចុះបញ្ជីពាណិជ្ជកម្មបានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងក្នុង និងក្រៅប្រទេស។
- **កិច្ចការកម្មសិទ្ធិបញ្ញា៖** ១.បានចូលជាសមាជិកនៃការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ កិច្ចព្រមព្រៀងទីក្រុងលីស្បោនអំពីឈ្មោះប្រភពដើមទំនិញ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងអង្គការបណ្តាញម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអន្តរជាតិ និង២.ចេញប្រកាសពាក់ព័ន្ធនឹងទំនិញពាក់ម៉ាកផ្តាច់មុខ កិច្ចការពារម៉ាកវិញ្ញាតកម្ម ចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក សេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានិងនីតិវិធីដោះស្រាយវិវាទ នីតិវិធី និងការកត់ត្រាអាជ្ញាបណ្ណ និងប្រៃបនយ។
- **ការនាំចេញ នាំចូល៖** ១.ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ អាជ្ញាបណ្ណនាំចេញ-នាំចូល និងការនាំចេញ-នាំចូលត្បូងពេជ្រមិនទាន់កែច្នៃ ២.សហការរៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្ម វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ទម្រង់ឌី ទៅក្នុងប្រព័ន្ធ ASYCUDA នៃប្រព័ន្ធបញ្ជរតែមួយ និងកំពុងសាកល្បងតភ្ជាប់ជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន ដើម្បីឈានទៅអនុវត្តជាក់ស្តែង ៣.ការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

## ការលើកកម្ពស់ពាណិជ្ជកម្ម

- លើកកម្ពស់ផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដើម្បីធ្វើឲ្យផលិតផលកម្ពុជាប្រើប្រាស់ជំនួសការនាំចូលនិងឈានទៅការនាំចេញទៅលក់នៅលើកទីផ្សារបរទេស
- ធ្វើយុទ្ធនាការទិញផលិតផលខ្មែរក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយបានរៀបចំនៅបណ្តាខេត្តទាំងអស់នៅកម្ពុជា និងចូលរួមពិព័រណ៍អន្តរជាតិ ក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងពិភពលោកជារៀងរាល់ឆ្នាំ

- ការអនុម័តពីរាជរដ្ឋាភិបាលលើអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា និងបានរៀបចំគោលនយោបាយអភិវឌ្ឍន៍ផលិតផលម្រេច នយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មកម្ពុជា និងចូលរួមរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ និងការអភិវឌ្ឍបរិយាកាសធុរកិច្ច និងវិនិយោគ
- ថែរក្សានិងពង្រីកស្តុកយុទ្ធសាស្ត្រស្បៀងត្រៀមបម្រុងសម្រាប់ចូលរួមអន្តរាគមន៍សង្គ្រោះជនរងគ្រោះ និងការស្វែងរកទីផ្សារ
- សម្រួលពាណិជ្ជកម្មលើកសិផលកម្ពុជា ដើម្បីឲ្យការនាំចេញមានភាពរលូន រហ័ស ជាមួយនឹងការបន្ថយសោហ៊ុយនាំចេញ
- ជំរុញការអភិវឌ្ឍស្ថាប័នក្នុងវិស័យឯកជន តាមរយៈការបង្កើតឲ្យមានសភាពាណិជ្ជកម្ម សមាគមអាជីវកម្ម នៅទូទាំងរាជធានី ខេត្ត
- ជំរុញឲ្យមានការបិតស្លាកថ្លៃជារូបិយបណ្ណជាតិ នៅតាមអង្គភាពអាជីវកម្មទូទាំងប្រទេស ដើម្បីឲ្យមានតម្លាភាពថ្លៃទំនិញ និងការពារផលប្រយោជន៍អ្នកប្រើប្រាស់
- រៀបចំបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីធានាឲ្យមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើប្រតិបត្តិការពាណិជ្ជកម្ម
- កំពុងពង្រឹងសមត្ថភាពផ្សព្វផ្សាយស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម តាមរយៈព្រឹត្តិបត្រពាណិជ្ជកម្ម និងប្រព័ន្ធព័ត៌មានវិទ្យា

### សមាហរណកម្មពាណិជ្ជកម្ម ក្នុងតំបន់ និងពិភពលោក

- ក្នុងនាមជាសមាជិកមួយរបស់អាស៊ាន កម្ពុជាបានខិតខំប្រឹងប្រែងរួមចំណែកក្នុងការធ្វើឲ្យសម្រេចបានជោគជ័យក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ ក្នុងក្របខ័ណ្ឌនៃ "**សហគមន៍សេដ្ឋកិច្ចអាស៊ាន**" ដែលត្រូវមានចរិតលក្ខណៈចម្បងបួនគឺ៖ ១.ទីផ្សារនិងមូលដ្ឋានផលិតកម្មតែមួយ ២.តំបន់សេដ្ឋកិច្ចមួយដែលមានការប្រកួតប្រជែងខ្ពស់ ៣.តំបន់មួយដែលមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និង ៤.តំបន់មួយដែលធ្វើសមាហរណកម្មពេញលេញទៅក្នុងសេដ្ឋកិច្ចសាកល។ ជាក់ស្តែង ដើម្បីរួមចំណែកជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចឲ្យដល់កម្រិត **"ទីផ្សារតែមួយ"** និយាយជារួមកម្ពុជាបានខិតខំរួមគ្នាជាមួយនឹងបណ្ដាប្រទេសសមាជិកដទៃទៀត ដើម្បីអាចឈានទៅអនុវត្តបាននូវគោលការណ៍ជាមូលដ្ឋានទាំងបួន គឺ៖ ១.ការដកចេញរបាំងពន្ធគយនិងមិនមែនពន្ធគយសម្រាប់ទំនិញ និងសេវាកម្មពិសេស ២.ការដកចេញរបាំងពន្ធគយនិងមិនមែនពន្ធគយសម្រាប់ទំនិញ និងសេវាកម្មទាំងអស់ ៣.គោលនយោបាយរួមស្ដីពីពន្ធគយសម្រាប់ការនាំចូលពីខាងក្រៅ និង

៤.លំហូរដោយសេរីនៃពលកម្មនិងមូលធន ហើយនិយាយដោយឡែក កម្ពុជាបាននិង កំពុងខិតខំធ្វើឲ្យប្រសើរឡើងនូវច្រកចេញចូលតែមួយរបស់ខ្លួន ដើម្បីអាចធ្វើសមាហរណកម្មបានទៅក្នុងច្រកចេញចូលតែមួយ អាស៊ាន សំដៅជានាឲ្យមានការសម្រួលពាណិជ្ជកម្មសម្រាប់ **"សហគមន៍សេដ្ឋកិច្ចអាស៊ាន"**។ ទោះជាដូចនេះក្តី ទាំងកម្ពុជា ទាំងប្រទេសមាជិកអាស៊ានផ្សេងទៀត ត្រូវបំពេញការងារជាច្រើនទៀតនៅក្នុងក្របខ័ណ្ឌនៃ **"សហគមន៍សេដ្ឋកិច្ចអាស៊ាន"**។

- បើកមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាចំនួន៥ទីតាំងនៅក្នុងប្រទេសចិន (ទីក្រុងប៉េកាំង សៀងហៃ ហាយនឹង ក្វាងចូវ និងនៅខេត្តស៊ីអាន)
- បើកស្ថានបេសកកម្មនៅអង្គការពាណិជ្ជកម្មពិភពលោក ដែលមានទីតាំងនៅប្រទេសស្វីស
- បញ្ចប់ការចរចាជាមួយភាគីវៀតណាមក្នុងការចុះអនុស្សារណៈយោគយល់រវាងក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម ស្តីពីការកសាងផ្សារព្រំដែនកម្ពុជានៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងកិច្ចសម្របសម្រួលពាណិជ្ជកម្មរវាងក្រសួងទាំងពីរក្នុងការផ្តល់ភាពអនុគ្រោះជូនគ្នាទៅវិញទៅមក
- ពង្រឹងដៃគូពាណិជ្ជកម្ម និងស្វែងរកទីផ្សារនៅក្រៅប្រទេសជាច្រើនលើក ដើម្បីទាក់ទាញវិនិយោគិនបរទេស និងការធ្វើពាណិជ្ជកម្មនៅកម្ពុជា
- សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលអាស៊ានចិន មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ មជ្ឈមណ្ឌលអាស៊ាននៅឥណ្ឌូនេស៊ី មជ្ឈមណ្ឌល អាស៊ាន-អាមេរិក អាស៊ាន-រុស្ស៊ី អាស៊ាន-ហុងកុងដើម្បីពង្រឹងភាពជាដៃគូពាណិជ្ជកម្ម-វិនិយោគ និងការលើកម្ពស់ផលិតផលកម្ពុជានៅក្នុងទីផ្សារបរទេស។
- ចាប់ពីចុងឆ្នាំ២០១៥ អាស៊ានបានប្រែក្លាយជាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងបានធ្វើឲ្យមានវឌ្ឍនភាពលើការធ្វើសេរីភាវូបនីកម្មពន្ធគយអាស៊ាន ការសម្រួលពាណិជ្ជកម្មតាមរយៈការចេញវិញ្ញាបនបត្រដោយអ្នកនាំចេញ ការចេញវិញ្ញាបនបត្រតាមប្រព័ន្ធអេឡិចត្រូនិក និហិដ្ឋានព័ត៌មានពាណិជ្ជកម្មអាស៊ាន ដំណោះស្រាយអាស៊ានសម្រាប់វិនិយោគ សេវាកម្ម និងពាណិជ្ជកម្ម ច្រកចេញ-ចូលតែមួយអាស៊ាន និងស្តង់ដានិងភាពអនុលោម និងសម្រេចបាននូវសេចក្តីប្រកាសស្តីពីអាស៊ានមួយសេចក្តីប្រកាសទីក្រុងវៀងច័ន្ទ ស្តីពីការអនុម័តលើផែនការការងារគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន សេចក្តីប្រកាសទីក្រុងវៀងច័ន្ទស្តីពីការតភ្ជាប់អាស៊ាន ឆ្នាំ២០២៥ និង កំពុងចរចាបន្តលើការធ្វើសមាហរណកម្មទ្វេភាគី និងក្នុងតំបន់។ ក្រសួងក៏បានចូលរួមចរចាយ៉ាងសកម្មលើក្របខ័ណ្ឌភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ ដែលមាន១៦ប្រទេសជាដៃគូ ដែលសមាជិកទាំងអស់បានប្តេជ្ញាថានឹងបញ្ចប់កិច្ចព្រមព្រៀងនេះនៅឆ្នាំ២០១៩ខាងមុខ

- កំពុងធ្វើកិច្ចសហការជាមួយ បណ្តាប្រទេសនៅអឺរ៉ុប មជ្ឈិមបូព៌ា អាហ្វ្រិក ទីម័រឡេសតេ និង បណ្តាប្រទេសនៅទ្វីបអាមេរិក ដើម្បីពង្រីកទីផ្សារផលិតផលកម្ពុជា
- រៀបចំរបាយការណ៍ត្រួតពិនិត្យឡើងវិញនៃ គោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលបានធ្វើរបាយការណ៍ជូនអង្គការពាណិជ្ជកម្មពិភពលោក កាលពីចុងឆ្នាំ២០១៧
- អនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ដែលរួមចំណែកក្នុងការកសាងគោលនយោបាយ អភិវឌ្ឍ និងកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យពាណិជ្ជកម្មដោយផ្តោតទៅលើកំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មធ្វើឲ្យមានកំណើនវិនិយោគទុនដោយផ្ទាល់ និងការធ្វើឲ្យមានកំណើនប្រាក់ចំណូលពីការបង់ពន្ធគយ
- អនុវត្តកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្មជំហានទី១ និងគម្រោងពិពិធកម្មនិងពង្រីកការនាំចេញកម្ពុជាជំហានទី១ ដែលធ្វើឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងអនុវត្តកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម រៀបចំយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម បញ្ជ្រាបវិស័យពាណិជ្ជកម្ម រៀបចំគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រពាណិជ្ជកម្មនានាពង្រឹងការទទួលស្គាល់គុណភាពផលិតកម្មក្នុងវិស័យស្រូវអង្ករ លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យពាណិជ្ជកម្ម និងបានជំរុញផលិតផលសូត្រនិងបង្កើតការងារក្នុងវិស័យនេះ
- អនុវត្តគម្រោង បច្ចុប្បន្នភាពយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា និងផែនទីបង្ហាញផ្លូវអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម ២០១៩–២០២៣
- អនុវត្ត គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច
- ដំណើរការត្រួតពិនិត្យទំនិញនាំចេញ-នាំចូលនៅតាមគ្រប់ច្រកទ្វារព្រំដែន និងឃ្លាំងពិនិត្យទីផ្សារក្នុងស្រុកដើម្បីទប់ស្កាត់ការនាំចូល-នាំចេញ និងការចរាចរទំនិញពុំសមស្របតាមបញ្ញត្តិបច្ចេកទេស
- សហការក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី លើការងារពង្រឹងគុណភាព និងសុវត្ថិភាព និងគោលនយោបាយពាណិជ្ជកម្ម ក្នុងទិសដៅបម្រើអ្នកប្រើប្រាស់ និងការពារកេរ្តិ៍ឈ្មោះផលិតផលកម្ពុជានៅលើទីផ្សារអន្តរជាតិ។

## តារាងទី ២.២៦ សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៤-២០១៨

| ល.រ | សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១ | តម្លៃនៃការនាំចូល | ពាន់លានរៀល | ៧៦ ៨១៨ | ៤៣ ៣១៦ | ៥០ ១៧៥ | ៥១ ៨៧០ | ៥២ ៦៩៦ |
| | | លានដុល្លារ | ១៩ ០២៤ | ១០ ៦៦៩ | ១២ ៣៧១ | ១២ ៨២៤ | ១២ ៩៨៤ |
| ២ | តម្លៃនៃការនាំចេញ | ពាន់លានរៀល | ៤៣ ១៤០ | ៣៤ ៦៨២ | ៤០ ៨៥៥ | ៣៨ ៩៨០ | ៣៩ ៣៣៦ |

| ល.រ | សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| | | លាន ដុល្លារ | ១០ ៦៨៣ | ៨ ៥៤២ | ១០ ០៧៣ | ៩ ៦៣៧ | ៩ ៦៨៧ |
| ៣ | តម្លៃនៃការនាំចេញសម្លៀកបំពាក់ | ពាន់លាន រៀល | ២១ ៥៧៦ | ២៣ ១៤៧ | ២៦ ៨៧៩ | ២២ ៨៣១ | ២៦ ២៨៧ |
| | | លាន ដុល្លារ | ៥ ៣៤៣ | ៥ ៧០១ | ៦ ៦២៧ | ៥ ៦៤២ | ៦ ៤៧៤ |
| ៤ | ការចុះបញ្ជីពាណិជ្ជកម្ម | ចំនួន | | | | | |
| ៤.១ | - ក្រុមហ៊ុន | | ៣ ៨៥០ | ៤ ៤១៧ | ៣ ១៦១ | ៥ ៧៨១ | ១១ ១៨៨ |
| ៤.២ | - ក្រុមហ៊ុនឯកបុគ្គល | | ៨៧៤ | ១ ៤៣០ | ៨៥៣ | ១ ៤៨៨ | ៣ ២២២ |
| ៤.៣ | - សាខាក្នុងស្រុក | | ៥០៥ | ៥៥០ | ៤០៩ | ២៤៦ | ៥៧៩ |
| ៤.៤ | - ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (ការិយាល័យតំណាង និងសាខាក្រុមហ៊ុនបរទេស) | | ៥៥ | ៧៣ | ៧៥ | ៩៩ | ១៤២ |
| ៥ | ការចុះបញ្ជីម៉ាក | ចំនួន | ៤ ៥៥៧ | ៤ ១៥៧ | ៤ ៣២៦ | ៣ ៨៤៧ | ៣ ៤៧៩ |
| ៦ | ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ១ ០៧៧ | ១ ១៨២ | ១ ២៧១ | ១ ៣៥០ | ១ ៤៤៥ |
| ៧ | ចំនួនកម្មករ (ប្រុស និងស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ៧៩៣ ៧៤៥ | ៨៧១ ៦៦៨ | ៨៨៤ ៤៨៩ | ៩៦៣ ៣៣០ | ៩៨៨ ៨៥៦ |
| ៨ | ប្រាក់បៀវត្សសរុប | លាន ដុល្លារ | ១ ១៩២ | ១ ៤១២ | ១ ៧៦៦ | ១ ៩៥២ | ២ ១៩៤ |

*ប្រភព :* ក្រសួងពាណិជ្ជកម្ម

២.១២៨- **បញ្ហាប្រឈម**

- ដំណើរការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ មិនទាន់មានភាពរលូន។ រីឯអ្នកប្រើប្រាស់សេវាសាធារណៈ ក្នុងវិស័យពាណិជ្ជកម្មមិនទាន់បានប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទូលំទូលាយនៅឡើយ។
- លទ្ធភាពនៃការអនុវត្តការងារនិងការបញ្ជ្រាបការយល់ដឹងដល់សាធារណៈជន ពិសេសធុរជនស្តីពីស្ថានភាព និងបរិបទនៃសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោកនៅមានកម្រិត។

២.១២៩- វិស័យទេសចរណ៍កម្ពុជា ដែលជាទេសចរណ៍វប្បធម៌និងធម្មជាតិ បាននិងកំពុងបោះជំហានរីកចម្រើនយ៉ាងខ្លាំងជាលំដាប់ ដោយរក្សាបាននូវកំណើនទេសចរណ៍ជារៀងរាល់ឆ្នាំ និងបានរួមចំណែកប្រមាណជាង១២% នៃ ផ.ស.ស.។ ព្រមជាមួយគ្នានេះ វិស័យទេសចរណ៍ត្រូវបានកំណត់ជាវិស័យអាទិភាព និងជាមាសបៃតង ដោយសារវិស័យនេះមិនត្រឹមតែបង្កើតនូវកាលានុវត្តភាពការងារ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបង្កើតប្រាក់ចំណូលជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងក្នុងស្រុក និងព្រមទាំងលំហូរចូលនូវរូបិយបណ្ណអន្តរជាតិ ដែលជាកត្តារួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។

២.១៣០- ក្នុងការអនុវត្តផ.យ.អ.ជ. ២០១៤-២០១៨ ក្រសួងទេសចរណ៍សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

### ការអភិវឌ្ឍផលិតផលទេសចរណ៍

ក្នុងឆ្នាំ២០១៧ រមណីយដ្ឋានទេសចរណ៍រាជធានី ខេត្តត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងនោះរួមមានរមណីយដ្ឋានទេសចរណ៍សរុបចំនួន៣៩៤កន្លែង ដោយមានរមណីយដ្ឋានកើនឡើងចំនួន៥៩កន្លែង រួមមាន៖

- រមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ១១៤កន្លែង
- រមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ២១កន្លែង
- រមណីយដ្ឋានធម្មជាតិកែច្នៃ២៤កន្លែង
- រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រ៦កន្លែង
- រមណីយដ្ឋានទេសចរណ៍កែច្នៃ៣៣កន្លែង
- រមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិ២៧កន្លែង
- រមណីយដ្ឋានទេសចរណ៍ធម្មជាតិ១៦៩កន្លែង

### ការពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ តាមទស្សនទាន “ សេវាមួយ ស្តង់ដាមួយ ”

ដើម្បីជំរុញការពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍តាមទស្សនទាន “ សេវាមួយស្តង់ដាមួយ” យើងបានដាក់ចេញស្តង់ដាគុណភាពទេសចរណ៍ជាច្រើន ទាំងក្នុងកម្រិតតំបន់និងថ្នាក់ជាតិ៖

**ស្តង់ដាគុណភាពទេសចរណ៍ថ្នាក់តំបន់អាស៊ាន៖**

- ស្តង់ដាសណ្ឋាគារបៃតងអាស៊ាន ស្តង់ដាផ្ទះស្នាក់អាស៊ាន ស្តង់ដាបង្គន់សាធារណៈអាស៊ាន ស្តង់ដាស្ប៉ាអាស៊ាន ស្តង់ដាទេសចរណ៍សហគមន៍អាស៊ាន ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន ស្តង់ដាបន្ទប់ប្រជុំអាស៊ាន ។

**ស្តង់ដាគុណភាពទេសចរណ៍ថ្នាក់ជាតិ៖**

- ស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ស្តង់ដាផ្ទះស្នាក់កម្ពុជា ស្តង់ដាបន្ទប់ប្រជុំកម្ពុជា ស្តង់ដាបង្គន់សាធារណៈកម្ពុជា ស្តង់ដាទេសចរណ៍សហគមន៍កម្ពុជា ស្តង់ដាទីក្រុងស្អាតកម្ពុជា ស្តង់ដាភោជនីយដ្ឋានស្អាតកម្ពុជា ស្តង់ដាមណ្ឌលព័ត៌មានទេសចរណ៍កម្ពុជា ស្តង់ដាមណ្ឌលកម្សាន្តមនុស្សពេញវ័យ

**ការងារសម្រាប់ទាក់ទាញភ្ញៀវទេសចរចិន**

- ប្រព័ន្ធវាយតម្លៃបញ្ជាក់គុណភាពសេវាកម្មទេសចរណ៍សម្រាប់ទីផ្សារចិន ការផ្សព្វផ្សាយ អប់រំ និងបញ្ជ្រាបការយល់ដឹង និងកិច្ចសហប្រតិបត្តិការ

**ការពង្រឹងការឃោសនាផ្សព្វផ្សាយទេសចរណ៍**

ក្នុងឆ្នាំ២០១៧ មានសកម្មភាពផ្សព្វផ្សាយទេសចរណ៍កម្ពុជាជាច្រើន នៅលើទីផ្សារអន្តរជាតិទាំងការប្រើប្រាស់វិធីសាស្ត្រឃោសនាតាមវិធីសាស្ត្រសាមញ្ញនិងវិធីសាស្ត្រឃោសនាតាមបែបបច្ចេកវិទ្យាទំនើប៖

- ផ្សព្វផ្សាយតាមវិធីសាស្ត្រសាមញ្ញ និងផ្សព្វផ្សាយតាមវិធីសាស្ត្របែបប្រព័ន្ធបច្ចេកវិទ្យាទំនើប
- កិច្ចសហការជាមួយដៃគូសារព័ត៌មានអន្តរជាតិ និងផលិត និងបោះពុម្ពឯកសារផ្សព្វផ្សាយ
- ពង្រឹង និងគ្រប់គ្រងស្ថានតំណាងក្រសួងទេសចរណ៍នៅក្រៅប្រទេស
- ផ្សព្វផ្សាយជាមួយអាស៊ាន និងផ្សព្វផ្សាយទេសចរណ៍ក្នុងប្រទេស

**ការពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងតំបន់ និងពិភពលោក**

- កិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយអង្គការទេសចរណ៍ពិភពលោក និងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន
- កិច្ចសហប្រតិបត្តិការទ្វេភាគី និងកិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខ័ណ្ឌអនុតំបន់

**ការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរ**

- ការងារសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរណ៍ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស
- ការងារពង្រឹង និងផ្សព្វផ្សាយសន្តិសុខ សុវត្ថិភាពទេសចរណ៍

**ការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្ត**

- អនុវត្តការប្រកួតប្រជែងជ្រើសរើស និងលើកទឹកចិត្តដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ឆ្នើម និង ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។
- ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ និង គ្រប់គ្រងអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

- គាំទ្រការទប់ស្កាត់សកម្មភាពលក់កញ្ចប់ទស្សនកិច្ចកម្សាន្ត " ថ្លៃសូន្យ "
- ធ្វើប្រតិភូកម្មមុខងារ " ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ " និងវាយតម្លៃចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។
- ណែនាំស្តីពីការអនុវត្តយុទ្ធនាការ " ភោជនីយដ្ឋានស្អាត៖ ភោជនីយដ្ឋានគ្មានសំរាមជាក្រដាស "។

### តារាងទី ២.២៧ សូចនាករនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ទេសចរណ៍អន្តរជាតិ | លាននាក់ | ៤,៥០ | ៤,៧៨ | ៥,០០ | ៥,៦០ | ៦,២០ |
| ទេសចរណ៍ជាតិ | លាននាក់ | ៩,០០ | ៩,៦៨ | ១០,៦៤ | ១០,៨៦ | ១១,០០ |
| សេវាកម្មស្នាក់នៅ | បន្ទប់ | ៥១ ៩៨៥ | ៦៣ ២៧៩ | ៧២ ៦២៣ | ៧៤ ៥៥៦ | ៨១ ៥៣៦ |
| កម្លាំងពលកម្មបម្រើឲ្យវិស័យទេសចរណ៍ | ពាន់នាក់ | ៤២៥ | ៤៥៥ | ៥០០ | ៥៥០ | ៦២០ |
| ចំណូលទេសចរណ៍អន្តរជាតិ | លានដុល្លារអាមេរិក | ២ ៧៣៦ | ៣ ០១២ | ៣ ២១២ | ៣ ៦៣៨ | ៤ ៣៧៥ |

*ប្រភព៖* ក្រសួងទេសចរណ៍

## វប្បធម៌និងវិចិត្រសិល្បៈ

២.១៣១- ដោយមានការតាំងចិត្តយ៉ាងមុតមាំ និងមានការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

### ១. លើកតម្កើងសិល្បៈទស្សនីយភាព និងការផ្សព្វផ្សាយឲ្យកាន់តែប្រសើរឡើងដើម្បីធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាក្លាយជាគោលដៅវប្បធម៌ ៖

២.១៣២- ក្រសួងបានបង្កើនការងារផ្សព្វផ្សាយវប្បធម៌ និងបង្កើតស្នាដៃថ្មីគឺជាកម្មវិធីអាទិភាពមួយដែលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង និងការចូលរួមគាំទ្ររបស់សាធារណជនតាមរយៈការបម្រើសេវាសាធារណៈ និងការរៀបចំព្រឹត្តិការណ៍វប្បធម៌។

#### ១.១ ការងារបម្រើសេវាសាធារណៈ

**តារាងទី ២.២៨ ចំនួនភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិចូលទស្សនាសារមន្ទីរ**

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| សារមន្ទីរជាតិភ្នំពេញ (អន្តរជាតិ) | នាក់ | ១៨៤ ៨១៦ | ២០៦ ៦៣៧ | ២៣៣ ៣៧១ | ៣១៣ ០៨៨ | ៣១១ ០៧៨ |
| | | ១៥៧ ២៨៧ | ១៧២ ៧៩៥ | ១៩៥ ០៥៤ | ២៣៣ ៩៧៨ | ២០៩ ២០១ |
| សារមន្ទីរទួលស្លែង (អន្តរជាតិ) | នាក់ | ៣០៥ ៣៧៣ | ៤៣៨ ៨៨២ | ៤៦៨ ១៨៤ | ៤៨៨ ៥៦៤ | ៤៧៦ ៧៤៣ |
| | | ១៨៨ ៩៧៨ | ៣៧៥ ៣៧៣ | ៣៨៩ ០៦៧ | ៤១៩ ៦៥៩ | ៤២១ ០២៤ |
| មណ្ឌលជើងឯក (អន្តរជាតិ) | នាក់ | ២១៤ ១៤៥ | ២៧៩ ៦៧៩ | ២៨៩ ០៨៧ | ២៦២ ៨៤១ | ២៤៩ ១០៣ |
| | | ១៦០ ៩៨២ | ២៣២ ៨៦៧ | ២៣២ ៩៧៧ | ២០៦ ៧៦៣ | ១៩៧ ៩៨០ |
| រមណីយដ្ឋានវត្តភ្នំ (អន្តរជាតិ) | នាក់ | ២១៨ ៩៦៥ | ១៥៧ ២៦៧ | ២១៤ ៦៦៥ | ២៦៨ ៧៩៨ | ២៧៨ ៧៣៣ |
| | | ១៥៣ ៩៨២ | ១១៤ ៣៦៧ | ១៥៧ ០៦៥ | ២០៥ ០០៨ | ២១១ ៩៧៤ |

*ប្រភព :* ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

### ១.២ ការងារផ្សព្វផ្សាយវប្បធម៌

- សហការនិងអនុញ្ញាតឲ្យបណ្តាប្រទេសជាមិត្តខ្ចីបុរាណវត្ថុជាតិទៅតាំងពិព័រណ៍នៅបណ្តាប្រទេសដើម្បីផ្សព្វផ្សាយឲ្យប្រជាជនលើពិភពលោកបានស្គាល់អំពីតម្លៃដ៏ឧត្តុង្គឧត្តមនៃអារ្យធម៌ដ៏រុងរឿងពីអតីតកាលរបស់ជាតិដែលជាការលើកស្ទួយនូវកិត្យានុភាពជាតិនិងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមកទស្សនាកម្ពុជាផងក្នុងនោះ
- រៀបចំព្រឹត្តិការណ៍សិល្បៈវប្បធម៌សំខាន់ៗ

### ១.៣ ការងារស្រាវជ្រាវ និងបោះពុម្ព

- សិក្សាស្រាវជ្រាវបុរាណស្ថានដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ
- សិក្សាស្រាវជ្រាវល្បែងប្រជាប្រិយខ្មែរ ប្រពៃណីទំនៀមទម្លាប់ជនជាតិដើមភាគតិចគ្រឹងនិងបានស្រាវជ្រាវសរសេរអត្ថបទទស្សនាវដ្តីវប្បធម៌ដែលបានបោះពុម្ពរៀងរាល់ឆ្នាំ។
- សិក្សា និងបង្កើតស្នាដៃទម្រង់របាំបុរាណ ប្រពៃណី និងល្ខោន។
- បានបង្កើតស្នាដៃគំនូរនិងចម្លាក់។

## ២. ប្រែក្លាយកម្ពុជាជាដែនដីស្វាគមន៍នៃការថតខ្សែភាពយន្តបរទេស

២.១៣៣- ផ្សព្វផ្សាយស្នាដៃភាពយន្ត ចម្រៀងខារ៉ាអូខេខ្មែរ ផលិតឯកសារកម្មវិធី «**នាទីវប្បធម៌**» ផលិតវីដេអូឯកសារវប្បធម៌ ខ្សែភាពយន្តខ្នាតវែង និងខ្លី និងវីដេអូបច្ចុប្បន្នភាព បានបញ្ចូលសារអប់រំស្តីពីការប្រឆាំងគ្រឿងញៀន និងប្រឆាំងអំពើពុករលួយ និងផ្សព្វផ្សាយទាក់ទាញការថតភាពយន្តបរទេសនៅកម្ពុជា។

## ៣.ជំរុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌

- រៀបចំធ្វើមហោស្រពជាតិស្តីពីតម្បាញសូត្រ គំនូរបុរាណ ចម្លាក់ស្ពាន់ ចម្លាក់ឈើ គំនូរវិចិត្រកម្ម

- សិក្សាស្រាវជ្រាវតម្បាញសូត្រ ទម្រង់ខ្នាតព្រះពុទ្ធ សៀវភៅក្បាច់ខ្មែរ "ភ្លីភ្លើង"សម្ភារៈប្រើប្រាស់ផ្ទះខ្មែរ
- បណ្ដុះបណ្ដាលផ្សព្វផ្សាយក្បួនខ្នាតចម្លាក់ខ្មែរតាមបណ្ដាខេត្តមួយចំនួន១៤ខេត្ត រួមមានកណ្ដាល កំពង់ស្ពឺ កំពង់ធំ ព្រៃវែង និងក្រចេះ
- បង្កើតស្នាដៃថ្មីចម្លាក់ឈើ និងគំនូរវិចិត្រកម្ម
- រៀបចំការតាំងពិព័រណ៍ស្នាដៃសិល្បៈសូនរូបក្នុងប្រទេសជារៀងរាល់ឆ្នាំ
- ចូលរួមការតាំងពិព័រណ៍ស្នាដៃសិល្បៈសូនរូបនៅក្រៅប្រទេស ដូចជា វៀតណាម ថៃ ឌូបៃ កូរ៉េ នេប៉ាល់ កូឌីវ៉រ ជប៉ុន និងចិន

### ៤. ថែរក្សាការពារអភិវឌ្ឍតំបន់បេតិកភណ្ឌដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ

២.១៣៤- ក្រសួងបានធ្វើការគាំពារ និងអភិរក្សសំណង់បុរាណដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ទ្រុឌទ្រោម បាក់បែកដោយបានជួសជុលទល់ទ្រប្រាសាទនៅតាមបណ្ដាខេត្ត និងបានធ្វើការគ្រប់គ្រងស្ថានីយបុរាណដែលប្រឈមនឹងការបាត់បង់ដោយបានចុះកំណត់និយាមការ និងបោះបង្គោលដែនការពារស្ថានីយនៅតាមរាជធានី ខេត្តមួយចំនួន។ ទន្ទឹមនេះក៏បានរៀបចំឯកសារសុំបញ្ចូល "**ល្ខោនខោលវត្តស្វាយអណ្ដែត**" ចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិត្រៀមសម្រាប់ឆ្នាំ២០១៨ បានសម្រេចជាស្ថាពរ ហើយក៏បានដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌រូបី និងអរូបីទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកផងដែរ។

#### ៤.១.សម្បត្តិបេតិកភណ្ឌវប្បធម៌រូបី-អរូបីដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

**តារាងទី ២.២៩ ការចុះបញ្ជីបេតិកភណ្ឌពិភពលោក**

| ល.រ. | បរិយាយ | កាលបរិច្ឆេទ |
|---|---|---|
| ១ | បញ្ចូល "ប្រពៃណីនិទានរឿងរាមកេរ្តិ៍តាគ្រុឌចុះក្នុងបញ្ជី "បេតិកភណ្ឌស្មារតីចងចាំពិភពលោក | ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤ |
| ២ | ល្បែងទាញព្រ័ត្រ និងពិធីប្រពៃណីទាញព្រ័ត្រ ចុះបញ្ជី បេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ |
| ៣ | ចាប៉ីដងវែងចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ |
| ៤ | តំបន់ប្រាសាទសំបូរព្រៃគុកចុះបញ្ជីបេតិកភណ្ឌពិភពលោក | ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ |
| ៥ | ល្ខោនខោលវត្តស្វាយអណ្ដែតចុះបញ្ជីបេតិកភណ្ឌ វប្បធម៌អរូបីនៃមនុស្សជាតិ | ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ |

*ប្រភព :* ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## តារាងទី ២.៣០ ការងារអភិរក្សនិងជួសជុល

| ល.រ. | សូចនាករ | ទីតាំង |
|---|---|---|
| ១ | អភិរក្សនិងជួសជុលប្រាសាទបន្ទាយឆ្មានិងបន្ទាយទ័ព | ខេត្តបន្ទាយមានជ័យ |
| ២ | អភិរក្សនិងជួសជុលប្រាសាទត្រពាំងប្រាសាទនិងស្ពានទ័ព | ខេត្តឧត្តរមានជ័យ |
| ៣ | អភិរក្សនិងជួសជុលប្រាសាទបាណន់ ប្រាង្គខាងជើងប្រាសាទបាសែត ប្រាសាទឯកភ្នំ និងប្រាសាទស្នឹង | ខេត្តបាត់ដំបង |
| ៤ | អភិរក្សនិងជួសជុលប្រាសាទព្រះស្ទឹង និងប្រាសាទបាកាន | ខេត្តព្រះវិហារ |
| ៥ | ជួសជុលក្រុមប្រាសាទសំបូរព្រៃគុក | ខេត្តកំពង់ធំ |
| ៦ | អភិរក្សនិងជួសជុលប្រាសាទភ្នំគ្រប់ ព្រះវិហារវត្តមហាលាភ ក្លោងទ្វារចូល ខាងកើតប្រាសាទនគរបាជ័យ ព្រះវិហារវត្តស្វាយសាច់ភ្នំ ប្រាសាទហាន់ជ័យ មណ្ឌលប្រាសាទហាន់ជ័យ | ខេត្តកំពង់ចាម |
| ៧ | អភិរក្សនិងជួសជុលប្រាសាទព្រះធាតុតូច ប្រាសាទជើងអង | ខេត្តត្បូងឃ្មុំ |
| ៨ | អភិរក្សនិងជួសជុលប្រាសាទកោះច្រឡឹង ប្រាសាទស្រីគ្រប់លក្ខណ៍ | ខេត្តកណ្ដាល |
| ៩ | អភិរក្សនិងជួសជុលប្រាសាទភ្នំជីសូរ ប្រាសាទនាងខ្មៅ ប្រាសាទថ្មដុះ ប្រាសាទតាម៉ៅ ប្រាសាទតាព្រហ្ម (ទន្លេបាទី) | ខេត្តតាកែវ |
| ១០ | អភិរក្ស និងជួសជុលប្រាសាទព្រះសម្ដី | ខេត្តត្បូងឃ្មុំ |

*ប្រភព :* ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

### ៤.៧. គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក

**ការងារផ្សព្វផ្សាយ និងជំរុញការយល់ដឹងពីបេតិកភណ្ឌពិភពលោក**

- បោះពុម្ពសៀវភៅសម្រាប់ការងារផ្សព្វផ្សាយពីបេតិកភណ្ឌពិភពលោក
- ប្រមូលនិងចងក្រងសៀវភៅស្ដីពីសម្បត្តិបេតិកភណ្ឌវប្បធម៌ដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោករហូតដល់ឆ្នាំ២០១៧
- ប្រមូលនិងចងក្រងកូនសៀវភៅលឿងស្ដីពីរចនាសម្ព័ន្ធ និងទំនាក់ទំនងនៅក្នុងគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក
- សិក្សានិងតាមដានរាល់ឯកសារ និងគ្រប់ទិដ្ឋភាពទាំងអស់នៃសម័យប្រជុំលើកទី៤១ នៅទីក្រុងក្រាកូវ ប្រទេសប៉ូឡូញ
- សិក្សាលើការណែនាំរបស់អង្គការពិគ្រោះយោបល់ ECOMOS និង IUCN លើឯកសារស្នើសុំចុះបញ្ជី និងសិក្សាលើអនុសាសន៍ឯកសារសំណើដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌និងរមណីយដ្ឋានធម្មជាតិរបស់រដ្ឋភាគីនៃអនុសញ្ញាបេតិកភណ្ឌឆ្នាំ១៩៧២ សម្រាប់កិច្ចប្រជុំលើកទី៤១ទីក្រុងក្រាកូវ ប្រទេសប៉ូឡូញ។

## ៥. ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិបាលកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសេវាកម្ម

២.១៣៥- ក្រសួងបានជំរុញការងារធ្វើកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការក៏ដូចជាការពង្រឹងការអនុវត្តច្បាប់ ការរៀបចំបទដ្ឋានគតិយុត្ត និងការងារផ្ដល់សេវាសាធារណៈ។

## ៥.១.ការងារផ្តល់សេវាសាធារណៈ

### តារាងទី ២.៣១ ការផ្តល់សេវាសាធារណៈ

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ចេញលិខិតអនុញ្ញាតសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ចម្រៀង | បទ | ៨៤ | ១២៧ | ៨៥ | ២០៧៧ | ១៥៨ |
| ផ្តល់អាជ្ញាបណ្ណបើកផលិតកម្មថ្មី | ច្បាប់ | ៤១ | ៦៦ | ៥៤ | ៥៩ | ៧៦ |
| ចុះបញ្ជីសុំផលិតវីដេអូខ្មែរ | ចំណងជើង | ១៣៦ | ១៤៤ | ៩៩ | ១០៦ | ៩៩ |
| អនុញ្ញាតច្បាប់ថតវីដេអូខ្មែរ | ចំណងជើង | ១២១ | ១០៧ | ៥៦ | ៦១ | ៨៥ |
| ផ្តល់ទិដ្ឋការឲ្យធ្វើអាជីវកម្មដល់វីដេអូរឿងខ្មែរ | ចំណងជើង | ១៤៨ | ១៤២ | ១០៦ | ៨៥ | ៦៨ |
| ផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូរឿងបរទេស | ចំណងជើង | ៤៣៤ | ៤១៥ | ៥០៨ | ៥៥២ | ៥៥០ |
| បានត្រួតពិនិត្យអនុញ្ញាតនាំចេញ-នាំចូលវត្ថុសិល្បៈ វត្ថុអនុស្សាវរីយ៍ | រូប | ៨ ៦៩៩ | ៥ ៥៥១ | ៤ ២៩៧ | ៨ ២៣៩ | ២ ៨០០ |
| អ្នកស្រាវជ្រាវចូលអាននៅបណ្ណាល័យជាតិ | នាក់ | ៧ ៩១៨ | ៧ ៨២៩ | ១៥ ៣៧៦ | ៩ ៧៤៨ | ១៥១ ៤២០ |
| ផ្តល់លេខ ISBN ដល់អ្នកបោះពុម្ព | លេខ | ៥៥៤ | ៥៧២ | ៥៩២ | ៤៥២ | ៥៣១ |

*ប្រភព :* ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## ៥.២. ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈនិងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សដូចជាតាមរយៈការធ្វើនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិជូនមន្ត្រីរាជការនិងដំឡើងថ្នាក់និងការតែងតាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់គោរពទៅតាមឋានានុក្រម
- ពិនិត្យឡើងវិញស្ថានភាពនៃការប្រើប្រាស់មន្ត្រីរាជការនៅតាមអង្គភាព រៀបចំចងក្រងរចនាសម្ព័ន្ធមុខតំណែង ការពិពណ៌នាមុខតំណែងមន្ត្រីរាជការ ដើម្បីធានាបាននូវការជ្រើសរើសការពង្រាយមន្ត្រីរាជការ ការប្រើប្រាស់ធនធានមនុស្សស្របតាមសេចក្តីត្រូវការពិតប្រាកដនៃការងារ
- ប្រឡងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌថ្មី និងការប្រឡងប្តូរប្រភេទក្របខ័ណ្ឌផ្ទៃក្នុងក្រសួង
- ពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្មសាធារណៈ។

## ៥ .៣. ការពង្រឹងសមត្ថភាពមន្ត្រីរាជការ

- បណ្តុះបណ្តាលនិងសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការលើចំណេះជំនាញពាក់ព័ន្ធនឹងការអនុវត្តការងារ ដូចជាការគ្រប់គ្រងរដ្ឋបាលសាធារណៈ អភិរក្ស និងចុះបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបី ជំនាញជាមូលដ្ឋាននៃវិជ្ជាជីវៈភាពយន្ត សិក្ខាសាលាស្តីពីការអនុវត្តអនុសញ្ញា២០០៣ ស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី និងអនុសញ្ញា២០០៥ស្តីពីការការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញាតិវប្បធម៌។

### ៥.៤ ការពង្រឹងការអនុវត្តច្បាប់ និង បទដ្ឋានគតិយុត្ត

- បង្រ្កាបបទល្មើសស្នាដៃភាពយន្ត និងដកហូតវីស៊ីឌីគ្មានទិដ្ឋាការ
- សហការជាមួយនគរបាលបេតិកភណ្ឌ និងអាជ្ញាធរដែនដីទប់ស្កាត់ការបំផ្លាញបុរាណស្ថាន
- ក្រៅអំពីពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តដែលមានស្រាប់ ក្រសួងបានរៀបចំព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសសំខាន់ៗដែលជាមូលដ្ឋានច្បាប់ក្នុងការអភិរក្ស និងអភិវឌ្ឍវប្បធម៌។

### ៥.៥. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

- សហការជាមួយអង្គការជាតិ និងអន្តរជាតិ ព្រមទាំងបណ្តាប្រទេសជាមិត្តជាច្រើន ដើម្បីកៀរគររកមូលនិធិអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ
- ផ្លាស់ប្តូរវប្បធម៌តាមរយៈការសម្តែងសិល្បៈ ការរៀបចំព្រឹត្តិការណ៍វប្បធម៌ ឬសប្តាហ៍វប្បធម៌ជាលក្ខណៈទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសជាមិត្តនានា
- សម្របសម្រួលក្នុងការឲ្យខ្ចីវត្ថុបុរាណខ្មែរយកទៅតាំងពិព័រណ៍ផ្សព្វផ្សាយនៅតាមបណ្តាប្រទេសជាមិត្តនានា ដើម្បីផ្សព្វផ្សាយអំពីអារ្យធម៌ដ៏រុងរឿងរបស់ជាតិ
- សហការជាមួយបណ្តាប្រទេសជាមិត្តរួមមាន៖ សហរដ្ឋអាមេរិក និងប្រទេសថៃក្នុងក្របខ័ណ្ឌសហការការពារ និងទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវនាំចេញដោយខុសច្បាប់ពីកម្ពុជា
- សហការយ៉ាងជិតស្និទ្ធជាមួយអង្គការ និងដៃគូប្រតិបត្តិការលើវិស័យសិល្បៈវប្បធម៌ដូចអង្គការសិល្បៈខ្មែរអមតៈ និងវិទ្យាស្ថានសិល្បៈខ្មែរតាមរយៈការចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការការងារ ដើម្បីរៀបចំការតាំងពិព័រណ៍ការរៀបចំមហោស្រពសិល្បៈ ការសម្តែងសិល្បៈ និងសិក្ខាសាលា
- សហការយ៉ាងជិតស្និទ្ធជាមួយអង្គការយូណេស្កូ ប្រចាំនៅកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការ សមាគម និងវិស័យឯកជន ដើម្បីរៀបចំឯកសារ "គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌"
- ពង្រឹងកិច្ចសន្ទនាតាមរយៈ "វេទិកាសិល្បៈ" ដើម្បីផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធនានាទាំងផ្នែករដ្ឋ និងឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល អ្នកប្រកបអាជីពក្នុងវិស័យវប្បធម៌បានបញ្ចេញយោបល់និងស្វែងយល់ពីគ្នាទៅវិញទៅមកដើម្បីរួមគ្នាអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ដូចជាបានរៀបចំវេទិកាសិល្បៈ ស្តីពី "ឧស្សាហកម្មវប្បធម៌នៅកម្ពុជា" ជាដើម
- សហការជាមួយក្រសួង ស្ថាប័នជាតិនានា ពិសេសចូលរួមសហការរៀបចំកម្មវិធីសិល្បៈទាំងក្នុងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងចូលរួមសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាក្នុងការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត នៅខេត្តសៀមរាប

- សហការជាមួយអង្គការស្ថាប័នអន្តរជាតិ និងបណ្តាប្រទេសនានាក្នុងការកសាងសមត្ថភាពជំនាញការអភិរក្ស និងការផ្សព្វផ្សាយសិល្បៈវប្បធម៌ជាតិ មហោស្រព ការតាំងពិព័រណ៍ សិក្ខាសាលា ពិសេសជាមួយអង្គការយូណេស្កូក្នុងការអនុវត្តអនុសញ្ញាឆ្នាំ២០០៣ ស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី និងអនុសញ្ញាឆ្នាំ២០០៥ ស្តីពីការការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។

**បញ្ហាប្រឈម**

២.១៣៦- ទន្ទឹមនឹងលទ្ធផលដែលបានរៀបរាប់ខាងលើនេះ ក្រសួងក៏បានជួបប្រទះបញ្ហាប្រឈមដែលកំពុងអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- ខ្វះខាតសាស្ត្រាចារ្យក្របខ័ណ្ឌសាកលវិទ្យាល័យ និងសាលាមធ្យមវិចិត្រសិល្បៈដែលមានជំនាញ និងបទពិសោធន៍។
- បទល្មើសក្នុងវិស័យវប្បធម៌បានកើតមានជាបន្តបន្ទាប់ដែលទាមទារឲ្យមានការចូលរួមសហការ និងថែរក្សាការពារ ពីក្រសួងស្ថាប័នពាក់ព័ន្ធ ព្រោះថាទំហំការងារវប្បធម៌ទូទាំងប្រទេសទាំងបេតិកភណ្ឌរូបី និងអរូបីមានវិសាលភាពធំធេង និងទូលំទូលាយ។
- ច្បាប់និងបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងនិងការផ្តល់សេវាលើវិស័យវប្បធម៌នៅខ្វះខាត និងខ្វះចន្លោះច្រើនរួមទាំងការអនុវត្តនៅមានកម្រិត ក្នុងស្ថានភាពជាក់ស្តែងទាំងក្នុង និងក្រៅប្រទេស ។
- លទ្ធភាពនៃការផ្សព្វផ្សាយ ការជូនដំណឹងតាមគ្រប់រូបភាពនៅខ្វះចន្លោះ និងពុំទាន់បានទូលំទូលាយ។
- សមត្ថភាពនៃការច្នៃប្រឌិតបង្កើតផលិតផលវប្បធម៌ថ្មីៗប្រកបដោយគុណភាពមានកម្រិត និងការអនុវត្តច្បាប់នៅមានកម្រិត ដែលធ្វើឲ្យមានការលួចចម្លងស្នាដៃ ការតែងនិពន្ធនៅមានបន្ត។
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជំរុញដល់វិស័យវប្បធម៌នៅមានការខ្វះខាតច្រើន ដូចជាសាលសម្តែងសិល្បៈៗល។
- ប្រព័ន្ធព័ត៌មានមិនទាន់មានប្រព័ន្ធច្បាប់គ្រប់គ្រងច្បាស់លាស់ ទន្ទឹមនឹងការយល់ដឹងការឲ្យតម្លៃនិងការប្រើប្រាស់សិល្បៈវប្បធម៌ជាតិពីសំណាក់សិល្បករ សិល្បការិនី យុវជន និងមហាជននៅមានកម្រិតកំពុងធ្វើឲ្យប៉ះពាល់ខ្លាំងដល់វប្បធម៌ប្រពៃណីដ៏ល្អថ្លៃថ្លារបស់ជាតិ។

## ៦.២- ការអភិវឌ្ឍឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យម វិស័យឧស្សាហកម្ម

២.១៣៧- ក្រសួងបានធ្វើការកែទម្រង់ការងារលើការងារគ្រប់គ្រងរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដោយពង្រឹងការអនុវត្តច្បាប់ និងការធ្វើវិសោធនកម្មច្បាប់ស្តីពីការ

គ្រប់គ្រងរោងចក្រ និងសិប្បកម្មឲ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងនោះផ្តោតសំខាន់ទៅលើការងារអធិការកិច្ចជាចម្បង ដោយប្រកាន់យកស្មារតីចុះជួយណែនាំដោយផ្ទាល់ដល់ម្ចាស់រោងចក្រសហគ្រាសអំពីបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស ហើយជៀសវាងដាច់ខាតការចុះទៅរំខាន ឬកៀបសង្កត់គេ។ លើសពីនេះក្រសួងបានដាក់ចេញរួចហើយនូវប្រកាសស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឧបករណ៍គ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលមានហានិភ័យ និងបានពង្រឹងបន្ថែមដល់ការគ្រប់គ្រងឡចំហាយ ដើម្បីកាត់បន្ថយជាអតិបរិមានូវបាតុភាពដែលបង្កមហន្តរាយដល់មនុស្ស សត្វ និងទ្រព្យសម្បត្តិផ្សេងៗជាយថាហេតុ ។

- រោងចក្រសរុបមានចំនួន១ ៦១១រោងចក្រ សរុបកម្លាំងពលកម្មចំនួន១ ០០៣ ២៥៣នាក់
- ធ្វើវិសោធនកម្មច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្ម
- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប
- អនុវត្តការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម និងគំរូឧស្សាហកម្មទៅវិញទៅមកជាមួយប្រទេសដៃគូ(សឹង្ហបូរី ជប៉ុន ចិន) ដើម្បីពង្រឹងកិច្ចការការពារកម្មសិទ្ធិឧស្សាហកម្ម និងទាក់ទាញវិនិយោគ
- កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិទី១៥១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម និងជាសមាជិកទី៦៦ នៃសន្ធិសញ្ញាទីក្រុងហ្សឺណែវ(ឆ្នាំ១៩៩៩) នៃកិច្ចព្រមព្រៀងទីក្រុងហេចទាក់ទងនឹងការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ
- ជំរុញបង្កើនផលិតភាពសំដៅកាត់បន្ថយថ្លៃដើម បង្កើនគុណភាព ទិន្នន័យផលិតកម្ម និងការប្រកួតប្រជែង ក្រសួងបានបណ្តុះបណ្តាលនិងប្រឹក្សាយោបល់ជូនដល់ម្ចាស់ និងបុគ្គលិកកម្មកររោងចក្រសហគ្រាសនិងសិប្បកម្ម លើវិធីសាស្ត្រ ស៥ ខាយហ្សិន(សម្រិតសម្រាំង-សណ្តាប់ធ្នាប់-សម្អាត-ស្តង់ដា-ស្ថិតស្ថេរ) លើប្រព័ន្ធគ្រប់គ្រងផលិតកម្ម ថែទាំម៉ាស៊ីន សុវត្ថិភាពម្ហូបអាហារ ផលិតកម្មលីន គ្រប់គ្រងពុទ្ធិ គ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់ ផលិតភាពបៃតង និងឧត្តមភាពធុរកិច្ច
- ផ្តល់សេវាបច្ចេកទេស និងបច្ចេកវិទ្យា និងការងារវាយតម្លៃទទួលស្គាល់ត្រូវបានពង្រឹងបន្ថែម និងធ្វើកំណែទម្រង់ថ្មី
- សិក្សាស្រាវជ្រាវ និងបកប្រែ ចងក្រងឯកសារព្រាងច្បាប់ ស្តីពីការជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យានៅកម្ពុជា
- កែសម្រួលសេចក្តីណែនាំស្តីពីការគ្រប់គ្រងសំណល់ឧស្សាហកម្ម

- រៀបចំនីតិវិធីត្រួតពិនិត្យវាយតម្លៃ និងបញ្ជាក់ការគ្រប់គ្រងបរិស្ថានឧស្សាហកម្មក្នុងរោងចក្រសិប្បកម្ម
- ចេញប្រកាសកំណត់តម្លៃសេវាសាធារណៈសម្រាប់ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពឧស្សាហកម្ម
- រៀបចំឡើងវិញនូវកម្រងសេវាសាធារណៈ កំណែទម្រង់លិខិតបទដ្ឋានគតិយុត្ត និងការធ្វើវិសោធនកម្មច្បាប់
- សម្របសម្រួលការងារផ្ទេរបច្ចេកវិទ្យារវាងចិន និងគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការ អាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- តម្លើងប្រព័ន្ធទំនើបកម្មកម្មសិទ្ធិឧស្សាហកម្ម
- ទទួលសំណុំលិខិតស្នើចុះបញ្ជីប្រកាសនីយបត្រ និងបានផ្តល់វិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មជូនតក្កករខ្មែរមួយរូប។
- អនុវត្តការងារវាយតម្លៃទទួលស្គាល់ ជូនស្ថាប័ន និងក្រុមហ៊ុនឯកជន

### តារាងទី ២.៣២ សូចនាកររបស់វិស័យឧស្សាហកម្ម

| សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ចំនួនរោងចក្រ | ១ ៣០១ | ១ ៤៥០ | ១ ៥៧៩ | ១ ៥២២ | ១ ៦១១ |
| កម្លាំងពលកម្ម | ៧៧៨ ៨៧៨ | ៨៥៩ ៥៤៦ | ៩២១ ៨៥៨ | ៩៨២ ២០៣ | ១ ០០៣ ២៥៣ |
| តម្លៃសរុបបរិមាណផលិតផល (លានដុល្លារអាមេរិក) | ៧ ៤១៣ | ៨ ៩៧៣ | ៩ ៥៦៨ | ១០ ៧៩៤ | ១២២០៣ |

*ប្រភព:* ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

### សហគ្រាសធុនតូចនិងមធ្យម

- រៀបចំក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមកម្ពុជា
- រៀបចំអនុក្រឹត្យស្តីពីការបង្កើតសហភាពនៃសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា
- ពន្លឿនការចុះបញ្ជី ការចេញលិខិតអនុញ្ញាតផ្សេងៗដល់ម្ចាស់រោងចក្រសហគ្រាស ក្រសួងបានចេញប្រកាសចំនួន៤ ទាក់ទងនឹងដំណើរការប្រតិភូកម្មអំណាចជូនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសស្តីពីការដាក់ប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលជាតិអ៊ីយ៉ូដ
- ស្នើសុំអ្នកជំនាញពីយូនីសេហ្វ ជួយរៀបចំអភិវឌ្ឍសិប្បកម្មកែច្នៃអំបិលនិងបច្ចេកទេសបញ្ចូលជាតិអ៊ីយ៉ូដ
- ផ្តល់ជំនួយបច្ចេកទេសនិងសម្របសម្រួលសកម្មភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យម ផលិតនិងកែច្នៃម្ហូបអាហារចំនួន១៣ ដើម្បីធ្វើការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មី

- បញ្ចប់សេចក្តីព្រាងគោលនយោបាយលើកទឹកចិត្ត សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម
- បណ្តុះបណ្តាលធនធានមនុស្សលើជំនាញផ្នែកទន់ និងផ្នែករឹង ដល់ម្ចាស់ បុគ្គលិក កម្មករ និងមន្ត្រី ជំនាញពាក់ព័ន្ធ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម តាមរយៈវគ្គខ្លីៗ នៅនឹងកន្លែង ក្នុងនិងក្រៅប្រទេស
- សាកល្បងបង្កើតសួនអេកូ សហគ្រាសធុនតូច និងមធ្យម ក្រោមប្រធានបទ "ខេត្តមួយ សួនសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មមួយ" តាមរយៈកិច្ចសហប្រតិបត្តិការមេគង្គ-ឡាងឆាង
- រៀបចំយន្តការសម្របសម្រួលការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាកម្មនានាក្រោមដំបូលតែមួយ
- សម្រួលដល់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ឲ្យកាន់តែមានភាពងាយស្រួល និងសាមញ្ញ តាមរយៈការចុះបញ្ជីតាមអ៊ិនឡាញ
- កំពុងដំណើរការរៀបចំបញ្ជីវិភាគមុខងាររួចហើយសម្រាប់ការធ្វើប្រតិភូកម្មអំណាចក្នុងការចុះបញ្ជីសហគ្រាស សិប្បកម្មដែលមានដើមទុនក្រោម៥ម៉ឺនដុល្លារអាមេរិក និងគ្មានហានិភ័យជូនរដ្ឋបាល ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ចងក្រងទិន្នន័យមូលដ្ឋានផលិតកម្មរវាងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

**តារាងទី ២.៣៣ ចំនួនសហគ្រាសនិងកម្លាំងពលកម្ម**

| សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| សហគ្រាស | ១៤៣ ១៩២ | ១៤៦ ៨៤២ | ១៥២ ៣៣២ | ១៥៥ ៦៤០ | ១៥៥ ៧៤៥ |
| ពលកម្ម | ៩៣៦ ៤៧៦ | ៩៦០ ៣៤៧ | ៩៩៦ ៦៧៣ | ១ ១០៦ ៧៤៥ | ១ ១០៧ ៨០៦ |

*ប្រភព:* ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

## វិស័យស្តង់ដានីយកម្ម

- ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៤-២០១៨ ស្តង់ដាចំនួន៨៩៥ ត្រូវបានអនុម័ត
- រៀបចំប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ទៅលើគុណភាព និងសុវត្ថិភាពផលិតផលនិងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងរបស់រោងចក្រ សហគ្រាសធុនតូច និងមធ្យមឲ្យស្របទៅតាមស្តង់ដាជាតិ ស្តង់ដាតំបន់ និងអន្តរជាតិ ក្នុងការធានាផលិតផល និងផលិតកម្មនៅកម្ពុជា ក៏បានប្រព្រឹត្តទៅស្របតាមស្តង់ដា ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព

- ប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់គុណភាពផលិតផលតាមស្តង់ដាផលិតផល និងបញ្ជាក់ប្រព័ន្ធគ្រប់គ្រងតាមស្តង់ដា( ISO 9001, ISO 14001, ISO 22000, GMP ។ល។) ប្រព័ន្ធទាំងពីរនេះត្រូវបានវាយតម្លៃទទួលស្គាល់ពីអង្គភាពវាយតម្លៃទទួលស្គាល់អន្តរជាតិរបស់ប្រទេសអូស្ត្រាលី និងញ៉ូវហ្សេឡែន ស្របតាមស្តង់ដាអន្តរជាតិ ISO/IEC 17065 និង ISO/IEC 17021 ។
- រៀបចំប្រព័ន្ធចុះបញ្ជីផលិតផល ស្របទៅតាមគោលការណ៍អន្តរជាតិ និងកិច្ចសម្របសម្រួលទទួលស្គាល់ទៅវិញទៅមក ក្នុងអាស៊ានដើម្បីបញ្ជាក់ពីសុវត្ថិភាពដល់អ្នកប្រើប្រាស់
- ទប់ស្កាត់ការប្រើប្រាស់សារធាតុគ្រោះថ្នាក់ ទប់ស្កាត់ការផលិតអាវុធគីមី ក៏ដូចជាការទប់ស្កាត់ការជួញដូរ ឬផលិតគ្រឿងញៀនដោយប្រើប្រាស់សារធាតុគីមីនាំចូល ក្រសួងក៏បានរៀបចំយន្តការត្រួតពិនិត្យ និងតាមដានការប្រើប្រាស់សារធាតុគីមី នៅក្នុងវិស័យឧស្សាហកម្ម ដោយធ្វើការកំណត់ស្តង់ដាប្រើប្រាស់សារធាតុគីមី និងស្តង់ដាប្រើប្រាស់សារធាតុគីមីជាប់បញ្ញត្តិ
- រៀបចំប្រព័ន្ធចុះបញ្ជីផលិតផលនិងចុះបញ្ជីសុវត្ថិភាពផលិតផល ព្រមទាំងយន្តការគ្រប់គ្រងសារធាតុគីមី ឬសារធាតុគីមីគ្រោះថ្នាក់ ឬទំនិញគ្រោះថ្នាក់
- ពង្រឹងសមត្ថភាព ក៏ដូចជាផ្តល់ភាពទុកចិត្តទៅវិញទៅមករវាងអ្នកផលិត និងអ្នកប្រើប្រាស់ ក្រសួងក៏បានប្រឹងប្រែងរៀបចំបង្កើននូវសមត្ថភាពនៃការធ្វើការសាកល្បងវិភាគរបស់មន្ទីរពិសោធន៍ដើម្បីឲ្យទទួលបាននូវការវាយតម្លៃទទួលស្គាល់សមត្ថភាពធ្វើការសាកល្បង ជាអន្តរជាតិ អនុលោមតាមស្តង់ដា ISO/IEC 17025។
- វាយតម្លៃទទួលស្គាល់ជាអន្តរជាតិ អនុលោមតាមស្តង់ដា ISO/IEC 17025 នេះ ជាសមត្ថភាពនៃការធ្វើសាកល្បងវិភាគរបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ចំពោះគំរូផលិតផលម្ហូបអាហារ និងទឹក ទាំងផ្នែកមីក្រូជីវសាស្ត្រ និងគីមីសាស្ត្រ

**តារាងទី ២.៣៤ ចំនួនគំរូផលិតផលពីឆ្នាំ២០១៤-២០១៨**

| ឆ្នាំ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|
| ចំនួនគំរូ | ៣ ៤២៦ | ៣ ៦៦៤ | ៥ ០២០ | ៥ ៥៣៤ | ៤ ៧៦៤ | ២២ ៤០៨ |

*ប្រភព:* ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

## មាត្រសាស្ត្រ

- ព្យាករសកម្មឧបករណ៍មាត្រាសាស្ត្របានចំនួន១៧៥៧គ្រឿង
- បង្កើតមន្ទីរពិសោធន៍ ផ្នែកអគ្គិសនី
- ពង្រឹងសមត្ថកិច្ចគ្រប់គ្រង ឲ្យមានការទទួលស្គាល់លំដាប់អន្តរជាតិ ISO/IEC 17025 និង 17020

- បង្កើនសមត្ថភាពក្នុងនាមជាសមាជិកអាស៊ាន អង្គការអន្តរជាតិ និងតំបន់
- ជំរុញសកម្មភាពការងារនីត្យានុកូលមាត្រាសាស្ត្រនិងជំរុញការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ និង លិខិតបទដ្ឋានគតិយុត្តដើម្បីជាមូលដ្ឋានក្នុងការអនុវត្តការងារមាត្រាសាស្ត្រ
- បង្កើតវគ្គបណ្តុះបណ្តាលជំនាញមាត្រាសាស្ត្រឆ្លើយតបតាមតម្រូវការជាក់ស្តែង និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងអង្គភាព និងជំរុញដល់ធុរជនអនុវត្តដោយតម្លាភាព និងគណនេយ្យភាពក្នុងសង្គម។

## ២.១៣៨- បញ្ហាប្រឈម

- ការត្រួតពិនិត្យនិងរៀបចំឡើងវិញនូវគម្រោងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគនៅតាមវិស័យនានាដែលមានចែងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នៅមានកម្រិត
- ការយល់ដឹងអំពីនីតិវិធីនិងបែបបទស្នើសុំបង្កើតនិងវិញ្ញាបនបត្រដំណើរការរោងចក្រសិប្បកម្ម នៅមានកម្រិត
- កង្វះធនធានមនុស្ស ហិរញ្ញវត្ថុ និងបរិក្ខារក្នុងដំណើរការចុះបញ្ជីសហគ្រាស
- ខ្វះមធ្យោបាយដឹកជញ្ជូនកូនទម្ងន់ស្តង់ដា២០តោន ចុះត្រួតពិនិត្យឧបករណ៍មាត្រាសាស្ត្រ

## ៦.៣- ការអភិវឌ្ឍទីផ្សារការងារ

### ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- រៀបចំនូវបញ្ជីត្រួតពិនិត្យអធិការកិច្ចការងារកាន់តែមានប្រសិទ្ធភាព តម្លាភាព និងភាពជឿជាក់ ព្រមទាំងដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់មន្ត្រីអធិការកិច្ចការងារ ជាពិសេសរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មជនបរទេស តាមការស្នើសុំកូតាបណ្ណ និងសៀវភៅការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- ដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងពី១៥៣ដុល្លារអាមេរិក ដល់ចំនួន១៧០ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ឆ្នាំ២០១៨ បូករួមនឹងអត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗអាចទទួលប្រាក់ខែពី១៨៧ ទៅដល់១៩៨ដុល្លារអាមេរិក។
- បន្តដំណើរការគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ព្រមទាំងបានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារ ។

- ចេញសេចក្តីណែនាំដើម្បីឲ្យម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាននានា អនុវត្តការអនុញ្ញាតឲ្យបងប្អូនកម្មការិនីមានផ្ទៃពោះចេញមុនម៉ោងធ្វើការងារយ៉ាងតិច១៥នាទី និងអនុញ្ញាតឲ្យបងប្អូនកម្មករនិយោជិតជាស្ត្រីខ្មែរឥស្លាមអាចប្រើប្រាស់សម្លៀកបំពាក់តាមប្រពៃណីឥស្លាម។
- ជំរុញគ្រប់រោងចក្រត្រូវរៀបចំបន្ទប់បំបៅកូន សម្រាប់កម្មការិនីដែលមានកូនក្រោមអាយុ១២ខែ និងត្រូវមានទារកដ្ឋានសម្រាប់កម្មការិនីដែលមានកូនអាយុលើស១៨ខែ។
- វិធានការដោះស្រាយទប់ស្កាត់ករណីដួលសន្លប់ ដោយតម្រូវឲ្យគ្រប់រោងចក្រសហគ្រាសទាំងអស់ ពិនិត្យលក្ខណៈបច្ចេកទេសនិងស្ថានភាពជុំវិញរោងចក្រឲ្យមានសុវត្ថិភាពមុនពេលចូលធ្វើការ។
- រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស គ្រឹះស្ថាន។

**ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- រៀបចំឲ្យមានអនុក្រឹត្យស្តីពីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កំណត់យកថ្ងៃទី១៥ ខែមិថុនា ជារៀលរាល់ឆ្នាំ។
- បណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្ររយៈពេលខ្លី(ក្រោមរយៈពេល១ឆ្នាំ) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បរិញ្ញាបត្របច្ចេកវិទ្យា សញ្ញាបត្រវិស្វករ បរិញ្ញាបត្រជាន់ខ្ពស់ និងហ្វឹកហ្វឺនកូនជាងដល់សិក្ខាកាម សិស្ស និងនិស្សិត លើមុខជំនាញឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេកទេស សិប្បកម្មសេវាកម្មទេសចរណ៍ និងកសិកម្ម។
- អភិវឌ្ឍកញ្ចប់ស្តង់ដាផ្អែកលើសមត្ថភាព លើវិស័យសំខាន់ៗមួយចំនួន។

**ការអភិវឌ្ឍមុខរបរ និងការងារ**

- សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កើនចំនួន២១,១%ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមប្រមាណជាង២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។
- សហគ្រាសផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ បានដើរតួនាទីយ៉ាងសកម្មក្នុងការបំពេញឲ្យគ្នាទៅវិញទៅមករវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងបានរួមវិភាគទានយ៉ាងធំក្នុងសេដ្ឋកិច្ចជាតិប្រមាណ៦ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។
- កម្លាំងពលកម្មសរុប៩៩,៣% មានការងារធ្វើ។
- កំពុងអនុវត្តកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិស្តីពីមុខរបរ និងការងារសម្រាប់យុវជននៅកម្ពុជា ដើម្បីអភិវឌ្ឍន៍យុវជន និងស្ត្រីវ័យក្មេងកាន់តែច្រើនឡើងទទួលបានឱកាសការងារសមរម្យ និងមានផលិតភាព។

- ផ្តល់សេវាជួយស្វែងរកការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋ បានចំនួនប្រមាណជាង ១,២លាននាក់ ក្នុងនោះមាន(ប្រទេស ថៃ កូរ៉េ ជប៉ុន ម៉ាឡេស៊ី សឹង្ហបុរី និង តំបន់រដ្ឋបាលពិសេសហុងកុង)។

### ការអភិវឌ្ឍរបបសន្តិសុខសង្គម

- អនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។
- ផ្តល់តាវកាលិកហានិភ័យការងារ កើនឡើងស្មើនឹង១០,៣០% បើប្រៀបធៀបនឹងឆ្នាំ ២០១៦។ ការចំណាយ តាវកាលិកហានិភ័យការងារមានចំនួន១៩ប៊ីលានរៀល មានការកើនឡើងស្មើនឹង២១,៩៨%។
- អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយបានពង្រីកដល់សហគ្រាស គ្រឹះស្ថាន និងបានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញត្រឹមឆ្នាំ២០១៧ ។
- អនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន ដែលមានកម្មការិនីសម្រាលកូន ចំនួន៩ ៩២៥នាក់ ចំនួនកូន ៩ ៩៩០នាក់ និង បានផ្តល់ប្រាក់ឧបត្ថម្ភសរុបចំនួន៣ ៩៩៦ លានរៀល។
- បន្តសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិតតាមរយៈការរៀបចំកែសម្រួលមធ្យោបាយ ដឹកជញ្ជូន និងពង្រឹងការអនុវត្តច្បាប់ចរាចរផ្លូវគោក។
- សហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធននិវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ និងដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធននិវត្តន៍។ ពលករដែលធ្វើការនៅក្រៅប្រទេសអាចទទួលបានរបបនេះដូចនៅក្នុងប្រទេស។

### បញ្ហាប្រឈម

២.១៣៩- ទន្ទឹមលទ្ធផលគួរជាទីមោទនខាងលើ ការអភិវឌ្ឍទីផ្សារការងារក៏នៅមានបញ្ហាប្រឈមគន្លឹះមួយចំនួនដែលតម្រូវឲ្យមានការបត់បែន និងជម្នះរាល់បញ្ហាទាំងនោះក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ៥ឆ្នាំខាងមុខនេះ លើបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- គុណភាពផលិតភាពនៃកម្លាំងពលកម្មនៅមានកម្រិតទាបបើធៀបនឹងបណ្តាប្រទេសក្នុងតំបន់ដោយសារកម្លាំងពលកម្មភាគច្រើនធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារ និងអតីតភាពការងារមិនទាន់រឹងមាំ
- ការរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅតាមបណ្តារោងចក្រសហគ្រាស មិនទាន់ល្អ រួមទាំងសុវត្ថិភាពការដឹកជញ្ជូនកម្មករនិយោជិតមិនសូវមានសុវត្ថិភាព

- ការគ្រប់គ្រងការបិទទ្វាររោងចក្រនិងការទូទាត់ប្រាក់អតីតភាពការងារនៅមិនទាន់ល្អ
- សេវាគាំពារទេសន្តរប្រវេសន៍នៅមានកម្រិត
- ការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ២០១៧-២០២៥ នៅមានកម្រិតទាំងវិស័យសាធារណៈ និងវិស័យឯកជន
- មិនទាន់ទទួលបានលទ្ធផលល្អប្រសើរក្នុងការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្តង់ដាជាតិ សមត្ថភាព និងកម្មវិធីសិក្សាផ្អែកលើសមត្ថភាព ក្របខ័ណ្ឌទទួលស្គាល់ឆ្លងពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទៅគ្រឹះស្ថានឧត្តមសិក្សា តម្រូវការបង្កើតមជ្ឈមណ្ឌលគំរូសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជាច្រើនកន្លែង និងការរៀបចំទិវាផ្សព្វផ្សាយគោលនយោបាយមិនទាន់បានទូលំទូលាយ។
- ការបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់មិនទាន់គ្រប់គ្រាន់
- ការបង្កើនសមត្ថភាពកម្លាំងពលកម្មដើម្បីបង្កើនផលិតភាពនៅមិនទាន់ទូលំទូលាយ
- ភាពមិនទាន់ឆ្លើយតបបានពេញលេញទាំងផ្នែកមុខជំនាញ កម្មសិក្សា មនសិការ វិជ្ជាជីវៈ និងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទៅនឹងតម្រូវការជាក់ស្តែង
- ភាពនៅមានកម្រិតនៃការចូលរួមពីវិស័យឯកជនក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ។
- កម្រិតវិសាលភាពគ្របដណ្តប់នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយ និងពេញលេញ
- ដំណើរការគ្រប់គ្រងកម្មវិធី និងរបបនៃប្រព័ន្ធគាំពារសង្គមមិនទាន់លក្ខណៈប្រមូលផ្តុំ។
- ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជាប្រព័ន្ធគាំទ្រនីត្យាកូលភាពរបស់ប្រជាជន និងជនងាយរងគ្រោះ និងការចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករនៅមិនទាន់ច្បាស់លាស់។
- ការដាក់ឲ្យអនុវត្តរបបសន្តិសុខសង្គម ព្រមទាំងការពង្រីកវិសាលភាពលើរបបដែលមានស្រាប់សំដៅ បង្កើនការគាំពារដល់ប្រជាជនគ្រប់រូបតម្រូវមានការប្រើប្រាស់ពេលវេលាយូររួមទាំងតម្រូវការធនធានដើម្បីដំណើរការ។
- ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង នៅពុំទាន់ទទួលបានការឆ្លើយតបពេញលេញនឹងតម្រូវការរបស់អ្នកប្រើប្រាស់សេវា ការរៀបចំកសាងផែនការការព្យាករណ៍ របាយការណ៍ ប្រព័ន្ធស្ថិតិមិនទាន់បានច្បាស់លាស់ អនុស្សារណៈនៃការយោគយល់គ្នា និងលិខិតូបករណ៍នានានៅមិនទាន់មានយន្តការគ្រប់គ្រងច្បាស់លាស់ និងការលើកកម្ពស់ការងារសមភាពយេនឌ័ររវាងបុរសនិងស្ត្រីក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅមានកម្រិត។

- ការធ្វើអធិការកិច្ច និងសវនកម្ម ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្រ្តនានា រួមទាំងការពង្រឹងយន្តការគណៈកម្មការ និងក្រុមការងារផ្សេងៗមិនទាន់មានដំណើរការល្អ។

## ៦.៤- ការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ

### ការអភិវឌ្ឍវិស័យធនាគារ

- ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបានកើនឡើងជាមធ្យមប្រចាំឆ្នាំ២២,៥% ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ ដោយបានកើនឡើងពី៦៦,៣ទ្រីលានរៀល( ៩៨,៣% នៃផ.ស.ស.) នៅឆ្នាំ២០១៤ ដល់១៤០ទ្រីលានរៀល( ១៩១,៥%នៃផ.ស.ស) នៅខែតុលា ឆ្នាំ២០១៨។ ប្រាក់បញ្ញើអតិថិជនបានកើនឡើងជាមធ្យមប្រចាំឆ្នាំ២២,៩% ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយពោលគឺបានកើនពី៣៦,៧ទ្រីលានរៀល( ៥៤,៣% នៃផ.ស.ស.) នៅឆ្នាំ២០១៤ ដល់៧៧,៦ទ្រីលានរៀល( ៧៨,៥% នៃផ.ស.ស.) នៅខែតុលា ឆ្នាំ២០១៨ ខណៈដែលឥណទានរបស់គ្រឹះស្ថានធនាគារទៅវិស័យឯកជនបានកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណ២៤,៥% ក្នុងអំឡុងពេល៥ឆ្នាំដូចគ្នាដោយកើនឡើងពី៣៦,២ទ្រីលានរៀល ក្នុងឆ្នាំ២០១៤ (៥៣,៧% នៃផ.ស.ស.) ដល់៧៩,១ទ្រីលានរៀល នៅខែតុលា ឆ្នាំ២០១៨( ៧៩,៩%នៃផ.ស.ស.)។

**រូបភាពទី ២.៣ ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ**




- ការរីកចម្រើនយ៉ាងឆាប់រហ័សគួរឲ្យកត់សម្គាល់ ទាំងចំនួនប្រតិបត្តិករ ទំហំប្រតិបត្តិការ និងវិសាលភាពរបស់វិស័យធនាគារនៅកម្ពុជាដោយសារ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តពង្រឹងការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់ដូចជា៖ ១.ការវិភាគតាមដាននិងវាយតម្លៃសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានប្រព័ន្ធត្រួតពិនិត្យ ២.ការវិភាគលើឯកសារប្រចាំគ្រា និង ៣.ការប្រើប្រាស់វិធីសាស្រ្ត CAMELS ដែលផ្អែកលើមូលដ្ឋានហា-

និភ័យនិងទស្សនៈអនាគតក្នុងការវាយតម្លៃដើម្បីធានានូវភាពរឹងមាំនិងសុវត្ថិភាពនៅក្នុងប្រព័ន្ធធនាគារទាំងមូល។

- ស្ថានភាពហិរញ្ញវត្ថុ គុណភាពទ្រព្យសកម្ម ដំណើរការអាជីវកម្ម ស្ថានភាពដើមទុន សន្ទនីយភាពអភិបាលកិច្ច និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានភាពល្អប្រសើរបន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសថ្មីៗមួយចំនួនដូចជា៖ ១.ប្រកាសស្តីពីក្របខណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព ២.ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមា ៣.ប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន ៤.ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យ ឥណទាននិងសំវិធានធនលើអ៊ីមតែរមិន ៥.ប្រកាសស្តីពីសវនកម្មចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុជាដើម។ ជាមួយគ្នានេះដែរធនាគារជាតិនៃកម្ពុជាបាននិងបន្តកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាអាជ្ញាធរត្រួតពិនិត្យនៃបណ្តាប្រទេសផ្សេងៗ ដែលមានគ្រឹះស្ថានបានបើកសាខានិងបុត្តសម្ព័ន្ធនៅកម្ពុជាដើម្បីពង្រឹងសហប្រតិបត្តិការ ការចែករំលែកព័ត៌មាននិងការបង្ហាញពីការព្រួយបារម្ភ ហានិភ័យជាប្រព័ន្ធក្នុងគោលបំណងរួមគ្នាដោះស្រាយវិបត្តិ ដែលអាចកើតឡើងនិងបញ្ចៀសហានិភ័យជាប្រព័ន្ធឆ្លងប្រទេស។
- បន្ថែមពីលើនេះទៀត ដើម្បីរក្សាបានជំនឿទុកចិត្តរបស់សាធារណៈជនមកលើវិស័យធនាគារ និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីក្រុមហ៊ុនសវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យយកចិត្តទុកដាក់ចំពោះការអនុវត្តតាមច្បាប់ ស្តីពីអនុលោមភាពពន្ធគណនីបរទេស ការត្រៀមរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ការអនុវត្តគោលការណ៍កិច្ចគាំពារអតិថិជន និងការអនុវត្តតាមគោលការណ៍គ្រឹះបាសែល ជា ដើម។
- ធនាគារជាតិនៃកម្ពុជាបានបង្កើតប្រព័ន្ធផ្តល់សញ្ញាជាមុន និងការបង្កើតក្រុមការងារស្ថិរភាពរូបិយវត្ថុព្រមទាំងបានសិក្សាពីការវិភាគហានិភ័យនិងអនុវត្តការធ្វើស្រ្តេសតេស្តដោយផ្អែកតាមកម្មវិធីវាយតម្លៃវិស័យហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។
- ធនាគារជាតិនៃកម្ពុជាកំពុងតែរៀបចំប្រកាសមួយផ្សេងទៀតទាក់ទងនឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបានពង្រឹងតួនាទីរបស់ខ្លួនជាអ្នកខ្ចីចុងក្រោយតាមរយៈ ការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពីការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីបង្ការជាមុននូវហានិភ័យជាប្រព័ន្ធ។
- ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជាបានបង្កើតក្រុមការងារមួយក្នុងគោលដៅផ្តួចផ្តើមឲ្យមានយន្តការគ្រប់គ្រងវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ។
- ការសម្រេចបាននូវសមិទ្ធផលខាងលើនេះ ដោយសារធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យដំណើរការជាផ្លូវការនូវប្រព័ន្ធសេវាទូទាត់រហ័ស ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល និងការទូទាត់សងប្រាក់ជាអេឡិចត្រូនិក ឲ្យកាន់តែមានប្រសិទ្ធភាពនិងដើម្បីលើកកម្ពស់ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានដាក់

ឲ្យដំណើរការប្រព័ន្ធ Central Shared Switch សម្រាប់សម្រួលប្រតិបត្តិការទូទាត់អន្តរធនាគារតាមរយៈបណ្ណទូទាត់ឥណពន្ធលើម៉ាស៊ីនATM និងម៉ាស៊ីន POS ក្នុងគោលដៅបង្កើននូវប្រសិទ្ធភាពសេវាទូទាត់ កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ។ ហើយនៅពេលថ្មីនេះ ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំ។

## ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ

- វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានបន្តរីកចម្រើនគួរឲ្យកត់សម្គាល់ និងប្រកបដោយនិរន្តរភាព ទាំងវិសាលភាព ទំហំប្រតិបត្តិការ និងប្រាក់ចំណេញ ព្រមទាំងបានផ្តល់សេវាផ្ទេរប្រាក់ និងសេវាធនាគារចល័តយ៉ាងសកម្ម។
- ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមធ្យមបានកើនក្នុងអត្រាប្រចាំឆ្នាំស្មើនឹង ៣៣,៣% ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ ដោយបានកើនឡើងពី៩,៩៤ទ្រីលានរៀល (១៤,៧% នៃផ.ស.ស) នៅឆ្នាំ២០១៤ ដល់ ២៥,៣៨ ទ្រីលានរៀល (២៥,៧% នៃផ.ស.ស.) នៅខែកញ្ញាឆ្នាំ២០១៨។ វិស័យនេះបានផ្តល់ឥណទានដល់អតិថិជនរបស់ខ្លួនជាមធ្យមក្នុងអត្រាកំណើន៣៤,៥% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលដូចគ្នានេះ ពោលគឺបានកើនឡើងពី៨,២២ ទ្រីលានរៀល(១២,២% នៃផ.ស.ស.) នៅឆ្នាំ២០១៤ ដល់ ២០,៦២ ទ្រីលានរៀល(២០,៨% នៃផ.ស.ស.) នៅខែកញ្ញា ឆ្នាំ២០១៨ ព្រមទាំងបានកេណ្ឌប្រមូលប្រាក់បញ្ញើពីសាធារណជនជាមធ្យមប្រមាណ៤៦,៧% ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ ពោលគឺបានកើនឡើងពី៣,៦២ ទ្រីលានរៀល(៥,៤% នៃផ.ស.ស.) នៅឆ្នាំ ២០១៤ ដល់១០,៣៣ទ្រីលានរៀល (១០,៤%នៃផ.ស.ស.) នៅខែកញ្ញាឆ្នាំ២០១៨។

រូបភាពទី ២.៤ ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គិតជាទ្រីលានរៀល ពីឆ្នាំ២០១៤-២០១៨



- គិតត្រឹមពាក់កណ្ដាលឆ្នាំ២០១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់បានបញ្ចប់ និងផ្ញើរបាយការណ៍ស្ដីពីការវិភាគហានិភ័យនៃការគំរាមកំហែងនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- កាលពីឆ្នាំ២០១៥ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍មីក្រូហិរញ្ញវត្ថុបានកំណត់ពីបញ្ហាប្រឈមនានាក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងបានដាក់ចេញនូវវិធានការគោលនយោបាយ និងវិធានការដោះស្រាយដើម្បីឲ្យធនាគារជាតិនៃកម្ពុជា និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ តាមដាននិងអនុវត្ត។

## បញ្ហាប្រឈម

### វិស័យធនាគារ

២.១៤០- ទោះជាវិស័យធនាគារបានអភិវឌ្ឍនិងមានភាពរឹងមាំក៏ដោយ ក៏កម្រិតនៃការអភិវឌ្ឍវិស័យនេះ នៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖

- កម្រិតដុល្លាររូបនីយកម្មខ្ពស់ បានធ្វើឲ្យកម្ពុជាបាត់បង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់ (Seigniorage) ព្រមទាំងជាឧបសគ្គដល់ការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុ មួយចំនួនដែលផ្អែកលើទីផ្សារ ព្រមទាំងបានកាត់បន្ថយលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការចាត់វិធានការតបទៅនឹងវិបត្តិដែលអាចកើតមានឡើង។
- កម្ពុជាមិនទាន់មានក្របខ័ណ្ឌស្ថាប័ន និងយន្តការសម្របសម្រួលច្បាស់លាស់ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ។ ការទទួលបានទិន្នន័យគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងមានភាពត្រឹមត្រូវ ក៏នៅមានកម្រិតក្នុងការឈានដល់ការតាមដានប្រកបដោយប្រសិទ្ធភាពទៅលើហានិភ័យដែលអាចប៉ះពាល់ស្ថិរភាពហិរញ្ញវត្ថុ។
- បរិមាណនៃប្រាក់បញ្ញើ និងរូបិយវត្ថុក្នុងចរាចរណ៍ជាប្រាក់រៀលមានកម្រិតទាបធៀបនឹងប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលមួយចំនួននៅតែធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ហើយអាជីវករជាច្រើនបានផ្សព្វផ្សាយការលក់ផលិតផលរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ ជាពិសេស នៅតំបន់ទីប្រជុំជន។
- ធនាគារជាតិនៃកម្ពុជា នៅតែបន្តអនុវត្តការត្រួតពិនិត្យ ដោយផ្អែកលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត តាមរយៈការដាក់ឱ្យអនុវត្តប្រកាសស្ដីពីការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត។ ការប្ដេជ្ញាខាងលើរបស់ធនាគារជាតិនៃកម្ពុជា នៅជួបបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះបុគ្គលិកដែលមានឯកទេសកម្មក្នុងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យថ្មីនេះ និងការខ្វះខាតបច្ចេកវិទ្យាព័ត៌មាន។ ទន្ទឹមនេះ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិទាមទារឲ្យមានការត្រួតពិនិត្យជាប្រចាំ ដើម្បីតាមទាន់ការវិវឌ្ឍនៃស្ថានភាពទីផ្សារ។

**វិស័យមីក្រូហិរញ្ញវត្ថុ**

- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីវិស័យមីក្រូហិរញ្ញវត្ថុនៅមានកម្រិតដោយយល់ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាគ្រឹះស្ថានរបស់រដ្ឋ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។
- អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅមានតម្លៃខ្ពស់ ដោយសារថ្លៃដើមនៃប្រភពទុន និងការចំណាយប្រតិបត្តិការនៅមានកម្រិតខ្ពស់។
- កង្វះប្រព័ន្ធព័ត៌មានវិទ្យា និងធនធានមនុស្សសម្រាប់អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងភាពមិនច្បាស់លាស់នៃមូលដ្ឋានគិតពន្ធចំពោះការធ្វើសំវិធានធន និងការបង្វែរប្រាក់ចំណេញរក្សាទុកនៅជាដើមទុនចុះបញ្ជី ដែលអាចមិនលើកទឹកចិត្តឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បង្កើរសំវិធានធនគ្រប់គ្រាន់ ដើម្បីបង្ការហានិភ័យជាយថាហេតុ។

## ៧- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

### ៧.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាល

២.១៤១- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានបង្ហាញពីដំណាក់កាលការងារដ៏សំខាន់របស់ក្រសួង អប់រំ យុវជន និងកីឡាក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ស្របតាមកំណែទម្រង់នានា របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥។

២.១៤២- ក្នុងរយៈពេល៥ឆ្នាំកន្លងមក ក្រសួងនិងដៃគូអភិវឌ្ឍបានរួមគ្នាអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយសម្រេចបាននូវសមិទ្ធផលធំៗគួរឲ្យកត់សម្គាល់ ដូចជា ការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់កម្រិត ជាពិសេសការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ ការពង្រឹងនិងពង្រីកអភិបាលកិច្ច គ្រឹះស្ថានសិក្សាសាធារណៈ ការដោះស្រាយតម្រូវការបន្ទាន់ភ្លាមៗ និងការបង្កើនអាហារូបករណ៍សម្រាប់សិស្សនិងនិស្សិតក្រីក្រ។ ក្រសួងក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ចំពោះវិធានការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃសេវាអប់រំ ជាពិសេសការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពនិងការលើកទឹកចិត្ត ព្រមទាំងការបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រងសេវាអប់រំ។

២.១៤៣- សមិទ្ធផលធំៗទាក់ទងនឹងការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

#### ១.១ វឌ្ឍនភាពតាមអនុវិស័យ

##### ១.១.១ ការអប់រំកុមារតូច

ចំនួនសាលាមត្តេយ្យសិក្សាគ្រប់រូបភាពបានកើនពី៥ ៦២៥សាលា/កន្លែង ឆ្នាំសិក្សា២០១៣-២០១៤ ដល់៧ ៥៨៧ សាលា/កន្លែង ឆ្នាំសិក្សា២០១៧-២០១៨ (សាលាមត្តេយ្យសិក្សារដ្ឋមាន ៤ ១៧៦ មត្តេយ្យសិក្សាឯកជន៤៥៦ និងមត្តេយ្យសិក្សាសហគមន៍២ ៩៥៥កន្លែង)។ ឆ្នាំសិក្សា២០១៧-

២០១៨ កុមារទទួលបានសេវាអប់រំគ្រប់រូបភាពមាន ៤៣១ ៥១០នាក់ ស្រី ២១៨ ៤៨៨នាក់ ស្មើ ៥០,៦៣%។

### ១.១.២ ការអប់រំបឋមសិក្សា

សាលាបឋមសិក្សារដ្ឋបានកើនពី៦ ៩៩៣ ឆ្នាំសិក្សា២០១៣-២០១៤ ដល់៧ ១៨៩ ឆ្នាំសិក្សា ២០១៧-២០១៨។ អត្រាពិតនៃការសិក្សានៅបឋមសិក្សា សម្រេចបាន៩៧,៨% ឆ្នាំសិក្សា ២០១៧-២០១៨ អត្រាបញ្ចប់ការសិក្សា៨២,៧%។ គោលនយោបាយស្តីពីសាលាកុមារមេត្រី ត្រូវបានអនុវត្តដោយជោគជ័យសំដៅផ្តល់ឱកាសដល់កុមារទាំងអស់បានចូលរៀន និងទទួលបានការអប់រំប្រកបដោយគុណភាពយ៉ាងហោចណាស់ត្រឹមកម្រិតអប់រំមូលដ្ឋាន។ ការផ្តល់អាហារពេលព្រឹក និងអាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងការផ្តល់មធ្យោបាយធ្វើដំណើរដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ បានបង្កើនអត្រាចូលរៀន និងស្ថិរភាពនៃការសិក្សា។

### ១.១.៣ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស

ក្នុងរយៈពេល៥ឆ្នាំកន្លងមក អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បានកើនរៀងគ្នាពី៥៣,៣% និង២៦%ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៥៩,២%(ចំណុចដៅ ៥៤,៦%) និង២៨,៥%(ចំណុចដៅ២៧,៧) ឆ្នាំសិក្សា២០១៧-២០១៨ ហើយអត្រាបញ្ចប់ការសិក្សាក៏បានកើនពី ៣៩,២% ឆ្នាំសិក្សា២០១៣-២០១៤ ដល់៤៦,៥% ឆ្នាំសិក្សា២០១៧-២០១៨ (ចំណុចដៅ៤៤,៦%)។ ក្រសួងបានអនុម័តគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី និងសាលារៀនជំនាន់ថ្មី៥ បាននិងកំពុងដំណើរ។

### ១.១.៤ ការអប់រំឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន១៦។ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន៧៣ រដ្ឋ១៣ និងឯកជន៦០។ គ្រឹះស្ថានឧត្តមសិក្សា៣៨ ផ្តល់សេវាអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ។

### ១.១.៥ ការអប់រំក្រៅប្រព័ន្ធ

រាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន២៥ កម្មវិធីក្រោយអក្ខរកម្មមាន ១៨ កម្មវិធីចូលរៀនឡើងវិញមាន២២ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន២៤ កម្មវិធីសមមូលបឋមសិក្សាមាន២២ និងកម្មវិធីបំពេញវិជ្ជាមាន២១។

### ១.១.៦ ការអភិវឌ្ឍយុវជន

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ ក្រសួងបានបង្កើតយន្តការអនុវត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជា បង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងអគ្គលេខាធិការដ្ឋាន បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជន ក្រសួង ស្ថាប័នចំនួន៣៣ និងក្រុមប្រឹក្សាអភិវឌ្ឍយុវជន រាជធានីភ្នំពេញ និងខេត្ត

ចំនួន២៤។ ក្រសួងបាន កសាងឯកសារក្របខ័ណ្ឌអភិវឌ្ឍយុវជនថ្នាក់ក្រោមជាតិ ឯកសារសេវាកម្ម យុវជនជាតិ ឯកសារគ្រប់គ្រងហានិភ័យក្នុងការអនុវត្តស្តីពីការអភិវឌ្ឍយុវជនកម្ពុជា សេចក្តីព្រាងគោលនយោបាយ សហគ្រិនភាព និងឯកសារតាមដាន ត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ក្រសួងបានធ្វើបច្ចុប្បន្នភាពឯកសារសម្រាប់ក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជនរៀបចំបណ្តាញយុវជនស្ម័គ្រចិត្តទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចលនាយុវជនកាកបាទក្រហម សមាជិកចលនាកាយរឹទ្ធិចំនួន១៥ម៉ឺននាក់ និងពង្រីកបន្ថែមសមាជិកកាយរឹទ្ធិចំនួន៥ ០០០នាក់ ក្នុងឆ្នាំ២០១៧។

ក្រសួងបានបន្តពង្រឹងជំនាញបច្ចេកទេសនិងជំនាញទន់ សម្រាប់យុវជនដោយបានផ្សព្វផ្សាយព័ត៌មានទីផ្សារការងារដល់យុវជន និងរៀបចំវេទិកាស្តីពីការសិក្សាការងារ និងព័ត៌មានទីផ្សារការងារដល់យុវជន និងបណ្តុះបណ្តាលសហគ្រិនភាព។ ក្រសួងបានរៀបចំឯកសារស្តីពីការផ្តល់ប្រឹក្សាអាជីពនិងព័ត៌មានស្តីពីការសិក្សាជំនាញធ្វើការបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពកម្រិតមធ្យមសិក្សា។

ក្រសួងបានរៀបចំសិក្ខាសាលាអប់រំបំណិនជីវិតស្តីពីការការពារជំងឺអេដស៍ ការបំបាត់ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ច្បាប់ចរាចរណ៍ ការបំបាត់អំពើហិង្សាក្នុងចំណោមយុវជន ។

### ១.១.៧ ការអប់រំកាយ និងកីឡា

ក្រសួងបានរៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ជាតិ នៅខេត្តកំពង់ចាម និង បានបញ្ជូនប្រតិភូទៅចូលរួមការប្រកួតលក្ខណៈអន្តរជាតិ រួមមានការប្រកួតប៉េតង់ជ្រើសរើសជើងឯកពិភពលោក ដែលកម្ពុជាយើងទទួលបានមេដាយមាស៣លើកជាប់ៗគ្នា។ សហការរៀបចំពិធីសំណេះសំណាលជាមួយកីឡាករ កីឡាការិនី និងប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តជូនដល់ជ័យលាភីនៃការប្រកួតជ្រើសរើសជើងឯកពិភពលោក និងការប្រកួតជាលក្ខណៈអន្តរជាតិនៅឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលបានផ្តល់នូវកម្លាំងចិត្ត និងភាពកក់ក្តៅដើម្បីយកប្រៀបឈ្នះនៅក្នុងការប្រកួតនាពេលបច្ចុប្បន្ន និងការប្រកួតស៊ីហ្គេមឆ្នាំ២០២៣ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ។

## ១.២ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់អាទិភាព

ក្រសួងបានដាក់ចេញកំណែទម្រង់វិស័យ៨ចំណុចនៅឆ្នាំ២០១៤ និងបានពង្រីកវិសាលភាពដល់១៥ចំណុច ពីឆ្នាំ២០១៥-២០១៨ ដោយឈរលើមូលដ្ឋានសសរស្តម្ភ៥ គឺ ១.ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២.ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា ៣.ការដាក់ឲ្យអនុវត្តអធិការកិច្ច ៤.ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង ៥.ការកែទម្រង់ឧត្តមសិក្សា។

- កំណែទម្រង់ទី១ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កំណែទម្រង់ទី២ ៖ ការពង្រាយគ្រូបង្រៀន
- កំណែទម្រង់ទី៣ ៖ កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន
- កំណែទម្រង់ទី៤ ៖ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន
- កំណែទម្រង់ទី៥ ៖ ការងារអធិការកិច្ច
- កំណែទម្រង់ទី៦ ៖ វង្វាយតម្លៃលទ្ធផលសិក្សា
- កំណែទម្រង់ទី៧ ៖ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- កំណែទម្រង់ទី៨ ៖ កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល
- កំណែទម្រង់ទី៩ ៖ ការសាងសង់អគារសិក្សានិងការជួសជុល
- កំណែទម្រង់ទី១០ ៖ ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា
- កំណែទម្រង់ទី ១១ ៖ ការលើកកម្ពស់វិស័យកីឡា
- កំណែទម្រង់ទី ១២ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន
- កំណែទម្រង់ទី១៣ ៖ ការអប់រំបច្ចេកទេស
- កំណែទម្រង់ទី១៤ ៖ ការបង្កើតសាលារៀនជំនាន់ថ្មី
- កំណែទម្រង់ទី១៥ ៖ ការរៀបចំគន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា

### តារាងទី ២.៣៥ សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា

| សូចនាករសំខាន់ៗ ក្នុងវិស័យអប់រំ | | ឯកតា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ | |
|---|---|---|---|---|---|---|---|---|---|
| | | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ព្យាករណ៍ |
| ១ | ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចនៅគ្រប់រូបភាព | % | ៥៦,៥ | ៥៩,៩ | ៦១,៤ | ៦៤,១ | ៦៦,៤ | ៦៨,៥ | ៦៨ |
| ២ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ៩១០ | ៦ ៩៩៣ | ៧ ០៥១ | ៧ ០៨៥ | ៧ ១៤៤ | ៧ ១៨៩ | ៧ ៦០៦ |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | | |
| ៣ | សរុប | % | ៩៧ | ៩៨,២ | ៩៨ | ៩៨,៤ | ៩៧,៧ | ៩៧,៨ | ១០០ |
| ៤ | ប្រុស | % | ៩៧ | ៩៧,៩ | ៩៧,៤ | ៩៧,៧ | ៩៧,២ | ៩៧,៥ | ១០០ |
| ៥ | ស្រី | % | ៩៧ | ៩៨,៥ | ៩៨,០ | ៩៩,៣ | ៩៨,២ | ៩៨,១ | ១០០ |
| ៦ | ទីប្រជុំជន | % | ៨៩,៨ | ៨៣,៦ | ៨២,៩ | ៨៣,៣ | ៨១,៣០ | ១០២,៨ | ១០០ |
| ៧ | ជនបទ | % | ៩៨,៦ | ៩៨,៤ | ៩៧,២ | ៩៦,៥ | ៩៦,៥០ | ៩៦,៧ | ១០០ |
| អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៨ | សរុប | % | ១២១,១ | ១១៩,២ | ១១៥,៣ | ១១៤,៩ | ១១៣,៧ | ១១៣,៨ | ១០៣ |
| ៩ | ប្រុស | % | ១២៣,១ | ១២០,៨ | ១១៦,១ | ១១៥,៤ | ១១៤,៤ | ១១៤,៦ | ១០៣ |
| ១០ | ស្រី | % | ១១៩ | ១១៧,៥ | ១១៤,៤ | ១១៤,៣ | ១១២,៩ | ១១២,៩ | ១០៣ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | | | |
| ១១ | សរុប | % | ៩១,៥ | ៨៨,៩ | ៨៤,១ | ៨០,៦ | ៧៩,៩ | ៨២,៧ | ៨៣ |
| ១២ | ប្រុស | % | ៩១,៩ | ៨៧,៧ | ៨១,៨ | ៨២,៥ | ៧៦,៧១ | ៧៩,១ | ៨៤,២ |
| ១៣ | ស្រី | % | ៩១ | ៩០,២ | ៨៦,៦ | ៨៣,៩ | ៨៣,២ | ៨៦,៤ | ៨៤,៥ |
| ១៤ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ១ ៦២២ | ១៦៥៩ | ១ ៦៧៤ | ១ ៦៨៤ | ១ ៦៩៩ | ១ ៧១៦ | ១ ៦៧២ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | | |
| ១៥ | សរុប | % | ៥៦,៥ | ៥៣,៣ | ៥៥,១ | ៥៦,៥ | ៥៧,៦ | ៥៩,២ | ៥៤,៦ |
| ១៦ | ប្រុស | % | ៥៦,២ | ៥២,១ | ៥៣,៣ | ៥៣,៨ | ៥៤,២ | ៥៥,៣ | ៥០,៩ |
| ១៧ | ស្រី | % | ៥៦,៧ | ៥៤,៥ | ៥៦,២ | ៥៩,៤ | ៦១,៥ | ៦៣,៤ | ៥៤,៩ |
| ១៨ | ទីប្រជុំជន | % | ៧៨,៤ | ៦០,០ | ៥៨,៣ | ៥៩,២ | ៥៧,១០ | ៥៧ | ៥៥,៥ |
| ១៩ | ជនបទ | % | ៥២,៦ | ៥១,៧ | ៥២,១ | ៥២ | ៦០,២០ | ៦១ | ៥៤,៨ |
| អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | | | |
| ២០ | សរុប | % | ៤២,២ | ៣៩,១ | ៤០,៣ | ៣៩,២ | ៤៤,៥ | ៤៦,៥ | ៤៤,៦ |
| ២១ | ប្រុស | % | ៤២ | ៣៨,២៣ | ៣៨,៩ | ៣៧,៣ | ៣៩,៣៩ | ៤២,៣ | ៤១,១ |
| ២២ | ស្រី | % | ២៥,៥ | ៤០ | ៤១,៨ | ៤១,២ | ៤៨,០ | ៥១,១ | ៤៤,៦ |
| ២៣ | ចំនួនសាលាមធ្យមសិក្សាទុតិយភូមិ | ចំនួន | ៤៣៣ | ៤៤៤ | ៤៥៥ | ៤៦៣ | ៤៨៦ | ៥១៦ | ៦៦៨ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | | | |
| ២៤ | សរុប | % | ២៩,៨ | ២៦ | ២៥,៣ | ២៥,១ | ២៦,៥ | ២៨,៥ | ២៧,៧ |
| ២៥ | ប្រុស | % | ៣១,៩ | ២៥,២ | ២៣,៨ | ២៤,១ | ២៣,៦ | ២១,៩ | ២៧,៥ |
| ២៦ | ស្រី | % | ២៧,៦ | ២៥,៧ | ២៦,៩ | ២៦ | ២៨,១ | ៣០,៩ | ២៧,៧ |
| ២៧ | ចំនួនវិទ្យាល័យអប់រំបច្ចេកទេស | ចំនួន | ២ | ៣ | ៣ | ៤ | ៧ | ៩ | ៨ |
| ២៨ | ចំនួនសិស្សនៅមធ្យមសិក្សាអប់រំបច្ចេកទេស | ចំនួន | ៨៩៧ | ៦៥៣ | ៨៦៨ | ១ ១៦៦ | ១ ១៤៨ | ១ ៤៧១ | ១ ៤៩២ |
| ២៩ | អត្រាអក្ខរកម្មជនពេញវ័យ (១៥-៤៥ ឆ្នាំ) | % | ៨០,៧ (២០១៣) | ៨០,៧ (២០១៣) | ៧៨,១ (២០១៤) | ៧៨,១ | ៧៨,១ | ៨២,៥ | ៨១,៤ |

***ប្រភព:*** ក្រសួងអប់រំ យុវជន និងកីឡា

## បញ្ហាប្រឈម

២.១៤៤-ទន្ទឹមនឹងសមិទ្ធផលសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡាខាងលើ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖

- **ការអប់រំកុមារតូច** ៖ ការចូលរៀនរបស់កុមារតូចនៅតាមតំបន់ជនបទ កុមារងាយរងគ្រោះ និងកុមារដែលមាន កម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គមទាប មិនទាន់បានឆ្លើយតប។ ការផ្តល់សេវាអប់រំកុមារតូច មិនទាន់ស្របតាមស្តង់ដាអប្បរមា ដូចជា គុណវុឌ្ឍិគ្រូអប់រំកុមារតូចនៅមានកម្រិត និងកង្វះគ្រូអប់រំកុមារតូច
- **ការអប់រំបឋមសិក្សា** ៖ ការរក្សាសិស្សឲ្យនៅគង់វង្សនិងបញ្ចប់ការសិក្សា ចាំបាច់ត្រូវធ្វើការកែលម្អ ជាពិសេស ក្រុមកុមារជួបការលំបាក ក្រុមកុមារបាត់បង់ឱកាស។ ចំនួនសមាមាត្រកុមារដែលទទួលបានបំណិនជាមូលដ្ឋានក្នុងការអាន ការសរសេរ និងការគិតនៅមានគម្លាតនៅឡើយ
- **ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស** ៖ ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្ពស់នៅឡើយ។ កង្វះសម្ភារបរិក្ខារតាមសា-លារៀនជាកត្តាធ្វើឲ្យមានអត្រារួមនៃការសិក្សាចុះទាប ក៏ដូចជាកង្វះគ្រូបង្រៀន ជាពិសេសកង្វះគ្រូបង្រៀនឯកទេសតាមមុខវិជ្ជា ដូចជាមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ និងមុខវិជ្ជាភាសាបរទេស។ គម្លាតរវាងជំនាញដែលផ្តល់ឲ្យសិស្សនៅតាមសាលាចំណេះទូទៅនិងអប់រំបច្ចេកទេសមិនឆ្លើយតបនឹងតម្រូវការទីផ្សារការងារ
- **ការអប់រំឧត្តមសិក្សា**៖ វិសមភាពក្នុងការសិក្សារបស់និស្សិត មកពីគ្រួសារដែលមានចំណូលទាប។ ការសិក្សាលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យានៅមានកម្រិតទាបនៅឡើយ។ កង្វះមធ្យោបាយដើម្បីលើកទឹកចិត្តក្នុងសកម្មភាព ការងារស្រាវជ្រាវតាមគ្រឹះស្ថានឧត្តមសិក្សា។
- **ការអប់រំក្រៅប្រព័ន្ធ**៖ បុគ្គលិកខ្វះជំនាញ និងធនធានសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅមានកម្រិត។
- **ការអភិវឌ្ឍយុវជន**៖ កម្មវិធីបណ្តុះបណ្តាលជំនាញទន់ ការអប់រំបណ្តុះបណ្តាលសហគ្រិនភាព ការបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់មានធនធានសម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គាំទ្រ។ ធនធានមនុស្សនិងមជ្ឈមណ្ឌលគ្រប់គ្រងយុវជនគ្របដណ្តប់ទូទាំងប្រទេសនៅមានកម្រិត។ ក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជនមិនទាន់ដំណើរការសមស្រប និងខ្វះការគាំទ្រពីអ្នកពាក់ព័ន្ធ។ ការអនុវត្តផែនការយុទ្ធសាស្ត្រពង្រីកសមាជិកកាយរឹទ្ធមិនទាន់គ្រប់តាមផែនការ។

- **ការអប់រំកាយនិងកីឡា៖** ហេដ្ឋារចនាសម្ព័ន្ធកីឡានៅមានកម្រិត។ សមត្ថភាពមន្ត្រីអប់រំកាយនិងកីឡា កីឡាករ គ្រូបង្វឹក និងអាជ្ញាកណ្ដាលនៅមានកម្រិត។ កង្វះធនធានសម្រាប់អនុវត្តផែនការគោលឆ្ពោះទៅជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ ២០២៣។

## ៧.២- ការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

### ១. លើកកម្ពស់សុខភាព និងសុខមាលភាពប្រជាពលរដ្ឋ

២.១៤៥- សុខភាពប្រជាពលរដ្ឋត្រូវបានលើកស្ទួយឲ្យកាន់តែប្រសើរតាមរយៈការពង្រីកការគ្របដណ្ដប់នៃសេវាថែទាំសុខភាពនិងលើកកម្ពស់គុណភាពសេវា និងការបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការមកប្រើប្រាស់សេវាថែទាំសុខភាព។ ជាពិសេសកំណើនសេដ្ឋកិច្ចនិងការធ្លាក់ចុះនៃភាពក្រីក្របានដើរតួចំបងក្នុងការបង្កើនអាយុកាលរស់នៅរំពឹងទុកនិងលើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ជាក់ស្តែង អាយុកាលរស់នៅរំពឹងទុកជាមធ្យមរបស់ប្រជាជនកម្ពុជាទាំងពីរភេទបានកើនឡើងពី៦១,៩ឆ្នាំនៅឆ្នាំ២០០០ ទៅ៦៨,៧ឆ្នាំ នៅឆ្នាំ២០១៥ (បុរស ៦៦,៧ឆ្នាំ និងស្ត្រី៧០,៧ឆ្នាំ)។

២.១៤៦- សុខភាពប្រជាពលរដ្ឋកម្ពុជា ត្រូវបានលើកស្ទួយឲ្យកាន់តែប្រសើរឡើងដែលបញ្ជាក់អះអាងដោយវឌ្ឍនភាពនៃការកែលម្អសូចនាករលទ្ធផលសុខភាពចំបងៗ ជាពិសេសការកាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និងកុមារ និងការកាត់បន្ថយការឈឺ និងស្លាប់ ដោយសារជំងឺឆ្លង ជំងឺមិនឆ្លង និងការប្រឈមមុខរបស់ប្រជាពលរដ្ឋនឹងកត្តាហានិភ័យនៃជំងឺ។

**តារាងទី ២.៣៦ និន្នាការនៃការកាត់បន្ថយមរណភាពមាតា ទារក កុមារ និងកង្វះអាហារូបត្ថម្ភ ២០០៥-២០១៥**

| សូចនាករ | ២០០៥ | ២០១០ | ២០១៤ |
|---|---|---|---|
| អត្រាមរណភាពមាតាក្នុងទារកកើតរស់១០០ ០០០នាក់ | ៤៧២ | ២០៦ | ១៧០ |
| អត្រាស្លាប់ទារក ក្នុងទារកកើតរស់ ១ ០០០នាក់ | ២៨ | ២៧ | ១៨ |
| អត្រាស្លាប់កុមារអាយុក្រោមមួយឆ្នាំក្នុងទារកកើតរស់ ១ ០០០នាក់ | ៦៦ | ៤៥ | ២៨ |
| អត្រាស្លាប់កុមារអាយុក្រោមប្រាំឆ្នាំក្នុងទារកកើតរស់១ ០០០នាក់ | ៨៣ | ៥៤ | ៣៥ |
| អត្រាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ(គ្រិន)ក្នុងចំណោមកុមារអាយុក្រោមប្រាំឆ្នាំ | ៤៣% | ៤០% | ៣២% |

**តារាងទី២.៣៧ និន្នាការនៃការកាត់បន្ថយអត្រាឈឺនិងស្លាប់ និងបន្ថយកត្តាហានិភ័យនៃជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ ២០១៤-២០១៨**

| សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| អត្រានៃករណីឆ្លងថ្មីនៃមេរោគអេសដ៍ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់* | - | ០,០៥ | ០,០៤ | ០,០៣ | ០,០៣ |

| | | | | | |
|---|---|---|---|---|---|
| អាំងស៊ីដង់នៃជំងឺរបេងគ្រប់ទំរង់ក្នុងប្រជាជន១០០ ០០០នាក់* | - | ៣៨០ | ៣៤៥ | ៣២៦ | - |
| អត្រាស្លាប់ដោយជំងឺរបេងក្នុងប្រជាជន១០០០០០នាក់*** | ៥៨ | ៥៥ | ២០ | ១៩ | - |
| អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ក្នុងប្រជាជន ១០០០នាក់ | ១,៦៤ | ២,២៦ | ១,៥០ | ២,៩៦ | ៤,០ |
| អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងប្រជាជន១០០ ០០០នាក់ | ០,០៧ | ០,០៨ | ០,០១ | ០,០១ | ០០ |
| ប្រេវ៉ាឡង់នៃជំងឺសម្ពាធឈាមខ្ពស់ក្នុងចំណោមប្រជាជនអាយុ២៥-៦៤ឆ្នាំ | ១១,២%[a] (២០១០) | | ១៤,៥%[b] | - | - |
| ប្រេវ៉ាឡង់នៃជំងឺទឹកនោមក្នុងចំណោមប្រជាជនអាយុ២៥-៦៤ឆ្នាំ | ២,៩% c (២០១០) | | ១,៥%d | - | - |
| ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមបុរសស្ត្រីពេញវ័យ<br>- អាយុលើសពី១៥ឆ្នាំ<br>- អាយុពី ១៣-១៥ឆ្នាំ | ២១,៨%e<br>៦,៣%e<br>(២០១០) | | ២១,៨%f<br>២,៤%f | - | - |
| ភាគរយនៃប្រជាជនអាយុ២៥-៦៤ឆ្នាំកំពុងប្រើប្រាស់សារជាតិអាល់កុល | ៥៣,៥% g (២០១០) | | ៤៥,៥h | - | - |

[a,b,c,d,e,f,g,h]របាយការណ៍អង្កេត STEPs ឆ្នាំ២០១០ និងឆ្នាំ២០១៦ សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

- ចំណុចដៅមិនអាចកំណត់តាមឆ្នាំបានទេ ដោយសារតែការអង្កេត STEPs ត្រូវធ្វើឡើងរវាងប្រាំឆ្នាំម្តង

* ទិន្នន័យចាប់ផ្តើមកត់ត្រានៅឆ្នាំ២០១៥ និង *** លទ្ធផលឆ្នាំ២០១៨ នឹងចេញនៅចុងឆ្នាំ២០១៩

## ២. បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការទទួលបានសេវាសុខភាព

២.១៤៧- ការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការទទួលបានសេវាសុខភាព មានគោលដៅដកចេញនូវរបាំងហិរញ្ញវត្ថុចេញពីការទៅប្រើប្រាស់សេវាថែទាំសុខភាព និងការពារប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះឲ្យជៀសផុតពីការធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដោយសារតែផលវិបាកនៃការចំណាយលើការថែទាំសុខភាព តាមរយៈយន្តការគាំពារសុខភាពសង្គមមួយចំនួនដូចជា គោលនយោបាយលើកលែងការបង់ថ្លៃលើសេវាសុខភាពជាអាទិភាពសម្រាប់ប្រជាពលរដ្ឋទូទៅ កម្មវិធីមូលនិធិសមធម៌ ការបង់ថ្លៃជួស និងបណ្ណសុខភាពបន្តពូជសម្រាប់ប្រជាពលរដ្ឋក្រីក្រ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ការធានារ៉ាប់រងសុខភាពសហគមន៍ដោយស្ម័គ្រចិត្ត ។ កម្មវិធីមូលនិធិសមធម៌ត្រូវបានពង្រីកយ៉ាងឆាប់រហ័សពី៦៦% នៃចំនួនមូលដ្ឋានសុខាភិបាលសរុបនៅឆ្នាំ២០១៤ ដល់ ៩៨% នៅដំណាច់ឆ្នាំ២០១៧ និង១០០% នៅត្រីមាសទី១នៃឆ្នាំ២០១៨។ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ២០១៨ មូលនិធិសមធម៌(ប្រជាពលរដ្ឋក្រីក្រកម្មករនិយោជិតក្រៅប្រព័ន្ធ សមាជិកក្រុមប្រឹក្សា/ឃុំ/សង្កាត់ មន្ត្រីភូមិ កីឡាជម្រើសជាតិ ប្រតិបត្តិករដោះមីន កម្មករត្រីចក្រយាន្ត) និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព(កម្មករនិយោជិតនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន) អាចរហូតដល់ជាង៣០% នៃប្រជាពលរដ្ឋកម្ពុជាសរុប។

២.១៤៨- ប្រសិទ្ធភាពនៃការពង្រីកការគ្របដណ្តប់នៃយន្តការគាំពារសុខភាពសង្គមខាងលើ រួមជាមួយការពង្រីកការគ្របដណ្តប់នៃការផ្តល់សេវានិងកែលម្អគុណភាពសេវាសុខភាព និងនិយ័តកម្មទីផ្សារសុខភាពបានកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ ក្នុងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាពលរដ្ឋទូទៅ។ វឌ្ឍនភាពនេះ ត្រូវបានបញ្ជាក់ដោយនិន្នាការធ្លាក់ចុះនៃសមាមាត្រចំនួនគ្រួសារជួបការចំណាយប្រកបដោយភយន្តរាយលើការថែទាំសុខភាពពី៨,៨% នៅឆ្នាំ២០០៩ មកនៅ៣,៧% នៅឆ្នាំ២០១៦។ រីឯសមាមាត្រចំនួនគ្រួសារដែលបានធ្លាក់ខ្លួនក្របន្ទាប់ពីបានចំណាយលើការថែទាំសុខភាពពី ៥,៧% នៅឆ្នាំ២០០៩ មកនៅត្រឹម ១,៦% នៅឆ្នាំ២០១៦ហើយការចំណាយប្រាក់ហោប៉ៅរបស់គ្រួសារលើការថែទាំសុខភាព (ទាំងនៅសេវាសុខាភិបាលសាធារណៈនិងឯកជន) នៅមានកម្រិតខ្ពស់ រហូតដល់ ៦០,៤% នៅឆ្នាំ២០១៦ ដែលអាចជាអន្ទាក់នៃភាពក្រីក្រ បើទោះបីជាបានថយចុះពី៦២,៣% នៅឆ្នាំ២០១៤ ក្តី [1]។

## ៣. បង្កើនការផ្តល់សេវាសុខាភិបាល

២.១៤៩- **លទ្ធភាពទទួលបានសេវានិងការគ្របដណ្តប់** ត្រូវបានកត់សម្គាល់ដោយវឌ្ឍនភាព ដោយសារនិន្នាការនៃកើនឡើងនៃការប្រើប្រាស់សេវាសុខភាពបន្តពូជសុខភាព មាតាទារក និងកុមារ អាហារូបត្ថម្ភ សេវាបង្ការ ពិនិត្យ ព្យាបាលជំងឺឆ្លង ជំងឺមិនឆ្លង ភ្នាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈចម្បងផ្សេងៗទៀត ដូចបានបង្ហាញក្នុងតារាងខាងក្រោម។

### តារាងទី ២.៣៨ និន្នាការសូចនាករនៃការប្រើប្រាស់សេវាសុខាភិបាល ២០១៤-២០១៨[2]

| សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ លទ្ធផល | ២០១៨ ចំណុចដៅ |
|---|---|---|---|---|---|---|
| ពិនិត្យពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ (ចំនួនលើក) | ០,៥៩ | ០,៦១ | ០,៦៣ | ០,៧១ | ០,៧២ | ០,៧៥ |
| អត្រាប្រើប្រាស់គ្រែ (%) | ៩៥,២ | ៨៧ | ៩៣,៩ | ៩៤,៤ | ១០០,៥ | ៩៥ |
| អត្រាស្លាប់នៅមន្ទីរពេទ្យ | ០,៩៧ | ០,៩៨ | ០,៨៤ | ០,៨៧ | ០,៧២ | <១ |
| អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប | ៣៥ | ៣៩ | ៣២,៦ | ២៤,៨ | ២១,៩ | ៤៣ |
| សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល | ៨០ | ៨០,៣៥ | ៨០,៥២ | ៨៥,៣៧ | ៨៤,០៥ | ៨៨ |
| អត្រាសម្រាលដោយវិធីវះកាត់ (គិតជា % នៃទារកកើតរស់) | ៥,៣៧ | ៥,២៦ | ៥,៣៥ | ៥,៨៣ | ៦,៧៧ | ៨ |
| ភាគរយនៃស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល | ៦៦,៤ | ៧១,៥ | ៧២,២ | ៧៦,៨ | ៧៧,២ | ៨៧ |
| ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១ (មុន៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល | ៥៦,៤ | ៦៨,២ | ៦៧ | ៧០ | ៦៨,៤ | ៩៨ |

[1]លទ្ធផលវិភាគទិន្នន័យក្នុងរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ ដល់ឆ្នាំ២០១៦ របស់អង្គការសុខភាពពិភពលោក
[2]របាយការណ៍សមិទ្ធផលវិស័យសុខាភិបាលឆ្នាំ២០១៤ និងឆ្នាំ២០១៧ ក្រសួងសុខាភិបាល

| | | | | | | |
|---|---|---|---|---|---|---|
| ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងម៉ោងទីមួយនៃកំណើត * | - | ៧០ | ៦៤,៦ | ៦៣ | ៦៧ | ៩០ |
| ភាគរយនៃស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | ៨៦,១ | ៧៣ | ៨៦,៥ | ៨៨ | ៧៩,៩ | ៧៩ |
| ភាគរយនៃស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៤២គ្រាប់ | ៨២,៤ | ៦២ | ៧៤,៣ | ៧៨,៣ | ៧០ | ៨០ |
| ភាគរយនៃកុមារអាយុ៦-៥៩ខែបានទទួលគ្រប់ថ្នាំជីវជាតិអាក្នុងរយៈពេល៦ខែចុងក្រោយ(ជុំទី២) | ៧១ | ៨៨ | ៩៣,១ | ៨១,៧ | ៧៨,២ | ៩៣ |
| ភាគរយនៃកុមារអាយុ១២-៥៩ខែបានទទួលថ្នាំទំលាក់ព្រូនមេបង់ដាហ្សុលក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | ៧០ | ៧០ | ៨៨,៤ | ៨០ | ៧៨ | ៧៩ |
| អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការជំងឺខាន់ស្លាក់ស្វិតដៃជើងតេតាណូស រលាកសួត | ៩៨ | ៩៥ | ១០០១ | ៩៧,៦ | ៩៨ | ៩៥ |
| អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹលនៅខែទី៩ | ៩៤ | ៩២ | ១០៦ | ៩៦ | ១០៣ | ១០០ |
| ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុង១ឆ្នាំ(ចំនួនលើក) | ១,៤៥ | ១,៥២ | ១,៦៤ | ១,៥៥ | ១,៦០ | ១,៥៦ |
| ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានធ្វើតេស្ត Viral load ហើយមានលទ្ធផល Viral load suppressed ក្នុងរយៈពេល១២ខែកន្លងមក * | - | ៨៤ | ៦៤ | ៨០,៧៨ | ៨៤,៦៣ | ៨៨ |
| ភាគរយនៃមនុស្សពេញអាយុ លើសពី១៤ឆ្នាំ ផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ * | - | ៧៩ | ៧៦,៥ | ៨៥ | - | - |
| ភាគរយនៃកុមារអាយុក្រោម១៤ឆ្នាំផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ * | - | ៩២ | ៩០ | ៩៧ | - | - |
| ចំនួននៃអ្នកផ្ទុកមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ** | - | - | - | - | ៥៩ ៥២៦ | |
| អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | ៩០ | ៩៣ | ៩០ | ៩៣ | ៩៣ | >៩០ |
| ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ *** | ១២ ២៥០ | ៣៥ ៦៣៨ | ៣៣ ៧៣៦ | ៣៤ ៤៦៧ | - | ៣៥ ០០០ |
| ភាគរយនៃប្រជាជនអាយុពី២៥-៦៤ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល * | - | ២៩ | ៣០ | ៣៣,៨ | ៣០ | ៥៥ |
| ភាគរយនៃប្រជាជនអាយុពី២៥-៦៤ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល * | - | ១៧ | ២០,៤ | ៣៦,៥ | ៣២ | ៤៥ |
| ភាគរយនៃស្ត្រីអាយុ៣០-៤៩ឆ្នាំដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន * | - | ១,១៨ | ២,៦២ | ១,៨១ | ០,២៦ | ៦ |
| ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួល សេវាព្យាបាល * | - | ២ | ២ | ២ | ១,៧១ | ៣០ |
| ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល * | - | ២២ (១ ៣០០) | ២៨ | ៣០,១១ (៣១១០) | ១០០ (៨ ០៩៦) | ៦០ |
| ចំនួនវះកាត់ជំងឺភ្នែកឡើងបាយក្នុងប្រជាជន១លាននាក់ក្នុង១ឆ្នាំ | ១ ៨០១ | ១ ៥០០ | ២ ១០៩ | ១ ៩៥៤ | ២ ២៨៦ | ២ ០០០ |

* ទិន្នន័យចាប់ផ្តើមកត់ត្រានៅឆ្នាំ២០១៥

** ទិន្នន័យចាប់ផ្តើមកត់ត្រានៅឆ្នាំ២០១៨

*** លទ្ធផលឆ្នាំ២០១៨ នឹងចេញនៅចុងឆ្នាំ២០១៩

២.១៥០- កត្តាចំបងៗ ដែលអំណោយផលដល់ការសម្រេចបាននូវវឌ្ឍនភាពក្នុងលើកកម្ពស់លទ្ធ-ភាពទទួលបានសេវានិងការគ្របដណ្តប់មានជាអាទិ៍៖ ១.មានការវិនិយោគយ៉ាងច្រើនលើការពង្រីក

ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ធនធានមនុស្ស ការផ្គត់ផ្គង់ឱសថបរិក្ខារ សម្ភារឧបករណ៍ពេទ្យ ២.ការពង្រីកការគ្របដណ្តប់នៃគម្រោងគាំពារសុខភាពសង្គម ជាពិសេសកម្មវិធីមូលនិធិសមធម៌ ៣.ការពង្រីកបណ្តាញផ្លូវគមនាគមន៍ជាពិសេសនៅក្នុងតំបន់ជនបទ និង ៤.ការកើនឡើងនៃសមត្ថភាពចំណាយរបស់គ្រួសារលើការថែទាំសុខភាព ៥.ការកើនឡើងចំណាយចរន្តនៃថវិកាជាតិលើសុខភាព។

### តារាងទី ២.៣៩ ស្ថិតិមូលដ្ឋានសុខាភិបាលពី ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨[3]

| មូលដ្ឋានសុខាភិបាលសាធារណៈ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ចំនួនមន្ទីរពេទ្យ | ៩៧ | ៩៩ | ១១១ | ១១៧ | ១២៣ |
| ចំនួនមណ្ឌលសុខភាព * | ១ ១០៥ | ១ ១៤១ | ១ ១៦៥ | ១ ១៩០ | ១ ២០៥ |
| ចំនួនប៉ុស្តិ៍សុខភាព | ១០៦ | ៨១ | ៩៦ | ១១៩ | ១២៩ |
| ចំនួនសរុប | **១ ៣០៨** | **១ ៣២១** | **១ ៣៧២** | **១ ៤២៦** | **១ ៤៥៧** |
| ចំនួនគ្រែសម្រាកព្យាបាល | ៩ ៨៩៧ | ១០ ៦៨៩ | ១០ ៨៧០ | ១១ ៤០៨ | ១១ ៨៨៣ |

### តារាងទី ២.៤០ ស្ថិតិបុគ្គលិកសុខាភិបាលសាធារណៈពី ២០១៤ ដល់ ឆ្នាំ២០១៨[4]

| ប្រភេទបុគ្គលិក | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| វេជ្ជបណ្ឌិត វេជ្ជបណ្ឌិតឯកទេស | ២ ៣៤៧ | ២ ៣៤៦ | ៣ ១២៩ | ៣ ១៣០ | ៣ ៤៣២ |
| គ្រូពេទ្យមធ្យម | ៩០៦ | ៨៦៣ | ៨៦៦ | ៨៣៩ | ៦១៣ |
| ឱសថបណ្ឌិត ឱសថការី ឱសថមធ្យម បឋម | ៥២៦ | ៥២៥ | ៧៥៩ | ៧៦៩ | ៧៤៥ |
| ទន្តបណ្ឌិត ទន្តពេទ្យ ទន្តគិលានុប្បដ្ឋាក | ២៤៣ | ២៥០ | ៤៧៦ | ៥០០ | ៤៩៧ |
| បរិញ្ញាបត្រឆ្មប | | | ៨៩ | ១៤៥ | ២៧២ |
| ឆ្មបមធ្យម | ២ ៩៦៣ | ៣ ១៣០ | ៤ ០២២ | ៤ ១៧៨ | ៤ ២៧៩ |
| ឆ្មបបឋម | ២ ៣២៧ | ២ ២៨២ | ២ ៣៦៤ | ២ ៣២០ | ២ ២៥៦ |
| បរិញ្ញាបត្រគិលានុប្បដ្ឋាក | | | ១១៦ | ១៤៩ | ២១៥ |
| គិលានុបដ្ឋាក/យិកាមធ្យម | ៥ ៧០០ | ៥ ៧៤៥ | ៧ ៨៩៧ | ៧ ៨៥០ | ៧ ៩១២ |
| គិលានុបដ្ឋាក/យិកាបឋម | ៣ ២៩៩ | ៣ ១៧៣ | ៣ ១៩៨ | ៣ ០៦០ | ២ ៨៦៤ |
| អ្នកបច្ចេកទេសមធ្យមមន្ទីរពិសោធន៍ | ៤៨៤ | ៥០៦ | ៨៣៣ | ៧៧៥ | ៧៩៧ |
| ប្រភេទបុគ្គលិកដទៃទៀត | ២ ១៧៩ | ២ ១៣៤ | ១ ៦៣៣ | ១ ៧៤៤ | ១ ៥៥៦ |
| សរុប | **២០ ៩៧៤** | **២០ ៩៥៤** | **២៥ ៣៨២** | **២៥ ៤៥៩** | **២៥ ៤៣៨** |

### តារាងទី ២.៤១ និន្នាការនៃការចំណាយថវិកាជាតិក្នុងវិស័យសុខាភិបាល ២០១៤ ដល់ ឆ្នាំ២០១៨[5]

| ទូទាំងវិស័យសុខាភិបាលសាធារណៈ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ចំណាយចរន្ត | ៨២៥ ១៩៩,៩ | ៩៥៩ ៧៦៩,៦ | ១ ០៥០ ១៧៧,៦ | ១ ១៧៧ ៤១៩,០ | ១ ៣៧៨ ១០៦,៧ |
| %នៃចំណាយធៀបនឹងផែនការថវិកាអនុម័ត | ៨៤,៤ | ៩៣,៨ | ៩៤,៥ | ៩៨,០ | ៩៨,៩ |
| ថ្នាក់កណ្តាល | | | | | |

[3]របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨ ក្រសួងសុខាភិបាល

[4]របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨ ក្រសួងសុខាភិបាល

[5]របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨ ក្រសួងសុខាភិបាល

| | | | | | |
|---|---|---|---|---|---|
| ចំណាយចរន្ត | ៥៥០ ១៣៨,១ | ៦៤៣ ៥៤៥,០ | ៦៥៣.១៩៨,៩ | ៦៧៩.៨៣៥,៧ | ៨២៥.៧៣៨,២ |
| %នៃចំណាយធៀបនឹងផែនការថវិកាអនុម័ត | ៧៩,៧ | ៨៩,៥ | ៩៣,៨ | ៩៥,០ | ១០០,៧ |
| ថ្នាក់រាជធានីខេត្ត | | | | | |
| ចំណាយចរន្ត | ២៧៥ ០៦១,៨ | ៣១៦ ២២៤,៧ | ៣៩៦ ៩៧៨,៧ | ៤៩៧ ៥៨៣,៣ | ៥៥២ ៣៦៧,៩ |
| %នៃចំណាយធៀបនឹងផែនការថវិកាអនុម័ត | ៩៥,៦ | ១០៤,១ | ៩៥,៨ | ១០២,៣ | ៩៦,៣ |

២.១៥១- **គុណភាពសេវា៖** គុណភាពទូទៅនៃសេវាសុខាភិបាលសាធារណៈ ត្រូវបានកែលម្អឲ្យប្រសើរឡើងជាលំដាប់ដោយសារភាពកាន់តែប្រសើរឡើងនៃគុណភាពរចនាសម្ព័ន្ធនិងគុណភាពបច្ចេកទេស (បែបបទនៃការផ្តល់សេវាថែទាំព្យាបាល)។ វឌ្ឍនភាពនេះបានរួមចំណែកជាសក្ខីនុពលដល់ការធ្លាក់ចុះមរណភាពមាតា ទារកនិងកុមារនិងការធ្លាក់ចុះបន្ទុកនៃជំងឺឆ្លង។ ទោះជាដូច្នេះក្តី គុណភាពសេវានៅមិនទាន់ឆ្លើយតបពេញលេញទៅនឹងសេចក្តីត្រូវការនិងការរំពឹងទុករបស់អ្នកប្រើប្រាស់នៅឡើយ ដោយសារនៅមានឧបសគ្គផ្នែកធនធាន។

២.១៥២- **ប្រសិទ្ធភាព៖** កំណើនសេដ្ឋកិច្ចលឿននិងមានសង្គតិភាព បានផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលបង្កើនចំណាយថវិកាជាតិលើសុខភាព ខណៈដែលមូលនិធិជំនួយមាននិន្នាការថយចុះ។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកំពុងប្រព្រឹត្តទៅ បានផ្តល់កាលានុវត្តភាពឲ្យក្រសួងសុខាភិបាលពង្រឹងប្រសិទ្ធភាពនៃការចំណាយ។ ប្រសិទ្ធភាពនិងភាពឆ្លើយតបរបស់អ្នកផ្តល់សេវាសុខាភិបាលសាធារណៈត្រូវបានលើកកម្ពស់ តាមរយៈយន្តការដែលផ្សារភ្ជាប់លទ្ធផលនៃការផ្តល់សេវាទៅនឹងធនធានហិរញ្ញវត្ថុដូចជាគម្រោងប្រាក់ឧបត្ថម្ភលើកទឹកចិត្តធ្មប កញ្ចប់ថវិកាផ្តល់សេវា ទីភ្នាក់ងារប្រតិបត្តិការពិសេស។

២.១៥៣- **សមធម៌៖** ក្នុងការមកទទួលបានសេវាសុខភាពនិងក្នុងហិរញ្ញប្បទានសុខាភិបាលត្រូវបានលើកស្ទួយជាបន្តបន្ទាប់ដោយសារបានប្រើប្រាស់ធនធានដែលមាន តម្រង់ឆ្ពោះទៅរកការផ្តល់សេវាសុខភាពបឋមនៅតំបន់ជនបទនិងការពង្រីកការគ្របដណ្តប់នៃមូលនិធិសមធម៌ រួមជាមួយនឹងអន្តរាគមន៍ហិរញ្ញប្បទានសុខាភិបាលផ្សេងៗទៀត។ គួរកត់សម្គាល់ថា ការស្វែងរកការថែទាំសុខភាពកាន់តែមានលក្ខណៈសមធម៌ជាងមុន ហើយឥរិយាបទរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកថែទាំសុខភាពក៏កាន់តែប្រសើរ ជាពិសេសក្នុងចំណោមប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបបំផុត។

## ៤. លើកកម្ពស់អភិបាលកិច្ចនិងគណនេយ្យភាព

២.១៥៤- វឌ្ឍនភាពត្រូវបានកត់សម្គាល់ នៅក្នុងការពង្រឹងការអនុវត្តច្បាប់ នីតិក្រមសុខាភិបាលជាពិសេសការលប់បំបាត់សេវាឯកជនអត់ច្បាប់ និងផលិតផលឱសថក្លែងក្លាយ។ លិខិតបទដ្ឋានគតិយុត្តផ្នែកសុខាភិបាលជាច្រើនត្រូវបានអភិវឌ្ឍនិងដាក់ឲ្យអនុវត្ត។ ប្រតិភូកម្មមុខងារនិយ័តកម្មសេវាឯកជនទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រព្រឹត្តទៅ។ ខណៈដែលរចនាសម្ព័ន្ធគតិយុត្តសម្រាប់អភិបាលកិច្ចប្រព័ន្ធសុខាភិបាលត្រូវបានអភិវឌ្ឍនិងដាក់ឲ្យដំណើរការ សមត្ថភាព

និយ័តកម្មដើម្បីពង្រឹងការអនុវត្តច្បាប់បានក្លាយជាបញ្ហាប្រឈមចំបង ដល់មុខងារដឹកនាំរបស់ក្រសួងសុខាភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលប្រតិបត្តិប្រតិភូកម្មមុខងារនិយ័តកម្ម។

## បញ្ហាប្រឈម

២.១៥៥- ទោះបីស្ថានភាពសុខភាពទូទៅរបស់ប្រជាពលរដ្ឋត្រូវបានកែលម្អឲ្យកាន់តែល្អប្រសើរឡើងក្តី ក៏វិស័យសុខាភិបាលនៅតែជួបបញ្ហាប្រឈមទាំងផ្នែកអេពីដេមីញូសាស្ត្រផង (បន្ទុកជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ) និងផ្នែកប្រតិបត្តិការនៃប្រព័ន្ធសុខាភិបាលផង ដែលតម្រូវឲ្យដោះស្រាយក្នុងលក្ខណៈជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព ក្នុងរយៈពេលខ្លី មធ្យម ទៅរយៈពេលវែង។

### ផ្នែកអេពីដេមីញូសាស្ត្រ

- មរណភាពមាតា ទារកនិងកុមារនិងកង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីនិងកុមារតូច (ស្រួចស្រាវនិងរ៉ាំរ៉ៃ) នៅខ្ពស់បើប្រៀបធៀបនឹងបណ្តាប្រទេសក្នុងតំបន់។
- ការឆ្លងនៃមេរោគអេដស៍នៅតែគួរឲ្យព្រួយបារម្ភក្នុងក្រុមប្រជាជនគន្លឹះមួយចំនួន។ ករណីថ្មីនិងអត្រាស្លាប់នៃជំងឺរបេងនៅខ្ពស់។ ភាពស៊ាំនឹងឱសថព្យាបាលច្រើនមុខនៃមេរោគរបេង និងភាពស៊ាំរបស់មេរោគគ្រុនចាញ់ជាមួយឱសថព្យាបាលនៅតែជាបញ្ហាប្រឈមចម្បងផ្នែកគ្លីនិក។
- កំណើនបន្ទុកនៃជំងឺមិនឆ្លង រួមជាមួយអាយុកាលរស់នៅវែងរបស់ប្រជាជន ចោទជាបញ្ហាដល់រចនាសម្ព័ន្ធ និងវិធីសាស្ត្រនៃការផ្តល់សេវាសុខភាព។
- ជំងឺឆ្លងលេចឡើងថ្មីឬលេចឡើងសារជាថ្មីម្តងទៀត នៅតែបន្តគំរាមកំហែងដល់សន្តិសុខសុខភាពតំបន់ និងអន្តរជាតិ។
- ផលប៉ះពាល់លើសុខភាពមនុស្ស ដោយសារការប្រើប្រាស់ប្រកបដោយហានិភ័យនៃគ្រឿងញៀនគ្រឿងស្រវឹង អាហារខ្វះសុវត្ថិភាព នគរូបនីយកម្មតំបន់ទីក្រុងហានិភ័យសុខភាពបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ ត្រូវការការឆ្លើយតបពីពហុវិស័យមានប្រសិទ្ធភាព។

### ផ្នែកប្រតិបត្តិប្រព័ន្ធសុខាភិបាល

- ការផ្តល់សេវាសុខភាពមានគុណភាពជួបឧបសគ្គផ្នែកធនធានមិនគ្រប់គ្រាន់ ជាពិសេសធនធានមនុស្សនិងសមត្ថភាពធ្វើរោគវិនិច្ឆ័យ ឱសថបរិក្ខារនៅខ្វះខាតដោយអន្លើ។
- សមត្ថភាពនៃការផ្តល់សេវាសុខាភិបាល មិនទាន់ឆ្លើយតបបានពេញលេញទៅនឹងបញ្ហាសុខភាពបណ្តាលមកពីជំងឺឆ្លង ជំងឺមិនឆ្លង-រ៉ាំរ៉ៃ ជំងឺផ្លូវចិត្ត និងបញ្ហាសុខភាពសាធារណៈចម្បងៗដទៃទៀត។

- ឥរិយាបថមិនសមរម្យរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកការថែទាំសុខភាព ពិសេសក្នុងតំបន់ជនបទ មានជាអាទិ៍៖ ពន្យារពេលស្វែងរកការព្យាបាល ព្យាបាលដោយខ្លួនឯង ។ល។
- កាត់បន្ថយគម្លាតនៃការផ្តល់សេវាសុខភាពមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព នៅគ្រប់ភូមិសាស្ត្រនិងបន្តលើកកម្ពស់សមធម៌។
- ចំណាយប្រាក់ហោប៉ៅរបស់ប្រជាពលរដ្ឋលើការថែទាំសុខភាពខ្ពស់ រីឯការប្រមូលផ្តុំហានិភ័យនៅមានកម្រិតទាប ហើយប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមសម្រាប់ប្រជាជននៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍ។
- ខ្វះបុគ្គលិកសុខាភិបាលជំនាញ ជាពិសេសនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យ ធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពក្នុងការពង្រីកការគ្របដណ្តប់នៃសេវា និងការលើកកម្ពស់គុណភាព។
- ការវិនិយោគលើបច្ចេកវិទ្យាវេជ្ជសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពក្នុងការវិភាគបកស្រាយ និងការប្រើប្រាស់ទិន្នន័យ/ព័ត៌មាន នៅមានកម្រិត ។
- ការរីកដុះដាលយ៉ាងលឿននៃសេវាសុខាភិបាលឯកជន នាំមកនូវបញ្ហាប្រឈមដល់មុខងារដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងសុខាភិបាល និងសមត្ថភាពនិយ័តកម្មនៅក្នុងប្រព័ន្ធសុខាភិបាលគ្រប់ថ្នាក់។
- ប្រតិភូកម្ម ឬការប្រគល់មុខងារ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានផលប៉ះពាល់ដល់មុខងារ និងរចនាសម្ព័ន្ធស្ថាប័នរបស់ក្រសួងសុខាភិបាល និងអង្គភាពសុខាភិបាលគ្រប់ថ្នាក់។

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

២.១៥៦- នៅកម្ពុជា កុមារដែលមានអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងចំណោមកុមារ៣នាក់ មានបញ្ហាក្រេះក្រិន ហើយម្នាក់ក្នុងចំណោម៤នាក់មានបញ្ហាខ្វះទម្ងន់ និងកុមារម្នាក់ក្នុងចំណោម១០នាក់កើតជំងឺស្លេកស្លាំង ។ ការប៉ាន់ប្រមាណពីបន្ទុកសេដ្ឋកិច្ចបានបង្ហាញថា៖បញ្ហាអាហារូបត្ថម្ភ គឺត្រូវចំណាយថវិកាជិត៤០០លានដុល្លារក្នុងមួយឆ្នាំៗ នៃតម្លៃផលិតផលក្នុងស្រុកសរុប។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជាស្ថាប័នសម្របសម្រួល បានប្តេជ្ញាក្នុងការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងលុបបំបាត់អសន្តិសុខស្បៀងនិងភាពអត់ឃ្លាន។ ដោយមានការចង្អុលបង្ហាញពីប្រមុខរាជរដ្ឋាភិបាល និងមានការគាំទ្រពីដៃគូអភិវឌ្ឍ តម្រូវឲ្យមាននូវអភិក្រម និងដំណោះស្រាយពីវិស័យពាក់ព័ន្ធនានា ដើម្បីជំរុញឲ្យមានការសម្របសម្រួលកាន់តែមានប្រសិទ្ធភាពទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

២.១៥៧- ក្នុងកំឡុងឆ្នាំ២០១៤-២០១៨ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានដឹកនាំការអភិវឌ្ឍក្របខ័ណ្ឌផែនការនិងយន្តការសម្របសម្រួលសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការដោះស្រាយបញ្ហាសន្តិសុខស្បៀងបានកត់សម្គាល់ឃើញថា មានភាពប្រសើរ

ឡើងក្នុងនោះរួមមាន៖ ភាពមានស្បៀង ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យបានលើសពីគោលដៅផែនការ និងបន្តការងារបានយ៉ាងល្អប្រសើរ។ ដោយឡែក សេវាសុខាភិបាល និងការអប់រំ ត្រូវបានកែលម្អទៅតាមផែនការហើយក៏មានការសម្របសម្រួលកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងវិបត្តិនានា។ ការរួមចំណែករបស់ក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍ គឺមានសារៈសំខាន់ដើម្បីរក្សាបានភាពប្រសើរឡើងនិងនិរន្តរភាពនៃវឌ្ឍនភាពការងារ។

២.១៥៨- សមិទ្ធផលសំខាន់ៗ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្មនិងជនបទ (ក.ក.ជ.) ក្នុងការសម្របសម្រួលពហុវិស័យជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានាមានដូចខាងក្រោម៖

- យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ បានផ្តល់នូវទិសដៅជាយុទ្ធសាស្ត្រសម្រាប់សកម្មភាពតាមវិស័យ និងអន្តរវិស័យដើម្បីគាំទ្រវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការលើកកម្ពស់ការយល់ដឹងជាសាធារណៈពីសារៈសំខាន់នៃអាហារូបត្ថម្ភ តាមរយៈការបង្កើតឲ្យមានទិវាជាតិអាហារូបត្ថម្ភ នៅថ្ងៃទី៦ ខែវិច្ឆិកាជារៀងរាល់ឆ្នាំ និងសិក្ខាសាលាជាតិនានាស្តីពីអាហារូបត្ថម្ភ។
- ការបណ្តុះបណ្តាល គឺជាការងារសំខាន់មួយរបស់ក.ក.ជ. ហើយក្រុមគ្រូបង្គោលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ បានបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលនិងសម្របសម្រួលអន្តរៈវិស័យ និងប្តេជ្ញាក្នុងការអភិវឌ្ឍវិជ្ជាជីវៈផ្នែកសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។
- ការត្រៀមបង្ការគ្រោះមហន្តរាយ បានប្រសើរឡើងតាមរយៈការសម្របសម្រួលរបស់វេទិកាឆ្លើយតបមនុស្សធម៌និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងការអនុវត្តប្រចាំឆ្នាំដោយមានការធ្វើលំហាត់សមយុទ្ធត្រៀមបង្ការគ្រោះមហន្តរាយ CamRex មួយចំនួននៅថ្នាក់ក្រោមជាតិផងដែរ។
- ប្រព័ន្ធព័ត៌មាននិងការស្រាវជ្រាវ ដើម្បីផ្តល់នូវទិន្នន័យមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តសម្រាប់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ មានផលិតភាពខ្ពស់ និងមានការសិក្សាជាច្រើនដែលបានរៀបចំនិងផ្សព្វផ្សាយដោយក.ក.ជ. និងដៃគូអភិវឌ្ឍ។
- ការតស៊ូមតិលើការផ្តល់ថវិការដ្ឋបន្ថែមសម្រាប់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភទៅក្រសួងសុខាភិបាលនិងក្រសួងផែនការ ដើម្បីអន្តរាគមន៍លើអាហារូបត្ថម្ភជាក់លាក់និងអាហារូបត្ថម្ភស្រួចស្រាវ ដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភធ្ងន់ធ្ងរនិងការដាក់បញ្ចូលសារធាតុអ៊ីយ៉ូដទៅក្នុងអំបិល ទឹកត្រី ទឹកស៊ីអ៊ីវ មានជាតិដែក អង្ករបញ្ចូលមីក្រូសារជាតិ។

**បញ្ហាប្រឈម**

២.១៥៩-បញ្ហាប្រឈមចម្បងៗសម្រាប់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជារួមមាន៖

- ប្រសិទ្ធភាពប្រតិបត្តិការនៃប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គឺជាបញ្ហាចម្បងសម្រាប់ការរៀបចំផែនការ ការសម្របសម្រួល និងការធ្វើសេចក្តីសម្រេចចិត្តនៅមានកម្រិត។
- ការផ្លាស់ប្តូរទិដ្ឋភាពយ៉ាងឆាប់រហ័សសម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យដែលរួមមាន និន្នាការសេដ្ឋកិច្ចសង្គម កំណើនប្រជាជន កំណើនសេដ្ឋកិច្ច នគរូបនីយកម្ម ចំណាកស្រុក យន្តការ និងការទំនាក់ទំនងស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពធនធានធម្មជាតិ។
- បញ្ហាប្រឈមនៅតែបន្តកើតមាន ដើម្បីធានាបាននូវសុវត្ថិភាពស្បៀងអាហារ គុណភាពទឹកស្អាត ការកាត់បន្ថយការបន្ទោរបង់ពាសវាលពាសកាល និងការលើកកម្ពស់អនាម័យកសិដ្ឋានលក្ខណៈគ្រួសារ។
- ការទទួលបានរបបអាហារចម្រុះរបស់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម៥ឆ្នាំ នៅតែជាបញ្ហាចោទក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការអនុវត្តល្អក្នុងការផ្តល់ចំណីអាហារសមស្របសម្រាប់កុមារតូចអាយុក្រោម២ឆ្នាំ គឺនៅតែចោទជាបញ្ហានៅឡើយ ដោយសារតែកត្តាឥទ្ធិពលរបស់សង្គម និងវប្បធម៌ ក្នុងនោះការលក់ម្សៅទឹកដោះគោជំនួសឲ្យការបៅទឹកដោះម្តាយនៅតាមទីផ្សារក៏ជាមូលហេតុដែលនាំឲ្យកុមារមិនទទួលបានអាហារសមស្របផងដែរ។
- ការអនុវត្តលិខិតបទដ្ឋានសម្រាប់ការប្រើប្រាស់ម្សៅទឹកដោះគោជំនួសឲ្យទឹកដោះម្តាយ និងការដាក់បញ្ចូលមីក្រូសារធាតុទៅក្នុងចំណីអាហារ គឺស្ថិតនៅបន្តជាបញ្ហាប្រឈមនៅឡើយ។ ចំពោះការដាក់បញ្ចូលមីក្រូសារធាតុទៅក្នុងចំណីអាហារ គឺជួបប្រទះបញ្ហាប្រឈមជាច្រើន ដូចជា ការរៀបចំស្ថាប័ន ការរៀបចំបទដ្ឋានចំណីអាហារ ការធានាគុណភាព ព្រមជាមួយនឹងការអនុវត្តច្បាប់ផងដែរ។
- ការរក្សាការប្តេជ្ញាចិត្តតាមវិស័យសម្រាប់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការជួបប្រទះបញ្ហាប្រឈមពហុវិស័យ តម្រូវឲ្យមានការបង្កើនមូលនិធិសាធារណៈ សម្រាប់អនាគតហើយមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាពនោះ គឺត្រូវមានការចូលរួមវិនិយោគ របស់វិស័យឯកជន។
- និន្នាការកើនឡើងបញ្ហាការលើសទំងន់និងជំងឺធាត់ជ្រុល ជាពិសេសចំពោះស្ត្រីស្ថិតក្នុងវ័យបន្តពូជ គឺសុទ្ធសឹងតែជាក្តីព្រួយបារម្ភដែលត្រូវដោះស្រាយ។
- តម្រូវការនៅតែបន្តមានសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធផលិតកម្មកសិកម្មចម្រុះ ក៏ដូចជាប្រព័ន្ធស្បៀងអាហារដែលយកចិត្តទុកដាក់លើអាហារូបត្ថម្ភ។ ការការពារធនធានធម្មជាតិ សំខាន់ៗ ជាពិសេស ទឹកនិងដី គឺជាក្តីកង្វល់និងជាបញ្ហាប្រឈមក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៧.៣- ការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម

២.១៦០- រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គមនិងបានធ្វើឲ្យប្រព័ន្ធនេះក្លាយជាប្រព័ន្ធមួយដែលមានលក្ខណៈសមាហរណកម្ម សង្គតិភាព និងប្រសិទ្ធភាពដែលគ្របដណ្ដប់លើវិស័យសាធារណៈនិងវិស័យឯកជន រួមមានការបែងចែកតួនាទីច្បាស់លាស់រវាងការរៀបចំគោលនយោបាយ ច្បាប់ និងការប្រតិបត្តិ។ សមិទ្ធផលមួយចំនួនស្ដីពីសុវត្ថិភាពសង្គម មានដូចខាងក្រោម៖

២.១៦១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធនិងក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានដឹកនាំរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសន្តិសុខសង្គម ២០១៦-២០២៥ ដែលមានពីរផ្នែកធំៗគឺ ជំនួយសង្គមនិងធានារ៉ាប់រងសង្គម។ ដៃគូអភិវឌ្ឍ បានសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសាកល្បងគម្រោងគាំទ្រចំណូលដែលនឹងផ្តល់ជាមេរៀននិងបទពិសោធសម្រាប់ការរៀបចំសមាសធាតុគាំទ្រចំណូលនៃជំនួយសង្គមនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសន្តិសុខសង្គម។

២.១៦២- កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រេចបានការគ្របដណ្ដប់តំបន់ជនបទទាំងអស់។ ចាប់តាំងពីឆ្នាំ២០១៥ ក្រសួងផែនការមានភាពជាម្ចាស់ពេញលេញលើផ្នែកហិរញ្ញវត្ថុសម្រាប់ការគ្របដណ្ដប់តំបន់ជនបទ។ យន្តការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតំបន់ទីប្រជុំជនបានបញ្ចូលការដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យភាពងាយរងគ្រោះ ដូចជា សុខភាព ពិការ ការអប់រំ និងបំណុល ហើយការដាក់ពិន្ទុនេះ ក៏បានអនុវត្តជាមួយតំបន់ជនបទ។

២.១៦៣- មានវឌ្ឍនភាពល្អក្នុងការអភិវឌ្ឍក្របខ័ណ្ឌស្ថាប័នគាំទ្រសុខមាលភាពកុមារ រួមទាំងផែនការកំណែទម្រង់ប្រព័ន្ធព្រហ្មទណ្ឌយុត្តិធម៌អនីតិជន ឆ្នាំ២០១៣។ អង្កេតស្ដីពីអំពើហិង្សាលើកុមារត្រូវបានបោះពុម្ពក្នុងឆ្នាំ២០១៤។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរាយការណ៍ពីវឌ្ឍនភាពទាក់ទងនឹងការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ក្នុងនាមដែលកម្ពុជាជាប្រទេសហត្ថលេខី។

២.១៦៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងដើម្បីគាំទ្រដល់ការសង្គ្រោះបន្ទាន់ពេលមានគ្រោះមហន្តរាយធម្មជាតិឬព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

### ការងារអាទិភាពទី១៖ លើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ

- បង្កើតនិងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ដោយមានកិច្ចសហការជាមួយកាកបាទក្រហមកម្ពុជា និងអង្គការនានាសម្រាប់ជួយប្រជាជនក្រីក្រ ទុរគតជន ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ រងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ដែលក្នុងរយៈពេល៥ឆ្នាំ ជនរងគ្រោះប្រមាណ៣៧៣ ៩៥២គ្រួសារត្រូវបានជួយសង្គ្រោះ សម្រាលស្ថានភាពលំបាកដោយបង្កលក្ខណសម្បត្តិសម្រាប់ការស្តារជីវភាពឡើងវិញ។ បានផ្សព្វផ្សាយ អប់រំ បញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់អជ្ញាធរមូលដ្ឋាននិងប្រជាជនចំនួន ៥២៦ ៥៧៥នាក់។
- បានបង្កើត និងអនុវត្តកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ តាមរយៈការរៀបចំទិវាជាតិនិងអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ជារៀងរាល់ឆ្នាំ។ បានបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្សព្វផ្សាយទស្សនទានយេនឌ័រ និងអនុសញ្ញាស៊ី-ដ(CEDAW) ដល់មន្ត្រីបង្គោលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ និងការផ្សព្វផ្សាយការយល់ដឹងស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍។
- បានរៀបចំនិងដាក់ឲ្យអនុវត្តនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។ ទន្ទឹមនោះ បានកសាងមណ្ឌលសំចតបោ៉យប៉ែតសម្រាប់ទទួលទុកដាក់ជនរងគ្រោះដែលទទួលបានពីអាជ្ញាធរនិងភាគីថៃ។

### តារាងទី ២.៤២ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ជនរងគ្រោះនិងងាយរងគ្រោះត្រូវបានទទួលជំនួយសង្គ្រោះបន្ទាន់ (គ្រួសារ) | ៣២ ២១២ | ១៧៨ ៥៣៨ | ៤៣ ៥៨០ | ៦២ ៤៧៦ | ៥៧ ១៤៦ | ៣៧៣ ៩៥២ |
| ២ | ជនអនាថាបានទទួលសេវាដោះស្រាយបញ្ហាទប់ស្កាត់និងការពារ (នាក់) | ៥៤៤ | ២ ៤៣៧ | ៨៨៤ | ១ ៧២៧ | ២ ០៤១ | ៧ ៦៣៣ |
| ៣ | ជនអនាថាដែលធ្វើសមាហរណកម្មទៅគ្រួសារនិងសហគមន៍វិញ (នាក់) | ៥៦ | ២ ៤៣៧ | ៨៨៤ | ១ ២៤៤ | ២ ៥២៤ | ៧ ១៤៥ |
| ៤ | ជនផ្ទុកមេរោគអេដស៍/ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗ | ២ ២៦៤ | ៦ ៧៤៨ | ៣ ៧២៤ | ២ ៧៥៨ | ៤ ២៨៥ | ១៩ ៧៧៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៅតាមសហគមន៍ទទួលបានសេវាប្រឹក្សា ថែទាំ គាំទ្រ (នាក់) | | | | | | |
| ៥ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សធ្វើសមាហរណកម្មទៅគ្រួសារ និង សហគមន៍វិញ (នាក់) | ១៤៦ | ៤៧ | ៥៨ | ១៤៧ | ៣៤៥ | ៧៤៣ |
| ៦ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាពិគ្រោះយោបល់ និង ស្តារនីតិសម្បទា (នាក់) | ២៧៩ | ៥៩៨ | ៤៥៥ | ៧២០ | ៨៤៨ | ២ ៩០០ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម នៅមិនទាន់ទូលំទូលាយនិងគ្របដណ្តប់ពេញលេញ ដែលធ្វើឱ្យក្រុមប្រជាជនមួយចំនួន មិនទាន់ទទួលបានការគាំពារ
- ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងអត្រានុកូលដ្ឋានប្រជាជនទូទៅ ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករនៅមិនទាន់បានតភ្ជាប់គ្នា ដែលនាំឲ្យមានការត្រួតគ្នាលើការកំណត់អត្តសញ្ញាណ និងការចុះបញ្ជី និងការផ្តល់អត្ថប្រយោជន៍ត្រួតគ្នាផងដែរ
- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិត។ ការពង្រឹងសមត្ថភាពមន្ត្រីក៏ត្រូវបង្កើនឲ្យស្របតាមស្ថានភាព និងតម្រូវការ
- ខណៈដែលគុណភាពនៃសេវាសុខាភិបាលត្រូវបានពង្រឹង ការលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារនៅមិនទាន់មានវឌ្ឍនភាពខ្លាំងក្លានៅឡើយ។ ស្ត្រីមានផ្ទៃពោះនិងកុមារក្រោមអាយុ៥ឆ្នាំ មកពីគ្រួសារក្រីក្រងាយនឹងជួបប្រទះបញ្ហាកង្វះអាហារូប-ត្ថម្ភ ដោយសារកង្វះធនធានហិរញ្ញវត្ថុ និងព័ត៌មាន ដែលចាំបាច់ដើម្បីទទួលសេវាថែទាំសុខភាព និងរបបអាហារូបត្ថម្ភព្រមទាំង ទឹកស្អាត និងអនាម័យ ផងដែរ
- ការពង្រឹងកម្មវិធីអភិវឌ្ឍន៍គ្រួសារនៅមានកម្រិត ដោយខ្វះខាតយន្តការនៃការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ

**ការងារអាទិភាពទី២៖ លើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា**

- ពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញគោលការណ៍ណែនាំស្តីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ
- ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនិងផ្សព្វផ្សាយសិទ្ធិកុមារយ៉ាងទូលំទូលាយ

- រៀបចំរបាយការណ៍ស្តីពីស្ថានភាពនៃការអនុវត្តសិទ្ធិកុមារជារៀងរាល់ឆ្នាំនិងរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារនិងរូបភាពអាសអាភាសកុមារ និងរបាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តមហាសន្និបាតអ.ស.ប.ស្តីពីការការពារកុមារពីការសម្លុតគំរាមកំហែង ។ បានរៀបចំ និងផ្សព្វផ្សាយដាក់ឲ្យអនុវត្តនូវផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨ និងរៀបចំរបាយការណ៍ជាតិខួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ
- អនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ ដោយបានសហការជាមួយអង្គការជាតិ អន្តរជាតិ។ បានបណ្តុះបណ្តាលគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារដល់មន្ត្រីជំនាញ បុគ្គលិកអង្គការជាច្រើន។
- ដើម្បីពង្រឹងប្រសិទ្ធភាពនិងគុណភាពការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងការគ្រប់គ្រងកុមារតាមសហគមន៍ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន០៣។ ក្រសួងបានចេញប្រកាសស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ។ បានចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារដើម្បីទប់ស្កាត់ការរំលោភបំពានលើកុមារ និងបិទមណ្ឌលថែទាំកុមារដែលមិនគោរពតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ
- អនុវត្តតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ក្រសួងបានបង្កើតយន្តការ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើន និងបានចុះកិច្ចព្រមព្រៀងស្តីពីការកំណត់ចំនួនទីភ្នាក់ងារជាមួយសុំកូនអន្តរប្រទេសជាមួយប្រទេសអ៊ីតាលី ប្រទេសអេស្ប៉ាញ និងប្រទេសម៉ាល់តា
- ប្រកាសនិងដាក់ឲ្យអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ព្រមទាំងបានផ្សព្វផ្សាយដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលយុវនីតិសម្បទា និងការកសាងមជ្ឈមណ្ឌលជាតិព្យាបាលបន្សាប និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកែវផុសខេត្តព្រះសីហនុ ព្រមទាំងប្រកាសស្តីពីការសាងសង់មណ្ឌលយុវនីតិសម្បទា ប្រកាសស្តីពីរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមណ្ឌលយុវនីតិសម្បទា ប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំបង្កើតមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគោលការណ៍ណែនាំស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។
- អប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌ និងការពារសិទ្ធិរបស់កុមារ និងជនរងគ្រោះដែលប្រព្រឹត្តល្មើស។ បាន

សហការជាមួយក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់ និងកុមារតាមម្តាយនៅក្នុងពន្ធនាគារ។

### តារាងទី ២.៤៣ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | កុមារកំព្រា និងកុមាររងគ្រោះធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | ៧២១ | ៥៧៤ | ៤៦២ | ៧៣៨ | ១ ១៤០ | ៣ ៦៣៥ |
| ២ | ចំនួនកុមារដែលទទួលបានការថែទាំនៅតាមសហគមន៍ (នាក់) | ៤១ ១៩៤ | ៤២ ៧៨៥ | ៩ ៦០៨ | ៩ ៦០៨ | ១០ ៧៤៨ | |
| ៣ | ចំនួនកុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ (នាក់) | ១១ ៤១១ | ១១ ១៧១ | ១៦ ៥៧៩ | ១៦ ៥៧៩ | ៧ ៦៣៩ | |
| ៤ | អនីតិជនទំនាស់នឹងច្បាប់ធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | ៥៣ | ៤០ | ៩៨ | ១១៨ | ១៤៧ | ៤៥៦ |
| ៥ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | ១ ៨៥៥ | ២ ០០៩ | ២ ៨៥១ | ៦ ៧២២ | ៧ ៦៧៧ | ២១ ១១៤ |
| ៦ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនទទួលបានសេវាស្តារនីតិសម្បទា (នាក់) | ២ ៨៧៥ | ៣ ៣៨៦ | ៥២០៣ | ១០ ១៧៨ | ៨ ០៩៧ | ២៩ ៧៣៩ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- នៅកម្ពុជាមិនទាន់មានទិន្នន័យជាក់លាក់ស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការទេ តែផែនការយុទ្ធសាស្ត្រជាតិស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការបានប៉ាន់ស្មានថា មានកុមារងាយរងគ្រោះប្រមាណ១៤%នៃចំនួនកុមារសរុប។
- ទិន្នន័យអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១៣ មានកុមារពិការកម្រិតទាប ព្រោះថាមិនបានប្រមូលទិន្នន័យជាក់លាក់ពីភ្នាក់ងារប្រមូលទិន្នន័យ។ ម្យ៉ាងវិញទៀត កុមារពិការ គឺជាក្រុមជនដែលងាយរងគ្រោះ ហើយមានកម្រិតក្នុងការទទួលបានសេវាកម្មនានាពីសង្គម ពួកគេខ្លះប្រឈមនឹងការរើសអើង និងករណីខ្លះ ក៏មានអំពើហិង្សាពីគ្រួសារផងដែរ

**ការងារអាទិភាពទី៣៖ លើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ**

- អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- អនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ “ធ្វើឲ្យសិទ្ធិក្លាយជា

ការពិត" បន្ថែមលើបទដ្ឋានគតិយុត្តជាតិដែលមានស្រាប់ ដោយបានរៀបចំរបាយការណ៍ជាតិលើកដំបូង ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ

- ប្រកាសជាផ្លូវការដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨ តាមរយៈផែនការនេះ ក្រសួងបានរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ ២០១៥ និងសេចក្តីព្រាងរបាយការណ៍បញ្ចប់អាណត្តិឆ្នាំ២០១៤-២០១៨
- រៀបចំទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ទិវាគ ថ្លង់ និងទិវាអូទីហ្ស៊ីមនិងដោនស៊ីនដ្រូមសម្រាប់ជនពិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័នចំនួន១៩ និងក្រុមប្រឹក្សាសកម្មភាពជនពិការតាមរាជធានី ខេត្តចំនួន២៥ និងបានបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទស្សនវិស័យជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ដល់សមាជិក មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.ជ. ក្រុមការងារក.ស.ជ. តាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្ត។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជនពិការក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស៊េរ៉ស្ប៉ាល់អូឡាំពិក និងប្រាក់ឧបត្ថម្ភគ្រូបង្វឹកនិងគ្រូបង្វឹកជំនួយ។
- ជំរុញក្រសួង ស្ថាប័នរដ្ឋ ក្នុងការជ្រើសរើសជនពិការចូលបម្រើការងារតាមអត្រាកំណត់២%។
- ចេញប្រកាសនិងបានផ្សព្វផ្សាយស្តីពីការដាក់ឲ្យប្រើប្រាស់នូវឯកសារណែនាំគោលស្តីពីនីតិវិធីអធិការកិច្ចលើ វិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា ។

## តារាងទី ២.៤៤ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ជនពិការដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ(នាក់) | ១៥៨ | ៤៧៨ | ២០៥ | ១២៣ | ១១៧ | ១ ០៨១ |
| ២ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ(នាក់) | ០ | ០ | ៣ ១៣៣ | ៦ ៦៥៨ | ៨ ៦៥៨ | |
| ៣ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា(នាក់) | ២៥ ៨៨៥ | ២៧ ១៧៥ | ៣០ ២៤៩ | ២៦ ៣២៥ | ២៥ ៤៦៤ | ១៣៥ ០៩៨ |
| ៤ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ(នាក់) | ៣៥ ២៩១ | ៥៣ ៦៧៣ | ២៧ ២៥៤ | ៨២ ៥៩៦ | ៥៦ ១១២ | ២៥៤ ៩២៦ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- ជនពិការ ជាពិសេស ជនពិការក្រីក្រតែងជួបប្រទះការរើសអើងពីសង្គម ព្រមទាំងជួបការលំបាក ទាំងផ្នែកកាយសម្បទា និងហិរញ្ញវត្ថុ ដែលរារាំងពួកគាត់ពីការទទួលយកសេវាសុខាភិបាល និងការអប់រំ ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ កត្តានេះនាំឲ្យជនពិការមិនមានលទ្ធភាពក្នុងការរួមចំណែកក្នុងការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ច ឬទទួលបានអត្ថប្រយោជន៍ពីកត្តាសេដ្ឋកិច្ចទាំងនេះឡើយ។
- យន្តការនៃការកំណត់អត្តសញ្ញាណរបស់ជនពិការនៅមានភាពខ្វះខាតច្រើននៅឡើយ ដែលនាំឲ្យជនពិការមួយចំនួន មិនបានទទួលអត្ថប្រយោជន៍ពីគោលនយោបាយនានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា។
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មភាគច្រើនទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ដូចនេះនៅពេលដែលដៃគូអភិវឌ្ឍបន្ថយ ឬបញ្ឈប់ការគាំទ្រ ធ្វើឲ្យមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជួបបញ្ហាហិរញ្ញវត្ថុ។ គុណភាពនៃការស្តារលទ្ធភាពពលកម្មនៅមានកម្រិត ដែលទាមទារឲ្យមានការពង្រឹងបន្ថែមទាំងលើមន្ត្រីជំនាញក្នុងការពន្លឿនការព្យាបាលជូនជនពិការ ជាមួយនឹងឧបករណ៍បច្ចេកទេសជំនួយសម្រាប់ប្រក្រតីភាពនៃជីវិតជនពិការ។
- ការជ្រើសរើសជនពិការចូលបម្រើការងារ មិនទាន់អនុវត្តបានតាមអត្រាកំណត់សម្រាប់វិស័យឯកជន។ រដ្ឋបាលសិទ្ធិជនពិការដែលជាយន្តការដ៏សំខាន់ក្នុងការរៀបចំបទដ្ឋានគតិយុត្តនីតិវិធី និងគោលការណ៍ណែនាំសម្រាប់អនុវត្តកិច្ចការនេះ កំពុងជួបការលំបាកខ្វះខាតមធ្យោបាយ និងធនធានសម្រាប់បម្រើឲ្យការអនុវត្តកម្មវិធីរបស់ខ្លួន។
- របបឧបត្ថម្ភជនពិការក្រីក្រនៅសហគមន៍ អនុវត្តបានតែ៥ខេត្ត ដោយសារការកំណត់អត្តសញ្ញាណជនពិការក្រីក្រមិនទាន់គ្របដណ្តប់ទូទាំងប្រទេស ដោយកញ្ចប់ថវិកាជាតិ សមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិ ធនធានរួមទាំងបច្ចេកវិទ្យានៅមានកម្រិត
- ការបណ្តុះបណ្តាលជនពិការនៅមិនទាន់បានទូលំទូលាយ។
- ការយល់ដឹង និងលទ្ធភាពទទួលព័ត៌មានអំពីសេវាស្តារលទ្ធភាពពលកម្មកាយសម្បទារបស់ជនពិការនៅមានកម្រិត ទោះបីជាមានការផ្សព្វផ្សាយយ៉ាងណាក៏ដោយ។

### ការងារអាទិភាពទី៤៖ លើកកម្ពស់សុខុមាលភាពមនុស្សចាស់

- រៀបចំផែនការសកម្មភាព ២០១៨-២០២០ របស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់
- សាងសង់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញនិងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០១៨ ទន្ទឹមនេះក្រសួងបានចេញប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់ រាជធានីភ្នំពេញ និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង។
- រៀបចំទិវាមនុស្សចាស់កម្ពុជា និងមនុស្សចាស់អន្តរជាតិ ០១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សចាស់។

- បំផុសលើកទឹកចិត្ត និងគាំទ្រ ដល់អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន ក្នុងការបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ សាងសង់ផ្ទះសម្រាប់មនុស្សចាស់ក្រីក្រគ្មានទីពឹង និងការផ្តល់ថវិកាសម្ភារបរិក្ខារដល់មនុស្សចាស់ក្រីក្រគ្មានទីពឹង។
- ក្រសួងបានបង្កើតសមាគមមនុស្សចាស់ និងកំពុងរៀបចំបង្កើតមូលនិធិមនុស្សចាស់ ដើម្បីបន្តនិរន្តរភាពការគាំពារដល់មនុស្សចាស់។

**តារាងទី ២.៤៥ សមិទ្ធផលស្តីពីការលើកកម្ពស់សុខុមាលភាពមនុស្សចាស់**

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | សមាគមមនុស្សចាស់ត្រូវបានបង្កើត (សមាគម) | ០ | ០ | ៣៩៤ | ១ ២៤២ | ១០ | ១ ៦៤៦ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- ទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវគិតគូ និងយកចិត្តទុកដាក់ ដូចជា ការកើនឡើងនូវចំនួនមនុស្សវ័យចាស់ដែលមានអាយុ៦០ឆ្នាំឡើង។ នៅក្នុងឆ្នាំ២០១៣ មនុស្សវ័យចាស់មាន៨% (ប្រជាជនសរុប១៥លាននាក់) ៧,២% នៅឆ្នាំ២០១៥ (១៥លាន៧សែននាក់) ហើយត្រូវបានព្យាករណ៍ថានឹងកើនឡើងរហូតដល់ ១១% (១៨លាននាក់) នៅឆ្នាំ២០៣០។ តាមប្រព័ន្ធព័ត៌មានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ២០១៦ បានរកឃើញថា មានមនុស្សវ័យចាស់ក្រីក្រសរុបប្រមាណ២៣២ ៣១១ នាក់ នៃចំនួនមនុស្សវ័យចាស់សរុប ក្នុងនោះ មនុស្សវ័យចាស់ស្ថិតក្នុងលំដាប់ក្រ ១ សរុប ៩៨ ១៦៥នាក់ និងមនុស្សវ័យចាស់ស្ថិតក្នុងលំដាប់ក្រ ២ សរុប១៣៤ ១៤៦នាក់។

**រូបភាពទី ២.៥ សមាមាត្រប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប**




*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្គាល់៖ ការព្យាករចំនួនប្រជាជនកម្ពុជារបាយការណ៍ជំរឿនទូទៅនូវប្រជាសាស្ត្រឆ្នាំ២០០៨

២.១៦៥- ពិតមែនតែមនុស្សវ័យចាស់កម្ពុជាមានអាយុកាន់តែវែង ហើយរស់នៅក្នុងជីវិតដែលមានសុខភាពល្អជាងមុនយ៉ាងនេះក្តី មនុស្សវ័យចាស់កម្ពុជាប្រឈមមុខកាន់តែច្រើនទៅនឹងកត្តាផ្នែកសង្គម សេដ្ឋកិច្ច ផលិតភាពចុះទាប ស្ថានភាពសុខភាព គួបផ្សំនឹងការថែទាំកូនៗរបស់មនុស្សពេញវ័យធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើឲ្យរស់នៅជាមួយ។ នៅពេលដែលមនុស្សចាស់មានអាយុកាន់តែច្រើន បញ្ហាដែលពួកគាត់កំពុងប្រឈមមានទំហំកាន់តែធំ។ មនុស្សកាន់តែចាស់ភាពងាយរងគ្រោះរបស់ពួកគាត់ក៏កាន់តែកើនឡើងផងដែរ។ ពួកគាត់អាចជួបនឹងបញ្ហាប្រឈមកាន់តែច្រើនឡើង រួមមានស្ថានភាពសុខភាពទន់ខ្សោយការចុះខ្សោយនៃប្រព័ន្ធការពាររាងកាយពីជំងឺឆ្លងផ្សេងៗ និងមានហានិភ័យកាន់តែខ្ពស់ចំពោះជំងឺមិនឆ្លង ដូចជា ជំងឺទឹកនោមផ្អែម និងសម្ពាធឈាមខ្ពស់ជាដើម។ ទន្ទឹមនឹងនេះ មនុស្សចាស់ក៏ច្រើនតែមានជំងឺធ្ងន់ធ្ងរដល់អាយុជីវិត ដូចជា ជំងឺមហារីក ពិការភាព និងការលែងដំណើរការនៃសរីរាង្គ ដែលទាមទារឱ្យមានការថែទាំរយៈពេលវែង

- ដើម្បីរក្សាបាននូវគុណភាពជីវិតរបស់មនុស្សចាស់ ការធានាបាននូវស្ថិរភាពនៃប្រាក់ចំណូលរបស់ពួកគាត់គឺជាប្រការចាំបាច់។ មនុស្សចាស់ដែលជួបប្រទះអសន្តិសុខហិរញ្ញវត្ថុ និងមិនមានសមត្ថភាពអាចធ្វើការបាន ចាំបាច់ត្រូវស្ថិតក្រោមគម្រោងគាំពារសង្គមនិងសុខុមាលភាព។ នាពេលបច្ចុប្បន្ននេះ វិសាលភាពនៃគម្រោងគាំពារសង្គមនិងសុខុមាលភាពនៅមានកម្រិតនៅឡើយ ហើយចាំបាច់ត្រូវពង្រីកបន្ថែមទៀតដើម្បីការពារមនុស្សចាស់ដែលងាយរងគ្រោះឱ្យគេចផុតពីភាពក្រីក្រ។

### ការងារអាទិភាពទី៥៖ លើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល

- ដើម្បីទ្រទ្រង់ដំណើរការបេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង់វិភាគទានចំនួន១៨% និងមន្ត្រីរាជការស៊ីវិលបង់វិភាគទាន ៦% នៃបៀវត្សសរុបប្រចាំខែ តែចំពោះមុខបច្ចុប្បន្ន រាជរដ្ឋាភិបាលទទួលរ៉ាប់រងនូវចំណែកនៃវិភាគទានជំនួសមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនឹងការទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិលើរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ធ្វើការកែសម្រួលដំឡើងរបបសន្តិសុខសង្គមនេះជាបន្តបន្ទាប់ ដើម្បីឲ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច និងលទ្ធភាពនៃថវិកាជាតិ។
- ប.ជ.ស. បានបង្កើតការិយាល័យថ្នាក់រាជធានី ខេត្ត ដែលជាសេនាធិការក្នុងការអនុវត្តការងារ និងដោះស្រាយបញ្ហានានាផ្ទាល់ជាមួយសិទ្ធិវន្ត។ រាជរដ្ឋាភិបាលបានចេញសារាចរស្តីពីការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍ ដើម្បីធានាប្រសិទ្ធភាពនៃការដាក់ឲ្យចូលនិវត្តន៍ និងទទួលប្រាក់សោធនទាន់ពេលវេលា។
- នៅដើមឆ្នាំ២០១៨ ប.ជ.ស. បានសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.) ដើម្បីផ្តល់គារកាលិកថែទាំសុខភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

ដោយត្រូវបានដាក់ឲ្យទទួលសេវាថែទាំសុខភាពនៅតាមបណ្ដាមូលដ្ឋានសុខាភិបាលដែលមានចុះកិច្ចសន្យាជាមួយ ប.ស.ស. ចាប់ពីខែមករា ឆ្នាំ២០១៨ តទៅ ។

- ក្នុងរយៈពេល៥ឆ្នាំ២០១៤-២០១៨ រាជរដ្ឋាភិបាលបានដំឡើងប្រាក់សោធនជាមធ្យមជូននិវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជារៀងរាល់ឆ្នាំ ដែលមានអត្រាកំណើនប្រមាណ ៤២%។ ដើម្បីធានាដល់ការបើកប្រាក់សោធនបានទាន់ពេលវេលា រាជរដ្ឋាភិបាលបានចេញសារាចរស្ដីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្ដល់ប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន។

### តារាងទី ២.៤៦ សមិទ្ធផលស្ដីពីការលើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១ | និវត្តន៍ជន និងជនបាត់បងសម្បទាវិជ្ជាជីវៈ ដែលទទួលបានរបបសោធននិវត្តន៍(នាក់) | ៤៧ ៣៧៥ | ៤៩ ៧០៩ | ៥២ ០១២ | ៥៣ ៧៨៥ | ៥៦ ៣៥៣ |
| | និវត្តន៍ជន(នាក់) | ៤៤ ៤៦៩ | ៤៦ ៨៥៦ | ៤៩ ៣៩២ | ៥១ ៣៤៥ | ៥៤ ០២៨ |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈ(នាក់) | ២ ៩០៦ | ២ ៨៥៣ | ២ ៦២០ | ២ ៤៤០ | ២ ៣២៥ |
| ២ | អ្នកនៅក្នុងបន្ទុក(នាក់) | ៤២ ០៤៦ | ៣៧ ៧២៨ | ៤០ ៤២៣ | ៤២ ៩២៦ | ៤៤ ០៣៣ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- ប.ជ.ស. នៅជួបបញ្ហាប្រឈមជាច្រើនដែលត្រូវបន្តដោះស្រាយក្នុងក្របខ័ណ្ឌរយៈពេលខ្លី មធ្យមនិងវែងប្រកបដោយភាពទន់ភ្លន់និងការទទួលខុសត្រូវ។ បញ្ហាទាំងនោះរួមមាន *ទី១.* ប្រព័ន្ធសោធនកំពុងប្រឈមជាមួយនឹងបញ្ហាអសង្គតិភាពនៃប្រាក់សោធន រវាងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលចូលនិវត្តន៍មុនឆ្នាំ២០១៥ និងក្រោយឆ្នាំ២០១៥ ដោយសារឥទ្ធិពលដែលកើតចេញពីការដំឡើងប្រាក់សោធនតាមកម្រិត និងការកែប្រែប្រព័ន្ធបៀវត្សរ៍មូលដ្ឋានថ្មី *ទី២.*ការកាលិកចំនួន៣ គឺ គ្រោះថ្នាក់ការងារ លំហែមាតុភាព និងមរណភាពសម្រាប់មន្ត្រីរាជការស៊ីវិលពុំទាន់ត្រូវបានអនុវត្តនៅឡើយ ដែលកន្លងមកអត្ថប្រយោជន៍ទាំងបីនេះផ្ដល់ដោយក្រសួង ស្ថាប័នសាមី *ទី៣.*នៅពុំទាន់មានមូលនិធិសម្រាប់ទ្រទ្រង់ដំណើរការ ប.ជ.ស. ក្រៅពីការឧបត្ថម្ភរបស់រដ្ឋ។
- មកទល់ពេលនេះ រដ្ឋរ៉ាប់រងទាំងស្រុងលើចំណាយបើកផ្ដល់ប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅតាមតម្រូវការនៃចំណាយជាក់ស្ដែងប្រចាំឆ្នាំ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្ដីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលតម្រូវឲ្យមន្ត្រីរាជការស៊ីវិលបង់ភាគទានចំនួន៦% និងរដ្ឋត្រូវចូលរួមបង់ភាគ

ទានចំនួន១៨%។ ប៉ុន្តែការប្រមូលភាគទានតាមអត្រាដែលបានកំណត់រួចនេះមិនទាន់បានអនុវត្តនៅឡើយ។ ដូច្នេះរដ្ឋនៅតែបន្តរ៉ាប់រងទាំងស្រុងលើការឧបត្ថម្ភអតីតមន្ត្រីរាជការស៊ីវិលនិងអ្នកនៅក្នុងបន្ទុក។ គម្រោងដំឡើងបៀវត្សរ៍ប្រចាំឆ្នាំ អាចនឹងគិតគូរពិចារណារួមគ្នាជាមួយនឹងការដាក់ឲ្យអនុវត្តការប្រមូលភាគទាននេះ។

**ការងារអាទិភាពទី៦៖ លើកកម្ពស់វិស័យអតីតយុទ្ធជន**

- ក្រសួងបានយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់អតីតយុទ្ធជន ដោយកែសម្រួលបន្ថែមប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ២០១៤ បានកែសម្រួលបង្កើនប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុក ម្តាយ អាណាព្យាបាលរបស់ជនពលីមរណៈ
- កែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋាន និងប្រាក់ម្ហូបអាហារជូនជនពិការ និវត្តន៍ជន និងជនបាត់បង់សមត្ថភាពការងារ ដែលបានផ្ទេរមកក្រសួងស.អ.យ. មុន និងក្រោយឆ្នាំ២០០៧ ឲ្យមានគុណភាពគ្នា។ ទន្ទឹមនេះអតីតយុទ្ធជននិងគ្រួសារទទួលបានភាពងាយស្រួលតាមរយៈការដាក់ឱ្យដំណើរការការប្រើប្រាស់កាតATM ការផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមជំនួសក្នុងករណីមានជំងឺឬធុរៈធ្ងន់ធ្ងរ នៅតាមរាជធានី ខេត្តទាំង២៥
- អនុវត្តគោលការណ៍ ស្តីពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជារៀបចំប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- រាជរដ្ឋាភិបាលកម្ពុជាបានឧបត្ថម្ភថវិកាចំនួន៤ពាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជាដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាព ចាប់តាំងពីឆ្នាំ២០១៦។
- រៀបចំនិងដាក់ឲ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ ព្រមជាមួយគ្នានេះ បានបង្កើតប្រព័ន្ធទិន្នន័យរក្សាព័ត៌មានស្តីពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជននិងគ្រួសារ។

**តារាងទី ២.៤៧ សមិទ្ធផលស្តីពីការលើកកម្ពស់វិស័យអតីតយុទ្ធជន**

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១ | អតីតយុទ្ធជននិងគ្រួសារដែលកំពុងទទួលរបប (នាក់) | ៨៧ ៤៨៤ | ៨៧ ២៤៨ | ៨៦ ៩៣១ | ៨៦ ៥១៧ | ៨៨ ៥២៦ |
| | *និវត្តន៍ជន(នាក់)* | ២៣ ៨៨៨ | ២៥ ០៧៨ | ២៥ ៦៤៣ | ២៦ ៤៧៩ | ២៧ ១០១ |
| | *ជនបាត់បង់សមត្ថភាពការងារ (នាក់)* | ១ ៦៧៤ | ១ ៦៣៩ | ១ ៦១៨ | ១ ៥៨៣ | ១ ៥៦៤ |
| | *ជនពិការ (នាក់)* | ២៦ ៩៦២ | ២៦ ២៨៦ | ២៥ ៩៧៧ | ២៦ ៥០១ | ២៧ ២០៥ |

| | | | | | | |
|---|---|---|---|---|---|---|
| | *ជនពលី (នាក់)* | ២៩ ៩៤៣ | ២៨ ៥៣៧ | ២៧ ៥៨៧ | ២៥ ៦៤៥ | ២៥ ៧៣២ |
| | *ជនមរណៈ (នាក់)* | ៥ ០១៧ | ៥ ៧០៨ | ៦ ១០៦ | ៦ ៣០៩ | ៦ ៩២៤ |
| ២ | សមាជិកស.អ.ក បានទទួលថវិកាបេឡាមរណសង្គ្រោះ (សព) | ១ ២០០ | ៣ ០៥៥ | ១ ១២៩ | ៨៩៩ | ២ ៦៩៦ |

***ប្រភព :*** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- វិស័យអតីតយុទ្ធជននៅមានបញ្ហាប្រឈមដ៏ធំគឺ គម្លាតប្រាក់របបសន្តិសុខសង្គមប្រចាំខែរវាងអ្នកចូលនិវត្តមុនឆ្នាំ២០១៥ រវាងជនពិការមុនឆ្នាំ២០១៥ និងការកំណត់តាវកាលិកសោធនសម្រាប់មន្ត្រីរាជការ នគរបាល និងយោធិន មិនមានសង្គតិភាពនឹងគ្នាដោយសារការកំណត់តាវកាលិកសោធនទាំងនោះត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិដោយឡែកពីគ្នា។
- ក្រៅពីរបបសន្តិសុខសង្គមដែលផ្តល់ដោយរាជរដ្ឋាភិបាល អតីតយុទ្ធជននិងគ្រួសារ តែងទទួលការឧបត្ថម្ភគាំទ្រពីសមាគមអតីតយុទ្ធជនកម្ពុជា និងសប្បុរសជននានា ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏មិនទាន់បានឆ្លើយតបបាន១០០%។ បេឡាជាតិអតីតយុទ្ធជនមានព័ត៌មានសម្រាប់តែគោលដៅរបបសន្តិសុខសង្គមដែលផ្តល់នូវតាវកាលិកផ្សេងៗដល់អតីតយុទ្ធជននិងគ្រួសារតែប៉ុណ្ណោះ។ ក្រសួងស.អ.យ. មិនទាន់មានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពជីវភាពនិងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដែលជាធាតុចូលយ៉ាងសំខាន់ក្នុងការឆ្លើយតបនឹងការរៀបចំគម្រោងអភិវឌ្ឍនានាដើម្បីលើកកម្ពស់ស្ថានភាពជីវភាពរបស់អតីតយុទ្ធជននិងគ្រួសារឲ្យមានជីវភាពរស់នៅសមរម្យនិងថ្លៃថ្នូរ។
- តម្រូវការសម្បទានដីសង្គមកិច្ចមានច្រើន តែលទ្ធភាពក្នុងការឆ្លើយតបនៅមានកម្រិត។

**ការងារអាទិភាពទី៧៖ បង្កើតរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ**

ក្រសួងបាននិងកំពុងសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់មជ្ឈដ្ឋាននានានិងប្រជាជនទូទៅ។

**ការងារអាទិភាពទី៨៖ ពង្រឹងសមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូ**

- ក្រសួងបានពង្រឹង និងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។
- ចុះអធិការកិច្ច និងសវនកម្ម ដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារការដោះស្រាយជម្លោះ ការអនុវត្តចំណូល ចំណាយថវិកាជាតិ ការគ្រប់គ្រងទ្រព្យ

សម្បត្តិរដ្ឋ នៅតាមមន្ទីរស.អ.យ រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចជូនជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ។

- អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្តការគ្រប់គ្រងការបើកផ្តល់បានត្រឹមត្រូវ និងទាន់ពេលវេលាដល់គ្រប់មុខសញ្ញាក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារ ថវិកា និងបច្ចេកទេស បម្រើឱ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធទាំងក្នុងក្របខ័ណ្ឌតំបន់អាស៊ាន ពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍរួមមាន ផែនការសកម្មភាពថ្នាក់តំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ គោលការណ៍ណែនាំស្តីពីយេនឌ័រក្នុងការដោះស្រាយបញ្ហាស្ត្រីរងគ្រោះក្នុងការជួញដូរមនុស្ស សេចក្តីថ្លែងការណ៍កូឡាឡាំពួរ ស្តីពីមនុស្សចាស់ "ផ្តល់សិទ្ធិអំណាចដល់មនុស្សចាស់នៅក្នុងតំបន់អាស៊ាន" ការអភិវឌ្ឍផែនការសកម្មភាពក្នុងការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម។

**តារាងទី ២.៤៨ សមិទ្ធផលស្តីពីការពង្រឹងសមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូ**

| ល.រ. | សូចនាករ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ (នាក់) | ៥៣ | ៦៩ | ៧៣ | ៥៩ | ១៥៥ | ៤០៩ |
| ២ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ(នាក់) | ២៣២ | ៣០១ | ៣៧៤ | ៤៣៣ | ៥០៣ | |
| ៣ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ (នាក់) | ០ | ០ | ៣៣ | ៨៨ | ២០ | ១៤១ |
| ៤ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ (នាក់) | ៥៣ | ៤៩ | ១៤៣ | ១០៥ | ៩១ | ៤៤១ |

*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**បញ្ហាប្រឈម**

- គ្មានប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមមុខសញ្ញារបស់ក្រសួង ដែលនាំឲ្យការរៀបចំផែនការសកម្មភាពមានភាពចន្លោះប្រហោងមិនបានគ្រប់ជ្រុងជ្រោយ មិនអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង
- ថវិកាដែលបានវិភាជសម្រាប់ក្រសួងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែថវិកាទាំងនោះភាគច្រើន ចំណាយទៅលើសោធន និងបៀវត្សរ៍របស់មន្ត្រី។
- ថវិកាដែលគាំទ្រដល់ការងារអធិការកិច្ច និងសវនកម្មមិនអាចឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង នាំឱ្យការតម្រង់ទិសក្នុងការអនុវត្តរបៀបរបបការងារ គ្រប់គ្រងមន្ត្រីនិងបុគ្គលិក

ការប្រើប្រាស់ថវិកា និងការគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ មិនបានចំគោលដៅត្រឹមត្រូវ និងមិនសូវមានប្រសិទ្ធភាព។

- វិទ្យាស្ថានសង្គមកិច្ចសម្រេចមិនបានតាមគោលដៅមកពី កង្វះមធ្យោបាយធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សិស្សនិស្សិត។ឥរិយាបទរបស់សិស្សមិនសូវឲ្យតម្លៃលើមុខជំនាញសង្គមកិច្ចដែលវិទ្យាស្ថានកំពុងបណ្តុះបណ្តាល ហើយកិត្តិសព្ទរបស់វិទ្យាស្ថានជាតិសង្គមកិច្ចនៅមិនទាន់ទទួលបានការទទួលស្គាល់និងគាំទ្រពីសិស្ស និស្សិត និងអាណាព្យាបាល ។

**រូបភាពទី ២.៦ ថវិការដ្ឋដែលបានវិភាជរយៈពេល ៥ឆ្នាំ២០១៤-២០១៨**

(លានរៀល)




*ប្រភព :* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ៧.៤- ពង្រឹងការអនុវត្តគោលនយោបាយប្រជាជននិងសមភាពយេនឌ័រគោលនយោបាយប្រជាជន

២.១៦៦- ក្នុងអាណត្តិនៃ ផ.យ.អ.ជ. ២០១៤-២០១៨ អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍនៃក្រសួងផែនការ បានសម្របសម្រួល និងសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រេចបានសមិទ្ធផលសំខាន់ៗ មួយចំនួន ដូចខាងក្រោម៖

- រៀបចំគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ និងត្រូវបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី និង បានផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដល់មន្ត្រីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ និងសិស្សនិស្សិតតាមសកលវិទ្យាល័យនានា។
- រៀបចំផែនការសកម្មភាពដំណាក់កាលទីមួយ ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍វឌ្ឍនភាពនៃផែនការសកម្មភាព ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។
- រៀបចំនិងកំពុងដាក់ឲ្យអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ ២០១៩-២០២១។

- រៀបចំសៀវភៅបណ្ដុះបណ្ដាលស្ដីអំពីគោលនយោបាយជាតិប្រជាជននិងប្រជាសាស្ត្រ ម៉ូឌុល១ ហើយបានបណ្ដុះបណ្ដាលដល់មន្ត្រីមន្ទីរផែនការទូទាំង២៥ រាជធានីខេត្ត។

២.១៦៧- **បញ្ហាប្រឈម**

- សមត្ថភាពស្ថាប័ននៅមានកម្រិតក្នុងការដាក់បញ្ចូលបញ្ហាប្រជាជននិងឌីណាមិកប្រជាសាស្ត្រ ទៅក្នុងផែនការអភិវឌ្ឍតាមវិស័យ។
- ការយល់ដឹងអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍនៅមានកម្រិតទាំងនៅថ្នាក់ជាតិ និងទាំងនៅថ្នាក់ក្រោមជាតិ។
- ការសិក្សាស្រាវជ្រាវអំពីទំនាក់ទំនងបញ្ហាប្រជាជនជាមួយគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជានៅមានកម្រិត។
- ធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ដើម្បីបន្តអនុវត្តផែនការសកម្មភាពនៃគោលនយោបាយជាតិប្រជាជននៅមានកម្រិត។

## សមភាពយេនឌ័រ

២.១៦៨- រយៈពេល៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ជាអតិបរិមាទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីលើគ្រប់វិស័យ និងគ្រប់កម្រិត ជាពិសេសតាមរយៈការបញ្ជ្រាបយ៉ាងស៊ីជម្រៅទៅក្នុង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** ដោយបានបញ្ចូលនូវសូចនាករជាក់លាក់ សម្រាប់តាមដានការអនុវត្ត។ កិច្ចសហការ ភាពជាដៃគូ និងការគាំទ្រ ពីក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បានរួមចំណែកធ្វើឱ្យសមភាពយេនឌ័រឆ្លើយតបនៅក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់សំខាន់ៗ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ គ្រប់ក្រសួង ស្ថាប័ន តាមវិស័យបានបង្កើត និងធ្វើបច្ចុប្បន្នភាព។ ក្រសួង ស្ថាប័នចំនួន២៨ បានទទួលថវិកាជាតិ និងថវិកាដៃគូសម្រាប់ការអនុវត្តការងារយេនឌ័រតាមវិស័យរបស់ខ្លួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់បង្កើនភាពអង់អាចដល់ស្ត្រី និងគាំពារលើបញ្ហាអាទិភាពសំខាន់ៗដូចខាងក្រោម៖។

### ១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

២.១៦៩- របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចបានបង្ហាញថា អត្រាស្ត្រីដែលធ្វើការងារមានប្រាក់កម្រៃក្នុងវិស័យចម្បងៗ ដូចជាវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម មានភាពរីកចម្រើនទោះបីជាអត្រានោះមិនទាន់សម្រេចបានដល់ចំណុចដៅដែលបានកំណត់៥០%ក៏ដោយ។

២.១៧០- តួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ត្រូវបានលើកកម្ពស់ តាមរយៈ កម្មវិធីគាំពារសង្គម អប់រំ បណ្ដុះបណ្ដាលបច្ចេកទេស វិជ្ជាជីវៈ អភិវឌ្ឍន៍កសិកម្ម និងជនបទ អភិវឌ្ឍន៍សហគ្រិន កំណែទម្រង់ដីធ្លីជាដើម។ កិច្ចខិតខំប្រឹងប្រែងក្នុងការផ្ដល់ឱកាសផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅក្នុងខេត្តចំនួន១៤ សមាគមសហគ្រិនស្ត្រីកម្ពុជា និងសហព័ន្ធស្ត្រីអ្នកជំនួញកម្ពុជា កំពុងដំណើរការក្នុងការជួយអភិវឌ្ឍន៍មុខរបរ រកទីផ្សារលក់ផលិតផល លើកកម្ពស់សហគ្រិនភាព ភាពជាអ្នកដឹកនាំ ព្រមទាំងពង្រឹងសម្លេងស្ត្រី សហគ្រិននៅក្នុងវិស័យសេដ្ឋកិច្ច។ សហគ្រិនស្ត្រីកម្ពុជាចំនួន៣៨នាក់ ទទួលបានពានរង្វាន់សហគ្រិន ស្ត្រីឆ្នើមអាស៊ាន ។

ទោះបីជាមានការប្រឹងប្រែងជាច្រើន ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ស្ត្រីភាគច្រើនកំពុងធ្វើការងារក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងឧស្សាហកម្មដែលផ្ដល់ប្រាក់ចំណូលទាប។
- សមត្ថភាព ជំនាញ និងលទ្ធភាពទទួលឱកាសគ្រប់គ្រងធនធាន (ពេលវេលា ព័ត៌មានបច្ចេកវិទ្យារបស់ស្ត្រីនៅមានកម្រិត ។
- ផលិតផលរបស់ស្ត្រីនៅមិនទាន់ឆ្លើយតបទីផ្សារក្នុងនិងក្រៅស្រុក។

## ២. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ស្ត្រីពិការ និងក្រុមជនងាយរងគ្រោះ

២.១៧១- ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤ បានបង្ហាញថា សមាមាត្រស្ត្រី និងក្មេងស្រី ដែលមានអាយុ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូបច្ចុប្បន្ន ឬអតីត ក្នុងរយៈពេល១២ខែចុងក្រោយមាន ៣០,៨%។

- សមាមាត្ររបស់ស្ត្រីអាយុពី២០-២៤ឆ្នាំ ដែលបានរៀបការឬរស់នៅជាមួយគ្នាមុនអាយុ១៨ឆ្នាំមាន ១,៩%។
- ក្រុមការងារកម្ពុជាប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) និងបានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍រួមលើកទី៣ ស្ដីពីការប្ដេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សត្រូវបានបង្កើត និងដឹកនាំដោយក្រសួងកិច្ចការនារី។
- មន្ត្រីពិការរបស់ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធត្រូវបានបណ្ដុះបណ្ដាលនិងអភិវឌ្ឍសមត្ថភាពស្ដីពីការលើកកម្ពស់កិច្ចការពារជនពិការឆ្លើយតបនឹងយេនឌ័រ និងច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការកម្រិតជាតិ និងអន្តរជាតិ ។

## ៣. ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ

### ៣.១. ស្ត្រីក្នុងអង្គនីតិបញ្ញត្តិ

២.១៧២- ស្ត្រីជាសមាជិកអង្គនីតិបញ្ញត្តិមានការកើនឡើងបន្តបន្ទាប់ពីមួយអាណត្តិទៅមួយអាណត្តិ។ ឆ្នាំ១៩៩៣ សមាជិករដ្ឋសភាជាស្ត្រីមាន៥% ឆ្នាំ ២០១៨ កើនដល់២០%។ ឆ្នាំ១៩៩៩ មានចំនួនស្ត្រីជាសមាជិកព្រឹទ្ធសភា១៤% ឆ្នាំ២០១៨ មានការកើនឡើងដល់១៩,៣៥%។

### ៣.២. ស្ត្រីជាសមាជិករាជរដ្ឋាភិបាល

២.១៧៣- ឆ្នាំ១៩៩៣ មិនមានស្ត្រីជារដ្ឋមន្ត្រី និងរដ្ឋលេខាធិការទេ គឺមានតែអនុរដ្ឋលេខាធិការចំនួន០២រូប។ ឆ្នាំ២០១៨ មានឧបនាយករដ្ឋមន្ត្រីជាស្ត្រី(១រូប) ស្មើ១០% រដ្ឋមន្ត្រីជាស្ត្រី(៣រូប) ស្មើ១០,៣៤% រដ្ឋលេខាធិការ(៤៥រូប)ស្មើ១៨% និងអនុរដ្ឋលេខាធិការ(៦៩រូប) ស្មើ១៥,៣៣%។

### ៣.៣. ស្ត្រីក្នុងរដ្ឋបាលសាធារណៈ

២.១៧៤- ក្នុងវិស័យមុខងារសាធារណៈចំនួនស្ត្រី មានការកើនឡើងជាលំដាប់ ពី ៣៥% នៅឆ្នាំ២០១២ ដល់៤១% នៅឆ្នាំ២០១៧។ លទ្ធផលនេះទទួលបាន ផ្អែកតាមការអនុវត្តសេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈ ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មី(ស្ត្រីចំនួនពី២០% ទៅ ៥០%) និងព្រះរាជក្រឹត្យ ស្តីពីការពន្យាអាយុនៃការចូលនិវត្តន៍របស់មន្ត្រីរាជការស្ត្រីដល់អាយុ ៦០ឆ្នាំ និងផ្អែកតាមការស្ម័គ្រចិត្ត។

### ៣.៤. ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិ

២.១៧៥- ស្ត្រីជាអភិបាល ខេត្ត ៤% អភិបាលរងរាជធានីខេត្ត២៦រូប ស្មើ១៧,៣៣% អភិបាល ក្រុង ស្រុក ខណ្ឌចំនួន៧រូប ស្មើនឹង៣,៥៥% អភិបាលរង ក្រុង ស្រុក ខណ្ឌចំនួន១៨៥ រូប ស្មើ២៦%ស្ត្រីជា ចៅសង្កាត់/មេឃុំ មានការកើនឡើងពី៤២រូបក្នុងឆ្នាំ២០០២ ដល់១៣០រូបក្នុងឆ្នាំ២០១៨ ស្ត្រីជាស្មៀនឃុំ សង្កាត់២៣៩រូប ។

## ៤. យេនឌ័រ និងសុខភាព

២.១៧៦- លទ្ធផលនៃការអង្កេតសុខភាពនិងប្រជាសាស្ត្រឆ្នាំ២០១៤ របាយការណ៍សមិទ្ធផលសុខាភិបាល ឆ្នាំ២០១៦ បានបង្ហាញដូចខាងក្រោម៖

- អត្រាមរណៈភាពមាតា អត្រាមរណៈភាពកុមារក្រោមអាយុ០១ឆ្នាំ និង អត្រាមរណៈភាពកុមារក្រោមអាយុ៥ឆ្នាំ មានការថយចុះ។
- ភាគរយស្ត្រីទៅពិនិត្យផ្ទៃពោះយ៉ាងតិច ២ដង មានការកើងឡើងជាលំដាប់ ។

ទោះបីជាសម្រេចបានលទ្ធផលដូចខាងលើ ក៏បញ្ហាសុខភាពស្ត្រី និងក្មេងស្រីនៅតែត្រូវការយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសនៅតំបន់ដាច់ស្រយាល ការពង្រីកព័ត៌មានអំពីសារៈសំខាន់នៃសុខភាព អនាម័យ និងអាហារូបត្ថម្ភ សម្រាប់ស្ត្រី និងកុមារ ជាដើម។

## ៥. លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ រួមទាំងស្ត្រី និងការអប់រំ

២.១៧៧- គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សហការជាមួយអង្គភាពពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់អាជ្ញាធរ មានសមត្ថកិច្ច សង្គមស៊ីវិល ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ បានរួមគ្នាអនុវត្តសកម្មភាពយុទ្ធសាស្ត្រពហុវិស័យ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ។ គណៈកម្មាធិការជាតិក៏បានរៀបចំវេទិកាយុវវ័យជជែកពិភាក្សា និងផ្សព្វ ផ្សាយតាមប្រព័ន្ធទូរទស្សន៍ជាតិកម្ពុជា លើការងារសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងគោលបំណងថែរក្សាវប្បធម៌ជាតិ ធានាដល់ការគោរពសីលធម៌សង្គម។ ក្រុមការងារអន្តរក្រសួងបានអនុម័តជាផ្លូវការ និងអនុវត្ត**យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ឆ្នាំ២០១៧-២០២១** ដោយឆ្លើយតបផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ។ គម្លាតយេនឌ័រ នៅក្នុងវិស័យអប់រំ បានកាត់បន្ថយនៅគ្រប់កម្រិត តាមរយៈការបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ជាពិសេសនារី ការបង្កើនចំនួនគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ការបង្កើនចំនួនអន្តេវាសិកដ្ឋានដែលផ្តល់សេវាសមរម្យ និងសុវត្ថិភាពសម្រាប់សិស្ស និងនិស្សិតនារី។ ប្រធានបទសមភាពយេនឌ័រនិងបរិយាប័ន្ន រួមទាំងការដាក់បញ្ចូលប្រធានបទយេនឌ័រ សូចនាករសំខាន់ៗត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា។

ជាមួយគ្នានេះ ក្រសួងកិច្ចការនារី បានចូលរួមចំណែកបង្កើតថ្នាក់អក្ខរកម្មសម្រាប់កម្មករកម្មការិនីរោងចក្រស្នាក់នៅតាមផ្ទះសរុបចំនួន១ ៩២៦នាក់(ស្រី១៥៥៩នាក់) និងបំផុសចលនាសហគមន៍ក្នុងការរៀបចំ ដំណើរការមត្តេយ្យសិក្សាសហគមន៍ នៅខេត្តគោលដៅចំនួន១២។

**បញ្ហាប្រឈម**

- ការយល់ដឹងរបស់ឪពុកម្តាយពីសារៈសំខាន់ នៃការសិក្សារបស់កូនស្រីនៅមានកម្រិត ជាពិសេសនៅតំបន់ដាច់ស្រយាល។
- ការចូលរួមរបស់ស្ត្រី ក្មេងស្រី ក្នុងវិស័យអប់រំ ដូចជា ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាស្តែម នៅមានកម្រិត ។។

## ៦. យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍបៃតង

ផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍបៃតង បានរៀបចំ និងដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងបានរៀបចំផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៣-២០២២។

យន្តការសម្របសម្រួលការងារយេនឌ័រនិងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារីសហការជាមួយក្រសួងពាក់ព័ន្ធ។

# ជំពូកទី៣

# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

# សម្រាប់

# ផ.យ.អ.ជ. ២០១៩-២០២៣

# ជំពូកទី៣

# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

## ៣.១ សេចក្តីផ្តើម

៣.១ ជំពូកនេះ បង្ហាញនូវការវិភាគពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងការកំណត់នូវគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និងហិរញ្ញវត្ថុ ដែលនឹងត្រូវបានអនុម័តនៅក្នុងអំឡុងពេលនៃអាណត្តិកាលរបស់ **ផ.យ.អ.ជ. ២០១៩-២០២៣**។ ការវិភាគនេះ ចាប់ផ្តើមពីការពិនិត្យមើលឡើងវិញនូវការអនុវត្តផែនការក្នុងរយៈពេល៥ឆ្នាំកន្លងទៅ លើកឡើងពីសមិទ្ធផលសំខាន់ៗនិងបញ្ហាប្រឈមនានាដែលបានជួបប្រទះនៅក្នុងអំឡុងពេលនៃការអនុវត្តផែនការនោះ។ ការវិភាគនេះរួមបញ្ចូលទាំងការពិភាក្សាស៊ីជម្រៅលើកម្រិតថាមវន្តសេដ្ឋកិច្ច (ឌីណាមិច) និងបរិការណ៍ដ៏ធំទូលាយនៃសង្គមសេដ្ឋកិច្ច។ ចំណុចទី២ នៃជំពូកនេះ គូសបញ្ជាក់ពីចំណុចដៅនានាដែលត្រូវបានកំណត់ដោយ**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** និងកំណត់នូវយុទ្ធសាស្ត្រដែលផ្តល់ឲ្យដឹងនូវបណ្តាគោលនយោបាយ និងសកម្មភាព នៅក្នុងជំពូកទី៤។ បន្ថែមលើនេះទៀត ផ្នែកនេះនឹងគូសបញ្ជាក់ពីការផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ ក្នុងការគោរពនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (រួមទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ)។ ចំណុចទី៣ ផ្តល់នូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនៅពេលអនាគត គូសបញ្ជាក់ពីផលប៉ះពាល់ដែលអាចមានរបស់ជំហរគោលនយោបាយធំៗ ដែលបានគ្រោងទុក និងអនុវត្តចំពោះការវិនិយោគនិងកម្រិតចំណាយសាធារណៈ។

៣.២ ជាទូទៅ ការវិភាគក្នុងជំពូកនេះ បង្ហាញពីភាពរឹងមាំនិងថាមភាពនៃសេដ្ឋកិច្ច ទោះបីជាមានឧបសគ្គព្យុះបក់បោកក្តី ក៏នៅតែកំណត់ជាទូទៅបាននូវកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ប្រចាំឆ្នាំនៅក្នុងតំបន់ប្រមាណ៧% ខណៈពេលដែលអាចរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងប្រទេស។ ប៉ុន្តែ ការវិភាគបន្ថែមទៀត បញ្ជាក់ពីសារសំខាន់នៃការដោះស្រាយបញ្ហាផលិតភាព និងបញ្ហាប្រកួតប្រជែង ដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅប្រទេស ដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងរយៈពេលមធ្យម។

## ៣.២ សមិទ្ធផល ឆ្នាំ២០១៤-២០១៨

៣.៣ ជំពូកនេះ ចែកចេញជាពីរផ្នែក។ ផ្នែកទី១ ផ្តល់នូវវិធីសាស្ត្រស្តង់ដាបីផ្នែកដែល ពិនិត្យមើលឡើងវិញនូវការអនុវត្តម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ វិធីសាស្ត្រនេះពិភាក្សាពី *ទី១* ធាតុចេញនិងកំណើនសេដ្ឋកិច្ច តុល្យភាពផ្ទៃក្នុង(អតិផរណានិងឱនភាពថវិកា) និងស្ថានភាពខាងក្រៅ(ជញ្ជីងទូទាត់)។ *ទី២* ពិនិត្យមើលឡើងវិញពីផលប៉ះពាល់ដល់សង្គមសេដ្ឋកិច្ច និងវឌ្ឍនភាពលើការពិចារណាលើរចនាសម្ព័ន្ធសំខាន់ៗ ដែលនឹងកំណត់លទ្ធផលនៃសេដ្ឋកិច្ចពិតប្រាកដនៅក្នុងរយៈពេលវែង។

### ចំហាក (សេណារីយ៉ូ) ម៉ាក្រូសេដ្ឋកិច្ច

### ធាតុចេញ និងការវិនិយោគ

៣.៤ សម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ន និងសមធម៌។ កម្ពុជាថែមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីឋានៈប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានចាត់ទុកថាជា **"ខ្លាថ្មីនៅអាស៊ី"** ក្នុងឆ្នាំ២០១៦។ ដូចបង្ហាញក្នុងរូបភាព ៣.១ កំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំ ៧,១% នៅក្នុងរយៈពេល៥ឆ្នាំនៃផែនការ(ទិន្នន័យឆ្នាំ២០១៨ ជាទិន្នន័យប៉ាន់ស្មាន)។ កំណើន ដ៏គួរឲ្យស្ញើចសរសើរនេះ បានបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋទូទាំងប្រទេសដែលឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារពិភពលោកដែលបានបង្ហាញថា ភាពអត់ការងារនៅប្រទេសកម្ពុជាស្ថិតក្នុងអត្រា0,៣% និងភាពក្រីក្រធ្ងន់ធ្ងរត្រូវបានលុបបំបាត់ទាំងស្រុងក្នុងឆ្នាំ២០១៧។ ទន្ទឹមនេះ ប្រាក់ចំណូលរបស់ប្រជាជនក៏មានការកើនឡើងផងដែរ ដោយ ផ.ស.ស. ក្នុងមនុស្សម្នាក់កើនពី១ ០៣៨ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ១ ៤២៩ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង ១ ៥៤៨ ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨(ប៉ាន់ស្មាន)។

## រូបភាពទី ៣.១ កំណើន ផ.ស.ស. ២០១៤-២០១៨




*ប្រភព៖* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ

**៣.៥** កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ មានការប្រែប្រួលគួរឲ្យកត់សម្គាល់(រូបភាព ៣.២)។ វិស័យឧស្សាហកម្មនិងសេវាកម្ម បានបន្តរក្សាកំណើនល្អប្រសើរទោះបីវិស័យកសិកម្មនៅទទួលបានកំណើនយឺត។ សម្រាប់វិស័យឧស្សាហកម្ម អនុវិស័យសំណង់ អចលនទ្រព្យ និងឧស្សាហកម្មផ្សេងទៀតមានការកើនឡើងខ្លាំងគួរឲ្យកត់សម្គាល់ ខណៈដែលវិស័យកាត់ដេរនៅរក្សាបានកំណើនល្អប្រសើរ ដែលអាចសម្រេចបានកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧,៨% ក្នុងចន្លោះឆ្នាំ២០១៤ ដល់ ២០១៨។ ក្នុងឆ្នាំ២០១៩ វិញ វិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនថមថយបន្តិចមកត្រឹមប្រមាណ៧,១% ដោយសារស្ថានភាពមិនប្រាកដប្រជារបស់សេដ្ឋកិច្ចពិភពលោក ជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាដែលមានកំណើនថមថយជាងការរំពឹងទុក។ ចំណែកវិស័យកសិកម្ម(អនុវិស័យដំណាំនិងអនុវិស័យកសិកម្មផ្សេងទៀត) បន្តសម្រេចបានកំណើនយឺតក្នុងរង្វង់១,៧% ក្នុងមួយឆ្នាំ។

**៣.៦** ការប្រែប្រួលទាំងនេះ បានធ្វើឲ្យការរួមចំណែកតាមវិស័យ ក្នុងកំណើនសេដ្ឋកិច្ចទាំងមូលមានការផ្លាស់ប្តូរ។ ជាការកត់សម្គាល់ វិស័យសំណង់បានក្លាយជាក្បាលម៉ាស៊ីនជំរុញកំណើនធំជាងគេដែលបានរួមចំណែកប្រមាណជា១,៦% ក្នុងកំណើនសេដ្ឋកិច្ចជាតិសរុប ក្នុងឆ្នាំ២០១៨ ស្របពេលដែលវិស័យកាត់ដេរបានរួមចំណែក១,៨% និងឧស្សាហកម្មផ្សេងទៀត មានចំនួនប្រមាណ០,៧% នៃកំណើនប្រចាំឆ្នាំ៧,៥%។

**៣.៧** និន្នាការវិនិយោគ ក៏មានការប្រែប្រួលជាវិជ្ជមាន(រូបភាព ៣.៣) ដែលការវិនិយោគសរុប

មានចំនួនប្រមាណ៣០% នៃ ផ.ស.ស. ក្នុងរយៈពេលនៃផែនការទាំងមូល។ ជារួមការវិនិយោគមានការកើនឡើងជាមធ្យមប្រមាណ១១,៨% ក្នុងមួយឆ្នាំ ខ្ពស់ជាងកំណើនរបស់ផ.ស.ស. ថ្លៃបច្ចុប្បន្ន។ ទោះជាដូចនេះក្តី សមាសភាគមានការប្រែប្រួល។ ជាទូទៅ ការវិនិយោគឯកជនដោយការផ្តល់ហិរញ្ញប្បទានពីបរទេស មានការកើនឡើងពី១០,៦% នៃផ.ស.ស. ក្នុងឆ្នាំ២០១៤ ទៅ១២,២% នៃផ.ស.ស. ក្នុងឆ្នាំ២០១៨ (ប៉ាន់ស្មាន)។ ចំណែកការវិនិយោគឯកជន ដោយការផ្តល់ហិរញ្ញប្បទានពីក្នុងស្រុករក្សានៅស្ថេរភាពក្នុងកម្រិត១១%។ ទន្ទឹមនេះការវិនិយោគសាធារណៈដោយប្រើប្រាស់ហិរញ្ញប្បទានពីបរទេសមានការថមថយពី៦,៣% ក្នុងឆ្នាំ២០១៤ មកនៅ៥,៧% ក្នុងឆ្នាំ២០១៨ ហើយការវិនិយោគសាធារណៈ ដោយការផ្តល់ហិរញ្ញប្បទានពីក្នុងស្រុកមានការកើនឡើងពី ២,១% ក្នុងឆ្នាំ២០១៤ ទៅ ២,៩% ក្នុងឆ្នាំ២០១៨ (ប៉ាន់ស្មាន)។

### រូបភាពទី ៣.២ ការវិនិយោគធៀបនឹង ផ.ស.ស. តាមប្រភេទនៃការវិនិយោគ




*ប្រភព៖* ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៤-២០១៨

៣.៨ នៅក្នុងរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា កម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧,១% ជាមធ្យម និងស្ថិរភាពអត្រាអតិផរណាក្នុងរង្វង់៣% ក្នុងមួយឆ្នាំ និងបានក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។ ក្នុងបរិការណ៍នៃភាពល្អប្រសើរ និងលូតលាស់របស់សេដ្ឋកិច្ចជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រយ័ត្នប្រយែងក៏ទទួលបានលទ្ធផលគួរជាទីមោទនៈ ដោយសារឱនភាពថវិកាទូទៅត្រូវបានរក្សាឲ្យនៅក្រោម៥%នៃផ.ស.ស។ ក្នុងនោះ តាមរយៈការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ការប្រមូលចំណូល

ក្នុងស្រុក[1] សរុបទទួលបានវឌ្ឍនភាពលើសពីការរំពឹងទុក ដោយការប្រមូលចំណូលចរន្តសម្រេចបានកំណើនជាមធ្យម១,៣ ពិន្ទុភាគរយនៃផ.ស.ស ក្នុងឆ្នាំ២០១៤-២០១៨ ខណៈដែលរាជរដ្ឋាភិបាលអនុលោមតាមវិន័យថវិកាជារួមបានយ៉ាងខ្ជាប់ខ្ជួន។ ទន្ទឹមនេះ តាមរយៈយុទ្ធសាស្ត្រនៃការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ ការគ្រប់គ្រងបំណុលសាធារណៈ ក៏រក្សាបានស្ថិរភាព ពោលគឺស្ថិតក្នុងរង្វង់៣០% នៃផ.ស.ស តែប៉ុណ្ណោះ។

## រូបភាពទី ៣.៣ ៖ តុល្យភាពថវិកាឆ្នាំ ២០១៤-២០១៨




*ប្រភព៖* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**៣.៩.** រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ប្រកបដោយផ្លែផ្កា និងជោគជ័យខ្ពស់ ដោយចំណូលចរន្តកើនឡើងជាមធ្យម១,៣ ពិន្ទុភាគរយនៃផ.ស.ស ក្នុងមួយឆ្នាំ(កំណើនជាមធ្យម១៨% ក្នុងមួយឆ្នាំ) ដែលខ្ពស់ជាងពីរដងធៀបនឹងគោលដៅ០,៥ ពិន្ទុភាគរយនៃផ.ស.ស។ ក្នុងរយៈពេល៥ឆ្នាំនេះ ចំណូលចរន្តបានកើនឡើងពី១៥,០%នៃផ.ស.ស នៅឆ្នាំ២០១៣ ដល់២២,២% នៃផ.ស.ស នៅឆ្នាំ២០១៨ (ប៉ាន់ស្មាន)[2]។ កំណើនចំណូលចរន្តលើសគោលដៅនេះបណ្តាលមកពីកំណើនរឹងមាំនៃចំណូលពន្ធក្នុងប្រទេស(ប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) ដែលគាំទ្រដោយកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ការកើនឡើងអនុលោមភាពបង់ពន្ធ និងកិច្ចខិតខំប្រឹងប្រែង ក៏ដូចជាការពង្រឹងការគ្រប់គ្រងរបស់រដ្ឋបាលប្រមូលចំណូលជារួម។ ការសម្រេចបាននូវការប្រមូលចំណូលដ៏ខ្លាំងក្លានេះ បានធ្វើឲ្យចំណូលថវិកាជាតិកម្ពុជាដែលធ្លាប់តែទាបជាងគេក្នុង

---

[1] ចំណូលក្នុងស្រុកសរុប សមមូលចំណូលចរន្ត បូកចំណូលមូលធនក្នុងស្រុក ។ ចំណូលចរន្តមានចំណែកជាង ៩៩%នៃចំណូលក្នុងស្រុកសរុប ។

2 ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩ ។

តំបន់ ខិតមកជិតកម្រិតកណ្តាលវិញ និងបានជំរុញឲ្យមជ្ឈដ្ឋានអន្តរជាតិកោតសរសើរពីកិច្ចកែទម្រង់ប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ។

៣.១០. បរិបទនៃទិដ្ឋភាពចំណូលនេះ បានផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលបង្កើនចំណាយសាធារណៈសម្រាប់បន្តកិច្ចការកែទម្រង់ធំ[3] បង្កើនកិច្ចអន្តរាគមន៍ដោះស្រាយបរាជ័យទីផ្សារ លើកកម្ពស់គុណភាព និងពង្រីកវិសាលភាពសេវាសាធារណៈឲ្យកាន់តែខិតជិតប្រជាពលរដ្ឋ ព្រមទាំងបង្កើនការវិនិយោគលើវិស័យ អាទិភាពសំខាន់ៗ ដូចជាវិស័យអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ។ល។ សំដៅគាំពារផលិតភាព និងភាពប្រកួតប្រជែងសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងក្នុងឆ្នាំ២០១៣-២០១៨ រាជរដ្ឋាភិបាលបានបង្កើនចំណាយសរុបជិត២ដង និងវិភាជប្រកបដោយសនិទានកម្មលើវិស័យនិងក្រសួងអាទិភាពនានា ដូចជា ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាង៣ដង, ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើនជិត៣ដង និងចំណាយសរុបរបស់ក្រសួងសុខាភិបាលត្រូវបានបង្កើនជិត២ដងកន្លះ។ លើសពីនេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសំដៅបង្កើនប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តថវិកា ជាពិសេសគឺការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយអាទិភាពដែលបានដាក់ចេញ។

**រូបភាពទី ៣.៤ ចំណាយចរន្ត និងចំណាយមូលធន**




*ប្រភព៖* ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣.១១. ស្ថិតក្នុងបរិការណ៍បច្ចុប្បន្ន បំណុលក្រៅប្រទេសនៅតែមានតួនាទីសំខាន់ក្នុងអំឡុងពេលនៃវដ្តផែនការអភិវឌ្ឍនេះ។ ក្នុងឆ្នាំ២០១៤ អនុបាតបំណុលរបស់ជាតិធៀបនឹងផ.ស.ស មានកម្រិត៣១,៥% ធៀបនឹងការនាំចេញ មានកម្រិត៦៤,៤% និងអនុបាតសេវាបំណុលរបស់

[3] កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

ជាតិធៀបនឹងការនាំចេញមានកម្រិត១,៥%។ ខណៈដែលឆ្នាំ២០១៨ បំណុលជាតិធៀបនឹងផ.ស.ស និងបំណុលជាតិធៀបនឹងការនាំចេញមានកម្រិត២៩% និង ៥៤,២% រៀងគ្នា ហើយដែលសេវាបំណុលជាតិធៀបនឹងការនាំចេញបានកើនឡើងបន្តិចដល់២%ពី១,៥% ក្នុងឆ្នាំ២០១៤(តារាង ៣.១)។ កម្ចីត្រូវបានធ្វើឡើងយ៉ាងប្រុងប្រយ័ត្នស្របតាមបរិបទសេដ្ឋកិច្ច និងគោលការណ៍ទាំង៤ របស់រាជរដ្ឋាភិបាល *១.* ខ្ចីត្រឹមកម្រិតចំនួនដែលថវិការដ្ឋអាចគាំទ្រ *២.* ខ្ចីតាមតែអាចធ្វើទៅបាន នៅអត្រានៃលក្ខខណ្ឌសម្បទានខ្ពស់ ដែលក្នុងនោះកម្ចីភាគច្រើនពីធនាគារអភិវឌ្ឍ និងទ្វេភាគីពីរដ្ឋាភិបាលដទៃទៀត *៣.* ខ្ចីសម្រាប់តែវិស័យអាទិភាព និងដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និង *៤.* ប្រាក់កម្ចីត្រូវតែប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

## តារាងទី ៣.១ អនុបាតកម្រិតស្ថិរភាពបំណុល (គិតជាភាគរយ)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| អនុបាតបំណុលធៀបនឹងផ.ស.ស. | ៣១,៥ | ៣១,១ | ២៩,១ | ៣០,៣ | ២៩,០ |
| អនុបាតបំណុលធៀបនឹងការនាំចេញ * | ៦៤,៤ | ៦០,៨ | ៥៧,១ | ៥៩,៩ | ៥៤,២ |
| អនុបាតសេវាបំណុលធៀបនឹងការនាំចេញ * | ១,៥ | ១,៥ | ១,៨ | ២,៤ | ២,០ |

*ការនាំចេញទំនិញ

*ប្រភព៖* ធនាគារជាតិនៃកម្ពុជា

**៣.១២.** រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលជោគជ័យក្នុងការ រក្សាបាននូវអតិផរណាក្នុងកម្រិតអាចគ្រប់គ្រងបាន ជាមធ្យមប្រចាំឆ្នាំប្រមាណ៣% (ក្នុងរូបភាព ៣.៥ ដែលពិពណ៌នាពីអតិផរណា និងស៊េរីនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់)។ ទោះជាដូចនេះក្ដី ក៏នៅមានការប្រែប្រួលខ្លះ នៅក្នុងអតិផរណា ដែលបណ្ដាលមកពីលក្ខណៈនៃសេដ្ឋកិច្ចបើកចំហខ្ពស់ និងឥទ្ធិពលពីរបស់វាលើអតិផរណាសាកលនិងសម្ពាធអតិផរណា។ ស្របពេលដែលតម្លៃរបស់ទំនិញមានការកើនឡើង ជាទូទៅការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក បានផ្ដល់នូវការកាត់បន្ថយដ៏មានប្រសិទ្ធភាពនូវសន្ទុះនៃការកើនឡើងនៃថ្លៃទំនិញ។

## រូបភាពទី ៣.៥ សម្ពាធអតិផរណា ២០១៤-២០១៨




*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣.១៣ ទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជា បង្ហាញថា កំណើនរូបិយវត្ថុ មានស្ថិរភាពក្នុងកម្រិតប្រមាណ ២០% នៅក្នុងអំឡុងពេលនៃវដ្តផែនការ ពោលគឺ រូបិយវត្ថុទូទៅ(M2) បានកើនឡើងពី៤២,៦ ទ្រីលានរៀល(៦៣% នៃផ.ស.ស) នៅឆ្នាំ២០១៤ ដល់ប្រមាណ ៨៨,៤ ទ្រីលានរៀល (៨៩% នៃផ.ស.ស) នៅឆ្នាំ២០១៨។ កំណើនឡើងនេះ ត្រូវបានគាំទ្រដោយកំណើននៃទ្រព្យសកម្មបរទេសសុទ្ធ និងទ្រព្យសកម្មក្នុងស្រុកសុទ្ធ។

៣.១៤ ទោះបីជាប្រាក់រៀលបានកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក៏សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារអាមេរិក ដែលបញ្ជាក់ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) និងប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបមានកម្រិតប្រមាណ ៨៣% និង ៩៥% ក្នុងឆ្នាំ២០១៤ និងមានកម្រិតប្រមាណ ៨៥% និង ៩៥% រៀងគ្នា ក្នុងឆ្នាំ២០១៨ (រូបភាព ៣.៧)។ កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ បានកើនឡើងពី ៣៥,២ ទ្រីលានរៀល នៅឆ្នាំ២០១៤ ដល់ ៧៥,0 ទ្រីលានរៀល នៅឆ្នាំ២០១៨ ដោយសារការបន្តកើនឡើងនៃប្រាក់ចំណូលនិងសន្សំរបស់សាធារណជន ការបន្តទទួលបានលំហូរមូលធនចូលមកក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារ និងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។

៣.១៥ ធនាគារជាតិនៃកម្ពុជា បានបន្តរក្សាតម្លៃប្រាក់រៀលក្នុងកម្រិត ៤000រៀល/ដុល្លារអាមេរិក ដោយអនុញ្ញាតឲ្យមានការប្រែប្រួលតិចតួច។ លើសពីនេះទៀត រដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា បានចាប់ផ្តើមដំបូងដើម្បីកសាងទំនុកចិត្តលើប្រាក់រៀលនិងលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈការអនុវត្តសកម្មភាពផ្សេងៗដូចជា ១. តម្រូវឲ្យមានប្រតិបត្តិការរបស់រដ្ឋាភិបាលទាំងអស់ធ្វើជាប្រាក់រៀល ២. ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ៣. ការកែលម្អគុណភាពក្រដាសប្រាក់និង ៤. ការចែកចាយប្រាក់រៀលដើម្បីបំពេញតាមតម្រូវការនៅក្នុងតំបន់និងវិស័យទាំងអស់។ ជាលទ្ធផល ចំណែកនៃប្រាក់បញ្ញើជារៀលធៀបនឹងរូបិយវត្ថុទូទៅ (M2) បានកើនឡើងពី៤,២% ក្នុងឆ្នាំ២០១៤ ដល់៤,៧% ក្នុងឆ្នាំ២០១៨។ រូបិយវត្ថុក្នុងចរាចរណ៍បានកើនឡើងពី៦,0 ទ្រីលានរៀល នៅឆ្នាំ២០១៤ ដល់ចំនួន ១0,0 ទ្រីលានរៀល និងមានសមាមាត្រ ១១,៣% ធៀបនឹង M2 និង ១0,១% ធៀបនឹងផ.ស.ស នៅឆ្នាំ២០១៨។

**រូបភាពទី ៣.៦ សមាសធាតុនៃរូបិយវត្ថុទូទៅ និង កំណើន**

(ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

## ជញ្ជីងទូទាត់កម្ពុជា

៣.១៦ ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ ស្ថានភាពជញ្ជីងទូទាត់កម្ពុជាបានបង្ហាញអតិរេកជាមធ្យម ៥,៤% នៃផ.ស.ស. ទោះបីជាឱនភាពគណនីចរន្តបានកើនឡើងក្នុងឆ្នាំ២០១៨ ក៏ដោយ។ នៅឆ្នាំ២០១៨ ជញ្ជីងទូទាត់កម្ពុជាមានអតិរេក១ ៥៧០ លានដុល្លារអាមេរិក ឬស្មើនឹង៦,៥% នៃផ.ស.ស. និងបានបន្តគរពូនទុនបម្រុងអន្តរជាតិដុលរបស់ប្រទេសជាលំដាប់។

៣.១៧ ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ គណនីចរន្តកម្ពុជាមានឱនភាពជាមធ្យម៨,៩%នៃផ.ស.ស. និងបន្តមានឱនភាព១១,៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១៨ ជាចម្បងបណ្តាលមកពីឱនភាពពាណិជ្ជកម្មទំនិញ។ ការកើនឡើងការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្មនាំចេញជាកត្តាចម្បងធ្វើឲ្យពាណិជ្ជកម្មទំនិញមានឱនភាព។ ម្យ៉ាងទៀតកំណើនតម្រូវការក្នុងស្រុកលើផលិតផលមួយចំនួន ដូចជា សម្ភារសំណង់ យានយន្ត និងគ្រឿងបរិភោគ ព្រមទាំងការកើនឡើងថ្លៃប្រេងនៅ លើទីផ្សារអន្តរជាតិ ក៏ជាកត្តាជំរុញកំណើនការនាំចូលសរុបផងដែរ។ វិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជានៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច ដោយការនាំចេញសម្លៀកបំពាក់ និងស្បែកជើងធៀបនឹងការនាំចេញសរុបមានសមាមាត្រ៧៣% ដូចគ្នាក្នុងឆ្នាំ២០១៤និងឆ្នាំ២០១៨។

៣.១៨ ជាមួយនឹងគោលនយោបាយដ៏រឹងមាំរបស់រដ្ឋាភិបាល កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចជាមួយទីផ្សារក្នុងតំបន់ និងពិភពលោក និងបណ្តាញផលិតកម្ម។ សកម្មភាពពាណិជ្ជកម្មមានការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេសជាមួយនឹងប្រទេសជិតខាង និងការធ្វើពិពិធកម្មទីផ្សារ

ថ្មីៗ នៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ទំហំពាណិជ្ជកម្មមានការកើនឡើងយ៉ាងឆាប់រហ័ស និងបានកើនដល់៣១ ៧៦៩ លានដុល្លារអាមេរិក(១៣១% នៃផ.ស.ស.) ក្នុងឆ្នាំ២០១៨។ សម-តុល្យជញ្ជីងពាណិជ្ជកម្មកម្ពុជា មានឱនភាពជាមធ្យម ២ ៩៣៦ លានដុល្លារអាមេរិក (២១% នៃផ.ស.ស.) ក្នុងអំឡុងឆ្នាំ២០១៤-២០១៨។ ឱនភាពពាណិជ្ជកម្មបានថយចុះប្រមាណ១% នៃផ.ស.ស. ក្នុងឆ្នាំ២០១៨ ធៀបនឹង ឆ្នាំ២០១៤ ដោយសារការនាំចេញកើនឡើងលឿនជាងការនាំចូល។ ថ្មីៗនេះ កម្ពុជាមិនត្រឹមតែផ្តោតលើផលិតកម្មសម្លៀកបំពាក់ និងស្បែកជើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើពិពិធកម្មការនាំចេញផលិតផលផ្សេងៗទៀត ដូចជា ទោចក្រយាន គ្រឿងបន្លាស់យានយន្ត និងបរិក្ខារអគ្គិសនី ដែលមានប្រមាណ ៥% នៃការនាំចេញសរុបសម្រាប់ឆ្នាំ២០១៨ និងបានបន្តកើនឡើងនាប៉ុន្មានឆ្នាំនេះ។ ការធ្វើពិពិធកម្មទៅរកខ្សែសង្វាក់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ បានធ្វើឲ្យវិស័យកម្មន្តសាលកាន់តែដើរតួនាទីសំខាន់ក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្រៅពីពិពិធកម្មមុខទំនិញ កម្ពុជាក៏បានធ្វើពិពិធកម្មគោលដៅនាំចេញទៅកាន់ប្រទេស ជប៉ុន កាណាដា អូស្ត្រាលី បន្ថែមទៀត ក្រៅពីដៃគូសំខាន់ៗដូចជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអាឡឺម៉ង់។ ជាមួយគ្នានេះដែរ ប្រទេសដៃគូនាំចូលចម្បងគឺប្រទេសនៅតំបន់អាស៊ី រួមមាន ចិន ថៃ វៀតណាម និងហុងកុង ដែលក្នុងនោះ ផលិតផលនាំចូលសំខាន់ៗរួមមាន ប្រេងឥន្ធនៈ យានយន្ត ក្រណាត់និងអំបោះ គ្រឿងបរិក្ខារអគ្គិសនី និង ឱសថ។

៣.១៩ ស្ថានភាពអំណោយផលនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានបន្តជំរុញឲ្យសមតុល្យរួមជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេកជាលំដាប់ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការគរពូនទុនបម្រុងអន្តរជាតិដុលរបស់កម្ពុជា។ ទុនបម្រុងអន្តរជាតិបានកើនឡើងពី ៤,៤ ប៊ីលានដុល្លារអាមេរិក(៣,៨ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់ឆ្នាំបន្ទាប់) នៅឆ្នាំ២០១៤ ដល់ប្រមាណ ១០,១ប៊ីលានដុល្លារអាមេរិក(ប្រមាណ៥ខែនៃការនាំចូលទំនិញនិងសេវាឆ្នាំបន្ទាប់) ក្នុងឆ្នាំ២០១៨។ ការរក្សាបាននូវកម្រិតល្អប្រសើរនេះ បានធ្វើឲ្យប្រទេសកម្ពុជាស្ថិតក្នុងផ្នែកសុវត្ថិភាពនៃចំណាត់ថ្នាក់ពិភពលោកស្តីពីភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ និងមានកម្រិតខ្ពស់ជាងប្រទេសជិតខាងជាច្រើន។

## សេដ្ឋកិច្ចពិត និងផលប៉ះពាល់ដល់សង្គម សេដ្ឋកិច្ច

៣.២០ កំណើនសេដ្ឋកិច្ចដែលកំពុងកើតមាន និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចបានបន្តជំរុញឲ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច សមត្ថភាពផលិតភាព និងកត្តានៃការប្រើប្រាស់។ សកម្មភាពដែលបន្ថែមតម្លៃបន្ថែមខ្ពស់ ជាពិសេសកម្មន្តសាលនិងឧស្សាហកម្មបើកទូលាយត្រូវបានគាំទ្រដោយការកើនឡើងនិងការផ្លាស់ប្តូរកម្លាំងពលកម្ម និងមូលធន ក្នុងវិស័យទាំងនេះ។ ទោះបីជាកម្រិតទូទៅនៃការងារនិងកម្លាំងពលកម្ម នៅតែមានកម្រិតខ្ពស់ក៏ដោយក៏នៅតែមានលទ្ធផលជាវិជ្ជមានលើការបែងចែកប្រាក់ចំណូល និងកាត់បន្ថយកម្រិតនៃភាពក្រីក្រនៅទូទាំងប្រទេស។

## ការផ្លាស់ប្តូររចនាសម្ព័ន្ធ

៣.២១ រំលឹកឡើងវិញពីការពិភាក្សាលើសមាសភាគនៃកំណើនសេដ្ឋកិច្ច (ក្នុងកថាខណ្ឌ ៣.៥ និង ៣.៦) ខាងលើ ការផ្លាស់ប្តូរនៅក្នុងចំណែកនៃតម្លៃបន្ថែមតាមវិស័យ កំពុងតែបន្តទៀត នៅក្នុងអំឡុងពេលនេះ។ ដូចបានបង្ហាញនៅក្នុងរូបភាព ចំណែករបស់វិស័យឧស្សាហកម្មមិនមានការរីកចម្រើនទេ ខណៈពេលដែលចំណែករបស់ វិស័យកសិកម្មក្នុង ផ.ស.ស. មានការធ្លាក់ចុះ។ តាមការធ្វើចំណោលទិន្នន័យ បង្ហាញថា ឆ្នាំ២០១៨ ចំណែកតម្លៃបន្ថែមក្នុងវិស័យកសិកម្មក្នុងផ.ស.ស. ធ្លាក់ចុះពី៣៤% ក្នុងឆ្នាំ២០១២ ដល់២១% ហើយវិស័យឧស្សាហកម្ម នឹងកើនឡើងពី២៤% ក្នុងឆ្នាំ២០១២ ដល់៣៣%។ វិស័យសេវាទទួលបានក្នុងកម្រិត ប្រមាណ៤0% ស្របពេលដែល តម្លៃបន្ថែមក្នុងវិស័យកម្មន្តសាល(វិស័យកម្មន្តសាលផ្ទាល់និងសមាសភាគនៃវិស័យឧស្សាហកម្ម) បានកំណត់ការកើនឡើងដល់១៦% ធៀបនឹងផ.ស.ស.។

## រូបភាពទី ៣.៧ តម្លៃបន្ថែមតាមវិស័យ គិតជា % នៃផលិតផលក្នុងស្រុកសរុប និងការព្យាករដល់ឆ្នាំ២០១៨




*ប្រភព៖* ធនាគារពិភពលោក និងគណនា

៣.២២ ការប្រែប្រួលក្នុងវិស័យនេះ ត្រូវបានឆ្លុះបញ្ចាំងដោយនិន្នាកាទីផ្សារការងារ។ តារាង ៣.២ បង្ហាញពីនិន្នាការនៃការចូលរួមក្នុងកម្លាំងពលកម្មរបស់បុរសនិងស្ត្រី ក្នុងវិស័យកសិកម្មមានការធ្លាក់ចុះ និងមានការកើនឡើងក្នុងវិស័យឧស្សាហកម្ម ក្នុងអាណត្តិកាលនៃផែនការ។ និន្នាការនេះ ជំរុញដោយផ្ទាល់ក្នុងការបង្កើនផលិតភាពរបស់កម្មករ និងធ្វើឲ្យកើនឡើងចំណូលរបស់គ្រួសារ។ កត្តាដ៏សំខាន់មួយទៀតគឺ សមាសភាពកម្រិតខ្ពស់និងនៅតែមានការកើនឡើងនៃការចូលរួមក្នុងទីផ្សារការងារក្នុងប្រទេសកម្ពុជា និងត្រូវបានគូសបញ្ជាក់ថា ការប្រើប្រាស់កត្តានេះកំពុងមានការកើនឡើងស្របពេលដែលមានការបែងចែកកម្លាំងពលកម្មឡើងវិញ ទៅវិស័យ

ដែលមានតម្លៃបន្ថែមខ្ពស់ជាង។ ជាថ្មីម្តងទៀត ផ្អែកលើ តារាង ៣.២ បង្ហាញថា ប្រមាណ៩០% នៃប្រជាជនកម្ពុជា ជាបុរស និង ៨៩% ជាស្ត្រី កំពុងចូលរួមក្នុងទីផ្សារការងារ។

## តារាងទី ៣.២ ទិន្នន័យទីផ្សារការងារពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា

| | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា ២០១៣ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា ២០១៤ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា ២០១៦ | | |
|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប |
| អត្រាចូលរួម | ៨៨,៧ | ៧៧,៨ | ៨៣ | ៨៧,៩ | ៧៧,៥ | ៨២,៦ | ៨៩,៤ | ៧៨,៩ | ៨៤ |
| កសិកម្ម | ៤៧,៤ | ៥០ | ៤៨,៧ | ៤៣,៩ | ៤៦,៧ | ៤៥,៣ | ៣៣,៧ | ៣៩,៣ | ៣៦,៤ |
| ឧស្សាហកម្ម | ២០,៥ | ១៩,២ | ១៩,៨ | ២៤,៥ | ២៤,១ | ២៤,៣ | ២៧,៩ | ២៥,២ | ២៦,៦ |
| សេវា | ៣២,១ | ៣០,៨ | ៣១,៥ | ៣១,៦ | ២៩,២ | ៣០,៤ | ៣៨,៤ | ៣៥,៥ | ៣៧ |
| | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖* អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា ២០១៣ ២០១៤ និង ២០១៦

## រូបភាពទី ៣.៨ របាយពលកម្មតាមវិស័យ




*ប្រភព៖* អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងការគណនា

៣.២៣ ការប្រែប្រួលនិងអត្រាចូលរួមខ្ពស់ក្នុងវិស័យនេះ ក៏ជាចំណុចល្អផងដែរសម្រាប់ការកាត់បន្ថយភាពក្រីក្រនិងបែងចែកចំណូលដល់ប្រជាជនកម្ពុជាដោយនិន្នាការនេះ គឺជាការកំណត់សំខាន់ៗ (រួមទាំងតម្លៃនៃការរស់នៅ) នូវវិសាលភាពនៃការគាំទ្រដល់ប្រជាជនក្រីក្រនិងបរិយាបន្ន។ ជាការពិតណាស់ ទិន្នន័យពីភាពក្រីក្រនិងកម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជនមានភាពប្រសើរឡើង ដូចរូបភាព៣.៨ បង្ហាញថា ទោះបីជាក្នុងរយៈពេលខ្លីនៃវដ្តផែនការក្តី ទិន្នន័យសម្រាប់គ្រប់តំបន់ភូមិសាស្ត្រ ភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ បានបង្ហាញពីការកើនឡើងនៃការប្រើប្រាស់ក្នុងគ្រួសារ។ ជាងនេះទៀត គ្រួសារនៅតំបន់ជនបទ ដែលមានប្រជាជនរស់នៅច្រើនជាងតំបន់ផ្សេងទៀត ត្រូវបានមើលឃើញថា មានការរីកចម្រើនដ៏ធំបំផុត

ក្នុងជីវភាពរស់នៅ។

### រូបភាពទី ៣.៩ ការប្រើប្រាស់របស់គ្រួសារក្នុងមនុស្សម្នាក់ តាមតម្លៃបច្ចុប្បន្ន ២០១៣-២០១៦




***ប្រភព៖*** អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងការគណនា

៣.២៤ ដោយសារតែទិន្នន័យនៃភាពក្រីក្រ មានតែមួយគត់ក្នុងអំឡុងពេលនេះ(១៣,៥% ក្នុងឆ្នាំ២០១៤) ធ្វើឲ្យមានការលំបាកក្នុងការកំណត់យ៉ាងពេញលេញអំពីផលប៉ះពាល់នានា។ ទោះបីជាទិន្នន័យប្រើប្រាស់មិនត្រូវគ្នាពេញលេញជាមួយនឹងការប្រើប្រាស់សម្រាប់គណនាអត្រានៃភាពក្រីក្រក្តី[4] និន្នាការដែលបានប៉ាន់ស្មាន បានចង្អុលបង្ហាញដើម្បីកាត់បន្ថយបន្ថែមទៀតនូវចំនួនប្រជាជនក្រីក្រនៅក្នុងឆ្នាំបន្តបន្ទាប់។ តាមអត្រានៃភាពក្រីក្រដែលមានវាស់វែងនៅថ្នាក់ក្រោមជាតិ បង្ហាញថា ប្រជាជនដែលនៅក្រីក្រភាគច្រើនរស់នៅក្នុងតំបន់ជនបទដែលភាគច្រើនប្រកបរបរកសិកម្ម(រូបភាព ៣.៩)។ ទោះជាដូចនេះក្តី អត្រានេះបានចង្អុលបង្ហាញពីភាពខុសគ្នារវាងតំបន់និងតម្រូវការដើម្បីរក្សាគំរូសេដ្ឋកិច្ច ដែលនឹងរួមបញ្ចូលនូវគ្រប់តំបន់និងក្រុមទាំងអស់។

[4] *ស្របតាមការអនុវត្តស្ថិតិស្តង់ដា ការវាស់វែងភាពក្រីក្រដោយផ្អែកលើទិន្នន័យ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា បានអនុញ្ញាតឱ្យមានការកែតម្រូវចំពោះការប្រើប្រាស់*

## រូបភាពទី ៣.១០ ការបែងចែកទិន្នន័យភាពក្រីក្រ ឆ្នាំ២០១៥ (ប្រើប្រាស់បច្ចេកទេសវាយតម្លៃរបស់តំបន់ជាមូលដ្ឋាន)




***ប្រភព៖*** ក្រសួងផែនការ (ឆ្នាំ២០១៦)

៣.២៥ ជាលទ្ធផល គំរូសេដ្ឋកិច្ច និងថាមវន្ត(ឌីណាមិច) នៃការបែងចែកជាវិជ្ជមានរបស់វា នឹងមានឥទ្ធិពលកាន់តែទូលំទូលាយដល់សង្គម លើលក្ខខណ្ឌនៃការរស់នៅ កម្រិតអាហារូបត្ថម្ភ ជំងឺ មរណភាពជាដើម។ ការខ្វះខាតទិន្នន័យបណ្តាលឲ្យមានការលំបាកក្នុងការពិនិត្យមើលពីផលប៉ះពាល់របស់គំរូសេដ្ឋកិច្ចទាំងនេះ ប៉ុន្តែ នៅក្នុងរយៈពេលនៃផែនការក៏បានមើលឃើញពីតាមរយៈឆ្នាំចុងក្រោយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.) ហើយវាមានតម្លៃសម្រាប់កត់សម្គាល់ថា លទ្ធផលជាវិជ្ជមានមួយចំនួនត្រូវបានធ្វើឲ្យកើតមានឡើង។ កម្ពុជាសម្រេចបានគោលដៅភាគច្រើន ជាពិសេសគោលដៅពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជីវភាពរស់នៅរបស់គ្រួសារប្រជាជន ដូចជា ភាពក្រីក្រ ភាពអត់ឃ្លាន អាហារូបត្ថម្ភ មរណភាព និងសុខភាព។ សមាសភាពសំខាន់មួយបានពន្លឿនកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឲ្យបាននូវគោលដៅដែលមិនទាន់បានសម្រេចនៅឆ្នាំចុងក្រោយ ជាពិសេសពាក់ព័ន្ធនឹងការថែទាំសុខភាពនិងការសិក្សា ដែលរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់បន្ថែមនូវធនធានសម្រាប់អនុវត្ត។ ទោះជាដូចនេះក្តី ដូចមានបង្ហាញនៅក្នុងតារាង ៣.៣ ដដែល នៅមានផ្នែកមួយចំនួនដែលមិនទាន់បានសម្រេច ហើយផ្នែកទាំងនេះគួរត្រូវបានដោះស្រាយនៅក្នុងឆ្នាំដំបូងនៃ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

## តារាងទី ៣.៣ សង្ខេបពីលទ្ធផលនៃការសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

| គោលដៅ | ចំណុចដៅ | លទ្ធផលអនុវត្ត |
|---|---|---|
| ១. លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ | (១a) កាត់បន្ថយឲ្យបានពាក់កណ្ដាលសមាមាត្រនៃប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្ររបស់ជាតិ | សម្រេចបាន |
| | (១b) កាត់បន្ថយសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន | សម្រេចបាន |
| | (១c) បង្កើនចំណែកនៃចំណូលរបស់ប្រជាជនក្របំផុត២០% | មិនទាន់សម្រេចបាន |
| | (១d) លើកកម្ពស់អាហារូបត្ថម្ភនិងលុបបំបាត់ភាពគ្រិន | មិនទាន់សម្រេចបាន |
| ២. សម្រេចឲ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា | (២a) សម្រេចឲ្យបាន១០០% ការសិក្សាពិតនៅកម្រិតបឋមសិក្សា | ហៀបនឹងសម្រេចបាន |
| | (២b) សម្រេចឲ្យបាន១០០% អត្រាបញ្ចប់ការសិក្សានៅកម្រិតសិក្សាបឋមភូមិ | មិនទាន់សម្រេចបាន |
| | (២c) សម្រេចឲ្យបានសកលកម្មអក្ខរកម្ម ក្នុងចំណោមប្រជាជនអាយុ ពី ១៥-២៥ ឆ្នាំ | ហៀបនឹងសម្រេចបាន |
| | (២d) សម្រេចឲ្យបាននូវសមភាពយេនឌ័រ នៅកម្រិតបឋមសិក្សា | សម្រេចបាន |
| ៣. លើកកម្ពស់សមភាពយេនឌ័រ និងការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី | (៣a) សម្រេចឲ្យបានសមភាពយេនឌ័រក្នុងវិស័យអប់រំនិងអក្ខរកម្ម | សម្រេចបាន |
| | (៣b) ផ្ដល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការងារទទួលបានប្រាក់ឈ្នួល | មិនទាន់សម្រេចបាន |
| | (៣c) ផ្ដល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត | មិនទាន់សម្រេចបាន |
| | (៣d) បញ្ចប់អំពើហិង្សាលើយេនឌ័រ | មិនមានចំណុចដៅ |
| ៤. កាត់បន្ថយអត្រាមរណភាពកុមារ | (៤a) កាត់បន្ថយអត្រាមរណភាពទារក | សម្រេចបាន |
| | (៤b) កាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ៥ឆ្នាំ | សម្រេចបាន |
| ៥. លើកកម្ពស់សុខភាពមាតា | (៥a) កាត់បន្ថយអត្រាមរណភាពមាតា | សម្រេចបាន |
| | (៥b) បង្កើនអត្រាសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ | សម្រេចបាន |
| ៦. ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត | (៦a) កាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ | សម្រេចបាន |
| | (៦b) កាត់បន្ថយ អត្រាស្លាប់ដោយជំងឺរបេងនិងអត្រាប្រេវ៉ាឡង់ | សម្រេចបាន |
| | (៦c) កាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | សម្រេចបាន |
| ៧. ធានាចីរភាពបរិស្ថាន | (៧a) បញ្ចូលគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពនិងការថយចុះនៃធនធានធម្មជាតិ | មិនមានចំណុចដៅ |
| | (៧b) សម្រេចឲ្យបាន ការទទួលបានទឹកសុវត្ថិភាពបរិភោគ និងអនាម័យ នៅតំបន់ជនបទនិងតំបន់ទីប្រជុំជន | សម្រេចបាន |
| | (៧c) កាត់បន្ថយ ការពឹងផ្អែករបស់គ្រួសារកម្ពុជា លើអុសសម្រាប់ប្រើជាថាមពល | មិនទាន់សម្រេចបាន |
| | (៧d) បង្កើនសមាមាត្រប្រជាជនកាន់កាប់ដីធ្លីប្រកបដោយចីរភាព | សម្រេចបាន |
| ៨. បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ | មិនមានចំណុចដៅ | មិនមានចំណុចដៅ |
| ៩. ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការ សង្គ្រោះជនពិការដោយសារមីន | (៩a) កាត់បន្ថយចំនួនប្រជាជនដែលរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | សម្រេចបាន |
| | (៩b) ផ្ទៃដីដែលបានបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម | សម្រេចបាន |

***ប្រភព៖*** ក្រុមប្រឹក្សា... 

## ៣.៣ គោលដៅ និង គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ ២០១៩-២០២៣

៣.២៦ ផ្នែកសំខាន់ទី២នេះ ចែកជាពីរផ្នែក ទី១ បង្ហាញពី**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤** បរិការណ៍និងទិសដៅរបស់យុទ្ធសាស្ត្រនិងការស្នើឡើងនូវទម្រង់នៃក្របខ័ណ្ឌលទ្ធផល ដែលមានគោលបំណងគោលនយោបាយ និងសកម្មភាពនានា ដែលកំណត់នៅក្នុងជំពូកទី៤ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ក្នុងជំពូកទី៦។ ទី២ កំណត់ចេញនូវគោលនយោបាយសារពើពន្ធនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធជាពិសេសទៅនឹងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងវដ្តនៃ**ផ.យ.អ.ជ. ២០១៩-២០២៣**។ ផ្នែកនេះគឺពឹងផ្អែកយ៉ាងខ្លាំងទៅនឹងអាណត្តិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា។

## យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងការធ្វើសមាហរណកម្មទៅក្នុង ផ.យ.អ.ជ. ២០១៩-២០២៣

### បញ្ហាប្រឈមចម្បងៗ និងកាលានុវត្តភាព

៣.២៧ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** និង **ផ.យ.អ.ជ. ២០១៩-២០២៣** នេះ មានគោលបំណងជំរុញដល់កិច្ចអភិវឌ្ឍនៅកម្ពុជា ជាពិសេសក្នុងគោលបំណងកែប្រែកម្ពុជាឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីមួយទៀត គឺប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០។ ឯកសារផែនការទាំងពីរនេះ នឹងដើរតួជាឯកសារមេសម្រាប់ជាមគ្គុទ្ទេសក៍ក្នុងការអនុវត្តនូវគោលនយោបាយនានា ដោយមានការរួមចំណែកទាំងកត្តាខាងក្នុង និងខាងក្រៅ ហើយនេះគឺជាកម្រិតមិនច្បាស់លាស់មួយ ដែលត្រូវបានមើលឃើញថា មានការប្រែប្រួលនាពេលបច្ចុប្បន្ន នៅក្នុងតំបន់និងក្នុងពិភពលោក។ នៅក្នុងគំនូសបំប្រួញកម្រិតខ្ពស់បំផុត យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ កំណត់នូវអរូបិយខ្ពស់បំផុតនិន្នាការធំៗចំនួន៤ ដែលមានផលប៉ះពាល់លើ *១. ការកកើតនូវពហុប៉ូលថ្មីរបស់ពិភពលោក ដោយសារតែការប្រែប្រួលតុល្យភាពនៃអំណាច ២. សេដ្ឋកិច្ចពិភពលោកកើនឡើងកាន់តែខ្លាំង ដឹកនាំដោយអាស៊ី ៣. ការអភិវឌ្ឍនៃបដិវត្តន៍ឧស្សាហកម្មទី៤ ដែលជាកត្តាកំណត់សំខាន់នៃនិន្នាការផលិតកម្មគំរូពាណិជ្ជកម្ម និង ៤. ការចាប់ផ្តើមនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ជាពិសេសសម្រាប់ប្រទេសកម្ពុជា ភាពរាំងស្ងួត រលកកម្តៅ និងទឹកជំនន់*[5]។

៣.២៨ បញ្ហាប្រឈមចម្បងគេគឺ រក្សាឲ្យបាននូវអត្រាកំណើនកម្រិតខ្ពស់ដែលទទួលបានជាមួយនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធនិងការការពារបរិស្ថាន។ បញ្ហាប្រឈមនៃប្រតិបត្តិការចំនួន១០

[5] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤។

បញ្ហាទាំង ១០នោះ គឺរួមមាន ៖ ១. ភាពមិនច្បាស់លាស់ខាងផ្នែកសេដ្ឋកិច្ច ដែលកើតមានឡើងដោយសារជម្លោះពាណិជ្ជកម្ម ដែលអាចប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាដែលមានការពឹងផ្អែកខ្លាំងលើពាណិជ្ជកម្មអន្តរជាតិ សម្រាប់ជំរុញការអភិវឌ្ឍប្រទេស។ ២. ការធានារក្សានូវសន្តិភាព ស្ថិរភាពនយោបាយនិងសណ្តាប់ធ្នាប់សង្គម ដែលបង្កពីកត្តាខាងក្នុងនិងក្រៅ ដែលនៅជាបញ្ហាប្រឈមដ៏សំខាន់។ ៣. ភាពទន់ខ្សោយនៃធនធានមនុស្សដែលតម្រូវឲ្យមានការអភិវឌ្ឍទៅរកធនធានដែលមាន សមត្ថភាព និងផលិតភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គម។ ៤. កង្វះពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតតម្លៃបន្ថែមក្នុងវិស័យឧស្សាហកម្មនិងវិស័យសេវាកម្ម។ ៥. ការធ្វើពិពិធកម្មនិងលើកកម្ពស់វិស័យកសិកម្ម ដោយសារកំណើនសេដ្ឋកិច្ចយឺតយ៉ាវនិងឧបសគ្គក្នុងវិស័យកសិកម្មដែលជាវិស័យទ្រទ្រង់ដ៏សំខាន់។ ៦. ភាពខ្វះទំនុកចិត្តនិងជំនឿចិត្តសាធារណៈ លើសេវាសាធារណៈនិងស្ថាប័នតុលាការ ការថែទាំសុខភាពដែលមានគុណភាពទាប។ ៧. គុណភាពរបស់វិស័យសុខាភិបាលនៅមានកម្រិត។ ៨. វិស័យហិរញ្ញវត្ថុនៅតែស្ថិតនៅក្រោមការអភិវឌ្ឍ(ជាមួយនឹងអត្រាការប្រាក់ខ្ពស់ ការសន្សំក្នុងស្រុកមិនគ្រប់គ្រាន់ និងការកើនឡើងនៃបំណុលគ្រួសារ)។ ៩. ហានិភ័យបរិស្ថាន ការផ្តល់ឲ្យដោយនូវការគ្រប់គ្រងធនធានធម្មជាតិមិនគ្រប់គ្រាន់និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលកំពុងប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាផងដែរ។ ១០. ការថយចុះជាបន្តបន្ទាប់នូវជំនួយអភិវឌ្ឍន៍ផ្លូវការ ផលវិជ្ជមាន(និងអវិជ្ជមាន) នៃការចាកចេញពីស្ថានភាពនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច ទៅលើការវិនិយោគនិងពាណិជ្ជកម្ម។

៣.២៩ ដើម្បីបង្ការនូវបញ្ហាទាំងនេះ យុទ្ធសាស្ត្រចតុកោណ បានកំណត់ចេញនូវបញ្ជីកាលានុវត្តភាពជាស៊េរីមួយចំនួន។ បញ្ជីនៃកាលានុវត្តភាពទាំងនេះរួមមាន៖ ១. សន្ទុះកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ផ្អែកលើបរិយាកាសអាជីវកម្មរីកចម្រើនរបស់ខ្លួន លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមានកម្រិតខ្ពស់ តម្រូវការនិងពាណិជ្ជកម្មក្នុងស្រុក ២. ការផ្លាស់ប្តូរទីប្រជុំទម្ងន់នៃកំណើនសេដ្ឋកិច្ចមកទ្វីបអាស៊ី ពិសេសមកអាស៊ីបូព៌ា ៣. ការកើនឡើងគួរឱ្យកត់សម្គាល់នៃការប្រកួតប្រជែងរវាងបណ្តាប្លុកពាណិជ្ជកម្មនៅអាស៊ី-ប៉ាស៊ីហ្វិក ៤. កម្ពុជានៅមានសក្តានុពលយ៉ាងច្រើន ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរួមមាន ការបន្តបង្កើនភាពស៊ីជម្រៅនៃអន្តរការីយកម្មហិរញ្ញវត្ថុ ការលើកកម្ពស់វិស័យធានារ៉ាប់រង និងការអភិវឌ្ឍទីផ្សារមូលបត្រ ៥. ផលលាភប្រជាសាស្ត្រ និងអត្រាទាបនៃអ្នករស់នៅក្នុងបន្ទុក គួបផ្សំនឹងការកើនឡើងនៃចំនួនប្រជាជន ដែលមានចំណូលមធ្យម និងជាវណ្ណៈកណ្តាលនឹងការបង្កើនកាលានុវត្តភាពសម្រាប់កម្ពុជាក្នុងការសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់សម្រាប់រយៈពេល៣ទសវត្សរ៍ខាងមុខ និង ៦. ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទី៤នេះ បានបង្កើតនូវមុខរបរ និងធុរកិច្ចថ្មីជា

ច្រើនដែលមិនធ្លាប់មានពីមុនមក។

## ទិសដៅទូទៅនៃគោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

៣.៣០ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ កំណត់ចេញនូវផែនទីបង្ហាញផ្លូវដ៏មានមហិច្ឆតាមួយ ដើម្បីសម្រេចឲ្យបាននូវទស្សនវិស័យ ជាស្ថានភាពប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាស្ថានភាពប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ជាមួយនឹងកម្រិតសមស្របនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ផលិតភាពខ្ពស់ និងការលើកកម្ពស់ការប្រកួតប្រជែងឲ្យកាន់តែប្រសើរឡើង គឺជាចំណុចស្នូលរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ រួមជាមួយនឹងបរិយាប័ន្នសង្គមសេដ្ឋកិច្ច និងចីរភាពបរិស្ថាន បានកំណត់នូវទិសដៅស្នូលចំនួន ៤ គឺៈ

១. កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ មានកម្រិត៧% ជាមួយគ្នានឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច(អតិផរណាសមតុល្យខាងក្រៅទាប) ឬសគល់ក្នុងការបង្កើនផលិតភាពនិងការប្រកួតប្រជែងដែលគូសបង្ហាញលើការធ្វើសមាហរណកម្មសាកល និងការអនុម័តនូវបច្ចេកវិទ្យាបដិវត្តន៍ឧស្សាហកម្មទី៤។
២. ការងារដែលមានគុណភាពកម្រិតខ្ពស់ ការបង្កើតការងារថ្មីសម្រាប់អ្នកទើបចូលរួមក្នុងទីផ្សារការងារ រួមទាំងប្រជាជនវ័យក្មេង រួមជាមួយនឹងតម្លៃនៃកាលានុវត្តភាពខ្ពស់ ជំនាញថ្មីនិងលក្ខខណ្ឌការងារល្អប្រសើរ។
៣. បន្តកាត់បន្ថយភាពក្រីក្រ ជាមួយនឹងអត្រាស្ថិតនៅក្រោម១០% ត្រឹមដំណាច់អាណត្តិកាលផែនការ ជាមួយនឹងការកាត់បន្ថយឲ្យបានលើសពី១% ក្នុងមួយឆ្នាំ និងកាត់បន្ថយភាពងាយរងគ្រោះ និងធានាសន្តិសុខចំណូល។
៤. អភិបាលកិច្ចនិងគណនេយ្យភាពតាមរយៈសមត្ថភាពរបស់ស្ថាប័នសាធារណៈការពង្រឹងប្រព័ន្ធភាពសុចរិតកម្រិតខ្ពស់និងភាពស្អាតស្អំក្នុងវិស័យសាធារណៈ ភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពក្នុងការផ្តល់សេវា។

៣.៣១ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ត្រូវបានរៀបចំឡើងដោយផ្អែកលើបរិការណ៍ប្រតិបត្តិការនៃសន្តិភាពនិងសណ្តាប់ធ្នាប់សាធារណៈ បរិយាកាសអនុគ្រោះដល់ការធ្វើអាជីវកម្មនិងការវិនិយោគ ពង្រឹងភាពជាម្ចាស់និងភាពជាដៃគូនៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍ ការធ្វើសមាហរណកម្មទៅក្នុងតំបន់និងក្នុងពិភពលោក។ យុទ្ធសាស្ត្រ ប្រកាន់ខ្ជាប់នូវស្នូលចតុកោណបូកជាមួយនឹងរចនាសម្ព័ន្ធចតុកោណ៤ផ្សេងទៀត ប៉ុន្តែភ្ជាប់ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយថ្មី។ ចំពោះភាពពេញលេញរបស់ចតុកោណ និងសមាសភាពសេដ្ឋកិច្ចច្បាស់លាស់របស់វាគឺៈ

- ស្នូលរបស់ចតុកោណ ផ្តោតទៅលើ ការពន្លឿនកំណែទម្រង់អភិបាលកិច្ច ការកំណត់ពីវឌ្ឍនភាពបន្ថែមទៀតលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- *ចតុកោណទី១* ការអភិវឌ្ឍធនធានមនុស្សដោយសង្កត់ធ្ងន់នៅក្នុងវិស័យសេដ្ឋកិច្ច ការកសាងធនធានមនុស្ស។
- *ចតុកោណទី២* ការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាមួយនឹងមុំទាំងបួន មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច ការដឹកជញ្ជូន ការតភ្ជាប់ ប្រភពថ្មីសម្រាប់កំណើន ការធ្វើឲ្យប្រសើរឡើងវិស័យហិរញ្ញវត្ថុ។
- *ចតុកោណទី៣* វិស័យឯកជន និងការអភិវឌ្ឍទីផ្សារ ជាមួយនឹងមុំទាំងបួន មានពាក់ព័ន្ធនឹងទីផ្សារការងារ សហគ្រាសធុនតូចនិងមធ្យមការចាប់ផ្តើមភាពជាដៃគូរវាងវិស័យសាធារណៈនិងផ្នែកឯកជន និងការប្រកួតប្រជែង។
- *ចតុកោណទី៤* ការអភិវឌ្ឍ ប្រកបដោយចីរភាពនិងបរិយាប័ន្នជាមួយនឹងមុំទាំងបួនបានផ្តោតលើ កំណើនរបស់វិស័យកសិកម្ម/តំបន់ជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ។

## ក្របខ័ណ្ឌលទ្ធផលចម្រុះដែលបានស្នើឡើងសម្រាប់គោលនយោបាយ និងសកម្មភាពចម្រុះ

៣.៣២ គោលបំណងដំបូងរបស់ ផ.យ.អ.ជ. គឺប្រែក្លាយបណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា កំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ទៅជាការអនុវត្តជាក់ស្តែង ដែលនឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងផ្តល់ព័ត៌មានដល់ក្រសួង ស្ថាប័នកណ្តាល ដើម្បីពិនិត្យមើលពីលទ្ធផលនៃការអនុវត្តគោលនយោបាយនៅកម្រិតម៉ាក្រូ។ ជំពូកទី៤ គូសបញ្ជាក់ពីតួនាទីរបស់ក្រសួង ស្ថាប័ន ដែលបែងចែកតាមចតុកោណទាំងបួន ហើយចតុកោណស្នូល គឺជាការប្តេជ្ញាចិត្តធ្វើឲ្យមានអភិបាលកិច្ចល្អ កំណត់ដោយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤។ ទោះជាដូចនេះក្តី ជាការចាំបាច់ត្រូវតែធានាឲ្យមានការផ្សារភ្ជាប់គ្នារវាងការរៀបចំគោលនយោបាយ ជាមួយនឹងការផ្តល់សេវា និងដើម្បីការពារកុំឲ្យមានការឃ្លាតឆ្ងាយពីភាពដាច់ដោយឡែកពីគ្នា។ តារាង ៣.៤ ខាងក្រោម បង្ហាញពីក្របខ័ណ្ឌលទ្ធផលអន្តរវិស័យដែលផ្តល់នូវទិសដៅ និងបញ្ជាក់ច្បាស់ពីទំនាក់ទំនងនិងកិច្ចសហការគ្នារវាងស្ថាប័នដែលជាតួអង្គសម្របសម្រួល។ ក្របខ័ណ្ឌនេះ ត្រូវបានតភ្ជាប់រវាងលទ្ធផលរបស់យុទ្ធសាស្ត្រចតុកោណ នៅកម្រិតពីរផ្សេងគ្នា និង ធាតុចេញរបស់វិស័យ/អន្តរវិស័យ និងធាតុចូល។ ក្របខ័ណ្ឌនេះ ក៏បង្ហាញផងដែរពីទំនាក់ទំនងរវាង លទ្ធផល និងធាតុចេញ នៅក្នុងក្របខ័ណ្ឌលទ្ធផល។ យើងនឹងត្រឡប់ទៅពិនិត្យមើលក្របខ័ណ្ឌនេះឡើងវិញ នៅជំពូកទី៦ ពីព្រោះវាបង្កើតជាមូលដ្ឋាននៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣។

## តារាងទី ៣.៤ ក្របខ័ណ្ឌលទ្ធផល ដែលបានស្នើឡើង

| ផលប៉ះពាល់: ស្ថានភាពប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ ឆ្នាំ២០៥០ ជាមួយនឹងការអភិវឌ្ឍសង្គមសមស្រប | | | | |
|---|---|---|---|---|
| លទ្ធផល (កម្រិតសង្ខេប) ទិសដៅរបស់យុទ្ធសាស្ត្រចតុកោណ | (កំណើន), ភាពធន់នៃសេដ្ឋកិច្ច កម្រិតអប្បបរមានៃកំណើនប្រចាំឆ្នាំ ៧% | (ការងារ) ការងារពេញលេញ ជាមួយគ្នានឹងចំនួនច្រើន ពី១ ឆ្នាំ ទៅ ១ឆ្នាំ / សមាមាត្រនៃការងារដែលមានគុណភាពល្អ | (សមធម៌) ចំណូលក្រោមកម្រិតភាពក្រីក្រ ១០% កាត់បន្ថយភាពងាយរងគ្រោះ និងវិសមភាពទាប | (ប្រសិទ្ធភាព) សមត្ថភាពស្ថាប័នសាធារណៈខ្ពស់ជាងមុន និងអភិបាលកិច្ចល្អ |
| លទ្ធផល(ការពិនិត្យពិច័យ)-ស្នូលយុទ្ធសាស្ត្រចតុកោណ និងចតុកោណ | ចតុកោណស្នូល: ការកែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព: ការធានាការគ្រប់គ្រងសាធារណៈប្រកបដោយសុចរិតភាព ការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីផ្តល់នូវរដ្ឋបាលនិងអភិបាលកិច្ចដែលមានប្រសិទ្ធភាព តាមរយៈការអនុវត្ត ការប្រកាន់ខ្ជាប់ស្តង់ដាអន្តរជាតិនៃអភិបាលកិច្ចវិស័យឯកជន<br><br>(១. ការអភិវឌ្ឍធនធានមនុស្ស)៖ ការអប់រំ ការលើកកម្ពស់សមត្ថភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការបង្កើតឱ្យមានបណ្តុះបណ្តាលវិជ្ជាជីវៈនិងលទ្ធភាពទូលំទូលាយក្នុងការទទួលបានការបណ្តុះបណ្តាលនេះ ការទទួលបានការថែទាំសុខភាពសាធារណៈត្រូវបានធ្វើឲ្យប្រសើរឡើង ស្ថានភាពអាហារូបត្ថម្ភត្រូវបានធ្វើឲ្យប្រសើរឡើង ដោយគ្មានអ្នកអត់ឃ្លាន និងធ្វើឲ្យប្រសើរឡើងសន្ទស្សន៍កម្ពស់ធៀបនឹងទម្ងន់ សមភាពយេនឌ័រក្នុងសង្គម សេដ្ឋកិច្ចនិងជីវិតសាធារណៈ និងកម្រិតនៃការធ្វើឲ្យប្រសើរឡើងប្រចាំឆ្នាំ គម្របគាំពារសង្គមដែលបានផ្តល់។<br><br>(២. **ការធ្វើពិពិធកម្មសេដ្ឋកិច្ច**)៖ ធ្វើឲ្យប្រសើរឡើង ការដឹកជញ្ជូន ថាមពល និងការតភ្ជាប់បែបឌីជីថល ស្វែងរកប្រភពថ្មីសម្រាប់ការអភិវឌ្ឍ ដែលផ្តល់ឲ្យតាមរយៈកំណើននៅក្នុងវិស័យថ្មី វេទិកាសេដ្ឋកិច្ចឌីជីថលអនុវត្តនៅក្នុងបច្ចេកវិទ្យាបដិវត្តន៍ឧស្សាហកម្មទី៤ ការស៊ីជម្រៅវិស័យហិរញ្ញវត្ថុ និងសំណុំនៃផលិតផលធនាគារដ៏ទូលំទូលាយ លុបបំបាត់ជាបណ្តើរៗប្រជាជនដែលមិនប្រើប្រាស់ប្រព័ន្ធធនាគារ។<br><br>(៣. **ការអភិវឌ្ឍវិស័យឯកជននិងការងារ**)៖ ទីផ្សារការងារមានភាពប្រសើរឡើង ជាមួយនឹងការងារនៅជិត ពេញលេញនិងផ្លូវការ ចំនួនច្រើននៃសហគ្រាសធុនតូចនិងមធ្យមនិងសហគ្រិនភាព ការចែកចាយនូវឥណទានកាន់តែច្រើនឡើងៗ ដោយវិស័យឯកជន ភាពជាដៃគូរវាងផ្នែកឯកជននិងសាធារណៈមានចំនួនដ៏ច្រើន និងមានតម្លៃខ្ពស់ ការប្រកួតប្រជែងត្រូវបានផ្តល់ឲ្យដោយអ្នកនាំចេញនិងតម្លៃបន្ថែមនៃការនាំចេញដែលកំពុងកើនឡើង។<br><br>(៤. **ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន**)៖ តម្លៃបន្ថែមនិងផលិតភាពកសិកម្មបានកើនឡើង ហើយការតភ្ជាប់ទៅតំបន់ជនបទត្រូវបានលើកកម្ពស់ អភិរក្សធនធានធម្មជាតិ(ព្រៃឈើ/ទឹក) និងបេតិកភណ្ឌវប្បធម៌ ទីក្រុងនិងទីប្រជុំជន គ្រប់គ្រងនិងសម្របសម្រួលល្អប្រសើរជាង សម្ពាធបរិស្ថាន/បរិយាកាស (ទិន្នផលកាបូន) បានថយចុះ។ | | | |
| ធាតុចេញរបស់គោលនយោបាយគន្លឹះ និងសកម្មភាព | -នីតិវិធីកែទម្រង់រដ្ឋបាលនិងអភិបាលកិច្ចកំពុងអនុវត្ត រួមទាំង សេវាស៊ីវិលដែលមានមូលដ្ឋានលើគុណសម្បត្តិសមត្ថភាពខ្ពស់ ហើយគណនេយ្យភាពថវិកានិងរបបដំណើរការដែលមានមូលដ្ឋាន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងទី៤)។<br><br>-វិមជ្ឈការនៃមុខងារថវិកានិងបុគ្គលិក នៅក្នុងវិស័យសំខាន់ៗ និងការវិភាជធនធានសម្រាប់ការអង្កេតនិងការវាស់វែងសម្រាប់បុគ្គលិកដែលមានប្រសិទ្ធភាពបំពេញការងារ។<br><br>-បង្កើនប្រាក់ចំណូលសាធារណៈ ទ្រទ្រង់លើស ២០%នៃ ផ.ស.ស. និងត្រូវបានគាំទ្រដោយប្រភពថ្មី។<br><br>-រក្សាគោលជំហរសារពើពន្ធនិងរូបិយវត្ថុ ប្រកបដោយប្រុងប្រយ័ត្ន ឱនភាពរួមមិនឲ្យលើស៥% នៃ ផ.ស.ស. ស្ថិរភាពតម្លៃនិងជញ្ជីងទូទាត់។<br><br>- ផ្តល់អាទិភាពដល់ការវិនិយោគមូលធន ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធដែលទ្រទ្រង់ដល់កំណើន។<br><br>-បង្កើនការវិភាជថវិកា ដល់វិស័យអភិវឌ្ឍន៍មនុស្ស(ការអប់រំ ច្រើនជាង ៣% នៃផ.ស.ស. សុខាភិបាល) និងគំនិតផ្តួចផ្តើមអាទិភាពលើធនធាន(កិច្ចគាំពារសង្គម សហគ្រាសធុនតូចនិងមធ្យម/សហគ្រិនភាព)។<br><br>-អាហារដែលមានសារសំខាន់/ភាពក្រីក្រធ្ងន់ធ្ងរត្រូវបានលុបបំបាត់ (កម្រិតអប្បបរមា ទាបជាង៣% នៅទូទាំងប្រទេស)។<br><br>-បង្កើនកម្រិតនៃការសន្សំនិងការវិនិយោគ(លើកម្រិតបច្ចុប្បន្ន កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ) ពង្រឹងវិស័យហិរញ្ញវត្ថុនិង | | | |

| | |
|---|---|
| | ធនាគារ ធ្វើអន្តរកម្មល្អប្រសើរ បរិយាប័ន្នហិរញ្ញវត្ថុច្រើនជាងមុន។<br>-កម្រិតផលិតភាពខ្ពស់ជាងមុន (កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងគ្រប់វិស័យ) ការផ្លាស់ប្តូរចទនាសម្ព័ន្ធតាមរយៈការវិនិយោគ ផ្ទេរ និងទទួលយកបច្ចេកវិទ្យានិងកសាងជំនាញ/ ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។<br>-ការពង្រីកធុរកិច្ច តាមរយៈការបញ្ចប់ការធ្វើសមាហរណកម្មទៅក្នុងសមាគមសេដ្ឋកិច្ចអាស៊ាន រៀបចំដំណើរការសម្រាប់ការចាកចេញពីស្ថានភាពនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច។<br>-គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ត្រូវបានអនុវត្ត លំហូរការវិនិយោគផ្ទាល់ពីបរទេសដែលរក្សាបាននៅក្នុងកម្រិតពីឆ្នាំកន្លងទៅ បានជំរុញឲ្យអនុម័តបច្ចេកវិទ្យាបដិវត្តន៍ឧស្សាហកម្មទី៤។<br>-គោលនយោបាយស្រូវ និងការអភិវឌ្ឍជនបទ បានអនុវត្ត ផលិតកម្មស្រូវបានបង្កើន ហើយតម្លៃបន្ថែមខ្ពស់ត្រូវបានធានា បានវិនិយោគបន្ថែមទៀតលើ ហេដ្ឋារចនាសម្ព័ន្ធ (ប្រព័ន្ធធារាសាស្ត្រ ការដឹកជញ្ជូន អគ្គិសនី និងទឹក)<br>-មូលដ្ឋានការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមុខជំនាញត្រូវបានធ្វើឲ្យប្រសើរឡើង រួមទាំងការសិក្សានៅកម្រិតមធ្យមសិក្សា។<br>-ការកែទម្រង់ការគាំពារសង្គម បានអនុវត្តដោយគ្របដណ្តប់ លើវដ្តជីវិតសំខាន់ៗ ការធ្វើឲ្យមានភាពផ្លូវការកាន់តែខ្លាំងឡើង នៃទីផ្សារការងារ ។<br>-សហគ្រាសធុនតូចនិងមធ្យមគាំទ្រដោយរដ្ឋនិងធនាគារពាណិជ្ជ ហើយសហគ្រិនភាពគាំទ្រដោយជំនាញ និងកិច្ចខិតខំប្រឹងប្រែងជំរុញល្បឿន។<br>-បង្កើនការប្រើប្រាស់ ភាពជាដៃគូរវាងវិស័យសាធារណៈនិងផ្នែកឯកជន នៅក្នុងវិស័យសំខាន់ៗ ។<br>-តំបន់ព្រៃការពារចំនួន២៣ ត្រូវបានធានាប្រកបដោយសុវត្ថិភាព ហើយធនធានធម្មជាតិ/រ៉ែធម្មជាតិ មានចីរភាព ផ្តល់ការគ្រប់គ្រងទឹកនិងជលផល។<br>-ការរួមចំណែករបស់កម្ពុជាចំពោះការកំណត់ការបំភាយផ្ទះកញ្ចក់ ត្រូវបានអនុវត្ត។<br>-គោលនយោបាយគ្រប់គ្រងតំបន់ទីប្រជុំជនត្រូវបានអនុវត្ត និងបានបញ្ចូលជាមួយគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។ |
| សកម្មភាព ដំណើរការ និង ធាតុចូល | បញ្ចូលក្នុងជំពូកទី៤ និងនៅក្រោមការគោរពគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។<br>(**បញ្ជាក់៖** ត្រូវបន្ថែមនិងពន្យល់ពីគោលនយោបាយនិងគោលដៅរបស់អន្តរក្រសួងដែលបានឯកភាព នៅជំពូកទី៤ ប៉ុន្តែគោលនយោបាយសំខាន់ៗ ដែលបានយោង មានខាងក្រោម។) |

៣.៣៣ ជំពូកទី៤ កំណត់ចេញនូវកម្មវិធីពេញលេញរបស់ ស្ថាប័នកណ្តាលនិងអន្តរក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយនិងគោលដៅប្រតិបត្តិការរបស់ស្ថាប័នទាំងនេះនៅក្នុងអាណត្តិកាលថ្មី។ ខណៈពេលដែលតារាងខាងលើភ្ជាប់ទៅនឹងគោលបំណងរបស់យុទ្ធសាស្ត្រចតុកោណ តារាងនេះ ក៏មានសារសំខាន់ផងដែរនៅក្នុងជំពូកនេះ ដើម្បីទទួលស្គាល់ថា យុទ្ធសាស្ត្រសំខាន់ៗមួយចំនួនគ្រប់គ្រងដោយក្រសួង ស្ថាប័ន មានផលប៉ះពាល់នៅកម្រិតជាតិ និងដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតលទ្ធផលសេដ្ឋកិច្ច។ ការសម្របសម្រួលជាទូទៅ និងការតាមដានត្រួតពិនិត្យ មានសារសំខាន់ណាស់សម្រាប់យុទ្ធសាស្ត្រចតុកោណ និង ផ.យ.អ.ជ ហើយចំណុចនេះ នឹងត្រូវគូសបញ្ជាក់បន្ថែមនៅក្នុងការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៅក្នុងជំពូកទី៦។ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះ រួមទាំងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលត្រួតពិនិត្យដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គោលនយោបាយស្រូវអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហគ្រិន

ភាពនិងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម អនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានបទពាក់ព័ន្ធនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ពិនិត្យមើលដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការដែលពិនិត្យមើលដោយក្រសួងមហាផ្ទៃ ។

# គោលដៅ គោលនយោបាយ និងសកម្មភាព ម៉ាក្រូសេដ្ឋកិច្ច

## ការកែទម្រង់ គោលនយោបាយសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៣.៣៤ នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីពង្រឹងនូវបុរេលក្ខខណ្ឌចាំបាច់នានា និងបរិស្ថានគាំទ្រ ការកែទម្រង់ស៊ីជម្រៅរបស់កម្ពុជា សម្រាប់បន្តបេសកកម្មរបស់ខ្លួន និងក្នុងទិសដៅសម្រេចឲ្យបានពេញលេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសសម្រេចចក្ខុវិស័យប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។

៣.៣៥ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៤-២០២៥ ជាកម្មវិធីកែទម្រង់ដ៏ធំមួយរបស់រាជរដ្ឋាភិបាល ដើម្បីកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឲ្យស្របតាមឧត្តមានុវត្តអន្តរជាតិក្នុងការគ្រប់គ្រងធនធានដែលកៀរគរ និងប្រែក្លាយប្រព័ន្ធថវិកាឲ្យទៅជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ត្រូវបានបែងចែកជា០៤ ដំណាក់កាលច្បាស់លាស់រួមមាន ដំណាក់កាលទី១ (ឆ្នាំ២០០៤-២០០៨)៖ ការបង្កើនភាពជឿទុកចិត្តនៃថវិកា ដែលផ្តោតអាទិភាពលើការពង្រឹងការប្រមូល និងគ្រប់គ្រងចំណូល, ការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា ដំណាក់កាលទី២ (ឆ្នាំ២០០៩-២០១៥)៖ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលផ្តោតជាសំខាន់លើការពង្រឹងការធ្វើរបាយការណ៍គណនេយ្យ ដំណាក់កាលទី៣ (ឆ្នាំ២០១៦-២០២០)៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលផ្តោតលើការបង្កើតនិងកែលម្អការតភ្ជាប់រវាងថវិកា និងគោលនយោបាយ និងដំណាក់កាលទី៤ (ឆ្នាំ២០២១-២០២៥)៖ ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម ហើយនឹងត្រូវបន្តពង្រឹងបន្ថែមការកែទម្រង់លើដំណាក់កាលបីមុនទៀតផងដែរ ។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់កាលទី៣ របស់ខ្លួនប្រកបដោយភាពជោគជ័យ ដែលគ្រោងនឹងបញ្ចប់ត្រឹមឆ្នាំ២០២០ និងចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ នៅឆ្នាំ២០២១។

៣.៣៦ ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំដាក់ចេញ និងអនុវត្តនូវ៖

(ក)- **ផ្នែកចំណូល៖ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** នឹងប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឲ្យមានលក្ខណៈទំនើប ដើម្បីជំរុញការប្រមូលចំណូលជាតិឆ្លើយតបនឹងតម្រូវការ

អភិវឌ្ឍន៍ ដោយឈរលើគោលការណ៍យុត្តិធម៌ក្នុងការប្រមូលចំណូល, សមធម៌រវាងអ្នកជាប់ពន្ធ, និងការគ្រប់គ្រងចំណូលតាមមធ្យោបាយទំនើបកម្មរដ្ឋបាលប្រមូលចំណូល។ វិធានការនៃយុទ្ធសាស្ត្រនឹងសង្កត់ធ្ងន់ទៅលើវិធានការ ផ្នែកគោលនយោបាយ និងវិធានការផ្នែករដ្ឋបាល៖

**វិធានការផ្នែកគោលនយោបាយ៖**

- បន្តធានាប្រសិទ្ធភាពការប្រមូលចំណូល និងកំណត់គោលដៅប្រមូលចំណូលចរន្តសរុបឲ្យកើនបានយ៉ាងតិចបំផុត០,៣ពិន្ទុភាគរយនៃ ផ.ស.ស. ។
- ធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ តាមរយៈការធ្វើវិចារណកម្មគោលនយោបាយ ដោយពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធបច្ចុប្បន្ន ដោយឈរលើគោលការណ៍សាមញ្ញភាព តម្លាភាព ភាពប្រាកដប្រជា សមធម៌ និងប្រសិទ្ធភាព ។
- ពង្រឹងវិធានការគោលនយោបាយសារពើពន្ធសំខាន់ៗរួមមាន៖ ១. ការពិនិត្យឡើងវិញនូវអត្រា អាករពិសេស និងមូលដ្ឋានគិតពន្ធគយ លើយានយន្ត ផលិតផលបារី ស្រាបៀរ ស្រា និងភេសជ្ជៈ មានជាតិស្ករ, ២. ត្រួតពិនិត្យអត្រាពន្ធគយ និងអាករពិសេសលើទំនិញប្រណិត, ៣. ការពង្រឹងការប្រមូលពន្ធលើអចលនទ្រព្យ តាមរយៈការធ្វើបច្ចុប្បន្នកម្មតម្លៃអចលនទ្រព្យ និងការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យ, ៤. ធ្វើការកែសម្រួលអាករសម្រាប់បំភ្លឺសាធារណៈ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងបង្កើនប្រសិទ្ធភាពចំណូល, ៥. ការរៀបចំការអនុវត្តពន្ធលើចំណូលបុគ្គលគ្រប់ជ្រុងជ្រោយ, និង ៦. ការពង្រឹងការប្រមូលពន្ធលើអាជីវកម្មក្នុងបរិវេណកាស៊ីណូ។

**វិធានការផ្នែករដ្ឋបាល៖**

- ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ តាមរយៈកសាង និងពង្រឹងសមត្ថភាពរដ្ឋបាលសារពើពន្ធ ឲ្យឆ្លើយតបទាន់ពេលវេលាទៅនឹងការផ្លាស់ប្តូរបរិយាកាសធុរកិច្ច និងឥរិយាបថអ្នកបង់ពន្ធ ព្រមទាំងធានាការសម្រេចគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។
- ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលពន្ធដារ ដែលនឹងចូលរួមលើកកម្ពស់អនុលោមភាពបង់ពន្ធដោយស្ម័គ្រចិត្តរបស់អ្នកជាប់ពន្ធ មានដូចជា៖ ១. ការរៀបចំផែនការពង្រឹងភាពជាម្ចាស់នៃមុខងារប្រតិបត្តិការស្នូលរបស់នាយកដ្ឋាន និងសាខាខេត្ត ខណ្ឌ, ២. ការរៀបចំ និងប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មាន និងទិន្នន័យបែបអេឡិចត្រូនិកនៅគ្រប់នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ, ៣. ការរៀបចំផែនការលើកកម្ពស់អនុលោមភាពគ្រប់ជ្រុងជ្រោយ ដែលរួមបញ្ចូលយុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីការពង្រឹងគុណភាពសេវាកម្មអ្នកបង់ពន្ធ និងយុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីការពង្រឹងសុក្រឹតភាពនៃការងារសវនកម្ម, ៤. ការអនុវត្តវិធីសាស្ត្រសវនកម្មដែលផ្អែកលើហានិភ័យ និងការធ្វើសេចក្តីសម្រេចចិត្តផ្អែក

លើកម្រិតហានិភ័យអ្នកបង់ពន្ធ ៥. ការពង្រឹងក្រមសីលធម៌ វិជ្ជាជីវៈ និងសមត្ថភាពមន្ត្រី តាមរយៈការបណ្តុះបណ្តាល និងប្រព័ន្ធគ្រប់គ្រងសមិទ្ធផលការងារ និង ៦. ការបញ្ចប់ការកសាងផែនការមេសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

- ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលពន្ធគយ មានដូចជា៖ ១. ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ២. ការពង្រឹងសវនកម្មក្រោយបញ្ចេញទំនិញ ការបង្ការ និងបង្ក្រាបបទល្មើសពន្ធគយ ៣. ពង្រឹងអនុលោមភាពលើគ្រប់ទំនិញជាប់អាករពិសេសពិសេសប្រភេទ ទំនិញដែលជាប្រភពចំណូលខ្ពស់ និង ៤. ពង្រឹងកិច្ចសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធដើម្បីពង្រឹងយន្តការបែងចែកទិន្នន័យ និងកិច្ចសហការក្នុងការបង្ក្រាបការគេចវេសពន្ធ និងអំពើរត់ពន្ធ។
- ពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ មានដូចជា៖ ១. ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីជំរុញឱ្យការប្រមូលចំណូលមិនមែនសារពើពន្ធកាន់តែមានតម្លាភាព ច្បាស់លាស់ ទាន់ពេលវេលា និងសម្រួលដល់ការបង់ចំណូល និង ២. ការពង្រឹងការប្រមូលប្រភពចំណូលថ្មីៗដែលមានសក្តានុពល។

(ខ)- **ផ្នែកចំណាយ ៖ យុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥** មានគោលបំណងពង្រឹងវិន័យថវិកា ចាប់តាំងពីការរៀបចំផែនការរហូតដល់ការវិភាជ និងការអនុវត្តថវិកា តាមរយៈការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយអាទិភាពឱ្យបានជាអតិបរមា និងការវិភាជប្រកបដោយសនិទានកម្មជាចម្បង(ផ្អែកលើព័ត៌មានសមិទ្ធកម្ម) សំដៅសម្រេចបានគោលនយោបាយជាតិសំខាន់ៗ។ យុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ឈរលើជាតុសំខាន់ៗបី គឺ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម ក្របខ័ណ្ឌថវិការយៈពេលមធ្យម និងក្របខ័ណ្ឌសមិទ្ធកម្មរយៈពេលមធ្យម ។

- បន្តរក្សាអាទិភាព និងវិចារណកម្មគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល កសិកម្ម សហគ្រិនភាព និង សេដ្ឋកិច្ចឌីជីថល ជាដើម។
- បន្តទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ។
- បង្កើនការវិនិយោគបន្ថែមលើចំណាយវិនិយោគសាធារណៈ ដើម្បីលើកកម្ពស់ការប្រកួតប្រជែងនិងផលិតភាពសេដ្ឋកិច្ច តាមរយៈការបង្កើនផលិតភាពដោយវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ "រឹង" "សង្គម" និង "ទន់"។

- ពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្ត៖ ១. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ២. ការពង្រឹងការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ៣. ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ៤. ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និង ៥. ការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ។
- បន្តគាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ តាមរយៈការបន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី។
- បន្តជំរុញការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុរយៈពេលខ្លី និងវែង ដើម្បីបន្តរួមចំណែកក្នុងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងរាជធានី-ខេត្ត ក្រុង-ស្រុក ពិសេសកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ។

(គ)- **ផ្នែកបំណុល៖ យុទ្ធសាស្ត្រនៃការគ្រប់គ្រងបំណុល ២០១៩-២០២៣** នឹងបន្តផ្តោតលើគោលការណ៍ខ្ទឹដែលអាចទ្រទ្រង់ផលិតភាពសេដ្ឋកិច្ច ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគាំពារចីរភាពហិរញ្ញវត្ថុសាធារណៈ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងកសាងនូវទុនបម្រុងឲ្យបានរឹងមាំ ដើម្បីផ្តល់នូវទ្រនាប់ការពារដ៏មានប្រសិទ្ធភាពប្រឆាំងនឹងវិបត្តិនានា។

- ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈ ១.ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ និង ២. ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន;
- ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឲ្យបានទូលំទូលាយជាងមុន តាមរយៈ៖ ការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងទីផ្សារមូលបត្រ និង
- ពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាននិងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី៖ ១. ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ២. វិស័យធនាគារនិងហិរញ្ញវត្ថុ និង ៣. ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ការអភិវឌ្ឍគោលនយោបាយរូបិយវត្ថុ និងវិស័យហិរញ្ញវត្ថុ

៣.៣៧ ដោយសារកម្រិតដុល្លាររូបនីយកម្មខ្ពស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធររូបិយវត្ថុ មិនអាចអនុវត្តគោលនយោបាយរូបិយវត្ថុដោយឯករាជ្យឲ្យបានពេញលេញនោះទេ។ សម្រាប់រយៈពេលនេះ រាជរដ្ឋាភិបាលទទួលផលប្រយោជន៍ពីដុល្លាររូបនីយកម្មច្រើនជាងការខាតបង់ ប៉ុន្តែរដ្ឋាភិបាលនៅតែបន្តលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល និងឈានទៅជំនួសប្រាក់ដុល្លារ ក្នុងរយៈពេលវែង។ ជាងនេះទៀត ស្ថានភាពនាពេលបច្ចុប្បន្ន មានគុណសម្បត្តិច្រើន ដោយបានផ្តល់នូវយុថ្កាប្រឆាំងនឹងអតិផរណា ដែលអាចកំណត់តម្លៃទំនិញមានតម្លាភាពសម្រាប់អ្នកផលិតជៀសវាងហានិភ័យរូបិយប័ណ្ណសម្រាប់អ្នកនាំចូលនិងអ្នកនាំចេញ និងទាក់ទាញការវិនិយោគពីបរទេស។

៣.៣៨ ដូចគ្នានេះដែរ ឧបករណ៍គោលនយោបាយហិរញ្ញវត្ថុជាច្រើនត្រូវបានដាក់ឲ្យអនុវត្ត ហើយរាជរដ្ឋាភិបាលកម្ពុជា នឹងប្រើប្រាស់ឧបករណ៍ទាំងនេះ ដើម្បីបន្តគោលជំហរគាំទ្រកំណើនសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន ដើម្បីធានាឲ្យមានស្ថិរភាពថ្លៃ ព្រមទាំងផ្តល់សន្ទនីយភាពឲ្យគ្រប់គ្រាន់ដើម្បីទ្រទ្រង់តម្រូវការពាណិជ្ជកម្ម។ ការផ្គត់ផ្គង់រូបិយវត្ថុនឹងបន្តធ្វើឡើងយ៉ាងច្រើនលើសលុបជាប្រាក់ដុល្លារនិងរូបិយវត្ថុក្នុងចរាចរ ហើយរាជរដ្ឋាភិបាលនឹងបន្តផ្គត់ផ្គង់បន្ថែម តាមរយៈការបោះផ្សាយជាប្រាក់រៀល។ ធនាគារជាតិនៃកម្ពុជាបានប្តេជ្ញាចិត្តក្នុងការរក្សាអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤០០០រៀល ក្នុង១ដុល្លារ។

៣.៣៩ រាជរដ្ឋាភិបាលកម្ពុជានឹងជួយសម្រួលក្នុងការផ្គត់ផ្គង់ឥណទានដល់សេដ្ឋកិច្ចដើម្បីសម្រេចទិសដៅកំណើនសេដ្ឋកិច្ចប្រកបដោយមហិច្ឆតា។ ការផ្តល់ឥណទាននេះនឹងត្រូវបានធ្វើឡើងតាមរយៈយន្តការចំនួនបី គឺការធ្វើឲ្យប្រសើរឡើងនូវអត្រាប្រាក់សន្សំក្នុងស្រុក ការបង្កើនប្រសិទ្ធភាពអន្តរការីយកម្មហិរញ្ញវត្ថុ និងការបោះផ្សាយមូលបត្របំណុលរាជរដ្ឋាភិបាលជាប្រាក់រៀល។

៣.៤០ អត្រាសន្សំប្រចាំឆ្នាំនៅបច្ចុប្បន្ននេះ មានកម្រិតប្រហែល ២៥% នៃផ.ស.ស។ ក្នុងអំឡុងនៃវដ្តផែនការ រាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមរក្សាអត្រាសន្សំប្រចាំឆ្នាំឲ្យមានកំណើនរហូតដល់ ៣០%។ គន្លឹះសំខាន់នៃការងារនេះ គឺកិច្ចខិតខំប្រឹងប្រែងនាំយកប្រជាពលរដ្ឋដែលបានរក្សាទ្រព្យសម្បត្តិក្នុងទម្រង់ជាមាស សាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀត ឲ្យចូលក្នុងប្រព័ន្ធធនាគារ ខណៈដែលបច្ចុប្បន្ននេះប្រជាពលរដ្ឋមិនទាន់បានប្រើប្រាស់ប្រព័ន្ធធនាគារនៅឡើយ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងខិតខំប្រឹងប្រែងជំរុញឲ្យមានការប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែងាយស្រួល សម្រាប់ប្រជាជនខ្មែរដែលធ្វើការនៅក្រៅប្រទេសក្នុងការផ្ញើប្រាក់ចំណូលមកឲ្យសមាជិកគ្រួសារនៅ ក្នុងស្រុក។

៣.៤១ រដ្ឋាភិបាលកម្ពុជា នឹងធ្វើឲ្យអន្តរការីយកម្មហិរញ្ញវត្ថុរវាងម្ចាស់ប្រាក់បញ្ញើនិងអ្នកផ្តល់ប្រាក់កម្ចីឲ្យកាន់តែមានភាពប្រសើរឡើងនិងងាយស្រួល តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងប្រព័ន្ធហិរញ្ញវត្ថុដែលមានសុវត្ថិភាព ហើយមានភាពសម្បូរបែបដែលអាចឲ្យប្រជាពលរដ្ឋនិងធុរកិច្ចទាំងអស់ធ្វើការសន្សំបំពេញតម្រូវការខ្ចីប្រាក់របស់គេនិងទទួលបានផលិតផលហិរញ្ញវត្ថុ។ ផ្នែកផ្គត់ផ្គង់កិច្ចខិតខំប្រឹងប្រែងនឹងរួមបញ្ចូលការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដែលពឹងផ្អែកលើទីផ្សារដែលមានលក្ខណៈ ពិពិធកម្មនិងបរិយាប័ន្ន និង ការកត់សំគាល់ពីសារៈសំខាន់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងផលិតផលរបស់គ្រឹះស្ថាននេះ។ ដូចគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការពង្រឹងប្រព័ន្ធទូទាត់ និងប្រព័ន្ធផាត់ទាត់ ដោយជំរុញឲ្យមានប្រព័ន្ធរួម និងឲ្យមានកំណើននៃការផ្តល់ម៉ាស៊ីនអេធីអឹម និងសេវាធនាគារចល័ត/បណ្តាញតាមអ៊ីនធឺណិតបន្ថែមទៀត។ ដូចគ្នានេះដែរ នៅលើផ្នែកតម្រូវការ ការកសាងមូលដ្ឋានអតិថិជនតាមរយៈការលើកកម្ពស់ការជឿទុកចិត្ត និងបរិយាប័ន្នហិរញ្ញវត្ថុបន្ថែមតាមរយៈគំនិតផ្តួចផ្តើមដើម្បីជួយជំរុញប្រជាជនដែលមិនប្រើប្រាស់ប្រព័ន្ធធនាគារនាពេលបច្ចុប្បន្នអោយប្រើប្រាស់សេវាធនាគារ។

៣.៤២ លើសពីនេះទៅទៀត ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ ដែលមានស្រាប់ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តលើកកម្ពស់សុវត្ថិភាពប្រព័ន្ធធនាគារ (កសាងភាពរឹងមាំតាមរយៈការពង្រឹងការត្រួតពិនិត្យនិងបទប្បញ្ញត្តិ) តាមរយៈការធានាឲ្យបានគ្រប់គ្រាន់នូវទុនបម្រុងធនាគារ និងទុនបម្រុងអន្តរជាតិដើម្បីទប់ទល់នឹងភាពតានតឹងនិងវិបត្តិនានា។ ការណ៍នេះនឹងត្រូវបានរៀបចំ និងតាមដានដោយធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងការសម្រួលនៃការប្រកួតប្រជែង តម្លាភាព និងការច្នៃប្រឌិតនៅក្នុងទីផ្សារហិរញ្ញវត្ថុ។

៣.៤៣ រាជរដ្ឋាភិបាលកម្ពុជាក៏នឹងបន្តស្វែងរកការអភិវឌ្ឍទីផ្សារធានារ៉ាប់រងក្នុងស្រុកថែមទៀត ដើម្បីឲ្យធុរកិច្ចនិងប្រជាជនអាចទប់ទល់នឹងហានិភ័យ។ ការងារនេះ ត្រូវស្របជាមួយនឹងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមទំនើប ដោយជួយសម្រួលដល់ការសន្សំតាមរយៈមូលនិធិធានារ៉ាប់រងសង្គមឯករាជ្យ ដែលផ្តល់ជូនសម្រាប់បុគ្គលិកក្នុងវិស័យផ្លូវការ និងដោយផ្តល់ការគាំទ្រជំនួយផ្នែកសង្គមសម្រាប់ប្រជាជនក្រីក្រនិងជនរងគ្រោះ។

៣.៤៤ រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តវិធានការជាក់លាក់ដូចខាងក្រោម៖

## (ក) ការគ្រប់គ្រងសាច់ប្រាក់

- ថែរក្សាស្ថិរភាពតម្លៃ និងស្ថិរភាពហិរញ្ញវត្ថុ ខណៈពេលជំរុញកំណើនសេដ្ឋកិច្ច រក្សាអត្រាប្តូរប្រាក់មួយដុល្លារអាមេរិក ចំនួន៤ ០០០រៀល និងការគ្រប់គ្រងរូបិយប័ណ្ណដែលកំពុងចរាចរក្នុងសេដ្ឋកិច្ច។
- ការពារនិងបង្កើតទុនបម្រុងដុល្លារអាមេរិក ស្របតាមសកម្មភាពសេដ្ឋកិច្ច ធានាថាត្រូវការតម្រូវការហិរញ្ញប្បទាននិងដើមទុន ត្រូវបានផ្តល់ជានិច្ច។

- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល តាមរយៈការបង្កើតគោលនយោបាយជាតិ ដែលកំណត់ដោយក្រុមការងារផ្សេងៗផ្អែកតាមជម្រើសទីផ្សារ សេវាថ្មី និងឧបករណ៍ផ្សេងៗ។ ធានាគារជាតិនៃកម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការវិនិយោគដោយប្រាក់រៀល ដូចជាបណ្ណរតនាគារ និងមូលប័ត្របំណុល។

## (ខ) វិស័យធនាគារ

- ពង្រឹងសមត្ថភាពរបស់អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធផ្តល់ដំណឹងជាមុន និងតម្រូវឲ្យស្ថាប័នហិរញ្ញវត្ថុផ្តល់ទិន្នន័យនិងព័ត៌មានចាំបាច់និងទាន់ពេលវេលា។
- បង្កើតគណៈកម្មាធិការជាតិស្តីពីស្ថិរភាពហិរញ្ញវត្ថុ ដើម្បីផ្តល់នូវក្របខ័ណ្ឌស្ថាប័នគ្រប់ជ្រុងជ្រោយមួយ សម្រាប់ត្រួតពិនិត្យស្ថិរភាពហិរញ្ញវត្ថុ។
- កែលម្អការត្រៀមរៀបចំសម្រាប់វិបត្តិ រួមទាំងការបង្កើតក្របខ័ណ្ឌសហប្រតិបត្តិស្ថាប័នផែនការបង្ការគ្រោះមហន្តរាយថ្នាក់ជាតិ រួមជាមួយផែនការត្រៀមបម្រុងរបស់ភ្នាក់ងារ។
- ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានគាំទ្រដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំសំណើសម្រាប់គម្រោងការពារប្រាក់បញ្ញើ ជាពិសេសសម្រាប់អ្នកដាក់ប្រាក់បញ្ញើតូចតាច។
- បង្កើតឡើងនូវរបបដោះស្រាយពិសេសមួយដោយផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវជម្រើសជំនួសតម្លៃតិចតួចសម្រាប់ដោះស្រាយភាពទន់ខ្សោយរបស់ធនាគារ។
- អនុវត្តតាមស្តង់ដាបាហ្សែលទី២ ផ្លាស់ប្តូរទៅតាមការអនុលោមពេញលេញជាមួយគោលការណ៍ស្នូលចំនួន២៩ ស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពដោយផ្តោតលើដំណើរការគ្រប់គ្រងហានិភ័យនិងការគ្រប់គ្រងរួម។
- ពិនិត្យឡើងវិញលើបទបញ្ញាស្តីពីសន្ទស្សន៍នៃការសន្សំនិងសកម្មភាពកែតម្រូវភ្លាមៗ។
- លើកកម្ពស់វិធីសាស្ត្រត្រួតពិនិត្យរបស់ខ្លួន ឆ្ពោះទៅរកការប្រថុយប្រថាននិងសម្លឹងមើលឆ្ពោះទៅមុខ និងបង្កើនកម្រិតសមត្ថភាពបុគ្គលិក (តាមរយៈការយកចិត្តទុកដាក់និងបច្ចេកវិជ្ជាព័ត៌មានមិនទាន់សម័យ)។
- កែលម្អការពិនិត្យមើលការលាងលុយកខ្វក់និងហិរញ្ញប្បទានភេរវកម្ម និង ធនាគារជាតិនៃកម្ពុជានិង CAFIU ការបង្កើនការយល់ដឹងក្នុងចំណោមធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- កែលម្អការចេញបណ្ណកម្មសិទ្ធិអចលនទ្រព្យនិងកាត់បន្ថយការចំណាយ និងបើកភាពជាម្ចាស់កម្មសិទ្ធិលើចំណែកសហជីពដែលត្រូវបានសន្យា។
- ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តដំណើរការចុះបញ្ជីអចលនទ្រព្យ នៅពេលខ្ចីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ។

- ពិនិត្យឡើងវិញពីបំណងប្រាថ្នានៃការពង្រីកការការពារអតិថិជនរបស់ធនាគារ ដោយកំណត់នូវតម្រូវការសម្រាប់ផលិតផលកម្ចី ការផ្សព្វផ្សាយនិងសម្ភារៈផ្សព្វផ្សាយ នីតិវិធីពាក្យបណ្តឹង កម្រៃសេវា ការគណនាអត្រាការប្រាក់ និងការអនុវត្តការប្រមូលប្រាក់។

## (គ) មីក្រូហិរញ្ញវត្ថុ

- ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រវិស័យមីក្រូហិរញ្ញវត្ថុ និងបង្កើតយុទ្ធសាស្ត្រថ្មីមួយសម្រាប់ការដាក់បរិយាប័ន្នហិរញ្ញវត្ថុ។
- អនុលោមតាមការលើកកម្ពស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាមួយនឹងគោលការណ៍មូលដ្ឋាននៃគណៈកម្មាធិការបាសែល ផ្តោតការយកចិត្តទុកដាក់លើការត្រួតពិនិត្យនិងបទបញ្ញា ការផ្លាស់ប្តូរកម្រិតនៃការអនុវត្តជាមួយនឹងធនាគារ។
- ពង្រឹងការអនុវត្តច្បាប់ ដោយចាត់វិធានការយ៉ាងតឹងរ៉ឹងប្រឆាំងនឹងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលមិនបានចុះបញ្ជីនិងអ្នកដែលប្រតិបត្តិការខុសច្បាប់។
- លើកកម្ពស់អក្ខរកម្មផ្នែកហិរញ្ញវត្ថុ តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ជាពិសេស នៅតាមជនបទ រួមបញ្ចូលទាំងកម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុ នៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ និងលើកកម្ពស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។
- ស្វែងរកប្រភពមូលនិធិការចំណាយទាប និងសិក្សាអំពីកត្តានានាដែលរួមចំណែកដល់ការចំណាយខ្ចីបុលរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងស្វែងរកវិធីសាស្ត្រនានាដើម្បីកាត់បន្ថយអត្រាការប្រាក់តាមរយៈយន្តការទីផ្សារ។
- កាត់បន្ថយសកម្មភាពធនាគារស្រមោល តាមរយៈការពង្រឹងទិន្នន័យនិងការប្រមូលព័ត៌មាននិងចាត់វិធានការច្បាប់។
- ដូចវិស័យធនាគារ ពិនិត្យឡើងវិញលើគោលបំណងនៃការពង្រីកការការពារអតិថិជន (នៅក្នុងវិស័យធនាគារដូចគ្នា) និងលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឲ្យអនុវត្តការការពារអតិថិជនដោយខ្លួនឯង តាមរយៈយុទ្ធនាការស្មាត។

## (ឃ) កាធានារ៉ាប់រង និងសន្តិសុខសង្គម

- ចាត់វិធានការដើម្បីបង្កើនចំណេះដឹង/ទំនុកចិត្តលើផលិតផលធានារ៉ាប់រង តាមរយៈការផ្សព្វផ្សាយព័ត៌មាននិងការយល់ដឹង និងចាត់វិធានការដើម្បីគ្រប់គ្រងទីផ្សារ។
- ពង្រឹងការគ្រប់គ្រងការលក់ធានារ៉ាប់រងតាមរយៈអេឡិចត្រូនិក/ទូរគមនាគមន៍(ឈ្មួញកណ្តាល) តាមរយៈការបង្កើតក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត។

- លើកកម្ពស់ការបង្កើតឈ្មួញកណ្ដាលធានារ៉ាប់រង យន្តការត្រួតពិនិត្យនិងសក្ដានុពលការផ្ដល់អាជ្ញាបណ្ណ/វិញ្ញាបនបត្ររបស់ឈ្មួញកណ្ដាល និងបើកកម្មវិធីបណ្ដុះបណ្ដាលនិងទទួលស្គាល់វិជ្ជាជីវៈធានារ៉ាប់រង។
- ធ្វើប្រតិបត្តិការក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម តាមរយៈ សាខាពីរ៖
  - *ការធានារ៉ាប់រងសង្គមៈ* បង្កើតគម្រោងសន្តិសុខសង្គមថ្មី និងពង្រីកការគ្របដណ្ដប់លើគម្រោងដែលមានស្រាប់សម្រាប់ប្រាក់សោធននិងការថែទាំសុខភាព និងពេលក្រោយសម្រាប់អ្នកគ្មានការងារធ្វើ។ បង្កើតស្ថាប័ននិយតម្មមួយសម្រាប់ត្រួតពិនិត្យលើមូលនិធិជាតិសន្តិសុខសង្គម រួមបញ្ចូលទាំងមូលនិធិជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ មូលនិធិជាតិសម្រាប់អតីតយុទ្ធជន។
  - *ជំនួយសង្គមៈ* ផ្ដួចផ្ដើមគម្រោងជំនួយសង្គម អនុវត្តជាដំណាក់កាលៗ សម្រាប់ប្រជាជនក្រីក្រនិងជនងាយរងគ្រោះ ដោយចាប់ផ្ដើមពីការសម្រាលកូនចាប់ពីពាក់កណ្ដាលឆ្នាំ២០១៩ និងក្រោយមក កម្មវិធីអាហារូបករណ៍និងការផ្ដល់អាហារនៅសាលារៀន ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រាក់សោធនដល់ជនចាស់ជរា ការថែទាំសុខភាពសម្រាប់ជនពិការ។ កំណត់ការរៀបចំថវិកាដើម្បីធានាហិរញ្ញវត្ថុបរិយាប័ន្ន។
- សម្រាប់ទាំងការធានារ៉ាប់រងសង្គម និងជំនួយសង្គមៈ ភ្ជាប់ទៅប្រព័ន្ធនៃការចុះបញ្ជីនិងការកំណត់អត្តសញ្ញាណជាតិ ប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងផ្ដល់ការចុះបញ្ជីប្រតិបត្តិករដើម្បីបង្កើនប្រសិទ្ធភាព

## (ង) ទីផ្សារភាគហ៊ុន និងផ្សេងទៀត

- បន្តអភិវឌ្ឍផ្សារហ៊ុនតាមរយៈ ការលើកកម្ពស់ការចុះបញ្ជីថ្នាក់ជាតិ និងការចេញបណ្ណភាគហ៊ុនសាធារណៈ។
- វាយតម្លៃវឌ្ឍនភាពនៃការបង្កើតអនាគតទីផ្សារទំនិញ និងវាយតម្លៃលក្ខខណ្ឌនិងករណីធុរកិច្ច និងរកដៃគូដើម្បីបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ។
- បង្កើតគណៈកម្មាធិការជាតិសម្រាប់ស្ថិតិហិរញ្ញវត្ថុ និងស្ថាប័នសម្រាប់ការវាយតម្លៃឥណទាន ក្នុងការបង្កើតយន្តការ/ឧបករណ៍គ្រប់គ្រងហានិភ័យសំខាន់ៗ ។
- រៀបចំច្បាប់ថ្មីស្ដីពី កិច្ចការសាជីវកម្ម អភិបាលកិច្ច និងការទទួលខុសត្រូវ។
- រៀបចំបទបញ្ញាស្ដីពីការប្រើប្រាស់បច្ចេកវិទ្យា នៅក្នុងមូលបត្រជួញដូរនិងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- បង្កើតក្រុមការងារដើម្បីបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម ត្រួតពិនិត្យ/អភិបាលកិច្ច រៀបចំសេចក្ដីព្រាងមាត្រានៃសមាគម ផែនការអាជីវកម្ម ជ្រើសរើសជំនួយបច្ចេកទេស។

## ៣.៤ ទស្សនវិស័យសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣

៣.៤៥ ផ្នែកចុងក្រោយនេះ ពិនិត្យមើលពីវដ្តនៃ **ផ.យ.អ.ជ. ២០១៩-២០២៣** ដែលបង្ហាញពីការព្យាករស្ថានភាពសេដ្ឋកិច្ច តម្រូវការវិនិយោគជាទូទៅ និងស្ថានភាពសារពើពន្ធនិងថវិកា (ឆ្នាំ ២០២១)។

### ចំហាក (សេណារីយ៉ូ) ម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅខាងមុខ

៣.៤៦ វដ្តនៃផែនការថ្មីនេះ ចាប់ផ្តើមពីដំណាក់កាលនៃការប្រែបាច់បញ្ចូលគ្នាឆ្ពោះទៅការបង្កើនល្បឿន។ ផែនការរាស់វែងថ្មីនេះចាប់ផ្តើមពីដំណាក់កាលនៃការបង្រួបបង្រួមទៅរកការពន្លឿន ដែលជាវិធានការដែលដាក់ឲ្យអនុវត្តដោយរដ្ឋាភិបាលដើម្បីជំរុញកំណើនសេដ្ឋកិច្ចឆ្ពោះទៅសម្រេចគោលបំណងរយៈពេលវែង គឺសម្រេចឲ្យក្លាយទៅជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដោយរំលឹកឡើងវិញថា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើនផលិតភាព និងការប្រកួតប្រជែង ហើយផ្តល់នូវការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។

៣.៤៧ ទិន្នន័យដែលបានធ្វើចំណោល សម្រាប់ចំហាក(សេណារីយ៉ូ) ម៉ាក្រូសេដ្ឋកិច្ចទៅមុខ ត្រូវបានផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រហូតដល់ឆ្នាំ២០២៣ ហើយទិន្នន័យទាំងនេះមានផ្តល់ជូននៅក្នុងតារាងដូចខាងក្រោម។ ជាទូទៅ ទិន្នន័យបង្ហាញថា សេដ្ឋកិច្ចមានកំណើន៧,៥% នៅក្នុងឆ្នាំ២០១៨ និង៧,០% នៅក្នុងឆ្នាំ២០២១(តារាង ៣,៥) ហើយនិន្នាការនេះ ត្រូវបានរំពឹងថា នឹងបន្តនៅក្រោយឆ្នាំ២០២១។ សម្រាប់បណ្តាឆ្នាំដែលបានព្យាករ ការវិនិយោគនៅតែរក្សាបានក្នុងកម្រិតប្រហែល២៨% នៃផ.ស.ស. (តារាង ៣.៥)។ ទោះជាដូចនេះក្តី តារាង ៣.៦ បង្ហាញថា ការរួមចំណែកដល់កំណើនសេដ្ឋកិច្ច កើតឡើងតាមរយៈការកើនឡើងនៃសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់(ជាពិសេសវិស័យឧស្សាហកម្ម)។ ទន្ទឹមនេះ សេដ្ឋកិច្ចក៏នៅមានតុល្យភាពផ្ទៃក្នុងផងដែរ ដោយយោងតាមទិន្នន័យដែលបានព្យាករណ៍ អត្រាអតិផរណា នឹងមានស្ថិរភាពក្នុងកម្រិតប្រមាណ៣% ហើយឱនភាពថវិកាក្នុងកម្រិត៣,៥% នាពេលបច្ចុប្បន្ន នឹងថមថយដល់៣,០% នៃផ.ស.ស. នៅឆ្នាំ២០២៣។ ចំពោះតុល្យភាពខាងក្រៅ ឱនភាពគណនីចរន្តនឹងមានភាពល្អប្រសើរពីកម្រិត៨,០% ទៅ១១,៣% នៃផ.ស.ស. ដែលឆ្លុះបញ្ចាំងពីការប្រសើរឡើងនៃការធ្វើធុរកិច្ច។ ដោយសន្មតថា កម្រិតនាពេលបច្ចុប្បន្ននៃលំហូរមូលធនកើនឡើង ទុនបម្រុងនឹងអាចធានាបានក្នុងរង្វង់៥,៥ ខែនៃការនាំចូល។

៣.៤៨ ការពិនិត្យឡើងវិញនៃសក្តានុពលខាងក្នុងនិងខាងក្រៅនាពេលបច្ចុប្បន្នបញ្ជាក់ថា ការព្យាករទាំងនេះមានលក្ខណៈសមស្រប ទៅនឹងការអនុវត្តដែលបានឃើញជាក់ស្តែងប៉ុន្មានឆ្នាំ

ចុងក្រោយ។ ប៉ុន្តែខណៈពេលដែលព្រឹត្តិការណ៍សេដ្ឋកិច្ចសកលលោក កាន់តែមាននិន្នាការបើកចំហតូច អាចមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ដល់ប្រទេសកម្ពុជា។ បញ្ហាសំខាន់បំផុតនោះគឺអាចបណ្តាលមកពី ជម្លោះពាណិជ្ជកម្មពិភពលោក ដែលផ្តោតលើទំនាក់ទំនងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក ជាមួយចិន សហភាពអឺរ៉ុប និងប្រទេសផ្សេងទៀត។ ដូចគ្នានេះដែរ ប្រទេសកម្ពុជាក៏ប្រឈមមុខនឹងការរំខានដល់ការងារធុរកិច្ច និងការបាត់បង់នូវការអនុគ្រោះផ្នែកពាណិជ្ជកម្ម ដែលបានផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ដល់ការនាំចេញទៅកាន់ទីផ្សាររបស់សហភាពអឺរ៉ុប និងអាមេរិក ហើយការអនុគ្រោះទាំងនេះ ដែលកម្ពុជាទទួលបានក្នុងឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួច ត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិ។ ការបាត់បង់នូវការអនុគ្រោះនេះ ក៏ជាកត្តារាំងមួយដល់ប្រទេសកម្ពុជាដើម្បីក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ ផងដែរ។

### តារាងទី ៣.៥ សង្ខេប ចំហាក ម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅឆ្នាំ២០២៣

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| **ធាតុចេញ** | | | | | | |
| ផ.ស.ស. តម្លៃបច្ចុប្បន្ន (លានដុល្លារអាមេរិក) | ២៤ ៣៧៤ | ២៦ ៧៨៦ | ២៩ ៣៦២ | ៣២ ២៩៣ | ៣៥ ៥៦២ | ៣៩ ១៩២ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក) | ១ ៥៤៨ | ១ ៦៧៩ | ១ ៨១៦ | ១ ៩៧២ | ២ ១៤៤ | ២ ៣៣៥ |
| អត្រាកំណើនពិត នៃ ផសស (%) | ៧,៥ | ៧,១ | ៦,៥ | ៧,០ | ៧,០ | ៧,០ |
| **ការវិនិយោគ និងការសន្សំ** | | | | | | |
| **ការវិនិយោគសរុប (% ផសស)** | ៣១,៤ | ៣២,៩ | ៣៤,០ | ៣៥,១ | ៣៦,៣ | ៣៥,២ |
| ការវិនិយោគសាធារណៈ(%ផ.ស.ស.) | ៨,២ | ៨,៥ | ១១,៧ | ១០,៦ | ១០,០ | ១០,១ |
| ការវិនិយោគឯកជន(%ផ.ស.ស.) | ២២,៩ | ២៤,៣ | ២៥,៤ | ២៦,៤ | ២៧,៥ | ២៦,៨ |
| សញ្ជ័យជាតិ *(សន្សំ)*(% ផ.ស.ស.) | ២០,២ | ២៣,៤ | ២៤,៧ | ២៦,៣ | ២៨,០ | ២៧,៥ |
| សញ្ជ័យក្រៅប្រទេស *(សន្សំ)* (% ផ.ស.ស.) | ១១,៣ | ៩,៦ | ៩,៣ | ៨,៨ | ៨,៣ | ៧,៧ |
| **អតិផរណា និង រូបិយវត្ថុ** | | | | | | |
| អតិផរណា(ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ - %) | ២,៥ | ២,៨ | ២,៩ | ៣,០ | ៣,០ | ៣,១ |
| អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ(មធ្យមប្រចាំឆ្នាំ) | ៤ ០៥៣ | ៤ ០៥៤ | ៤ ០៥៤ | ៤ ០៥៤ | ៤ ០៥៤ | ៤ ០៥៤ |
| **ស្ថានភាពសារពើពន្ធ** | | | | | | |
| ចំណូលថវិកាសរុប(% ផ.ស.ស.) | ២២,២ | ២២,៦ | ២២,៥ | ២២,៥ | ២២,៦ | ២២,៤ |
| ចំណាយថវិកាសរុប(% ផ.ស.ស.) | ២៤,៤ | ២៥,០ | ២៨,៤ | ២៧,៦ | ២៧,៤ | ២៧,៩ |
| ឱនភាព/អតិរេកថវិកាចរន្ត(% ផ.ស.ស.) | ៥,៨ | ៦,០ | ៥,៦ | ៥,៣ | ៥,០ | ៤,៧ |
| ឱនភាព/អតិរេកថវិកាទូទៅ(% ផ.ស.ស.) | -២,២ | -២,៤ | -៥,៩ | -៥,១ | -៤,៨ | -៥,៣ |
| **ជញ្ជីងជីងទូទាត់** | | | | | | |
| ការនាំចេញទំនិញ (% ផ.ស.ស.) | ៥៣,២ | ៥៤,៨ | ៥៣,២ | ៥៣,០ | ៥២,៨ | ៥២,៥ |
| ការនាំចូលទំនិញ (% ផ.ស.ស.) | ៧៧,២ | ៧៦,៧ | ៧៥,០ | ៧៤,៥ | ៧៣,៩ | ៧៣,៥ |
| តុល្យភាពពាណិជ្ជកម្ម (% ផ.ស.ស.) | -២៤,០ | -២១,៩ | -២១,៨ | -២១,៥ | -២១,០ | -២១,០ |
| តុល្យភាពគណនីចរន្ត(% ផ.ស.ស.) | -១១,៣ | -៩,៦ | -៩,៣ | -៨,៨ | -៨,៣ | -៨,៣ |
| **ទុនបម្រុង** | | | | | | |

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ទុនបម្រុងបរទេសដុល (លានដុល្លារអាមេរិក) | ១០ ០៥២ | ១១ ៥០៥ | ១៣ ០០៧ | ១៤ ៤៨៤ | ១៥ ៩៧៣ | ១៧ ៤៥៦ |
| ទុនបម្រុងបរទេសដុល (ចំនួនខែនាំចូលទំនិញនិងសេវា) | ៥,៥ | ៥,៨ | ៦,១ | ៦,២ | ៦,២ | ៦,២ |
| | | | | | | |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣.៤៩ បើតាមព្រឹត្តិការណ៍រយៈពេលខ្លីនិងមធ្យម ស្ថានភាពពាណិជ្ជកម្មមានលក្ខណៈអវិជ្ជមាន ដូចជាការចាកចេញរបស់ចក្រភពអង់គ្លេស ពីសហភាពអឺរ៉ុប "*Brexit*" និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-សហភាពអឺរ៉ុប។ ទន្ទឹមនេះស្ថានភាពក្នុងតំបន់ក៏បានផ្តល់នូវផលវិជ្ជមានដូចជា ការធ្វើឲ្យមានលក្ខណៈស៊ីជម្រៅយឺតនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និងការផ្តួចផ្តើមនៃគម្រោងខ្សែក្រវ៉ាត់និងផ្លូវថ្នល់របស់ប្រទេសចិន។ ជាចុងក្រោយ គួរកត់សម្គាល់ផងដែរនូវភាពមិនច្បាស់លាស់ដែលកើតឡើងពីព្រឹត្តិការធម្មជាតិនិងបរិយាកាស ហើយហានិភ័យទាំងនេះនឹងត្រូវបានកើនឡើងខ្ពស់ដោយការប្រែប្រួលអាកាសធាតុដែលកំពុងបន្តកើតឡើង។

៣.៥០ បញ្ហាប្រឈមសម្រាប់កម្ពុជា និងការលំបាកក្នុងការព្យាករ គឺការផ្លាស់ប្តូរកាន់តែស៊ីជម្រៅនិងយូរអង្វែងនៅក្នុងសេដ្ឋកិច្ច។ ការផ្លាស់ប្តូរនេះបណ្តាលមកពីមូលហេតុស្មុគស្មាញច្រើនដូចជាដំណើរការសង្គមសេដ្ឋកិច្ចស៊ីជម្រៅ (ឧស្សាហូបនីយកម្ម ប្រជាសាស្ត្រ រួមទាំងការអន្តោប្រវេសន៍ និងនគរូបនីយកម្ម) និងទំនាក់ទំនងរបស់ពួកគេ ជាមួយនិន្នាការសាកល។ លើសពីនេះទៅទៀត ការលំបាកក្នុងការបង្ហាញពីផលប៉ះពាល់យូរអង្វែងដែលមានភាពច្បាស់លាស់ក្នុងកំឡុងពេលនៃផែនការនេះ ជាពិសេសទិន្នន័យដែលបានព្យាករណ៍។

## តារាងទី ៣.៦ ការព្យាករអត្រាកំណើនតាមវិស័យ ឆ្នាំ២០១៩-២០២៣

| | ២០១៨ ប៉ាន់ស្មាន | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **១,៦%** | **១,៦%** | **១,៧%** | **១,៨%** | **១,៨%** | **១,៨%** |
| ដំណាំ | ១,៩% | ១,៧% | ១,៧% | ១,៨% | ១,៨% | ១,៨% |
| ផលិតផលកសិកម្មផ្សេងៗ | ១,២% | ១,៦% | ១,៧% | ១,៨% | ១,៨% | ១,៨% |
| **ឧស្សាហកម្ម** | **១២,៣%** | **១០,៧%** | **៨,៩%** | **១០,២%** | **១០,១%** | **១០,០%** |
| កាត់ដេរ | ១០,១% | ៧,១% | ៣,៥% | ៦,២% | ៦,០% | ៦,០% |
| សំណង់ | ១៨,១% | ១៧,៣% | ១៦,១% | ១៥,៥% | ១៤,៩% | ១៤,១% |
| ឧស្សាហកម្មផ្សេងៗ | ១០,៣% | ១០,៥% | ១១,៥% | ១១,២% | ១១,៣% | ១១,៣% |
| **សេវា** | **៦,៥%** | **៦,៧%** | **៦,៤%** | **៦,៣%** | **៦,២%** | **៦,២%** |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៥,៧% | ៥,៦% | ៥,៦% | ៥,៦% | ៥,៦% | ៥,៦% |
| ពាណិជ្ជកម្ម | ៦,៦% | ៦,៨% | ៦,៨% | ៦,៨% | ៦,៩% | ៧,០% |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៨,១% | ៧,៩% | ៧,៧% | ៧,៦% | ៧,៧% | ៧,៧% |
| អចលនវត្ថុ | ៨,៩% | ៨.៨% | ៨,៥% | ៧,៩% | ៧,៥% | ៧,៣% |
| សេវាផ្សេងៗ | ៤,៥% | ៥,០% | ៤,៨% | ៤,៣% | ៤,៣% | ៤,៣% |
| ពន្ធ ដក ឧបត្ថម្ភធន | ៦,៣% | ៥,៦% | ៥,៤% | ៥,៤% | ៥,៤% | ៥,៤% |
| **(សរុប ផ.ស.ស.)** | **៧,៥%** | **៧,១%** | **៦,៥%** | **៧,០%** | **៧,០%** | **៧,០%** |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

៣.៥១ ទោះជាដូចនេះក្តី ដោយការបញ្ចូលគ្នានូវទិន្នន័យឆ្នាំកន្លងទៅ សម្រាប់សមាសភាពនៃកំណើនប្រចាំឆ្នាំ (ដូចបានពិភាក្សាក្នុងកថាខ័ណ្ឌ ៣.៥ និង ៣.៦ ខាងលើ) ជាមួយនឹងការព្យាកររហូតដល់ឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជាអាចត្រូវបានបង្ហាញថា កំពុងមានចលនាឆ្ពោះទៅរកសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។ ការព្យាករនេះ បញ្ជាក់ពីការផ្លាស់ប្តូរទៅរកសកម្មភាពឧស្សាហកម្មនិងសេវាដែលមានតម្លៃបន្ថែមខ្ពស់ ដែលត្រូវបានបង្កើតឡើងយ៉ាងល្អ និងកំពុងបន្ត។ ចំណុចគួរឲ្យចាប់អារម្មណ៍នោះគឺ ការលើកកម្ពស់នៅក្នុងវិស័យកម្មន្តសាលនិងសំណង់ផ្សេងទៀត។ ការព្យាករនេះនឹងត្រូវបានឆ្លុះបញ្ចាំងទាន់ពេលវេលាពីការផ្លាស់ប្តូរនៅក្នុងការងារ និងនៅក្នុងការបង្កើតសេដ្ឋកិច្ចជារួម។

## ការប៉ាន់ស្មានតម្រូវការវិនិយោគ សម្រាប់ ផ.យ.អ.ជ. ២០១៩-២០២៣

៣.៥២ កំណើនទូទៅនិងតាមវិស័យ ដែលបានព្យាករណ៍ខាងលើ បានបង្ហាញពីតម្រូវការអនុវត្តសំខាន់ៗរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និង ផ.យ.អ.ជ. ដើម្បីសម្រេចឲ្យបាននូវការបង្កើនល្បឿនចាំបាច់រយៈពេលវែង គោលដៅនៃប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០ និងចំណូលខ្ពស់ ឆ្នាំ២០៥០។ ម្យ៉ាងវិញទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានប៉ាន់ស្មានផងដែរពីកម្រិតនៃការវិនិយោគ ដែលជាកត្តាកំណត់សំខាន់នៃសមត្ថភាពផលិតចាំបាច់ (ដល់ឆ្នាំ២០២៣) ដើម្បីសម្រេចបាននូវអត្រាកំណើននេះ។

៣.៥៣ ការវិនិយោគសរុបសម្រាប់អាណត្តិ ផ.យ.អ.ជ. ត្រូវបានព្យាករណ៍ក្នុងទំហំ ៥៩,៩ ប៊ីលានដុល្លារអាមេរិក សមមូល ២៤៥ ៥៧៥ប៊ីលានរៀល ក្នុងនោះ ការវិនិយោគប្រចាំឆ្នាំ ត្រូវបានព្យាករណ៍ថា នឹងកើនដល់ ១៥,១ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣។

### តួនាទីរបស់សារពើពន្ធនាពេលអនាគត

៣.៥៤ **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាឧបករណ៍គោលនយោបាយមួយសម្រាប់ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្នតាមរយៈគោលនយោបាយគាំទ្រ និងលើកស្ទួយសមធម៌ និងចីរភាពក្នុងកិច្ចដំណើរការរបស់រាជរដ្ឋាភិបាល។** គោលនយោបាយនេះមានភាពចាំបាច់ក្នុងការធានាភាពជោគជ័យនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥
- គាំទ្រដល់ការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ និងមូលនិធិអភិវឌ្ឍន៍ជំនាញ
- បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំនិងគោលនយោបាយសុខាភិបាល
- គាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥

- គាំទ្រគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម តាមរយៈការផ្ដល់ការលើកទឹកចិត្ត ផ្នែកពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យម ការបង្កើតធនាគារអេសអឹមអ៊ី និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ព្រមទាំងមជ្ឈមណ្ឌលលើកកម្ពស់អភិវឌ្ឍសហគ្រិនភាព
- គាំទ្រគោលនយោបាយកែទម្រង់រចនាសម្ព័ន្ធ តាមរយៈការកែទម្រង់រដ្ឋបាលសាធារណៈ និងកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លើយតបទៅនឹងការដោះស្រាយបញ្ហារចនាសម្ព័ន្ធ ឧទាហរណ៍ ដូចជា ការសម្របសម្រួលពាណិជ្ជកម្មនិងស្វ័យប្រវត្តិកម្មឡូជីស្ទីក អគ្គិសនី ការលុបបំបាត់កម្រៃក្រៅផ្លូវការ ការបង្កើនផលិតភាព
- អភិវឌ្ឍគោលនយោបាយពន្ធជំរុញកំណើន តាមរយៈការធ្វើឲ្យប្រសើរឡើងនៃការផ្ដល់សេវាបង់ពន្ធ និងការធ្វើទំនើបកម្មរដ្ឋបាលពន្ធ
- គាំទ្រការផ្សារភ្ជាប់វិស័យកសិកម្មទៅនឹងវិស័យកម្មន្តសាល(កសិ-ឧស្សាហកម្ម) ដើម្បីបង្កើនតម្លៃបន្ថែម
- គាំទ្រការតភ្ជាប់រវាងវិស័យទាំងបីមាន៖ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ថាមពល និងឌីជីថល និង
- គាំទ្រការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សំដៅកាត់បន្ថយផលអវិជ្ជមានជាអតិបរមាមកលើកំណើនសេដ្ឋកិច្ច និងជវភាពសេដ្ឋកិច្ច ។

៣.៥៥ ដោយផ្អែកលើយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ កម្ពុជានឹងដាក់ឲ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យមក្នុងឆ្នាំ២០២១។ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម កំណត់យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ ដោយគូសរំលេចនូវទិសដៅគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងកំណត់ពិដានចំណាយតាមវិស័យ សំដៅរក្សាវិន័យថវិកា និងបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា។ ចំណែកក្របខ័ណ្ឌថវិការយៈពេលមធ្យម កំណត់ពិដានចំណាយតាមក្រសួង ស្ថាប័ន ដោយរក្សាសង្គតិភាពជាមួយពិដានចំណាយតាមវិស័យ សំដៅធានាប្រសិទ្ធភាពនៃចំណាយប្រតិបត្តិការ ។

៣.៥៦ **ក្នុងរយៈពេល៥ឆ្នាំខាងមុខ ដែលមានបរិការណ៍សុខសន្តិភាព ស្ថិរភាពនយោបាយ និងបូរណភាពទឹកដី** រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៦ បន្តផ្ដោតអាទិភាពចម្បងលើ៖ *១.* ការអភិវឌ្ឍធនធានមនុស្ស សុខុមាលភាពប្រជាពលរដ្ឋ ព្រមទាំងកិច្ចគាំពារសង្គមនិងកម្មវិធីអត្ថប្រយោជន៍សង្គមផ្សេងៗទៀត និង *២.* កិច្ចសម្របសម្រួលរវាងស្ថាប័ននិងអភិបាលកិច្ចល្អ។ ក្នុងន័យនេះ ការវិភាជចំណាយចរន្តថ្នាក់ជាតិទៅវិស័យសង្គមកិច្ច និងរដ្ឋបាលទូទៅនឹងមានកំណើនលឿនដូចគ្នា ពោលគឺខ្ពស់ជាងកំណើនផ.ស.ស ដែលធ្វើឲ្យផលធៀបនឹងផ.ស.ស កើនឡើងសន្សឹមៗ។

៣.៥៧ ចំណែក ការវិភាជចំណាយចរន្តថ្នាក់ជាតិសម្រាប់វិស័យការពារជាតិ និងសន្តិសុខសង្គម អាចនឹងមានកំណើនថមថយបន្តិច ដោយសារការរក្សាបាននូវសុខសន្តិភាព និងស្ថិរ

ភាពសង្គម ព្រមទាំងការរំពឹងទុកនៃការកែទម្រង់វិស័យយោធា និងកងកម្លាំងប្រដាប់អាវុធ។ ទន្ទឹមនេះ កំណើនចំណាយចរន្តក្នុងវិស័យសេដ្ឋកិច្ច នឹងបន្តកើនឡើងជាលំដាប់ បើទោះជាល្បឿននៃកំណើននេះ ទាបជាងកំណើនសេដ្ឋកិច្ចជារួមក៏ដោយ។ កត្តានេះបណ្តាលមកពីចរិតលក្ខណៈពិសេសនៃចំណាយក្នុងវិស័យនេះ ដែលភាគច្រើនជាចំណាយមូលធន។ បន្ថែមពីនេះ ចំណាយផ្សេងៗក៏ត្រូវបានរំពឹងថានឹងរក្សាកំណើនក្នុងអត្រាមួយសមស្របសម្រាប់អនុវត្តគោលនយោបាយក៏ដូចជាអន្តរាគមន៍ភ្លាមៗរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយនូវបញ្ហាសេដ្ឋកិច្ច សង្គមនានា ។

៣.៥៨ ក្នុងរយៈពេល៥ឆ្នាំខាងមុខ រាជរដ្ឋាភិបាលនឹងផ្តោតលើការតភ្ជាប់វិស័យចំនួន៣ គឺ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ថាមពល និងឌីជីថល តាមរយៈការបង្កើនវិនិយោគសាធារណៈសំដៅជំរុញផលិតភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែងសេដ្ឋកិច្ច។ ការវិនិយោគសាធារណៈនឹងមានកំណើនខ្ពស់ជាងកំណើនផ.ស.ស ដែលនឹងធ្វើឲ្យផលធៀបនឹងផ.ស.ស កើនឡើងជាបន្តបន្ទាប់។

# ជំពូកទី៤

# គោលនយោបាយ
# និង
# សកម្មភាពអាទិភាព
# ២០១៩-២០២៣

# ជំពូកទី ៤

# គោលនយោបាយនិងសកម្មភាពអាទិភាព ២០១៩-២០២៣

៤.១- ទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយ ដែលរឹងមាំមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមមានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារភ្ជាប់គ្នានឹងត្រូវបានពង្រឹងដើម្បីធានាថាប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និង មានសុខភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើរាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា នឹងប្តេជ្ញាខិតខំយ៉ាងពេញទំហឹងដើម្បីថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមសម្រាប់លើកកម្ពស់ការអនុវត្តច្បាប់ និង ការគោរពសិទ្ធិមនុស្សសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មានកំណើនសេដ្ឋកិច្ចរយៈពេលវែង និងគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៤.២- ដោយផ្អែកលើបទពិសោធ និងលទ្ធផលសម្រេចបានក្នុងនីតិកាលទី៥ និង **“កម្មវិធីនយោបាយ”** សម្រាប់នីតិកាលទី៦របស់ខ្លួន រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្ត្រចតុកោណ ជាពិសេសគោលដៅសម្រាប់ **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** នៅតែចាំបាច់ និងសមស្របសម្រាប់កម្ពុជាបន្តអនុវត្តនៅក្នុងនីតិកាលទី៦(២០១៨-២០២៣) ទៀតដោយរក្សាទុកនូវចតុកោណទាំងបួនឲ្យនៅដដែល ដោយកែសម្រួលលំដាប់អាទិភាពតាមការដ្ឋាន និង មុំមួយចំនួននៃយុទ្ធសាស្ត្រ ព្រមទាំងបញ្ចូលអាទិភាពថ្មីមួយចំនួន ហើយបានសម្រិតសម្រាំង និងសម្រួចសកម្មភាពមួយចំនួនបន្ថែមទៀត ដើម្បី *ទី១* ឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង និងបរិការណ៍ថ្មីៗរបស់កម្ពុជា ហើយដែលត្រូវបានរំលេចក្នុង “កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា” និង *ទី២* លើកកម្ពស់កិច្ចអភិវឌ្ឍតាមរយៈការពង្រឹងទំនាក់ទំនង ឬអន្តរសកម្មរវាងបណ្តាទិសដៅទាំង៤ នៃយុទ្ធសាស្ត្រគឺ **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលជាកញ្ចប់នៃសមីការតែមួយដើម្បីឆ្លុះបញ្ចាំងឲ្យឃើញច្បាស់អំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។ ក្នុងន័យនេះ **“កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា”** និង **“យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤”** រួមជាមួយគ្នា គឺជាឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ”** ដោយកំណត់សូចនាករ និងពេលវេលាច្បាស់លាស់ សម្រាប់អនុវត្តដែលមានសង្គតិភាពជាមួយនឹង ឯកសារគោលនយោបាយតាមវិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល។

ដូច្នេះ “**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤**” គឺជាឯកសារមគ្គុទ្ទេសក៏ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់រយៈពេលវែងសំដៅ ***ជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើត ការងារ បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឲ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។***

៤.៣- ក្នុងខ្លឹមសារនេះ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** គឺជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា។

៤.៤- ដូចមានចែងនៅក្នុងជំពូកទី១ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** មានទម្រង់ប្រហាក់ប្រហែលនឹង**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**ដែរ ដោយបានកំណត់យក “**គោលដៅជាយុទ្ធសាស្ត្រ៤**” និង “**វិស័យអាទិភាព៤**” ជាការប្ដេជ្ញាចិត្តបន្តអនុវត្ត**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** នេះ។

៤.៥- បញ្ហាអន្តរវិស័យសំខាន់ៗនៅក្នុង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣** នេះ គឺ យេនឌ័រ បរិស្ថាន ធនធានធម្មជាតិ និងកំណើនបៃតង គ្រប់គ្រងគ្រោះមហន្តរាយ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **ផ.យ.អ.ជ. ២០១៩-២០២៣** បញ្ជាក់ពីតម្រូវការចាំបាច់ដែលក្រសួង ស្ថាប័ន តាមវិស័យទាំងអស់ ត្រូវពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហការជិតស្និទ្ធរបស់ខ្លួនសម្រាប់ការអនុវត្តទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិ។

៤.៦- **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** គឺជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ដោយបានសម្រិតសម្រាំង និងសម្រួចនូវគោលនយោបាយអាទិភាពឲ្យមានភាពមុតស្រួចបន្ថែមទៀត ដើម្បីជម្នះបាននូវលក្ខខណ្ឌនាពេលបច្ចុប្បន្ន។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនានារបស់រាជរដ្ឋាភិបាលកម្ពុជា **យុទ្ធសាស្ត្រចតុកោណ** បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ៤យ៉ាង ដែលស្តែងចេញតាមរយៈបាវចនា **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** ដូចខាងក្រោម៖

- ទី១ ធានាឲ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាព និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ និង មានភាពប្រកួតប្រជែងជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឲ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និង ការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់។
- ទី២ បង្កើតការងារឲ្យបានកាន់តែច្រើនទាំងបរិមាណ និង គុណភាព ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញ ព័ត៌មានទីផ្សារការងារ ការ

កែលម្អលក្ខខណ្ឌការងារ ការលើកកម្ពស់សកម្មភាពធុរកិច្ច និង ការជំរុញការវិនិយោគទាំងក្នុងប្រទេស និង ក្រៅប្រទេស។

ទី៣ សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឲ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% ការពារមិនឲ្យភាពក្រីក្រវិលត្រឡប់មកវិញដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និង ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និង ការកាត់បន្ថយគម្លាតសង្គម។

ទី៤ បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និង បរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។

៤.៧- បន្ថែមពីលើនេះ នៅមានកត្តាជាក់ស្តែងមួយចំនួនទៀត ដែលកំណត់ពីភាពចាំបាច់ក្នុងការបន្តអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ**" ដូចជា៖

ទី១ ភាពចាំបាច់ក្នុងការបន្តពង្រីកនិងពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន តាមរយៈការអនុវត្ត**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ក្នុងនីតិកាលទី៥នៃរដ្ឋសភាកន្លងមក។

ទី២ ដូចបានរំលេចខាងលើការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ក្នុងនីតិកាលទី៥នៃរដ្ឋសភាកន្លងមក បានបង្ហាញឲ្យឃើញនូវបញ្ហាប្រឈមនិងកាលានុវត្តភាពសំខាន់ៗមួយចំនួន ដែលទាមទារឲ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង សម្រួចឲ្យមុតស្រួចបន្ថែមទៀតនិងពង្រឹងអាទិភាពគោលនយោបាយរបស់ខ្លួន ហើយជំរុញការអនុវត្តនូវរបៀបវារៈគោលនយោបាយនេះនៅក្នុងដំណាក់កាលបន្ទាប់ទៀត។

ទី៣ ការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** គឺជាជំហាននាំឆ្ពោះទៅមុខរបស់កម្ពុជា ដើម្បីឈានឡើងទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពោលគឺការឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលមធ្យមកម្រិតទាប បន្តរៀបចំកសាងមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ពិសេសគឺមហិច្ឆតាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ទី៤ ឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់ឆ្នោត និងរួមទាំងការប្រែប្រួលនៃពិភពលោក និងក្នុងប្រទេស គឺជាកត្តាកំណត់សំខាន់ថ្មីបន្ថែមទៀត ដែលទាមទារឲ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង សម្រួចឲ្យមុតស្រួចបន្ថែមទៀតនូវ**យុទ្ធសាស្ត្រ**

**ចតុកោណ ដំណាក់កាលទី៣** និងជំរុញអនុវត្តនៅក្នុងដំណាក់កាលទី៤ឲ្យខ្លាំងក្លាថែមទៀត។

៤.៨- **ផ.យ.អ.ជ. ២០១៩-២០២៣** បង្ហាញដោយសង្ខេបនូវ គោលនយោបាយ យុទ្ធសាស្ត្រជាអាទិភាពសំខាន់ៗ រួមទាំងបញ្ជីសកម្មភាព កម្មវិធី និងគម្រោងនានា ដែលក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តនៅក្នុងនីតិកាលទី៦នៃរដ្ឋសភា។ នៅក្នុងជំពូកទី៤នេះ គោលនយោបាយយុទ្ធសាស្ត្រ ជាអាទិភាពសំខាន់ៗដែលក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្ត គឺត្រូវបានរៀបចំទៅតាមទម្រង់នៃ**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤**។ ចំពោះសមាសភាគ និង សមាសភាគរងនីមួយៗរបស់**យុទ្ធសាស្ត្រចតុកោណ** នេះត្រូវបានរៀបចំតាមរយៈការដាក់ចេញនូវ ***ទី១ គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់វិស័យជាក់លាក់នីមួយៗ និង ទី២ សកម្មភាព កម្មវិធី និងគម្រោងនានា ដែលបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលយកដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងអស់នេះ***។

## ១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

៤.៩- សម្រាប់នីតិកាលទី៦នៃរដ្ឋសភា នឹងអនុវត្តនូវ ១.ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន ២.ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ៣.ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង ៤.ការពង្រឹងអភិបាលកិច្ចវិស័យឯកជន។ ទិសដៅសំខាន់បំផុតនៃការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចនេះ ដើម្បីធានាធម្មានុរូបភាព និង ភាពជឿជាក់ពីសាធារណជនតាមរយៈការកសាងប្រព័ន្ធស្ថាប័នរដ្ឋឲ្យមានប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតប គណនេយ្យភាព និង តម្លាភាព។

## ១.១- ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៦

៤.១០- ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន ជារបៀបវារៈអាទិភាពខ្ពស់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា។ ដើម្បីអនុវត្តការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន ប្រកបដោយប្រសិទ្ធភាពក្នុងនីតិកាលទី៦នេះ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពលើការងារស្នូលចំនួន៥ ដូចខាងក្រោម៖

- ការធ្វើវិចារណកម្មមុខងារ និង ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និង ការសម្របសម្រួលអន្តរស្ថាប័ន ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ

និង បន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួង ស្ថាប័ននីមួយៗ ពិសេសតាមរយៈការអនុវត្តម៉ឺងម៉ាត់នូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

- ការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និង សាមគ្គីភាពផ្ទៃក្នុងស្ថាប័ន ការរៀបចំ និង អនុវត្តហ្មត់ចត់នូវ ក្រមប្រតិបត្តិសម្រាប់បំពេញការងារ និង ការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និង គុណវុឌ្ឍិល្អប្រសើរសម្រាប់ការតែងតាំងមុខតំណែងដឹកនាំនៅក្នុងមុខងារសាធារណៈ។
- ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ ព្រមទាំង ការលើកទឹកចិត្ត និង ការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈ និង អង្គភាពសាធារណៈ ជាពិសេស ការរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងវិស័យសាធារណៈ។
- ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំក្របខ័ណ្ឌច្បាប់ និង លិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធការងារ ក្របខ័ណ្ឌអភិវឌ្ឍមូលធនមនុស្សដែលទាក់ទាញសមត្ថភាពជំនាញ និង ទេពកោសល្យ និង ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីសាធារណៈ។
- ការបន្តកែទម្រង់កងកម្លាំងប្រដាប់អាវុធ តាមរយៈ ១.ការពង្រឹង ការដឹកនាំ ការគ្រប់គ្រង និង ខ្សែរយៈចាត់តាំង ២.ការអភិវឌ្ឍធនធានមនុស្ស និង បង្កើនសមត្ថភាពកងកម្លាំងប្រដាប់អាវុធ ដោយបង្កើនគុណភាពហ្វឹកហ្វឺន បំពាក់បច្ចេកវិទ្យាសមស្រប និង កសាងជួរកងកម្លាំងបន្តវេន ៣.ការលើកកម្ពស់សមត្ថភាពក្នុងការរក្សាសន្តិសុខ ការបន្តជំរុញកងទ័ព និង គ្រួសារកងទ័ពឲ្យរស់នៅតាមបណ្តោយព្រំដែន ការប្រយុទ្ធប្រឆាំង នឹងភេរវកម្ម ដើម្បីធានាបាននូវព្រំដែនសន្តិភាព និង ការអភិវឌ្ឍ សុវត្ថិភាពជាតិ និង គ្មានការគំរាមពីអំពើភេរវកម្ម ៤.ការពង្រឹងសមត្ថភាពក្នុងការចូលរួមពង្រីក និង ពង្រឹងទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិ ពិសេសក្នុងការចូលរួមបំពេញបេសកកម្ម រក្សាសន្តិភាពនៅក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ និង ៥.ការលើកកម្ពស់សមត្ថភាពចូលរួមគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការការពារបរិស្ថាន និង ធនធានធម្មជាតិ ការធ្វើអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ការបំពេញប្រតិបត្តិការមនុស្សធម៌ និង ការជួយបង្កបង្កើនផលកសិកម្មដល់ប្រជាជន។

## ខ- សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១១- ដើម្បីអនុវត្តបណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាខាងលើនេះ ទិសដៅរបស់ ***ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និង ក្រសួងការពារជាតិ*** រួមមាន៖

៤.១២- ***ក្រសួងមហាផ្ទៃ*** នឹងអនុវត្តនូវបណ្តាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ពង្រឹងសន្តិសុខជាតិ ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
    - ពង្រឹងសន្តិសុខជាតិ បង្ការទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ
    - ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពក្នុងសង្គម
    - ពង្រឹងវិធានការនៅក្នុងការបង្ការ ទប់ស្កាត់ និង បង្ក្រាបបទល្មើសនានានៅក្នុងសង្គម
    - បង្កើននិងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការបង្ការ ទប់ស្កាត់ និង បង្ក្រាបការចរាចរ ការចែកចាយ និង ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និង ការស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ព្រមទាំងការលាងលុយ
    - ពង្រឹងសុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ
    - លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និង សុវត្ថិភាពនៅក្នុងសង្គម
    - លើកកម្ពស់សមត្ថភាព គុណភាពបំពេញការងារ ក្រមសីលធម៌វិជ្ជាជីវៈរបស់កងកម្លាំងនគរបាលជាតិ
- លើកកម្ពស់ការរក្សាការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ
- ពង្រឹងការគ្រប់គ្រងជនបរទេសគ្រប់ប្រភេទ
- លើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈដល់អ្នកទោស និង ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍
- លើកកម្ពស់ការគ្រប់គ្រងអត្តសញ្ញាណបុគ្គលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅជាប្រព័ន្ធមួយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់សេវាសាធារណៈ និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
    - ពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
    - ការលើកកម្ពស់ប្រសិទ្ធភាព និងសមត្ថភាពស្ថាប័ន និង ធនធានមនុស្សក្នុងការបំពេញការងារ និងការប្រើប្រាស់ធនធាន
    - ការលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ។

៤.១៣- ***ក្រសួងមុខងារសាធារណៈ*** នឹងផ្តោតការយកចិត្តទុកដាក់លើការងារកំណែទម្រង់រដ្ឋបាលសាធារណៈ និង វិស័យមុខងារសាធារណៈ ដូចខាងក្រោម៖

- កំណែទម្រង់រដ្ឋបាលសាធារណៈ នឹងផ្តោតលើទិសដៅការងារជាយុទ្ធសាស្ត្រសម្រាប់អនុវត្ត ក្នុងឆ្នាំ ២០១៩-២០២៣ ដូចជា៖
    - រៀបចំប្រព័ន្ធមុខងារសាធារណៈ ឆ្ពោះទៅរកការគ្រប់គ្រងធនធានមនុស្សបែបនិយោជន៍
    - កសាងប្រព័ន្ធផែនការក្របខ័ណ្ឌមន្ត្រីរាជការឲ្យមានសង្គតិភាពទៅនឹងផែនការថវិកា

▪ធ្វើវិចារណកម្មទំហំនៃមន្ត្រីសាធារណៈនិងរចនាសម្ព័ន្ធស្ថាប័នស្របតាមតម្រូវការការងារពិតប្រាកដ
▪រៀបចំនិងអនុវត្តកម្មវិធីកសាងសមត្ថភាពគ្រប់ជ្រុងជ្រោយនិងជាប្រព័ន្ធ ដើម្បីលើកកម្ពស់សមត្ថភាព ដឹកនាំ គ្រប់គ្រង និងជំនាញ
▪រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល ដោយមានយន្តការផ្តល់ការលើកទឹកចិត្ត
▪រៀបចំប្រព័ន្ធបៀវត្សដែលគាំទ្រដល់ការលើកកម្ពស់ផលិតភាព ជំនាញវិជ្ជាជីវៈ និងសមត្ថភាពដឹកនាំ និងគ្រប់គ្រង
▪បង្កើនសមត្ថភាព និងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្សឲ្យមានដំណើរការពេញលេញនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
▪លើកកម្ពស់គុណភាពសេវាសាធារណៈ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន យន្តការសមាហរណកម្មសេវាទៅក្នុងយន្តការច្រកចេញចូលតែមួយ

- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ ដោយអនុវត្តការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ តាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាល ដោយផ្តោតទៅលើវគ្គបណ្តុះបណ្តាលដំបូង វគ្គបណ្តុះបណ្តាលបន្ត និងវគ្គបណ្តុះបណ្តាលជំនាញសម្រាប់សិស្ស និស្សិត និងមន្ត្រីរាជការ សម្រាប់បម្រើ ការងារក្នុងវិស័យមុខងារសាធារណៈ។
- ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល៖ ពង្រឹងការត្រួតពិនិត្យរដ្ឋបាលមន្ត្រីរាជការ និងការគ្រប់គ្រងក្របខ័ណ្ឌដើម្បី៖ ១.បង្កើនប្រសិទ្ធភាពក្នុងការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់សាលាកបត្រព័ត៌មាន លិខិតបទដ្ឋានឯកត្តជន ពិនិត្យការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់គ្រួសារមន្ត្រីរាជការស៊ីវិល និង ២.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគ្រប់ក្រសួង ស្ថាប័ន។ ជំរុញការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល។

៤.១៤- ដើម្បីអនុវត្តគោលនយោបាយអាទិភាពខាងលើនេះ ***ក្រសួងមុខងារសាធារណៈ*** នឹងផ្តោតលើសកម្មភាព ដូចខាងក្រោម៖

- លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ

▪រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំដើម្បីពង្រឹងប្រសិទ្ធភាពនិងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវាសាធារណៈទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- ជំរុញការរៀបចំនិងអនុវត្តស្តង់ដាសេវាសាធារណៈនៅតាមអង្គភាពផ្តល់សេវាសាធារណៈ ដើម្បីលើកកម្ពស់ស្តង់ដានៃការផ្តល់សេវាសាធារណៈនិងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ
- សម្របសម្រួល តាមដានការអនុវត្ត និងផ្តល់អនុសាសន៍កែលម្អគុណភាពសេវាសាធារណៈនៅតាមអង្គភាពផ្តល់សេវាសាធារណៈ
- បន្តពង្រីកការដាក់ឲ្យអនុវត្តយន្តការនៃការផ្តល់សេវាសាធារណៈ
- បន្តនិងពង្រីកការអនុវត្តការជំរុញចលនានៃការប្រឡងប្រជែងការកែលម្អគុណភាពសេវាសាធារណៈរបស់អង្គភាពផ្តល់សេវារបស់ក្រសួង ស្ថាប័ន
- រៀបចំនិងដាក់ឲ្យដំណើរការមូលនិធិនវានុវត្តន៍ដើម្បីការកែលម្អការផ្តល់សេវាសាធារណៈ ដើម្បីលើកកម្ពស់ការអនុវត្តនវានុវត្តក្នុងការផ្តល់សេវាសាធារណៈ
- រៀបចំករណីសិក្សាស្តីពីអង្គភាពផ្តល់សេវាសាធារណៈគំរូនិងអង្គភាពផ្តល់សេវាសាធារណៈដែលមាននវានុវត្តន៍និងអនុវត្តការផ្សព្វផ្សាយដើម្បីជំរុញចលនានៃការផ្តល់សេវាសាធារណៈ
- បណ្តុះបណ្តាលនិងជំរុញការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពនិងសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីផ្តល់សេវាទាំងផ្នែកជួរមុខ ទាំងផ្នែកជួរក្រោយ
- បណ្តុះបណ្តាលមន្ត្រីបង្គោល និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការកែលម្អគុណភាពសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ជំរុញការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការទទួលនិងដោះស្រាយព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវានៅគ្រប់អង្គភាពផ្តល់សេវាសាធារណៈ

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន
  - បង្កើតមូលដ្ឋានទិន្នន័យអំពីជំនាញមន្ត្រីរាជការស៊ីវិលគ្រប់ជ្រុងជ្រោយនិងអាចប្រើប្រាស់សម្រាប់គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពការងារ
  - ពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការស៊ីវិលតាមរយៈការរៀបចំមន្ត្រីរាជការស៊ីវិល មុខតំណែង និងការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ
  - រៀបចំនិងដាក់ឲ្យអនុវត្តក្របខ័ណ្ឌគតិយុត្តនៃការបណ្តុះបណ្តាល និងរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចនិងជាប្រព័ន្ធដើម្បីបង្កើនសមត្ថភាពមន្ត្រីរាជការស៊ីវិល
  - ដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលនិងប្រព័ន្ធលើកទឹកចិត្តនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
  - វិភាគមុខងារ រចនាសម្ព័ន្ធ និងត្រួតពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- កែទម្រង់ប្រព័ន្ធបៀវត្សនិងលាភការផ្សេងៗ
  - បន្តរៀបចំនិងដាក់ឲ្យអនុវត្តការបើកផ្តល់បៀវត្សមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាតាមធនាគារដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច
  - រៀបចំនិងដំឡើងបៀវត្សដោយផ្តោតទៅលើការកែសម្រួលបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ
  - រៀបចំនិងដំឡើងប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន
- ពង្រឹងយន្តការសម្របសម្រួលកំណែទម្រង់អន្តរវិស័យ និងដៃគូពាក់ព័ន្ធ
- ជំរុញតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- បណ្តុះបណ្តាល និង អភិវឌ្ឍមន្ត្រីរាជការ
- ត្រួតពិនិត្យរដ្ឋបាលមន្ត្រីរាជការ និង គ្រប់គ្រងក្របខ័ណ្ឌ
- ធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
  - គ្រប់គ្រងសលាកបត្រព័ត៌មាន និងឯកសារមន្ត្រី រាជការស៊ីវិលតាមប្រព័ន្ធព័ត៌មានវិទ្យា
  - គ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល និងទិន្នន័យសម្រាប់ការចូលនិវត្តន៍តាមប្រព័ន្ធព័ត៌មានវិទ្យា
  - រៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការធ្វើទំនើបកម្មមុខងារសាធារណៈ
  - បណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាដែលបានរៀបចំដោយក្រសួងមុខងារសាធារណៈ។

៤.១៥- សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងការពារជាតិ*** នឹងបន្តអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអធិបតេយ្យភាព បូរណភាពទឹកដី សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ សកម្មភាពជាអាទិភាព រួមមាន៖

- លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ របស់កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលយោធាតាមរយៈការបន្តអនុវត្ត ***យុទ្ធសាស្ត្រ៣ សកម្មភាពប្រតិបត្តិការ និងការអភិវឌ្ឍ១០*** ព្រមទាំងធ្វើបច្ចុប្បន្នកម្ម និងជំរុញអនុវត្តផែនការយុទ្ធសាស្ត្រនគរបាលសន្តិសុខ ក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធភាព នៃការបំពេញតួនាទី របស់កងកម្លាំងប្រដាប់អាវុធ ពិសេសពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ។
- អភិវឌ្ឍធនធានមនុស្ស និងការបង្កើនសមត្ថភាពកម្លាំងប្រដាប់អាវុធតាមរយៈការធ្វើទំនើបកម្ម និងបំពាក់បច្ចេកវិទ្យាសមស្រប ពង្រឹងគុណភាពហ្វឹកហ្វឺន ជាពិសេសការបណ្តុះបណ្តាលយោធិនអាជីព។

- ពង្រឹងខ្សែរយៈចាត់តាំងក្នុងកងកម្លាំងប្រដាប់អាវុធ ពិសេសជួរកងទ័ពនៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង។
- ផ្គត់ផ្គង់សម្ភារៈបច្ចេកទេស និងលើកកម្ពស់សុខុមាលភាពកងទ័ព ជាពិសេសការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងភស្តុភារហិរញ្ញវត្ថុ សម្រាប់បណ្ដាកងឯកភាព ដែលឈរជើងនៅខ្សែត្រៀមជួរមុខ និងកងការពារដែនកោះ។
- បន្តផ្ដល់ការយកចិត្តទុកដាក់ដល់អតីតយុទ្ធជន និងយោធិនពិការ គ្រួសារយោធិនពលីមរណៈ និងគ្រួសារកងទ័ព និងគម្រោងអភិវឌ្ឍសម្រាប់សហគមន៍នៃគ្រួសារនៅតាមបន្ទាត់ព្រំដែន និងទីជនបទ។
- លើកកម្ពស់នៃកិច្ចសហប្រតិបត្តិការ រវាងកងកម្លាំងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងកម្លាំងប្រដាប់អាវុធជាមួយក្រសួងបរិស្ថាននិង ប្រជាជន តាមរយៈការធ្វើអន្តរាគមន៍ ក្នុងពេលមានគ្រោះធម្មជាតិ ការបំពេញប្រតិបត្តិការមនុស្សធម៌ ការជួយបង្កបង្កើនផល ព្រមទាំងការរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ។
- ពង្រឹងនិងពង្រីកទំនាក់ទំនង កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធលើគ្រប់ផ្នែករួមទាំងការបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។
- អភិវឌ្ឍធនធានមនុស្សក្នុងកងយោធពលខេមរភូមិន្ទ លើជំនាញអាជីពនៃវិស័យ កសិកម្មផលិតកម្មកែច្នៃ និងជំនាញដទៃទៀតដែលអាចបង្កើតរបរផ្ទាល់ខ្លួន ដើម្បីឲ្យអង្គភាពនិងសហគមន៍កងទ័ពអាចរកចំណូលទ្រទ្រង់ខ្លួនបាន និងជាការលើកកម្ពស់សុខុមាលភាពក្នុងសហគមន៍កងទ័ព។
- លើកកម្ពស់សមភាពយេនឌ័រ ក្នុងកងយោធពលខេមរភូមិន្ទ ដោយជំរុញឲ្យមានកំណើនយោធិនស្ត្រីក្នុងជួរថ្នាក់ដឹកនាំអង្គភាព។
- បង្កើតដៃគូវិនិយោគអភិវឌ្ឍយុទ្ធសាស្ត្រ លើវិស័យកសិកម្មឧស្សាហកម្ម និងការកែច្នៃធនធាន ជាពិសេសដីធ្លីរបស់សហគមន៍កងទ័ព ដើម្បីបង្កើនការប្រើប្រាស់ឲ្យអស់សក្ដានុពល និងមានប្រសិទ្ធភាព ធនធានរបស់កងយោធពលខេមរភូមិន្ទ ដើម្បីលើកកម្ពស់ជីវភាពកងទ័ព តាមរយៈការបង្កើតការងារនិងមុខរបរសម្រាប់សហគមន៍កងទ័ព។
- អនុវត្តគម្រោងវិនិយោគបៃតងពិសេស វិស័យថាមពលតាមសហគមន៍កងទ័ព ដើម្បីជួយសម្រួលដល់ការងារអភិវឌ្ឍនានា ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ផ្អែកតាមសៀវភៅសការពារជាតិបានបញ្ជាក់យ៉ាងច្បាស់ថា (គ្មានកាលទេសណា ឬទីកន្លែងណាមួយ ដែលការអភិវឌ្ឍអាចប្រព្រឹត្តទៅបានដោយគ្មានសន្តិសុខនោះទេ) ដូចនេះសន្តិភាព និងការអភិវឌ្ឍជាតិ ពិតជាមិនអាចខ្វះបានឡើយ សម្រាប់កម្ពុជានាពេលបច្ចុប្បន្ននិងឆ្ពោះទៅអនាគត។

# ១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

## ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៦

៤.១៦- រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតលើការងារអាទិភាពចំនួន៦ គឺៈ *ទី១* ការសម្រេចយុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និង បង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងក្របខណ្ឌ "***មិនហ៊ាន មិនអាច និង មិនចង់***" ប្រព្រឹត្តអំពើពុករលួយ *ទី២* ការពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និង ឯកសារគោលនយោបាយជាតិ *ទី៣* ការជំរុញឲ្យមានការចូលរួមពីសំណាក់ប្រជាជនក្នុងដំណើរការនៃការអភិវឌ្ឍ ការរៀបចំគោលនយោបាយ និងការអនុវត្ត *ទី៤* ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និង ដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវារួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រការអនុវត្ត *ទី៥* ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និង សវនកម្មក្នុងវិស័យសាធារណៈ *ទី៦* ការពង្រឹងប្រសិទ្ធភាពរៀបចំ និង អនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និង ទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ។

## ខ- សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៧- ដើម្បីអនុវត្តបណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាខាងលើនេះ ទិសដៅរបស់ ***អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និង អធិការកិច្ច និង ក្រសួងមុខងារសាធារណៈ*** រួមមានៈ

៤.១៨- ដើម្បីបន្តការងារប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាពក្នុងនីតិកាលទី៦នេះ ***អង្គភាពប្រឆាំងអំពើពុករលួយ*** នឹងពង្រឹង និងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង៣ដូចខាងក្រោមៈ

- ពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ បន្តពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វ-ផ្សាយច្បាប់ ការអប់រំស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយទាំងក្នុងនិងក្រៅសាលារៀន តាមគ្រប់រូបភាព គ្រប់វិស័យ និង គ្រប់ជាន់ថ្នាក់ និង បន្តពង្រីកដល់គ្រឹះស្ថានឧត្តមសិក្សា សាលាវិជ្ជាជីវៈ ដើម្បីបញ្ជ្រាបការយល់ដឹងពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងស្មារតីសុចរិតភាពក្នុងការបំពេញការងារ និង ប្រកបរបរចិញ្ចឹមជីវិត។ បំផុសការចូលរួមប្រឆាំងអំពើពុករលួយនឹងបន្តជំរុញតាមរយៈការរៀបចំវេទិកាប្រកួតប្រជែងចំណេះដឹងអំពីការប្រឆាំងអំពើពុករលួយ។
- បង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ ពង្រឹងសុចរិតភាព អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ និង ឯកជន ជាយុទ្ធសាស្ត្រគន្លឹះក្នុងការបង្ការទប់ស្កាត់អំពើពុករលួយ។ បន្តជំរុញ

ការរៀបចំ និងអនុវត្តផែនការប្រឆាំងអំពើពុករលួយក្នុងស្ថាប័នសាធារណៈ និងកម្មវិធីប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន និង បង្កើតគំនិតផ្តួចផ្តើមថ្មីៗរួមគ្នាលើកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយ។ ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈសំដៅបង្កើនការជឿទុកចិត្តលើរាជរដ្ឋាភិបាល បន្តអនុវត្តតាមរយៈការចូលរួមពិនិត្យ ដាក់ចេញ និងកែសម្រួលនូវប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ។ បន្តចូលរួមទប់ស្កាត់បាតុភាពអវិជ្ជមាន ក៏ដូចជាការប្រព្រឹត្តល្មើសបទប្បញ្ញត្តិនានា តាមរយៈការចូលរួមសង្កេតការណ៍ ក្នុងដំណើរការប្រឡងក្របខ័ណ្ឌមន្ត្រីរាជការ សិស្ស និង ការងារគន្លឹះសំខាន់ៗអាទិភាពរបស់ ក្រសួង ស្ថាប័ន។ ការប្រកាសទ្រព្យសម្បត្តិ និងបំណុលគឺជា វិធានការ បង្ការទប់ស្កាត់អំពើពុករលួយ និងគាំទ្រដល់ការស៊ើបអង្កេតដ៏មានប្រសិទ្ធភាព ដែលនឹងបន្តបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាក្នុងការប្រកាសទ្រព្យសម្បត្តិ និង បំណុល ជាពិសេសចំពោះបុគ្គលដែលទទួលបានការតែងតាំងថ្មី បុគ្គលដែលចប់អាណត្តិ ឬចូលនិវត្តន៍ និង ពង្រីកវិសាលភាពនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលទៅតាមគោលដៅ ដែលត្រូវប្រកាសស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលបានកំណត់។

- បង្ក្រាបបទល្មើសបញ្ជូនទៅតុលាការ បន្តពង្រឹងយន្តការត្រួតពិនិត្យ និងវិភាគពាក្យប្តឹង និងបន្តចាត់វិធានការម៉ឺងម៉ាត់ និងតឹងរ៉ឹងចំពោះជនល្មើសនៃអំពើពុករលួយដោយពុំមានការលើកលែង ក៏ដូចជាបន្តពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនបន្ថែមទៀត តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស ស្តីពីការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ការស៊ើបអង្កេតចារកម្មការ តាមរក ការរឹបអូសផលនៃបទល្មើសពុករលួយ។
- ឆ្នាំ២០១៦-២០២០ កម្ពុជាបានត្រៀមខ្លួនក្នុងដំណើរការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញានេះ នៅជុំទី២ ផ្តោតលើជំពូកចំនួន២ គឺ ជំពូកទី២ វិធានការការពារ និងទប់ស្កាត់ និងជំពូកទី៤ គឺកិច្ចការសហប្រតិបត្តិការអន្តរជាតិ។ បន្តធ្វើការងារជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធនានា ទាំងក្នុងប្រទេសនិងអន្តរជាតិ តាមរយៈការបង្កើតការិយាល័យអាំងទែប៉ូល និងការិយាល័យប្រឆាំងការសម្អាតប្រាក់ នៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយ។

## តារាងទី ៤.១ សូចនាករសំខាន់ៗ និងចំណុចដៅ ឆ្នាំ២០១៩-២០២៣

| សកម្មភាពគោល | សូចនាករ |
|---|---|
| ការងារពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ | |
| ១.ពង្រីកវិសាលភាពនៃការអប់រំស្តីពីការប្រឆាំងអំពើពុករលួយនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង បណ្តុះបណ្តាល វិជ្ជាជីវៈ | ១.១.មានមេរៀនស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>១.២.កម្រិតនៃការយល់ដឹង និងគោរពច្បាប់ តម្លៃសុចរិតភាព សីលធម៌ និងវិន័យក្នុងចំណោមយុវជន (ការស្ទង់មតិ) |
| ២.ពង្រឹងការផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយ | ២.១.ចំនួនការផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយនៅតាមប្រព័ន្ធផ្សព្វផ្សាយ-វិស័យសាធារណៈ-វិស័យឯកជន-គ្រឹះស្ថានសិក្សា- |

| | |
|---|---|
| | ប្រជាពលរដ្ឋ-ទីកន្លែង ងាយរងអំពើពុករលួយ<br>២.២.ចំនួនអ្នកទទួលបានការផ្សព្វផ្សាយអំពីការប្រឆាំងអំពើពុករលួយ |
| ការងារបង្ការ ទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ | |
| ១.ពង្រីកវិសាលភាពគោលដៅដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល | ១.១.កម្រិតវិសាលភាព និងប្រភេទគោលដៅដែលត្រូវ ប្រកាសទ្រព្យសម្បត្តិ និងបំណុល |
| ២.ជំរុញការអនុវត្តបន្តលើដំណើរការត្រួតពិនិត្យការអនុវត្ត UNCAC នៅកម្ពុជា | ២.១. មានការរៀបចំដំណើរការត្រួតពិនិត្យការអនុវត្តUNCAC នៅកម្ពុជាជុំទី២ |
| ៣.ពង្រឹងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និយ័តកម្មតាមតម្រូវការ និងកាលៈទេសៈជាក់ស្តែង | ៣.១.ច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយមួយចំនួនត្រូវបានអនុម័ត និងកែសម្រួល |
| ៤.បង្កើតឲ្យមានការិយាល័យប្រឆាំងអំពើពុករលួយនៅតាមរាជធានីខេត្ត | ៤.១.ចំនួនការិយាល័យប្រឆាំងអំពើពុករលួយតាម ខេត្ត-តំបន់ |
| ៥.ជំរុញឲ្យមានការពង្រឹងសីលធម៌ សុចរិតភាព និងអភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ | ៥.១.ចំនួនក្រសួង-ស្ថាប័នមានរៀបចំ និងអនុវត្តកម្មវិធី ពង្រឹងសីលធម៌ និងអភិបាលកិច្ចល្អ |
| ៦.ពង្រឹងប្រសិទ្ធភាព និងតម្លាភាពចំណូលចំណាយសាធារណៈ | ៦.១.ចំនួនក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ចូលរួមសង្កេតការណ៍ក្នុងកិច្ចលទ្ធកម្មសាធារណៈ និងកិច្ចការ ផ្សេងៗពាក់ព័ន្ធចំណាយរដ្ឋ |
| ៧.ពង្រឹងប្រសិទ្ធភាព និងតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ | ៧.១.ចំនួនប្រកាសរួមពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ការពិន័យ និងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ដែលបានដាក់ចេញកែសម្រួល<br>៧.២.កម្រិតប្រសិទ្ធភាពនិងតម្លាភាពនៃការផ្តល់សេវាសាធារណៈ (ការស្ទង់មតិពីអ្នកទទួលសេវា) |
| ៨.ពង្រីកការចូលរួមប្តេជ្ញាប្រតិបត្តិធុរកិច្ចស្អាតស្អំពីវិស័យឯកជន | ៨.១.ចំនួនវិស័យឯកជនដែលបានចូលរួមប្តេជ្ញាធ្វើធុរកិច្ចស្អាតស្អំតាមរូបភាពផ្សេងៗ |
| ការអនុវត្តច្បាប់បង្ក្រាប | |
| ១.បង្កើនប្រសិទ្ធភាពការតាមដាន និងស៊ើបអង្កេត | ១.១.ចំនួនកម្មវិធីអភិវឌ្ឍន៍ជំនាញ |
| ២.ពង្រឹងយន្តការត្រួតពិនិត្យពាក្យប្តឹង | ២.១.មានការធ្វើឲ្យប្រសើរឡើងនូវយន្តការត្រួតពិនិត្យពាក្យប្តឹង |
| ៣.ពង្រីកកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ ស្ថាប័នអន្តរជាតិលើការតាមរក និងរឹបអូសផលនៃបទល្មើស | ៣.១.មានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ ស្ថាប័នអន្តរជាតិលើការតាមរកនិងរឹបអូសផលនៃបទល្មើសពុករលួយ |

៤.១៩- ***ក្រសួងទំនាក់ទំនងជាមួយ ព្រឹទ្ធសភា រដ្ឋសភា និង អធិការកិច្ច*** នឹងផ្តោតយកចិត្តទុកដាក់ក្នុងការរួមចំណែកការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ តាមរយៈចក្ខុវិស័យរបស់ក្រសួង គឺ “**ការកសាងកម្ពុជាឲ្យក្លាយទៅជាសង្គមនីតិរដ្ឋ ប្រកបដោយតម្លាភាព គណនេយ្យភាព និងភាពទទួលខុសត្រូវ**” ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅនៃចក្ខុវិស័យនេះ ក្រសួងបានដាក់ចេញនូវគោលនយោបាយចម្បងមួយ គឺ “**ការលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាពប្រសិទ្ធភាពការងារ និងពង្រឹងនីតិរដ្ឋ**” ក្នុងគោលបំណងឆ្លើយតបទៅនឹងគោលនយោបាយអភិបាលកិច្ចល្អ ដែលគ្របដណ្តប់លើការកែ

ទម្រង់ស៊ីជម្រៅទាំងបួនគឺ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

៤.២០- ***ក្រសួងទំនាក់ទំនងជាមួយ ព្រឹទ្ធសភា រដ្ឋសភា និង អធិការកិច្ច*** នឹងបន្តដាក់ចេញនូវយុទ្ធសាស្រ្តធំៗចំនួន០៤ ដែលអមដោយសកម្មភាពស្នូលដូចខាងក្រោម ៖

**១- ការពង្រឹងវិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាៈ**

**ពង្រឹងការងារនីតិកម្ម៖** ពង្រឹងស្ថេរភាព សន្តិសុខសង្គមនីតិរដ្ឋ កាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍ និងវិបុលភាព ព្រមទាំងភាពសុខដុមរមនា និងសុភមង្គលជូនប្រជាពលរដ្ឋកម្ពុជា តាមរយៈ ១. បន្តចូលរួមរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច សេចក្តីព្រាងអនុក្រឹតស្តីពីនីតិវិធីអធិការកិច្ច សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ច និងតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតដែលជាតម្រូវការចំពោះមុខរបស់ក្រសួង ២. បន្តចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ភូមិបាលនៅតាមខេត្តគោលដៅ។

**ពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់៖** ពង្រឹងស្ថេរភាព សន្តិសុខសង្គម នីតិរដ្ឋ កាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍនិងវិបុលភាពព្រមទាំងភាពសុខដុមរមនា និងសុភមង្គលជូនប្រជាពលរដ្ឋកម្ពុជាតាមរយៈ *១.* បន្តការផ្សព្វផ្សាយច្បាប់អាទិភាពទាំង១១ ជូនប្រជាពលរដ្ឋនៅទូទាំងប្រទេសដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់ សិទ្ធិ និងកាតព្វកិច្ចដែលមានក្នុងច្បាប់ ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្រ្តអមវេជ្ជសាស្រ្ត និងជំនួយវេជ្ជសាស្រ្ត ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌ និងវប្បធម៌ *២.* បន្តចុះវិភាគស្ថានភាព និងសិក្សាបឋមទៅលើច្បាប់អាទិភាពទាំង១១ ដើម្បីវាស់ស្ទង់កម្រិតយល់ដឹង និងតម្រូវការអំពីច្បាប់របស់ប្រជាពលរដ្ឋតាមភូមិសាស្រ្តនីមួយៗ មុននឹងបើកយុទ្ធនាការផ្សព្វផ្សាយច្បាប់ជាផ្លូវការ និង *៣.* រៀបចំកម្មវិធីពិភាក្សាតុមូល (តាមទូរទស្សន៍) និងរៀបចំកម្មវិធីសន្ទនាមតិតាមវិទ្យុ ។

**ពង្រឹងការងារទំនាក់ទំនងរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា៖** ពង្រឹងស្ថេរភាព សន្តិសុខសង្គមនីតិរដ្ឋ កាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍនិងវិបុលភាព ព្រមទាំងភាពសុខដុមរមនា និង សុភមង្គលជូនប្រជាពលរដ្ឋកម្ពុជា។

**២- ការងារអធិការកិច្ចៈ**

រៀបចំយុទ្ធសាស្រ្ត និងចាត់តាំងប្រតិបត្តិលើការងារ បង្ការ ទប់ស្កាត់ បាតុភាពអសកម្ម ការរំលោភដោយអំណាច ដើម្បីបង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និង ប្រឆាំងអំពើ

ពុករលួយ។ កិច្ចការដ៏សំខាន់នេះក្រសួងបន្តកំណត់យក ១. ការងារអធិការកិច្ចទៅលើ ការគ្រប់គ្រង រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងក្រោមជាតិ ២. ការងារតាមដានការអនុវត្តច្បាប់លើវិស័យ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាធារណការ និងដឹកជញ្ជូន សុខាភិបាល រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទេសចរណ៍ ព្រមទាំងទូរគមនាគមន៍ ៣. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ បន្តទទួល ពាក្យបណ្តឹងរបស់ ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋាន និងអង្កេតស្រាវជ្រាវដោះស្រាយពាក្យបណ្តឹងដែលជាសមត្ថកិច្ចរបស់ក្រសួង ៤. ការងារទំនាក់ទំនងជាមួយអធិការកិច្ចតាមបណ្តាក្រសួង អង្គភាព បង្កើនកិច្ចទំនាក់ទំនងជាមួយអង្គភាពអធិការកិច្ចនៃក្រសួង ស្ថាប័ន អង្គភាពនានាក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ និង ៥. ការងារវិវាទកម្ម បន្តស្រាវជ្រាវអំពីទំហំនៃការប្រព្រឹត្តខុសឆ្គងរបស់បុគ្គលនៃក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងអ្នកពាក់ព័ន្ធ។

**៤- ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ថ្នាក់រាជធានី-ខេត្ត**

មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ថ្នាក់រាជធានី-ខេត្ត ទាំង២៥ បន្តធ្វើការផ្សព្វផ្សាយច្បាប់ រៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន រៀបចំធ្វើការស្ទង់មតិប្រជាពលរដ្ឋយល់ដឹងច្បាប់ ទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ តាមដានការអនុវត្តច្បាប់ និងធ្វើអធិការកិច្ច នៅតាមមន្ទីរ-អង្គភាព ជុំវិញរាជធានី-ខេត្តទាំង២៥។

## ១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.២១- នៅក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖ ១. ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងបង្កើនប្រាក់សោធនជូននិវត្តជន និង អតីតយុទ្ធជន ដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារក្នុងរយៈពេល២សប្តាហ៍ម្តង ២. ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងការចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការនិងវិសហមជ្ឈការ ដល់អង្គភាពរដ្ឋបាលគ្រប់កម្រិតក្រោមឱវាទក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបានស្វ័យភាពសមស្របទាំងការសម្រេចចិត្ត ការគ្រប់គ្រង និង ការចាត់ចែងធនធានមនុស្ស និង ហិរញ្ញវត្ថុ ទន្ទឹមនឹងការកំណត់ឲ្យបានច្បាស់លាស់នូវគណនេយ្យភាព និង ការទទួលខុសត្រូវរបស់អង្គភាពសាធារណៈ និង មន្ត្រីសាធារណៈ ៣. ការជំរុញនវានុវត្ត និងរដ្ឋបាលឯកភាពនៅក្នុងកម្រិតក្រុង ស្រុក-ខណ្ឌ ខេត្ត-រាជធានី ដើម្បីធានាប្រសិទ្ធភាពទាំងក្នុងការបំពេញមុខងារ និង ទាំងក្នុងការប្រើប្រាស់ធនធាន ៤. ការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ជាពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំ និងគ្រប់គ្រងស្ថាប័នសាធារណៈ ៥. ការដាក់ឲ្យអនុវត្តយន្តការតាមដាន និង វាយតម្លៃ ដើម្បីជំរុញ

ការអនុវត្ត កែលម្អវិធានការតម្រង់ទិសយុទ្ធសាស្ត្រ និង ពង្រឹងកិច្ចសហប្រតិបត្តិការ អន្តរក្រសួង សម្រាប់ការកសាង រៀបចំ និង អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ៦. ការពង្រឹងយន្ត ការចែករំលែក និង ការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ សេវាសាធារណៈនៅក្នុងការវិវឌ្ឍដ៏ឆាប់រហ័សនៃបរិការណ៍ជាតិ និង អន្តរជាតិ និង ៧. ការលើក កម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រី អនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្ត ពីសាធារណជនលើវិស័យយុត្តិធម៌ និងប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌នៅក្នុងសង្គម តាមរយៈ (ក)ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ (ខ)ការពង្រឹងភាពស្អាតស្អំ និង ក្រម សីលធម៌ វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់ (គ)ការពង្រឹងយន្តការវិន័យការងារ និង ការធ្វើ ទំនើបកម្មរដ្ឋបាលយុត្តិធម៌ (ឃ)ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និង (ង)ការពង្រឹង និង កែ លម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកប ដោយប្រសិទ្ធភាព។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.២២- ដើម្បីសម្រេចនូវគោលនយោបាយអាទិភាពសំខាន់ៗខាងលើ ***ក្រសួងមុខងារសាធា-រណៈ*** បាននិងកំពុងបន្តអនុវត្តសកម្មភាពការងារសំខាន់ៗដូចខាងក្រោម៖

- លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ
- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន
- កែទម្រង់ប្រព័ន្ធបៀវត្សនិងលាភការផ្សេងៗ
- ពង្រឹងយន្តការសម្របសម្រួលកំណែទម្រង់អន្តរវិស័យ និងដៃគូពាក់ព័ន្ធ
- ជំរុញតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- បណ្តុះបណ្តាលនិងអភិវឌ្ឍមន្ត្រីរាជការ
- ត្រួតពិនិត្យរដ្ឋបាលមន្ត្រីរាជការនិងការគ្រប់គ្រងក្របខណ្ឌ
- ធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

### កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៤.២៣- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដោយផ្តោតការយកចិត្តទុកដាក់លើ៖

ទី១ ធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងការចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ ដល់អង្គភាពរដ្ឋបាលគ្រប់កម្រិតក្រោមឱវាទ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបាន ស្វ័យភាពសមស្របទាំងការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្ស

និងហិរញ្ញវត្ថុ ទន្ទឹមនឹងការកំណត់ឲ្យបានច្បាស់លាស់នូវគណនេយ្យភាព និងការទទួលខុសត្រូវ របស់អង្គភាពសាធារណៈ និងមន្ត្រីសាធារណៈ

ទី២ ជំរុញនវានុវត្ត និងរដ្ឋបាលឯកភាព នៅក្នុងកម្រិត ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីធានាប្រសិទ្ធភាពទាំងក្នុងការបំពេញមុខងារ និង ការប្រើប្រាស់ធនធាន

ទី៣ ពង្រឹងយន្តការចែករំលែក និងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសារធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងការវិវឌ្ឍដ៏ឆាប់រហ័សនៃបរិការណ៍ជាតិ និងអន្តរជាតិ។

៤.២៤- ដើម្បីធានាដល់ការសម្រេចបាននូវគោលដៅ នៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ***គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)*** បានរៀបចំតាក់តែងនិងដាក់ឲ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការអនុវត្តកម្មវិធីជាតិ បានផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការជាអាទិភាពនិងចំណុចដៅមួយចំនួនដូចខាងក្រោម៖

- **បន្តការពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់** ដោយត្រូវធានាដល់ការលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ គ្រប់គ្រងសម្របសម្រួល និងអនុវត្តកិច្ចដំណើរការកំណែទម្រង់ បន្តពង្រឹងការធ្វើសុខដុមនីយកម្មជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យកាន់តែមានភាពផ្សារភ្ជាប់គ្នា កាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារកំណែទម្រង់ទាំងនេះ។
- **បន្តពង្រឹងនិងកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** កំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឲ្យកាន់តែមានភាពច្បាស់លាស់ និងការអភិវឌ្ឍមូលដ្ឋានកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម ដោយផ្តោតលើការពិនិត្យ និងការរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីធានាដល់ការលើកកម្ពស់តួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ឲ្យក្លាយជារដ្ឋបាលមូលដ្ឋានដ៏សំខាន់មួយក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ទន្ទឹមគ្នានេះ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏នឹងត្រូវបន្តពង្រឹង ដើម្បីលើកទឹកចិត្ត និងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាការងារ ដែលបានកំណត់ឲ្យកាន់តែបានល្អប្រសើរឡើង។

- **លើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធនមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ** ដោយផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងឲ្យទៅរដ្ឋ បាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការដាក់ពិន័យ និងកិច្ចការផ្សេងៗ
- **បន្តជំរុញការផ្ទេរមុខងារក្នុងវិស័យអាទិភាពនានាទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នដែលមានលទ្ធភាព និងសមត្ថភាពពេញលេញក្នុងការគ្រប់គ្រង ចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការ "**ច្រកចេញចូលតែមួយ**" នឹងត្រូវបន្តពង្រឹង ពង្រីក និងធ្វើទំនើបកម្មទៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេស ដើម្បីបង្កលក្ខណៈកាន់តែងាយស្រួលជូនប្រជាពលរដ្ឋក្នុងការទទួលបានសេវាឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។
- **បន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ** ដើម្បីធានាដល់ការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋ បាលថ្នាក់ក្រោមជាតិ រួមទាំងធនធានហិរញ្ញវត្ថុជាឆន្ទានុសិទ្ធិ និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ព្រមទាំង បន្តកែលម្អប្រព័ន្ធ និងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុ និងសមត្ថ-ភាពសមស្របក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព។

៤.២៥- ដើម្បីធានាដល់ការសម្រេចបាននូវគោលដៅ នៃការពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ លើកកម្ពស់ប្រសិទ្ធភាព និងសមត្ថភាពក្នុងការបំពេញមុខងារ និងការប្រើប្រាស់ធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ក្រសួងមហាផ្ទៃ បានផ្តោតការយកចិត្តទុកដាក់លើកិច្ចការជាអាទិភាព និងចំណុចដៅមួយចំនួនដូចខាងក្រោម៖

### ទី១ លើកកម្ពស់ប្រសិទ្ធភាព និងសមត្ថភាពក្នុងការបំពេញមុខងារ និងការប្រើប្រាស់ធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- **បន្តកែសម្រួលតួនាទី ភារកិច្ចរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ដោយជំរុញការតាមដានគាំទ្រលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ពង្រឹងការអនុវត្តច្បាប់ លើកកម្ពស់ស្វ័យភាព និងការទទួលខុសត្រូវ។

- **ពង្រឹង និង គាំទ្រការអនុវត្តការផ្ទេរមុខងារ និងធនធាន ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកសេវាសង្គម ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ នវានុវត្ត ប្រសិទ្ធភាពតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។
- **បន្តលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយផ្តល់ការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព តាមរយៈការបង្កើត និងអនុវត្តប្រព័ន្ធអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព កែលម្អប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ បង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដល់សាធារណជន និងអ្នកពាក់ព័ន្ធនានា។
- **បន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា** ដោយកៀគរធនធានចាំបាច់នានា ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាព និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈ មានភាពងាយស្រួល និងនៅកៀកជិតប្រជាពលរដ្ឋមូលដ្ឋាន។
- **បន្តពិនិត្យ តាមដាន និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយបន្តដឹកនាំសម្របសម្រួលគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តមុខងារត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា បន្តគាំទ្រលើកិច្ចការរដ្ឋបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ការអភិវឌ្ឍមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការក្នុងកម្រិតជាតិ និងអន្តរជាតិ ។

### ទី២ លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ

- **បន្តធ្វើកំណែទម្រង់ការគ្រប់គ្រងពន្ធនាគារ** ដោយគ្រប់គ្រងជនជាប់ឃុំប្រកបដោយសន្តិសុខ សុវត្ថិភាព និងមនុស្សធម៌ ក្រោមបរិយាកាសមានអនាម័យល្អ មានការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ និងមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។
- **បន្តគ្រប់គ្រងអត្តសញ្ញាណបុគ្គលឲ្យកាន់តែច្បាស់លាស់ ដែលមនុស្សគ្រប់រូបត្រូវបានកំណត់អត្តសញ្ញាណ** ដោយបង្កើនអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងលើកកម្ពស់ការងារអត្តសញ្ញាណកម្ម បន្តអភិវឌ្ឍនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន រៀបចំដាក់ឲ្យប្រើប្រាស់

ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជន និងដាក់ឲ្យដំណើរការប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្តល់សេវាជូនប្រជាជនប្រកប ដោយប្រសិទ្ធភាព និងតម្លាភាព។

- **បន្តពង្រឹងការធ្វើសវនកម្មផ្ទៃក្នុង និងលើកកម្ពស់សុចរិតភាពរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ការពង្រីកវិសាលភាព និងពង្រឹងគុណភាពក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងបន្តលើកកម្ពស់សុចរិតភាព និងពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អ នីតិវិធីដាក់ពាក្យបណ្តឹង ការរៀបចំវេទិកាសាធារណៈ ការផ្សព្វផ្សាយយុទ្ធសាស្ត្រ ស្តីពីគណនេយ្យភាពសង្គម និងការផ្សព្វផ្សាយ និងតាមដានសុចរិតភាពនៃអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **បន្តអនុវត្តមុខងារដែលបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យបានកាន់តែល្អប្រសើរ** ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តមុខងារដែលបានផ្ទេរ និងផ្តល់សេវារដ្ឋបាលនៅតាមការិយាល័យច្រកចេញចូលតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែល្អប្រសើរ និងបន្តជំរុញ គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។
- **បន្តជំរុញឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានផែនការ និងថវិកាសម្រាប់ផ្តល់សេវាសាធារណៈ** ធ្វើការណែនាំ និងគាំទ្រឲ្យមានការលើកជាផែនការ និងថវិកាច្បាស់លាស់សម្រាប់ការផ្តល់សេវាសាធារណៈនៅក្នុងមូលដ្ឋាន ការរៀបចំវេទិកាសាធារណៈ ការពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋ ដើម្បីប្រមូលធាតុចូលក្នុងការរៀបចំកសាងផែនការ និងថវិកា នៅថ្នាក់ក្រោមជាតិ និងបន្តជំរុញការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។
- **បន្តពង្រឹងការអនុវត្ត ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីគណបក្សនយោបាយ** បន្តធ្វើបច្ចុប្បន្នភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ បន្តធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីគណបក្សនយោបាយ បន្តគាំទ្រនិងផ្តល់សិទ្ធិសេរីភាពពេញលេញដល់សកម្មភាពស្របច្បាប់របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៤.២៦- ដើម្បីសម្រេចនូវគោលនយោបាយអាទិភាពសំខាន់ៗខាងលើ ***ក្រសួងយុត្តិធម៌*** បាននិងកំពុងបន្តអនុវត្តសកម្មភាពការងារសំខាន់ៗដូចខាងក្រោម៖

ទី១ បន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីឈានទៅសម្រេចឲ្យបានទិសដៅយុទ្ធសាស្ត្រទាំង៧ គឺ៖

- ពង្រឹងការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន។
- ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់។
- ជំរុញលទ្ធភាពឲ្យទទួលព័ត៌មានអំពីច្បាប់ និងតុលាការឲ្យប្រសើរឡើង។
- ធ្វើឲ្យគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ កាន់តែប្រសើរឡើង។

- ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ។
- បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់ និងតុលាការឲ្យអាចបំពេញអាណត្តិរបស់ខ្លួនបានជោគជ័យ។

ទី២ ការងារអភិវឌ្ឍច្បាប់ ៖

- រៀបចំច្បាប់ និងជំរុញការអនុម័តច្បាប់
- ពង្រឹង និងពង្រីកការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងស្ត្រី និងកុមារឲ្យបានទូលំទូលាយ។
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់ និងយុត្តិធម៌។

ទី៣ លើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយរឿងក្តី ក្រសួងយុត្តិធម៌នឹងត្រូវពង្រឹង និងពង្រីក៖

- ការបណ្តុះបណ្តាលច្បាប់មូលដ្ឋាន បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងស្ត្រី និងកុមារ និងជំនាញផ្សេងៗដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា និងអ្នកប្រកបវិជ្ជាជីវៈច្បាប់។
- យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- ការគ្រប់គ្រងបញ្ជីសំណុំរឿងក្តីតាមប្រព័ន្ធថ្មី។
- លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌។
- ការតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់។

ទី៤ ចំពោះការងារលើកកម្ពស់សមត្ថភាពគ្រប់គ្រងស្ថាប័ន ក្រសួងយុត្តិធម៌នឹងត្រូវ៖

- បង្កើនសមត្ថភាពការងារ និងពង្រឹងការអនុវត្តការងារគ្រប់គ្រងរួម។
- ពង្រីក កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រសួង និងតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។
- ពង្រឹង និងពង្រីកការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

## ១.៤- ការពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.២៧- នៅក្នុងនីតិកាលទី៦នៃរដ្ឋសភានេះរាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពលើ៖ ១. ការសិក្សា និងការរៀបចំក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យឯកជនដែលជាគោលការណ៍រួមដើម្បីធានាការគ្រប់គ្រង និង ការអនុវត្តល្អក្នុងវិស័យឯកជន ២. ការសិក្សា និង រៀបចំក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថានដើម្បីជំរុញការចូលរួមដោះស្រាយបញ្ហាសង្គម និង លើកកម្ពស់ការថែរក្សាបរិស្ថាន តម្លៃសីលធម៌សង្គម និង វប្បធម៌ជាតិ ព្រមទាំងពង្រឹងការការពារសិទ្ធិ និង សុវត្ថិភាពអតិថិជន តាមរយៈ

ការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការការពារអតិថិជន ៣. ការបន្តអនុវត្តយន្តការសន្ទនាក្នុងភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេសទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីជំរុញការពិភាក្សាផ្នែកគោលនយោបាយ និង ស្វែងរកដំណោះស្រាយបញ្ហាប្រឈមដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្ម និង ៤. ការជំរុញ និងការលើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគឡើងវិញលើការចូលរួមអភិវឌ្ឍមូលធនមនុស្ស និងនវានុវត្តន៍។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.២៨- ដើម្បីសម្រេចនូវគោលនយោបាយអាទិភាពសំខាន់ៗខាងលើ ***រាជរដ្ឋាភិបាលកម្ពុជា*** បាននិងកំពុងបន្តអនុវត្តសកម្មភាពការងារសំខាន់ៗដូចខាងក្រោម៖

- បន្តអនុវត្តនិងដំណើរការ**យន្ត*ការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន*** ដើម្បីបន្តដោះស្រាយកង្វល់ផ្សេងៗរបស់វិស័យឯកជន និងដើម្បីបន្តពង្រឹងវិស័យឯកជនឲ្យកាន់តែមានជីវភាពនិងឲ្យកាន់តែមានភាពជាម្ចាស់។
- លើកកម្ពស់សហគ្រិនភាព រួមទាំងសហគ្រាសធុនតូចនិងមធ្យម ជាពិសេសក្នុងចំណោមប្រជាជនកម្ពុជាឲ្យចេះធ្វើធុរកិច្ចនិងវិនិយោគ តាមរយៈការផ្តល់ការលើកទឹកចិត្ត ការប្រឹក្សា មូលធន និងបច្ចេកទេស។ បន្តពង្រឹងយន្តការ ***វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន*** ក្នុងទិសដៅជំរុញឲ្យយន្តការទាំងនេះឈានក្លាយទៅជា***វេទិកាអភិវឌ្ឍន៍កម្ពុជា*** ដែលជាយន្តការសម្រាប់ភាគីពាក់ព័ន្ធចូលរួមពិភាក្សាលើបញ្ហានានាក្នុងការអភិវឌ្ឍប្រទេស។

# ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

## ២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ក- គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៦

៤.២៩- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភាកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានជោគជ័យក្នុងការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដីតាមរយៈការសម្រាលស្ថានភាពតានតឹងនៅតំបន់មួយចំនួននៃព្រំដែន និង ការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដោយសន្តិវិធី ការទប់ស្កាត់ដោយជោគជ័យនូវចលនាបដិវត្តន៍ពណ៌ ការពង្រឹងស្ថិរភាពនយោបាយ នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការលើកកម្ពស់ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ការសម្រេចបាននូវការបោះឆ្នោតដោយជោគជ័យទាំងសកល និង អសកល និង ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ប្រកបដោយភាពសេរីត្រឹមត្រូវ និង យុត្តិធម៌ និង ការពង្រឹងការអនុវត្តច្បាប់ក៏ដូចជាសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈតាមរយៈការអនុ

វត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ "***ភូមិ-ឃុំមានសុវត្ថិភាព***" ព្រមទាំងការទប់ស្កាត់ និង បង្ក្រាបដោយជោគជ័យនូវបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមបញ្ចូលទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និង ហិរញ្ញប្បទានភេរវកម្ម ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធគ្រឿងញៀន ការជួញដូរមនុស្ស និង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ។

៤.៣០- នៅក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តោតអាទិភាពលើ៖ ១. ការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី ព្រមទាំងការទប់ស្កាត់ និង ប្រឆាំងដាច់ខាតរាល់សកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ ឬ ការញុះញង់ណាមួយដើម្បីធ្វើសកម្មភាពខុសច្បាប់ បង្កអស្ថិរភាពនយោបាយ ឬ ចលាចលក្នុងសង្គម ២. ការបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និង ការបន្តពង្រឹងបរិយាកាស និង ប្រក្រតីភាពក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ ៣. ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និង ទឹកជាមួយប្រទេសជិតខាងដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំនិងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព និង សហប្រតិបត្តិការ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំងនឹងប្រទេសជិតខាង ៤. ការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និង ហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងទៀត ព្រមជាមួយនឹងការបន្តជំរុញអនុវត្ត "***គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព***" ៥. ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់សាធារណៈ ៦. ការបន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និង ច្បាប់អន្តោប្រវេសន៍តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និង ព្រំដែនទឹកជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ និង ៧. ការពង្រឹងការអនុវត្តច្បាប់ និង កសាងសមត្ថភាពដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា។

## ខ- សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ សម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៣១- ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងមហាផ្ទៃ*** នឹងបន្តផ្តោតការយកចិត្តទុកដាក់លើ **ទី១** ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងការទប់ស្កាត់និងប្រឆាំងដាច់ខាតរាល់សកម្មភាពខុសច្បាប់បង្កអស្ថិរភាពនយោបាយ ឬចលាចលក្នុងសង្គម **ទី២** ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និងទឹកជាមួយប្រទេសជិតខាងដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំ និងជំរុញអនុវត្តយុទ្ធ

សាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង **ទី៣** ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងៗទៀត ព្រមជាមួយនឹងការបន្តជំរុញអនុវត្ត **"គោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព" ទី៤** ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ **ទី៥** ការបន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និងព្រំដែនទឹកជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ និង **ទី៦** ពង្រឹងការអនុវត្តច្បាប់ និងកសាងសមត្ថភាពដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា។

៤.៣២- ដើម្បីសម្រេចគោលនយោបាយអាទិភាពសំខាន់ៗខាងលើ ***ក្រសួងមហាផ្ទៃ*** នឹងត្រូវ៖

ទី១ **ពង្រឹងការការពារអធិបតេយ្យជាតិ និងអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍** ដោយបន្តការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី បន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹក បន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍។

ទី២ **ពង្រឹងវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស** ដោយបន្តទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងបន្តពង្រឹងការអនុវត្តច្បាប់ បន្តលើកកម្ពស់ចំណេះដឹង និងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីនៅបណ្ឌិត្យសភានគរបាល និងបន្តកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា។

ទី៣ **ពង្រឹងសុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ** ដោយបន្តពង្រឹងការអនុវត្តច្បាប់ ការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព និងបន្តរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាប្រចាំ។

៤.៣៣- ***ក្រសួងមហាផ្ទៃ*** នឹងបន្តអនុវត្តរបៀបវារៈជាអាទិភាព ដូចខាងក្រោម៖

**ទី១ ការពង្រឹងការការពារអធិបតេយ្យភាពជាតិ និងការអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍**

- **បន្តការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី** ព្រមទាំងការទប់ស្កាត់ និងប្រឆាំងដាច់ខាតរាល់សកម្មភាពខុសច្បាប់ បង្កអស្ថិរភាពនយោបាយ ឬចលាចលក្នុងសង្គម ពិសេសបង្ការទប់ស្កាត់ និងបំបាត់ប្រសិទ្ធភាពមិនឲ្យកើនមានឡើងចលនាបដិវត្តន៍

ពណ៌ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង។

- **បន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹក** ជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំ និងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការល្អ។
- **បន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍** ដោយបង្កើនប្រសិទ្ធភាពផ្តល់សេវាអន្តោប្រវេសន៍និងការគ្រប់គ្រងជនអន្តោប្រវេសន៍ បង្ការទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ការពារផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងចូលរួមអនុវត្តគោលនយោបាយបើកចំហជើងមេឃរបស់រាជរដ្ឋាភិបាលបន្តពង្រឹងប្រសិទ្ធភាពគ្រប់គ្រងវត្តមាននៃការស្នាក់នៅ និងការប្រកបមុខរបររបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។

**ទី២ ពង្រឹងវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស**

- **បន្តទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ** ដូចជាបទល្មើសព្រហ្មទណ្ឌ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។
- **បន្តពង្រឹងការអនុវត្តច្បាប់ និងកសាងសមត្ថភាព** ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា និងការសហការក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសនេះ បន្តអនុវត្តការងារឧក្រិដ្ឋវិទ្យាបម្រើយុទ្ធសាស្ត្រកាត់បន្ថយបទល្មើស បន្តការកត់ត្រា និងបញ្ចូលទិន្នន័យបទល្មើសមានភាពសុក្រឹត ទាន់សភាពការណ៍ ជំរុញអនុម័ត និងអនុវត្តច្បាប់ស្តីពីនគរបាលជាតិកាន់តែល្អប្រសើរឡើង អភិវឌ្ឍន៍កម្លាំងនគរបាលដោយការបណ្តុះបណ្តាល និងការត្រៀមមន្ត្រីបន្តវេនសម្រាប់រយៈពេលមធ្យម និងវែង។

**ទី៣ ពង្រឹងសុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ**

- **បន្តពង្រឹងការអនុវត្តច្បាប់ និងការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព** ដោយបន្តជំរុញការងារផ្សព្វផ្សាយអប់រំ ណែនាំប្រជាពលរដ្ឋ ឲ្យចូលរួមក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ គោរពច្បាប់ចរាចរណ៍ផ្លូវគោក បន្តរឹតបន្តឹងការអនុវត្តច្បាប់ និងការលើកកម្ពស់សមត្ថភាពជំនាញដល់មន្ត្រីនគរបាលសណ្តាប់ធ្នាប់ ចរាចរណ៍ បន្តលើកកម្ពស់ការយល់ដឹងស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក និងផ្លូវទឹក និងពន្យល់ប្រជាពលរដ្ឋឲ្យមានមនសិការចូលរួមអនុវត្តច្បាប់។

- **បន្តរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាប្រចាំ** ដោយបន្តរក្សាការពារសន្តិសុខ សុវត្ថិភាពគ្រប់ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ នៃការធ្វើបាតុកម្ម កូដកម្ម ដោយទប់ស្កាត់មិនឲ្យកើតមានអំពើហិង្សា។ បន្តជំរុញការចូលរួមពីសំណាក់ប្រជាពលរដ្ឋតាមសហគមន៍ ក្នុងចលនារក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ឲ្យមានការកើនឡើងជារៀងរាល់ឆ្នាំ។

## ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

៤.៣៤- ***អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*** នឹងបន្តដឹកនាំការអនុវត្តឲ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រទាំង៥របស់ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរួមមាន ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ៣. ការព្យាបាល ស្តារនីតិសម្បទានិងធ្វើសមាហរណកម្ម ៤. ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និង ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទាំង៥ខាងលើ ***អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន***បានដាក់ឲ្យអនុវត្តវិធានការយុទ្ធសាស្ត្រចំនួន៧ ដែលមានដូចខាងក្រោម៖

- អប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀនៈ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀននៅក្នុងសង្គម។ ការជំរុញរៀបចំយន្តការសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន។
- ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀនៈ ការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល។ រៀបចំបង្កើតរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន។
- ពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ៈ ជំរុញការអនុវត្តការងារនីតិកម្ម ឲ្យមានប្រសិទ្ធភាព ជំរុញការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន ក្នុងនោះរួមមាន៖ អនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដោយបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងទៅនឹងការចរាចរខុសច្បាប់គ្រឿងញៀន និង សារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៨៨ និង អនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឲ្យមានប្រសិទ្ធភាព។ បង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ និង បង្ក្រាប ការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែក

ចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងពង្រឹងប្រសិទ្ធភាពការងារស៊ើបអង្កេតរបស់ស្ថាប័នអនុវត្តច្បាប់។

- ត្រួតពិនិត្យសារធាតុគីមីផ្សំៈ ការបង្កើនការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។ ជំរុញការរៀបចំបទប្បញ្ញត្តិនានា និងទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅផលិតគ្រឿងញៀនខុសច្បាប់ ការរៀបចំផែនការគ្រប់គ្រង និង ត្រួតពិនិត្យការផលិត និងការចរាចរប្រេងរុក្ខជាតិដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់ចម្រាញ់ចេញពីដើមម្រះព្រៅភ្នំនិងរុក្ខជាតិផ្សេងៗទៀត។
- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែនៈ ការជំរុញយន្តការភូមិឃុំស គ្មានគ្រឿងញៀននៅតាមតំបន់ព្រំដែន។
- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍនានាៈ ការពង្រឹង និងពង្រីកការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាគ្រឿងញៀនអន្តរជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។
- ពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ពង្រឹងរចនាសម្ព័ន្ធរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

៤.៣៥- ដើម្បីពង្រឹងតម្លៃរបស់គ្រួសារនិងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំសង្គមកម្ពុជា ***ក្រសួងធម្មការនិងសាសនា*** នឹងបន្តជំរុញលើកកម្ពស់យ៉ាងសកម្មនូវតួនាទីរបស់គ្រួសារ និងការផ្សារភ្ជាប់ទៅនឹងតម្លៃជាប្រពៃណីនៃសាសនារបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបន្តពង្រឹងពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះពុម្ពផ្សាយគម្ពីរដីកា ក្បួនច្បាប់នានា និងពង្រឹងការប្រតិបត្តិធម៌វិន័យ ដោយសហការជាមួយ**សម្តេចព្រះសង្ឃរាជ** និង**សម្តេចព្រះសង្ឃនាយក**ទាំងពីរគណៈ ទន្ទឹមនឹងនេះក្រសួងគាំទ្រសកម្មភាព និងលើកកម្ពស់សិទ្ធិសេរីភាពខាងជំនឿសាសនាផ្សេងៗទៀតដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គម។

៤.៣៦- នៅក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ ***ក្រសួងធម្មការនិងសាសនា*** នឹងបន្តដាក់ចេញនូវគោលនយោបាយអាទិភាពមួយគឺ "***លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គមនិងសុខដុមនីយកម្មសាសនា***" ដែលអមដោយសកម្មភាពស្នូលដូចខាងក្រោម៖

- **ការងារវិស័យពុទ្ធិកសិក្សា**
  - បន្តសម្របសម្រួលការងារពុទ្ធិកសិក្សា សំដៅបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃពីកម្រិតធម្មវិន័យ រហូតដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា។
  - បន្តធ្វើសហប្រតិបត្តិការអន្តរជាតិវិស័យធម្មការ និងសាសនា។
  - បន្តពង្រឹងការបណ្តុះបណ្តាលធនធានមនុស្ស (ព្រះសង្ឃ) ពីកម្រិតបឋមរហូតដល់ឧត្តមសិក្សាឲ្យបានសមស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។

- បន្តពង្រីកសាលាពុទ្ធិកសិក្សាទៅតាមមូលដ្ឋាន។

- **ពង្រឹង និងពង្រីកការគ្រប់គ្រងផ្សព្វផ្សាយព្រះពុទ្ធសាសនា និងរក្សាសុខដុមនីយកម្មខាងជំនឿសាសនា**
  - រៀបចំអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស និងផ្សព្វផ្សាយតាមរាជធានីខេត្ត។
  - បន្តយកចិត្តទុកដាក់សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រីកការផ្សព្វផ្សាយព្រះធម៌ តាមរយៈនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម។
  - បន្តផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនាអប់រំនៅតាមសាលារៀនតាមរយៈកម្មវិធីទស្សនាទានព្រះពុទ្ធសាសនា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។
  - យកចិត្តទុកដាក់សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើកកម្ពស់ដល់ការសិក្សាស្រាវជ្រាវ និងចងក្រងនូវរាល់គម្ពីរ ក្បួនតម្រា ក្បួនរៀបមង្គល ពិធីបុណ្យផ្សេងៗ និងពិធីកិច្ចសាសនា។
  - បន្តទំនាក់ទំនងនិងសហការជិតស្និទ្ធ ជាមួយមេដឹកនាំពាហិរសាសនាក្នុងវិស័យកិច្ចការសាសនា។
  - បន្តរៀបចំច្បាប់ និងគោលនយោបាយសម្រាប់ការគ្រប់គ្រង និងរៀបចំរចនាសម្ព័ន្ធសាសនាគ្រប់និកាយទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  - បន្តទំនាក់ទំនងជាមួយបណ្តាប្រទេសនិងអង្គការ សមាគមចរិកសាសនាដើម្បីស្វែងយល់ពីសាសនាផ្សេងៗលើសកលលោក។
  - បន្តណែនាំ និងត្រួតពិនិត្យអង្គការសាសនាក្រោមឱវាទក្រសួង វត្តអារាម និកាយសាសនា មណ្ឌលសិក្សាស្រាវជ្រាវសាសនានានា និងរាល់អង្គការសមាគមដែលមានចរិតសាសនា ឲ្យប្រតិបត្តិ និងធ្វើសកម្មភាពសាសនាឲ្យស្របតាមច្បាប់របស់រដ្ឋ។
  - បន្តធ្វើអធិការកិច្ចលើវិស័យសាសនា និងសម្របសម្រួលដោះស្រាយអធិករណ៍
  - បន្តជំរុញការបង្កើតបណ្ណាល័យនៅតាមវត្តអារាមនានា សម្រាប់ជាប្រយោជន៍ដល់សាធារណៈជន រួមទាំងបព្វជិត ទាំងគ្រហស្ថ ក្នុងព្រះរាជាណាចក្រកម្ពុជា។
  - បន្តលើកទឹកចិត្តឲ្យគ្រប់សាសនាទាំងអស់ ចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជំរុញវត្តអារាម និងវិហារសាសនានានា ឲ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ វប្បធម៌ និងសង្គមកិច្ច រក្សានូវសុខដុមនីយកម្ម និងសេរីភាពខាងជំនឿសាសនាទាំងអស់។

## ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍ

## ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៣៧- ក្នុងនីតិកាលកន្លងទៅនេះ រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការរក្សាស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដោយសម្រេចបានកំណើនមធ្យមក្នុងរង្វង់ប្រមាណ៧% ក្នុងមួយឆ្នាំ ដែលតាមរយៈនេះ កម្ពុជាបានក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៦ និងរំពឹងថានឹងចាកចេញផុតពី***ប្រទេសមានការអភិវឌ្ឍតិចតួច*** ហើយឡើងឋានៈជា***ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០***។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តខិតខំដើម្បីសម្រេចឲ្យបានការកាត់បន្ថយភាពក្រីក្រជាង១%ក្នុងមួយឆ្នាំ និងឈានទៅសម្រេចឲ្យបាន***គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០***។ អត្រា អតិផរណាត្រូវបានរក្សាឲ្យស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបានខណៈដែលអត្រាប្តូរប្រាក់បន្តមានស្ថិរភាពក្នុងរង្វង់៤ ០៥០រៀល ក្នុងមួយដុល្លារអាមេរិក។ ទន្ទឹមនេះទុនវិនិយោគទាំងផ្នែកឯកជននិងសាធារណៈ ដែលត្រូវបានអនុម័តចាប់ពីឆ្នាំ២០១៣ មកដល់ ២០១៧ មានទំហំសរុប ២៧,៧ប៊ីលានដុល្លារអាមេរិក ដែលបញ្ជាក់ពីទំនុកចិត្តខ្ពស់របស់វិនិយោគិនមកលើបរិយា កាសវិនិយោគរបស់កម្ពុជា។

៤.៣៨- ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រផ្នែកម៉ាក្រូសេដ្ឋកិច្ច រាជរដ្ឋាភិបាលនីតិកាលទី៦នឹងផ្តោតអាទិភាពលើ៖

- ទី១ ការបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយប្រុងប្រយ័ត្ន ដោយប្រកាន់យកនូវការផ្សំនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និង ការកែទម្រង់រចនាសម្ព័ន្ធ ដែលមានលក្ខណៈបុរេសកម្មតែប្រយ័ត្នប្រយែង ដើម្បីធានាឲ្យបាននូវស្ថិរភាពកំណើន អតិផរណាទាប ស្ថិរភាព អត្រាប្តូរប្រាក់ និង ជំរុញការវិនិយោគ។
- ទី២.ការរៀបចំនូវយន្តការគ្រប់គ្រងវិបត្តិ និង ហានិភ័យផ្នែកសេដ្ឋកិច្ច ដែលអាចកើនឡើងក្នុងវិស័យហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និង វិស័យមិនមែនធនាគារ ទាំងវិស័យអចលនទ្រព្យ និង ក្នុងវិស័យដទៃផ្សេងទៀត។
- ទី៣.ការជំរុញបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និង ការជំរុញការអនុវត្តច្បាប់នេះ រួមទាំងច្បាប់ស្តីពីតំបន់ សេដ្ឋកិច្ចពិសេសផងឲ្យមានប្រសិទ្ធភាពខ្ពស់។
- ទី៤.ការជំរុញរៀបចំការកែទម្រង់ប្រព័ន្ធពន្ធដារគ្រប់ជ្រុងជ្រោយ និង ស៊ីជម្រៅ រួមទាំងការរៀបចំច្បាប់ស្តីពីសារពើពន្ធថ្មីផង ដោយឈរលើគោលការណ៍បង្កើនប្រសិទ្ធភាពប្រមូលចំណូលថវិកាជាតិ ធានាបាននូវបរិយាកាសប្រកួតប្រជែងដោយតម្លាភាព គណនេយ្យភាព ស្មើភាព និង យុត្តិធម៌ លើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ច ធុរកិច្ច និង ការវិនិយោគព្រមទាំងធានាបាននូវសមធម៌សង្គម។

ទី៥.ការរៀបចំ និង ជំរុញអនុវត្តនូវយន្តការសម្រួលដល់ការបង្កើតធុរកិច្ចថ្មី ដោយកាត់បន្ថយពេលវេលានៃការចុះបញ្ជី ការស្នើសុំអាជ្ញាបណ្ណ និង នីតិវិធីពាក់ព័ន្ធផ្សេងៗទៀតព្រមទាំងរៀបចំកែលម្អនូវសេវាសាធារណៈដែលបម្រើធុរជន ឬដំណើរការធុរកិច្ច។

ទី៦.ការបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ដោយបញ្ចប់នូវការរៀបចំប្រព័ន្ធបញ្ជរជាតិតែមួយ ការកែលម្អយន្តការត្រួតពិនិត្យនៅតាមព្រំដែនឲ្យស្ថិតក្នុងកម្រិតអប្បបរមា និងការបន្តកាត់បន្ថយនីតិវិធីដែលមិនចាំបាច់ និង ជាឧបសគ្គដល់ពាណិជ្ជកម្ម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

## កំណើនប្រកបដោយចីរភាព

៤.៣៩- ដើម្បីសម្រេចឲ្យបាននូវបណ្តាគោលនយោបាយអាទិភាព សម្រាប់នីតិ កាលទី៦ នៃ រដ្ឋសភា ***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គណៈកម្មាធិការវិនិយោគកម្ពុជា*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈ (១)ពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ (២)គ្រប់គ្រងកំណើនឥណទានក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យឲ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម (៣)បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតសម្រាប់វិស័យឯកជន ដូចជា៖ ការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណនិងទីផ្សាររូបិយបណ្ណ និងការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម (៤)បន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ និងខិតខំជំរុញការអភិវឌ្ឍលំនៅឋានដែលមានថ្លៃសមរម្យ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង (៥)បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកនៅតាមទីជនបទពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។
- ជំរុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងធន់នឹងវិបត្តិ តាមរយៈ (១) ការបង្កើនសមត្ថភាពប្រកួតប្រជែងកម្ពុជា (២)ការជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច។
- ពន្លឿនការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈ (១)កាត់បន្ថយចំណាយលើការធ្វើធុរកិច្ច ដោយពិនិត្យជាចាំបាច់លើបញ្ញាបទប្បញ្ញត្តិ នីតិវិធីនៃការអនុវត្ត និងចំណាយលើសេវាសាធារណៈ ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកកម្ពុជាឲ្យមានប្រសិទ្ធភាព និង (៣)ពង្រឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពទាំងជំនាញកម្រិតទាប មធ្យម និងខ្ពស់សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។
- រៀបចំលិខិតបទដ្ឋានគតិយុត្តចំនួន៤ គឺ (១)រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ (២)រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់

គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន (៣)រៀបចំច្បាប់គ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ (៤)រៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទំនិញប្រើប្រាស់រួច និង រៀបចំស្តង់ដាវាយតម្លៃអចលនវត្ថុ។

- បន្តពង្រឹងចំណេះដឹង និងទំនុកចិត្តរបស់ប្រជាជនកម្ពុជាលើវិស័យធានារ៉ាប់រង តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងអន្តរការីធានារ៉ាប់រង។
- ពង្រឹងការគ្រប់គ្រងការលក់ផលិតផលធានារ៉ាប់រងតាមរយៈទូរគមនាគមន៍ ដោយបង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។
- បន្តអភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈការជំរុញ និងការលើកទឹកចិត្តសហគ្រាស និងក្រុមហ៊ុនឲ្យបោះផ្សាយលក់មូលបត្រសាធារណៈ ការលើកកម្ពស់ការជួញដូរ និងការពិនិត្យអំពីតម្រូវក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋ។
- បង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា។
- បង្កើតយន្តការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា។
- គ្រប់គ្រង បោះផ្សាយមូលបត្ររដ្ឋ ការគ្រប់គ្រងសាច់ប្រាក់ និងប្រតិបត្តិការទីផ្សារចំហ។
- គ្រប់គ្រងការបោះផ្សាយមូលបត្រត្រេជ្ជអធិបតេយ្យ។
- អភិវឌ្ឍន៍ប៊ុនម៉ាកឃាលយូរ។
- បង្កើតស្ថាប័នវាយតម្លៃកម្រិតឥណទាន។
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតទីផ្សារឌុមុឌីធីអនាគត។
- សិក្សាលក្ខណៈភូមិសាស្ត្រនិងស្វែងរកដៃគូរក្នុងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ។
- ពង្រឹងការកៀរគរចំណូលពីវិស័យកាស៊ីណូឲ្យអស់លទ្ធភាព ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ និងជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងវិស័យកាស៊ីណូ។
- រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- រៀបចំសេចក្តីព្រាងច្បាប់វិនិយោគថ្មី និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។
- បន្តពង្រឹង និងពង្រីកវិស័យឯកជន តាមរយៈការធ្វើឱ្យកាន់តែមានប្រសិទ្ធភាពលើកិច្ចការគ្រប់គ្រង និងសម្របសម្រួលការងារវិនិយោគឯកជន ក៏ដូចជាការជំរុញ ទាក់ទាញ គាំទ្រ និងថែទាំការវិនិយោគឯកជន។
- ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការតាមដាននិងត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការគោរពគោលការណ៍និងលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន។

- ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់អ្នកវិនិយោគ ក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ។
- រៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយ និងទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់។
- បង្កបង្កើតបរិយាកាសអំណោយផល សម្រាប់ទទួលការវិនិយោគទាំងក្នុងនិងក្រៅប្រទេស រួមមានការសម្រួលការចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ជាពិសេសតាមយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កើនល្បឿនរាល់ប្រតិបត្តិការ នានាទាក់ទងនឹងធុរកិច្ចនិងវិនិយោគ ព្រមទាំងការកាត់បន្ថយចំណាយក្រៅផ្លូវការ។

៤.៤០- ដើម្បីសម្រេចឱ្យបាននូវបណ្តាគោលនយោបាយអាទិភាព សម្រាប់នីតិកាលទី៦ នៃ រដ្ឋសភា ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

ទី១ ការចុះបញ្ជីពាណិជ្ជកម្ម៖ ១)ពង្រីក និងពង្រឹងការផ្តល់សេវាតាមរយៈការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មឱ្យមានលក្ខណៈប្រកួតប្រជែងនៅក្នុងបណ្តាប្រទេសអាស៊ាន ២) បង្កើនប្រសិទ្ធភាពការងារចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីឱ្យប្រទេសកម្ពុជាទទួលបាននូវចំណាត់ថ្នាក់ប្រសើរនៅក្នុងការវាយតម្លៃរបស់ធនាគារពិភពលោក (ភាពងាយស្រួលក្នុងការចាប់ផ្តើម និងធ្វើពាណិជ្ជកម្មជារៀងរាល់ឆ្នាំ)។

ទី២ កិច្ចការកម្មសិទ្ធិបញ្ញា៖ ១)ធ្វើឱ្យប្រសើរឡើងដល់លទ្ធភាព និងសមត្ថភាពក្នុងការគ្រប់គ្រង ដើម្បីផ្តល់និងប្រើប្រាស់សេវាកម្មសិទ្ធិបញ្ញាក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ២)ធ្វើឱ្យប្រសើរឡើងដល់លទ្ធភាពនិងសមត្ថភាពរដ្ឋាភិបាលកម្ពុជាដើម្បីផ្តល់នូវគោលនយោបាយកម្មសិទ្ធិបញ្ញា និងសេវាកម្មក្នុងការគាំទ្រវិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌និងឧស្សាហកម្មទេសចរណ៍កម្ពុជា ៣)បង្កើនចំណេះដឹង និងការយល់ដឹងក្នុងស្រទាប់ប្រជាជនទូទៅអំពីតួនាទីកម្មសិទ្ធិបញ្ញាទៅលើវិស័យសេដ្ឋកិច្ចដើម្បីគាំទ្រការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា ដោយធុរៈជនកម្ពុជា និង៤) អភិវឌ្ឍន៍និងរក្សាច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជាឱ្យស្របជាមួយបទដ្ឋានអន្តរជាតិដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចនិងសង្គមកម្ពុជា។

ទី៣ អភិវឌ្ឍន៍កិច្ចការនាំចេញ-នាំចូល៖ ១)ពង្រឹងការធ្វើប្រតិភូកម្មនៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី ដល់មន្ទីរពាណិជ្ជកម្មទៅតាមបណ្តាខេត្តជាប់ព្រំដែន ២)ពង្រឹង និងពង្រីកការអនុវត្តគម្រោងការប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ប្រភពដើមទំនិញក្នុងអាស៊ាន ៣)ពង្រឹងការថែទាំ កែលម្អប្រព័ន្ធស្វ័យប្រវត្តិ

កម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងតភ្ជាប់ C/O ទម្រង់D នៅក្នុងប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជា និងរៀបចំបន្ថែមC/O ទម្រង់ផ្សេងៗស្របតាមវិធានប្រភពដើមនៃប្រទេសនាំចូល ៤)រៀបចំបណ្តុះបណ្តាលនិងផ្សព្វផ្សាយការចុះបញ្ជីសម្រាប់អ្នកនាំចេញទៅសហគមន៍អឺរ៉ុប។

ទី៤ ពង្រឹងការត្រួតពិនិត្យទំនិញ ការពារអ្នកប្រើប្រាស់ និងកិច្ចការប្រកួតប្រជែង៖ ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវាទប់ស្កាត់សកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ រាំងស្កាត់និងបង្ក្រាបនូវការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលហួសកាលបរិច្ឆេទប្រើប្រាស់គ្មានអនាម័យមានចម្លងមេរោគមានសារធាតុគីមីហាមឃាត់ ឬខូចគុណភាព ។

## ចីរភាពបរិស្ថាន

៤.៤១- ការគ្រប់គ្រងបរិស្ថាននិងការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាប្រឈមមួយទៀតសម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមកម្ពុជា ដោយសារសម្ពាធពីកំណើនប្រជាជន ចរន្តនគរូបនីយកម្ម វិបុលកម្ម និងប្រពលវប្បកម្មកសិកម្ម ក៏ដូចជាការអភិវឌ្ឍវិស័យដឹកជញ្ជូន ថាមពល និងវិស័យដទៃទៀត។ បញ្ហាប្រឈមផ្នែកបរិស្ថានភាគច្រើនមានលក្ខណៈអន្តរ-វិស័យ ដែលទាមទារឲ្យមានការសម្របសម្រួលរវាងស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិព្រមទាំងកិច្ចសហការជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ។

៤.៤២- ក្នុងនីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងបរិស្ថាន និង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព*** នឹងបន្តប្រកាន់យកនូវអភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការគ្រប់គ្រងបរិស្ថាននៅកម្ពុជា តាមរយៈ៖

***ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា***

- ធានាសង្គតិភាពលើការរៀបចំអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធីនិរន្តរភាពរបស់ជាតិ និងការបន្សុីអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធីគោលនយោបាយថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដែលកម្ពុជាបានចូលជាភាគីសមាជិក។
- ជំរុញការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យានវានុវត្តន៍ ការកសាងធនធានមនុស្ស ការលើកកម្ពស់ការយល់ដឹង ការប្រើប្រាស់បច្ចេកវិទ្យាបៃតង និងបច្ចេកវិទ្យានុយក្លេអ៊ែរសម្រាប់បម្រើឲ្យគោលបំណងសន្តិភាពដើម្បីគាំទ្រការអភិវឌ្ឍដោយចីរភាព។
- ធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីបង្កើនការចូលរួមចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះរបស់កម្ពុជា។
- រៀបចំនិងគាំទ្រការអនុវត្តរបៀបវារៈនៃការស្រាវជ្រាវដើម្បីធានាការអភិវឌ្ឍដោយចីរភាព។

- ជំរុញការដាក់បញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានិរន្តរភាពបរិស្ថាន និង ធនធានធម្មជាតិ។
- ជំរុញនិរន្តរភាពក្នុងការអភិវឌ្ឍ ដែលធានាបាននូវវិបុលភាពសេដ្ឋកិច្ច ទន្ទឹមនឹងរក្សាការពារគុណភាពបរិស្ថាន ការរស់នៅដោយចីរភាព និងភាពពេញលេញនៃធនធានធម្មជាតិ
- អនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនៅក្នុងទីក្រុង/ទីប្រជុំជន

*ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

- ធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការទទួលខុសត្រូវភាពម្ចាស់ការ សំដៅធានានិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន។
- ជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងបង្កលក្ខណៈងាយស្រួលសម្រាប់វឌ្ឍនភាពនៃការកសាងសង្គមមួយដែលបញ្ចេញកាបូនតិច។
- បង្កើតផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

*ជីវៈចម្រុះ និងជីវសុវត្ថិភាព ៖*

- ធានានិរន្តរភាពមុខងារ និងតួនាទីពេញលេញរបស់ធនធានជីវៈចម្រុះ ជីវសុវត្ថិភាព និងប្រព័ន្ធអេកូឡូស៊ី។
- បង្កើតក្របខ័ណ្ឌគោលនយោបាយសម្រាប់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី។

***កិច្ចគាំពារបរិស្ថាន***

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការទប់ស្កាត់ កាត់បន្ថយ ការបំពុលបរិស្ថាន ទឹក ដី ខ្យល់ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។
- ពង្រឹងសមត្ថភាព និងពង្រីកវិសាលភាពការងារតាមដានគុណភាពបរិស្ថាន។
- ពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាននៅតាមទីតាំងប្រភពបំពុល និងជំរុញការបំពាក់ឧបករណ៍ស្វ័យប្រវត្តកម្មតាមដានការបញ្ចេញសារធាតុបំពុលទៅក្នុងបរិស្ថាន។
- លើកកម្ពស់ការអនុវត្តកម្មវិធីកាត់បន្ថយ ការប្រើប្រាស់និងកែច្នៃសំណល់(3R)ដើម្បីកាត់បន្ថយបរិមាណសំណល់ឲ្យនៅកម្រិតអប្បបរមា។
- ជំរុញការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគ្រប់គម្រោងវិនិយោគទាំងគម្រោងសារធារណៈនិងឯកជន និង បង្កើនប្រសិទ្ធភាពតាមដានការអនុវត្ត

ផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន ព្រមទាំងជំរុញឲ្យម្ចាស់គម្រោងឲ្យបង់មូលនិធិបរិស្ថាននិងសង្គមនិងមូលនិធិទាយជ្ជទានបរិស្ថាន។

***ការគ្រប់គ្រងតំបន់ការពារធម្មជាតិ***

- ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ។
- កំណត់ព្រំប្រទល់ កំណត់តំបន់និងបែងចែកគ្រប់គ្រង និង ចុះបញ្ជិកាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ តំបន់ការពារធម្មជាតិនីមួយៗ។
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង តាមរយៈការបំពាក់សម្ភារៈ ឧបករណ៍ទំនើប និងការបណ្តុះបណ្តាលស្តីពីពង្រឹងការអនុវត្តច្បាប់ និងជំនាញពាក់ព័ន្ធតាមការចាំបាច់នៃតំបន់នីមួយៗ។
- ជំរុញការធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សាស្រាវជ្រាវកំណត់តំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត។
- ដោះស្រាយទំនាស់ដីធ្លីនៅក្នុងតំបន់ការពារធម្មជាតិ។
- ជំរុញការ បង្កើនគម្របព្រៃឈើ តាមរយៈការការពារ និងការដាំស្តារព្រៃឈើឡើងវិញ និងលើកកម្ពស់ការអភិរក្សប្រភពដើមធនធានសេនេទិក រុក្ខជាតិព្រៃឈើ និង សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ។
- ជំរុញ ការអនុវត្ត ផែនការយុទ្ធសាស្ត្ររេដបូកជាតិ ដោយត្រូវបង្កើនកិច្ចសហការអនុវត្តជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ រួមទាំងផ្នែកឯកជន។
- ពង្រឹង និងពង្រីកកិច្ចសហការជាមួយដៃគូអន្តរជាតិ គ្រឹះស្ថានសិក្សា លើសារៈសំខាន់ធនធានតំបន់ការពារធម្មជាតិ។

***ការអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន***

- ពង្រឹងនិងពង្រីកសកម្មភាពអប់រំបរិស្ថាន បង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ការធ្វើបច្ចុប្បន្នកម្មទិន្នន័យនិងស្ថិតិបរិស្ថាន ជំរុញការចូលរួមប្រតិបត្តិសកម្មភាពមេត្រីភាពបរិស្ថានឲ្យបានផុសផុលសំដៅសម្រេចឲ្យបាននូវការលើកកម្ពស់ការចូលរួមរបស់សាធា-រណជនឲ្យកាន់តែប្រសើរឡើងក្នុងកិច្ចគាំពារបរិស្ថានការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

***ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគ្រប់គ្រងតំបន់បេតិកភណ្ឌ***

- បន្តធ្វើការសិក្សារៀបចំចងក្រង បង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីៗ បន្ថែមទៀត
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បន្តការងារទាក់ទងនឹងការរៀបចំបង្កើតបណ្តាញសហគមន៍តំបន់ការពារធម្មជាតិ ដែលរួមមានថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់គណៈកម្មការតំបន់ការពារធម្មជាតិ។

- ជំរុញការលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈការពង្រីក និងបង្កើតមុខរបរសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ។
- សមាហរណកម្មសកម្មភាពនៅក្នុងផែនការគ្រប់គ្រងសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់។
- លើកកម្ពស់ការរៀបចំនិងអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចមូលដ្ឋាន កម្រិតជីវភាពប្រជាសហគមន៍ ក៏ដូចជាការការពារនិងអភិរក្សធនធានធម្មជាតិ។
- ពង្រឹងការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័ននិងដៃគូពាក់ព័ន្ធ។

## ២.៣- ការពង្រឹងភាពម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៤៣- រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចលទ្ធផលជាច្រើន ដោយបានដាក់ឲ្យអនុវត្ត *"យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៤-២០១៨"* ដោយបានកំណត់គោលការណ៍ និង ឧបករណ៍មួយចំនួនសម្រាប់ជាមូលដ្ឋានក្នុងការពង្រីកភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ព្រមទាំងបានបង្កើន និង ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិនានា និងជាមួយបណ្តាប្រទេសជាមិត្តចំនួន១៧២ប្រទេស និងមានស្ថានតំណាងកម្ពុជាប្រចាំនៅបរទេសសរុបចំនួន៦០ (ស្ថានឯកអគ្គរាជទូតចំនួន២៥ ស្ថានបេសកកម្មអចិន្ត្រៃយ៍ចំនួន៤ ស្ថានអគ្គកុងស៊ុលចំនួន១០ ស្ថានកុងស៊ុលកិត្តិយសចំនួន២១)។ ក្នុងកម្រិតអាស៊ាន និង រវាងដៃគូសន្ទនារបស់អាស៊ាន កម្ពុជាបានធ្វើការងារយ៉ាងសកម្មជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ ដើម្បីសម្រេចបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយដែលផ្អែកលើវិធានច្បាប់ ដោយយកចិត្តទុកដាក់លើប្រជាជន និង យកប្រជាជនជាស្នូល។ គិតចាប់ពីឆ្នាំ២០០៨មក កម្ពុជាកៀរគរធនធានហិរញ្ញប្បទានសហប្រតិបត្តិការបានជាមធ្យមប្រមាណជាង១ប៊ីលានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ លើសពីនេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ឲ្យអនុម័ត *"ច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល"* ដើម្បីបង្កើតបរិយាកាសភាពជាដៃគូប្រកបដោយសុខដុមនីយកម្ម។

៤.៤៤- ការពិនិត្យឡើងវិញអំពីសមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាព បានបង្ហាញយ៉ាងច្បាស់ថា បរិការណ៍អភិវឌ្ឍន៍របស់កម្ពុជា ក៏ដូចជាសកលលោក តម្រូវឲ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ឲ្យបានខ្ពស់បន្ថែមទៀតក្នុងនីតិកាលទី៦ នៃរដ្ឋសភាលើ៖

ទី១-ការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយបណ្តាតួអង្គអភិវឌ្ឍដើម្បីកៀរគរធនធានហិរញ្ញប្បទាន ពីគ្រប់ប្រភពយកមកបម្រើឲ្យកិច្ចប្រឹងប្រែងសម្រេចឲ្យបាននូវ

*គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០* ដោយឈរលើគោលការណ៍ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល។

ទី២-ការរៀបចំ និង អនុវត្ត *"យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៩-២០២៣"* ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល លើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និង ចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អភិវឌ្ឍយន្តការគណនេយ្យភាពសង្គម ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្សក្នុងបរិការណ៍ដែលកម្ពុជាសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតាជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងតែរៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច។

ទី៣-ការបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក ដើម្បីបង្កើនកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេស ពិសេសទាក់ទាញនូវទំនុកចិត្តមកលើសុខសន្តិភាព សុវត្ថិភាព និង បរិស្ថានវិនិយោគរបស់កម្ពុជា ក៏ដូចជាដើម្បីគោលដៅនៃការលើកកម្ពស់កិត្យានុភាពរបស់កម្ពុជាផងដែរ។

ទី៤-ការបន្តអនុវត្តនូវការប្តេជ្ញានានាដែលកម្ពុជាបានឯកភាពនៅក្នុងវេទិកាអន្តរជាតិស្តីពីស័ក្តិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍព្រមជាមួយនឹងការបន្តពង្រឹងការអនុវត្តយន្តការពិគ្រោះយោបល់ដែលមានស្រាប់សម្រាប់ពិភាក្សាលើប្រធានបទនានាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសជាតិ។

ទី៥-ការបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការនេះ។

ទី៦-ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ការបង្កើតបន្ថែមនូវយន្តការថ្មីៗ ដើម្បីទាក់ទាញការវិនិយោគថែមទៀត ទាំងពីវិស័យឯកជន និង ពីស្ថាប័នអភិវឌ្ឍផ្លូវការ ក៏ដូចជាដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម ជំរុញការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្ម និង កសិកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៤៥- ក្នុងនីតិកាលទី៦ រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ៖

ទី១ រៀបចំ និងអនុវត្ត*យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូឆ្នាំ ២០១៩-២០២៣* ដើម្បីបន្តពង្រឹង និងតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍជាមួយអាទិភាពនៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និងតម្រឹមជាមួយគោលការណ៍សកលស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍដែលផ្តោតសំខាន់លើភាពជាម្ចាស់ ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងលទ្ធផលសម្រាប់ជាមូលដ្ឋានក្នុងការកៀរគរធនធានអភិវឌ្ឍជាតិ។

ទី២ បន្តពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ដោយបញ្ចូលគោលការណ៍សកលស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍទៅក្នុងគោលការណ៍ និងយន្តការជាតិក្នុងការការគៀរគរ និងសម្របសម្រួលការប្រើប្រាស់ធនធានអភិវឌ្ឍ។

ទី៣ បន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ក្នុងការគៀរគរហិរញ្ញប្បទានអភិវឌ្ឍពីគ្រប់តួអង្គអភិវឌ្ឍទាំងអស់ដើម្បីធានាសង្គតិភាព លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងពង្រឹងការប្រើប្រាស់ប្រព័ន្ធជាតិ។

ទី៤ បន្តចូលរួមយ៉ាងសកម្មក្នុងវេទិកាសកលស្តីពីភាពស័ក្តិសិទ្ធក្នុងកិច្ចអភិវឌ្ឍ និងបន្តពង្រឹងការអនុវត្តយន្តការពិគ្រោះយោបល់ដែលមានចែងក្នុង ***យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូឆ្នាំ ២០១៩-២០២៣***។

ទី៥ ពង្រឹងកិច្ចអភិវឌ្ឍផ្តោតលើលទ្ធផល ដោយរៀបចំប្រព័ន្ធតាមដាន និងគោលការណ៍ ស្តីពីគណនេយ្យភាពទ្វេទិស ដើម្បីជាមូលដ្ឋានសម្រាប់ពង្រឹងភាពជាដៃគូដោយផ្អែកលើសក្ខីកម្ម។

ទី៦ បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹង ***ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល*** ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការ។

## ២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៤៦- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភាកន្លងមក រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗជាច្រើន ដូចជា ការចូលរួមជាសមាជិកនៃ “***សហគមន៍សេដ្ឋកិច្ចអាស៊ាន***” ដែលជាតំបន់ពាណិជ្ជកម្មសេរីមានប្រជាជនសរុប៦២២លាននាក់ និង ជាភាគីហត្ថលេខីមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និង ប្រទេស ឬ តំបន់ដៃគូ ការបង្កើនការតភ្ជាប់ខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត ជាមួយនឹងប្រទេសក្នុងតំបន់ ការកែលម្អជាលំដាប់នូវក្របខ័ណ្ឌគតិយុត្ត និងស្ថាប័ន និង ការធ្វើពិពិធកម្មទីផ្សារជាដើម។ កម្ពុជាបានចូលរួមក្នុងគំនិតផ្តួចផ្តើម “***ខ្សែក្រវាត់មួយ-ផ្លូវមួយ***” ដែលមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និង ធនាគារ និង វិស័យសេវាផ្សេងទៀត។ ទន្ទឹមនេះ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និង ក្របខ័ណ្ឌអាស៊ាន កម្ពុជាបានពង្រឹងទំនាក់ទំនងធុរកិច្ចយ៉ាងសកម្ម តាមរយៈការចូលរួមក្នុងវេទិកាធុរកិច្ច ការតាំងពិព័រណ៍ និង ការចាប់ដៃគូអាជីវកម្មនានា។ កិច្ចប្រឹងប្រែងទាំងអស់នេះ បានផ្តល់ផលជាកំណើននៃសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ការវិនិយោគដែលបានបង្កើតការងារសម្រាប់ប្រជាជនរាប់ម៉ឺននាក់។

៤.៤៧- ការវិវត្តនៃភូមិសាស្ត្រនយោបាយថ្មីៗនេះ បានធ្វើឲ្យតួនាទីអង្គការពាណិជ្ជកម្មពិភពលោកមានភាពមិនច្បាស់លាស់ និង ទន់ខ្សោយ ហើយបង្កើតនូវការមិនសូវយកចិត្តទុកដាក់លើជំហរមជ្ឈភាពរបស់អាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយទីផ្សារសំខាន់ៗនៅក្រៅតំបន់។ លើសពីនេះ ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសដែលមានកម្រិតអភិវឌ្ឍតិចតួចនៅក្នុងពេលខាងមុខក៏នឹងបណ្ដាលឲ្យបាត់បង់នូវភាពអនុគ្រោះ ព្រមទាំងអត្ថប្រយោជន៍នានានៅក្នុងការអនុវត្តកិច្ចព្រមព្រៀង និង កាតព្វកិច្ចផ្សេងៗ ដែលកម្ពុជាកំពុងតែមានក្នុងពេលបច្ចុប្បន្ន។

៤.៤៨- យ៉ាងណាក៏ដោយតទៅមុខ កម្ពុជាមិនត្រឹមតែត្រូវបន្តខិតខំរក្សាឲ្យបាននូវទីផ្សារនាំ ចេញដែលខ្លួនមានក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវប្រឹងប្រែងបើកច្រកចូលទីផ្សារសម្រាប់ការនាំចេញឲ្យកាន់តែធំទូលាយថែមទៀតដោយផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានលក្ខណៈអចិន្ត្រៃយ៍(ជាជាងពឹងផ្អែកលើការអនុគ្រោះពាណិជ្ជកម្មក្នុងលក្ខណៈទ្វេភាគីដែលអាចនឹងងាយបាត់បង់ទៅវិញ) ដើម្បីបង្កើនទំហំនៃវិមាត្រសេដ្ឋកិច្ច ដែលជាចលករដ៏ចម្បងមួយសម្រាប់ជំរុញលើកកម្ពស់កំណើនប្រកបដោយចីរភាព។

៤.៤៩- នៅក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖

- ទី១-ការបន្តខិតខំបំពេញនូវកាតព្វកិច្ចសេសសល់នានា ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក សហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្របខ័ណ្ឌទ្វេភាគី ជាពិសេសការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត ព្រមទាំងការកែលម្អក្របខ័ណ្ឌគតិយុត្តក៏ដូចជាការកសាងសមត្ថភាពស្ថាប័ន និង មនុស្ស ដើម្បីទាញយកចំណេញឲ្យបានអតិបរមាពីសមាហរណកម្ម និង ពីការលើកកម្ពស់លំហូរពាណិជ្ជកម្ម និង ការវិនិយោគនៅក្នុងតំបន់ និង ពិភពលោក។
- ទី២-ការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និង បង្កើតតំបន់ពាណិជ្ជកម្ម សេរីពហុភាគីជាមួយនឹងតំបន់សំខាន់ៗ ដូចជា អឺរ៉ាស៊ី សហគមន៍អឺរ៉ុប ព្រមទាំងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ RCEP និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀត។
- ទី៣-ការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ច ដោយរៀបចំឲ្យមានវេទិកាដំណើរទស្សនកិច្ច ឬ ការតាំងបង្ហាញផលិតផល សំដៅលើកកម្ពស់ការចាប់ដៃគូពាណិជ្ជកម្ម និង ការស្វែងយល់អំពីតម្រូវការទីផ្សារ ព្រមជាមួយនឹងការបន្តជំរុញពិពិធកម្មទីផ្សារនាំចេញ។
- ទី៤-ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមក្នុងផ្នែកសមាហរណកម្មសេដ្ឋកិច្ចនៅកម្រិតអន្តរជាតិ តំបន់ និង ទ្វេភាគី។

ទី៥-ការជំរុញកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលរវាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល និង គ្រប់តួអង្គអភិវឌ្ឍផ្សេងទៀតក្នុងគោលដៅពង្រឹងសមត្ថភាព និង ប្រព័ន្ធជាតិ ដើម្បីកែលម្អនូវការផ្តល់សេវា និង ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។

ទី៦-ការបន្តកសាងសមត្ថភាព សម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៥០- ដើម្បីអនុវត្តគោលនយោបាយអាទិភាពសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***រាជរដ្ឋាភិបាលកម្ពុជា*** នឹងបន្តពង្រឹងការសម្របសម្រួលអន្តរក្រសួង អនុម័តច្បាប់ និងលិខិតបទដ្ឋានចាំបាច់នានាដើម្បីបំពេញនូវកាតព្វកិច្ចជាសមាជិកនៃអង្គការអន្តរជាតិនិងក្នុងតំបន់ ថែមទាំងការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគ្រប់គ្រងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋាននានាឲ្យមានប្រសិទ្ធភាព។

៤.៥១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការពង្រឹងសមត្ថភាពកម្ពុជា និងបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក និង ពង្រឹងសមត្ថភាពកម្ពុជាក្នុងការជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក ***ក្រសួងពាណិជ្ជកម្ម*** នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត។ សកម្មភាពសំខាន់ៗរួមមាន៖

ទី១ ពង្រឹងនិងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម៖ ១)ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនិងកិច្ចសម្របសម្រួលក្នុងការចរចារពាណិជ្ជកម្ម ២)សិក្សាស្រាវជ្រាវរបាំងពាណិជ្ជកម្ម និង៣)ពង្រឹងនិងពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មនៅតំបន់អាស៊ីប៉ាស៊ីហ្វិក អឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក សហរដ្ឋអាមេរិក និងប្រទេសដទៃទៀត។

ទី២ ពង្រឹងកិច្ចការពិព័រណ៍៖ ១)បន្តរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ២)បន្តចូលរួមនិងរៀបចំពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ៣)ជំរុញឲ្យមានដៃគូពាណិជ្ជកម្មរវាងវិស័យឯកជន និងវិស័យឯកជន ក្នុងនិងក្រៅប្រទេស ៤)ជំរុញដល់ក្រុមហ៊ុនរៀបចំពិព័រណ៍។

ទី៣ ពង្រឹងការអភិវឌ្ឍទីផ្សារ៖ ១)ផ្តល់សេវាពិគ្រោះយោបល់ និងប្រឹក្សាកិច្ចការពាណិជ្ជកម្មនិងទីផ្សារជូនដល់ធុរជន ២)ការតាំងបង្ហាញ ផ្សព្វផ្សាយ ប្រឹក្សាយោបល់ និងជំរុញអត្តសញ្ញាណផលិតខ្មែរ ៣)ពង្រឹងនិងបង្កើតបន្ថែមមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា ការិយាល័យតំណាងសភាពាណិជ្ជកម្មនៅក្រៅប្រទេស និង៤) ពង្រឹងនិងពង្រីកទីផ្សារនាំចេញរបស់កម្ពុជា។

ទី៤ រៀបចំផែនទីបង្ហាញផ្លូវក្នុងដំណើរការសមាហរណកម្មលើវិស័យពាណិជ្ជកម្ម ប្រកបដោយភាពច្បាស់លាស់។

ទី៥ អភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម៖ ១)បន្តធ្វើបច្ចុប្បន្នភាពតម្រូវការព័ត៌មានពាណិជ្ជកម្ម (២)ពង្រឹងនិងពង្រីកការផលិតព័ត៌មានពាណិជ្ជកម្ម ស្របតាមបរិការណ៍សង្គម (៣)ពង្រឹងនិងពង្រីកការផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម (៤)តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម។

ទី៦ បន្តកែលម្អក្របខ័ណ្ឌគតិយុត្តសំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវបរិស្ថានធុរកិច្ចពាណិជ្ជកម្មនិងការវិនិយោគ។ អភិវឌ្ឍន៍កិច្ចការផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ពាណិជ្ជកម្មក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីការងារអង្គការពាណិជ្ជកម្មពិភពលោក។

## តារាងទី ៤.២ សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៩-២០២៣

(តួលេខព្យាករណ៍តាមបែបលីនេអ៊ែរ)

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| តម្លៃនៃការនាំចូល | ពាន់លានរៀល | ៥២ ២៨៣ | ៥២ ៦៩៦ | ៥២ ៩០២ | ៥៣ ១០៩ | ៥៣ ៣១៥ |
| | លានដុល្លារ | ១២ ៩០៤ | ១២ ៩៨៤ | ១៣ ០២៤ | ១៣ ០៦៤ | ១៣ ១០៤ |
| តម្លៃនៃការនាំចេញ | ពាន់លានរៀល | ៣៩ ១៥៨ | ៣៩ ៣៣៦ | ៣៩ ៤២៦ | ៣៩ ៥១៥ | ៣៩ ៦០៤ |
| | លានដុល្លារ | ៩ ៦៦២ | ៩ ៦៨៧ | ៩ ៦៩៩ | ៩ ៧១២ | ៩ ៧២៤ |
| តម្លៃនៃការនាំចេញសម្លៀកបំពាក់ | ពាន់លានរៀល | ២៤ ៥៥៩ | ២៦ ២៨៨ | ២៧ ១៥២ | ២៨ ០១៦ | ២៨ ៨៨១ |
| | លានដុល្លារ | ៦ ០៥៨ | ៦ ៤៧៤ | ៦ ៦៨២ | ៦ ៨៩០ | ៧ ០៩៨ |
| ការចុះបញ្ជីពាណិជ្ជកម្ម | ចំនួន | | | | | |
| - ក្រុមហ៊ុន | | ១៤ ៥៤៤ | ១៨ ៩០៧ | ២៤ ៥៧៩ | ៣១ ៩៥២ | ៤១ ៥៣៧ |
| - ក្រុមហ៊ុនឯកបុគ្គល | | ៤ ១៩៨ | ៥ ៤៤៤ | ៧ ០៧៧ | ៩ ២០០ | ១១ ៩៦០ |
| - សាខាក្នុងស្រុក | | ៧៥២ | ៩៧៧ | ១ ២៧០ | ១ ៦៥១ | ២ ១៤៦ |
| - ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (ការិយាល័យតំណាង និង សាខាក្រុមហ៊ុនបរទេស) | | ១៩៤ | ២៣៩ | ៣១០ | ៤០៣ | ៥២៣ |
| ការចុះបញ្ជីម៉ាក | ចំនួន | ៤ ០០២ | ៤ ០៨២ | ៤ ១៦៤ | ៤ ២៤៧ | ៤ ៣៣២ |
| ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ១ ៦៣២ | ១ ៧៤៦ | ១ ៨៦០ | ១ ៩៧៤ | ២ ០៨៩ |
| ចំនួនកម្មករ (ប្រុស និងស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ១ ១០០ ៤៩៨ | ១ ១៦២ ៥៦៥ | ១ ២២៤ ៦៣២ | ១ ២៨៦ ៦៩៩ | ១ ៣៤៨ ៧៦៦ |
| ប្រាក់បៀវត្សសរុប | លានដុល្លារ | ២ ៣០២ | ២ ៥១៦ | ២ ៧២៩ | ២ ៩៤២ | ៣ ១៥៦ |

*ប្រភព៖* ក្រសួងពាណិជ្ជកម្ម

៤.៥២- ដើម្បីបន្តចូលរួមក្នុងការអនុវត្តគោលនយោបាយអាទិភាពពាក់ព័ន្ធនឹង“**ការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និងបង្កើតតំបន់ពាណិជ្ជកម្មសេរីពហុភាគីជាមួយនឹងតំបន់សំខាន់ៗ ដូចជា អឺរ៉ាស៊ី សហគមន៍អឺរ៉ុប ព្រមទាំងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយRCEP និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀត**” ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បន្តចូលរួមកាន់តែសកម្មក្នុងការចរចាកិច្ចព្រមព្រៀង ឬជំពូកវិនិយោគនៅក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដូចជា កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) និងកិច្ចព្រមព្រៀងសេរីជាច្រើនទៀត ដើម្បីជំរុញសមាហរណកម្មកម្ពុជាចូលទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។
- ចូលរួមគ្រប់យន្តការ និងគ្រប់កម្រិត ទាំងថ្នាក់ក្រុមការងារ ថ្នាក់គណៈកម្មាធិការសម្របសម្រួលផ្នែកវិនិយោគ ថ្នាក់គណៈកម្មាធិការចរចាពាណិជ្ជកម្ម និងថ្នាក់រដ្ឋមន្ត្រី។
- បន្តពង្រឹង និងអភិវឌ្ឍសមត្ថភាពចរចាផ្នែកវិនិយោគជូនដល់មន្ត្រី ក.អ.ក. ឲ្យកាន់តែមានជំនាញនិងបទពិសោធន៍ខ្ពស់។

៤.៥៣- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ*** នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ដោយផ្តោតលើការបន្តអនុវត្តការងារ ធំៗទាំង៥ របស់ខ្លួន ដែលគម្រោងសកម្មភាពសំខាន់ៗរួមមាន៖

**ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ និងអធិបតេយ្យភាព**

- បន្តការពារឯករាជ្យ អធិបតេយ្យភាព ការតស៊ូដើម្បីទទួលយុត្តិធម៌សម្រាប់បុព្វហេតុសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ។
- ខិតខំបន្តដោះស្រាយបញ្ហាព្រំដែនគោកជាមួយប្រទេសជិតខាងដោយផ្អែកច្បាប់អន្តរជាតិ និងគោលការណ៍នៃការមិនកែប្រែខ្សែបន្ទាត់ព្រំដែនក្រោយទទួលឯករាជ្យពីអាណានិគម (Uti Possidetis) ឲ្យបានចប់សព្វគ្រប់ ហើយប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។

**ការអនុវត្តនូវគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ តបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានា**

- កម្ពុជាបន្តចូលរួមយ៉ាងសកម្មជាមួយប្រទេសទាំងអស់ក្នុងតំបន់និងពិភពលោក ក្នុងការរិះរកដំណោះស្រាយចំពោះបញ្ហាប្រឈម ដែលពិភពលោកកំពុងជួបប្រទះ ជាពិសេសបញ្ហានៅមជ្ឈិមបូព៌ា បញ្ហាកម្មវិធីនុយក្លេអ៊ែររបស់អ៊ីរ៉ង់ បញ្ហាឧបទ្វីបកូរ៉េ បញ្ហាសមុទ្រចិនខាងត្បូង វិបត្តិនៅរដ្ឋរ៉ាក់ឃីន ភេរវកម្ម គ្រោះមហន្តរាយ ការទប់ស្កាត់ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន ជំងឺឆ្លង អន្តោប្រវេសន៍ខុសច្បាប់ ។

**ការអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិ**

- បន្តពង្រីកទំនាក់ទំនងការទូតជាមួយប្រទេសនានានៅលើសកលលោក ព្រមទាំងលើកកម្ពស់ថែមទៀត នូវតួនាទី និងកិត្យានុភាពរបស់កម្ពុជាលើឆាកតំបន់ និងអន្តរជាតិ ក្នុងសហគមន៍អាស៊ាន ក៏ដូចជាក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអន្តរជាតិនានា ក្នុងនោះមានការត្រៀមរៀបចំធ្វើជាប្រធាន និងជាម្ចាស់ផ្ទះកិច្ចប្រជុំអាស៊ី-អឺរ៉ុប ឆ្នាំ២០២០ ការបំពេញតួនាទីជាអនុប្រធានមហាសន្និបាតនៃ អ.ស.ប. លើកទី៧៣ និងជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម។
- បន្តអនុវត្តការទូតសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ក្នុងគោលដៅជំរុញគោលនយោបាយនាំចេញ ពង្រឹងនិងផ្សព្វផ្សាយវប្បធម៌ជាតិព្រមទាំងទាក់ទាញទេសចរណ៍បរទេស។
- បន្តសហការយ៉ាងសកម្មជាមួយប្រទេសសមាជិកអាស៊ានទាំងអស់ ក្នុងការកាត់បន្ថយគម្លាតអភិវឌ្ឍ នៅក្នុងចំណោមប្រទេសសមាជិកអាស៊ាន ធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងការតភ្ជាប់អាស៊ាន ដើម្បីបន្តលើកកម្ពស់ការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចសំដៅសម្រេចឲ្យបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយស្របតាម «ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ» ។

**ការចូលរួមកាន់តែសកម្មថែមទៀតដល់បុព្វហេតុ សន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក**

- កម្ពុជាបន្តបញ្ជូនកងកម្លាំងរក្សាសន្តិភាពកម្ពុជាចូលរួម ក្នុងក្របខ័ណ្ឌប្រតិបត្តិការរក្សាសន្តិភាពរបស់ អ.ស.ប រួមទាំងពង្រឹងសមត្ថភាពកងកម្លាំងរក្សាសន្តិភាពកម្ពុជាតាមរយៈការបណ្តុះបណ្តាល។

**ការបន្តការដ្ឋានកំណែទម្រង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអ្នកការទូតប្រកបដោយវិជ្ជាជីវៈស្នេហាជាតិ សកម្ម និងមានសមត្ថភាព**

- ក្រសួងនឹងបន្តកំណែទម្រង់ផ្ទៃក្នុង និងលើកកម្ពស់សមត្ថភាពស្ថាប័ន ដែលរួមមាន៖ លើកកម្ពស់បរិស្ថាន ការងារល្អប្រសើរ ពង្រឹងការទទួលខុសត្រូវនិងសាមគ្គីភាពក្នុងស្ថាប័នព្រមទាំងបណ្តុះបណ្តាលមន្ត្រីទាំងក្នុង និងក្រៅប្រទេស ដើម្បីទទួលបានអ្នកការទូតដែលមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងគុណវុឌ្ឍិល្អប្រសើរ។

## ៣- ការអភិវឌ្ឍធនធានមនុស្ស

៤.៥៤- ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលកម្ពុជាឈានទៅក្នុង**ប្រទេសមានចំណូលមធ្យម**

**កម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០** តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។

៤.៥៥- ការអភិវឌ្ឍធនធានមនុស្ស ក្នុងនីតិកាលទី៦ នឹងបន្តផ្តោតលើ៖ (១)ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា (២)ការបណ្តុះបណ្តាលជំនាញបច្ចេកទេស (៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ និង (៤)ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម។

## ៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៥៦- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺ អភិវឌ្ឍ "***ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និង បរិយាប័ន្ន***" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និង ការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

៤.៥៧- សម្រាប់នីតិកាលទី ៥ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗ ជាអាទិ៍ៈ អត្រាចូលរៀនខ្ពស់នៅកម្រិតបឋមសិក្សា ការលើកកម្ពស់គុណភាព និង តម្លៃនៃការអប់រំ ការធ្វើទំនើបកម្មប្រព័ន្ធអប់រំ ដូចជា ការបញ្ចូលមុខវិជ្ជា STEM ក្នុងកម្មវិធីសិក្សា និង សៀវភៅសិក្សាគោល ការរៀបចំបរិស្ថានសិក្សា និង ការរៀបចំឲ្យមានសាលាជំនាន់ថ្មី ការពង្រឹងអធិការកិច្ចវិស័យអប់រំ និងការកែទម្រង់ឧត្តមសិក្សា ព្រមទាំងការរៀបចំ និង អនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេស ពិសេសលើមុខជំនាញអគ្គិសនី អេឡិចត្រូនិក មេកានិក បសុវប្បកម្ម និង កៀ្សត្រសាស្ត្រ។

៤.៥៨- ទន្ទឹមនឹងសមិទ្ធផលខាងលើ កម្ពុជាក៏នៅជួបបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ៈ លទ្ធផលនៃការសិក្សានៅគ្រប់កម្រិត នៅមិនទាន់បានល្អតាមការរំពឹងចង់បាន អត្រាសិស្សបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានៅតែខ្ពស់ អភិបាលកិច្ចតាមសាលារៀននៅមានកម្រិត វិសាលភាពគ្របដណ្តប់នៃការអប់រំបច្ចេកទេសនៅមានកម្រិត ហើយការចូលរួមពីវិស័យឯកជនក្នុងវិស័យអប់រំបច្ចេកទេសនៅមិនទាន់ទូលំទូលាយ ការអប់រំមិនទាន់ឆ្លើយតបពេញលេញទៅនឹងទីផ្សារការងារ និង ការរស់នៅ គុណភាពឧត្តមសិក្សានៅមានគម្លាតខ្ពស់ធៀបទៅនឹងតម្រូវការ និងស្តង់ដាតំបន់ ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រង និង អភិបាលកិច្ចលើគ្រឹះស្ថានឧត្តមសិក្សានៅមានកម្រិត។ លើសពីនេះ វិស័យកីឡាក៏ត្រូវការនូវការពង្រឹងថែមទៀត ទាំងការអប់រំកាយ និងការត្រៀមខ្លួនឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣។

៤.៥៩- ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១ ការបន្តដំឡើងបៀវត្ស និង ប្រាក់លើកទឹកចិត្តផ្អែកតាមសមិទ្ធកម្មជូន គ្រូបង្រៀន និង បុគ្គលិកអប់រំ ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងរបស់នាយកសាលា ដោយផ្សារភ្ជាប់សមិទ្ធកម្មទៅនឹងថវិកាសាលារៀន ការបន្តលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពបង្រៀន និង គន្លងអាជីពគ្រូបង្រៀនដោយបង្កើនការបណ្តុះបណ្តាល និង រឹត្រឹតការគ្រូបង្រៀនយ៉ាងតិចកម្រិតបរិញ្ញាបត្រ ការពង្រាយគ្រូបង្រៀន សមត្ថភាពខ្ពស់ទៅតំបន់ខ្វះគ្រូបង្រៀន និង បង្កើតយន្តការជួយសិស្សដែលរៀនខ្សោយ ដោយលើកទឹកចិត្តតាមការជាក់ស្តែង ការស្រាវជ្រាវ និង ការអភិវឌ្ឍវិធីសាស្រ្តបង្រៀន និង រៀនតាមបែបថ្មី ការបន្តអនុវត្តការកែទម្រង់ការប្រឡង និង ការវាយតម្លៃការសិក្សាឲ្យបានជាទៀងទាត់, ការបង្កើនការវិនិយោគលើសម្ភារសិក្សា ឧបករណ៍ ពិសោធន៍ និង បរិក្ខារបង្រៀនពិសេស ពង្រីកវិសាលភាពសាលាជំនាន់ថ្មី និង លើកកម្ពស់ការចូលរួមពីសហគមន៍ និង មាតាបិតាសិស្ស។

ទី២- ការបន្តវិនិយោគលើការកសាងសាលាបឋមសិក្សាឲ្យបានដល់ភូមិ និង អនុវិទ្យាល័យឲ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ការបន្តផ្តល់អាហារូបករណ៍ និង មធ្យោបាយទ្រទ្រង់ចាំបាច់ផ្សេងៗទៀត ដល់សិស្សក្រីក្រ សិស្សស្ថិតនៅតំបន់ជួបការលំបាក និង សិស្សមានពិការភាព ការរៀបចំយុទ្ធនាការផ្សព្វផ្សាយ ទូទាំងប្រទេសអំពីសារៈប្រយោជន៍នៃការអប់រំកម្រិតមូលដ្ឋាន ការបង្កើនការវិនិយោគដើម្បីអភិវឌ្ឍកុមារតូច និង ការបន្តបង្កើតថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព ព្រមទាំងជំរុញការរៀបចំឲ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដានព័ត៌មានសិស្ស សំដៅផ្តល់កិច្ចអន្តរាគមន៍ឲ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយដើម្បីទប់ស្កាត់នូវការបោះបង់ការសិក្សារបស់សិស្សានុសិស្ស។

ទី៣- ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀនសំដៅធានាការបង្រៀនឲ្យបានពេញលេញទៅតាមកម្មវិធីសិក្សា និង បង្កើនគុណភាពអភិបាលកិច្ចសាលារៀន ដោយរៀបចំឲ្យមានយន្តការចូលរួមជាប្រចាំពីអ្នកមានចំណែកពាក់ព័ន្ធនិងបង្កើតប្រអប់ទទួលព័ត៌មាន រៀបចំប្រព័ន្ធពិនិត្យ និង តាមដានដំណើរការសាលារៀន ព្រមទាំងរៀបចំប្រព័ន្ធឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលា។

ទី៤- ការធ្វើបច្ចុប្បន្នភាព និង ការជំរុញការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និង ពង្រីកការអប់រំបច្ចេកទេសឲ្យមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេសតាមទស្សនទាន ***“ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលមធ្យម និង ស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេស មួយយ៉ាងតិច***

***សម្រាប់រយៈពេលវែង"*** ព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន។

ទី៥- ការបង្កើនភាពឆ្លើយតបឲ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ និង ការរស់នៅតាមរយៈទស្សនាទាន ***"យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"*** ដោយរៀបចំកម្មវិធីបង្កើនគំនិតសហគ្រិនភាព និង ភាសាបរទេស ពង្រឹងការអប់រំផ្នែក STEM ដោយបង្កើតឲ្យមានមជ្ឈមណ្ឌលអប់រំ និង វិទ្យាសាស្ត្រ បន្តជំរុញកម្មវិធីបំណិនជីវិត ពិសេសកម្មវិធីយុវជនក្នុងភាពជាអ្នកដឹកនាំ សីលធម៌ និង សុជីវធម៌ក្នុងការរស់នៅ ការចូលរួមការងារសង្គម បរិស្ថាន និង ការអភិវឌ្ឍ ព្រមទាំងបន្តបង្កើតក្រុមប្រឹក្សាកុមារ និង យុវជនឲ្យបានគ្រប់សាលារៀន។

ទី៦- ការរៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ រួមទាំងការបញ្ចូលSTEM និង វិទ្យាសាស្ត្រសង្គមគន្លឹះៗសម្រាប់ឧត្តមសិក្សាស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដាតំបន់ និង អន្តរជាតិ ការពង្រឹងយន្តការទទួលស្គាល់គុណភាពឧត្តមសិក្សាការ បង្កើនចំនួនសាស្ត្រាចារ្យកម្រិតបណ្ឌិតប្រកបដោយគុណភាពនៅឧត្តមសិក្សា ការបង្កើនការវិនិយោគលើឧត្តមសិក្សា និង ការបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិសំដៅអភិវឌ្ឍមូលនិធិអាហារូបករណ៍ និង ឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា ការជំរុញការអភិវឌ្ឍសមត្ថភាព និង ធនធានសម្រាប់គាំទ្រការរៀន ការបង្រៀន និង ការសិក្សាស្រាវជ្រាវ ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវ និង យន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ ព្រមទាំងការបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ច និង ការគ្រប់គ្រងឧត្តមសិក្សា។

ទី៧- ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣ ដោយបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាសំខាន់ៗ រៀបចំប្រភេទកីឡាអាទិភាព បណ្តុះបណ្តាលគ្រូបង្វឹក និង បច្ចេកទេសកីឡាកម្រិតខ្ពស់ ពង្រឹងការបណ្តុះបណ្តាល និង ការហ្វឹកហាត់កីឡាករ-កីឡាការិនីថ្នាល និង ជំរុញចលនា ***"យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"*** និង រៀបចំវិទ្យាសាស្ត្រសុខាភិបាលកីឡាដើម្បីគាំទ្រដំណើរការប្រកួតកីឡាស៊ីហ្គេម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៦០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ ***ក្រសួងអប់រំ យុវជន និងកីឡា*** បានដាក់ចេញគោលនយោបាយអប់រំរយៈពេលមធ្យមពីរ និងអាទិភាពកំណែទម្រង់នានាតាមរយៈ**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣** ឆ្ពោះទៅរួមចំណែកក្នុងការអនុវត្តអាទិភាពរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

**គោលនយោបាយទី១៖** ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

**គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

៤.៦១- ក្រសួងបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដោយផ្តោតលើសសរស្តម្ភ ៥៖ (១)ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន (៣)ការដាក់ឲ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃការសិក្សា និង (៥)ការកែទម្រង់ឧត្តមសិក្សា ដូចខាងក្រោម៖

- **យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ៖** (១)កំណែទម្រង់ការគ្រប់គ្រងការសិក្សាផ្តោតលើវង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ការកែលម្អវិធីសាស្ត្របង្រៀននិងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (២) កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (៣) កំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតលើការបង្កើនស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ និង (៤) កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សផ្តោតលើការបណ្តុះបណ្តាលដោយផ្តោតលើវិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។
- **យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ៖** (១) ពិនិត្យលទ្ធភាពប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល (២) ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស (៣) រៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាឲ្យឆ្លើយតបទៅនឹងការវិវត្តឧស្សាហកម្ម (៤) ជំរុញការស្រាវជ្រាវ និងលើកទឹកចិត្តការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង (៥) វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងនិងវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា។
- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន ៖ (១)** ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាពនិង សមធម៌ (២) លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព (៣) អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះ

ធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាពនិងសុខដុមនីយកម្ម (៤)បង្កឱកាសឲ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ និង(៥)ពង្រឹងយន្តការគ្រប់គ្រងនិងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន។

- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា៖** (១)អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងគតិយុត្ត (២)អភិវឌ្ឍកីឡាកម្រិតខ្ពស់ (៣)ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា (៤)អភិវឌ្ឍវិស័យអប់រំកាយនិងកីឡានៅគ្រប់គ្រឹះស្ថានសិក្សានិងសហគមន៍ និង (៥)អភិរក្សនិងអភិវឌ្ឍកីឡាគ្រប់ប្រភេទ។

៤.៦២- ដើម្បីសម្រេចបាននូវគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ខាងលើ ***ក្រសួងអប់រំ យុវជន និងកីឡា*** នឹងផ្តោតលើយុទ្ធសាស្ត្រអាទិភាព ដូចខាងក្រោម ៖

### ការអប់រំកុមារតូច

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន
- លើកកម្ពស់គុណភាពសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដា
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច

### ការអប់រំបឋមសិក្សា

- វិធានការបង្កើនការចូលរៀនឲ្យបានទៀងទាត់ និងរៀនចប់បឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាស្អាតនិងមានសុវត្ថិភាពស្របតាមស្តង់ដាសាលាបឋមសិក្សា ជាពិសេសសាលារៀនមិនគ្រប់កម្រិតនិងសាលារៀនជួបការលំបាក
- លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនដែលមានស្រាប់ និងកែលម្អការពង្រាយគ្រូ
- ពង្រឹងសមត្ថភាពគ្រូបង្រៀន និងអ្នកពាក់ព័ន្ធលើកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលសម្រាប់គ្រូបឋមសិក្សា
- កែលម្អការផ្គត់ផ្គង់ និងការប្រើប្រាស់សៀវភៅសិក្សាគោលនិងសម្ភារៀន និងបង្រៀន
- ពង្រឹងការងារអធិការកិច្ច និងការពិនិត្យតាមដាននិងវាយតម្លៃពីគ្រប់កម្រិតថ្នាក់
- ពង្រឹងការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

### ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

- វិធានការកែលម្អការចូលរៀននិងរក្សាឲ្យបានគង់វង្សនៅមធ្យមសិក្សា ជាពិសេសក្រុមជួបការលំបាក
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តសម្រាប់សាលាមធ្យមសិក្សា

- ពង្រឹងនិងពង្រីកមុខវិជ្ជាវិទ្យាសាស្ត្រស្តែម និងភាសាបរទេសដើម្បីឆ្លើយតបក្របខ័ណ្ឌជំនាញសតវត្សទី២១
- ជំរុញការអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងអភិក្រមការគ្រប់គ្រងតាមសាលារៀននៅកម្រិតសាលារៀន
- ពង្រីកការអនុវត្តស្តង់ដាគំរូសាលារៀនជំនាន់ថ្មី
- អភិវឌ្ឍក្របខ័ណ្ឌធានាគុណភាពអប់រំរបស់សាលារៀននៅមធ្យមសិក្សា
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៃអធិការកិច្ចនៅតាមសាលារៀន
- ពង្រីកភាពជាដៃគូរជាមួយវិស័យឯកជននិងសហគ្រាស ដើម្បីពង្រឹងការអប់រំបច្ចេកទេស
- ពង្រឹងតម្រង់ទិសការសិក្សាឆ្ពោះទៅរកអាជីព និងពង្រីកការអប់រំបច្ចេកទេស។

## ការអប់រំឧត្តមសិក្សា

- បង្កើនការវិនិយោគលើកម្មវិធីអប់រំឧត្តមសិក្សាអាទិភាព ដោយផ្អែកលើលទ្ធផល
- កែលម្អសមត្ថភាពនៃការបង្រៀននិងរៀន និងការស្រាវជ្រាវ តាមរយៈការបង្កើតភាពជាដៃគូឧត្តមសិក្សា
- បង្កើនបុគ្គលិកសិក្សាពេញម៉ោងដែលមានគុណវុឌ្ឍិថ្នាក់បណ្ឌិត
- ពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សរបស់គ្រឹះស្ថានឧត្តមសិក្សាឆ្ពោះទៅទទួលបានស្វ័យភាពពេញលេញ
- កែលម្អប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សា។

## ការអប់រំក្រៅប្រព័ន្ធ

- អភិវឌ្ឍ និងកែលម្អកម្មវិធីអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ
- ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងការចូលរួមគាំទ្រដល់កម្មវិធី អប់រំក្រៅប្រព័ន្ធរបស់អ្នកពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃការសិក្សាពេញមួយជីវិត
- កែលម្អប្រសិទ្ធភាព និងគុណភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់។

## ការអភិវឌ្ឍយុវជន

- ពង្រឹងជំនាញឌីជីថល និងលើកកម្ពស់ចំណេះដឹងអនុវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យាសម្រាប់យុវជនដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហ៍កម្មទី៤

- បង្កើនការបណ្តុះទម្លាប់នៃការគិតបែបច្នៃប្រឌិត និងការបង្កើតថ្មីតាមរយៈស្មារតីសហគ្រិនភាព ការលើកកម្ពស់ការប្រកបមុខរបរដោយខ្លួនឯង និងលទ្ធភាពទទួលបានសេវាណែនាំអាជីវកម្មនិងការងារ និងព័ត៌មានទីផ្សារ
- អភិវឌ្ឍយុវជនឲ្យបានពេញលេញ និងអប់រំពួកគេឲ្យរស់នៅជាមួយគ្នាក្នុងសន្តិភាពនិងសុខដុមនីយកម្ម ប្រកបដោយស្មារតីស្នេហាជាតិ ស្រឡាញ់ប្រជាជន ជឿជាក់និងផ្តល់តម្លៃខ្ពស់ដល់ខ្លួនឯង មានភាពជាអ្នកដឹកនាំ និងការយល់ដឹងទូលំទូលាយអំពីសង្គម
- លើកទឹកចិត្តយុវជនឲ្យចែករំលែកការយល់ឃើញទស្សនវិស័យ និងចូលរួមក្នុងដំណើរការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍និងសង្គម
- ប្រែក្លាយមជ្ឈមណ្ឌលយុវជនឲ្យក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមសហគមន៍

### ការអភិវឌ្ឍការអប់រំកាយ និងកីឡា

- អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងគតិយុត្ត
- អភិវឌ្ឍកីឡាកម្រិតខ្ពស់
- អភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា
- អភិវឌ្ឍវិស័យអប់រំកាយនិងកីឡានៅគ្រប់គ្រឹះស្ថានសិក្សានិងសហគមន៍
- អភិរក្សនិងអភិវឌ្ឍកីឡាគ្រប់ប្រភេទ
- លើកទឹកចិត្តឲ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងមហាជនចូលរួមលេងកីឡា
- បំផុសសកម្មភាពអប់រំកាយនិងកីឡានៅក្នុងសាលារៀន
- ពង្រឹងនិងលើកទឹកចិត្តដល់សហព័ន្ធកីឡា
- បន្តការជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡា ជាពិសេសពហុកីឡាដ្ឋានជាតិ កីឡាដ្ឋាននៅតាមខេត្ត វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និង គ្រឹះស្ថានសិក្សា
- បន្តបណ្តុះបណ្តាលថ្នាលនិស្សិតកីឡា និងហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣។

### តារាងទី ៤.៣ សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា

| ល.រ | សូចនាករសំខាន់ៗ ក្នុងវិស័យអប់រំ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | | | ជាក់ស្តែង | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ |
| | កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | | | | | | | |
| ១ | អត្រាកុមារចូលរៀន អាយុ៥ឆ្នាំគ្រប់រូបភាព (មត្តេយ្យរដ្ឋ ឯកជន និងសហគមន៍) | % | ៥៨,០ | ៥៩,៣ | ៦០,៦ | ៦១,៩ | ៦៣,២ | ៦៤,៥ |
| ២ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ៩៧,៨ | ៩៧,៩ | ៩៨,១ | ៩៨,២ | ៩៨,៤ | ៩៨,៥ |
| | ប្រុស | % | ៩៧,៦ | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,៣ | ៩៨,៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ស្រី | % | ៩៨,១ | ៩៨,៣ | ៩៨,៥ | ៩៨,៦ | ៩៨,៨ | ៩៩,០ |
| | ទីប្រជុំជន | % | ១០២,៨ | ១០២,១ | ១០១,៦ | ១០១,២ | ១០០,៩ | ១០០ |
| | ជនបទ | % | ៩៦,៧ | ៩៧,០ | ៩៧,៣ | ៩៧,៥ | ៩៧,៦ | ៩៨,០ |
| ៣ | អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ១១៣,៧ | ១១២,៣ | ១១១,២ | ១១០,៤ | ១០៩,៨ | ១០៨ |
| | ប្រុស | % | ១១៤,៦ | ១១៣,២ | ១១២,៣ | ១១១,៤ | ១១០,៤ | ១០៩ |
| | ស្រី | % | ១១២,៩ | ១១១,៤ | ១១០,៣ | ១០៩,៥ | ១០៨,៩ | ១០៧ |
| ៤ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ |
| | ប្រុស | % | ៧៩,១ | ៨០,៣ | ៨១,៥ | ៨២,៦ | ៨៣,៨ | ៨៥,០ |
| | ស្រី | % | ៨៦,៤ | ៨៧,៣ | ៨៨,២ | ៨៩,២ | ៩០,១ | ៩១,០ |
| ៥ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| | សរុប | % | ៥៩,២ | ៦០,៧ | ៦២,២ | ៦៣,៧ | ៦៥,២ | ៦៦,៧ |
| | ប្រុស | % | ៥៥,២ | ៥៧,២ | ៥៩,១ | ៦១,១ | ៦៣,០ | ៦៥,០ |
| | ស្រី | % | ៦៣,៤ | ៦៥,១ | ៦៦,៨ | ៦៨,៦ | ៧០,៣ | ៧២,០ |
| | ទីប្រជុំជន | % | ៦៧,០ | ៦៨,៨ | ៧០,១ | ៧១,០ | ៧១,៨ | ៧៤,០ |
| | ជនបទ | % | ៦១,០ | ៦៣,០ | ៦៤,៥ | ៦៥,៦ | ៦៦,៥ | ៦៩,០ |
| ៦ | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | |
| | សរុប | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ |
| | ប្រុស | % | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ |
| | ស្រី | % | ៥១,១ | ៥២,១ | ៥៣,២ | ៥៤,២ | ៥៥,៣ | ៥៦,៣ |
| ៧ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| | សរុប | % | ២៨,៥ | ៣០,៤ | ៣២,៣ | ៣៤,២ | ៣៦,១ | ៣៨,០ |
| | ប្រុស | % | ២៦,៣ | ២៨,៣ | ៣០,២ | ៣២,២ | ៣៤,១ | ៣៦,១ |
| | ស្រី | % | ៣០,៩ | ៣២,៧ | ៣៤,៥ | ៣៦,៤ | ៣៨,២ | ៤០,០ |
| ៨ | អត្រាអក្ខរកម្មជនពេញវ័យ (១៥ឆ្នាំឡើង) | % | ៨២,៥ | ៨៣,៦ | ៨៤,៧ | ៨៥,៨ | ៨៦,៩ | ៨៨,០ |
| ៩ | អត្រាបញ្ចប់នៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| | សរុប | % | ២៣,៦ | ២៥,២ | ២៦,៤ | ២៧,៣ | ២៨,០ | ៣០,០ |
| | ប្រុស | % | ២១,៩ | ២៣,៤ | ២៤,៦ | ២៥,៤ | ២៦,១ | ២៨,០ |
| | ស្រី | % | ២៥,៣ | ២៧,២ | ២៨,៧ | ២៩,៨ | ៣០,៦ | ៣៣,០ |
| ១០ | យុគភាពយេនឌ័រ នៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សទុតិយភូមិ | GPI | ១,១៨ | ១,១៤ | ១,១១ | ១,០៩ | ១,០៨ | ១,០៣ |
| | កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១១ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) សរុប | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ |
| | ស្រី | % | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ |
| ១២ | ភាគរយនិស្សិតរៀនមុខវិជ្ជាស្វែមកម្រិតបរិញ្ញាបត្រ | % | ២៧,១ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | ៣២,០ |
| | ស្រី | % | ១៧,៤ | ១៨,៤ | ១៩,៤ | ២០,៥ | ២១,៥ | ២២,៥ |

*ប្រភព:* ក្រសួងអប់រំ យុវជន និងកីឡា

## ៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៦៣- ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា គឺសំដៅធានាថា ***"យុវជន ម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"*** ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឲ្យឈានឡើងមួយកម្រិតទៀត។ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ធ្វើឡើងក្នុងរូបភាពពីរដែលមានការផ្សារភ្ជាប់គ្នា គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និង ធនធានមនុស្សនៅក្រៅប្រព័ន្ធអប់រំ ឬក្នុងទីផ្សារការងារ។

៤.៦៤- ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗ ជាអាទិ៍ បានអនុវត្តគោលនយោបាយជាតិស្តីពី***ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥*** បានអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្តង់ដាជាតិសមត្ថភាព និង កម្មវិធីសិក្សាផ្អែកលើសមត្ថភាព ក្របខ័ណ្ឌទទួលស្គាល់ឆ្លងពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទៅគ្រឹះស្ថានឧត្តមសិក្សា បានបង្កើតមជ្ឈមណ្ឌលគំរូសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជាច្រើនកន្លែងនិងបានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទន្ទឹមនេះ កម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួន ជាអាទិ៍៖ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យមនិងកម្រិតខ្ពស់នៅមិនទាន់គ្រប់គ្រាន់ ការបង្កើនសមត្ថភាពជំនាញនៃកម្លាំងពលកម្មដើម្បីបង្កើនផលិតភាពនៅមិនទាន់ទូលំទូលាយ ភាពមិនទាន់ឆ្លើយតបបានពេញលេញទាំងផ្នែកមុខជំនាញ កម្មវិធីសិក្សា មនសិការ វិជ្ជាជីវៈ និង គុណភាពនៃការបណ្តុះបណ្តាលបច្ចេកទេសទៅនឹងតម្រូវការទីផ្សារជាក់ស្តែង និងភាពនៅមានកម្រិតនៃការចូលរួមពីវិស័យឯកជនក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ។ល។

៤.៦៥- នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១-ការបន្តជំរុញការអនុវត្ត ***"គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥"*** សំដៅលើកកម្ពស់ការបណ្តុះបណ្តាលជំនាញបច្ចេក-ទេស ពិសេសកម្រិតមធ្យម និង កម្រិតខ្ពស់ ដល់យុវជន ដោយគ្របដណ្តប់មុខវិជ្ជាពហុ

ជំនាញដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ពលកម្ម វិស័យឧស្សាហកម្ម និង ការចាប់ផ្តើមធុរកិច្ចថ្មី។

ទី២-ការបង្កើនកិច្ចសហការរវាងសាលារៀន និង សហគ្រាស ក្នុងការបណ្តុះបណ្តាលសំដៅបង្កើនសមត្ថភាព ជំនាញបច្ចេកទេស និង ផលិតភាពរបស់កម្លាំងពលកម្ម ដែលកំពុងបម្រើការងារ និង ការរៀបចំកម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរជំនាញស្របតាមនិន្នាការផ្លាស់ប្តូរនៃបច្ចេកវិទ្យាថ្មីៗ និងជំរុញការអនុវត្ត "***មូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញ***"។

ទី៣-ការបន្តរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញតាមតម្រូវការជាក់ស្តែងរបស់វិស័យនីមួយៗ ពិសេសគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ដោយមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋ វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបង្កើនកិច្ចសហការជាក់លាក់រវាងគ្រឹះស្ថានបណ្តុះបណ្តាល និង សហគ្រាសក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដើម្បីពង្រឹងគុណភាព និង បង្កើនភាពឆ្លើយតបទៅនឹងសភាពការណ៍វិវឌ្ឍថ្មីៗ។

ទី៤-ការធ្វើវិចារណកម្ម និង អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈក្នុងការផ្គត់ផ្គង់ជំនាញ ច្រើនប្រភេទឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មផង និង ការចាប់ផ្តើមធុរកិច្ចថ្មីផង ដោយមានកិច្ចសហការជាមួយវិស័យឯកជន។

ទី៥-ការតម្រង់ទិសវិជ្ជាជីវៈនៅតាមអនុវិទ្យាល័យ និង វិទ្យាល័យក្នុងប្រព័ន្ធអប់រំចំណេះទូទៅ និង ការបន្តបង្កើនការផ្សព្វផ្សាយអំពីសារសំខាន់ និង ភាពចាំបាច់អំពីជំនាញបច្ចេកទេស និង វិជ្ជាជីវៈក្នុងការកសាងអនាគតរបស់យុវជន គ្រួសារ និង ប្រទេសជាតិ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៦៦- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ ***ក្រសួងអប់រំ យុវជន និងកីឡា*** បានដាក់ចេញគោលនយោបាយជាអាទិភាព និង សកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- ជំរុញការអនុវត្តគោលនយោបាយស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ពង្រឹងវិធីសាស្ត្របង្រៀន និងរៀនតាមបែបថ្មី ដូចជាវិធានតាមបែបស្វែងរក និងវិធានផ្សេងទៀត ដើម្បីឲ្យសិស្សមានបំណិនសតវត្សរ៍ទី២១
- ពង្រីកការអប់រំបំណិនជីវិត ការប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន និងក្លឹបសិក្សាមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរ
- រៀបចំកម្មវិធីសិក្សា ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នករៀន និងទីផ្សារការងារ
- រៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាឲ្យឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- បណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា
- ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពនិង សមធម៌

- លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព
- បញ្ជ្រាបចំណេះដឹងមូលដ្ឋានអំពី ការយល់ដឹងពីធុរកិច្ច និងសហគ្រិនភាព ដល់យុវជនក្នុងសាលារៀន និងអំពីការអភិវឌ្ឍសហគ្រិនភាពនៅតាមសហគមន៍ដល់យុវជនក្រៅសាលារៀន និងបញ្ចូលទៅជាកម្មវិធីសិក្សាបំណិនជីវិត

៤.៦៧- ដើម្បីសម្រេចបានការអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ ***ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*** បានកំណត់សកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តបើកទូលាយទីផ្សារការងារនៅក្រៅប្រទេស ផ្តល់ឱកាសជូនប្រជាជនធ្វើការស្របច្បាប់នៅក្រៅប្រទេស ការពារសិទ្ធិ ផលប្រយោជន៍ និងគាំពារគ្រួសារពលករចំណាកស្រុក ។
- បន្តការអភិវឌ្ឍការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រកបដោយគុណភាពនិងជំនាញច្បាស់លាស់ស្របតាមតម្រូវការទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេស។ បន្តផ្តល់អាហារូបករណ៍ និងបង្កលក្ខណៈងាយស្រួលដល់យុវជន យុវនារី ឲ្យទទួលបានការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- បន្តជំរុញកម្មវិធីលើកកម្ពស់ផលិតភាពជាតិ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ជាតិនៅក្នុងតំបន់ ជាពិសេសក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- ធានាសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដើម្បីការពារសិទ្ធិសេរីភាព របស់កម្មករនិយោជិត និងនិយោជក និងការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជកស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិខាងការងារ។

## ៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៦៨- ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់គឺសំដៅលើកកម្ពស់សុខភាពប្រជាជន និង អាហារូបត្ថម្ភ ដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និង វឌ្ឍនភាពសង្គមប្រកបដោយចីរភាព។

៤.៦៩- ជាលទ្ធផលក្នុងកិច្ចការនេះ រាជរដ្ឋាភិបាលបានសម្រេច***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍***ក្នុងការកាត់បន្ថយអត្រាមរណភាពមាតា ទារក និង កុមារ ការកាត់បន្ថយការឈឺ និង ស្លាប់ដោយសារជំងឺឆ្លង ដូចជា ជំងឺអេដស៍ គ្រុនចាញ់ និង របេង និង ការលុបបំបាត់ជំងឺកញ្ជ្រិលទាំងស្រុងនៅឆ្នាំ២០១៦។ ទន្ទឹមនេះ អាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនបានកើនពី ៥៦,៧ ឆ្នាំ នៅឆ្នាំ១៩៩៨ ដល់ ៧០,៦ ឆ្នាំ នៅឆ្នាំ២០១៨។ ចំណាយប្រាក់ចេញពីហោប៉ៅរបស់ប្រជាជនលើការថែទាំសុខភាព ពិសេសប្រជាជនក្រីក្រ និង ក្រុមជនងាយរងគ្រោះត្រូវបានកាត់បន្ថយដោយសារការពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម មានជាអាទិ៍៖ មូលនិធិសមធម៌

សុខាភិបាលសម្រាប់ប្រជាជនក្រីក្រ និង របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពកាន់តែទូលាយដល់ប្រជាជនជាង៣លាននាក់។ វឌ្ឍនភាពនេះបានធ្វើឲ្យគ្រួសារដែលជួបភយន្តរាយនៃចំណាយលើការថែទាំសុខភាពថយចុះពី៨,៨% នៃចំនួនគ្រួសារសរុបនៅឆ្នាំ២០០៩ មកត្រឹម៣,៧% នៅឆ្នាំ២០១៦ និង គ្រួសារធ្លាក់ខ្លួនក្រដោយសារភយន្តរាយនៃចំណាយលើការថែទាំសុខភាពបានថយចុះពី៥,៧% មកត្រឹម១,៦% ក្នុងអំឡុងពេលដូចគ្នា។

៤.៧០- ទោះបីជាសម្រេចបាននូវសមិទ្ធផលធំៗដូចខាងលើ ក៏កម្ពុជានៅតែជួបបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ សេវាថែទាំសុខភាពបឋមនៅមិនទាន់ឆ្លើយតបបានពេញលេញ និង ទាន់ពេលវេលា គុណភាពនៃការផ្តល់សេវាថែទាំ និង ព្យាបាលនៅមានកម្រិត ចំនួនគ្រូពេទ្យ និង បុគ្គលិកសុខាភិបាលតាមប្រភេទជំនាញនៅពុំទាន់គ្រប់គ្រាន់តាមនិយាមនៅឡើយ ប្រព័ន្ធធានារ៉ាប់រងសុខភាពមិនទាន់គ្របដណ្តប់សម្រាប់ទាំងអស់គ្នា ការយល់ដឹងពីការប្រើប្រាស់ឱសថ ថ្នាំជក់ គ្រឿងស្រវឹង និង ការយល់ដឹងពីអនាម័យ និង សុវត្ថិភាពចំណីអាហារ នៅមានកម្រិត ហើយមរណភាពមាតា ទារក និង កុមារ និង កង្វះអាហារូបត្ថម្ភរបស់ស្ត្រី ទារក និង កុមារ ក្នុង ចំណោមគ្រួសារក្រីក្រនៅតំបន់ជនបទនៅតែជាបញ្ហាប្រឈម។

៤.៧១- ក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១-ការបន្តជំរុញការអនុវត្ត និង ធ្វើបច្ចុប្បន្នកម្ម "***ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០***" ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និង សមធម៌ នៃសេវាសុខភាព។
- ទី២-ការជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកលនៅកម្ពុជា ដោយបង្កើនវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌ សុខាភិបាល បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន និង របបថែទាំសុខភាពសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ និង ដោយរៀបចំរបបថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍។
- ទី៣-ការលើកកម្ពស់គុណភាព សុវត្ថិភាព និង ប្រសិទ្ធភាព សេវាសុខភាព ជាពិសេសសេវាជាសារវន្ត និង សេវាសង្គ្រោះបន្ទាន់ដោយបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និង បច្ចេកវិទ្យាវេជ្ជសាស្ត្រ ដាក់ឲ្យដំណើរការប្រព័ន្ធទទួលស្គាល់គុណភាពនៅមូលដ្ឋានសុខាភិបាល ពង្រឹងការងារគ្រប់គ្រង សមត្ថភាពនិយ័តកម្ម អធិការកិច្ច ទាំងនៅមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន រៀបចំ និង ពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និង នីតិក្រមសុខាភិបាល ពិសេសពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងការផ្លាស់ប្តូរ ឥរិយាបថរបស់អ្នកផ្តល់សេវាសុខាភិបាលប្រកបដោយសីលធម៌ លើកកម្ពស់សមត្ថភាព និង អភិវឌ្ឍការស្រាវជ្រាវសុខាភិបាល ក្នុងនោះមានទាំងការសិក្សាស្រាវ

ប្រារអំពីជំងឺឆ្លង និងជំងឺមិនឆ្លង និងបន្តពង្រឹងប្រព័ន្ធអង្កេតតាមដាន និង ឆ្លើយតបជំងឺស្របតាមលក្ខខ័ណ្ឌតម្រូវនៃបទដ្ឋាននិយ័តកម្មសុខភាពអន្តរជាតិ។

ទី៤-ការរៀបចំ និង អនុវត្តឲ្យមានប្រសិទ្ធភាព នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល សំដៅពង្រឹងបន្ថែមនូវសមត្ថភាព និង ជំនាញធនធានមនុស្សក្នុងវិស័យសុខាភិបាល ដោយលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល ទាំងការបណ្តុះបណ្តាលមូលដ្ឋាន ឬ មុនពេលបម្រើការងារ និង ទាំងការបណ្តុះបណ្តាលបន្ត ឬ ក្នុងពេលបម្រើការងារ រៀបចំ និង ពង្រឹងយន្តការធានា និង ទទួលស្គាល់គុណភាពអប់រំ វិស័យសុខាភិបាល អភិវឌ្ឍប្រព័ន្ធទិន្នន័យគ្រប់គ្រងធនធានមនុស្សសុខាភិបាល និង គ្រប់គ្រងការពង្រាយបុគ្គលិកសុខាភិបាល ដែលមានសមត្ថភាពជំនាញច្បាស់លាស់ ប្រកបដោយសមធម៌ និង ពង្រឹងយន្តការលើកទឹកចិត្តដ៏សមរម្យជូនដល់បុគ្គលិកសុខាភិបាល ពិសេសនៅតាមទីជនបទដាច់ស្រយាល។

ទី៥-ការពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និង ការត្រួតពិនិត្យគុណភាពផលិតផលឱសថ ការប្រើប្រាស់ឱសថដោយគ្មានវេជ្ជបញ្ជា ការប្រើសារធាតុគីមីក្នុងចំណីអាហារ និង ការប្រើគ្រឿងស្រវឹង និង ថ្នាំជក់។

ទី៦-ការជំរុញអនុវត្តវិធានការទប់ស្កាត់ បង្ការ និង កាត់បន្ថយជំងឺ ដោយបង្កើនកិច្ចសហការជាមួយសហគមន៍ និង គ្រប់ភាគីពាក់ព័ន្ធ ដើម្បីអប់រំ និង ផ្សព្វផ្សាយអំពីអនាម័យ សុវត្ថិភាពចំណីអាហារ ការថែទាំសុខភាព និង ផលប៉ះពាល់ពីការប្រើសារធាតុគីមី ការប្រើគ្រឿងស្រវឹង និង ថ្នាំជក់ និង ការប្រែប្រួលអាកាសធាតុមកលើសុខភាព។

ទី៧-ការដាក់ឲ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ នៃគ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗសំដៅលើកកម្ពស់អាហារូបត្ថម្ភ និង រៀបចំឲ្យមានយន្តការពហុវិស័យ ដោយមានការចូលរួមពីសហគមន៍ និង រដ្ឋបាលថ្នាក់ក្រោមជាតិនៃតំបន់ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភកម្រិតខ្ពស់។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៧២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាព ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើគោលនយោបាយជាយុទ្ធសាស្ត្រ គឺ “លើកស្ទួយលទ្ធផលសុខភាពប្រជាពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើង និងបង្កើនបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការមកប្រើប្រាស់សេវាថែទាំសុខភាព”។

៤.៧៣- ដើម្បីសម្រេចបានគោលនយោបាយជាអាទិភាពខាងលើនេះ ***ក្រសួងសុខាភិបាល*** នឹងអនុវត្តកម្មវិធីសកម្មភាព ផ្តោតទៅលើប្រជាជនគ្រប់រូប និង វិស័យសុខាភិបាលទាំងមូល (ទាំងសាធារណៈនិងឯកជន)ដូចខាងក្រោម៖

១. លើកស្ទួយសុខភាពបន្តពូជ កាត់បន្ថយមរណភាព មាតា ទារក និងកុមារ និងកែលម្អកង្វះអាហារូបត្ថម្ភ ក្នុងចំណោមស្ត្រី និងកុមារតូច។
២. កាត់បន្ថយការឈឺ និងស្លាប់ ដោយជំងឺឆ្លង ជំងឺពុំរ៉ៃ។
៣. កាត់បន្ថយការឈឺនិងស្លាប់ដោយជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ។
៤. ប្រព័ន្ធសុខាភិបាលកាន់តែមានភាពធន់ ភាពឆ្លើយតប និងគណនេយ្យភាព ចំពោះតម្រូវការ ផ្នែកសុខភាពរបស់ប្រជាជន។

៤.៧៤- សូចនាករសំខាន់ៗដែលបានជ្រើសរើស សម្រាប់កម្មវិធីនីមួយៗ ដែលក្រសួងសុខាភិបាល នឹងរាយការណ៍តាមពេលវេលា មានបង្ហាញនៅក្នុងតារាងខាងក្រោម។

### តារាងទី ៤.៤ សូចនាករពិនិត្យតាមដានវឌ្ឍនភាព ២០១៩-២០២៣

| សូចនាករ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| អត្រាមរណភាពមាតាក្នុងទារកកើតរស់១០០ ០០០នាក់ | | ១៣០ | | | ១០០[a] |
| អត្រាស្លាប់ទារក ក្នុងទារកកើតរស់ ១ ០០០នាក់ | | ១៤ | | | ១៣[a] |
| អត្រាស្លាប់កុមារអាយុក្រោមប្រាំឆ្នាំក្នុងទារកកើតរស់១ ០០០នាក់ | | ៣០ | | | ២៨[a] |
| អត្រាស្គមស្គាំងលើកុមារអាយុក្រោម៥ឆ្នាំ | | ៩ | | | ៦[a] |
| សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្តនឹងមធ្យោបាយពន្យារកំណើតទំនើប | | ៦២ | | | ៦៥[a] |
| ករណីឆ្លងថ្មីនៃមេរោគអេសដ៏ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ |
| អាំងស៊ីដង់នៃជំងឺរបេងគ្រប់ទម្រង់ក្នុងប្រជាជន១០០ ០០០នាក់ | ៣២៣ | ៣១០ | ២៦១ | ២៤៣ | ២២៦ |
| អត្រាស្លាប់ដោយជំងឺរបេងក្នុងប្រជាជន១០០ ០០០នាក់ | ១៧ | ១៦ | ១៥ | ១៤ | ១៣ |
| អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ក្នុងប្រជាជន ១ ០០០នាក់ | ១,២៥ | ១,០៥ | ០,៨៥ | ០,៦៥ | ០,៤០ |
| អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងប្រជាជន១០០ ០០០នាក់ | ០,១៥ | 0.00 | 0.00 | 0.00 | 0.00 |
| ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់<br>- អាយុលើសពី១៥ឆ្នាំ<br>- អាយុពី ១៣-១៥ឆ្នាំ | <br>២០,៨<br>២,៣ | <br>១៩,៨<br>២,២ | <br>១៨,៣<br>២,១ | <br>១៧,៨<br>២,០ | <br>១៦,៨<br>១,៩ |
| ប្រេវ៉ាឡង់នៃការប្រើប្រាស់សារជាតិអាល់កុលក្នុងចំណោមមនុស្សពេញវ័យចាប់ពីអាយុ១៨ឆ្នាំ | ៤៥,៤ | ៤៥,៣ | ៤៥,២ | ៤៥,១ | ៤៥,០ |
| ពិនិត្យពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ(ចំនួនលើក) | ០,៨០ | ០,៨៥ | ០,៨៦ | ០,៨៧ | ០,៨៩ |
| អត្រាប្រើប្រាស់គ្រែ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៥ |
| អត្រាស្លាប់នៅមន្ទីរពេទ្យ | <១ | <១ | <១ | <១ | <១ |
| អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប | ៤៤,៥ | ៤៦ | ៤៧ | ៤៨ | ៤៩ |
| សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ |
| អត្រាសម្រាលដោយវិធីវះកាត់(គិតជា% នៃទារកកើតរស់) | ៩ | ១០ | ១០,២ | ១០,៤ | ១០,៦ |
| ភាគរយនៃស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល | ៨៨ | ៨៩ | ៨៩,៥ | ៩០ | >៩០ |
| ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១ | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ |

| | | | | | |
|---|---|---|---|---|---|
| (មុន៤៨ ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល | | | | | |
| ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងម៉ោងទីមួយនៃកំណើត | ៦៦ | ៦៧ | ៦៧,៥ | ៦៨ | ៦៨,៥ |
| ភាគរយនៃស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់ | ៨២ | ៨៥ | ៨៧ | ៨៩ | ៩០ |
| ភាគរយនៃស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ | ៨៥ | ៩០ | ៩៥ | >៩៥ | >៩៥ |
| ភាគរយនៃកុមារអាយុ ៦-៥៩ ខែ បានទទួលគ្រប់ថ្នាំជីវជាតិ អា ក្នុងរយៈពេល៦ខែចុងក្រោយ (ជុំទី២) | ៩៤ | ៩៥ | >៩៥ | >៩៥ | >៩៥ |
| ភាគរយនៃកុមារអាយុ១២-៥៩ ខែ បានទទួលថ្នាំទម្លាក់ព្រូនមេបង់ដាហ្សុលក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | ៨២ | ៨៥ | ៨៨ | ៩០ | ៩០ |
| អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការជំងឺខាន់ស្លាក់ ស្អិតដៃជើង តេតាណូស រលាកសួត | ៩៥ | ៩៥ | ៩៥ | >៩៥ | >៩៥ |
| អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូចដូសទី១ | ៩៥ | ៩៥ | ៩៥ | ៩៥ | >៩៥ |
| ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុង១ឆ្នាំ(ចំនួនលើក) | ១,៥៨ | ១,៦ | ១,៦២ | ១,៦៥ | ១,៦៧ |
| ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍(មនុស្សពេញវ័យនិងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressedក្នុងរយៈពេល១២ខែកន្លងមក | ៨៥ | ៩០ | ៩០ | ៩០ | ៩០ |
| ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៩០ | ៩០ | ៩០ | ៩០ | ៩០ |
| អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | >៩០ | >៩០ | >៩០ | >៩០ | >៩០ |
| ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ | ៣៦ ០០០ | ៣៧ ០០០ | ៣៥ ៥០០ | ៣៤ ០០០ | ៣៣ ០០០ |
| ភាគរយនៃប្រជាជនអាយុពី ១៨-៦៩ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល | ៣២ | ៣៥ | ៤០ | ៤៥ | ៥០ |
| ភាគរយនៃប្រជាជនអាយុពី ១៨-៦៩ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | ១៩ | ២០ | ២២ | ២៤ | ២៦ |
| ភាគរយនៃស្ត្រីអាយុ ៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិចមួយលើក | ៤ | ៦ | ៨ | ១០ | ១២ |
| ចំនួននិងភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល | ១៥ | ២០ | ២២ | ២៤ | ២៥ |
| ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | ៧០ | ៨០ | ៨០ | ៨០ | >៨០ |
| អត្រាវះកាត់ជំងឺភ្នែកឡើងបាយក្នុងប្រជាជន១លាននាក់ក្នុង១ឆ្នាំ | ២ ៥០០ | ៣ ០០០ | ៣ ១០០ | ៣ ២០០ | ៣ ៣០០ |
| ចំណាយចរន្តនៃថវិកាជាតិលើសុខភាពគិតជា%នៃផលិតផលសរុបក្នុងស្រុក | ២ | ២ | ២,១ | ២,២ | ២,៣ |
| ភាគរយនៃប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិសមធម៌និងធានារ៉ាប់រងសុខភាព) | ៤០ | ៥០ | ៥៥ | ៦០ | ៦៥ |
| ភាគរយនៃមូលដ្ឋានសុខាភិបាលដែលមានស្តុកឱសថសារវន្តនិងឧបករណ៍បរិក្ខារពេទ្យចាំបាច់ដែលបានកំណត់ ១៥មុខ | ៨០ | ៨៥ | ៨៦ | ៨៧ | ៨៨ |

| | | | | | |
|---|---|---|---|---|---|
| ភាគរយនៃការផ្តល់ឈាមដោយស្ម័គ្រចិត្ត | ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ |
| ភាគរយនៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យផ្តល់របាយការណ៍ប្រចាំខែ HC1 និង HO2 ពេញលេញ ១០០% និងទាន់ពេលកំណត់ | ៩៨ | ១០០ | ១០០ | ១០០ | ១០០ |
| ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការតាមមុខងារ | ៨៥ | >៨៥ | >៨៥ | >៨៥ | ៩០ |

*ប្រភព:* ក្រសួងសុខាភិបាល

*ខ គោលដៅ ចំណុចដៅ ឆ្នាំ២០២៥*

៤.៧៥- សកម្មភាពជាអាទិភាពតាមយុទ្ធសាស្ត្រនីមួយៗរបស់ ***ក្រសួងសុខាភិបាល*** នឹងអនុវត្ត រួមមានចំនួន៧៖

*ប្រព័ន្ធផ្តល់សេវាសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- បង្កើនការគ្របដណ្តប់និងការប្រើប្រាស់សេវា និងព័ត៌មានសុខភាពមានគុណភាព សុវត្ថិភាពនិងប្រសិទ្ធភាពដល់ប្រជាជន ពិសេសប្រជាពលរដ្ឋ និងតំបន់ភូមិសាស្ត្រដែលពិបាកមកទទួលសេវា។
- ពង្រឹងប្រព័ន្ធបញ្ជូន ដើម្បីជួយអ្នកជំងឺឬជនរងគ្រោះទទួលបានសំណុំសេវាសុខភាពឬសេវាទាក់ទងសុខភាពគ្រប់ជ្រុងជ្រោយយោងតាមតម្រូវការជាក់ស្តែង។
- ផ្តល់សេវាសុខាភិបាលមានគុណភាព ស្របតាមពិធីសារជាតិ មគ្គុទ្ទេសក៍ប្រតិបត្តិគ្លីនិក និងបមាណីយគុណភាពជាតិ ។
- ជំរុញឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវា ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកជំងឺ និងអតិថិជននិងការផ្លាស់ប្តូរឥរិយាបទរបស់ប្រជាជនក្នុងការថែទាំសុខភាព។
- ពង្រឹងការអនុវត្តអភិក្រមផ្តល់សេវាសុខភាពមានគុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងមាននិរន្តរភាព ព្រមទាំងបង្កើនគណនេយ្យភាពលើលទ្ធផល។

*ហិរញ្ញប្បទានប្រព័ន្ធសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- បង្កើនចំណាយថវិកាជាតិលើសុខភាពអនុលោមតាមកំណើនសេដ្ឋកិច្ចនិងសមត្ថភាពសារពើពន្ធ។
- តម្រង់ធនធានដែលមានឆ្ពោះទៅកាន់តម្រូវការផ្នែកសុខភាពរបស់ប្រជាជន។
- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលមាន ប្រកបដោយតម្លាភាព និងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល ។
- បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងការមករកសេវា និងប្រើប្រាស់សេវាថែទាំសុខភាពមានគុណភាព និងសុវត្ថិភាព ។
- តម្រង់និងសុខដុមនីយកម្មជំនួយអភិវឌ្ឍន៍ជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល និងពង្រឹងការសម្របសម្រួលមូលនិធិដៃគូអភិវឌ្ឍ។

*អភិវឌ្ឍធនធានមនុស្សសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- អនុវត្តអភិក្រមឯកភាព ក្នុងការកសាងផែនការអភិវឌ្ឍធនធានមនុស្សសុខាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពរបស់ប្រជាពលរដ្ឋ និងតម្រូវការនៃការផ្តល់សេវា ។
- លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងជំនាញដែលត្រូវការនិងតម្រូវការនៃការអភិវឌ្ឍធនធានមនុស្ស នៅក្នុងបរិបទនៃការផ្លាស់ប្តូរប្រជាសាស្ត្រ និងអេពីដេមីញូសាស្ត្រ។
- លើកកម្ពស់ការបែងចែកបុគ្គលិកឲ្យកាន់តែមានលក្ខណៈសមធម៌ និងធានាការរក្សាទុកបុគ្គលិកដែលមានពហុជំនាញ ដើម្បីផ្តល់សេវាសុខាភិបាលមានប្រសិទ្ធភាព។
- លើកកម្ពស់បរិស្ថានអំណោយផល ដោយគិតទាំងទីកន្លែងធ្វើការ ដើម្បីធានាផលិតភាពការងារខ្ពស់ ការលើកទឹកចិត្ត និងការចូលរួមបំពេញការងាររបស់បុគ្គលិក។
- ពង្រឹងការងារនិយតកម្ម និងការគ្រប់គ្រងធនធានមនុស្សសុខាភិបាល ដើម្បីធានាគុណ ភាព និងសុវត្ថិភាពនៃការផ្តល់សេវាសុខាភិបាល។

*ប្រព័ន្ធគាំទ្រជាសារវន្តដោយផ្តោតលើអន្តរាគមន៍៖*

- ផ្គត់ផ្គង់គ្រប់គ្រាន់ដល់មូលដ្ឋានសុខាភិបាលសាធារណៈនូវឱសថ បរិក្ខា វ៉ាក់សាំង ប្រតិករនិងសម្ភារពេទ្យដែលមានគុណភាព សុវត្ថិភាពនិងស័ក្តិសិទ្ធិភាព នៅក្នុងតម្លៃដែលអាចរ៉ាប់រងបាន។
- លើកកម្ពស់ការប្រើប្រាស់ឱសថ បរិក្ខារវ៉ាក់សាំង ប្រតិករនិងសម្ភារពេទ្យដោយសនិទានកម្ម។
- ពង្រឹងការអនុវត្តយន្តការនិយតកម្ម ដើម្បីធានាគុណភាពនៃផលិតផលឱសថវិទ្យាដោយរាប់បញ្ចូលទាំងឱសថ បរិក្ខារ វ៉ាក់សាំង ប្រតិបត្តិករ សម្ភារនិងឧបករណ៍ពេទ្យ។
- អភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ដើម្បីបង្កើនភាពជឿទុកចិត្តបាននៃលទ្ធផលវិភាគ និង ពង្រឹងយន្តការត្រួតពិនិត្យគុណភាព។
- ផ្គត់ផ្គង់ឈាម និងផលិតផលឈាមគ្រប់គ្រាន់ មានសុវត្ថិភាពនិងនិរន្តភាព ព្រមទាំងពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ឈាម សម្រាប់អ្នកជំងឺ។

*អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- សាងសង់និងពង្រីកសំណង់អគារមូលដ្ឋានសុខាភិបាល យោងតាមផែនការគ្របដណ្តប់សុខាភិបាល បច្ចុប្បន្នកម្ម និងស្របតាមប្លង់និមាបនកម្មគំរូ។
- បំពាក់ឧបករណ៍ពេទ្យកម្រិតមូលដ្ឋាន និងបច្ចេកវិទ្យាវេជ្ជសាស្ត្រទំនើបដល់មូលដ្ឋានសុខាភិបាល ដើម្បីលើកកម្ពស់សមត្ថភាពធ្វើរោគវិនិច្ឆ័យ និងបង្កើនគុណភាពសេវាព្រមទាំងផ្គត់ផ្គង់មធ្យោបាយបញ្ជូន។

- លើកកម្ពស់បរិស្ថានគាំទ្រដល់ការធ្វើឲ្យប្រសើរឡើងទិដ្ឋភាពទូទៅនៃគុណភាព ដើម្បីសុវត្ថិភាពអ្នកជំងឺ និងអ្នកផ្តល់សេវា។
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ដើម្បីសម្រួលដល់មូលដ្ឋានសុខាភិបាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងការបង្រៀន ផ្តល់សេវា និងការត្រួតពិនិត្យតាមដាន។
- ពង្រឹងការគ្រប់គ្រងការថែទាំជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្ភារៈឧបករណ៍ពេទ្យ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងមធ្យោបាយដឹកជញ្ជូន ។

*ប្រព័ន្ធព័ត៌មានសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- អភិវឌ្ឍ និងប្រើប្រាស់ឧបករណ៍គតិយុត្ត និងពិធីសារសម្រាប់ការគ្រប់គ្រងព័ត៌មានសុខាភិបាល។
- បង្កើនប្រភពទិន្នន័យព័ត៌មានសុខាភិបាល និងព័ត៌មានទាក់ទងសុខាភិបាលព្រមទាំងបង្កើនគុណភាពទិន្នន័យ។
- បង្កើនសមត្ថភាពនៃការវិភាគទិន្នន័យ បកស្រាយ ចងក្រងរបាយការណ៍ ប្រើប្រាស់ និង ផ្សព្វផ្សាយជាពិសេសនៅមូលដ្ឋានសុខាភិបាល និងស្រុកប្រតិបត្តិ ។
- ពង្រឹងប្រព័ន្ធជាតិអង្កេតតាមដាន និងឆ្លើយតបនឹងជំងឺ ដោយរាប់បញ្ចូលទាំងប្រព័ន្ធអន្តរាគមន៍បន្ទាន់នៃសុខភាពសាធារណៈ និងប្រព័ន្ធរាយការណ៍អំពីជំងឺ។
- ពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងលើកកម្ពស់ការសិក្សាស្រាវជ្រាវសុខាភិបាល។

*អភិបាលកិច្ចប្រព័ន្ធសុខាភិបាលដោយផ្តោតលើអន្តរាគមន៍៖*

- រៀបចំរចនាសម្ព័ន្ធ និងមុខងារស្ថាប័នសុខាភិបាលគ្រប់ជាន់ថ្នាក់ ដើម្បីឆ្លើយតបមានប្រសិទ្ធភាពទៅនឹងបរិស្ថានផ្លាស់ប្តូរ និងផលប៉ះពាល់ពីកម្មវិធីជាតិកំណែទម្រង់សំខាន់ៗ។
- អភិវឌ្ឍគោលនយោបាយ បញ្ញត្តិ និងវិធានសុខាភិបាល និងពង្រឹងសមត្ថភាពនិយ័តកម្មនៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល ។
- បង្កើនភាពម្ចាស់ការ និងគណនេយ្យភាព ដើម្បីលើកកម្ពស់លទ្ធផលសុខភាព និងភាពប្រសើរឡើងនៃការសម្របសម្រួល និងសហប្រតិបត្តិការក្នុងចំណោមដៃគូភាគីពាក់ព័ន្ធទាំងអស់។
- ប្រើប្រាស់សក្តានុពលនៃភាពជាដៃគូរវាងផ្នែកសុខាភិបាលសាធារណៈ និងឯកជនក្នុងការផ្តល់សេវាសុខភាព ការអភិវឌ្ឍសមត្ថភាព ការអនុវត្តគោលនយោបាយ និងនីតិក្រមសុខាភិបាល។

- លើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋក្នុងសហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងគណនេយ្យភាពលើសុខភាពនៅមូលដ្ឋាន។

៤.៧៦- ***អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*** ជាស្ថាប័នជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលមានតួនាទីដឹកនាំ ចាត់ចែង និងសម្របសម្រួលការឆ្លើយតបទៅនឹងជំងឺអេដស៍នៅទូទាំងប្រទេស។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ លើកទី៣ ឆ្នាំ២០១១-២០១៥ និងការរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ឆ្នាំ២០១៦-២០២០ ដើម្បីសម្រេចបានគោលដៅបីសូន្យ គឺ (១)មិនមានការចម្លងមេរោគអេដស៍ថ្មី (២)មិនមានការរើសអើងជាមួយអ្នកផ្ទុកមេរោគអេដស៍ និង (៣)មិនមានការស្លាប់ដោយសារមេរោគអេដស៍។ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តជាគោលនយោបាយក្នុងការបញ្ចប់ការចម្លងរាលដាលមេរោគអេដស៍នៅត្រឹមឆ្នាំ២០២៥ និងបានកំណត់គោលដៅ ៩៥/៩៥/៩៥ នៅឆ្នាំ២០២៥-២០៣០។

៤.៧៧- ដើម្បីសម្រេចគោលដៅខាងលើ ***អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*** បានកំណត់គោលនយោបាយសំខាន់ៗមួយចំនួនក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ ក៏ដូចជាការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជាផងដែរ។ គោលនយោបាយសំខាន់ៗមានដូចជា៖

- ការបញ្ចូលការឆ្លើយតបអេដស៍ទៅក្នុងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។
- ដាក់ឲ្យអនុវត្តនិយាមបែបបទស្ដីពីការធ្វើសមាហរណកម្មកម្មវិធីអេដស៍ក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ និងផែនការវិនិយោគឃុំសង្កាត់។
- គោលនយោបាយដាក់បញ្ចូលអ្នកផ្ទុកមេរោគអេដស៍ក្រីក្រទៅក្នុងមូលនិធិសមធម៌។
- បន្តការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

៤.៧៨-កម្មវិធីជាអាទិភាពសម្រាប់អនុវត្តគោលនយោបាយខាងលើ រួមមាន៖

- ពង្រឹង និងពង្រីកបទអន្តរាគមន៍ដែលមានប្រសិទ្ធភាពទៅលើភូមិសាស្ត្រ និងក្រុមគោលដៅប្រឈមមុខខ្ពស់ បង្កើនការគ្របដណ្ដប់សេវាធ្វើតេស្តឈាម និងការទទួលថ្នាំប្រឆាំងមេរោគអេដស៍ និង កាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី។
- ធ្វើសមាហរណកម្មកម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ ដើម្បីអនុវត្តបទអន្តរាគមន៍ទាក់ទងនឹងសកម្មភាពមេរោគអេដស៍ និងជំងឺអេដស៍ និងសេវាកម្មដែលពាក់ព័ន្ធ បង្កើនការអប់រំបង្ការ បង្កើនការរកករណីឆ្លងមេរោគថ្មី និងបង្កើនការគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងធានាឲ្យមានការចូលរួមយ៉ាងសកម្មក្នុងការលុបបំបាត់មេរោគអេដស៍នៅត្រឹមឆ្នាំ២០២៥-២០៣០។

- បញ្ចូលកម្មវិធីអេដស៍ទៅក្នុងមូលនិធិសមធម៌៖ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានខិតខំដើម្បីដាក់បញ្ចូលអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះព្រមទាំងសេវាព្យាបាលមេរោគអេដស៍ទៅក្នុងមូលនិធិសមធម៌ ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងផែនការ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ បានសហការរួមគ្នាបន្តពង្រីកកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ។

### តារាងទី ៤.៥ សូចនាករសំខាន់ៗតាមវិស័យ និងកំណត់ចំណុចដៅសម្រាប់ឆ្នាំ២០១៩-២០២៣

| សូចនាករសំខាន់ៗ | ឯកតា | ទិន្នន័យគោល ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជនឆ្លងមេរោគថ្មី ធៀបនឹងប្រជាជនដែលគ្មានឆ្លងមេរោគអេដស៍១ ០០០ នាក់។ | % | ០,០៤ | | ០,០៣ | | | ០,០៣ |
| អាត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ អាយុ ១៥ ដល់ ៤៩ឆ្នាំ | % | ០,៦ | ០,៥ | ០,៥ | ០,៥ | ០,៤ | ០,៤ |
| ៩៥% នៃអ្នកសង្ស័យថា មានផ្ទុកមេរោគអេដស៍ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន | % | ៨៦ | ៨៨ | ៩០ | ៩១ | ៩២ | ៩៣ |
| ៩៥% នៃអ្នកដែលដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | % | ៩៨ | ៩៨ | ៩៨ | ៩៨ | ៩៨ | ៩៨ |
| ៩៥% នៃអ្នកដែលទទួលការព្យាបាល និងមានមេរោគអេដស៍នៅក្នុងឈាមកម្រិតទាបបំផុត | % | ៨០ | ៨៥ | ៩០ | ៩១ | ៩២ | ៩៣ |

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៤.៧៩- បច្ចុប្បន្ននេះ ***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ*** បានត្រូវបានកំណត់សសរស្តម្ភចំនួន៤ នៃសន្តិសុខស្បៀង គឺ**ភាពមានស្បៀង ភាពទទួលបានស្បៀង ការប្រើប្រាស់ស្បៀង និង ស្ថេរភាពស្បៀង** សំដៅសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០ គឺ "**មិនទុកឲ្យនរណាម្នាក់នៅឯកកោ**" ។ សកម្មភាពអាទិភាពទាំងនោះ រួមមានដូចខាងក្រោម៖

### ភាពមានស្បៀង

- ធ្វើពិពិធកម្មផលិតកម្មកសិកម្ម - ផលិតកម្មស្បៀងដែលគិតគូរពីអាហារូបត្ថម្ភ។
- លើកកម្ពស់ខ្សែសង្វាក់ផលិតកម្មនិងដំណើរការបញ្ចូលមីក្រូសារធាតុក្នុងចំណីអាហារ។
- លើកកម្ពស់គុណភាពនិងសុវត្ថិភាពស្បៀង(ទាំងនាំចូល នាំចេញ និងទីផ្សារក្នុងស្រុក)។

- លើកកម្ពស់ប្រសិទ្ធភាពនិងតម្លៃបន្ថែមបច្ចេកទេសកសិកម្មប្រកបដោយនិរន្តរភាព។
- ធ្វើឲ្យប្រសើរឡើងភាពមានស្បៀង ស្ថេរភាពស្បៀង។
- ផ្តោតលើការនាំចេញនិងសមត្ថភាពប្រកួតប្រជែង ដោយផ្តោតលើវិស័យកសិកម្មដោយគិតគូពីអាហារូបត្ថម្ភ។

### ភាពទទួលបានស្បៀង

- បង្កើនការយកចិត្តទុកដាក់ក្នុងការទទួលបានស្បៀង (លទ្ធភាពទូទាត់ និង ធនធាន)
- ដោះស្រាយវិសមភាពនៃការទទួលបានស្បៀង (ដោយមិនទុកឲ្យនរណាម្នាក់នៅឯកកោ)
- រៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ដោយផ្អែកលើទិន្នន័យភាពងាយរងគ្រោះ
- លើកកម្ពស់ប្រពន្ធ័សុវត្ថិភាពសង្គមនិងធានាឲ្យមានទំនាក់ទំនងផ្សារភ្ជាប់រវាងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការគាំពារសង្គម។

### ការប្រើប្រាស់ស្បៀង

- បង្កើនលទ្ធភាពទទួលបាន ការផ្លាស់ប្តូរឥរិយាបទសម្រាប់កម្មវិធីទឹកស្អាត និងអនាម័យ
- បង្កើនលទ្ធភាពទទួលបានសេវាសង្គមនិងសុខភាពនិងការផ្លាស់ប្តូរឥរិយាបថ
- បង្កើនការផ្តល់ចំណីអាហារឲ្យត្រឹមត្រូវ
- លើកកម្ពស់អភិក្រមវដ្តជីវិតដើម្បីអាហាររូបត្ថម្ភដូចជាកម្មវិធី១ 000ថ្ងៃដំបូងនៃជីវិត កុមារគ្រប់អាយុចូលរៀន កុមារវ័យជំទង់
- ផ្តោតលើការអន្តរាគមន៍សម្រាប់បញ្ហាបន្ទុកទ្វេដងនៃអាហារូបត្ថម្ភនិងជំងឺមិនឆ្លង។

### ស្ថេរភាពស្បៀង

- បង្កើនការឆ្លើយតបយន្តការគាំពារសង្គមដោយភ្ជាប់នឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- បង្កើនការយកចិត្តទុកដាក់លើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការប្រឆាំងនឹងភាពរិចរឹលបរិស្ថាន
- បន្តការពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ(កាត់បន្ថយហានិភ័យ រៀបចំ និងឆ្លើយតប) រាល់វិបត្តិដែលអាចកើតមាន ដូចជា៖ អាកាសធាតុ សេដ្ឋកិច្ច សុខភាពជាដើម
- បង្កើនភាពធន់ទ្រាំនឹងអាកាសធាតុនៅតាមសហគមន៍។

៤.៨០- សម្រាប់ការងារអាទិភាពស្ថិតនៅក្នុងការសម្របសម្រួល និងផ្តោតជាពិសេសទៅលើសកម្មភាពអន្តរវិស័យ ដូចខាងក្រោម៖

- ពង្រឹងយន្តការស្ថាប័នដើម្បីពង្រឹងអភិបាលកិច្ចលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- បន្តការផ្សារភ្ជាប់ទំនាក់ទំនងរវាងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងគាំពារសង្គម ព្រមទាំងការពង្រីកវិសាលភាពអាហារូបត្ថម្ភទៅនឹងវិធានការគាំពារសង្គម។

- បង្កើនសកម្មភាពបន្ទុកទ្វេដងក្នុងការដោះស្រាយបញ្ហាអាហារូបត្ថម្ភ ដើម្បីសម្រេចបានគោលដៅទី២ និងគោលដៅទី៣ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។
- ពង្រីកប្រព័ន្ធសុវត្ថិភាពស្បៀង និងការគិតគូរពីអាហារូបត្ថម្ភ ដោយត្រូវការការយកចិត្តទុកដាក់ចំពោះផលិតកម្មស្បៀង និងការប្រើប្រាស់ស្បៀង កាកសំណល់ស្បៀង សុវត្ថិភាពស្បៀង និងបញ្ហាយេនឌ័រ ព្រមទាំងការគាំទ្រពហុវិស័យ។
- បង្កើនការតស៊ូមតិដើម្បីធានាឲ្យមានការរួមចំណែកបន្ថែមទាំងថវិកា និងសម្ភារៈពីរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍ ប្រព័ន្ធផ្សព្វផ្សាយនិងគ្រឹះស្ថានសិក្សាអប់រំដទៃទៀត។
- បន្តកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ និងកម្មវិធីសន្តិសុខស្បៀង គាំទ្រដល់ការសម្របសម្រួល និងអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលតម្រូវឲ្យមានការផ្តោតលើកម្មវិធីរួមដើម្បីជួយលើកកម្ពស់អាហារូបត្ថម្ភតាមរយៈកសិដ្ឋានគ្រួសារ សហគមន៍ព្រៃឈើនិងនេសាទ។

៤.៨១- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ***ក្រសួងសុខាភិបាល*** នឹង៖

- លើកកម្ពស់ការអនុវត្តវិធានចិញ្ចឹមទារកនិងកុមារតូច ជាពិសេស ការបំបៅកូនដោយទឹកដោះម្តាយនិងការផ្តល់អាហារបន្ថែម។
- បង្កើនការគ្របដណ្តប់នៃការផ្តល់បន្ថែមជីវជាតិអានិងថ្នាំទម្លាក់ព្រូន ដោយផ្តោតការយកចិត្តទុកដាក់នៅតំបន់ដែលលំបាកទៅដល់។
- បង្កើនការគ្របដណ្តប់នៃការផ្តល់បន្ថែមអាហារមានផ្ទុកពហុមីក្រូសារជាតិចិញ្ចឹម(ម្សៅពហុមីក្រូសារជាតិសម្រាប់កុមារ អាហារបំប៉ន ទឹកត្រី ទឹកស៊ីអ៊ីវ មានលាយសារជាតិដែក និងអំបិលអ៊ីយ៉ូដ)។
- ពង្រឹងការផ្តល់សេវាសមាហរណកម្មតាមមូលដ្ឋាននិងតាមសហគមន៍ ដោយរាប់បញ្ចូលទាំងការពិនិត្យតាមដានការលូតលាស់របស់កុមារនិងផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ។
- ពង្រឹងសេវាគ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរនៅតាមមន្ទីរពេទ្យ។
- ពង្រឹងការអនុវត្តវិធានច្បាប់ទាក់ទងនឹងអាហារូបត្ថម្ភ ដូចជាកំហិតការផ្សាយពាណិជ្ជកម្ម និងការជំរុញការប្រើប្រាស់ផលិតផលទឹកដោះគោ។

៤.៨២- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពី ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ***ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*** និង ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*** នឹងបន្តសកម្មភាពអាទិភាពដូចខាងក្រោម៖

- ជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកលនៅកម្ពុជា បង្កើនវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល បន្តអនុវត្តរបបសន្តិសុខសង្គមសម្រាប់ មន្ត្រីសាធារណៈ

អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន និងរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត និងរៀបចំរបបថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍

- ដាក់ឲ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ នៃគ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗ សំដៅលើកកម្ពស់អាហារូបត្ថម្ភ និងរៀបចំឲ្យមានយន្តការពហុវិស័យ ដោយមានការចូលរួមពីសហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃតំបន់ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភកម្រិតខ្ពស់។

៤.៨៣- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពីការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ***ក្រសួងផែនការ*** នឹងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ តាមរយៈការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ក្នុងសកម្មភាពដូចខាង ក្រោម៖

- រៀបចំឲ្យមានគោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស លិខិតបទដ្ឋានគតិយុត្ត ច្បាប់ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឲ្យបានទូលំទូលាយ និងជំរុញការអនុវត្តខ្លឹមសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព
- ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារផ្សេងៗទៀតដែលសមស្រប និងធានាបាននូវគុណភាពសុវត្ថិភាពនិងបរិមាណគ្រប់គ្រាន់តាមតម្រូវការ។
- ជំរុញការដាក់បញ្ចូលកម្រិតឬបរិមាណមីក្រូសារជាតិនីមួយៗទៅក្នុងបញ្ជីស្តង់ដាជាតិ។
- តម្រូវការចាំបាច់នូវការវិភាគទិន្នន័យស្តីពីការបរិភោគចំណីអាហារតាមប្រភេទនីមួយៗ។
- ជំរុញឲ្យមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិឲ្យបានទូលំទូលាយ(អំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក អង្ករបញ្ចូលមីក្រូសារជាតិ)។

## វិស័យទឹកស្អាត

៤.៨៤- សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ដើម្បីឲ្យប្រជាពលរដ្ឋនៅទីប្រជុំជន១០០% ទទួលបានសេវាទឹកស្អាតនៅឆ្នាំ២០២៥ និងធានាបាននូវបុរេលក្ខខណ្ឌ៤ គឺ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ***ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*** មានគោលដៅលើកកម្ពស់សកម្មភាព ដូចខាងក្រោម៖

- ជំរុញ និងលើកកម្ពស់ការគ្រប់គ្រង បច្ចេកទេស និង ហិរញ្ញវត្ថុ។
- លើកកម្ពស់ប្រសិទ្ធភាព កិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជំនួយអន្តរជាតិ។
- លើកកម្ពស់ក្របខ័ណ្ឌគោលនយោបាយ និងបញ្ញត្តិកម្ម។
- រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន។
- ជំរុញវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន។

- បង្កើនការការពារប្រភពទឹក និងពង្រឹងបញ្ញត្តិកម្ម។
- លើកម្ពស់ការអភិវឌ្ឍធនធានមនុស្ស។
- លើកកម្ពស់ ការយល់ដឹងអំពីគុណប្រយោជន៍ទឹកស្អាត និងការចូលរួម ដើម្បីអនុវត្ត "**ទឹកស្អាតសម្រាប់ទាំងអស់គ្នា**"។

**តារាងទី ៤.៦ ការប៉ាន់ស្មានអត្រា ប្រជាជនទីប្រជុំជនទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត តាមបំពង់ ២០១៩-២០២៣**

| ល.រ | សូចនាករ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ១ | អត្រាប្រជាជនទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ | ៥៣,៧១ | ៦១,៧១ | ៦៩,៧១ | ៧៧,៧១ | ៩០ |
| ២ | ចំនួនប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ | ៤ ៣២៦ ៧០៣ | ៤ ៦៧២ ៨៣៩ | ៥ ០៤៦ ៦៦៧ | ៥ ៤៥០ ៤០០ | ៥ ៨៨៦ ៤៣២ |

## ៣.៤- ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៨៥- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និង ពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិ ។

៤.៨៦- រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគួរឲ្យកត់សម្គាល់ ជាអាទិ៍ បានបញ្ជ្រាបយេនឌ័រទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និង ផែនការអភិវឌ្ឍជាតិ បានកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ មុខងារសាធារណៈ បានពង្រីកសហគ្រិនភាពរបស់ស្ត្រីបានកាត់បន្ថយអំពើហិង្សា និង ការរំលោភបំពានផ្លូវភេទលើស្ត្រី និង កុមារ បានលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ និង បានពង្រឹងកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារ។ ក្នុងផ្នែកគាំពារសង្គម រាជរដ្ឋាភិបាលបានដាក់ចេញ និង អនុវត្ត ***«ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥»*** ដែលមានភាពគ្រប់ជ្រុងជ្រោយ ស្របតាម ដំណាក់កាល និង កម្រិតនៃការអភិវឌ្ឍប្រទេស ព្រមទាំងបាននិងកំពុង បន្តរៀបចំស្ថាប័នគ្រប់គ្រងឡើងវិញ។ ជាក់ស្តែង រាជរដ្ឋាភិបាលកំពុងអនុវត្តគម្រោងស្បៀងបម្រុង កម្មវិធីផ្តល់អាហារតាមសាលារៀន កម្មវិធីអាហារូបករណ៍ និង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និង កុមារដែលជាផ្នែកនៃប្រព័ន្ធជំនួយសង្គម និង កំពុងអនុវត្តមូលនិធិសមធម៌សុខាភិបាល របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព និង ហានិភ័យការងារសម្រាប់កម្មករនិយោជិតនៅក្រោម បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន និង មូលនិធិជនពិការ ដែលជាផ្នែកនៃប្រព័ន្ធសន្តិសុខសង្គម។

៤.៨៧- ទន្ទឹមនឹងសមិទ្ធផលនេះ កម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ការរើសអើងលើស្ត្រីនៅតែមាន បន្ទុកការងារ និង គ្រួសារ នៅតែរារាំងឱកាសស្ត្រីក្នុងការងារ អប់រំ សេដ្ឋកិច្ចសង្គម និង នយោបាយ ការជួញដូរ និង អំពើហិង្សាលើស្ត្រី និង កុមារនៅបន្ត កើតមាន ពិសេសចំពោះស្ត្រីចំណាកស្រុក វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយ និង ពេញលេញ ដំណើរការគ្រប់គ្រងកម្មវិធី និង របបនៃប្រព័ន្ធគាំពារសង្គមមិនទាន់មានលក្ខណៈប្រមូលផ្តុំ។

៤.៨៨- ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់ គឺ៖

ទី១-ការបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និង ការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្រសួង-ស្ថាប័ន ទាំងកម្រិតនយោបាយ និង កម្រិតជំនាញ។

ទី២-ការធ្វើបច្ចុប្បន្នភាព និង អនុវត្ត *"ផែនការយុទ្ធសាស្ត្រនារីរតនៈ"* ដោយបន្តជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និង ផែនការអភិវឌ្ឍគ្រប់ផ្នែកគ្រប់វិស័យ និង គ្រប់កម្រិត បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និង ការពង្រឹងភាពជាដៃគូរវាងស្ថាប័ន ពាក់ព័ន្ធសំដៅទប់ស្កាត់ការជួញដូរ និង អំពើហិង្សាលើស្ត្រី និង កុមារ។

ទី៣-ការជំរុញអនុវត្ត *"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥"* ពិសេសដោយដាក់ឲ្យអនុវត្តនូវរបបហានិភ័យការងារមន្ត្រីសាធារណៈ និង របបសោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារការកែទម្រង់របបសោធនសម្រាប់មន្ត្រីរាជការ ការធ្វើសមាហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គម និង ក្របខ័ណ្ឌអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ទន្ទឹមនឹងការជំរុញការអនុវត្ត*គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០* និង *គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០*។

ទី៤-ការរៀបចំក្របខ័ណ្ឌគតិយុត្ត និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីដាក់ឲ្យដំណើរការ កម្មវិធីជាតិជំនួយសង្គមថ្មីៗ និង ពង្រីកកម្មវិធីដែលមានស្រាប់សំដៅបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រ និង ជនងាយរងគ្រោះ និង ដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមថ្មី ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៨៩- រាជរដ្ឋាភិបាលកម្ពុជានៅក្នុងអាណត្តិទី៦នេះ តាមរយៈ***ក្រសួងកិច្ចការនារី***នឹងរៀបចំ និងអនុវត្ត**គោលនយោបាយស្តីពីសមភាពយេនឌ័រ** តាមរយៈការបញ្ជ្រាបយេនឌ័រ និងការអនុវត្តអនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទទៅក្នុងគ្រប់វិស័យ និងកម្មវិធីអភិវឌ្ឍនានាដើម្បីកាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះរបស់ស្ត្រី ជាពិសេសស្ត្រីពិការ ស្ត្រីជនជាតិដើមភាគតិច។ ក្នុងបរិការណ៍នេះ ក្រសួងនឹងបន្តការយកចិត្តទុកដាក់ជាពិសេសលើការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការធ្វើសេចក្តីសម្រេចរបស់ស្ត្រីក្នុងវិស័យសាធារណៈនិងនយោបាយទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី សុខភាព និងការអប់រំសម្រាប់ស្ត្រីនិងកុមារី និងការពង្រឹងយន្តការក្នុងការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ និងកម្មវិធីជាតិនានារួមទាំងកម្មវិធីប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង។

៤.៩០- សកម្មភាពអាទិភាព មានដូចខាងក្រោម៖

*ស្ត្រី ក្នុងវិស័យអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ច*

ក្រសួងបន្តដឹកនាំការសម្របសម្រួល ក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធី និងប្រព័ន្ធអប់រំ និងការបង្កើនភាព អង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ព្រមទាំងលើកកម្ពស់ជីវភាពសេដ្ឋកិច្ចគ្រួសារនៅតាមសហគមន៍ តាមរយៈ៖

- ពង្រឹងសេវាអភិវឌ្ឍន៍សហគ្រិនភាព និងធុរកិច្ចរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ប្រកបដោយច្នៃប្រឌិត នវានុវត្តន៍ និងបរិយាប័ន្ន។
- បង្កើនកាលានុវត្តភាព បរិយាកាសមេត្រីភាព និងលទ្ធភាពឲ្យស្ត្រីទទួលបានការងារសមស្រប ការអភិវឌ្ឍជំនាញ បច្ចេកទេស និងវិជ្ជាជីវៈ រួមទាំងបច្ចេកវិទ្យាឌីជីថល ទៅតាមតម្រូវការរបស់ស្ត្រី និងតម្រូវការទីផ្សារ ជាពិសេសបច្ចេកទេសកម្រិតស្តង់ដា។
- ពង្រីកភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សហគ្រិនភាព និងអភិវឌ្ឍន៍សក្តានុពលបទពិសោធន៍ និងបច្ចេកទេស ក្នុងការបង្កើនផលិតភាព គុណភាពផលិតផល និងអាចឈានចូលទៅកាន់ទីផ្សារជាតិ និងក្នុងតំបន់។
- បង្កើនការចូលរួមរបស់ស្ត្រី ក្មេងស្រី ក្នុងវិស័យអប់រំ នៅកម្រិតខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាស្តែម ។
- លើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ គាំទ្រសហគ្រាសធនតូច និងមធ្យម រួមទាំងមូលនិធិជាតិសហគ្រិនភាព និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពដែលឆ្លើយតបនឹងសមភាពយេនឌ័រ។
- បន្តអនុវត្តយុទ្ធសាស្ត្រ ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ដែលឆ្លើយតបផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ។

### ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី

ក្រសួងកិច្ចការនារី នឹងដឹកនាំសម្របសម្រួល ទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ ដោយការធ្វើបច្ចុប្បន្នកម្ម និងអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ អនុវត្តផែនការសកម្មភាពស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងចូលរួមអនុវត្តផែនការសកម្មភាពប្រឆាំងនឹងអំពើជួញដូរមនុស្ស តាមរយៈ៖

- ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីវប្បធម៌អហិង្សា សីលធម៌សង្គម និងជំរុញការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាលើស្ត្រីដល់សាធារណជន ។
- ការបង្កើត និងកែលម្អសេវាសង្គម សេវាសុខាភិបាល និងសេវាផ្នែកច្បាប់ ជាពិសេសបង្កើតមណ្ឌលសេវាចម្រុះ សម្រាប់ស្ត្រីនិងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់។
- ការបង្កើត និងកែលម្អគោលនយោបាយ និងច្បាប់ដែលពាក់ព័ន្ធនានា ។
- អភិវឌ្ឍន៍សមត្ថភាព អាជ្ញាធរ សមត្ថកិច្ច ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ រួមទាំង ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារគ្រប់រូបភាព រួមទាំងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីពិការ និងស្ត្រីដែលស្ថិតក្នុងក្រុមជនងាយរងគ្រោះនានា ។
- បន្តអនុវត្តផែនការអនុតំបន់មេគង្គ លើកទី៤ និងក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃគណៈកម្មាធិការជាតិប្រយុទ្ធអំពើជួញដូរមនុស្ស។
- ដឹកនាំ និងសម្របសម្រួលការរៀបចំ និងអនុវត្តផែនការសកម្មជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ឆ្នាំ២០១៩-២០២៣។
- បន្តផែនការសកម្មភាពការងារឆ្នាំ២០១៩-២០២០ គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មការចម្រុះលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

### ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ

ក្រសួងកិច្ចការនារី នឹងសហការជាមួយដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់តួនាទីស្ត្រី ក្នុងជួរថ្នាក់ដឹកនាំ ក្នុងវិស័យសាធារណៈ និងនយោបាយ តាមរយៈ៖

- បង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាព ស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយ និងទាំងកម្រិតជំនាញ។
- លើកកម្ពស់ការយល់ដឹង ការយកចិត្តទុកដាក់របស់សាធារណជន អ្នកមានចំណែកពាក់ព័ន្ធអំពីតម្លៃភាពចាំបាច់នៃសមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍនិងអភិបាល-កិច្ច។

### យេនឌ័រ និងសុខភាព

ក្រសួងនឹងបន្តជំរុញការលើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់ ទទួលសេវាសុខាភិ-បាល និងការងារពាក់ព័ន្ធ ដើម្បីធានាឲ្យជីវិតរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ លើកកម្ពស់សុខុមាលភាពរបស់ប្រជាជនគ្រប់រូប និងគ្រប់វ័យ តាមរយៈ៖

- ការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសុខាភិបាល ។
- ការបង្កើនការយល់ដឹងជាសាធារណៈ ក្នុងការលើកកម្ពស់សុខភាពបន្តពូជ កាត់បន្ថយមរណៈភាពមាតា ទារក និងកុមារ កង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រី និងកុមារ កាត់បន្ថយការឈឺ ស្លាប់ដោយជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត។

***ពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ និងកម្មវិធីជាតិ រួមទាំងការប្រែប្រួលអាកាសធាតុ៖***

ក្រសួង នឹងពង្រឹងយន្តការសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ តាមវិស័យ កម្មវិធីកំណែទម្រង់នានា ប្រកបដោយបរិយាប័ន្ន តាមរយៈ៖

- ការតាក់តែងសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងក្របខ័ណ្ឌតាមដាន និងវាយតម្លៃនៃការអនុវត្តគោលនយោបាយជាតិ។
- ពង្រឹងសមត្ថភាព និងលទ្ធភាពយន្តការក្នុងការបញ្ជ្រាបយេនឌ័រ រួមទាំងក្រុមការងារបញ្ជ្រាបយេនឌ័រ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ។
- បន្តអនុវត្តយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍបៃតង ។

### តារាងទី ៤.៧ សូចនាករសំខាន់ៗសម្រាប់វាស់វែងក្នុងវិស័យយេនឌ័រ ២០១៩-២០២៣

| សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ***១. ស្ត្រី ក្នុងវិស័យអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ច*** | | | | | | | |
| ១.១. ភាគចំណែករបស់ស្ត្រីចូលរួមក្នុងការងារមានប្រាក់កម្រៃ អាយុពី១៥-៦៤ ឆ្នាំ | | | | | | | |
| កសិកម្ម | % | ៣៥,៣ (២០១៧) | | ៤០ | | ៤២ | ៤២ |
| ឧស្សាហកម្ម | % | ២៧,៣ (២០១៧) | | ៣០ | | ៣២ | ៣២ |
| សេវាកម្ម | % | ៣៧,៦ (២០១៧) | | ៣៩ | | ៤១ | ៤១ |
| ១.២. អត្រាស្ត្រីដែលមានការងារធ្វើអាយុពី១៥-៦៤ ឆ្នាំ | % | ៧៩,៩ (២០១៧) | | ៨១ | | ៨៣ | ៨៣ |
| ***២. ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី*** | | | | | | | |
| ២.១. ចំនួនមណ្ឌល | ចំនួន | ០ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | | |
|---|---|---|---|---|---|---|
| សេវាចម្រុះសម្រាប់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ដើម្បីសម្រួលការផ្តល់សេវាផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗទៀតជូនជនរងគ្រោះ | | | | | | |
| *៣.ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ* | | | | | | |
| ៣.១ សមាមាត្រស្ត្រីដែលមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈ ទាំងថ្នាក់ជាតិនិងក្រោមជាតិ(អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យនិងប្រធានមន្ទីរ) | % | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ |

*ប្រភព៖* ក្រសួងកិច្ចការនារី

៤.៩១- ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី*** សុទ្ធតែបានទទួលភារកិច្ច ដើម្បីផ្តល់នូវសេវាសង្គមដល់ប្រជាពលរដ្ឋ និងការពារដល់ក្រុមជនងាយរងគ្រោះឲ្យរួចផុតពីហានិភ័យទាំងឡាយ។ ការធ្វើអន្តរាគមន៍ដោយឡែកនៃបណ្តាញសុវត្ថិភាពសង្គម ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ឧទាហរណ៍***ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***។ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គមនិងការគាំពារសង្គម ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*** កំណត់យុទ្ធសាស្ត្រ៣ គឺ (១)បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម (២)បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង(៣)ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ។

៤.៩២- ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលស្តីពី ការពង្រឹងសមត្ថភាពយេនឌ័រ និង ការគាំពារសង្គម ***ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា*** នឹងបន្តសកម្មភាពអាទិភាពដូចខាងក្រោម៖

***កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម***

**អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ**

- លើកកម្ពស់សុខុមាលភាពជនរងគ្រោះនិងជនងាយរងគ្រោះ និងកិច្ចការគ្រួសារ
- ផ្តល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ
- ដាក់ឲ្យដំណើរការកម្មវិធីឧបត្ថម្ភជាជំហានៗ សម្រាប់គ្រួសារក្រីក្រ ដោយបន្ថែមការឧបត្ថម្ភពេលសម្រាលនៅពាក់កណ្តាលឆ្នាំ២០១៩។
- តភ្ជាប់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងអត្រានុកូលដ្ឋានប្រជាជនទូទៅប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រ និងងាយរងគ្រោះ និងប្រព័ន្ធរបស់ស្ថាប័នប្រតិបត្តិករដើម្បីបង្កើនប្រសិទ្ធភាពការងារ កាត់បន្ថយពេលវេលានិងចំណាយ និងការបង្កើនការលើកម្ពស់ការយល់ដឹងរបស់ប្រជាជនពាក់ព័ន្ធនិងប្រព័ន្ធគាំពារសង្គម។

**ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា**

- ពង្រឹងគុណភាពសេវាថែទាំកុមារក្នុងមណ្ឌល និងពង្រីកសេវាថែទាំកុមារតាមសហគមន៍
- ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងរបាយការណ៍ស្តីពីស្ថានភាពកុមារ
- អនុវត្តការងារសុំកូនអន្តរប្រទេស ដោយធានាឧត្តមប្រយោជន៍និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ
- ស្តារនីតិសម្បទាអនីតិជនដែលប្រព្រឹត្តល្មើសនឹងច្បាប់
- ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

**ការអភិវឌ្ឍសុខុមាលភាពជនពិការ**

- បង្កើនប្រសិទ្ធភាពផ្តល់សេវាសុខុមាលភាពជនពិការ និងលើកកម្ពស់សិទ្ធិជនពិការ
- ពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងលិខិតបទដ្ឋានគតិយុត្ត

**ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

- ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ តាមឃុំ សង្កាត់
- សិក្សា និងបង្កើតកម្មវិធីគាំពារមនុស្សចាស់ជរា

**ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

- អភិវឌ្ឍសហគមន៍អតីតយុទ្ធជន
- សម្របសម្រួលការងារសមាគមអតីតយុទ្ធជននៅថ្នាក់ឃុំ សង្កាត់

### កម្មវិធីទី២៖ បង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

**អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធ ភាព**

- ផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលជូនសិទ្ធិវន្តនៃ ប.ជ.ស

**បង្កើនប្រសិទ្ធិភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

- បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
- លើកស្ទួយជីវភាពអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

**បន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- ផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ
- កៀរគរប្រភពធនធានថវិកាសម្រាប់និរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ
- ផ្តល់របបគោលនយោបាយឧបត្ថម្ភដល់ជនពិការ
- ផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ

### កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ

**ពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ**

- ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល
- បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស
- អនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤

**អភិវឌ្ឍធនធានមនុស្ស**

- បណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ
- ពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច

**តារាងទី៤.៨ សូចនាករសំខាន់ៗ សម្រាប់វាស់វែង ២០១៩-២០២៣**

| ល.រ | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | ៦៦ ០៥៦ | ៦៧ ៤១៨ | ៦៨ ៨៦៦ | ៧០ ២៤៣ | ៧១ ៦៤៨ | ៣៤៤ ២៧១ |
| ២ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៩៦៨ | ៨២៣ | ៧០០ | ៥៩៥ | ៥០៦ | ៣ ៥៩២ |
| ៣ | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | ២ ៥៦៧ | ២ ៨០០ | ៣ ០៣៣ | ៣ ២៦៦ | ៣ ៤៩៩ | ១៥ ១៦៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | ២ ១៦៧ | ២ ២៧៦ | ២ ៣៨៩ | ២ ៥០៩ | ២ ៦៣៤ | ១១ ៩៧៥ |
| ៥ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំក្នុងមជ្ឈមណ្ឌល | នាក់ | ១១០ | ១២១ | ១៣៣ | ១៤៦ | ១៦១ | ៦៧១ |
| ៦ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ៣៦ ០០០ | ៧២ ០០០ | ៧២ ០០០ | ៧២ ០០០ | ៧២ ០០០ | ៣២៤ ០០០ |
| ៧ | កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | ១៨ ០០០ | ១០៨ ០០០ | ១៨០ ០០០ | ១៤៤ ០០០ | ១៤៤ ០០០ | ៥៩៤ ០០០ |
| ៨ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភ ទទួលបានការស្តារនីតិសម្បទា | នាក់ | ៣០០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ១ ៣០០ |
| ៩ | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | ៣០០ | ២២០ | ២២០ | ២២០ | ២២០ | ១ ១៨០ |
| ១០ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ១០ | ១០ | ១០ | ១០ | ១០ | ៥០ |
| ១១ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | ៣៥០ | ២២០ | ២២០ | ២២០ | ២២០ | ១ ២៣០ |
| ១២ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវទទួលបានការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | ៣០០ | ២២០ | ២២០ | ២២០ | ២២០ | ១ ១៨០ |
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានផ្តល់នូវសេវាក្រោយធ្វើសមាហរណកម្ម | នាក់ | ៣០០ | ២០០ | ២០០ | ២០០ | ២០០ | ១ ១០០ |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបិទករណី | នាក់ | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ | ៧៥០ |
| ១៥ | កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់ | នាក់ | ៧ ៤៨១ | ៧ ៣៣៦ | ៧ ១៨៩ | ៧ ០៤៥ | ៦ ៩០៤ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | នៅក្នុងមណ្ឌលថែទាំកុមារ | | | | | | | |
| ១៦ | កុមារកំព្រា និង កុមាររងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ១ ១៦៣ | ១ ១៨៦ | ១ ២១០ | ១ ២៣៤ | ១ ២៩៦ | ៦ ០៨៩ |
| ១៧ | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារនិងសហគមន៍ | នាក់ | ១០ ៧៧១ | ១០ ៧៩៤ | ១០ ៨១៨ | ១០ ៨៤២ | ១០ ៩០៤ | |
| ១៨ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | ១០ | ១៥ | ១៥ | ១៥ | ១៥ | ៧០ |
| ១៩ | ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | ២ | ២ | ២ | ២ | ២ | ១០ |
| ២០ | អត្រាអនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែនិងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ | ២ ៥០០ |
| ២១ | កូនតាមម្តាយដែលមានអាយុចាប់ពី៣(បី)ឆ្នាំឡើងទៅនៅក្នុងពន្ធនាគារ ត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ២០ | ២០ | ២០ | ២០ | ២០ | ១០០ |
| ២២ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ៤ ០០០ | ៣ ៨០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ១៨ ៣០០ |
| ២៣ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ | ២ ៥០០ |
| ២៤ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ១៤០ ០០០ |
| ២៥ | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៩ ០០០ | ៤៥ ០០០ |
| ២៦ | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាស្តារនិងពិនិត្យថែទាំសុខភាព | នាក់ | ២៩ ២៥៣ | ៣៩ ៧០១ | ៥០ ១៤៨ | ៦០ ៥៩៦ | ៧១ ០៤៣ | |
| ២៧ | ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ៥៩០ | ៥៩០ | ៥៩០ | ៥៩០ | ៥៩០ | ២ ៩៥០ |
| ២៨ | ជនពិការត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារ | នាក់ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៥០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | នៅតាមស្ថាប័នរដ្ឋ(២%)[1] | | | | | | | |
| ២៩ | ជនពិការត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%)[2] | នាក់ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ១៧ ៥០០ |
| ៣០ | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ១០ ២២៨ | ១៣ ២២៨ | ១៦ ២២៨ | ១៩ ២២៨ | ២២ ២២៨ | |
| ៣១ | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ | ៥៥ ០០០ | ២៧៥ ០០០ |
| ៣២ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | ២% | ៣% | ៤% | ៥% | ៦% | |
| ៣៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | ៣០ | ៥០ | ៨០ | ១០០ | ១៣០ | |
| ៣៤ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានរបបគាំពារសង្គម | នាក់ | ៦ ២៥០ | ៧ ៥០០ | ៨ ៧៥០ | ១០ ០០០ | ១១ ២៥០ | |
| ៣៥ | និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | ១០៥ ០៩៥ | ១០៩ ៤៤៥ | ១១៣ ៨១៥ | ១១៨ ១៧៥ | ១២២ ៥៣៥ | |
| | និវត្តន៍ជនដែលទទួលរបបសោធន | នាក់ | ៥៥ ៧៩៩ | ៥៨ ២៩៩ | ៦០ ៧៩៩ | ៦៣ ២៩៩ | ៦៥ ៧៩៩ | |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ២ ១៣៩ | ២ ០៣៩ | ១ ៩៣៩ | ១ ៨៣៩ | ១ ៧៣៩ | |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤៧ ១៥៧ | ៤៩ ១១៧ | ៥១ ០៧៧ | ៥៣ ០៣៧ | ៥៤ ៩៩៧ | |
| ៣៦ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៩១ ៧៤៩ | ៩៦ ២៤៩ | ៩៧ ២៤៩ | ៩៧ ៧៤៩ | ៩៨ ២៤៩ | |
| | និវត្តន៍ជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៣១ ៦៦២ | ៣៥ ៩៩២ | ៣៧ ០៤៧ | ៣៧ ៧៣២ | ៣៨ ៥៨២ | |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៤៥០ | ១ ៣៣៥ | ១ ២២៥ | ១ ១១០ | ៩៩៥ | |
| | ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៦ ៥៣១ | ២៦ ៦៨៦ | ២៦ ៦៩១ | ២៦ ៦៤៦ | ២៦ ៥៥១ | |
| | ជនពលីដែលកំពុងទទួល | នាក់ | ២៥ ៤២១ | ២៥ ៤៤១ | ២៥ ៤៤១ | ២៥ ៤១៦ | ២៥ ៣៧៦ | |

[1] ទិន្នន័យបានទទួលពីក្រសួង ស្ថាប័នចំនួន៤៣

[2] ទិន្នន័យទទួលបានពីក្រុមហ៊ុនចំនួន៦៣

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | របបសន្តិសុខសង្គម | | | | | | | |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៦ ៦៨៥ | ៦ ៧៩៥ | ៦ ៨៤៥ | ៦ ៨៤៥ | ៦ ៧៤៥ | |
| ៣៧ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ១៥០ | ១៥០ | ២០០ | ២០០ | ២០០ | ៩០០ |
| ៣៨ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៥០០ | ៥០០ | ៥៥០ | ៥៥០ | ៥៥០ | ២ ៦៥០ |
| ៣៩ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ៨៩ | ៩៨ | ១២០ | ១៥០ | ១៥០ | ៦០៧ |
| ៤០ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ១៥០ | ១៥០ | ២០០ | ២៥០ | ២៥០ | ១ ០០០ |

៤.៩៣- ***គ្រប់ក្រសួង ស្ថាប័នទាំងអស់*** សុទ្ធតែដើរតួក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជនរបស់រាជរដ្ឋាភិបាលកម្ពុជា។ ***អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ*** មានតួនាទីក្នុងការដឹកនាំ សម្របសម្រួលរៀបចំ គោលនយោបាយជាតិប្រជាជន និងយុទ្ធសាស្ត្រនានា សម្រាប់អនុវត្ត រួមទាំងបញ្ហាប្រជាជនទាំងឡាយដែលស្ថិតនៅកម្រិតក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចគាំទ្រនិងជំរុញ បញ្ហាគោលនយោបាយជាតិប្រជាជន ដោយផ្តោតលើវិស័យអាទិភាពចំនួន៤ រួមមាន៖ (១)ការអភិវឌ្ឍនិងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ (២)ការគ្រប់គ្រងការធ្វើទេសន្តប្រវេសន៍និងនគរូបនីយកម្ម (៣)ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ (៤)ការវិនិយោគលើវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស។ គោលដៅសំខាន់បំផុតនៃគោលនយោបាយជាតិប្រជាជន គឺសម្របសម្រួលការបញ្ចូលកត្តាឌីណាមិកប្រជាសាស្ត្រទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅគ្រប់វិស័យនិងគ្រប់កម្រិត និងធានាឲ្យបានការអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ សំដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃប្រែប្រួលប្រជាសាស្ត្រទៅលើការអភិវឌ្ឍ នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ តំបន់ និងសកល ដោយរក្សាតម្លៃវប្បធម៌និងប្រពៃណីខ្មែរ និងការធានាការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន។ **គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** បន្តឈរលើគោលការណ៍ដែលមានចែងនៅក្នុងគោលនយោបាយ ជាតិប្រជាជន ឆ្នាំ២០០៣ ដោយទទួលស្គាល់ និងគាំទ្រចំពោះសិទ្ធិរបស់គូស្វាមីភរិយា និងបុគ្គលទាំងអស់ឲ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើចំនួនកូននិងការពន្យារកំណើត ហើយឲ្យមានលទ្ធភាពទទួលបានព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយ ដើម្បីធ្វើការសម្រេចចិត្តនេះ។

៤.៩៤-ដើម្បីសម្រេចបានចក្ខុវិស័យនិងគោលដៅខាងលើ ***អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ*** ដើរតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្ត កម្មវិធីនិងគម្រោង របស់ក្រសួងស្ថាប័នពាក់ព័ន្ធដោយផ្អែកលើអាទិភាពទាំងបួន ដែលបានចែងក្នុងគោលនយោបាយជាតិប្រជាជន តាមរយៈការអនុវត្ត

ផែនការសកម្មភាពរយៈពេលបីឆ្នាំ ដែលត្រូវរៀបចំឡើងជាប្រាំដំណាក់កាលរហូតដល់ឆ្នាំ២០៣០។ ផែនការសកម្មភាពនេះ គឺជាឧបករណ៍សម្រាប់ការអនុវត្ត និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃអំពីវឌ្ឍនភាពនៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។ នៅក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ នឹងផ្តោតលើសកម្មភាពដូចខាងក្រោម៖

- អនុវត្តផែនការសកម្មភាពដំណាក់កាលទី២ ២០១៩-២០២១
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍វឌ្ឍនភាពនៃផែនការសកម្មភាព ២០១៩-២០២១
- រៀបចំ និង អនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ ២០២២-២០២៤
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃផែនការសកម្មភាព ២០២២-២០២៤
- រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃគោលនយោបាយជាតិប្រជាជននៅឆ្នាំ ២០២៣ ដែលរបាយការណ៍នេះនឹងរំលេចអំពីវឌ្ឍនភាព បញ្ហាប្រឈម និងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រទៅលើការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។
- ជំរុញការការអនុវត្តគោលនយោបាយជាតិប្រជាជន ក្នុងក្របខ័ណ្ឌនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

## ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

៤.៩៥- ការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាដំណើរការចាំបាច់នៃការបង្កើតចន្លល់ឲ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រីកការនាំចេញ ឬ បង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីអាចរក្សាកំណើនសេដ្ឋកិច្ច នៅក្នុងកម្រិតខ្ពស់ក្នុងរយៈពេលមធ្យម និង វែងខាងមុខ។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចផ្តោតលើអាទិភាពចំនួន៤ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធ និង បំពេញឲ្យគ្នាទៅវិញទៅមក គឺ៖ (១)ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល (២)ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ (៣)ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និង (៤)ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ ។

### ៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល

#### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.៩៦- ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺយើងសម្រេចបានវឌ្ឍនភាពគួរជាទីមោទន ទោះជាយ៉ាងនេះក្តីកម្ពុជានៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលរួមមានថ្លៃឡូជីស្ទីកនៅតែខ្ពស់ ការសម្របសម្រួលស្ថាប័នក្នុងការអភិវឌ្ឍ និង ការថែទាំហេដ្ឋារចនាស

ម្ព័ន្ធនៅមានភាពទន់ខ្សោយ ហេដ្ឋារចនាសម្ព័ន្ធនៅតែមិនទាន់គ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី និង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយ និង ដល់ទីតាំងសហគ្រាស ឬ រោងចក្រ ឲ្យស្របតាម ប្លង់គោលរៀបចំដែនដីនគរូបនីយកម្ម និង ប្លង់ប្រើប្រាស់ដីធ្លី។ ផ្នែកថាមពលនៅប្រឈមនឹងថ្លៃអគ្គិសនីខ្ពស់ បញ្ហាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី និង ប្រភពថាមពលកកើតឡើងវិញ នៅមិនទាន់បញ្ចូលក្នុងល្បាយថាមពលឲ្យអស់សក្តានុពលសេដ្ឋកិច្ចនៅឡើយ។ ផ្នែកឌីជីថល នៅបន្តជួបបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការវិនិយោគ និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការពង្រីកវិសាលភាព និងប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នង និងខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ។

៤.៩៧- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នឹងផ្តោតអាទិភាពលើ៖

- ទី១-អនុម័ត និង អនុវត្តផែនការមេសម្រាប់វិស័យដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីក ដើម្បីបង្កើនល្បឿនសមាហរណកម្ម ការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និង អភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះឲ្យកាន់តែមានលក្ខណៈប្រកួតប្រជែងខ្ពស់នៅក្នុងតំបន់ និង ពិភពលោក។
- ទី២-ការបន្តបង្កើនថវិកាវិនិយោគ និង កៀរគរហិរញ្ញប្បទាន ដើម្បីស្តារកសាង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្លូវគោក ស្ពាន ផ្លូវដែក ផ្លូវទឹក និង ផ្លូវអាកាស ព្រមទាំងផ្លូវល្បឿនលឿនសំដៅឆ្លើយតបឲ្យបានទាំងបរិមាណ គុណភាព សុវត្ថិភាព និង ភាពធន់មាំទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេស ដែលកិច្ចការនេះត្រូវដើរទន្ទឹមគ្នាជាមួយនឹងការពង្រឹងការសម្របសម្រួលយន្តការស្ថាប័នឲ្យកាន់តែប្រសើរឡើង។
- ទី៣-ការបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញគ្របដណ្តប់ និងបង្កើនស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយបន្ថែមឲ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់។
- ទី៤-ការបន្តអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល តាមរយៈការពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកជាបណ្តាញចែកចាយ ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នង និង ខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ ទូរស័ព្ទចល័តប្រកបដោយគុណភាព មានលក្ខណៈទំនើបទាន់សម័យ មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូទាំងប្រទេស។
- ទី៥-ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការធ្វើផែនការ ការរៀបចំថវិកា ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃគម្រោង។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.៩៨- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងសាធារណការ និង ដឹកជញ្ជូន*** នឹងខិតខំបន្តការងារ៖

### ១- ការងារច្បាប់ បទដ្ឋានគតិយុត្ត និងកំណែទម្រង់

- បន្តរៀបចំបញ្ចប់គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តចាំបាច់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យដឹកជញ្ជូន និងបទដ្ឋាននានា ដែលពាក់ព័ន្ធការកំណត់ស្តង់ដាសំណង់ផ្លូវថ្នល់ ការដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹក។
- កំណត់ និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក និងផ្លូវសមុទ្រ ច្បាប់អាជីវកម្មដឹកជញ្ជូនផ្លូវគោក និងច្បាប់ដឹកជញ្ជូនពហុរូបភាព ភស្តុភារកម្ម និងផែស្ងួត ច្បាប់ស្តីពីប្រព័ន្ធចម្រោះទឹកកខ្វក់ ច្បាប់ស្តីពីផ្លូវល្បឿនលឿន និងស្ពានធំៗ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមនឹងការជំរុញការអនុម័ត ពង្រឹងការគ្រប់គ្រង និងការអនុវត្ត។
- កំណត់ និងធ្វើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលទាក់ទងនឹងផ្លូវដែក។
- បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ស្លាកលេខសម្គាល់យានជំនិះ។
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិញ្ញាបនបត្រកណ្ណធារ និងអនុក្រឹត្យស្តីពីការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា និងពិនិត្យឡើងវិញសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធជាតិសម្រាប់ការត្រៀមឆ្លើយតបនឹងប្រេងកំពប់និងកិច្ចសហប្រតិបត្តិការ។
- បន្តរៀបចំ និង ផ្សព្វផ្សាយច្បាប់អាទិភាពមួយចំនួនជាពិសេស ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ផ្លូវថ្នល់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តពង្រឹងស្ថាប័នតាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស និងការជ្រើសរើសបុគ្គលិកប្រកបដោយគុណភាព និងដោយតម្លាភាព។
- បន្តចូលរួម និងជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- រៀបចំអនុក្រឹត្យ ប្រកាស ប្រកាសអន្តរក្រសួង និងលិខិតបទដ្ឋានគតិយុត្តនានា តាមការកំណត់ដែលមានចែងនៅក្នុងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។
- បន្តរួមចំណែកសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤៖
    - ការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃ
    - បន្តចុះបញ្ជីតាមអនឡាញឲ្យកាន់តែមានប្រសិទ្ធភាព
    - បន្តរៀបចំ និងដាក់ប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ
    - ពង្រឹងដំណើរការកម្មវិធីអេប(App)សម្រាប់ការចូលរួមកម្មវិធីថែទាំផ្លូវថ្នល់
    - រៀបចំដាក់ឲ្យដំណើរការកម្មវិធីអេប សម្រាប់ដីចំណីផ្លូវ(ជប៉ុន)។

### ២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

#### ការងារសាធារណការ

- បន្តស្តារ សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឲ្យបានយ៉ាងហោចប្រវែង ៣ ០០០គ.ម.បន្ថែម។

- បន្តស្តារ សាងសង់ និងពង្រីកផ្លូវជាតិកម្រិត១ ពីប្រភេទផ្លូវក្រាលកៅស៊ូ២ជាន់ ២គន្លង ទៅបេតុងកៅស៊ូ(AC)៤គន្លង ដែលតភ្ជាប់ទៅតំបន់អភិវឌ្ឍន៍និងនៅជុំវិញទីក្រុងសំខាន់ៗ ឲ្យបានយ៉ាងហោច ៧០០គ.ម. ។
- បន្តស្តារ សាងសង់ផ្លូវជាតិ ផ្លូវខេត្ត ភ្ជាប់ទៅតំបន់អភិវឌ្ឍន៍ឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ថ្មីៗដែលបានបង្កើតឡើង និងតាមតំបន់ព្រំដែន។
- បន្តបង្កើនអត្រាក្រាលកៅស៊ូសម្រាប់ផ្លូវជាតិកម្រិត២ ឲ្យបាន ១០០% និងផ្លូវខេត្តឲ្យបាន យ៉ាងតិច ៤០%។
- បន្តពង្រឹងគុណភាពលើការថែទាំ ជួសជុល និងការងារសាងសង់ និងធានាឲ្យបាននូវលំហូរថវិកាជាតិលើការថែទាំប្រចាំ និងថែទាំខួបបណ្តាញផ្លូវថ្នល់។
- បង្កើនស្លាកសញ្ញាសុវត្ថិភាពចរាចរលើផ្លូវជាតិ និងតំបន់ទីប្រជុំជន និងរៀបចំដាក់ឲ្យមានកាមេរ៉ាសម្រាប់តាមដានការបើកបរលើសល្បឿនកំណត់នៅតាមផ្លូវជាតិ។
- បន្តការស្តាបនាស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមបណ្តាខេត្តសំខាន់ៗ។
- បន្តកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ អង្គការនានា និងក្រុមហ៊ុនឯកជនមួយចំនួនក្នុងការវិនិយោគលើវិស័យទឹកកខ្វក់(បណ្តាញលូ ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធសម្អាតទឹកកខ្វក់ និងទីលានសំរាម)។
- ជំរុញបញ្ចប់ និងអនុវត្តផែនការមេ សម្រាប់ស្ថានីយ៍ប្រព្រឹត្តកម្ម ទឹកកខ្វក់ទូទាំងប្រទេស
- ជំរុញការសិក្សាសាងសង់ផ្លូវល្បឿនលឿន និងស្ពានធំៗជាមួយនឹងដៃគូអភិវឌ្ឍពិសេស ខ្សែផ្លូវភ្នំពេញ-បាវិត និងភ្នំពេញ-ប៉ោយប៉ែត-សៀមរាប តាមផែនការមេនៃការអភិវឌ្ឍផ្លូវល្បឿនលឿននៅកម្ពុជា។

**គម្រោងបញ្ចប់ បើកឲ្យប្រើប្រាស់ និងដំណើរការអនុវត្តក្នុងអាណត្តិទី៦ ហិរញ្ញប្បទានចិន៖** គម្រោងផ្លូវជាតិលេខ៥៥, លេខ៥៨, ផ្លូវក្រវាត់ក្រុងខ្សែទី២ និងទី៣, លេខ៧ជំហានទី១(ខ្លាស្ទុះ-ឃុំរមាត), លេខ៧ជំហានទី២(ឃុំរមាត-ត្រពាំងគ្រៀល), ស្ពានឆ្លងកាត់ទន្លេមេគង្គក្រូចឆ្មារ-ស្ទឹងត្រង់, លេខ១១, លេខ៥១,លេខ៣, លេខ៧០បេ (ទន្លេបិទ-ស្រីសន្ធ-ព្រែកតាមាក់),លេខ៦០បេ(កំពង់ថ្ម-ក្រុងក្រចេះ),ស្ពានឆ្លងកាត់ទន្លេមេគង្គខេត្តក្រចេះ, លេខ៧១សេ, លេខ១០(សំឡូត-វាលវែង-កោះកុង), លេខ៥០C, ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ, ផ្លូវបាត់ដំបង-សៀមរាប, លេខ៤១, លេខ៣១០ (អ្នកលឿង-កោះរការព្រំប្រទល់កម្ពុជា-វៀតណាម), លេខ៣៣ និង ៣១,សាងសង់ស្ពានស្អាង,លេខ៤៣,លេខ៣៧៨(ដុងក្រឡ-សៀមប៉ាង-អូរជុំ-បានលុង), លេខ២៩៤(ឆែប-ទន្លេល្ពៅ), លេខ៧២(ត្រពាំងថ្លុង-ត្រើង-កំពុងថ្ម), លេខ៩២(សំអាង-កំពង់ស្រឡៅ១ និង២-មុំបី), លេខ៧៨-៥ (បានលុង-កន្ទួយនាគ),ផ្លូវជុំគីរី, និងគម្រោងសាងសង់ប្រព័ន្ធចម្រោះទឹកកខ្វក់ក្នុងបណ្តាខេត្តមួយចំនួនជាពិសេសខេត្តព្រះសីហនុ។

**ហិរញ្ញប្បទានជប៉ុន** គម្រោងជួសជុលឡើងវិញស្ពានជ្រោយចង្វារ, ផ្លូវជាតិលេខ៥ (បាត់ដំបង-សិរីសោភ័ណ,ព្រែកក្តាម-ធ្លាម្អម, ធ្លាម្អម-បាត់ដំបង និងសិរីសោភ័ណ-ប៉ោយប៉ែត) និងគម្រោងសាងសង់ឡើងវិញបន្ទាន់ ស្ពានចំនួន០៧(ផ្លូវជាតិ៧៣ និង១១)។

**ហិរញ្ញប្បទានសាធារណរដ្ឋកូរ៉េ** គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២១ ជំហ៊ានទី១ និងទី២(រង្វង់មូលតាខ្មៅ-ជ្រៃធំ), លេខ២(ក្រុងតាខ្មៅ-ក្រុងដូនកែវអូរចំបក់), និងលេខ២២(អូរចំបក់-អង្គតាសោម/ខេត្តតាកែវ), លេខ៤៨, កែលម្អស្ទឹងសៀមរាប ជំហានទី២, និងសាងសង់ប្រព័ន្ធលូចម្រោះទឹកកខ្វក់ក្រុងតាខ្មៅ។

**ហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី** ផ្លូវជាតិលេខ១៣ និងលេខ៣១៤ដេ, លេខ៥៣និងលេខ១៥១បេ អភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង(កែលម្អហេដ្ឋរចនាសម្ព័ន្ធ៤ ក្រុង ប៉ោយប៉ែត បាត់ដំបង បាវិត និង អ្នកលឿង), គម្រោងអភិវឌ្ឍរបៀង២(កំពត និងក្រុងព្រះសីហនុ) និងគម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញទន្លេសាប។

**ហិរញ្ញប្បទានធនាគារពិភពលោក** គម្រោងថែទាំ ជួសជុល(AC)៖ ផ្លូវជាតិលេខ៧(ថ្នល់ទទឹង-ខេត្តត្បូងឃ្មុំ-ក្រុងក្រចេះ) ផ្លូវជាតិលេខ៣(កំពត-វាលរេញ) និងផ្លូវជាតិលេខ៤(ភ្នំពេញ-ក្រុងព្រះសីហនុ)។

**ហិរញ្ញប្បទានថៃ** គម្រោងសាងសង់ស្ពានស្ទឹងបត់ គម្រោងសាងសង់អគារច្រកទ្វារព្រំដែនអន្តរជាតិ និងផ្លូវតភ្ជាប់(ប៉ុស្តិ៍ព្រំដែនមកភ្ជាប់នឹងផ្លូវជាតិលេខ៥)។

### ៣. ការងារផ្លូវដែក

- ស្វែងរកទុនកែសម្រួលខ្សែផ្លូវដែកពីភ្នំពេញ-ប៉ោយប៉ែត ឲ្យឡើងកម្រិតទម្ងន់២០តោន និងសាងសង់ ជួសជុលស្ថានីយ៍ បំពាក់ស្លាកសញ្ញាសុវត្ថិភាព ជួសជុលផ្លូវជៀស។
- ស្វែងរកទុនដើម្បីតភ្ជាប់ផ្លូវដែកពីភ្នំពេញទៅកំពង់ផែស្វយ័តភ្នំពេញថ្មី។
- ជំរុញឲ្យមានការតភ្ជាប់ផ្លូវដែកចូលរោងចក្រ សហគ្រាស តំបន់សេដ្ឋកិច្ចពិសេស ដូចជាពីស្ថានីយ៍ទូកមាសទៅរោងចក្រស៊ីម៉ង់ ពីស្ថានីយ៍ទូកមាសទៅរោងចក្រស៊ីម៉ង់ចក្រីទីង និងពីស្ថានីយ៍វាលរេញទៅកំពង់ផែកែរផុស។
- សាងសង់ទីលានកុងតឺន័រផ្លូវដែក នៅស្ទឹងបត់។
- ជំរុញការអនុវត្តកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់តាមព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ។
- ស្វែងរកហិរញ្ញប្បទានដើម្បីអនុវត្តគម្រោងធ្វើសមាហរណកម្មផ្នែកក្នុងផ្លូវដែក និងតភ្ជាប់ទៅបណ្តាប្រទេសជិតខាងតាមរយៈការសាងសង់ថ្មី តាមផែនការមេអភិវឌ្ឍផ្លូវដែកកម្ពុជា ដែលសិក្សាដោយសាធារណរដ្ឋកូរ៉េ ពិសេសផ្លូវដែកភ្នំពេញ-បាវិត-ហូជីមិញ។
- បន្តស្វែងរកដៃគូអភិវឌ្ឍនានា និងផ្នែកឯកជន ដើម្បីសាងសង់បណ្តាញផ្លូវដែកសិង្ហបុរី-គុនមិញ។

### ៤. ការងារឡូជីស្ទីក

ដើម្បីផ្តល់នូវការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពនៃតម្លៃ និងភាពងាយស្រួលសេវាកម្មនៅក្នុងការឆ្លើយតបទៅនឹងតម្រូវការ។ ក្រសួង នឹងបន្តការងារអាទិភាព៖

- ដំណើការអនុវត្តផែនការមេឡូជីស្ទីក ។
- បង្កើតមជ្ឈមណ្ឌលព័ត៌មាន និងផែនការអភិវឌ្ឍវិស័យព័ត៌មានវិទ្យាក្នុងវិស័យ ឡូជីស្ទីក។
- ជំរុញការវិនិយោគមជ្ឈមណ្ឌលឡូជីស្ទីក ឃ្លាំង ចំណតកុងតឺន័រ និងផែស្ងួត។
- រៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងផ្នែកឡូជីស្ទីក កិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិនូវទំនិញដែលមានគ្រោះថ្នាក់តាមផ្លូវថ្នល់ ច្បាប់គ្រប់គ្រងឃ្លាំងស្តុកទំនិញ និងច្បាប់នៃការផ្តល់សេវា និងគ្រប់គ្រងប្រតិបត្តិករឡូជីស្ទីក។
- ជំរុញការអនុវត្តគំនិតផ្តួចផ្តើមភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- បញ្ចូលទស្សនទានថ្មី ស្តីពីការប្រែក្លាយកម្ពុជាក្លាយជាមជ្ឈមណ្ឌលផ្លាស់ប្តូរទំនិញ និងភស្តុភារកម្ម នៅក្នុងតំបន់ ទៅក្នុងផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូន និងភស្តុភារកម្មដើម្បីទាញផលប្រយោជន៍នៃលំហូរពាណិជ្ជកម្មរវាងប្រទេសវៀតណាម និងថៃ។
- បន្តកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តផែនការមេតភ្ជាប់អាស៊ាន ២០២៥។
- រៀបចំគោលនយោបាយភស្តុភារកម្ម ដូចជាៈ ការគ្រប់គ្រងទំនិញក្នុងខ្សែចង្វាក់គ្រប់គ្រងសីតុណ្ហភាព ភស្តុភារកម្មបៃតង។

### ៥. ការអភិវឌ្ឍវិស័យដឹកជញ្ជូនប្រកបដោយចីរភាព

- បន្តពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នក្នុងការគ្រប់គ្រងបរិស្ថាន។
- ការបញ្ជ្រាបការអនុវត្តបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលនយោបាយបទដ្ឋានគតិយុត្ត និងកែសម្រួលផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ការប្រែប្រួលអាកាសធាតុ ក្នុងវិស័យដឹកជញ្ជូន។
- បន្តស្រាវជ្រាវបទដ្ឋានបច្ចេកទេសគំនូសប្លង់សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដើម្បីធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- បន្តផ្សព្វផ្សាយជំរុញការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីការធ្វើដំណើរដោយយានយន្តតាមរយៈការលើកទឹកចិត្តប្រជាជនឲ្យប្រើរថយន្តក្រុង រថភ្លើង ការប្រើប្រាស់កង់ និងថ្មើរជើង។
- បន្តបណ្តុះបណ្តាលមន្ត្រីជំនាញថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថវិកាជាតិសម្រាប់ការងារសាធារណការ ដោយប្រើប្រាស់ការវិភាគសេដ្ឋកិច្ច និងបណ្តុះបណ្តាលមន្ត្រីបង្គោលនូវវិធីសាស្ត្រវិភាគសេដ្ឋកិច្ចក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងសាងសង់ផ្លូវដោយប្រើប្រាស់ថវិកាជាតិ។

## ៦. ការងារដឹកជញ្ជូនផ្លូវគោក ដឹកជញ្ជូនសាធារណៈក្រុង និងសុវត្ថិភាពចរាចរផ្លូវគោក

### ការងារដឹកជញ្ជូនផ្លូវគោក

- ពង្រឹងការគ្រប់គ្រង ការចុះបញ្ជី ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការផ្តល់បណ្ណបើកបរតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងពង្រីកបន្ថែមទីតាំងផ្តល់សេវាសាធារណៈដឹកជញ្ជូនផ្លូវគោក កាន់តែខិតជិតប្រជាពលរដ្ឋ។
- ពង្រឹង ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ទាំងមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ការចុះបញ្ជីយានយន្ត ការផ្តល់បណ្ណបើកបរ ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងចុះបញ្ជីអាជីវកម្មដឹកជញ្ជូន)។
- ជំរុញបង្កើតបន្ថែមមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងរថយន្តត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័ត។
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និង ការចុះបញ្ជីយានជំនិះ ការចេញបណ្ណបើកបរ ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការផ្តល់សេវាសាធារណៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- ដំឡើងមជ្ឈមណ្ឌលទិន្នន័យដែលមានស្តង់ដាបច្ចេកវិទ្យាខ្ពស់ រក្សាបាននូវសុវត្ថិភាពទិន្នន័យ កាត់បន្ថយការចំណាយ បង្កើនគណនេយ្យភាពក្នុងការផ្តល់សេវា។
- បន្តធ្វើសមាហរណកម្មប្រព័ន្ធស្វ័យប្រវត្តកម្ម ចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងស្លាកលេខយានយន្តជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។
- ពិនិត្យលទ្ធភាពការចេញលិខិតអនុញ្ញាតច្បាប់អាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងឆ្លងដែន តាមផ្លូវគោក ឲ្យបានឆាប់ មានតម្លាភាព និងគណនេយ្យភាព។
- បន្តដាក់ឲ្យដំណើរការមណ្ឌលពន្យារ ឬប្តូរបណ្ណបើកបរនៅផ្សារទំនើប។

### ការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន

- បន្តពិភាក្សាអំពីការស្នើសុំការកែសម្រួលពិធីសារឆ្នាំ២០០៥ សម្រាប់ការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជា-វៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវគោក។
- បន្តការចរចាជាមួយប្រទេសជិតខាងដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងដោះស្រាយបញ្ហាប្រឈមលើការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែនទ្វេភាគី។
- ជំរុញការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់មេគង្គ។
- រៀបចំនីតិវិធី ច្បាប់ បទដ្ឋានគតិយុត្តចាំបាច់នានា ដើម្បីចូលរួមអនុវត្តកិច្ចព្រមព្រៀងទាំងបី ក្នុងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្របសម្រួលការដឹកជញ្ជូន គឺៈ១. កិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ ២.កិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលការដឹកជញ្ជូនអន្តររដ្ឋ និង៣.កិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្របសម្រួលការដឹកជញ្ជូនពហុរូបភាព។

- រៀបចំស្នើសុំសច្ចាប័នពីស្ថាប័នរដ្ឋសភា លើកិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌអាស៊ានស្តីពីការសម្របសម្រួលការដឹកជញ្ជូនអ្នកដំណើរតាមរថយន្ត។

**ការងារដឹកជញ្ជូនសាធារណៈក្រុង**

- ជំរុញការរៀបចំគោលនយោបាយជាតិ ផែនការមេ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងផ្នែកដឹកជញ្ជូនសាធារណៈ។
- ជំរុញការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃ និងការគ្រប់គ្រងចរាចរ។
- បន្តអភិវឌ្ឍផ្លូវវៀងក្រុងដើម្បីបញ្ចៀសការដឹកជញ្ជូនធន់ធ្ងន់ឆ្លងកាត់ក្រុង។
- បន្តការសិក្សាដោះស្រាយចំណុចកកស្ទះចរាចរក្នុងរាជធានីភ្នំពេញ។
- បន្តសិក្សាលទ្ធភាពសាងសង់ប្រព័ន្ធរថភ្លើងស្វ័យប្រវត្តិកម្មនិងសិក្សាលទ្ធភាពសាងសង់ត្រាំវ៉េ ម៉ូណូរ៉ែល (Tramway, Monorail) រថភ្លើងក្រោមដីនៅរាជធានីភ្នំពេញ។

**ការងារសុវត្ថិភាពចរាចរផ្លូវគោក**

- បន្តពង្រឹងសុវត្ថិភាពចរាចរផ្លូវគោក និងកាត់បន្ថយចំនួននៃការស្លាប់នៅតាមដងផ្លូវឱ្យនៅក្រោម៥នាក់ក្នុង ១ម៉ឺនគ្រឿងនៅត្រឹមឆ្នាំ២០២០។
- អនុវត្តសកម្មភាព និងពង្រីកកិច្ចសហការដើម្បីសម្រេចគោលដៅទសវត្សរ៍របស់អង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពចរាចរផ្លូវគោក បន្ថយអត្រាស្លាប់៥០% ត្រឹមឆ្នាំ២០២០។
- បន្តចុះអប់រំផ្សព្វផ្សាយច្បាប់ស្តីពីចរាចរផ្លូវគោកដល់សាធារណជនតាមគ្រប់រូបភាព។
- បន្តកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល លើការអនុវត្តការងារសុវត្ថិភាពចរាចរផ្លូវគោក។
- បន្តជំរុញផ្នែកឯកជនបង្កើតកម្មវិធីផ្សព្វផ្សាយ បណ្តុះបណ្តាលច្បាប់ចរាចរផ្លូវគោកដល់បុគ្គលិក កម្មកររបស់ក្រុមហ៊ុន។
- បន្តចែកស្ទីកឃ័រចំណាំងផ្លាត និងមួកសុវត្ថិភាពដល់អ្នកប្រើប្រាស់ទោចក្រយានយន្ត។
- បន្តចុះសិក្សា និងត្រួតពិនិត្យតំបន់ដែលមានគ្រោះថ្នាក់ញឹកញាប់នៅទូទាំងប្រទេស។

**ការងារបង្ការ និងទប់ស្កាត់បទល្មើសយានយន្តដឹកជញ្ជូនលើសទម្ងន់**

- បន្តអប់រំ ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងបញ្ជ្រាបការយល់ដឹង ស្តីពីច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការដឹកជញ្ជូនលើសទម្ងន់ និងពង្រឹងសមត្ថភាព និងសីលធម៌របស់មន្ត្រីឱ្យប្រកបដោយឆន្ទៈចំពោះការងារ ធានាសុក្រឹតនៃឧបករណ៍ត្រួតពិនិត្យទម្ងន់
- បន្តលុបបំបាត់ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងការកែច្នៃរថយន្តខុសលក្ខណៈបច្ចេកទេស និងរឹតបន្តឹង ការឃុបឃិត ការប្រព្រឹត្តបទល្មើសទម្ងន់ពីតាមបណ្តាស្ថានីយ៍។

## ៧. ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

### ដឹកជញ្ជូនផ្លូវទឹក

- ជំរុញអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពកិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាម ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០០៩។
- ពង្រឹងគុណភាពផ្ដល់សេវាសាធារណៈ លើការងារចុះបញ្ជីជលយាន និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ផ្ដល់បណ្ណបើកបរ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ និងជំរុញការអភិវឌ្ឍ និងគ្រប់គ្រងយានដ្ឋាននាវា។
- ពង្រឹងការងារគ្រប់គ្រង និងការចុះបញ្ជីនាវាតាមផ្លូវទឹក រួមទាំងការងារពាក់ព័ន្ធផ្សេងទៀតនៅតាមបណ្ដាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តដែលមានផ្លូវទឹក។
- សហការ និងចូលរួមក្នុងការងារសមាគមហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវទឹកអន្តរជាតិ។

### នាវាជំនួញសមុទ្រ

- ពង្រឹងគុណភាពផ្ដល់សេវាសាធារណៈលើការងារចុះបញ្ជីនាវា ត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា លិខិតអនុញ្ញាតធ្វើអាជីវកម្មនាវា និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ និងជំរុញការអភិវឌ្ឍ និងគ្រប់គ្រងយានដ្ឋាននាវា។
- ពិនិត្យរៀបចំការចុះបញ្ជីនាវាទង់ជាតិកម្ពុជាឡើងវិញ។
- បន្តកិច្ចសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍនាវាតំបន់ឆ្នេរ កម្ពុជា ថៃ និងវៀតណាម។
- បន្តអនុវត្តគម្រោង IMO/NORAD ស្ដីពីការបង្ការការបំពុលបរិស្ថានសមុទ្រចេញពីនាវា។
- ពិនិត្យឡើងវិញសេចក្ដីព្រាងផែនការជាតិគ្រោះអាសន្ន សម្រាប់ទប់ទល់នឹងការកំពប់ប្រេង
- ពង្រឹងការងារគ្រប់គ្រងនាវា និងនាវិក រួមទាំងការងារពាក់ព័ន្ធផ្សេងទៀត។
- ចូលរួមអនុវត្តការងារជាមួយគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។
- សហប្រតិបត្តិការជាមួយ ReCAAP ISC និងបណ្ដាប្រទេសជាសមាជិក។
- សហការជាមួយមជ្ឈមណ្ឌលសម្របសម្រួលបច្ចេកវិទ្យាដឹកជញ្ជូនតាមផ្លូវសមុទ្រ ដើម្បីទទួលចំណេះដឹងក្នុងការបង្កើតបទប្បញ្ញត្តិ និងគ្រប់គ្រងនាវា និងនាវិក។

### រដ្ឋបាលកំពង់ផែ

- បន្តអនុវត្តគោលនយោបាយជាតិស្ដីពីកំពង់ផែ និងរៀបចំផែនការមេស្ដីពីការអភិវឌ្ឍកំពង់ផែ និងជំរុញការអភិវឌ្ឍកំពង់ផែ ស្របតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ។
- សហការជាមួយផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា ក្នុងការធានាអភិវឌ្ឍកំពង់ផែប្រកបដោយនិរន្តរភាព រួមនឹងទំនើបកម្មប្រតិបត្តិការកំពង់ផែ ដូចជាការរៀបចំនឹងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យកំពង់ផែ។
- បង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលនាវិក ចុះផ្សព្វផ្សាយ និងផ្ដល់ការបណ្ដុះបណ្ដាលសមត្ថភាពជំនាញដល់បុគ្គលិកដែលទទួលខុសត្រូវផ្នែកសន្តិសុខបបនីយភ័ណ្ឌផែ។

### ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ

- ជំរុញការរៀបចំបង្កើតគម្រោងផែត្បូងឃ្មុំ(ទន្លេបិទ)។

- សិក្សា និងរៀបចំគម្រោងកាណូតដឹកជញ្ជូនអ្នកដំណើរសាធារណៈ សាងសង់កំពង់ផែខ្នាតតូច និងកំពង់ចម្លងនៅស្រុក និងតំបន់ផ្សេងៗមួយចំនួននៃប្រព័ន្ធទន្លេមេគង្គ។
- សាងសង់កំពង់ផែទេសចរណ៍នៅខេត្តកែប និងនៅតាមតំបន់ឆ្នេរ។
- សិក្សា និងរៀបចំសញ្ញាជំនួយនាវាចរណ៍ និងបូមស្តារប្រឡាយនាវាចរណ៍ ទន្លេរ៉ៃគោ ស្ទឹងអង្គរបូរី និងតំបន់ផ្សេងៗទៀតនៃប្រព័ន្ធទន្លេមេគង្គ។
- សិក្សាវាស់ស្ទង់ជម្រៅទឹក និងផលិតផែនទីអេឡិចត្រូនិកនាវាចរណ៍នៅតំបន់សមុទ្រ និងតំបន់ផ្សេងៗទៀតនៃប្រព័ន្ធទន្លេមេគង្គ។
- សិក្សា និងកសាងចំណាត់ថ្នាក់ផ្លូវទឹកសម្រាប់នាវាចរណ៍។
- សិក្សាវាស់ស្ទង់សម្រាប់សាងសង់កំពង់ផែ និងរៀបចំបទដ្ឋានបច្ចេកទេសកំពង់ផែ និងផ្លូវទឹក
- សហប្រតិបត្តិការជាមួយអង្គការជលសាស្ត្រអន្តរជាតិ គណៈកម្មការជលសាស្ត្រអាស៊ីខាងកើត និងសមាគមសញ្ញាជំនួយនាវាចរណ៍អន្តរជាតិ។

### ៨. អង្គភាពសហគ្រាសសាធារណៈ

មន្ទីរពិសោធន៍សំណង់ និងសាធារណការៈ

- ពង្រឹងគុណភាពមន្ទីរពិសោធន៍ ឲ្យបានសមស្របតាមស្តង់ដា ISO/IEC១៧០២៥។
- ពង្រឹងសេវាកម្មពិសោធន៍ ឲ្យខិតទៅជិតតំបន់អភិវឌ្ឍន៍តាមរយៈការបង្កើតសាខាមន្ទីរពិសោធន៍ នៅតាមបណ្តាខេត្តអភិវឌ្ឍសំខាន់ៗ។
- ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយដៃគូដើម្បីអភិវឌ្ឍន៍មន្ទីរពិសោធន៍។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

- សាងសង់ចំណតកំពង់ផែកុងតឺន័រប្រវែង៣៥០ម៉ែត្រ ជម្រៅទឹក-១៤,៥ម៉ែត្រ ទីលានកុងតឺន័រ និងបបនីយភ័ណ្ឌនិងការងារបូមស្តារអាងនាវា និងឃ្លូងនាវាជម្រៅ-១៤,៥ម៉ែត្រ។
- សិក្សាគម្រោងអភិវឌ្ឍទីលានស្តុកទំនិញនិងកុងតឺន័រ លើផ្ទៃដីជាង៥៤ហ.ត.។
- សិក្សាគម្រោងធ្វើឲ្យប្រសើរឡើងចំណតស្ថានីយ៍នាវាទេសចរណ៍អន្តរជាតិនៅផែចាស់។
- សិក្សាបន្ថែមតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ដោយបង្កើតគម្រោងសាកល្បង "Customs Manufacturing Bonded Warehouse" និង "Free Port" បម្រុងជា Logistic Hub។
- ខិតខំសម្រេចឲ្យបានទំនិញឆ្លងកាត់ឲ្យបានចំនួន ៣៧ ៤៤៥ ០០០ តោន។
- បរិមាណកុងតឺន័រឆ្លងកាត់ឲ្យបានចំនួន ៣ ៧៩៣ ០០០ TEUs ។
- បរិមាណនាវាឆ្លងកាត់ឲ្យបានចំនួន ៩ ២៧០ គ្រឿង។

កំពង់ផែស្វយ័តភ្នំពេញ

- បន្តជំរុញគម្រោងអភិវឌ្ឍន៍ជំហានទី៣ លើផ្ទៃដីទំហំ ៥,៥ហ.ត. ដែលមានសមត្ថភាពផ្ទុកកុងតឺន័របន្ថែមបានចំនួន ២០០ ០០០TEUs ក្នុងមួយឆ្នាំ។

- បន្តជំរុញការអភិវឌ្ឍចំណតផែទន្លេបិទUM២ និងសាងសង់ចំណតផែរណបតាមដងទន្លេ បន្តជំរុញការសាងសង់ចំណតផែទំនិញចាក់ធារ នៅជិតចំណតផែកុងតឺន័រ LM១៧។
- បន្តជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ ឃ្លាំងស្ងួត និងឃ្លាំងត្រជាក់ និងអភិវឌ្ឍមជ្ឈ-មណ្ឌលផ្តល់សេវាកម្មប្រមូល និងចែកចាយទំនិញ។
- បន្តធ្វើទំនើបកម្ម និងពង្រីកចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១។
- បន្តជំរុញ និងខិតខំសម្រេចឲ្យបានក្នុងរយៈពេល ៥ឆ្នាំ (២០១៩-២០២៣)នូវ៖
  - បរិមាណទំនិញឆ្លងកាត់ចំនួន ១៨ ៦០៨ ០០០តោន
  - បរិមាណកុងតឺន័រឆ្លងកាត់ចំនួន ១ ៣៧០ ០០០TEUs
  - បរិមាណនាវាផ្ទុកទំនិញឆ្លងកាត់ចំនួន ១៣ ៧០០គ្រឿង
  - បរិមាណនាវាដឹកអ្នកដំណើរអន្តរជាតិឆ្លងកាត់ចំនួន ៣ ៣១០ជើង

### ៩- ភាពជាដៃគូក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- បន្តរៀបចំក្របខ័ណ្ឌគតិយុត្តនានា និងរៀបចំវេទិកាសម្រាប់គាំទ្រការអភិវឌ្ឍ និងដោះស្រាយបញ្ហាឲ្យមានប្រសិទ្ធភាព ជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជន ។
- បន្តជំរុញផ្នែកឯកជន សិក្សាអំពីលទ្ធភាពវិនិយោគលើគម្រោង ផ្លូវស្ពាន ផ្លូវដែក កំពង់ផែបន្តទៀត ពិសេសផ្លូវល្បឿនលឿន ដែលជាអាទិភាពដូចមានចែងក្នុងផែនការមេ។
- បន្តលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូក្នុងវិស័យដឹកជញ្ជូន។
- បន្តចូលរួមសហការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដឹកជញ្ជូន និងគំនិតផ្តួចផ្តើមនានាក្នុងតំបន់ និងពិភពលោក។

៤.៩៩- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិ-កាលទី៦នៃរដ្ឋសភា ***រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល*** នឹងបន្តការងារអាទិភាពរបស់ខ្លួន រួមទាំងសកម្មភាពសំខាន់ៗរួមមាន៖

### ១. ការពង្រឹងសុវត្ថិភាពហោះហើរ

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធីស្តង់ដា តម្រូវការសេចក្តីណែនាំ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងការត្រួតពិនិត្យលទ្ធភាពហោះហើរ និងកិច្ចការពារបរិស្ថានឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្របតាមស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ICAO។
- សហការរៀបចំបទប្បញ្ញត្តិ បទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការកំណត់អាយុអាកាសយានដែលប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្អាក ដកហូត និងបន្តលិខិតអនុញ្ញាតប្រតិបត្តិការហោះហើរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា(ចេញ-ចូល និងឆ្លងកាត់)។

- ត្រួតពិនិត្យប្រតិបត្តិការគ្រប់អាកាសយានបរទេសដែលហោះហើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា(ចេញ-ចូល និងឆ្លងកាត់)និង គ្រប់គ្រងលើការងាររុករក និង សង្គ្រោះ។
- ស្រាវជ្រាវ និងវាយតម្លៃឧប្បត្តិហេតុ ឬ គ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយាននៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រចុះបញ្ជីអាកាសយាន វិញ្ញាបនបត្រលទ្ធភាពហោះហើរ វិញ្ញាបនបត្របញ្ជាក់សមត្ថភាពវិស្វករ និងជំនាញបច្ចេកទេសអាកាសយាន វិញ្ញាបនបត្រសំឡេង អាជ្ញាបណ្ណវិទ្យុ វិញ្ញាបនបត្រកិច្ចសន្យាជួលអាកាសយាន ស្ថានីយប្រេងអាកាសយាន អង្គភាពជួសជុលថែរក្សាអាកាសយាន និងកម្មវិធីថែទាំអាកាសយាន។
- ត្រួតពិនិត្យលទ្ធភាពហោះហើរចំពោះអាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។
- សហការស្រាវជ្រាវ និងវាយតម្លៃឧប្បត្តិហេតុ ឬ គ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយាននៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។

**២.ការពង្រឹងសន្តិសុខអាកាសចរស៊ីវិល៖** ការពង្រឹងសន្តិសុខអាកាសចរ មានគោលបំណង ផ្តល់ទំនុកចិត្តជាលក្ខណៈជាតិ និងអន្តរជាតិ ដោយត្រូវបានធានាតាមរយៈការអនុវត្តយ៉ាងហ្មត់ចត់នូវបទដ្ឋានជាតិ និងអន្តរជាតិទៅលើសន្តិសុខអាកាសចរស៊ីវិលសំដៅការការពារ ទប់ស្កាត់ រាល់អំពើរំលោភច្បាប់ ការបំផ្ទុះ អំពើភេរវកម្ម ការបំផ្លិចបំផ្លាញ ការគំរាមកំហែងដល់ជីវិតនិងទ្រព្យសម្បត្តិ។

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធីស្តង់ដា តម្រូវការសេចក្តីណែនាំ សៀវភៅណែនាំ និងលិខិតបទដ្ឋានគត្តិយុត្តនានាដែលទាក់ទងនឹងវិធានការសន្តិសុខ និងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- រៀបចំផែនការនិងធ្វើការហ្វឹកហ្វឺនដល់មន្ត្រីសន្តិសុខនិងសុវត្ថិភាពដោយសហការជាមួយក្រសួង ស្ថាប័ននិងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការទប់ស្កាត់នូវអំពើរំលោភបំពាន បំផ្លិចបំផ្លាញដល់វិស័យ អាកាសចរស៊ីវិល។
- អនុវត្ត និងគ្រប់គ្រងកម្មវិធីសុវត្ថិភាពរដ្ឋ និងកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល ដោយធ្វើការវិភាគ និងធ្វើរបាយការណ៍អំពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខរបស់ប្រតិបត្តិករ សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស និងអ្នកផ្តល់សេវាកម្មនានា។
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រអ្នកត្រួតពិនិត្យ អាកាសចរស៊ីវិល។

- ធ្វើអធិការកិច្ចលើ (១)អាកាសយាននិងឧទ្ធម្ភាគចក្រ (២)សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស និងប្រតិបត្តិករ (៣)អាកាសយានដ្ឋាន និង(៤)សេវាកម្មនាំផ្លូវអាកាស។

**៣. ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងការតភ្ជាប់ការហោះហើរ៖** ដើម្បីការបន្តកិច្ចខិតខំប្រឹងប្រែង ពង្រឹងនូវកិច្ចសហប្រតិបត្តិការវិស័យអាកាសចរស៊ីវិល និងផ្តល់ជាប្រយោជន៍នៅក្នុងការបង្កើត និងការធ្វើឲ្យមានភាពសុខដុមនីយកម្មរវាងគោលនយោបាយ និងផែនទីមគ្គុទេសក៏ក្នុងការអភិវឌ្ឍវិស័យអាកាសចរស៊ីវិលនៅក្នុងអនុតំបន់ តំបន់ និងពិភពលោកទាំងមូល ។

- សហប្រតិបត្តិការ និងសម្របសម្រួលរាល់ការងារជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិស្តីពីការកំណត់ស្តង់ដា និងអនុសាសន៍ដែលត្រូវយកទៅអនុវត្តកម្មវិធីសវនកម្មសន្តិសុខ និងសុវត្ថិភាព។
- សិក្សារៀបចំតាក់តែងសេចក្តីព្រាងបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានា សិក្សារៀបចំធ្វើវិសោធនកម្ម ការកែសម្រួលបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធវិស័យអាកាសចរស៊ីវិលជាតិ និងអន្តរជាតិ។
- រៀបចំ និងចងក្រងគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាសឲ្យស្របទៅតាមគោលបំណង និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- រៀបចំចរចា និងបង្កើតអនុស្សរណៈយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។
- ចូលរួមគ្រប់គ្រង និងចាត់ចែងលើការងារអាកាសចរណ៍ចាំបាច់មួយចំនួន ដូចជា សេរីភាវូបនីយកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាមួយសមាគមន៍អាស៊ាន និងអង្គការដទៃទៀតទាំងក្នុងកម្រិតតំបន់ និងអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម។
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រដឹកជញ្ជូនតាមផ្លូវអាកាស។
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស។
- រៀបចំ និងផ្តល់ការអនុញ្ញាតសេវាកម្មហោះហើរតាមកម្មវិធី និងក្រៅកម្មវិធី និងរៀបចំចងក្រងឯកសារស្ថិតិ និងទិន្នន័យស្តីពីអាកាសចរស៊ីវិលដោយសហការជាមួយនាយកដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។

**៤. ការពង្រឹងសេវាកម្មនាំផ្លូវអាកាស៖** ដើម្បីធានាឲ្យបាននូវការនាំផ្លូវហោះហើរនៃអាកាសយាន និងសេវាកម្មចរាចរដែនអាកាសប្រកបដោយសុវត្ថិភាពខ្ពស់ ធានាបាននូវទំនុកចិត្តក្នុងការផ្តល់សេវាកម្មតាមបទដ្ឋានអន្តរជាតិ ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នាំផ្លូវហោះហើរ។

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធីស្តង់ដា តម្រូវការសេចក្តីណែនាំ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងទៅនឹងស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស និងសេវាកម្មនាំផ្លូវអាកាសសម្រាប់អាកាសយាន ដែលធ្វើប្រតិបត្តិការហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា។
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រ ឬវិញ្ញាបនបត្រ បញ្ជាក់សមត្ថភាព ក្រុមបញ្ជាហោះហើរ វិស្វករ និងអ្នកជំនាញនាំផ្លូវអាកាស និងមន្ត្រីផ្តល់ព័ត៌មានអាកាសចរវិទ្យា។
- រៀបចំ និងបោះពុម្ពផ្សព្វផ្សាយ សៀវភៅស្តីពី ព័ត៌មានអាកាសចរវិទ្យា ដែលពាក់ព័ន្ធទៅនឹងលំហអាកាសកម្ពុជា និងលំហអាកាសដែលបានរក្សាទុកដល់កម្ពុជាក្រោមកិច្ចសហប្រតិបត្តិការនិងកិច្ចព្រមព្រៀងជាតិ និងអន្តរជាតិដោយមានការទទួលស្គាល់ ឬអនុញ្ញាតពីអង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងរលកសញ្ញាវិទ្យុអេឡិចត្រូនិច ដើម្បីជៀសវាងការរំខានដល់សេវាកម្មនាំផ្លូវអាកាស
- គ្រប់គ្រងចាត់ចែងប្រេកង់អាកាសចរណ៍ដោយទទួលសិទ្ធិពីអាជ្ញាធរទូរគមនាគមន៍ ស្របតាមការណែនាំរបស់សហភាពទូរគមនាគមន៍អន្តរជាតិ។
- ពិនិត្យរៀបចំកិច្ចសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការផ្តល់សេវាកម្មនាំផ្លូវអាកាស ដូចជាសេវាកម្មឧត្តុនិយម សេវាកម្មទូរគមនាគមន៍។ល។
- គ្រប់គ្រងចាត់ចែង និងផ្តល់សេវាកម្មនាំផ្លូវអាកាសនៅក្នុងការចេញ-ចូល និងឆ្លងកាត់ដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និង ស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- សហការលើការងាររុករក សង្គ្រោះ និងពន្លត់អគ្គីភ័យ។

**៥. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ-អន្តរជាតិ៖** ដើម្បីឆ្លើយតបបានយ៉ាង ល្អប្រសើរបំផុតចំពោះតម្រូវការនានារបស់អ្នកប្រើប្រាស់មានអ្នកដំណើរតាមផ្លូវអាកាស និង ការចុះចតអាកាសយានប្រកបដោយប្រសិទ្ធភាព។ អភិវឌ្ឍអាកាសយានដ្ឋានស៊ីវិល និងជំរុញឲ្យមានការអភិវឌ្ឍក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព ទំនុកចិត្ត និងមានលក្ខណៈសេដ្ឋកិច្ច។

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធីស្តង់ដា តម្រូវការសេចក្តីណែនាំ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងទៅនឹងស្តង់ដាសុវត្ថិភាពអាកាសយានដ្ឋាន ប្រព័ន្ធគ្រប់គ្រង សុវត្ថិភាពរបស់ប្រតិបត្តិការអាកាសយានដ្ឋាន ការផ្គត់ផ្គង់ទឹក ភ្លើងអគ្គិសនី និងកិច្ចការពារបរិស្ថាន ស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។

- ត្រួតពិនិត្យការអនុវត្ត និងស្តង់ដាសម្រាប់គម្រោងកសាងអាកាសយានដ្ឋានដែលមានស្រាប់ និងអាកាសយានដ្ឋានថ្មី សិក្សាទីតាំងកិច្ចដំណើរការ(រួមមានទាំងសម្ភារៈនិងបរិក្ខារ) ការងារ វិស្វកម្ម និងជួសជុលថែទាំ។
- សិក្សានិងវាយតម្លៃលើសំណើសុំអាជ្ញាប័ណ្ណសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី។
- សិក្សា និង វាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋាន។
- សិក្សានិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជីនិងប្រតិបត្តិអាកាសយានដ្ឋាន
- ផ្តល់យោបល់ និងណែនាំស្តីពីឧបសគ្គទាំងឡាយណាដែលរំខានទាំងនៅក្នុងនិងក្រៅអាកាសយានដ្ឋាននិងអនុវត្តឲ្យបានសមស្របតាមស្តង់ដា និងការណែនាំ ដូចមានចែងអំពីសញ្ញានិងភ្លើងរំខាន។

**៦. ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន៖** ដើម្បីធានាសុវត្ថិភាព សន្តិសុខឲ្យបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវការ។ មានមន្ត្រីមានសមត្ថភាព និងជំនាញអាកាសចរស៊ីវិលគ្រប់គ្រាន់ក្នុងការអនុវត្តការងារស្របតាមគោលការណ៍ណែនាំផ្សេងៗរបស់រដ្ឋាភិបាល ព្រមទាំងអាចលើកកម្ពស់ការងារគ្រប់គ្រងស្ថាប័ននិងជួយគាំទ្រដល់ការអនុវត្តការងារបច្ចេកទេស។

៤.១០០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាល ទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** នឹងបន្តការងារអាទិភាពរបស់ខ្លួន ក្នុងការគ្រប់គ្រងនិងជំរុញការអភិវឌ្ឍវិស័យអគ្គិសនី ដើម្បីឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ និងគ្រប់គ្រង និងជំរុញការអភិវឌ្ឍប្រសិទ្ធភាពថាមពលនិងសន្សំសំចៃថាមពល។ ក្រសួងក៏មានគោលដៅគ្រប់គ្រងនិងជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ ក្នុងគោលបំណងសន្តិភាព សុវត្ថិភាព និងមានសន្តិសុខ។ ដើម្បីសម្រេចបាននូវការប្តេជ្ញាខាងលើ ក្រសួងបានដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រមួយចំនួន ដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍវិស័យថាមពល និងថាមពលអគ្គិសនី ដោយបង្កើនការតភ្ជាប់អគ្គិសនីជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃសមរម្យដែលផលិតពីប្រភពផ្សេងៗ រួមទាំងវារីអគ្គិសនី ចំហេះ និងពន្លឺព្រះអាទិត្យ។
- ពង្រឹងការងារបច្ចេកទេសថាមពល និងស្តង់ដាអគ្គិសនីក្នុងអគារ និងលំនៅដ្ឋាន។
- ពង្រឹងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ។

## តារាងទី ៤.៩ សូចនាករសំខាន់ៗនៃវិស័យថាមពល

| ល.រ | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | | មូលដ្ឋាន | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ |
| ១ | ការផ្គត់ផ្គង់ថាមពលអគ្គិសនី | លាន គ.វ.ម. | ៩ ៣០៧ | ១០ ៨០៨ | ១២ ៩៦៩ | ១៥ ៣០៤ | ១៧ ៥៩៩ | ២០ ០៦៣ |
| ២ | ភាគរយនៃភូមិទទួលបានការផ្គត់ផ្គង់អគ្គិសនី | (%) | ៨៦,៨៥ | ៩៣,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ៣ | ការប្រើប្រាស់អគ្គិសនីរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គ.វ.ម./១ នាក់ | ៥៧៩ | ៦៦៤ | ៧៨៦ | ៩១៥ | ១ ០៣៧ | ១ ១៦៥ |
| ៤ | ភាគរយនៃខ្នងផ្ទះដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី | % | ៧២,១ | ៧៤,៦ | ៧៧,៤ | ៨៣,០៥ | ៨៧,៩ | ៩០,០ |
| ៥ | ភាគរយនៃប្រភពថាមពលអគ្គិសនីកកើតឡើងវិញ (អានុភាពតម្លើង) | % | ៥២,៦ | ៥១,១ | ៥២,១ | ៥៤,០៤ | ៥៥,២២ | ៤៨,២៣ |
| ៦ | ប្រវែងខ្សែបណ្តាញបញ្ជូនជាតិ១១៥/២៣០ គីឡូវ៉ុល | គ.ម. | ២ ១៤១ | ១ ៤៤១ | ២ ៤៤១ | ២ ៥៣៦ | ២ ៦១១ | ២ ៦១១ |
| ៧ | ប្រវែងខ្សែបណ្តាញបញ្ជូនជាតិ ៥០០គីឡូវ៉ុល | គ.ម. | ០ | ១៤០ | ១៤០ | ២៣០ | ២៣០ | ២៣០ |
| ៨ | រៀបចំច្បាប់ស្តីពីបរមាណូនៃព្រះរាជាណាចក្រកម្ពុជា | % | ២០ | ៤០ | ១០០ | | | |
| ៩ | រៀបចំបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព និងការការពារសុវត្ថិភាពនៃសារធាតុវិទ្យុសកម្ម និងបរមាណូ | ឯកសារ | - | ២ | ៥ | - | - | - |
| ១០ | គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល | % | - | ៤០ | ១០០ | | | |
| ១១ | អនុក្រឹត្យស្តីពីបទដ្ឋានបច្ចេកទេសអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រៀបចំបណ្តាញអគ្គិសនីក្នុងអាគារនិងលំនៅដ្ឋាន | % | ៦០ | ៨០ | ១០០ | | | |
| ១២ | មជ្ឈមណ្ឌលបាញ់កាំរស្មីវិទ្យុសកម្មសម្លាប់មេរោគ | % | - | - | ៣០ | ៥០ | ១០០ | |

៤.១០១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍*** នឹងបន្តការងារអាទិភាពរបស់ខ្លួនរួមឲ្យស្របតាមការវិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលសកម្មភាពជាអាទិភាព រួមមាន៖

- បន្តការរៀបចំក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត។
- បន្តរៀបចំវិស័យប្រៃសណីយ៍ឲ្យមានលក្ខណៈទំនើបស្របតាមស្តង់ដាអន្តរជាតិ ជាពិសេសការទទួលនិងចែកចាយបញ្ញើ ដើម្បីរុញច្រានវិស័យប្រៃសណីយ៍ឲ្យកាន់តែមានប្រសិទ្ធភាព និង វឌ្ឍនភាពក្នុងឆាកអន្តរជាតិ ដោយការចាប់ដៃគូពាណិជ្ជកម្មជាមួយក្រុមហ៊ុនក្នុងនិងក្រៅប្រទេស។
- បន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងទូរគមនាគមន៍ឲ្យបានដល់ទីជនបទដាច់ស្រយាល និងតំបន់មានសក្តានុពលខាងសេដ្ឋកិច្ចនិងទេសចរណ៍តាមរយៈ៖ ១. ការកសាងបណ្តាញ

ខ្សែកាប្លិ៍អុបទិកឲ្យបានដល់គ្រប់ខេត្តនិងស្រុកសំខាន់ៗបំពេញដល់វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ២. ការកសាងបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសចិននិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្របខ័ណ្ឌមហាអនុតំបន់មេគង្គ។

- បន្តផ្តោតការយកចិត្តទុកដាក់លើ ១. ការបណ្តុះបណ្តាលនិស្សិត និងមន្ត្រីរាជការលើជំនាញប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ២. ការស្រាវជ្រាវ និងនវានុវត្តន៍ ដោយផ្តោតលើសកម្មភាពសំខាន់ៗមាន៖
    - សហការជាមួយវិស័យឯកជននិងសកលវិទ្យាល័យដើម្បីពង្រឹងសមត្ថភាពបណ្តុះបណ្តាល។
    - អភិវឌ្ឍកម្មវិធីសិក្សាឲ្យកាន់តែល្អប្រសើរ។
    - ជំរុញការបណ្តុះបណ្តាលតាមប្រព័ន្ធសិក្សា e-learning។
    - លើកកម្ពស់អ្នកស្រាវជ្រាវនិងនវានុវត្តន៍ក្នុងនិងក្រៅប្រទេស។

## ៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១០២- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦នេះ គឺធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដែលមានលក្ខណៈ បរិយាប័ន្ន លើមូលដ្ឋានទូលំទូលាយ រឹងមាំ ធន់នឹងវិបត្តិ និង មានភាពប្រកួតប្រជែង។

៤.១០៣- កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ ក៏ប៉ុន្តែ មូលដ្ឋានទ្រទ្រង់កំណើននៅមិនទាន់ទូលាយ។ ចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចបច្ចុប្បន្ន ដែលរួមមាន កសិកម្ម ទេសចរណ៍ វាយនភ័ណ្ឌ និង សំណង់ មិនអាចធានាបាននូវកំណើនខ្ពស់ក្នុងរយៈពេលវែង ដោយសារការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក រចនាសម្ព័ន្ធប្រជាសាស្ត្រ ការប្រកួតប្រជែងខ្ពស់ និង ការងាយទទួលហានិភ័យពីខាងក្រៅ។ ក្នុងន័យនេះ ចាំបាច់ត្រូវគិតគូរលើការបង្កើតប្រភពកំណើនថ្មី តាមរយៈការជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចថ្មីៗ ការបង្កើត និង បង្កើនតម្លៃបន្ថែម ក្នុងចន្ទល់កំណើនដែលមានស្រាប់។

៤.១០៤- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៦ ផ្តោតអាទិភាពលើ៖

ទី១-ការបន្តជំរុញការអនុវត្ត ***"គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥"*** ពិសេស ជំរុញការអភិវឌ្ឍខេត្តព្រះសីហនុឲ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងទន្ទឹមនឹងការវាយតម្លៃពាក់កណ្តាលអាណត្តិ។

ទី២-ការរៀបចំ និង អនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍវិស័យកាត់ដេរ និង ផលិតស្បែកជើងដើម្បីបង្កើនភាពប្រកួតប្រជែង បង្កើតតម្លៃបន្ថែម បង្កើតឧស្សាហកម្មគាំទ្រ និង អភិវឌ្ឍខ្សែច្រវាក់តម្លៃ។

ទី៣-ការបន្តជំរុញកិច្ចដំណើរការ និង ទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកសាងមូលដ្ឋាន ឧស្សាហកម្ម រួមទាំងការកែច្នៃកសិផល ការផ្គុំ និង ដំឡើង ការផលិតគ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ក្នុងលំនៅឋាន ការផលិតវត្ថុអនុស្សាវរីយ៍បម្រើឲ្យវិស័យទេសចរណ៍ជាដើម។

ទី៤-ការរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ ដោយផ្តោតលើការធ្វើពិពិធកម្មផលិតផល និង គោលដៅទេសចរណ៍ ការទាក់ទាញភ្ញៀវចំណាយខ្ពស់និងការលើកទឹកចិត្តឧស្សាហកម្មគាំទ្រវិស័យទេសចរណ៍។

ទី៥-ការជំរុញការអភិវឌ្ឍវិស័យសេវាផ្នែកកំសាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល និង ភាពយន្ត ដែលជាឧស្សាហកម្មច្នៃប្រឌិតមានសក្តានុពលខ្ពស់ក្នុងការបង្កើតតម្លៃបន្ថែម និងបង្កើតការងារ ព្រមទាំងការលើកកម្ពស់ការផលិត និងការប្រើប្រាស់ផលិតផលក្នុងស្រុក ពិសេសផលិតផលមានលក្ខណៈប្រពៃណីខ្មែរ និងផលិតផលសម្គាល់ភូមិសាស្ត្រ។

ទី៦-ការជំរុញការអភិវឌ្ឍវិស័យប្រេងកាត និង ឧស្ម័ន ជាពិសេសការដាក់ដំណើរការអណ្តូងប្រេងដំបូងឲ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូល ដែលបានមកពីធនធានទាំងនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១០៥- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងបន្តការងាររបស់ខ្លួនដើម្បីជំរុញតាមដានការអនុវត្ត ***គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម(គ.អ.ឧ.ក.) ឆ្នាំ២០១៥-២០២៥*** តាមរយៈសកម្មភាពសំខាន់ៗមួយចំនួនដូចជា៖

- កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការរៀបចំផែនការ វាយតម្លៃ ការស្រាវជ្រាវ និងវិភាគដែលមានលក្ខណៈវិទ្យាសាស្ត្រ និងការផ្តល់អនុសាសន៍គោលនយោបាយ។
- សម្របសម្រួលជំរុញ និងតាមដានវឌ្ឍនភាពនៃការអនុវត្ត គ.អ.ឧ. របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។
- បន្តអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ដែលបានកំណត់នៅក្នុង គ.អ.ឧ. ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ ក.អ.ក. ពិសេសវិធានការគោលនយោបាយពាក់ព័ន្ធដែលស្ថិតនៅក្រោមយុទ្ធសាស្ត្រគន្លឹះ "**ការជំរុញការទាក់ទាញវិនិយោគ**" ។
- ប្រមូល វិភាគ សំយោគ និងរៀបចំចងក្រងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយតាមកាលកំណត់។
- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស និងកិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹងការជំរុញការអនុវត្ត គ.អ.ឧ.។

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគោលនយោបាយ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ។
- បន្តធ្វើបច្ចុប្បន្នភាពជំនួយស្មារតីពាក់ព័ន្ធនឹងប្រធានបទអាទិភាពទាំងបួន រួមមាន៖ ការជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស និងការជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក។
- បន្តរៀបចំឯកសារជំនួយស្មារតី និងឯកសារទស្សនទានពាក់ព័ន្ធនឹងបទពិសោធន៍ និងឧត្តមានុវត្តន៍ជាសកលនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម។
- សិក្សាស្រាវជ្រាវ និងចូលរួមក្នុងការរៀបចំបង្កើតផែនការមេ ឬឯកសារទស្សនទានពាក់ព័ន្ធនឹងការប្រែក្លាយខេត្តព្រះសីហនុឲ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង។
- បន្តសហការជាមួយដៃគូអភិវឌ្ឍដើម្បីសិក្សាស្រាវជ្រាវនិងកំណត់វិស័យវិនិយោគអាទិភាព និងកៀរគរធនធានគាំទ្រការអនុវត្ត គ.អ.ឧ.។
- សហការរៀបចំឯកសារយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការថែទាំការវិនិយោគ និងរៀបចំឯកសារទស្សនទានពាក់ព័ន្ធនឹងយុទ្ធសាស្ត្រជំរុញការអភិវឌ្ឍវិស័យកាត់ដេរ និងផលិតស្បែកជើង ដើម្បីបង្កើនតម្លៃបន្ថែម និងជំរុញការអភិវឌ្ឍចង្កោមឧស្សាហកម្មគាំទ្រ។
- សម្របសម្រួលការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្ត គ.អ.ឧ.ក. ។

៤.១០៦- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការបន្តជំរុញកិច្ចដំណើរការនិងទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកសាងមូលដ្ឋានឧស្សាហកម្ម ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលក្នុងការពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម។
- ជំរុញឲ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន/អ្នកអភិវឌ្ឍន៍តំបន់ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដើម្បីធានាឲ្យមានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់អ្នកវិនិយោគ។
- បន្តជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឲ្យឈានដល់កម្រិតស្តង់ដាអន្តរជាតិលើគ្រប់ទិដ្ឋភាព ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

- បន្តសហការអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេស តាមរយៈការផ្តល់អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងឡជីស្ទីក ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀត។
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករស្ទួលសម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត និងជំរុញឧត្តមានុវត្តន៍។
- ចូលរួម និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសនៅជុំវិញតំបន់សេដ្ឋកិច្ចពិសេស។
- បន្តរៀបចំកែសម្រួលរចនាសម្ព័ន្ធអភិបាល និង ពង្រឹងសមត្ថភាពមន្ត្រីនៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្តល់សេវាឲ្យកាន់តែមានប្រសិទ្ធភាពជូនអ្នកវិនិយោគ។
- ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។

៤.១០៧- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងឧស្សាហកម្ម និង សិប្បកម្ម*** នឹងបន្តការងារអាទិភាពរបស់ខ្លួន រួមទាំងសកម្មភាពសំខាន់ៗរួមមាន៖

- ធ្វើពិពិធកម្មឧស្សាហកម្ម និងការពង្រីកសមត្ថភាពផលិតកម្មឧស្សាហកម្ម ការបង្កើនផលិតភាពដោយផ្តល់អាទិភាពជាពិសេសដល់ការអនុវត្ត **"គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥"**។
- លើកគម្រោងផែនការសកម្មភាព សំដៅទាក់ទាញជំនួយគាំទ្របច្ចេកទេស និងថវិកា ពីកម្មវិធីភាពជាដៃគូសម្រាប់ប្រទេស ក្រោមការសម្របសម្រួលរបស់អង្គការយូនីដូ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍនានា។
- ជំរុញ និងលើកទឹកចិត្តដល់ការវិនិយោគ បង្កើតជាកម្រងឧស្សាហកម្ម សួនឧស្សាហកម្ម និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងការវិនិយោគទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្សារភ្ជាប់ទាំងផ្នែកទន់ និងផ្នែករឹង ដែលគាំទ្រដល់សកម្មភាពផលិតកម្មឧស្សាហកម្មគ្រប់ប្រភេទ។
- បន្តពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការគ្រប់គ្រងរោងចក្រ និងទាក់ទាញគ្រប់បណ្តារោងចក្រ សហគ្រាស ឲ្យមកចុះបញ្ជីសុំប្រកាសបង្កើតរោងចក្រ សុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលើកស្លាកឈ្មោះរោងចក្រ។

- បន្តការតាមដាន ត្រួតពិនិត្យ ប្រមូលគ្រប់គ្រង និងចងក្រងទិន្នន័យស្ថិតិ ឲ្យកាន់តែមានភាពប្រសើរឡើង ។
- ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ និងជំរុញកិច្ចការស្រាវជ្រាវនានា ព្រមទាំងលើកទឹកចិត្តដល់គំនិតច្នៃប្រឌិតថ្មីៗ ទាំងក្នុងអាជីវកម្ម សេវាកម្ម និងផលិតផល ដែលសមស្របក្នុងបរិការណ៍ជាតិ និងសម័យឌីជីថល ឬបដិវត្តន៍ឧស្សាហកម្មទី៤។
- រៀបចំសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសំណល់ឧស្សាហកម្ម។
- ពង្រឹងនីតិវិធី និងកិច្ចសហប្រតិបត្តិការជាមួយដៃគូទាំងក្នុង និងក្រៅប្រទេស ក្នុងកិច្ចការពង្រឹង និងសម្រួលដល់ការចុះបញ្ជី ការការពារ និងការផ្តល់ប្រកាសនីយបត្រតក្កកម្មផ្នែកកម្មសិទ្ធិបញ្ញា ក្នុងវិស័យឧស្សាហកម្ម។
- ពង្រឹងការអនុវត្តកិច្ចការស្តង់ដា និងមាត្រាសាស្ត្រជាតិ ក្នុងការការពារសុខមាលភាពសាធារណៈជន បង្កើនភាពប្រកួតប្រជែងក្នុងតំបន់និងសកលលោក ។
- ជំរុញកសាងសមត្ថភាពផ្តល់សេវាអភិវឌ្ឍធុរកិច្ច និងសមត្ថភាពស្ថាប័នគាំទ្រ ជាពិសេសវិទ្យាស្ថានស្តង់ដា មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មជ្ឈមណ្ឌលផលិតភាពជាតិ មន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីជំរុញការវិនិយោគ និងប្រសិទ្ធភាពនៃការផ្តល់សេវាកម្មជូនសាធារណជន។

### សហគ្រាសធុនតូច និងមធ្យម

- ពិនិត្យឡើងវិញនូវចំណុចយុទ្ធសាស្ត្រ ឬផែនការសកម្មភាព គាំទ្រវិស័យឯកជនលើការងារផលិតកម្ម ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងការពង្រីកទីផ្សារផលិតផលកម្ពុជា។
- ជំរុញ និងលើកទឹកចិត្ត ការអនុវត្តគំរូអាជីវកម្មប្រកបដោយបរិយាប័ន្ន ឬសកម្មភាពអាជីវកម្មលក្ខណៈបរិយាប័ន្ន និងការផ្តួចផ្តើមអាជីវកម្មបែបសហគ្រាសសង្គម ដើម្បីបង្កើតជាជវភាពថ្មីមួយសម្រាប់ជាដំណោះស្រាយមានលក្ខណៈជាប្រព័ន្ធក្នុងការពន្លឿនធុរកិច្ចបែបនវានុវត្តន៍របស់វិស័យឯកជន ដែលអាចជួយផ្តល់ជាដំណោះស្រាយចំពោះបញ្ហានានាជូនប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលមានចំណូលទាបនៅកម្ពុជា។
- អនុវត្តវេទិកាជំនួបទូលំទូលាយដែលមានចរឹកអន្តរវិស័យ ផ្សារភ្ជាប់ទំនាក់ទំនងគ្នាជាប្រព័ន្ធរវាងអ្នកផលិត អ្នកផ្គត់ផ្គង់ និងអ្នកជួយរកទីផ្សារ ដោយចាំបាច់ទាមទារការចូលរួម និងកិច្ចសហការគ្នាជិតស្និទ្ធជាមួយក្រសួង ស្ថាប័នរដ្ឋ និងផ្នែកឯកជនដែលពាក់ព័ន្ធ ដូចជាសភាពាណិជ្ជកម្ម សភាមុខរបរ សមាគម ឬសហភាពសម្ព័ន្ធ សហគ្រាសនានា។
- បន្តជំរុញបង្កើត **មជ្ឈមណ្ឌលផ្តល់ប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច** និងសហការជាមួយបណ្តាស្ថាប័ន ផ្តល់សេវាប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច ឯកជននានា។

- បង្កើតបរិយាកាសធុរកិច្ច សំដៅការបង្កើនការចុះបញ្ជី ការអនុញ្ញាត ការបង្កើតរោងចក្រ សហគ្រាសកម្មន្តសាលធុនតូច មធ្យម និងសិប្បកម្ម ព្រមទាំងសេវាច្រកចេញចូលតែមួយឲ្យកាន់តែប្រសើរឡើង។
- លើកកម្ពស់សមត្ថភាពសិប្បកម្មកែច្នៃផលិតផលក្នុងស្រុក និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងអាជីវកម្ម ពិសេសប្រភេទអាជីវកម្មបែបច្នៃប្រឌិត និងផ្តល់អត្ថប្រយោជន៍ជូនសង្គម ដូចជាប្រភេទអាជីវកម្មបែបសហគ្រាសសង្គមរួមចំណែកបង្កើតការងារក្នុងស្រុក។
- ជំរុញការកសាងគោលនយោបាយ គ្រប់គ្រង និងអភិវឌ្ឍស្រែអំបិល។
- រៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពចំណីអាហារ និងជំរុញភាពអនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិ។
- ជំរុញ និងលើកកម្ពស់សកម្មភាពសិប្បកម្មកែច្នៃវត្ថុធាតុដើមពីធម្មជាតិក្នុងស្រុក ដូចជា វល្លិ៍ផ្តៅ ឬស្សី កំប្លោក។
- បន្តជំរុញការគ្រប់គ្រងទិន្នន័យស្ថិតិសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៅទូទាំងប្រទេសជាមូលដ្ឋាន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីជំរុញ និងគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។
- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការជំរុញអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម និងសិប្បកម្ម។
- ជំរុញ គាំទ្រ និងលើកកម្ពស់សកម្មភាពចលនាភូមិមួយផលិតផលមួយ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបញ្ជីហិរញ្ញវត្ថុ និងការគ្រប់គ្រងសហគ្រាស សិប្បកម្ម ដោយសហការជាមួយដៃគូអភិវឌ្ឍ។
- បង្កើនសកម្មភាពផ្សព្វផ្សាយ និងរៀបចំកម្មវិធីប្រកួតប្រជែង កម្មវិធីតាំងពិព័រណ៍ផលិតផល ទាំងក្នុង និងក្រៅប្រទេស សំដៅលើកកម្ពស់ផលិតផលក្នុងស្រុក។
- ជំរុញការដាក់បញ្ចូលជាផ្លូវការ គោលនយោបាយអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងផែនការអនុវត្ត៥ឆ្នាំ និង អនុវត្តសកម្មភាពនានាដែលមានចែងក្នុងគោលនយោបាយនេះ ដែលផ្តោតលើចំណុចអាទិភាពរួមមាន៖ ជំរុញបរិយាកាសផ្នែកច្បាប់ និងបទដ្ឋានគតិយុត្ត ក៏ដូចជាសមត្ថភាពស្ថាប័នសាធារណៈ ការអភិវឌ្ឍសមត្ថភាពសហគ្រិន និងធនធានមនុស្ស ជំរុញពាណិជ្ជកម្មក្នុងស្រុក ផលិតភាព គុណភាព បច្ចេកវិទ្យា និងនុវានុវត្តន៍ពង្រីកការផ្សារភ្ជាប់ទៅកាន់ទីផ្សារបរទេស និងអន្តរជាតិ។

៤.១០៨- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងទេសចរណ៍*** នឹងបន្តអនុវត្តគោលនយោបាយអាទិភាពរបស់ខ្លួនសំខាន់ៗរួមមាន៖

- អភិវឌ្ឍផលិតផលនិងការវិនិយោគទេសចរណ៍៖ ១. រៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍និងសកម្មភាពអាទិភាព ២. ធ្វើពិពិធកម្មផលិតផលទេសចរណ៍ថ្មីៗ

បន្ថែមទៀតដោយមិនពឹងផ្អែកតែលើតំបន់អង្គរ ៣. ជំរុញការទាក់ទាញ និងវិនិយោគលើវិស័យទេសចរណ៍ ៤. ពិនិត្យ វាយតម្លៃ និងជំរុញក្រុមហ៊ុនវិនិយោគទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល និង ៥. ជំរុញការរៀបចំតំបន់ទេសចរណ៍ពិសិដ្ឋ។

- សិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍៖ ១. ជំរុញការផ្សព្វផ្សាយ "**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈប្រកបដោយភាពកក់ក្តៅ**" ២. ជំរុញការសិក្សាទីផ្សារ និងពង្រីកការផ្សព្វផ្សាយទេសចរណ៍ទៅគោលដៅទីផ្សារអាទិភាពផងទៃទៀត ៣. ជំរុញ និងពង្រីកការផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេសបន្ថែមទៀត តាមរយៈក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា និងស្ថានតំណាងនៅក្រៅប្រទេស និង ៤. ជំរុញការសិក្សាស្រាវជ្រាវ ធ្វើអង្កេតទីផ្សារ និងរៀបចំចងក្រងស្ថិតិទេសចរណ៍។
- ពង្រឹង និងលើកកម្ពស់គុណភាពផលិតផល និងសេវាកម្មទេសចរណ៍៖ ១. ការពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ ២. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបង្កើត និងដាក់ឲ្យប្រើប្រាស់នូវស្តង់ដាសេវាកម្មសាធារណៈ ៣. អនុវត្តស្តង់ដាទេសចរណ៍ថ្នាក់ជាតិ ៤. ជំរុញចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**" "**កម្ពុជាស្អាត**" និង ៥. ពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍តាមទស្សនទាន "**សេវាមួយ ស្តង់ដាមួយ**"។
- ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍៖ ១. បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈទេសចរណ៍ ២. បញ្ជូនមន្ត្រីទៅធ្វើកម្មសិក្សា ដកស្រង់បទពិសោធន៍ និងសិក្សានៅក្រៅប្រទេស។
- សម្របសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍៖ ១. ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធវិស័យទេសចរណ៍របស់ក្រសួងស្ថាប័នពាក់ព័ន្ធ ២. ជំរុញលើកទឹកចិត្ត និង សម្រួលការធ្វើដំណើរទេសចរណ៍ ៣. សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការកាត់បន្ថយរបាំង និងការងារពុំចាំបាច់តាមច្រកទ្វារ និងច្រកទ្វារព្រំដែនអន្តរជាតិ។
- ពង្រឹងសមត្ថភាពវិស័យឯកជន និងភាពជាដៃគូរដ្ឋ-ឯកជន៖ ១. ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ក្នុងបរិបទអនុតំបន់ និងពិភពលោក ២. ជំរុញឲ្យមានការចូលរួមសកម្មពីផ្នែកឯកជន ៣. ជំរុញភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- អភិបាលកិច្ចល្អក្នុងវិស័យទេសចរណ៍៖ ១. អភិវឌ្ឍសមត្ថភាព កែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សជាពិសេសសមត្ថភាពគ្រប់គ្រង និងចាត់ចែងការងារឲ្យស្របតាមតម្រូវការអង្គភាព ២. ពង្រឹងគុណភាពធនធានមនុស្សក្នុងឧស្សាហកម្មទេសចរណ៍តាមទស្សនទាន "**បុគ្គលិកម្នាក់ ជំនាញមួយ**" ៣. ជំរុញការធ្វើវិមជ្ឈការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ពង្រឹង សន្តិសុខ សុវត្ថិភាពភ្ញៀវទេសចរណ៍៖ ១. លើកកម្ពស់តួនាទីស្ត្រី សុវត្ថិភាពកុមារជនពិការ ២. ទប់ស្កាត់ការរីករាលដាលនិងការឆ្លងជំងឺអេដស៍ក្នុងវិស័យទេសចរណ៍ ៣. ការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងវិស័យទេសចរណ៍។

៤.១០៩- ***ក្រសួងទេសចរណ៍*** ចាំបាច់ត្រូវបញ្ចូលនូវមូលដ្ឋានគ្រឹះសំខាន់ៗចំនួន៥ **បន្ថែមទៀត** ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ដែលក្នុងនោះរួមមាន ៖

- អភិរក្ស ការពារ កែលម្អ និងអភិវឌ្ឍប្រកបដោយចីរភាព និងសមស្របនូវទីកន្លែង ដែលមានសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិដែលជាគោលដៅទេសចរណ៍ ប្រកបដោយសក្តានុពលរបស់ជាតិ។
- គោរពនូវតម្លៃរបស់ប្រជាពលរដ្ឋមូលដ្ឋាន តាមសហគមន៍នីមួយៗ និងជំរុញឲ្យមានការចែករំលែកបទពិសោធន៍ល្អៗប្រកបដោយគុណភាពខ្ពស់ដល់ភ្ញៀវទេសចរណ៍ និងប្រជាជនមូលដ្ឋាន ព្រមទាំងផ្តល់នូវសេវាប្រកបដោយគុណភាព។
- ជំរុញឲ្យភាគីពាក់ព័ន្ធទទួលផលប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច ពីវិស័យទេសចរណ៍ ប្រកបដោយសមធម៌ កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍មកលើ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។
- ថែរក្សានូវគុណតម្លៃនៃសម្បត្តិមរតក និងធនធានទាំងអស់ ដើម្បីទ្រទ្រង់ដល់សកម្មភាពទេសចរណ៍យូរអង្វែង និងចីរភាពសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។
- ជំរុញឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងរដ្ឋ ឯកជន ប្រជាជន ដៃគូអភិវឌ្ឍក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព ចីរភាព និងការទទួលខុសត្រូវខ្ពស់។

៤.១១០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*** នឹងបន្តអនុវត្តគោលនយោបាយអាទិភាពរបស់ខ្លួនសំខាន់ៗរួមមាន ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។

៤.១១១- ការអភិរក្សមរតកវប្បធម៌ជាតិ គឺជាការងារដែលត្រូវចាត់ទុកជាកាតព្វកិច្ចចម្បង ដែល ***ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ***ត្រូវខិតខំពុះពារបំពេញឲ្យសម្រេចបាន។ ទន្ទឹមនេះវប្បធម៌ក៏ត្រូវមានវឌ្ឍនភាពនិងរីកដុះដាលទៅមុខផងដែរ។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជានឹងដាក់បញ្ចូលនូវគោលនយោបាយដែលជួយបង្កលក្ខខណ្ឌសមប្រកបដែលជាឱកាសក្នុង "***ការអភិវឌ្ឍវប្បធម៌ជាតិ***" តាមរយៈនយោបាយលើកទឹកចិត្តដល់គំនិតច្នៃប្រឌិតបង្កើតថ្មីក្នុងវិស័យសិល្បៈវប្បធម៌ ព្រមទាំងពង្រីកឲ្យបានទូលំទូលាយនូវឧស្សាហកម្មវប្បធម៌ផងដែរ។ ការអភិរក្សនិងអភិវឌ្ឍវប្បធម៌បានល្អប្រសើរ គឺជាការលើកកម្ពស់ សីលធម៌ គុណធម៌ និងកិត្យានុភាពជាតិ។ កំណើនសេដ្ឋកិច្ចជាកាលានុវត្តភាពនៃការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិឲ្យកាន់តែមានភាពរីកចម្រើននិងមានប្រសិទ្ធភាពខ្ពស់ស្របតាមទិសស្លោក "***អភិរក្សដើម្បីអភិវឌ្ឍ***" និង"***អភិវឌ្ឍលើមូលដ្ឋានអភិរក្ស***" ប្រកបដោយចីរភាព ដែលជា "***វដ្ត***" មួយនៃវឌ្ឍនភាពវប្បធម៌និងកំណើនសេដ្ឋកិច្ចស្របតាមគោលដៅយុទ្ធសាស្ត្រគឺ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

### ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបីនិងអរូបី៖

- ធ្វើបច្ចុប្បន្នកម្មបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ជាតិ ដោយបង្កើតឲ្យមាននូវ "ប្រព័ន្ធទិន្នន័យមូលដ្ឋាន" ជាតិមួយ ដែលងាយស្រួលក្នុងការកំណត់ហានិភ័យបេតិកភណ្ឌវប្បធម៌ជាប្រចាំ។
- រៀបចំបទដ្ឋានគតិយុត្ត និងផែនការការងារដែលឆ្លើយតបនឹងស្ថានភាពជាក់ស្តែងក្នុងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។
- រៀបចំវិធានថែទាំ និង ជួសជុលសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ។
- ពង្រឹងយន្តការទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរ ដែលត្រូវបានលួចនិងកាន់កាប់ដោយខុសច្បាប់ទាំងនៅក្នុងនិងក្រៅប្រទេស។
- លើកកម្ពស់ការយល់ដឹង និងបង្កឲ្យមានការចូលរួមពីសាធារណជនក្នុងការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ។
- ជំរុញការអភិរក្សបេតិកភណ្ឌក្នុងសហគមន៍។
- ពង្រឹង និងពង្រីកការអភិវឌ្ឍចំណេះដឹងនិងជំនាញវិជ្ជាជីវៈលើវិស័យវប្បធម៌។
- ថែរក្សា និងជំរុញឲ្យកាន់តែខ្លាំងចំពោះការផ្ទេរចំណេះដឹងប្រពៃណី។
- បង្កើនការយល់ដឹងការយកចិត្តទុកដាក់ និងការចូលរួមពីមហាជន ពិសេសយុវជននិងកុមារដោយធ្វើការបណ្តុះបណ្តាលដោយឈរលើគោលការណ៍ "អប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីអប់រំ"។
- ថែរក្សា និងលើកកម្ពស់ការការពារវប្បធម៌ជនជាតិដើមភាគតិច។
- បង្កលក្ខណៈឲ្យស្ត្រី កុមារនិងជនពិការចូលរួមកាន់តែច្រើនក្នុងវិស័យវប្បធម៌។

**ការលើកតម្លៃវប្បធម៌ជាតិ៖**

- ពង្រឹង និងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវប្បធម៌ជាតិ ឲ្យកាន់តែទូលំទូលាយតាមរយៈការសម្តែង មហោស្រព ការតាំងពិព័រណ៍។
- ពង្រឹង និងពង្រីកតួនាទីរបស់សារមន្ទីរ និងមណ្ឌលវប្បធម៌។
- ស្រាវជ្រាវ និងផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ជាតិ។
- រៀបចំចងក្រងឯកសារបេតិកភណ្ឌប្រណិត និងមានតម្លៃលេចធ្លោរបស់កម្ពុជាដើម្បីដាក់បញ្ចូលក្នុងបញ្ជីរបស់អង្គការយូណេស្កូ។

**ការអភិវឌ្ឍវប្បធម៌៖**

- រៀបចំបទដ្ឋានគតិយុត្ត និងយន្តការអនុវត្តសម្រាប់ជួយទ្រទ្រង់ដល់សិល្បករផលិតករ អង្គការ សមាគម និងសហគ្រិនដែលប្រកបអាជីពក្នុងវិស័យវប្បធម៌។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញដល់ការបង្កើតទីផ្សារផលិតផលវប្បធម៌និងទីផ្សារការងារក្នុងវិស័យវប្បធម៌ និងសិល្បៈ។
- ពង្រីកទីផ្សារផលិតផលនិងសេវាកម្មវប្បធម៌ ដោយផ្តល់ឱកាសឲ្យបានទូលំទូលាយជូនដល់សិល្បករ ផលិតករ និងអ្នកប្រកបអាជីពក្នុងវិស័យវប្បធម៌ និង សិល្បៈ។

- បង្កលក្ខណៈលើកទឹកចិត្តនិងជំរុញដល់ការច្នៃប្រឌិតបង្កើតថ្មីស្នាដៃដើម ហើយថ្មីក្នុងផ្នែក តន្ត្រី សោតទស្សន៍ ភាពយន្ត សិល្បៈទស្សនីយភាព សិប្បកម្ម វិចិត្រកម្ម តម្បាញ ប្រពៃណី និងការរចនាច្នៃម៉ូដ។
- ជំរុញការរៀបចំពិព័រណ៍ស្នាដៃច្នៃប្រឌិតបង្កើតថ្មីក្នុងវិស័យសិល្បៈវប្បធម៌និងឧស្សាហកម្ម។
- លើកកម្ពស់វិស័យភាពយន្តនៅកម្ពុជាដោយ ៖
  - អភិវឌ្ឍធនធានមនុស្សក្នុងវិស័យភាពយន្ត។
  - បង្កើនការផ្សព្វផ្សាយគ្រប់រូបភាព ដើម្បីទាក់ទាញក្រុមហ៊ុនបរទេសមកថតភាពយន្ត នៅកម្ពុជា ប្រែក្លាយជាដែនដីស្វាគមន៍នៃការថតភាពយន្តបរទេស។
  - បង្កើនយន្តការសម្របសម្រួលក្នុងការស្នើសុំថតភាពយន្តតាមច្រកចេញចូលតែមួយ។
  - បន្តនយោបាយ "ម៉ោងមាស" សម្រាប់ភាពយន្តក្នុងស្រុក។
  - ប្រែក្លាយរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ ទៅជាគោលដៅនៃការទាក់ទាញក្នុងការ ថតភាពយន្ត ការសម្តែងសិល្បៈនិងការវិនិយោគក្នុងវិស័យទេសចរណ៍។
- ជំរុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌
  - បង្កើតប្រព័ន្ធទិន្នន័យស្តីពីអង្គការ សមាគម និងសហគ្រាសវប្បធម៌។
  - ធ្វើអត្តសញ្ញាណកម្មវប្បធម៌ និងភូមិមួយផលិតផលមួយ។
- រៀបចំយន្តការសម្រួលការនាំចូលសម្ភារបច្ចេកវិទ្យាស្តង់ដានិងស្របច្បាប់ជូនដល់សហ គ្រិនប្រកបមុខរបរលើវិស័យវប្បធម៌។

៤.១១២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** មានបេសកកម្មយ៉ាងធំធេងក្នុងការអភិវឌ្ឍវិស័យប្រេងកាតឲ្យអស់លទ្ធភាព តាមរយៈការស្វែងរុករក អភិវឌ្ឍផលិតកម្ម ប្រព្រឹត្តកម្ម ដឹកជញ្ជូន សន្និធិ និងការធ្វើពាណិជ្ជកម្ម ប្រេងនិងឧស្ម័ន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងនៃប្រទេសជាតិ និងភាពល្អប្រសើរនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

៤.១១៣- ដើម្បីសម្រេចបាននូវបេសកកម្មខាងលើ ***ក្រសួងរ៉ែនិងថាមពល*** នឹងរៀបចំ***គោលនយោបាយជាតិប្រេងកាត ឆ្នាំ២០២០-២០៣០*** និងដាក់ចេញផែនការសកម្មភាពសម្រាប់អនុវត្តឲ្យបានចប់សព្វគ្រប់នៅឆ្នាំ២០២០។ សកម្មភាពជាអាទិភាព រួមមានដូចខាងក្រោម៖

- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។
- កសាងសមត្ថភាព និងពង្រឹងស្ថាប័ន ទាំងផ្នែកអាប់ស្ទ្រីម និងដោនស្ទ្រីម
- បង្កើនចំណូលពីវិស័យប្រេងកាត។
- ជំរុញភាពទទួលខុសត្រូវសង្គម និងបរិស្ថានក្នុងប្រតិបត្តិការប្រេងកាត និងសន្តិសុខថាមពល។

៤.១១៤- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- អភិវឌ្ឍន៍ការធ្វើពិពិធកម្មផលិតផល៖ ១. សិក្សា និងចងក្រងអត្តសញ្ញាណផលិតផលសក្តានុពលកម្ពុជា ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងពង្រីកការនាំចេញផលិតផលទាំងនោះទៅទីផ្សារអន្តរជាតិ ២. បន្តការងារបង្កើតនិងគ្រប់គ្រងមជ្ឈមណ្ឌលអចិន្ត្រៃយ៍ផលិតផលកម្ពុជា និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មនៅក្នុងនិងក្រៅប្រទេស ៣. សហការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រៅប្រទេសដើម្បីជំរុញផលិតផលកម្ពុជាទៅក្នុងទីផ្សារតំបន់និងពិភពលោក។
- អភិវឌ្ឍការធ្វើពិពិធកម្មទីផ្សារនាំចេញ៖ ១. រៀបចំគោលនយោបាយជំរុញការនាំចេញ ២. រៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ៣. ពង្រឹងនិងពង្រីកការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស និងអន្តរជាតិ ៤. បន្តស្រាវជ្រាវ តាមដាន និងវិភាគការវិវឌ្ឍសេដ្ឋកិច្ចពាណិជ្ជកម្ម របាំងពាណិជ្ជកម្ម និងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ប្រទេសត្រូវធ្វើពាណិជ្ជកម្ម ៥. ធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មលើគ្រប់ប្រតិបត្តិការនៃដំណើរការនាំចេញ ៦. ពង្រឹងនិងពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី។

## ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១១៥- បដិវត្តន៍ឧស្សាហកម្មសកល បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវស្ថានភាពសង្គម-សេដ្ឋកិច្ចសកល ដោយសារនវានុវត្តន៍បច្ចេកវិទ្យា ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូរថ្មីមួយទៀត គឺបដិវត្តន៍ឧស្សាហកម្មទី៤។ ការណ៍នេះ តម្រូវឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការរៀបចំខ្លួនចាប់យកកាលានុវត្តភាព និងការត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈមដែលកើតចេញពីវិស័យសេដ្ឋកិច្ចថ្មីៗ ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ការលើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពវិស័យកសិកម្ម ការធ្វើឲ្យប្រសើរនូវប្រព័ន្ធសុខាភិបាល ការបង្កើនសមត្ថភាពរៀបចំខ្លួនសម្រាប់ទប់ទល់នឹងគ្រោះមហន្តរាយ ព្រមទាំងការរៀបចំនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និង ការគ្រប់គ្រងបរិស្ថានជាដើម។ លើសពីនេះ រាជរដ្ឋាភិបាលត្រូវគ្រប់គ្រងផល

វិបាកបណ្តាលមកពីបដិវត្តន៍ឧស្សាហកម្ម ដូចជា ការប្រែប្រួលនូវរបៀបរបបនៃការ ធ្វើធុរកិច្ច និង ការបាត់បង់ការងារ អស្ថិរភាពនយោបាយ និងសង្គម និងការវាយប្រហារផ្នែកបច្ចេកវិទ្យាព័ត៌មាន។

៤.១១៦- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នឹងផ្តោតអាទិភាពលើ៖

ទី១-ការរៀបចំ និង អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និង ដាក់វិស័យ ឌីជីថល ជាអនុវិស័យនៅក្នុងប្រព័ន្ធគណនីជាតិ។

ទី២-ការបន្តធ្វើបច្ចុប្បន្នភាព និង អនុវត្តគោលនយោបាយអភិវឌ្ឍវិស័យ ទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន, ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ព្រមទាំងច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិ ពាក់ព័ន្ធនានា ការរៀបចំ និង អនុវត្ត ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

ទី៣-ការបន្តពង្រឹង និង ពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់រួមមាន ហេដ្ឋារចនា សម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និង ដឹក ជញ្ជូនបញ្ញើរហ័សក្នុងស្រុកព្រមទាំងឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធទូទាត់ការសងប្រាក់ អេឡិកត្រូនិក ព្រមទាំងពិនិត្យលទ្ធភាពកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូល ប្រព័ន្ធ អ៊ីនធឺណិតថ្នាក់ជាតិ។

ទី៤-ការជំរុញ និងការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់ការអភិវឌ្ឍវិស័យឌីជីថល ដោយរួម ទាំងការជំរុញការអនុវត្តយុទ្ធសាស្ត្ររដ្ឋាភិបាលឌីជីថល និង សន្តិសុខព័ត៌មាន ច្បាប់ស្តី ពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ព្រមទាំង វិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលគាំទ្រ និង ជំរុញការរីកចម្រើន និងការ ការពារហានិភ័យក្នុងវិស័យនេះ។

ទី៥-ការអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេក វិទ្យាឌីជីថលឲ្យបានទូលាយ និង បញ្ចូលការប្រើប្រាស់ និង ការយល់ដឹងពីបច្ចេកវិទ្យាឌី ជីថលទៅក្នុងកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ រួមទាំងការបង្កើតយន្តការ ភាពជាដៃគូរវាងធុរកិច្ច និងគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បី បង្កើតកម្មវិធីអភិវឌ្ឍ និងបណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ។

ទី៦-ការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផល ដល់ការបង្កើតធុរកិច្ចថ្មីៗ ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរកិច្ច និងការបង្កើត យន្តការសហប្រតិបត្តិការសហគ្រិនភាពក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល ឬភាពជាដៃគូជា មួយវិស័យឯកជន។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១១៧- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា*** នឹងបន្តការងាររបស់ខ្លួនដែលមានសកម្មភាពសំខាន់ៗរួមមាន៖

ទី១-***កសាង និងពង្រឹងធនធានមនុស្សឲ្យបានគ្រប់គ្រាន់*** ទាំងបរិមាណ គុណភាព និងសមាសភាព ដោយពិនិត្យពិចារណាទៅលើកត្តាសមភាពយេនឌ័រ និងបរិយាប័ន្ន ផ្តល់លទ្ធភាពឲ្យបំពេញភារកិច្ច និងមានការលើកទឹកចិត្តសមស្រប ដើម្បីឲ្យបានធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍(វ.ប.ន.) ពេញសមត្ថភាពសម្រាប់បរិការណ៍បច្ចេកទេស និងផែនការយុទ្ធសាស្ត្រជាតិ។ វិធានការ ចាំបាច់ត្រូវអនុវត្តមានដូចខាងក្រោម ៖

- កំណត់អាទិភាពការអភិវឌ្ឍធនធានមនុស្សវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយអាស្រ័យលើប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ មានការគាំទ្រពីសង្គមជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមូលដ្ឋាន។ ជាមួយគ្នានេះ ធ្វើការលើកទឹកចិត្តអ្នកវិទ្យាសាស្ត្រដែលមានស្នាដៃល្អ និងទាក់ទាញអ្នកមានទេពកោសល្យចាំបាច់ពីបរទេស ដែលជាកិច្ចការកសាងធនធានមនុស្សដ៏មានប្រសិទ្ធភាព។ រហូតដល់ឆ្នាំ ២០២៣ រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនរួមគ្នាកសាងធនធានមនុស្ស វ.ប.ន. ឲ្យបានចំនួនអ្នកស្រាវជ្រាវប្រមាណ៦៦៤នាក់ ក្នុងប្រជាជន១លាននាក់ ជាមួយនឹងចំនួនសមមូលនៃរយៈពេលធ្វើការពេញម៉ោងប្រមាណ៣៧៧ ក្នុងប្រជាជន១លាននាក់។
- កសាងសមាសភាពធនធានមនុស្ស វ.ប.ន. ចាំបាច់នៅគ្រប់កម្រិត និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។

ទី២- ***ផ្តល់លទ្ធភាពឲ្យដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ និងកសាងប្រព័ន្ធអេកូនវានុវត្តន៍បរិយាប័ន្ន*** ដែលផ្តោតលើសមត្ថភាពធ្វើការសម្រប និងមូលដ្ឋាននីយកម្មបច្ចេកវិទ្យាដែលបាននាំចូល។ លើកស្ទួយឧស្សាហកម្មជាអាទិភាពជាតិដើម្បីបម្រើឲ្យការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ និង ការអភិវឌ្ឍប្រសើរជាង។ ជាមួយគ្នានោះ បង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាអន្តរជាតិ ដើម្បីបានជាកម្លាំងសន្ទុះឲ្យចាកផុតពីស្ថានភាពប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និង ប្រទេសអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ដើម្បីសម្រេចភារកិច្ចនេះ វិធានការចាំបាច់ត្រូវមានដូចខាងក្រោម ៖

- ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍ ដោយផ្តោតលើការស្រាវជ្រាវអភិវឌ្ឍបែបបង្កើតដោយពិសោធន៍ សម្រាប់បច្ចេកវិទ្យាជាអាទិភាពជាតិដើម្បីផ្ទេរនិងសម្របបច្ចេកវិទ្យាដែលទទួលបានពីបរទេសដោយផ្អែកលើយុទ្ធសាស្ត្រ ទិញខ្លះនិងបង្កើតខ្លះ ហើយផ្ទេរបន្ទុកនេះទៅវិស័យឯកជនតាមដំណាក់កាលនីមួយៗ។

- បង្កើត អនុវត្ត និងគ្រប់គ្រង ១. មូលនិធិការស្រាវជ្រាវនិងអភិវឌ្ឍអាណត្តិនៃបណ្តាក្រសួង ស្ថាប័ន ២. មូលនិធិលទ្ធកម្មបច្ចេកវិទ្យាសម្រាប់ក្រសួង ស្ថាប័នដែលមិនធ្វើការស្រាវជ្រាវផ្ទាល់ និង ៣. មូលនិធិជាតិការស្រាវជ្រាវនិងអភិវឌ្ឍប្រកួតប្រជែងដើម្បីគាំទ្រដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍជាអាទិភាពជាតិដែលបានកំណត់នៅក្នុងរបៀបវារៈ វ.ប.ន. ជាតិ ដើម្បីស្តេរភាពនៃថវិកាសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍសំខាន់ៗ ដែលជាគោលការណ៍គ្រឹះចម្បងមួយនៃការអភិវឌ្ឍ វ.ប.ន.។

ទី៣- ***ពង្រឹងស្ថាប័ន ក្របខ័ណ្ឌគតិយុត្ត និងប្រព័ន្ធគាំទ្រហិរញ្ញវត្ថុ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*** ដើម្បីផ្តល់លទ្ធភាពឲ្យប្រព័ន្ធអេកូវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាតិដែលអាចរួមគ្នាអនុវត្តការកសាងធនធានមនុស្ស និងអនុវត្តកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ ព្រមទាំងការធ្វើពាណិជ្ជូបនីយកម្មលទ្ធផលនៃការស្រាវជ្រាវនោះ ដើម្បីអភិវឌ្ឍវិស័យឯកជននិងរដ្ឋឲ្យបានប្រកបដោយថាមភាព និងទីផ្សារប្រកបដោយសក្តានុពល ព្រមជាមួយនឹងកិច្ចសហការអន្តរជាតិបានល្អប្រសើរ។ ដើម្បីសម្រេចភារកិច្ចនេះ វិធានការចាំបាច់ត្រូវអនុវត្ត ដូចខាងក្រោម ៖

- រៀបចំនិងពង្រឹង ក្រសួង ស្ថាប័ន ដើម្បីទទួលបន្ទុកវ.ប.ន. និង ការស្រាវជ្រាវ និងនវានុវត្តន៍។
- ពង្រឹងសេវាសាធារណៈដែលជាចំណែកសំខាន់របស់ប្រព័ន្ធអេកូនវានុវត្តន៍ ដូចជា ប្រកាសនីយបត្រតក្កកម្ម និងស្តង់ដាជាតិសម្រាប់វិញ្ញាបនកម្ម និងការទទួលស្គាល់សម្បទាបច្ចេកវិទ្យា ដែលប្រកបដោយមោទនភាពជាតិ និងការទុកចិត្តជាសាកល។
- រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងប្រព័ន្ធគាំទ្រហិរញ្ញវត្ថុ ដែលជាមូលដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិផ្នែកវ.ប.ន. និងរៀបចំឲ្យមានការទូតផ្នែកវិទ្យាសាស្ត្រជាផ្លូវការ មានរបៀបវារៈ វ.ប.ន. សម្រាប់កិច្ចពិភាក្សាកម្រិតកំពូលដើម្បីឲ្យទំនាក់ទំនង វ.ប.ន. ឆ្លងប្រទេសបានប្រព្រឹត្តទៅដោយរលូន។

ទី៤- ***បណ្តុះសង្គមឲ្យមានវប្បធម៌វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាតិ*** មានលក្ខណៈបរិយាប័ន្ន ដោយការកសាងទំនុកចិត្តនិងជំនឿជាសាធារណៈលើផលិតផល និងសេវាបច្ចេកវិទ្យាជាតិ និងការពេញចិត្តទៅលើលទ្ធផលនៃការខិតខំ និងការវិនិយោគលើការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ដូចជា ទៅលើការកែទម្រង់អភិបាលកិច្ច។

៤.១១៨- ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានប្រកបដោយប្រសិទ្ធភាពទាមទារនូវកិច្ចសហការជាអន្តរជាតិ និងការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកិច្ចសហប្រតិបត្តិការដែលសំដៅកសាងយុទ្ធសាស្ត្ររួមគ្នា ហើយបង្កើតឡើងជាប្រព័ន្ធនវានុវត្តន៍សហវិជ្ជមាន។

៤.១១៩- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍*** នឹងបន្តការងាររបស់ខ្លួន រួមមានសកម្មភាពសំខាន់ៗរួមមាន៖

**ជំរុញការអភិវឌ្ឍវិស័យ ប.គ.ព ៖**

- រៀបចំគោលនយោបាយស្តីពីរដ្ឋាភិបាលឌីជីថល។
- រៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញព័ត៌មានជាតិសម្រាប់បច្ចេកវិទ្យាពពក។
- រៀបចំមជ្ឈមណ្ឌលទិន្នន័យខ្នាតតូច សម្រាប់ដំណើរការគម្រោងអ៊ិនធឺណិតល្បឿនលឿនដល់លំនៅដ្ឋាន មជ្ឈមណ្ឌលព័ត៌មាន ការសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក។
- បង្កើតប្រព័ន្ធកម្មវិធីកុំព្យូទ័រគ្រប់គ្រងថ្មីៗនិងបង្កើតវេបសាយជាតិរួម។
- ពង្រីកសមត្ថភាពម៉ាស៊ីនមេវេបសាយម៉ាស៊ីនមេសារអេឡិកត្រូនិក និងរៀបចំយន្តការផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថល ជូនក្រសួង ស្ថាប័ន រាជធានី/ខេត្ត និងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- រៀបចំយន្តការផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលជូនក្រុមហ៊ុនអាជីវកម្ម និងការចុះបញ្ជីសុំការអនុញ្ញាតប្រកបអាជីវកម្មលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។
- គ្រប់គ្រង និងដោះស្រាយបញ្ហាសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។
- រៀបចំបង្កើតសួនឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបង្ហាញអំពីការវិវត្តនៃបច្ចេកវិទ្យាចុងក្រោយ។

**បញ្ជ្រាបការយល់ដឹងនិងជំរុញការប្រើប្រាស់ ប.គ.ព.** នៅជនបទ ជាពិសេសសម្រាប់ជនងាយរងគ្រោះដូចជា ជនពិការ ស្ត្រី កុមារ មនុស្សចាស់ដើម្បីកាត់បន្ថយការគំរាមកំហែងលើស្ត្រី និងកុមារ តាមបណ្តាញអ៊ិនធឺណិត និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសប.គ.ព.ខ្លីៗជូនក្រសួង ស្ថាប័នរាជធានី/ ខេត្ត និងអង្គភាពពាក់ព័ន្ធដទៃទៀត។

៤.១២០- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ និងកិច្ចការនីតិកម្មក្នុងវិស័យពាណិជ្ជកម្មឆ្លើយតបនឹងសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មទី៤៖ ១. តាក់តែងគោលនយោបាយពាណិជ្ជកម្មស្របតាមបរិបទប្រទេស តំបន់ និងពិភពលោក ២. ជំរុញការបង្កើតច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៣. សម្របសម្រួល ពង្រឹង និងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកនិងគ្រប់គ្រងសកម្មភាពទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៤. បន្តគ្រប់គ្រងប្រព័ន្ធ និងការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា (តាមរយៈគេហទំព័រ www.setfo.gov.kh) ឲ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងទំនុក

ចិត្ត និង ៥. ការអភិវឌ្ឍការកសាង ការវិភាគ ការវាយតម្លៃ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មស្របតាមបរិបទពិភពលោក ។

- អភិវឌ្ឍសហគ្រិនភាព និងរបៀបរបបនៃការធ្វើធុរកិច្ចនៅក្នុងសេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤៖ ១. ពង្រឹងការងារសភាពាណិជ្ជកម្មគ្រប់មណ្ឌល និងផ្សព្វផ្សាយពីសារប្រយោជន៍នៃការរៀបចំសមាគមអាជីវកម្ម និងលិខិតបទដ្ឋានទាំងឡាយទាក់ទងដល់ការបង្កើតសមាគម ព្រមទាំងពង្រឹងសមត្ថភាពសមាគមអាជីវកម្មដែលមានស្រាប់ ២. បន្តផ្សព្វផ្សាយ និងអូសទាញពាណិជ្ជករ និងវិនិយោគទុនក្នុងស្រុក-បរទេសដើម្បីចូលរួមអភិវឌ្ឍ និងបង្កើតផលិតកម្ម លើផលិតផលសក្តានុពល ៣. ពង្រឹង និងពង្រីកការរៀបសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលអំពីគុណភាពវេចខ្ចប់ តម្លៃដើមស្តង់ដា ស្លាកសញ្ញាបង្ហាញពីគំនិតនៃការបង្កើតផលិតផលថ្មីៗ បង្ហាញអំពីផលិតផលដែលកំពុងចរាចរនៅលើទីផ្សារ។

៤.១២១- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងព័ត៌មាន*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- បន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឲ្យខិតខំពង្រីកសក្តានុពលប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយគ្របដណ្តប់ឲ្យបានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ជូនប្រជាពលរដ្ឋខ្មែរនៅគ្រប់ច្រកល្ហកនៃមាតុប្រទេស និងឆ្ពោះទៅកាន់ពិភពលោកខាងក្រៅរួមចំណែកលើកតម្កើងអត្តសញ្ញាណ និងមោទនភាពជាតិខ្មែរ និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។
- រៀបចំផែនការទំនើបនីយកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស សម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ ដើម្បីឆ្លើយតបនឹងភាពចាំបាច់នៃការផ្សព្វផ្សាយជាសំឡេងផ្លូវការរបស់ជាតិ។
- បន្តជំរុញការសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ថ្នាក់ក្រោមជាតិនៅតាមបណ្តាខេត្តបន្ទៀតដោយផ្តល់អាទិភាពចំពោះបណ្តាខេត្តនៅប៉ែកពាយ័ព្យនិងឦសាននៃមាតុប្រទេស។ ស្របតាមគោលការណ៍ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនិងអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ ដែលកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។
- ជំរុញការបើកវគ្គបណ្តុះបណ្តាលបច្ចេកទេស និងលើកកម្ពស់សមត្ថភាពសម្រាប់មន្ត្រីផលិតកម្មវិធីនិងព័ត៌មានថ្នាក់ក្រោមជាតិ ដើម្បីឲ្យស្ថានីយវិទ្យុ ទូរទស្សន៍ថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្សព្វផ្សាយបន្តផ្ទាល់នូវព្រឹត្តិការណ៍សំខាន់ៗពីថ្នាក់ជាតិ និងមានលទ្ធភាពផលិតកម្មវិធីអប់រំសង្គម និងបញ្ហាទាក់ទងស្ត្រីនិងកុមារ។

- ជំរុញការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងបន្តខិតខំសិក្សាស្រាវជ្រាវ ដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តថ្មីៗ សម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ឲ្យស្ថិតក្នុងក្របខ័ណ្ឌនីតិរដ្ឋ ដោយធានាបានទាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាននិងលទ្ធិប្រជាធិបតេយ្យ។
- បន្តលើកទឹកចិត្តនិងបើកទូលាយនូវការចូលរួមរបស់វិស័យឯកជនសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យព័ត៌មាននិងសោតទស្សន៍។
- លើកកម្ពស់គុណភាពនៃកម្មវិធីផ្សាយព័ត៌មានគ្រប់ដណ្តប់ ដោយព័ត៌មានជាតិដែលឆ្លុះបញ្ចាំងពីគ្រប់ទិដ្ឋភាពនៃជីវភាពសង្គមកម្ពុជា ជាព័ត៌មានពិតត្រឹមត្រូវតាមទិសស្លោក “**ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន**” ដោយឈរលើស្មារតីទទួលខុសត្រូវនិងគោរពសីលធម៌វិជ្ជាជីវៈ ដើម្បីធានានូវការលើកស្ទួយនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។
- បង្កើតកម្មវិធីផ្សព្វផ្សាយសម្បូរបែប អប់រំសង្គម អប់រំច្បាប់ កម្មវិធីអប់រំអំពីយេនឌ័រ និងកុមារ និងកម្មវិធីយល់ដឹងសម្រាប់គ្រប់មជ្ឈដ្ឋាននិងសហគមន៍ ដោយសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។
- តាមរយៈមធ្យោបាយផ្សព្វផ្សាយទំនើប របស់ខ្លួនប្រព័ន្ធផ្សព្វផ្សាយជាតិទាំងអស់ក៏មានកាតព្វកិច្ចរួមចំណែកលើកកម្ពស់អត្តសញ្ញាណជាតិ និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ ព្រមទាំងម្ចាស់ការប្រតិកម្មតបទាន់ពេលវេលាចំពោះរាល់ការផ្សាយ និងព័ត៌មានទាំងឡាយណាដែលប្រាសចាកការពិត អាចបណ្តាលឲ្យប៉ះពាល់ដល់កិត្តិយសនិងអន្តរាយដល់សន្តិភាពជាតិ ឬបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ក៏ដូចជាប៉ះពាល់ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់មនុស្សទូទៅ។

## តារាងទី ៤.១០ សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន

| សូចនាករសំខាន់ៗ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ក. ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ: | | | | | | | |
| ១-ស្ថានីយទូរទស្សន៍រដ្ឋ (ទ.ទ.ក.) | | | | | | | |
| -ស្ថានីយកណ្តាល | ចំនួន | ០១ | ០១ | ០១ | ០២ | ០២ | ០២ |
| -ស្ថានីយខេត្ត | ចំនួន | ០៧ | ០៨ | ០៨ | ១០ | ១០ | ១២ |
| ២-ស្ថានីយវិទ្យុរដ្ឋ (វិទ្យុជាតិកម្ពុជា) | | | | | | | |
| -ស្ថានីយកណ្តាល | ចំនួន | ០៣ | ០៣ | ០៣ | ០៣ | ០៣ | ០៤ |
| -ស្ថានីយខេត្ត | ចំនួន | ១៨ | ២០ | ២០ | ២២ | ២៣ | ២៤ |
| ៣-ទីភ្នាក់ងារសារព័ត៌មានរដ្ឋ | អង្គភាព | ០១ | ០១ | ០១ | ០១ | ០១ | ០១ |
| ខ. ប្រព័ន្ធផ្សព្វផ្សាយឯកជន: | | | | | | | |
| ១-ស្ថានីយទូរទស្សន៍ឯកជន | ចំនួន | ១២ | ១៣ | ១៤ | ១៤ | ១៥ | ១៥ |
| ២-ស្ថានីយទូរទស្សន៍ខ្សែកាប (រាជធានី ខេត្ត) | ចំនួន | ៩៦ | ១៥៥ | ១៦១ | ១៦៧ | ១៧៣ | ១៧៩ |
| ៣-ស្ថានីយវិទ្យុឯកជន | ចំនួន | ៥១ | ៥៣ | ៥៥ | ៥៧ | ៥៩ | ៦០ |
| ៤-សារព័ត៌មានបោះពុម្ព (កាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី ភាសាខ្មែរ និងបរទេស ) | អង្គភាព | ៥៧៤ | ៥៨០ | ៥៨០ | ៦០០ | ៦០០ | ៦០០ |
| ៥-រោងពុម្ព | អង្គភាព | ១៣៦ | ១៣៨ | ១៤០ | ១៤២ | ១៤៤ | ១៤៥ |

*ប្រភព:* ក្រសួងព័ត៌មាន

៤.១២២- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងឧស្សាហកម្ម និង សិប្បកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួន ក៏ដូចជាសកម្មភាពគាំទ្រផ្សេងៗ ដូចខាងក្រោម៖

- ធ្វើពិពិធកម្មឧស្សាហកម្ម និងការពង្រីកសមត្ថភាពផលិតកម្មឧស្សាហកម្ម ការបង្កើនផលិតភាពដោយផ្តល់អាទិភាពជាពិសេសដល់ការអនុវត្ត **"គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥"**។
- ជំរុញ និងលើកទឹកចិត្តដល់ការវិនិយោគ បង្កើតជាកម្រងឧស្សាហកម្ម សួនឧស្សាហកម្ម និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងការវិនិយោគទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្សារភ្ជាប់ទាំងផ្នែកទន់ និងផ្នែករឹងដែលគាំទ្រដល់សកម្មភាពផលិតកម្ម ឧស្សាហកម្មគ្រប់ប្រភេទ។
- ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ និងជំរុញកិច្ចការស្រាវជ្រាវនានា ព្រមទាំងលើកទឹកចិត្តដល់គំនិតច្នៃប្រឌិតថ្មីៗ ទាំងក្នុងអាជីវកម្ម សេវាកម្ម និងផលិតផល ដែលសមស្របក្នុងបរិការណ៍ជាតិ និងសម័យឌីជីថល ឬបដិវត្តន៍ឧស្សាហកម្មទី៤។

- បន្ត និងចូលរួមរៀបចំគោលនយោបាយលើកកម្ពស់ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- រៀបចំឯកសារស្នើសុំគោលការណ៍ធ្វើសេចក្តីព្រាងច្បាប់ ស្តីពីការផ្ទេរបច្ចេកវិទ្យា។
- ពង្រឹងនីតិវិធី និងកិច្ចសហប្រតិបត្តិការជាមួយដៃគូទាំងក្នុង និងក្រៅប្រទេស ក្នុងកិច្ចការពង្រឹង និងសម្រួលដល់ការចុះបញ្ជី ការការពារ និងការផ្តល់ប្រកាសនីយបត្រតក្កកម្ម ផ្នែកកម្មសិទ្ធិបញ្ញា ក្នុងវិស័យឧស្សាហកម្ម។
- ជំរុញ និងលើកទឹកចិត្ត ការអនុវត្តគំរូអាជីវកម្មប្រកបដោយបរិយាប័ន្ន ឬសកម្មភាពអាជីវកម្មលក្ខណៈបរិយាប័ន្ន និងការផ្តួចផ្តើមអាជីវកម្មបែបសហគ្រាសសង្គម ដើម្បីបង្កើតជាជវភាពមួយសម្រាប់ជាដំណោះស្រាយមានលក្ខណៈជាប្រព័ន្ធ ក្នុងការពន្លឿនធុរកិច្ចបែបនវានុវត្តន៍របស់វិស័យឯកជន ដែលអាចជួយផ្តល់ជាដោះស្រាយ ចំពោះបញ្ហានានាជូន ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលមានចំណូលទាបនៅកម្ពុជា។
- លើកកម្ពស់សមត្ថភាពសិប្បកម្មកែច្នៃផលិតផលក្នុងស្រុក និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងអាជីវកម្ម ពិសេសប្រភេទអាជីវកម្មបែបច្នៃប្រឌិត និងផ្តល់អត្ថប្រយោជន៍ជូនសង្គម ដូចជាប្រភេទអាជីវកម្មបែបសហគ្រាសសង្គម រួមចំណែកបង្កើតការងារក្នុងស្រុក
- ជំរុញ គាំទ្រ និងលើកកម្ពស់សកម្មភាពចលនាភូមិមួយផលិតផលមួយ។
- បន្តជំរុញការគ្រប់គ្រងទិន្នន័យស្ថិតិសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៅទូទាំងប្រទេសជាមូលដ្ឋាន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីជំរុញ និងគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។
- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការជំរុញអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម និងសិប្បកម្ម។
- ជំរុញ គាំទ្រ និងលើកកម្ពស់សកម្មភាពចលនាភូមិមួយផលិតផលមួយបង្កើតវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបញ្ជីហិរញ្ញវត្ថុ និងការគ្រប់គ្រងសហគ្រាស សិប្បកម្ម ដោយសហការជាមួយដៃគូអភិវឌ្ឍ។
- ជំរុញការដាក់បញ្ចូលជាផ្លូវការគោលនយោបាយអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងផែនការអនុវត្ត៥ឆ្នាំ និងការអនុវត្តសកម្មភាពនានាដែលមានចែងក្នុងគោលនយោបាយនេះ ដែលផ្តោតលើចំណុចអាទិភាពចំនួន៥ រួមមាន៖ ១. ជំរុញបរិយាកាសផ្នែកច្បាប់ និងបទដ្ឋានគតិយុត្ត ក៏ដូចជាសមត្ថភាពស្ថាប័នសាធារណៈ ២. ជំរុញការអភិវឌ្ឍសមត្ថភាពសហគ្រិន និងធនធានមនុស្ស ៣. ជំរុញពាណិជ្ជកម្មក្នុងស្រុក ផលិតភាព គុណភាព បច្ចេកវិទ្យា និងនុវានុវត្តន៍ ៤. ពង្រីកការផ្សារភ្ជាប់ទៅកាន់ទីផ្សារបរទេស និងអន្តរជាតិ ៥. លើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញប្បទាន។

៤.១២៣- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***ក្រសួងអប់រំ យុវជន និង កីឡា*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- រៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាឲ្យឆ្លើយតបទៅនឹងការវិវត្តឧស្សាហកម្មទី៤។

- ពង្រឹងវិធីសាស្ត្របង្រៀន និងរៀនតាមបែបថ្មី ដូចជាវិធានតាមបែបរិៈរក និងវិធានផ្សេងទៀត ដើម្បីឲ្យសិស្សមានបំណិនសតវត្សរ៍ទី២១។
- បណ្ដុះបណ្ដាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិតនិងគណិតវិទ្យា។
- ជំរុញការអនុវត្តគោលនយោបាយស្ដីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។
- ជំរុញការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

៤.១២៤- ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ***អគ្គលេខាធិការដ្ឋានជាតិជំរុញចលនាភូមិមួយផលិតផលមួយ*** នឹងអនុវត្តសកម្មភាពមួយចំនួននៃ **គោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ឆ្នាំ ២០១៦-២០២៦** ដូចខាងក្រោម ៖

- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ។
- រៀបចំផែនទីផលិតផលភូមិមួយផលិតផលមួយ។
- ជំរុញការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដែលពាក់ព័ន្ធដល់ការងារជំរុញចលនាភូមិមួយ ផលិតផលមួយ។
- លើកកម្ពស់ការយល់ដឹងពីបទពិសោធនានានៃការជំរុញចលនាភូមិមួយផលិតផលមួយ។
- លើកកម្ពស់ការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ។
- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ។
- អភិវឌ្ឍសមត្ថភាពក្នុងការផលិតនូវផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និង សេវាកម្ម។
- លើកកម្ពស់គុណភាពផលិតផលតាមស្ដង់ដាផលិតផលភូមិមួយផលិតផលមួយ។
- លើកកម្ពស់ការអភិវឌ្ឍទីផ្សារ និងការគ្រប់គ្រងអាជីវកម្ម។
- បង្កើត ចងក្រង ឬពង្រឹងនិងពង្រីកសមាគម សហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការចូលរួមរបស់យុវជន និងស្ត្រីក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការចូលរួមពីបុគ្គលដែលមានជំនាញ មានបទពិសោធ និងប្រជាជនតាមមូលដ្ឋានក្នុងសកម្មភាពជំរុញចលនាភូមិមួយផលិតផលមួយ។
- ជំរុញការអភិវឌ្ឍប្រកបដោយចីរភាព។

## ៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១២៥- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុឲ្យកាន់តែមានពិពិធភាព រឹងមាំធន់នឹងវិបត្តិ និង ប្រកបដោយបរិយាប័ន្ន ដោយផ្អែកលើគោលការណ៍ទីផ្សារ ស្របតាមសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងតំបន់សំដៅរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង លើកកម្ពស់ជីវភាពប្រជាជន។ កន្លងមករាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឲ្យកត់សម្គាល់ មានជាអាទិ៍ ការអភិវឌ្ឍគោលនយោបាយ

និង ក្របខ័ណ្ឌគតិយុត្ត ពិសេសការពង្រឹង យន្តការគ្រប់គ្រង និង ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និង ធនាគារ ការពង្រឹង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ការផ្តល់លក្ខខណ្ឌកាន់តែអនុគ្រោះសម្រាប់ប្រជាជន តាមរយៈការដាក់ពិដានអត្រាការប្រាក់១៨% លើកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការបន្តអភិវឌ្ឍវិស័យធានារ៉ាប់រង និង ការបន្តអភិវឌ្ឍ ទីផ្សារមូលបត្រ ដែលរួមមាន ការបង្កើតទីផ្សារគោល និង ទីផ្សារកំណើន ការបង្កើតទីផ្សារឧបករណ៍និស្សន្ទ និង ការបង្កើតកម្មវិធីឧត្តមភាពសម្រាប់ជួយសម្រួលដំណើរការ ចុះបញ្ជីរបស់សហគ្រាសខ្នាតតូច និង មធ្យម។

៤.១២៦- យ៉ាងណាមិញ វិស័យនេះនៅបន្តជួបបញ្ហាប្រឈមមួយចំនួន រួមមាន ឧបករណ៍ហិរញ្ញវត្ថុនៅមិនទាន់ត្រូវបានធ្វើពិពិធកម្មឱ្យអស់លទ្ធភាព យន្តការបង្ការ និង ដោះស្រាយវិបត្តិ រួមទាំងយន្តការផ្តល់សញ្ញាជាមុននៅពុំទាន់ត្រូវបានរៀបចំរួចរាល់ ការសម្របសម្រួលគោលនយោបាយនៅមិនទាន់មានភាពល្អប្រសើរគ្រប់គ្រាន់ ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត ខណៈដែលប្រព័ន្ធហិរញ្ញវត្ថុមានការរីកចម្រើនឆាប់រហ័ស ការសន្សំក្នុងស្រុកនៅមានកម្រិតទាប អត្រាការប្រាក់នៅមានកម្រិតខ្ពស់នៅឡើយ កម្រិតខ្ពស់នៃដុល្លាររូបនីយកម្ម ដែលបន្តដាក់កំហិតលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និង ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅមានកម្រិត។

៤.១២៧- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតទៅលើ ៖

ទី១-ការបន្តអនុវត្ត "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥**" និងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកចេញ-ចូលនៃប្រព័ន្ធទូទាត់ ការជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ដោយប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុ ការសម្របសម្រួលក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌគតិយុត្ត ការពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ និង ធនាគារ ឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសមាហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ទៅក្នុងតំបន់ និង អន្តរជាតិ។

ទី២-ការបន្តធានាស្ថិរភាពហិរញ្ញវត្ថុ ពិសេសតាមរយៈការពង្រឹងយន្តការគ្រប់គ្រង និង ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និង ធនាគារ តាមវិធីសាស្ត្រផ្អែកលើហានិភ័យ និង ទស្សនអនាគត ការពន្លឿនដំណើរការបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ ក៏ដូចជាការអភិវឌ្ឍយន្តការបង្ការ និង ដោះស្រាយវិបត្តិ រួមមានៈ យន្តការផ្តល់សញ្ញាជាមុន ជម្រើសហិរញ្ញប្បទាន និង ច្បាប់ស្តីពីកិច្ចការពារប្រាក់បញ្ញើ។

ទី៣-ការបន្តពង្រីកតួនាទីវិស័យធនាគារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុនៅក្នុងស្រុក ការសិក្សានិងរៀបចំគោលនយោបាយ និង យន្តការដើម្បីពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុ ព្រមទាំងការពង្រីកគោលការណ៍គាំពារអ្នកប្រើប្រាស់ សេវាហិរញ្ញវត្ថុដើម្បីលើកកម្ពស់ជីវភាពប្រជាជន និង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។

ទី៤-ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ ដោយជំរុញ និង លើកទឹកចិត្តដល់សហគ្រាស និង ក្រុមហ៊ុនឲ្យបោះផ្សាយមូលបត្រជាសាធារណៈ ការលើកកម្ពស់យន្តការជួញដូរដោយបង្កើតឲ្យមានវិនិយោគិនស្ថាប័ន ការបង្កើតប្រតិបត្តិករ ទីផ្សារមូលបត្រអនាគត ព្រមទាំងការសិក្សា និង បង្កើតយន្តការគ្រប់គ្រងការជួញដូរទ្រព្យឌីជីថល។

ទី៥-ការសិក្សា និង រៀបចំឲ្យមានទីផ្សារសញ្ញាបណ្ណរដ្ឋ ដើម្បីជាមូលដ្ឋាន សម្រាប់កំណត់អត្រាកាប្រាក់គោល ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគសាធារណៈ និង ការជួយពង្រឹងគោលនយោបាយរូបិយវត្ថុ។

ទី៦-ការជំរុញ និង លើកទឹកចិត្តដល់ការអភិវឌ្ឍ និង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ Fin Tech ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ប្រតិបត្តិការធនាគារឲ្យកាន់តែទំនើប មានប្រសិទ្ធភាព សុវត្ថិភាព និង មានតម្លៃសមរម្យ។

ទី៧-ការលើកកម្ពស់ និង បង្កើនសមត្ថភាពវិភាគ តាមដាន និង ត្រួតពិនិត្យកិច្ចការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម។

ទី៨-ការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឲ្យកាន់តែទូលំទូលាយ តាមរយៈការបង្កើតគោលនយោបាយថ្នាក់ជាតិដែលបង្កើនការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និង ការបន្តលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនលើវិស័យហិរញ្ញវត្ថុសំដៅបង្កើនប្រសិទ្ធភាព និង ការរួមចំណែករបស់វិស័យហិរញ្ញវត្ថុនៅក្នុងកំណើនសេដ្ឋកិច្ចជាតិ។

ទី៩-ការបន្តពង្រឹង និង ពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ ពិសេសសេវាធានារ៉ាប់រងអាយុជីវិត និង ធានារ៉ាប់រងខ្នាតតូច ដោយរៀបចំ និងកែសម្រួលក្របខ័ណ្ឌគតិយុត្ត ការពង្រឹងសមត្ថភាពបញ្ញត្តិករធានារ៉ាប់រង និង កិច្ចការពារអ្នកប្រើប្រាស់។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១២៨- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ធនាគារជាតិនៃកម្ពុជា*** នឹងបន្តការងាររបស់ខ្លួនរួមមានសកម្មភាពសំខាន់ៗ៖

### វិស័យធនាគារ

- បន្តរក្សាស្ថិរភាពហិរញ្ញវត្ថុ ដោយធ្វើការពង្រឹងជំនាញ និងសមត្ថភាពរបស់ក្រុមការងារតាមដានស្ថិរភាពហិរញ្ញវត្ថុ។ ប្រព័ន្ធផ្តល់សញ្ញាជាមុន ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើនដែលត្រូវបានប្រើដើម្បីផ្តល់សញ្ញាជាមុនអំពីការធ្លាក់ចុះនៃភាពរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ អាជ្ញាធរទាំងអស់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ នឹងផ្តល់ទិន្នន័យនិងព័ត៌មានចាំបាច់ ដើម្បីរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុមួយដែល គ្រប់ជ្រុងជ្រោយនិងមានគុណភាពខ្ពស់។ រាជរដ្ឋាភិបាលគ្រោងនឹងបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុថ្នាក់ជាតិ ដែលនឹងបង្កើតក្របខ័ណ្ឌស្ថាប័ន ច្បាស់លាស់ ដើម្បីតាមដាន និងធានាស្ថិរភាពហិរញ្ញវត្ថុ។

- ត្រៀមបង្ការដោះស្រាយវិបត្តិ ដោយអាជ្ញាធរត្រួតពិនិត្យនានា និងអនុម័តក្របខ័ណ្ឌនិងនីតិវិធីសហប្រតិបត្តិការដោះស្រាយវិបត្តិ។ អាជ្ញាធរនីមួយៗនឹងបង្កើតផែនការយថាភាពរៀងៗខ្លួន និងចូលរួមបង្កើតផែនការយថាភាពជាតិមួយ។
- សិក្សាពីលទ្ធភាពបង្កើតយន្តការការពារប្រាក់បញ្ញើរបស់អតិថិជន ដើម្បីបង្កើនជំនឿទុកចិត្ត សាធារណជនមកលើប្រព័ន្ធធនាគារ។ ស្ថានភាពអភិវឌ្ឍប្រព័ន្ធធនាគារបច្ចុប្បន្នទាមទារឲ្យមានការរៀបចំជាស្រេចនូវក្របខ័ណ្ឌដោះស្រាយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបញ្ហា ពោលគឺអាចអនុញ្ញាតឲ្យធនាគារជាតិនៃកម្ពុជាមានជម្រើសច្រើនជាងមុនក្នុងការដោះស្រាយបញ្ហាបានឆាប់រហ័សទាន់សភាពការណ៍ និងចំណាយទាប។
- អនុវត្តគោលការណ៍គ្រឹះស្នូលបាសែលស្តីពីការត្រួតពិនិត្យធនាគារ និងស្តង់ដាសាកលលោកគឺជាធាតុដ៏សំខាន់ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការត្រួតពិនិត្យធនាគារ។ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងការអនុវត្ត តាមគោលការណ៍ស្នូលបាសែល ជាពិសេសលើដំណើរការគ្រប់គ្រងហានិភ័យដូចជា ហានិភ័យ អធិបតេយ្យ ហានិភ័យផ្ទេរប្រាក់ ហានិភ័យប្រតិបត្តិការហានិភ័យអត្រាកាប្រាក់ និងការត្រួតពិនិត្យគួបសរុប។
- ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិស្តីពីអនុបាតសាធនភាព និងស្តីពីសកម្មភាពកែតម្រូវបន្ទាន់។ ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកថ្មីលើផ្នែកត្រួតពិនិត្យធនាគារ លើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យធនាគារ សំដៅអនុវត្តឲ្យបានពេញលេញនូវវិធីសាស្ត្រត្រួតពិនិត្យធនាគារលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត។ ដំណើរការនេះទាមទារឲ្យមានការបណ្តុះបណ្តាលនិងការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបន្ថែមទៀត។
- ជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល។ រាជរដ្ឋាភិបាលមានផែនការបង្កើតក្រុមការងារចម្រុះ ដើម្បីវាយតម្លៃទីផ្សារ ប្រតិបត្តិការថ្មីៗ និងឧបករណ៍ថ្មីៗ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលផងដែរ។
- គ្រប់គ្រងហានិភ័យនៃការសម្អាតប្រាក់ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យ និងតាមដានធនាគារ។ ធនាគារជាតិនៃកម្ពុជារួមជាមួយនឹងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចប្រឆាំងនឹងការសម្អាតប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។
- បង្កើនប្រសិទ្ធភាពនៃដំណើរការចេញបណ្ណកម្មសិទ្ធិអចលនទ្រព្យនិងចលនទ្រព្យ និងសិក្សាពីថ្លៃចំណាយ និងលទ្ធភាពកាត់បន្ថយថ្លៃចំណាយលើការចេញបណ្ណកម្មសិទ្ធិជាដើម។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏មានផែនការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការចេញកម្មសិទ្ធិប្រភេទតូចៗលើអគារសហកម្មសិទ្ធិ និងការចុះបញ្ជីអចលនទ្រព្យនៅនាយកដ្ឋានចុះបញ្ជីទ្រព្យធានា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងជំរុញដំណើរការចុះបញ្ជីចលនទ្រព្យសម្រាប់ប្រើប្រាស់ក្នុងការស្នើសុំឥណទានពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

- ពិនិត្យឡើងវិញនូវតម្រូវការ នៃការពង្រឹកគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងបទប្បញ្ញត្តិ ដែលមានស្រាប់ដោយចែងឲ្យកាន់តែច្បាស់ពីលក្ខខណ្ឌនានាចំពោះផលិតផលឥណទាន ការផ្សព្វផ្សាយពាណិជ្ជកម្ម នីតិវិធីប្ដឹងនិងតវ៉ា កម្រៃសេវា ការគណនាការប្រាក់ និងនីតិវិធីនៃការប្រមូលឥណទាន។
- លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុដោយ ១. កាត់បន្ថយអត្រាប្រជាជន ដែលពុំមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ២. ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង បរិយាប័ន្ន ៣. ជំរុញការអភិវឌ្ឍបរិស្ថាន ដែលគាំទ្រដល់បរិយាប័ន្នហិរញ្ញវត្ថុ និង ៤. ធ្វើឲ្យប្រជាពលរដ្ឋ ទាំងអស់អាចទទួលបានអត្ថប្រយោជន៍ពីបរិយាប័ន្នហិរញ្ញវត្ថុ។

### វិស័យមីក្រូហិរញ្ញវត្ថុ

- អនុម័តយុទ្ធសាស្ត្រជាតិស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ ដែលបានធ្វើបច្ចុប្បន្នកម្ម ព្រមទាំងយុទ្ធសាស្ត្រថ្មី ស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ។
- បន្តការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងមានផែនការលើកកម្ពស់ការប្រតិបត្តិតាមគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារ ប្រកបដោយប្រសិទ្ធភាពសម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុរបស់គណៈកម្មាធិការបាសែល។ ធនាគារជាតិនៃកម្ពុជានឹងបន្តផ្តោតការយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យ និងដាក់ចេញនូវបទប្បញ្ញត្តិដែលស្របតាមស្តង់ដារអន្តរជាតិសម្រាប់ ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- បន្តពង្រឹងការអនុវត្តច្បាប់ ដោយចាត់វិធានការតឹងរឹងដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលមិនព្រមមកចុះបញ្ជី ហើយនៅបន្តធ្វើអាជីវកម្មខុសច្បាប់។
- បន្តពង្រឹងអក្ខរកម្មហិរញ្ញវត្ថុ ដោយបន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន ពិសេសប្រជាពលរដ្ឋនៅតំបន់ជនបទ ដើម្បីជំរុញឲ្យមានការយល់ដឹងអំពីផ្នែកហិរញ្ញវត្ថុបន្ថែមទៀតក្នុងគោលបំណងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដោយបញ្ជាក់ឲ្យប្រជាពលរដ្ឋបានយល់ថាប្រតិបត្តិករ មីក្រូហិរញ្ញវត្ថុមិនមែនជារបស់រដ្ឋទេ ហើយប្រតិបត្តិករមីក្រូហិរញ្ញវត្ថុក៏មិនមែនជាអង្គការមនុស្សធម៌ដែរ។
- សិក្សាស្វែងរកប្រភពទុនដែលមានតម្លៃទាប និងសិក្សាពីកត្តារួមផ្សំទាំងឡាយដែលធ្វើឲ្យថ្លៃដើមទុនខ្ពស់និងរិះរកមធ្យោបាយដើម្បីបញ្ចុះអត្រាការប្រាក់ដោយគោរពតាមយន្តការទីផ្សារ។
- កាត់បន្ថយសកម្មភាពធនាគារស្រមោល ដោយពង្រឹងការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធ និងចាត់វិធានការកាត់បន្ថយសកម្មភាព ដែលមានលក្ខណៈជាធនាគារស្រមោលដែលអាចបង្កឲ្យមានហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុ។

## ៥- ការអភិវឌ្ឍវិស័យឯកជន និង ការងារ

៤.១២៩- ការអភិវឌ្ឍវិស័យឯកជននៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍ សេដ្ឋកិច្ចទីផ្សារ និង មានតួនាទីគន្លឹះក្នុងការជំរុញកំណើន និង ការអភិវឌ្ឍសង្គម សេដ្ឋ

កិច្ច។ ក្នុងស្មារតីនេះ ការអភិវឌ្ឍវិស័យឯកជន នឹងត្រូវបានអនុវត្តតាមរយៈវិធានការជាកញ្ចប់ និង គ្រប់ជ្រុងជ្រោយដោយគ្របដណ្តប់មុំ ៤ គឺ ១. ការអភិវឌ្ឍទីផ្សារការងារ ២. ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព ៣. ការរៀបចំ និង អនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន និង ៤. ការពង្រឹងការប្រកួតប្រជែង។

## ៥.១- ការអភិវឌ្ឍទីផ្សារការងារ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៣០- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍទីផ្សារការងារដែលមានប្រាក់ចំណូលខ្ពស់ មានលក្ខខណ្ឌ ការងារល្អ និង ការយកចិត្តទុកដាក់លើសុខុមាលភាពកម្មករ-និយោជិតទាំងក្នុង និង ក្រៅប្រព័ន្ធ។

៤.១៣១- ទន្ទឹមនេះ កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ដូចជា គុណភាព និងផលិតភាពនៃកម្លាំងពលកម្មនៅមានកម្រិតទាប បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ កម្លាំងពលកម្មភាគច្រើន ធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារ និង អតីតភាពការងារមិនទាន់រឹងមាំ ការរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាព និង សុវត្ថិភាពការងារ នៅតាមរោងចក្រសហគ្រាសមិនទាន់ល្អ ការដឹកជញ្ជូនកម្មករ-និយោជិតមិនសូវមានសុវត្ថិភាព ការគ្រប់គ្រងការបិទរោងចក្រ និង ការទូទាត់ប្រាក់អតីតភាពការងារនៅមិនទាន់បានល្អ និង សេវាគាំពារពលករទេសន្តរប្រវេសន៍នៅមានកម្រិត។

៤.១៣២- ក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖

ទី១-ការបន្តពង្រឹងយន្តការ *"វេទិកាការងារ"* ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ និង ការពង្រីកការផ្តល់សេវារកការងារ និង ការផ្សព្វផ្សាយ ព្រមទាំងការបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនឱកាសការងារប្រកបដោយសមធម៌ និង កាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន។

ទី២-ការអនុវត្តច្បាប់ ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យមានប្រសិទ្ធភាព ដោយបន្តពង្រឹងយន្តការត្រីភាគី លក្ខណៈវិនិច្ឆ័យ និង គោលការណ៍ដែលបាននិងកំពុងអនុវត្តសម្រាប់ចរចា ដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ-និយោជិតជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពសង្គម សេដ្ឋកិច្ច និង ផលិតភាព ការរៀបចំបើកប្រាក់ឈ្នួលប្រចាំខែក្នុងរយៈពេល២សប្តាហ៍ម្តង និង ការទូទាត់ប្រាក់អតីតភាពការងារ ប្រចាំឆ្នាំឲ្យបានទៀងទាត់ដល់កម្មករ-និយោជិត។

ទី៣-ការពង្រឹង និង ពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង/កម្មសិក្សា ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ និង ធ្វើស្ថាប័នីយកម្មប្រព័ន្ធហ្វឹកហ្វឺនកូនជាង/កម្មសិក្សាដោយភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់សហគ្រាស និង គ្រឹះស្ថាន ដែលអនុវត្តប្រព័ន្ធនេះ។

ទី៤-ការពង្រឹងគុណភាព និង ប្រសិទ្ធភាពអធិការកិច្ចការងារ តាមរយៈការអនុវត្តឲ្យបានពេញលេញនូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និង បទដ្ឋានការងារអន្តរជាតិ ដើម្បីធានាសិទ្ធិសេរីភាព អង្គការ វិជ្ជាជីវៈ លក្ខខណ្ឌការងារ សុខភាព និង សុវត្ថិភាពការងារនៅកន្លែងធ្វើការ ក៏ដូចជា សុវត្ថិភាពដឹកជញ្ជូនកម្មករ-និយោជិត ព្រមទាំងអត្ថប្រយោជន៍កម្មករនិយោជិត និង ការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មករនិយោជិត ដើម្បីគ្រប់គ្រងការផ្តល់បណ្ណការងារ និង ការបើកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ និង ប្រាក់សោធននិវត្តន៍។

ទី៥-ការពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ ការអនុវត្តច្បាប់ស្តីពីសហជីព និង ការបកស្រាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធច្បាប់ស្តីពីការងារច្បាប់ ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និង អនុសញ្ញាអន្តរជាតិស្តីពីការងារ។

ទី៦-ការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និង ពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និង ទ្វេភាគី ដើម្បីបើកទូលាយទីផ្សារកាងារស្របច្បាប់នៅក្រៅប្រទេស ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់ លើកកម្ពស់ការគាំពារសិទ្ធិ ផលប្រយោជន៍ សុខភាព និង សុវត្ថិភាពការងារ កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និង ការរៀបចំធ្វើសមាហរណកម្មពលករ ទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តតាមរយៈការទទួលស្គាល់ជំនាញ ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស ការផ្តល់ការប្រឹក្សារកការងារធ្វើ និង ការបង្កើតមុខរបរដោយខ្លួនឯង។

ទី៧-ការបន្តពង្រីកការតបណ្តាញអគ្គិសនី និង ទឹកស្អាត ដោយតម្លៃទាប សមរម្យជូនកម្មករ-និយោជិត សិស្ស-និស្សិត នៅតាមផ្ទះជួល ការជំរុញការរៀបចំកន្លែងស្នាក់នៅ និង មធ្យោបាយធ្វើដំណើរសម្រាប់កម្មករ-និយោជិត ដោយសុវត្ថិភាព ការអនុញ្ញាតឈប់លំហែមាតុភាពរយៈពេល៣ខែ ដោយទទួលបានប្រាក់ឈ្នួលពលកម្ម១២០% ការផ្តល់សេវាថែទាំសុខភាព និង ការពិនិត្យផ្ទៃពោះដល់កម្មការិនីដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ/មណ្ឌលសុខភាពរដ្ឋ ការផ្តល់ការឧបត្ថម្ភដល់កម្មការិនីដែលមានផ្ទៃពោះ និង សម្រាលកូនរួច និង ការបន្តកែសម្រួលកម្រិតប្រាក់ឈ្នួលអប្បបរមាដែលត្រូវជាប់ពន្ធ និង ការអនុគ្រោះពន្ធចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៣៣- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិ-កាលទី៦នៃរដ្ឋសភា ***ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*** នឹងបន្តការងាររបស់ខ្លួនដែលមានសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖

- អភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដោយត្រូវបន្តការលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង ការពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនិងការងារដោយបង្ខំ ការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមានិងអត្ថប្រយោជន៍របស់កម្មករ និយោជិត និងការពង្រឹងសុខដុមនីយកម្មនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ សំដៅលើកកម្ពស់ការគោរពលក្ខខណ្ឌការងារនិងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈដែលផ្តល់នូវសេចក្តីទុកចិត្តដល់កម្មករ និយោជិត និងនិយោជកដែលកំពុងវិនិយោគនៅកម្ពុជា។
- ធ្វើទំនើបកម្មប្រព័ន្ធអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយបន្តការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការពង្រីកការបណ្តុះបណ្តាលជំនាញដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងដៃគូនានាដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការជំរុញស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍សំដៅធានាថា "**យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត**" ក្នុងការលើកកម្ពស់ចំណេះដឹងជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ និងស្មារតីទទួលខុសត្រូវ សុខភាពល្អនិងកាយសម្បទារឹងមាំ តួនាទីស្ត្រី និងកិច្ចគាំពារសង្គម ជាពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ឲ្យឈានឡើងមួយកម្រិតទៀតជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។
- បរិយាកាសមុខរបរនិងការងារកាន់តែទូលំទូលាយ ដោយការបង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់ ការពង្រីកយន្តការ វិសាលភាពនិងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឲ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា គ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ ដើម្បីបង្កើនឱកាសការងារប្រកបដោយសមធម៌ និងការកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន និងការលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។
- អភិវឌ្ឍរបបសន្តិសុខសង្គមដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយបន្តការពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ការបន្តពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ការជំរុញការរៀបចំនិងដាក់ឲ្យដំណើរការរបបប្រាក់សោធន និងការពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងការអភិវឌ្ឍសមត្ថភាព

ដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា សំដៅលើកកម្ពស់សុខមាលភាព និងសាមគ្គីភាពសង្គម ព្រមទាំងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រជាអតិបរមា ជាពិសេសប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករ និយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

- បន្តសហការជាមួយ ***ក្រសួងរ៉ែ និង ថាមពល*** និង ***ក្រសួងឧស្សាហកម្ម និង សិប្បកម្ម*** ជំរុញការតបណ្តាញអគ្គិសនី ទឹកស្អាត ដោយតម្លៃថោកសមរម្យជូនកម្មករនិយោជិត សិស្សនិស្សិត ស្នាក់នៅតាមផ្ទះជួល និងជំរុញការអនុវត្តច្បាប់ស្តីពីភតិសន្យាពិសេស(ច្បាប់ជួលបន្ទប់) បន្តលើកលែងពន្ធចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម និងបន្តកែសម្រួលកម្រិតប្រាក់បៀវត្សអប្បបរមាត្រូវជាប់ពន្ធចាប់ពី១លានរៀលឡើង។

៤.១៣៤- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងផែនការ*** នឹងបន្តការងាររបស់ខ្លួនដែល មានសកម្មភាពអាទិភាពសំខាន់ៗ រួមមាន៖

- បន្តកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងផលិតបណ្ណក្រីក្រឬបណ្ណសមធម៌ឲ្យបានឆាប់។
- ពង្រីកតំបន់គ្របដណ្តប់ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមទាំងតំបន់ទីប្រជុំជន និងតាមការស្នើសុំ ជាពិសេសប្រជាជនងាយរងគ្រោះ ដូចជា ជនពិការ ឬយុទ្ធជន គ្រួសារពលី អ្នកផ្ទុកមេរោគអេដស៍ជំងឺអេដស៍។
- ផ្សព្វផ្សាយទិន្នន័យក្រីក្រដល់គ្រប់ក្រសួង ស្ថាប័ន និង អ្នកមានចំណែកពាក់ព័ន្ធនានា។

## ៥.២- ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៣៥- សហគ្រាសធុនតូច និង មធ្យម រួមចំណែកយ៉ាងសំខាន់ នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច ការបង្កើតការងារ និង ក្នុងការកាត់បន្ថយភាពក្រីក្រ និង ការធ្វើចំណាកស្រុក។ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបន្តពង្រឹងការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម លើកកម្ពស់សហគ្រិនភាព និង សហគ្រាសបង្កើតថ្មី ដើម្បីជំរុញផលិតកម្មនៅក្នុងស្រុកជំនួសការនាំចូល តភ្ជាប់សហគ្រាសធុនតូច និង មធ្យម ជាមួយនឹងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និង ជំរុញការនាំចេញផលិតផលដែលមានសក្តានុពល ជាពិសេសក្នុងវិស័យកសិកម្មកែច្នៃម្ហូបអាហារ និង កសិឧស្សាហកម្ម។

៤.១៣៦- បញ្ហាប្រឈមក្នុងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម មានជាអាទិ៍៖ ការផ្តល់សេវាសាធារណៈ និង ការសម្របសម្រួលស្ថាប័ន នៅមិនទាន់មានប្រសិទ្ធភាពល្អ ស្មុគស្មាញ និង ប្រើពេលវេលាច្រើន ការទទួលបានឥណទាននៅមានកម្រិត និង ប្រភពទុនវិនិយោគនៅមានភាពចង្អៀត ការលើកទឹកចិត្តផ្នែកពន្ធមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ កង្វះខាតនូវ

សហគ្រិនភាព និង សមត្ថភាព គ្រប់គ្រងសហគ្រាសខ្លួនឯងផ្ទាល់ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា មន្ទីរពិសោធន៍ថ្នាក់ជាតិនៅមានកម្រិត កិច្ចសម្រួលពាណិជ្ជកម្ម នៅមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ និង ចំណាយថ្លៃដើមខ្ពស់ធៀបនឹងប្រទេសជិតខាងក្នុងតំបន់។

៤.១៣៧- ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១-ការបញ្ចប់ការរៀបចំ និងជំរុញការអនុវត្ត "**គោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម**" ឲ្យមានប្រសិទ្ធភាព។

ទី២-ការពង្រឹងការអនុវត្តយន្តការគាំទ្រដើម្បីជួយសម្រួលដល់ការចុះបញ្ជីការផ្តល់សេវាសម្របសម្រួល ការផ្សព្វផ្សាយព័ត៌មានទីផ្សារឲ្យបានទូលំទូលាយ និងទាន់ពេលវេលា ការផ្សព្វផ្សាយ និងបញ្ជ្រាបបច្ចេកវិទ្យាថ្មី និង ការបន្តខិតខំស្វែងរក និង ជ្រៀតចូលទីផ្សារនាំចេញសម្រាប់ផលិតផលកម្ពុជា។

ទី៣-ការបង្កើត "**ធនាគារសហគ្រាសធុនតូច និង មធ្យម**" ដើម្បីផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និង មធ្យម ព្រមទាំងការជំរុញការរៀបចំ និង អនុវត្តនូវជម្រើសហិរញ្ញប្បទាននានា រួមទាំងយន្តការគ្រប់គ្រងអាជីវកម្ម និងគម្រោងវិនិយោគ។

ទី៤-ការបង្កើត "***មូលនិធិជាតិសហគ្រិនភាព***" និង "***មជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាព***" ដោយសហការជាមួយវិស័យឯកជនសំដៅលើកកម្ពស់សហគ្រិនភាព និង ប្រសិទ្ធភាពធុរកិច្ច។

ទី៥-ការពង្រឹងនិងពង្រីកបន្ថែមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា មន្ទីរពិសោធន៍ថ្នាក់ជាតិ ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម ការកែលម្អប្រព័ន្ធឡូជីស្ទីកព្រមទាំងការបន្តលើកទឹកចិត្ត និង ការទាក់ទាញការវិនិយោគក្នុងការបង្កើតចង្កោមសហគ្រាសធុនតូចនិងមធ្យម។

ទី៦-ការជំរុញការលើកកម្ពស់គុណភាពផលិតផលនៃសហគ្រាសធុនតូច និង មធ្យម តាមរយៈការពង្រឹងអនុលោមភាពលក្ខខណ្ឌអនាម័យ និង ភូតគាមអនាម័យ និងស្តង់ដា ព្រមទាំងការលើកកម្ពស់នវានុវត្តន៍ តាមរយៈការការពារកម្មសិទ្ធិបញ្ញា និងការផ្តល់ប្រកាសនីយបត្រតក្កកម្ម។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៣៨- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងឧស្សាហកម្ម និង សិប្បកម្ម*** នឹងបន្តការងាររបស់ខ្លួន។ សកម្មភាពសំខាន់ៗរួមមាន៖

- ពិនិត្យឡើងវិញនូវចំណុចយុទ្ធសាស្ត្រ ឬផែនការសកម្មភាព គាំទ្រវិស័យឯកជនលើការងារផលិតកម្ម ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងការពង្រីងទីផ្សារផលិតផលកម្ពុជា។

- ជំរុញ និងលើកទឹកចិត្ត ការអនុវត្តគំរូអាជីវកម្មប្រកបដោយបរិយាប័ន្ន ឬសកម្មភាពអាជីវកម្មលក្ខណៈបរិយាប័ន្ន និងការផ្តួចផ្តើមអាជីវកម្មបែបសហគ្រាសសង្គម ដើម្បីបង្កើតជាជវភាពថ្មីមួយសម្រាប់ជាដំណោះស្រាយមានលក្ខណៈជាប្រព័ន្ធ ក្នុងការពន្លឿនធុរកិច្ចបែបនវានុវត្តន៍របស់វិស័យឯកជន ដែលអាចជួយដោះស្រាយចំពោះបញ្ហានានាជូន ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលមានចំណូលទាបនៅកម្ពុជា។
- អនុវត្តវេទិកាជំនួបទូលំទូលាយដែលមានចរិតអន្តរវិស័យ ផ្សារភ្ជាប់ទំនាក់ទំនងគ្នាជាប្រព័ន្ធរវាងអ្នកផលិត អ្នកផ្គត់ផ្គង់ និងអ្នកជួយរកទីផ្សារ ដោយចាំបាច់ទាមទារការចូលរួម និងកិច្ចសហការគ្នាជិតស្និទ្ធជាមួយក្រសួង ស្ថាប័នរដ្ឋ និងផ្នែកឯកជនដែលពាក់ព័ន្ធ ដូចជាសភាពាណិជ្ជកម្ម សភាមុខរបរ សមាគម ឬ សហភាពសម្ព័ន្ធសហគ្រាសនានា។
- បន្តជំរុញបង្កើត **មជ្ឈមណ្ឌលផ្តល់ប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច និងសហការជាមួយ បណ្តាស្ថាប័នផ្តល់សេវាប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច ឯកជននានា**។
- បង្កើតបរិយាកាសធុរកិច្ច សំដៅការបង្កើនការចុះបញ្ជី ការអនុញ្ញាត ការបង្កើតរោងចក្រសហគ្រាសកម្មន្តសាលធុនតូច មធ្យម និងសិប្បកម្ម ព្រមទាំងសេវាច្រកចេញចូលតែមួយឲ្យកាន់តែប្រសើរឡើង។
- ពិនិត្យបន្ថែមទៀតលើការធ្វើប្រតិភូកម្មអំណាចដល់ថ្នាក់ក្រោមជាតិ និងបញ្ហាប្រឈមដែលត្រូវជម្នះដោះស្រាយដើម្បីជំរុញឲ្យគោលការណ៍ណែនាំនេះ អាចសម្រេចបាននូវលទ្ធផលជាក់ស្តែង ធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។
- លើកកម្ពស់សមត្ថភាពសិប្បកម្មកែច្នៃផលិតផលក្នុងស្រុក និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងអាជីវកម្ម ពិសេសប្រភេទអាជីវកម្មបែបច្នៃប្រឌិត និងផ្តល់អត្ថប្រយោជន៍ជូនសង្គម ដូចជាប្រភេទអាជីវកម្មបែបសហគ្រាសសង្គម រួមចំណែកបង្កើតការងារក្នុងស្រុក
- បណ្តុះបណ្តាល និងផ្សព្វផ្សាយគំរូបញ្ជីគណនេយ្យដល់ម្ចាស់សិប្បកម្ម។
- ជំរុញការកសាងគោលនយោបាយ គ្រប់គ្រង និងអភិវឌ្ឍន៍ស្រែអំបិល។
- រៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពចំណីអាហារ និងជំរុញភាពអនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិ។
- ជំរុញ និងលើកកម្ពស់សកម្មភាពសិប្បកម្មកែច្នៃវត្ថុធាតុដើមពីធម្មជាតិក្នុងស្រុក ដូចជា វល្លិ៍ ផ្តៅ ឬស្សី កំប្លោក។
- បន្តជំរុញការគ្រប់គ្រងទិន្នន័យស្ថិតិសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៅទូទាំងប្រទេស។
- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការជំរុញអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម និងសិប្បកម្ម។
- ជំរុញ គាំទ្រ និងលើកកម្ពស់សកម្មភាពចលនាភូមិមួយផលិតផលមួយ បង្កើតវគ្គបណ្តុះបណ្តាលស្តីពីកការគ្រប់គ្រងសហគ្រាស សិប្បកម្ម ដោយ សហការជាមួយដៃគូអភិវឌ្ឍ។

- ជំរុញការដាក់បញ្ចូលជាផ្លូវការណ៍ គោលនយោបាយអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងផែនការអនុវត្ត០៥ឆ្នាំ និងការអនុវត្តសកម្មភាពនានាដែលមានចែងក្នុងគោលនយោបាយនេះ ដែលផ្តោតលើចំណុចអាទិភាពចំនួន៥ រួមមាន៖ ១. ជំរុញបរិយាកាសផ្នែកច្បាប់ និងបទដ្ឋានគតិយុត្តក៏ដូចជាសមត្ថភាពស្ថាប័នសាធារណៈ ២. ជំរុញការអភិវឌ្ឍសមត្ថភាពសហគ្រិន និងធនធានមនុស្ស ៣. ជំរុញពាណិជ្ជកម្មក្នុងស្រុក ផលិតភាព គុណភាព បច្ចេកវិទ្យា និងនវានុវត្តន៍ ៤. ពង្រីកការផ្សារភ្ជាប់ទៅកាន់ទីផ្សារបរទេស និងអន្តរជាតិ និង ៥. លើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញប្បទាន។

៤.១៣៩- ដើម្បីចូលរួមអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ក្នុងការទាក់ទាញការវិនិយោគ ដើម្បីបង្កើតចង្កោមសហគ្រាសធុនតូច និងមធ្យម ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ចូលរួមពិភាក្សាលើគោលនយោបាយនៃការលើកទឹកចិត្តដល់សួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក។
- រៀបចំ ឬចូលរួម ធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីការរៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់ នៅប្រទេសថៃ ឬវៀតណាម ឬប្រទេសក្នុងតំបន់ណាមួយដែលមានលក្ខណៈប្រហាក់ប្រហែល តាមលទ្ធភាពជាក់ស្តែង។

៤.១៤០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព ***ក្រសួងពាណិជ្ជកម្ម*** នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត។ សកម្មភាពសំខាន់ៗរួមមាន៖

ទី១ **អភិវឌ្ឍកិច្ចការស្រាវជ្រាវ និងបណ្តុះបណ្តាលពាណិជ្ជកម្ម៖** ១. ផ្សព្វផ្សាយពីគោលនយោបាយពាណិជ្ជកម្មថ្មីៗ និងជំរុញការសិក្សាមុខវិជ្ជាពាក់ព័ន្ធនឹងពាណិជ្ជកម្ម លើប្រព័ន្ធការសិក្សាពីចម្ងាយ ២. បណ្តុះបណ្តាលលើការលើកកម្ពស់សហគ្រិនភាព និងអភិវឌ្ឍន៍អាជីវកម្ម ការបង្កើត គ្រប់គ្រងគម្រោង ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱកាស និងបញ្ហាប្រឈមរបស់សហគ្រាសធុនតូច និងមធ្យម ជាដើម ។

ទី២ **អភិវឌ្ឍន៍កិច្ចការពាណិជ្ជកម្មនៅតាមរាជធានី-ខេត្ត៖** ១. អភិវឌ្ឍន៍ការងារគ្រប់គ្រងអាជីវកម្ម ២. អភិវឌ្ឍន៍ការងារជំរុញពាណិជ្ជកម្ម។

ទី៣ **អភិវឌ្ឍន៍យេនឌ័រក្នុងវិស័យពាណិជ្ជកម្ម៖** ១. លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម ក៏ដូចជានៅក្នុងវិស័យមុខងារសាធារណៈ ២. ពង្រឹង និងពង្រីកគោលគំនិត

យេនឌ័រ សមភាពយេនឌ័រ និងការអភិវឌ្ឍស្ត្រីក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម និង ៣. បញ្ជ្រាបយេនឌ័រតាមអន្តរវិស័យ សម្រាប់យុទ្ធសាស្ត្របន្ទាន់(បណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញផ្សេងៗ) និងយុទ្ធសាស្ត្ររយៈពេលវែង ។

## ៤.៣- ការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៤១- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺ បង្កើត និងអនុវត្តឲ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

៤.១៤២- ជាលទ្ធផល កម្ពុជាសម្រេចបានវឌ្ឍនភាពសំខាន់ៗ ក្នុងការជំរុញការចូលរួមរបស់ វិស័យឯកជន ដោយបានដាក់ចេញនូវ "**ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" និងបានបង្កើតយន្តការស្ថាប័ន ព្រមទាំងបានអនុវត្តគម្រោងវិនិយោគធំៗ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថាមពល និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាពិសេសក្នុងទម្រង់ "**សាងសង់-អាជីវកម្ម-ផ្ទេរ**"។

៤.១៤៣- បញ្ហាប្រឈមសំខាន់ៗ រួមមានការបន្តប្រើប្រាស់ "**យន្តការចំពោះកិច្ច**" ក្នុងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនមិនទាន់មានការវាយតម្លៃហានិភ័យនៃគម្រោងហិរញ្ញវត្ថុ ក្របខ័ណ្ឌគតិយុត្តមិនទាន់គ្រប់គ្រាន់ សមត្ថភាពផ្តួចផ្តើមរៀបចំការចរចា និងការគ្រប់គ្រងគម្រោងនៅមានកម្រិត។

៤.១៤៤- ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១-ការបន្តអនុវត្ត "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ ភាពជាដៃគូរវាងរដ្ឋ និង ឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" និង ការរៀបចំ "**គោលនយោបាយអនុវត្តគម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន**" សម្រាប់រយៈពេលវែងដើម្បីរួមចំណែកបង្កើតបរិស្ថាន អំណោយផលសម្រាប់បន្តជំរុញ និង លើកទឹកចិត្តការចូលរួមរបស់វិស័យឯកជន និង ស្ថាប័នហិរញ្ញវត្ថុ។
- ទី២-ការបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និង បទប្បញ្ញត្តិពាក់ព័ន្ធ ការដាក់ឲ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួម ព្រមទាំងការពិនិត្យលទ្ធភាពរៀបចំបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុនានា តាមការចាំបាច់ និង ស្របតាមបរិការណ៍អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ទី៣-ការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស តាមក្រសួង ស្ថាប័នពាក់ព័ន្ធលើការគ្រប់គ្រង និង អនុវត្តគម្រោងតាមរូបភាពយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន។

ទី៤-ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដើម្បីឲ្យហិរញ្ញប្បទានពីវិស័យឯកជនអាចចូលរួមបង្កើន និងពន្លឿនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក៏ដូចជាគាំទ្រដល់ការបន្ធូរបន្ទុកថវិកាជាតិ និង បំណុលសាធារណៈ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៤៥- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*** នឹងអនុវត្តសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន៖

- រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- បន្តលើកទឹកចិត្តនិងជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស តំបន់កែច្នៃការនាំចេញ តំបន់ពាណិជ្ជកម្មសេរី និងការអភិវឌ្ឍទីផ្សារតាមតំបន់ព្រំដែន ដោយមានការចូលរួមពីវិស័យឯកជន។
- បន្តអនុវត្តនិងដំណើរការយន្តការវេទិការាជរដ្ឋាភិបាល វិស័យឯកជន ដើម្បីបន្តដោះស្រាយកង្វល់ផ្សេងៗរបស់វិស័យឯកជន និងដើម្បីបន្តពង្រឹងវិស័យឯកជនឲ្យកាន់តែមានជីវភាពនិងឲ្យកាន់តែមានភាពជាម្ចាស់។

៤.១៤៦- ដើម្បីចូលរួមអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ក្នុងការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បន្តចូលរួមអនុវត្ត **“ឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការ ភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០”**
- បន្តជំរុញ និងទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសឲ្យមកដាក់ទុនវិនិយោគលើគម្រោងសាធារណៈធំៗ ដូចជា គម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មានជាអាទិ៍៖ ផ្លូវថ្នល់ ស្ពានគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពល និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងការចូលរួមចំណែកគាំទ្រដល់ការសម្រាលបន្ទុកថវិកាជាតិ និងបំណុលសាធារណៈ។
- បន្តចូលរួមពិនិត្យ និងផ្ដល់ធាតុចូលលើការរៀបចំ **“គោលនយោបាយអនុវត្តគម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន”** និងការបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និង បទប្បញ្ញត្តិពាក់ព័ន្ធ។

- បន្តចូលរួមពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាព រួមទាំងគម្រោងដែលនឹងដាក់ឲ្យអនុវត្តសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

៤.១៤៧- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន ***ក្រសួងពាណិជ្ជកម្ម*** នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត។ សកម្មភាពសំខាន់ៗរួមមាន៖

- ពង្រឹងការអភិវឌ្ឍវិស័យឯកជន៖ ១. ពង្រឹងនិងពង្រីកការអភិវឌ្ឍស្ថាប័នឯកជនតាមរយៈការបង្កើតសមាគមអាជីវកម្ម និងសភាពាណិជ្ជកម្ម ២. ធ្វើការវាយតម្លៃនូវតម្រូវការកិច្ចសម្រួលពាណិជ្ជកម្ម របស់ស្ថាប័នពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ៣. អនុវត្តនូវទំនាក់ទំនងពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាលើវិស័យពាណិជ្ជកម្មជាទៀងទាត់ជាមួយស្ថាប័នពាក់ព័ន្ធ ៤. ជំរុញការនាំចេញ និងការសិក្សាខ្សែចង្វាក់ផលិតតម្លៃសម្រាប់ផលិតផលសក្តានុពល ៥. បន្តតាមដានតម្លៃលក់រាយប្រេងឥន្ធនៈលើទីផ្សារក្នុងនិងក្រៅប្រទេស និងកែសម្រួលសន្ទស្សន៍ថ្លៃទំនិញ ៦. ពង្រីកសកម្មភាពបណ្តុះបណ្តាលឲ្យបានទៅដល់មន្ត្រីក្រសួងពាក់ព័ន្ធ និងវិស័យឯកជន និងបង្កើតឲ្យមានកម្មវិធីស្រាវជ្រាវមួយដែលគាំទ្រដោយ ភ្នាក់ងារផ្តល់មូលនិធិអភិវឌ្ឍ។
- ពង្រឹង និងពង្រីកកិច្ចសម្រួលពាណិជ្ជកម្ម៖ ១. បន្តអភិវឌ្ឍនីតិវិធីរដ្ឋបាល និង ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម ២. ពង្រឹងកិច្ចសហការរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនលើផ្នែកពាណិជ្ជកម្ម ៣. តាមដានត្រួតពិនិត្យ និងវាយតម្លៃនូវកិច្ចសម្រួលពាណិជ្ជកម្ម។

## ៥.៤- ការពង្រឹងការប្រកួតប្រជែង

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៤៨- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច លើកកម្ពស់ឧត្តមភាព និង ជំរុញនវានុវត្តន៍ ដែលចាំបាច់ត្រូវធ្វើជាប្រចាំទាំងសម្រាប់ស្ថាប័នសាធារណៈ ធុរជន និង ប្រជាជន។ ជាវឌ្ឍនភាព សន្ទស្សន៍នៃភាពប្រកួតប្រជែងសកលរបស់កម្ពុជាត្រូវបានកែលម្អឲ្យប្រសើរឡើងពីចំណាត់ថ្នាក់ទី១១២ ក្នុងចំណោម១១៧ ប្រទេសនៅឆ្នាំ២០០៥ មកចំណាត់ថ្នាក់ទី៩៤ ក្នុងចំណោម១៣៧ប្រទេស នៅឆ្នាំ២០១៧-២០១៨ ។

៤.១៤៩- យ៉ាងណាមិញ ការប្រកួតប្រជែងបាន និង កំពុងជួបបញ្ហាប្រឈមសំខាន់ៗ មួយចំនួនរួមមាន កង្វះក្របខ័ណ្ឌច្បាប់ ក្នុងការលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាព និង ស្មោះត្រង់ សមត្ថភាពកែច្នៃ និង បង្កើតតម្លៃបន្ថែមនៅមានកម្រិត កង្វះពលកម្មជំនាញ និង ប្រសិទ្ធភាពនៃវិស័យគាំទ្រនៅមានកម្រិត។

៤.១៥០- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ៖

ទី១-ការជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង ដែលជាក្របខ័ណ្ឌសម្រាប់ជំរុញការប្រកួតប្រជែង ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម រៀបចំយន្តការសម្រាប់អនុវត្តច្បាប់ និងលើកកម្ពស់វប្បធម៌ប្រកួតប្រជែង។

ទី២-ការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ស្តីពីក្ស័យធន ដែលជំរុញការទទួលយកហានិភ័យ និងការពារសហគ្រិនភាព។

ទី៣-ការជំរុញអនុវត្តយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានសមត្ថភាពអាចទុកចិត្តបាន និងដោះស្រាយជម្លោះធុរកិច្ចដែលអាចទទួលយកបាន។

ទី៤-ការបន្តជំរុញការរៀបចំ និងការអនុវត្តស្តង់ដាទំនិញ សេវា និងការគ្រប់គ្រង ហើយលើកកម្ពស់ស្តង់ដាទាំងនោះជាប្រចាំដើម្បីជំរុញការចាប់យកបច្ចេកវិទ្យាថ្មី និងលើកកម្ពស់គុណភាព។

ទី៥-ការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ និងរៀបចំយន្តការអនុវត្តដើម្បីការពារសិទ្ធិ និងសុវត្ថិភាពអ្នកប្រើប្រាស់ លើកកម្ពស់សុខភាព ពង្រឹងស្តង់ដាទំនិញ និងសេវាព្រមទាំងលើកកម្ពស់ការប្រកួតប្រជែង។

ទី៦-ការពង្រឹងយន្តការជំរុញការប្រកួតប្រជែងដោយស្មើភាព ជាពិសេសក្នុងការបំពេញកាតព្វកិច្ចពន្ធ-អាករ និង ការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៥១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការពង្រឹងការប្រកួតប្រជែង ***ក្រសួងពាណិជ្ជកម្ម*** នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត។ សកម្មភាពសំខាន់ៗរួមមាន៖

ទី១.**កិច្ចការប្រកួតប្រជែង និងការពារអ្នកប្រើប្រាស់៖** ១. ពង្រឹងកិច្ចដំណើរការទប់ស្កាត់រាល់ការបន្លំ ការប៉ុនប៉ងបន្លំលើផលិតផល ក្រៅអំពីបញ្ហាគុណភាព សុវត្ថិភាពតាមគ្រប់រូបភាព និងតាមទីផ្សារទូទាំងប្រទេស ២. បន្តជំរុញប្រសិទ្ធភាពនៃសកម្មភាពគ្រប់គ្រង តាមដានការផ្តល់ព័ត៌មានត្រឹមត្រូវដល់អ្នកប្រើប្រាស់ជាអាទិ៍ ការដាក់ស្លាកសញ្ញាលើផលិតផល ការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផល ការផ្សព្វផ្សាយការលក់ ពិសេសការផ្សាយពាណិជ្ជកម្មភូតកុហក ពង្វាងការពិត ឬធ្វើឲ្យមានការភ័ន្តច្រឡំដល់អ្នកប្រើប្រាស់ ៣. បន្តពិនិត្យបទដ្ឋានតាមលំដាប់ឯកភាព អំពីស្តង់ដាសុវត្ថិភាពម្ហូបអាហារដោយអនុម័តយកស្តង់ដាជាតិ និងស្តង់ដាកូដិចដែលពាក់ព័ន្ធ ៤. បន្តជំរុញសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ការកសាងឯកសារការបណ្តុះបណ្តាល និងផ្សព្វផ្សាយខ្លឹមសារច្បាប់ប្រកួតប្រជែង។

ទី២. បន្តកិច្ចសហការជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងស្រាវជ្រាវលិខិតបទដ្ឋានពាក់ព័ន្ធនឹងក្រសួងយុត្តិធម៌ ដើម្បីជំរុញដំណើរការតុលាការពាណិជ្ជកម្ម។

៤.១៥២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងឧស្សាហកម្ម និង សិប្បកម្ម*** នឹងបន្តការងាររបស់ខ្លួន។ សកម្មភាពសំខាន់ៗរួមមាន៖

- ជំរុញឲ្យមានការរៀបចំផែនការ រយៈពល មធ្យម សម្រាប់អភិវឌ្ឍសប្រាគាសធុនតូច និងមធ្យម ដោយយកំណត់យកមុខសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ខ្សែសង្វាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍសហគ្រាសទាំងនោះ។
- ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់ សហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើ គ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែសង្វាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ។
- ពង្រឹងយន្តការក្រោមដំបូលតែមួយ សម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌ សម្រាប់ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាល។
- បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាព គ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដាដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្តិ និងការទទួលស្គាល់ជាអន្តរជាតិ នូវស្ថាប័នជាតិសំខាន់ៗរួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដាកម្ពុជា។
- កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីឧស្សាហកម្ម តាមរយៈការអនុវត្តនីតិវិធីកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យស្នើសុំ រួមទាំងយកចិត្តទុកដាក់ក្នុងការធ្វើស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម។
- ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចលើផ្នែកស្តង់ដា និងមាត្រាសាស្ត្រក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងការគ្រប់គ្រង។
- ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល និងសិប្បកម្ម។
- ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឲ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់។

- ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសតាមរយៈការពង្រីកសមត្ថភាពអង្គភាពទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេស និងអនុលោមតាមស្តង់ដាទឹកបរិភោគជាតិ។

# ៦- ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន

៤.១៥៣- ទន្ទឹមនឹងការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹង **"គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា"**។

៤.១៥៤- ក្នុងការអនុវត្តកិច្ចការនេះ បញ្ហាប្រឈមសំខាន់ៗរួមមានៈ កំណើនទាបក្នុងវិស័យកសិកម្ម ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត ការរីកចម្រើននៃនគរូបនីយកម្មក្នុងសន្ទុះលឿន ប៉ុន្តែមិនទាន់ធានាបាននូវគុណភាព និង ភាពចាំបាច់ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការណ៍នេះតម្រូវឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ៖ ១. ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ ២. ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ប្រកបដោយចីរភាព ៣. ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង ៤. ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ៦.១- ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៥៥- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺពង្រឹងតួនាទីវិស័យកសិកម្មក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍជនបទ។

៤.១៥៦- យ៉ាងណាក៏ដោយ វិស័យកសិកម្មនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ផលិតភាពនៅមានកម្រិត គុណភាពទាបនៃធាតុចូលកសិកម្ម ការផ្តល់សេវាបច្ចេកទេសមិនទាន់ឆ្លើយតបនឹងតម្រូវការ ការអភិវឌ្ឍខ្សែច្រវាក់ផ្គត់ផ្គង់កសិផលមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារ ការចិញ្ចឹមសត្វ និង វារីវប្បកម្ម នៅមានកម្រិត យន្តការសម្រួលការនាំចេញនៅមិនទាន់មានភាពប្រទាក់ក្រឡា និង បំពេញគ្នាបាន ការបន្តការនាំចូលកសិផល ដែលអាចមានលទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក ប្រព័ន្ធអនាម័យ និង ភូតគាមអនាម័យ នៅមិនទាន់រឹងមាំ មិនទាន់មានយន្តការផ្តល់ព័ត៌មានទីផ្សារកសិកម្ម ដោយផ្សារភ្ជាប់នឹងផែនការដាំដុះ និង ប្រមូលផល ការស្រាវជ្រាវ និង ការអភិវឌ្ឍ នៅមិនទាន់ទូលំទូលាយ ព្រមទាំងការប្រើប្រាស់ដីធ្លីកសិកម្មនៅមិនទាន់អស់សក្តានុពល។ ជាមួយនេះ បញ្ហាប្រឈមផ្នែកអភិវឌ្ឍជនបទ រួមមាន ភាពចាំបាច់ក្នុងការបន្ត

លើកកម្ពស់គុណភាព និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ការទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព និង ការជំរុញការលើកកម្ពស់អនាម័យជនបទ។

៤.១៥៧- លើមូលដ្ឋាននេះ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោត អាទិភាពលើ៖

ទី១-ការជំរុញការរៀបចំ និង ដាក់ឲ្យអនុវត្ត **"ផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ ២០៣០"** និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មឆ្នាំ ២០១៩-២០២៣"**។

ទី២-ការបន្តជំរុញការរៀបចំ អនុម័ត និង ការអនុវត្ត **"ច្បាប់ស្តីពីការការពាររុក្ខជាតិ និង ភូតគាមអនាម័យ"** និង **"ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា"**។

ទី៣-ការបង្កើនផលិតភាព គុណភាព និង ពិពិធកម្ម តាមរយៈការបង្កើនការវិនិយោគលើការស្រាវជ្រាវ និង ការអភិវឌ្ឍពូជដំណាំ ពូជសត្វ និង ការចិញ្ចឹមត្រី ដែលផ្តល់តម្លៃបន្ថែមខ្ពស់ ការជំរុញការអភិវឌ្ឍកសិដ្ឋានគំរូ ការជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្ម ការពង្រឹងការគ្រប់គ្រងសហគមន៍កសិករ ការរៀបចំយន្តការ ផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបន្តកាត់បន្ថយថ្លៃ និង ពង្រឹងគុណភាពនៃធាតុចូលកសិកម្ម ការសិក្សារៀបចំឲ្យមានសេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ការរៀបចំឲ្យមានផលិតផលហិរញ្ញវត្ថុសម្រាប់ផលិតកម្មកសិកម្ម និង ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាត និង ឌីជីថល។

ទី៤-ការលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញឲ្យមានការវិនិយោគឯកជនលើកសិផលដែលមានសក្តានុពល ដូចជា ស្រូវ ដំឡូងមី ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ បន្លែ ជាដើម តាមរយៈការរៀបចំយុទ្ធសាស្ត្រ តាមមុខដំណាំនីមួយៗ។

ទី៥-ការបន្តជំរុញការដាំបន្លែគ្រប់ប្រភេទជំនួសឲ្យការនាំចូល និង ការរៀបចំបង្កើតទីផ្សារបោះដុំ និង ចែកចាយបន្លែ ដែលមានស្តង់ដា និង អនាម័យខ្ពស់។

ទី៦-ការជំរុញពាណិជ្ជបនីយកម្មកសិកម្ម តាមរយៈការបន្តពង្រឹងប្រព័ន្ធអនាម័យ និង ភូតគាមអនាម័យ SPS ការសម្រួលពាណិជ្ជកម្ម ការវិនិយោគ បន្ថែមលើមន្ទីរពិសោធន៍គុណភាពសម្រាប់ការនាំចេញ ព្រមទាំងការជំរុញការផលិត និង ប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុក។

ទី៧-ការជំរុញការចិញ្ចឹមសត្វ និង វារីវប្បកម្ម តាមរយៈការបន្តអនុវត្ត **"ច្បាប់ស្តីពីសុខភាពសត្វ និង ផលិតកម្មសត្វ"** **"ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វ ឆ្នាំ ២០១៦-២០២៥"** និង **"ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍវារីវប្បកម្មឆ្នាំ ២០១៦-២០៣០"**។

ទី៨-ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបន្តជំរុញការបោសសម្អាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ និង ការបន្តផ្តល់ដីសម្បទានសង្គមកិច្ច ពិសេសដល់គ្រួសារក្រីក្រ សម្រាប់ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

ទី៩-ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដោយយកចិត្តទុកដាក់លើការបង្កើនការតភ្ជាប់ទៅនឹងផលិតកម្មកសិកម្ម ការថែទាំជាប្រព័ន្ធនិងការពង្រឹងការគ្រប់គ្រង។

ទី១០-ការបន្តជំរុញការអភិវឌ្ឍជនបទឲ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី ការពង្រីកការទទួលបានទឹកស្អាត ការលើកកម្ពស់អនាម័យ ការរៀបចំភូមិនិងលំនៅឋាន ព្រមទាំងការលើកកម្ពស់ជីវភាពប្រជាជន តាមរយៈការបន្តអនុវត្ត **"ចលនាភូមិមួយ-ផលិតផលមួយ"** និង **"ចលនាភូមិថ្មី"** ។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៥៨- ដើម្បីចូលរួមអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការលើកកម្ពស់ឧស្សាហកម្មកែច្នៃតាមរយៈការជំរុញការវិនិយោគឯកជនលើកសិផលដែលមានសក្តានុពល ***ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*** នឹងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ចូលរួមពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ព្រមទាំងពិនិត្យផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ។
- សហការរៀបចំវេទិកាធុរកិច្ច និងវិនិយោគដើម្បីទាក់ទាញអ្នកវិនិយោគឲ្យបានច្រើនក្នុងវិស័យកែច្នៃកសិ-ឧស្សាហកម្ម។
- ចូលរួមពិនិត្យ និងពិភាក្សាលើគោលនយោបាយលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលវិនិយោគលើឧស្សាហកម្មកែច្នៃកសិផល។
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការបង្កើតតំបន់ផលិតកែច្នៃនាំចេញកសិផល។
- ចូលរួមរៀបចំ និងបង្កើតយុទ្ធសាស្ត្រនិងផែនការមេសម្រាប់អភិវឌ្ឍតំបន់កែច្នៃកសិ-ឧស្សាហកម្ម។

៤.១៥៩- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- **បង្កើនផលិតភាពផលិតកម្ម៖** ១. បន្តអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច៖ គម្រោងមានវិសាលភាពគ្របដណ្តប់លើខេត្តចំនួន១៧ និងផលិតផល៥ប្រភេទគឺ ស្រូវក្រអូប បន្លែ មាន់ស្រែ ដំឡូងមី និងសសៃសូត្រ ២. បន្តលើកកម្ពស់ផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដើម្បីធ្វើឲ្យផលិតផលកម្ពុជាប្រើប្រាស់ជំនួសការនាំចូល និងឈានទៅការនាំចេញទៅលក់នៅលើកទីផ្សារបរទេស ៣. បន្តយុទ្ធនាការទិញផលិតផលខ្មែរក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយបានរៀបចំនៅបណ្តាខេត្តទាំងអស់នៅកម្ពុជា និងចូលរួមពិព័រណ៍អន្តរជាតិ ក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់និងពិភពលោក ៤. អភិវឌ្ឍស្ថាប័ន

ក្នុងវិស័យឯកជន តាមរយៈការបង្កើតឲ្យមានសភាពាណិជ្ជកម្ម សមាគមអាជីវកម្ម នៅទូទាំងរាជធានី ខេត្ត ។

- ពង្រឹងនិងពង្រីកនូវសន្តិសុខស្បៀង៖ ១. បន្តពង្រឹង និងថែរក្សាស្តុកយុទ្ធសាស្ត្រស្បៀងត្រៀមបម្រុងសម្រាប់ចូលរួមអន្តរាគមន៍សង្គ្រោះដល់ជនរងគ្រោះ ដោយទឹកជំនន់ ខ្យល់ព្យុះ និងអន្តរាយផ្សេងៗ ២. បន្តនិងពង្រឹងធានានូវស្ថេរភាពតម្លៃអង្ករទីផ្សារក្នុងស្រុក ដើម្បីរក្សានូវផលប្រយោជន៍ជីវភាពរស់នៅរបស់ប្រជាជន និងទប់ស្កាត់ជនឆ្លៀតឱកាសធ្វើឲ្យចលាចលនៅលើទីផ្សារ ៣. បន្តទិញចូល និងលក់ចេញអង្ករ និង ៤. បន្តធ្វើការចរចាពាណិជ្ជកម្មទ្វេភាគី ជាមួយទីផ្សារអង្ករមានស្រាប់រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលស្ដីពីការធ្វើពាណិជ្ជកម្មអង្ករ ។

៤.១៦០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាព រួមមាន៖

ទី១-បន្តលើកកម្ពស់ការស្រាវជ្រាវ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប ក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្ម ប្រកបដោយនិរន្តរភាព ក្នុងបរិបទការប្រែប្រួលអាកាសធាតុ និងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ។

ទី២-ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងការចិញ្ចឹមសត្វដែលបានចុះបញ្ជីរួចហើយឲ្យមានលក្ខណៈជាជំនាញអាជីព ដោយជំរុញឲ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់សន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែតម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាង ***រដ្ឋ ឯកជន និងសហគមន៍កសិកម្ម*** ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាពតាមរយៈការជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូចជាដើម។

ទី៣-ពង្រឹង និងពង្រីកសហគមន៍កសិករកៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករ ទាំងការដាំដុះ ការយកផល ការកែច្នៃ ព្រមទាំងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ។

ទី៤-ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការ

កែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ស្តង់ដាគុណភាព ក៏ដូចជាពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ។

ទី៥-ជំរុញការចិញ្ចឹមសត្វរបស់កសិករឲ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។

ទី៦- បង្កើតស្ថានីយ៍ចត្តាឡីស័ក ដំណាំ សត្វ និងផលផល នៅតាមតំបន់ជាប់ព្រំដែនសំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី និងទប់ស្កាត់ ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មមិនមានគុណភាព និងសុវត្ថិភាព ដែលនាំឲ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។

ទី៧-ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទ ដែលបានបង្កើតឡើងរួចហើយឲ្យបានរឹងមាំក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។

ទី៨-ធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ ឆ្លើយតបនឹងស្ថានភាពក្នុងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍវិស័យព្រៃឈើជាតិយូរអង្វែង។

ទី៩-បន្តប្រើប្រាស់កម្លាំងសរុប ចុះស្រាវជ្រាវ រុករក និងបង្ក្រាបបទល្មើសជលផល និងការកាប់រាន ដុត ឈូសឆាយដីព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ អយ្យការ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំដែនព្រៃ លិចទឹកឲ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឲ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃលិចទឹក និងដីព្រៃឈើជាដើម។

ទី១០-ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍនានាទាំងក្នុងក្របខ័ណ្ឌពហុភាគី ទ្វេភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ ព្រមទាំងខិតខំបង្កើនកិច្ចសហប្រតិបត្តិការ និងធ្វើការចរចាដើម្បីស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្មឲ្យបានទូលំទូលាយជាមួយប្រទេសនានា ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។

៤.១៦១- ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*** បានកំណត់កម្មវិធីចំនួន ៥ រួមមាន៖

### *១. បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម*

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម៧%ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាព ពិពិធកម្មដំណាំ

ដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់ ដូចមានសកម្មភាពអាទិភាពសំខាន់ៗខាងក្រោម៖

- ជំរុញផលិតកម្ម និងផលិតភាពដំណាំដែលមានសក្តានុពលទីផ្សារខ្ពស់។
- លើកកម្ពស់ការការពារដំណាំ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។
- លើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍សហគមន៍កសិកម្ម។
- ការស្រាវជ្រាវនិងការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។
- លើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម។
- ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព។
- ការកសាងនិងអនុវត្តគម្រោងពាក់ព័ន្ធគោលនយោបាយអន្តរវិស័យ។

### ២. ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

ជំរុញផលិតកម្មសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងការអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានិភ័យជំងឺឆ្លងសត្វ និងពង្រឹងការត្រួតពិនិត្យ អនាម័យសត្វ និងផលិតផលសត្វ ដូចមានសកម្មភាពអាទិភាពសំខាន់ៗខាងក្រោម៖

- ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ។
- ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈ បសុព្យាបាល និងសុខុមាលភាពសត្វ។
- លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា។
- ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។
- បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។
- លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន។
- ពង្រឹងសេវាផ្សព្វផ្សាយស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងការអភិវឌ្ឍទីផ្សារ និង
- ពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស កម្រិតជាតិនិងអន្តរជាតិលើអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ។

### ៣. ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម

បង្កើនការគ្រប់គ្រងធនធានជលផលឲ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល រក្សាការចាប់ផលនេសាទពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ បង្កើនផលវារីវប្បកម្ម២០%ក្នុងមួយឆ្នាំ និងធ្វើឲ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង ដូចមានសកម្មភាពអាទិភាពសំខាន់ៗខាងក្រោម៖

- ពង្រឹងការនេសាទ ការគ្រប់គ្រង និងការអភិរក្សធនធានជលផល។
- អភិវឌ្ឍន៍វារីវប្បកម្មទឹកសាបនិងសមុទ្រ។
- ការគ្រប់គ្រង និងអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃជលផល។
- ការស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានជលផល។

- ពង្រឹងសមត្ថភាពអង្គភាព និងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកជលផល។

### ៤. ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ

បង្កើនការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយចីរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំដុះព្រៃឈើឡើងវិញ បង្កើនការស្រាវជ្រាវ និងអភិឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ ព្រមទាំងពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើឲ្យមានជីវភាពកាន់តែប្រសើរឡើង ដូចមានសកម្មភាពអាទិភាពសំខាន់ៗខាងក្រោម៖

- គ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ។
- ពង្រឹងការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ។
- គ្រប់គ្រងឧទ្យានសួនសត្វនិងសង្គ្រោះថែរក្សាសត្វព្រៃ។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ។
- ពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រអង្គភាព។

### ៥. បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព ដូចមានសកម្មភាពអាទិភាពសំខាន់ៗខាងក្រោម៖

- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ផ្តល់សេវាគាំទ្រនានា និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម តាមរយៈជំរុញការអនុវត្តថវិកាកម្មវិធី ពង្រឹងប្រព័ន្ធព័ត៌មានវិទ្យាក្នុងការរៀបចំផែនការ គ្រប់គ្រងតាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធី ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងលើកកម្ពស់គុណភាពអប់រំកសិកម្ម។
- លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការវិនិយោគឯកជន ដើម្បីចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីទទួលបានព័ត៌មានកាន់តែងាយស្រួល ទាំងការយល់ដឹងពីបច្ចេកទេសក្នុងការផលិតព័ត៌មានទីផ្សារ ខ្សែច្រវាក់តម្លៃ និងព័ត៌មានកសិកម្មផ្សេងៗទៀត។
- ជំរុញការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយគាំទ្រវិស័យកសិកម្ម
- ជំរុញការវិនិយោគលើការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់ចំណេះដឹងលើបច្ចេកទេសនិងបន្តរៀបចំរចនាសម្ព័ន្ធសម្រាប់គាំទ្រ ដោយបង្កើនសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ ឲ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យកសិកម្មស្រុក សំដៅសម្រេចបាននូវការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។
- រៀបចំនិងដាក់ឲ្យអនុវត្តនូវបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មកម្ពុជា ដើម្បីបង្កើនប្រសិទ្ធភាព នៃការសិក្សាស្រាវជ្រាវកសិកម្មនៅកម្ពុជា។
- លើកកម្ពស់ប្រសិទ្ធភាពនៃការចូលរួមក្នុងការទប់ស្កាត់ និងលុបបំបាត់នូវរាល់សកម្មភាពជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀតក្នុងវិស័យកសិកម្ម ដែលបង្កជាផលប៉ះពាល់

ដល់ការគ្រប់គ្រង និងអភិវឌ្ឍដល់វិស័យកសិកម្ម ដើម្បីធានាអោយបាននូវសុវត្ថិភាពស្បៀង និងនិរន្តរភាពនៃធនធានធម្មជាតិយើង។

## តារាងទី ៤.១១ សូចនាករសំខាន់នៃវិស័យកសិកម្ម

| ល.រ | សូចនាករលទ្ធផល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ១ | ទិន្នផលស្រូវ (តោន/ហិកតា) | ៣,៣៥ | ៣,៣៧ | ៣,៣៩ | ៣,៤១ | ៣,៤៤ |
| ២ | អនុបាត % ពិពិធកម្មដំណាំ ធៀបទៅនឹងផ្ទៃដីស្រូវ | ៦៣,៤៤ | ៦៤,៥៥ | ៦៥,៦៥ | ៦៦,៧៣ | ៦៧,៧៩ |
| ៣ | តម្លៃបន្ថែមក្នុងវិស័យកសិកម្ម ប្រចាំឆ្នាំ (ប៊ីលានរៀល) | ២២ ៦១០ | ២៣ ៥១៥ | ២៤ ២២០ | ២៤ ៩៤០ | ២៥ ៦៩០ |
| ៤ | ប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយកសិកម្ម ដល់គ្រួសារកសិករ (%) | ៣៥ | ៣៧ | ៤០ | ៤២ | ៤៣ |
| ៥ | បរិមាណផលដំណាំកសិកម្មសរុបប្រចាំឆ្នាំ (លានតោន) | ២៩,៩៣ | ៣១,៤៨ | ៣៣,១៤ | ៣៤,៩០ | ៣៦,៧៧ |
| ៦ | បរិមាណផលិតផលកសិកម្មនាំចេញប្រចាំឆ្នាំ (លានតោន) | ៥,៨៧ | ៦,២៩ | ៦,៧៣ | ៧,២០ | ៧,៧០ |
| ៧ | ផលិតផលសាច់សត្វសរុប (ពាន់តោន) | ២៤០ | ២៤៧ | ២៥៤ | ២៦២ | ២៧០ |
| ៨ | ផលិតកម្មកៅស៊ូប្រចាំឆ្នាំ (ពាន់តោន) | ២៩២,០០ | ២៥៣,០០ | ៣៩៥,០០ | ៤១២,០០ | ៤១៧,០០ |
| ៩ | បរិមាណផលនេសាទចាប់ពីធម្មជាតិ ប្រចាំឆ្នាំ (ពាន់តោន) | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ |
| ១០ | បរិមាណផលិតផលវារីវប្បកម្ម ប្រចាំឆ្នាំ (ពាន់តោន) | ២៩៨,៧ | ៣៥៨,៥ | ៤៣០,១ | ៥១៦,២ | ៦១៩,៤ |
| ១១ | ផលនេសាទនិងផលិតផលវារីវប្បកម្មនាំចេញប្រចាំឆ្នាំ (ពាន់តោន) | ២០ | ២០ | ៣០ | ៥០ | ៥០ |
| ១២ | បរិមាណផលឈើដាំត្រូវបានប្រមូល (ពាន់ម៉ែត្រគូប/ឆ្នាំ) | ២០០ | ២២៥ | ២៥០ | ២៧៥ | ៣០០ |
| ១៣ | ផ្ទៃដីដំណាំស្រូវដែលធន់នឹងអាកាសធាតុ (លានហិកតា) | ១,២ | ១,២៣ | ១,២៦ | ១,២៩ | ១,៣២ |

*ប្រភព:* ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៤.១៦២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាពរបស់ ***ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥*** ដើម្បីពន្លឿនការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមឆ្ពោះទៅសម្រេចបានចក្ខុវិស័យសកម្មភាពមីន ***"ឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីនឆ្នាំ២០២៥"*** រួមមាន៖

**គោលបំណងទី១៖** រំដោះផ្ទៃដីដែលដឹងថាមានមីនឲ្យអស់នៅត្រឹមឆ្នាំ២០២៥

- បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិ សម្រាប់បណ្ដាស្រុកដែលនៅសេសសល់ទាំងអស់ ត្រឹមឆ្នាំ២០២០។
- អនុវត្តការរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យផ្ទៃដីដែលមានមីន។
- រំដោះផ្ទៃដីក្នុងភូមិអាទិភាព ដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសេសសល់ ផ្សេងៗទៀតនៅត្រឹមឆ្នាំ២០២៥។
- ពិនិត្យឡើងវិញនិងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់។

**គោលបំណងទី២៖** រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥

- រៀបចំផែនការនិងចាត់អាទិភាពតំបន់ដែលមានគ្រាប់បែកចង្កោម។

- ធ្វើការស្រាវជ្រាវនិងរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោម។

**គោលបំណងទី៣៖** ដោះស្រាយបញ្ហាគំរាមកំហែងបណ្តាលមកពីស.ផ.ស.ផ្សេងទៀត

- ស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមានស.ផ.ស.។
- ផ្តល់ការឆ្លើយតបទាន់ពេលវេលានៅពេលមានសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះពីសំណាក់សហគមន៍និងអាជ្ញាធរ។

**គោលបំណងទី៤៖** កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស.ផ្សេងទៀតឲ្យនៅកម្រិតអប្បបរមាព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារគ្រាប់មីននិងស.ផ.ស.

- ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់មីននិងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជននៅតាមតំបន់ដែលមានហានិភ័យនាពេលបច្ចុប្បន្ន និងតំបន់មានហានិភ័យកើតឡើងថ្មី។
- ផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារមីននិងស.ផ.ស. និងជនរងគ្រោះដោយប្រយោលឲ្យទទួលបាននូវសេវាថែទាំសុខភាព និងផ្លូវចិត្តគ្រប់គ្រាន់ និងសមស្របទៅតាមយេនឌ័រព្រមទាំងការស្តារលទ្ធភាពពលកម្ម កាយសម្បទា។
- លើកកម្ពស់សមត្ថភាពប្រកបរបរចញ្ចឹមជីវិត សម្រាប់អ្នករស់រានមានជីវិតដោយសារគ្រោះថ្នាក់ពីមីននិង ស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលដើម្បីលើកកម្ពស់ការចូលរួមពេញលេញនៅក្នុងសង្គម។

**គោលបំណងទី៥៖** រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

- គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីនគ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត។
- គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**គោលបំណងទី៦៖** ជំរុញនិសព្វាវុធការនិងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់និងអន្តរជាតិក្នុងសកម្មភាពមីន

- ជំរុញការអនុវត្តកាតព្វកិច្ចនៃអនុសញ្ញាអន្តរជាតិស្តីពីការហាមប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន(អ.ហ.ផ.ម.) និងអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន គាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥
- ចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម និងគាំទ្រប្រតិបត្តិការបោសសម្អាតមីនក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិក្នុងសកម្មភាពមីន រួមមានកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង។

**គោលបំណងទី៧៖** បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាពដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥

- ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រងនិងអនុវត្តកម្មវិធីសកម្មភាពមីនឲ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល។

- ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះ និងដល់វិស័យផ្សេងៗទៀត។
- ធ្វើការពិនិត្យមើលឡើងវិញនៅត្រឹមឆ្នាំ២០២០ ទៅលើក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រ និងសមត្ថភាព ដែលត្រូវការចាំបាច់សម្រាប់ដោះស្រាយរាល់បញ្ហាគំរាមកំហែងដែលនៅសេសសល់។
- កសាង ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពរាល់បញ្ហាគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥។

**គោលបំណងទី៨៖** ធានាថាសកម្មភាពមីនត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាព ដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានដែលមានប្រសិទ្ធភាព ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់អំពីយេនឌ័រ និងការការពារបរិស្ថាន

- ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព និងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន។
- ជំរុញការបញ្ជ្រាបយេនឌ័រ និងការការពារបរិស្ថាននៅក្នុងសកម្មភាពមីន។
- អនុវត្តប្រព័ន្ធត្រួតពិនិត្យសកម្មភាពមីន។

### តារាងទី ៤.១២ សូចនាករក្នុងវិស័យសកម្មភាពមីន ឆ្នាំ២០១៩-២០២៣

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ចំនួនជនរងគ្រោះដោយសារមីននិងស.ផ.ស. (របួស/ស្លាប់) | នាក់ | ៥៨ | ៥២ | ៤៧ | ៤២ | ៣៨ | ៣០ |
| ចំនួនជនរងគ្រោះដោយសារការលេង និងច្នៃគ្រាប់មីននិងស.ផ.ស. (ស្លាប់/របួស) | នាក់ | ៤១ | ៣៧ | ៣៣ | ៣០ | ២៧ | ២០ |
| ចំនួនជនពិការដោយសារមីន/ស.ផ.ស. ទទួលបានការផ្សព្វផ្សាយពីសិទ្ធិ | នាក់ | ២៥៦ | ២៦០ | ២៦០ | ២៦០ | ២៦០ | ២៦០ |
| ចំនួនជនពិការដោយសារមីន/ស.ផ.ស. ទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា | នាក់ | ២ ៦៨៣ | ២ ៧០០ | ២ ៧០០ | ២ ៧០០ | ២ ៧០០ | ២ ៧០០ |
| ចំនួនជនពិការដោយសារមីន/ស.ផ.ស.ដែលទទួលបានការចូលរួមចំណែកឧបត្ថម្ភពីអាជ្ញាធរមីន | នាក់ | ១២៤ | ១២៥ | ១២៥ | ១២៥ | ១២៥ | ១២៥ |
| **សរុបផ្ទៃដីបោសសម្អាតមីននិងស.ផ.ស.** | **ហ.ត.** | **២១ ៤០០** | **២១ ៤០០** | **២១ ៤០០** | **២១ ៤០០** | **២១ ៤០០** | **២១ ៤០០** |
| ផ្ទៃដីបោសសម្អាតមីន | ហ.ត. | ១១០០០ | ១១០០០ | ១១០០០ | ១១០០០ | ១១០០០ | ១១០០០ |
| ផ្ទៃដីបោសសម្អាតស.ផ.ស. | ហ.ត. | ១០៤០០ | ១០៤០០ | ១០៤០០ | ១០៤០០ | ១០៤០០ | ១០៤០០ |

៤.១៦៣- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងធនធានទឹក និង ឧតុនិយម*** នឹងត្រូវផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រ៥ផ្នែក គឺ៖

- កែលម្អការគ្រប់គ្រងរដ្ឋបាលនិងការអភិវឌ្ឍធនធានមនុស្ស

- គ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ
- គ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត និងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម
- ការពារនិងការអភិរក្សធនធានទឹក

៤.១៦៤- ***កែលម្អការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- ពង្រឹងដំណើរការរដ្ឋបាល និងផ្តល់ការបណ្តុះបណ្តាលក្នុងការងារដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឆ្លើយតបទៅនឹងកម្រិតស្តង់ដាជាតិនិងអន្តរជាតិ។
- បន្តពង្រឹងសមត្ថភាពរបស់មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងសមត្ថភាពរបស់សហគមន៍កសិករ ប្រើប្រាស់ទឹកឲ្យយល់ដឹងពីអត្ថប្រយោជន៍របស់ទឹកចំពោះជីវភាពប្រចាំថ្ងៃ និងណែនាំពួកគាត់ឲ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការគ្រប់គ្រង ការថែទាំការអភិរក្ស និងការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាពនិងចីរភាព ដើម្បីរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីល្អ ។
- បង្កើតប្រព័ន្ធការងារយេនឌ័រ នៅគ្រប់មន្ទីរធនធានទឹក និងឧតុនិយម រាជធានី ខេត្ត។
- បង្កើនការយល់ដឹងនិងការវិភាគពីយេនឌ័រ នៅគ្រប់រាជធានី ខេត្ត។
- ធានាឲ្យមានការចូលរួមរបស់ក្រុមការងារយេនឌ័រ នៅក្នុងគ្រប់ទិដ្ឋភាពការងាររបស់ក្រសួងធនធានទឹក និងឧតុនិយម។
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងគ្រប់គ្រងដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយមទាំងបុរសនិងស្ត្រី ដើម្បីអនុវត្តវិធីសាស្ត្រនៃបច្ចេកវិទ្យាស្រោចស្រពនិងដោះទឹក។

៤.១៦៥- **ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹក និងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ** ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ស្តារឡើងវិញនិងសាងសង់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ក្នុងគោលបំណងឆ្លើយតបជាបន្ទាន់នូវតម្រូវការទឹកសម្រាប់កសិកម្ម។
- ផ្តល់អាទិភាពខ្ពស់ដល់ការស្តារឡើងវិញនិងសាងសង់ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកនៅតាមតំបន់ដែលភាពក្រីក្រមានកម្រិតខ្ពស់។
- ជំរុញការថែទាំនិងពង្រីកបន្ថែមនូវអាងតម្កល់ទឹក ស្រះទឹក ប្រឡាយនាំទឹកនិងប្រព័ន្ធដោះទឹកដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកសម្រាប់ផ្ទៃដីបង្កបង្កើនផល វារីវប្បកម្ម ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនិងសត្វពាហនៈ។
- ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្របមួយក្នុងតំបន់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀង។
- ជីកនិងស្តារប្រឡាយជើងក្អែបដើម្បីប្រព័ន្ធធារាសាស្ត្រមានលក្ខណៈពេញលេញសម្រាប់បង្ហូរទឹកចូលដល់ស្រែរបស់ប្រជាកសិករ។
- បង្កើតសហគមន៍កសិករប្រើប្រាស់ទឹកនៅតាមប្រព័ន្ធធារាសាស្ត្រដែលបានសាងសង់រួច។

- ជំរុញការសិក្សា និងរៀបចំផែនការអភិវឌ្ឍន៍អាងទន្លេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ការប្រែប្រួលធារទឹកទន្លេ ការផ្លាស់ប្តូរចរន្តទឹក និងល្អាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ការប្រើប្រាស់ធនធានទឹកនាពេលបច្ចុប្បន្ននិងពេលអនាគត។
- អនុវត្តវិធីសាស្ត្រចម្រុះចំពោះការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកដោយគិតគូរឲ្យបានច្បាស់លាស់ពីប្រភពទឹក ការផ្សារភ្ជាប់គ្នារវាងធនធានទឹកជាមួយនឹងផ្នែកផ្សេងទៀតនៃបរិស្ថានការប្រែប្រួលនូវតម្រូវការរបស់មនុស្ស និងបរិស្ថានមកលើធនធានទឹក ព្រមទាំងតម្រូវការនូវវិធីសាស្ត្រនានាក្នុងការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។
- បង្កើនការយល់ដឹង និងជំរុញការរៀបចំការអនុវត្តផែនការគ្រប់គ្រងនិងផែនការអភិវឌ្ឍអាងទន្លេ ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ អ្នកពាក់ព័ន្ធ និងអ្នកទទួលផល ជាពិសេសស្ត្រី។
- ប្រមូលផ្តុំនិងជំរុញឲ្យមានការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹក អ្នកទទួលផលជាពិសេសកសិករស្ត្រីនិងផ្នែកឯកជននៅគ្រប់ដំណាក់កាលនៃការរៀបចំគម្រោង ការកែលម្អការអភិវឌ្ឍនិងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធដោះទឹក។
- បង្កើនសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹកស្តីពីរបៀបគ្រប់គ្រង ថែទាំ និងកិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល។
- បន្តពង្រឹងនិងរៀបចំបន្ថែមនូវសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីចូលរួមក្នុងការគ្រប់គ្រងទឹក បែងចែកទឹក និងថែរក្សាប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរក្សាបាននូវនិរន្តរភាព។
- ជំរុញការវិនិយោគពីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ព្រមទាំងផ្នែកឯកជនដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល។
- បង្កើនប្រាក់ចំណូលតាមរយៈផ្នែកធារាសាស្ត្រកសិកម្ម និងធានាបន្តការវិនិយោគក្នុងវិស័យធនធានទឹកសម្រាប់ការផលិតដំណាំ។

## តារាងទី ៤.១៣ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក រួមទាំងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ

| សូចនាករ | ឯកតា | ឆ្នាំ២០១៨ ជាក់ស្តែង | ឆ្នាំ២០១៩ ព្យាករណ៍ | ឆ្នាំ២០២០ ព្យាករណ៍ | ឆ្នាំ២០២១ ព្យាករណ៍ | ឆ្នាំ២០២២ ព្យាករណ៍ | ឆ្នាំ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| ១.បង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវ (ប្រាំង+វស្សា) | ហិកតា | ១ ៨០២ ៣៥៩ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | ហិកតា | | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ | ៣០ ០០០ |
| +សរុបបន្តបន្ទាប់ | ហិកតា | | ១ ៨៣២ ៣៥៩ | ១ ៨៦២ ៣៥៩ | ១ ៨៩២ ៣៥៩ | ១ ៩២២ ៣៥៩ | ១ ៩៥២ ៣៥៩ |
| ២.បង្កើនលទ្ធភាពស្រោចស្រពដំណាំរួមផ្សំ | ហិកតា | ៤ ៤១៣ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | ហិកតា | | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| +សរុបបន្តបន្ទាប់ | ហិកតា | | ៤ ៩១៣ | ៥ ៤១៣ | ៥ ៩១៣ | ៦ ៤១៣ | ៦ ៩១៣ |
| ៣.បង្កើត និងពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក | កន្លែង | ៥៤៤ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | កន្លែង | | ៧ | ៧ | ៧ | ៧ | ៧ |
| +សរុបបន្តបន្ទាប់ | កន្លែង | | ៥៥១ | ៥៥៨ | ៥៦៥ | ៥៧២ | ៥៧៩ |

*ប្រភព :* ក្រសួងធនធានទឹកនិងឧតុនិយម

៤.១៦៦- **ការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត** ***ក្រសួងធនធានទឹក និងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ជំរុញនិងយកចិត្តទុកដាក់លើ ការសិក្សានិងការសាងសង់ ទំនប់ការពារទឹកជំនន់ព្រមទាំងប្រឡាយដោះទឹក ក្នុងគោលបំណងកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះធម្មជាតិដែលបណ្តាលមកពីទឹក។
- អនុវត្តគ្រប់សកម្មភាពទាំងអស់ ដើម្បីកាត់បន្ថយទឹកជំនន់នៅគ្រប់តំបន់ ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ តាមរយៈការអប់រំដល់សហគមន៍ និងការផ្តល់ព័ត៌មានជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។
- ឆ្លើយតបជាបន្ទាន់ចំពោះតម្រូវការរបស់ប្រជាជននៅតំបន់ដែលទទួលរងពីគ្រោះរាំងស្ងួតគ្រោះទឹកជំនន់និងគ្រោះមហន្តរាយផ្សេងទៀតដែលបង្កឡើងដោយសារទឹក។
- បន្តលើកទឹកចិត្តដល់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ស្ថាប័នឲ្យចូលរួមក្នុងសកម្មភាពកាត់បន្ថយឥទ្ធិពលនៃគ្រោះទឹកជំនន់ ដូចជាការរៀបចំទីទួលសុវត្ថិភាព ការផ្គត់ផ្គង់សម្ភារបរិក្ខារ គ្រឿងចក្រ ការផ្តល់ការអប់រំ និងចូលរួមក្នុងកម្មវិធីជាតិ និងអន្តរជាតិនានាដើម្បីកាត់បន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយដែលបង្កឡើងដោយសារទឹក។
- សាងសង់ស្ថានីយបូមទឹក ជួសជុលស្ថានីយបូមទឹក និងជួសជុលម៉ាស៊ីនបូមទឹក។
- ត្រៀមលក្ខណៈចុះធ្វើអន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវប្រាំងនិងស្រូវវស្សា ពេលជួបការខ្វះខាតទឹក និងគ្រោះរាំងស្ងួតជូនប្រជាកសិករគ្រប់ខេត្ត ជាពិសេស តំបន់នៅជិតប្រភពទឹកហើយគ្មានប្រព័ន្ធស្រោចស្រពទៅដល់។

- រៀបចំផែនទីបង្ហាញតំបន់រងគ្រោះដោយសារទឹកជំនន់។
- ស្តារព្រែកនាំដីល្បាប់ដើម្បីកាត់បន្ថយទឹកជំនន់។

### តារាងទី ៤.១៤ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

| សូចនាករ | ឯកតា | ឆ្នាំ២០១៨ ជាក់ស្តែង | ឆ្នាំ២០១៩ ព្យាករណ៍ | ឆ្នាំ២០២០ ព្យាករណ៍ | ឆ្នាំ២០២១ ព្យាករណ៍ | ឆ្នាំ២០២២ ព្យាករណ៍ | ឆ្នាំ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ១.កាត់បន្ថយ និងការពារ ទប់ស្កាត់ទឹកជំនន់ | ហិកតា | ១៣៩ ១៥៦ | រក្សានិរន្តរភាពនិងបង្កើនការការពារផ្ទៃដីកសិកម្ម ការពារទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ជាតិ | | | | |
| ២.កាត់បន្ថយ និងការពារ ទប់ស្កាត់ទឹកប្រៃ | ហិកតា | ២១ ០៤៣ | រក្សានិរន្តរភាពនិងបង្កើនការការពារផ្ទៃដីកសិកម្ម និងដំណាំគ្រប់ប្រភេទ | | | | |
| ៣.ត្រៀមជួយសង្គ្រោះដំណាំស្រូវ ពេលរាំងស្ងួត និងខ្វះទឹក | ហិកតា | ៩៣ ២៨៧ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ |
| ៤.សាងសង់ស្ថានីយបូមទឹក | កន្លែង | ៣១ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | កន្លែង | | ៥ | ៥ | ៥ | ៥ | ៥ |
| +សរុបបន្តបន្ទាប់ | កន្លែង | | ៣៦ | ៤១ | ៤៦ | ៥១ | ៥៦ |
| ៥.ជួសជុលស្ថានីយបូមទឹក ក្នុងឆ្នាំនីមួយៗ | កន្លែង | | ៩ | ៩ | ៩ | ៩ | ៩ |
| ៦.ជួសជុលម៉ាស៊ីនបូមទឹក ក្នុងឆ្នាំនីមួយៗ | កន្លែង | | ១៨ | ១៨ | ១៨ | ១៨ | ១៨ |

*ប្រភព :* ក្រសួងធនធានទឹកនិងឧតុនិយម

៤.១៦៧- **ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម** ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បន្តពង្រឹងនិងបង្កើនប្រព័ន្ធឧតុនិយម និងជលសាស្ត្រ រួមទាំងការប្រមូលផ្តុំព័ត៌មាននិងការផ្សព្វផ្សាយ។
- ធ្វើការព្យាករ និងប្រកាសភាពអាសន្នដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រងគ្រោះពីភាពរាំងស្ងួត ទឹកជំនន់ និងព្យុះ សម្រាប់រយៈពេលខ្លី មធ្យម និងវែង។
- កែលម្អនិងសាងសង់ស្ថានីយឧតុនិយមនិងជលសាស្ត្រ ព្រមទាំងប៉ុស្តិ៍តម្រងទឹកភ្លៀង និងក្តារម៉ែត្រវាស់កម្ពស់ទឹក នៅតាមទីតាំង និងស្ទឹងសំខាន់ៗ។
- ដំឡើងប្រព័ន្ធអង្កេតជលសាស្ត្រ ដើម្បីផ្តល់នូវកម្រិតកម្ពស់ទឹកជាក់លាក់ និងទិន្នន័យធារទឹក សម្រាប់ការព្យាករទឹកជំនន់ និងទិន្នន័យជលសាស្ត្រដែលត្រូវយកទៅប្រើប្រាស់សម្រាប់ការរៀបចំគម្រោង និងការគ្រប់គ្រងធនធានទឹក។
- ដំឡើងប្រព័ន្ធអង្កេតឧតុនិយម ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់សម្រាប់ព្យាករអាកាសធាតុ។
- ផ្តល់ព័ត៌មានស្តីពីការព្យាករអាកាសធាតុ ការណែនាំ និងការអប់រំ ដល់សាធារណជន ដើម្បីលើកកម្ពស់ចំណេះដឹងពួកគាត់ឲ្យចេះបង្ការទប់ស្កាត់ និងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់ ដែលបង្កឡើងដោយការប្រែប្រួលធម្មជាតិ និងអាកាសធាតុ ដូចជាខ្យល់ព្យុះ រន្ទះ ស៊ូណាមី ទឹកជំនន់ ជាដើម។

- រៀបចំសារពើភណ្ឌនិងផែនទីភូមិសាស្ត្រសម្រាប់ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ទំនប់ការពារ ទឹកប្រៃ អាងទន្លេ ស្ទឹង ផ្ទៃដីលិចទឹក និងការគ្រប់គ្រងធនធានទឹក ដោយមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់។

## តារាងទី ៤.១៥ ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម

| សូចនាករ | ឯកតា | ឆ្នាំ២០១៨ ជាក់ស្តែង | ឆ្នាំ២០១៩ ព្យាករណ៍ | ឆ្នាំ២០២០ ព្យាករណ៍ | ឆ្នាំ២០២១ ព្យាករណ៍ | ឆ្នាំ២០២២ ព្យាករណ៍ | ឆ្នាំ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ១.ដំឡើងស្ថានីយជលសាស្ត្រវាស់កម្ពស់ទឹក | កន្លែង | ៤៤ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | កន្លែង | | ១៧ | ១៧ | ១៧ | ១៧ | ១៧ |
| +សរុបបន្តបន្ទាប់ | កន្លែង | | ៦១ | ៧៨ | ៩៥ | ១១២ | ១២៩ |
| ២.ជួសជុលស្ថានីយជលសាស្ត្រក្នុងឆ្នាំនីមួយៗ | កន្លែង | | ១២ | ១២ | ១២ | ១២ | ១២ |
| ៣.ដំឡើងស្ថានីយជលសាស្ត្រពិនិត្យគុណភាពទឹក | កន្លែង | ១៩ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | កន្លែង | | ១ | ១ | ១ | ១ | ១ |
| +សរុបបន្តបន្ទាប់ | កន្លែង | | ២០ | ២១ | ២២ | ២៣ | ២៤ |
| ៤.ដំឡើងស្ថានីយឧតុនិយម | កន្លែង | ៦៥ | | | | | |
| +ក្នុងឆ្នាំនីមួយៗ | កន្លែង | | ៥ | ៥ | ៥ | ៥ | ៥ |
| +សរុបបន្តបន្ទាប់ | កន្លែង | | ៧០ | ៧៥ | ៨០ | ៨៥ | ៩០ |
| ៥.ជួសជុលស្ថានីយឧតុនិយមក្នុងឆ្នាំនីមួយៗ | កន្លែង | | ១២ | ១២ | ១២ | ១២ | ១២ |

*ប្រភព*: ក្រសួងធនធានទឹកនិងឧតុនិយម

៤.១៦៨- នៅក្នុងផ្នែកនៃ**ការការពារនិងការអភិរក្សធនធានទឹក** ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងអនុវត្តនូវសកម្មភាព ដូចខាងក្រោម៖

- ពង្រឹងនិងជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនានា ដើម្បីតាមដានត្រួតពិនិត្យនិងទប់ស្កាត់នូវរាល់គម្រោងស្តារឡើងវិញនិងសាងសង់ ដែលអាចមានផលប៉ះពាល់ដល់ធនធានទឹកនិងប្រព័ន្ធអេកូឡូស៊ី។
- រក្សាឲ្យបាននូវធារទឹកនិងកម្រិតកម្ពស់អប្បបរមា ទឹកទន្លេ ស្ទឹង បឹងបួ ព្រែក ដើម្បីធានានូវចីរភាព ប្រព័ន្ធអេកូឡូស៊ី និងនាវាចរណ៍។
- ហាមឃាត់ និងមានវិធានការជាបន្ទាន់ ចំពោះការចាក់បំពេញ ការជីក ឬរំលោភបំពានដោយខុសច្បាប់លើផ្លូវទឹក ទន្លេ ស្ទឹង ឬដីទំនាបដែលលិចទឹកជាប្រចាំ និងឆ្នេរសមុទ្រ ដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់ធនធានទឹក ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។
- ពង្រឹងការងារអភិរក្សអាងទឹកនិងបឹងធម្មជាតិ ដែលមានលទ្ធភាពស្តុកទឹក ដើម្បីជួយដល់ការកាត់បន្ថយទឹកជំនន់ ព្រមទាំងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី។
- រៀបចំអនុក្រឹត្យស្តីពីការកំណត់ទីតាំងភូមិសាស្ត្រនៃប្រព័ន្ធធារាសាស្ត្រនិងអាងស្តុកទឹក។

- ផ្តោតការយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងលើអាងស្ទឹងអាទិភាព ព្រមទាំងអភិរក្សលទ្ធភាពល្អាងទឹកក្រោមដី។

៤.១៦៩- ការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ***ក្រសួងធនធានទឹកនិងឧតុនិយម*** នឹងផ្តោតលើ៖

- ការប្រើប្រាស់ជាអតិបរមានូវសក្តានុពលនៃប្រព័ន្ធធារាសាស្ត្រ ដើម្បីជាផលប្រយោជន៍សម្រាប់ការដោះស្រាយបញ្ហាទឹកដល់វិស័យកសិកម្ម និងធានាឲ្យមានការចូលរួមច្រើនជាងមុនពីកសិករទាំងឡាយនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹក។
- ការពង្រឹងនូវដំណើរការនៃការផ្តល់អាទិភាពដល់ការស្តារឡើងវិញ ការសាងសង់ ការថែទាំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។
- ការយកចិត្តទុកដាក់លើមតិយោបល់និងសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត និងការធានានូវសុវត្ថិភាពស្បៀងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។
- ការធានាឲ្យមានការចូលរួមរបស់ស្ថាប័ននានា និងភាពជាម្ចាស់របស់ប្រជាជនក្នុងការប្រើប្រាស់និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។
- ការធានាឲ្យមានទឹកស្អាតគ្រប់គ្រាន់ ហើយគុណភាពទឹកឆ្លើយតបទៅនឹងតម្រូវការនៅគ្រប់វិស័យពេញទូទាំងឆ្នាំ និងដើម្បីការពារប្រព័ន្ធអេកូឡូស៊ី។
- ការកាត់បន្ថយនៅកម្រិតតិចបំផុតនូវផលប៉ះពាល់ពីទឹកជំនន់ និងកសាងសមត្ថភាពដើម្បីការពារទល់នឹង ទឹកជំនន់ ដែលបណ្តាលមកពីទឹកភ្លៀងនិងទឹកសមុទ្រ។
- ការបញ្ចៀសការបំពុលធនធានទឹក ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ជាពិសេសធនធានត្រី។

## ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ

៤.១៧០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា*** នឹងបន្តកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយបណ្តាប្រទេសជាសមាជិកមេគង្គ ក្រោមយន្តការគណៈកម្មការទន្លេមេគង្គដើម្បីធានាអធិបតេយ្យភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ។ អនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ និងរួមគ្នាឆ្ពោះទៅការអភិវឌ្ឍប្រកបដោយភាពប្រសើរនិងដោយចីរភាពនៃអាងទន្លេមេគង្គ។ ការគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែន តម្រូវការសម្រាប់ផ្សារភ្ជាប់គ្នារវាងទឹក-ស្បៀង-ថាមពល និងទស្សនៈវិស័យលើផ្នែកយេនឌ័រក៏ដូចជាការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការផ្សារភ្ជាប់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងការរៀបចំផែនការអភិវឌ្ឍនិងការអនុវត្ត ការការពារទប់ទល់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ និងការថែរក្សាការពារនូវទ្រព្យសម្បត្តិបរិស្ថានសំខាន់ៗ និងជីវភាពរស់នៅរបស់សហគមន៍ប្រជាជនដែលងាយរងគ្រោះ មានសារៈសំខាន់ណាស់សំដៅរួមចំណែកសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលបានប្តេជ្ញាចិត្តដោយប្រទេសជាសមាជិកគណៈកម្មការទន្លេ

មេគង្គ ជាពិសេសគោលដៅទី៦ "**ធានាឲ្យបាននូវធនធានទឹកនិងការគ្រប់គ្រងទឹក ប្រកបដោយចីរភាព និងអនាម័យសម្រាប់ទាំងអស់គ្នា**"។

៤.១៧១- ដើម្បីអនុវត្តគោលនយោបាយអាទិភាព ដែលបានប្ដេជ្ញាចិត្ត ***គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា*** នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសជាសមាជិកមេគង្គក្នុងការធ្វើឲ្យប្រសើរឡើងនូវកាលានុវត្តភាពនៃការអភិវឌ្ឍ និងការគិតគូរដោះស្រាយបញ្ហាប្រឈម តាមរយៈដំណើរការពហុជំនាញរួមបញ្ចូលគ្នាទូទាំងអាង ជាពិសេសការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ។ បន្តអនុវត្តនូវរាល់នីតិវិធីទាំងអស់របស់គណៈកម្មការទន្លេមេគង្គ ស្ដីពីការប្រើប្រាស់ទឹកដើម្បីគាំទ្រការប្រើប្រាស់ទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព សមហេតុផល និងដោយសមធម៌។ ពង្រឹងបណ្ដាញតាមដានត្រួតពិនិត្យ និងប្រព័ន្ធព្យាករណ៍អាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងព័ត៌មាន។ បន្តធ្វើឲ្យប្រសើរឡើងនូវការផ្សព្វផ្សាយ ការទទួលយកនិងការប្រើប្រាស់ផលិតផលរបស់គណៈកម្មការទន្លេមេគង្គ ដោយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ។ កំណត់និងចាប់យកកាលានុវត្តភាពសម្រាប់កិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយដៃគូសន្ទនា ដៃគូអភិវឌ្ឍ និងយន្តការសហប្រតិបត្តិការជាក់លាក់ផ្សេងទៀតដូចជាកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន មេគង្គ-ឡានឆាង និងមហាអនុតំបន់ទន្លេមេគង្គ។

៤.១៧២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងអភិវឌ្ឍន៍ជនបទ*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាព រួមមាន៖

**១. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ**

- ស្ដារ និងសាងសង់ផ្លូវជនបទ (ប្រវែងផ្លូវសរុប ៤៥ ០០០ គ.ម.)
- កែលម្អផ្លូវជនបទទៅជាកៅស៊ូពីជាន់ ឬ បេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុ
- ថែទាំផ្លូវជាលក្ខណៈខួប និង ប្រចាំ
- រៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ ផែនទីផ្លូវជនបទ និងការដាក់ស្លាកចរាចរ

**២. ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត**

- បន្តសាងសង់និងជួសជុលអណ្ដូងគ្រប់ប្រភេទ ស្ដារស្រះសហគមន៍ អាងត្រងទឹកភ្លៀងគ្រប់ប្រភេទ ប្រព័ន្ធចែកចាយទឹកសហគមន៍ ស្ដារប្រព័ន្ធធារាសាស្ត្រខ្នាតតូច
- បន្តការផ្ដល់ធុងចម្រោះទឹកស្អាត
- បន្តបង្កើត និងដំណើរការមន្ទីរពិសោធន៍គុណភាពទឹក
- បន្តរៀបចំបញ្ជីសារពើភណ្ឌប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ
- បន្តលើកកម្ពស់ការយល់ដឹងផែនការសុវត្ថិភាពទឹក

- បន្តបង្កើតកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយថវិកាពីប្រភពថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានការគាំទ្រពីដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា
- បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនៅថ្នាក់ជាតិ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បង្កើតកម្មវិធីសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹក នៅថ្នាក់ភូមិ

**៣. ការងារអនាម័យជនបទ**

- បង្កើតកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា
- បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនៅថ្នាក់ជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ
- បង្កើតយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានសម្រាប់អនាម័យដោយផ្តោតជាពិសេស លើគ្រួសារក្រីក្រ និងងាយរងគ្រោះ
- រៀបចំតួនាទីស្ថាប័នថ្នាក់ក្រោមជាតិ(ឃុំសង្កាត់ស្រុកខណ្ឌ)ក្នុងការផ្តល់សេវាកម្មវិធីអនាម័យជនបទតាមគោលការណ៍ណែនាំនិងកម្មវិធីកសាងសមត្ថភាព
- ពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការងារលើកកម្ពស់អនាម័យជនបទ
- រៀបចំបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ
- ជំរុញការអនុវត្តអនាម័យក្នុងសហគមន៍ជនបទ និងផ្លាស់ប្តូរឥរិយាបថប្រតិបត្តិអនាម័យ
- រៀបចំបង្កើតយុទ្ធសាស្ត្រជាតិស្តីពីការ ផ្លាស់ប្តូរទម្លាប់ និងការទំនាក់ទំនង
- បង្កើនការយល់ដឹងអំពីអនាម័យជនបទ តាមរយៈការប្រាស្រ័យទាក់ទង
- រៀបចំបង្កើត និងអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីអនាម័យដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ
- បង្កើតបណ្តាញនិងកសាងសមត្ថភាពក្រុមសម្របសម្រួលអនាម័យភូមិ
- សាងសង់បង្គន់អនាម័យ និងកន្លែងលាងដៃតាមសាលារៀននៅជនបទ
- សកម្មភាពស្វែងរកការគាំទ្រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីអនាម័យ

**៤. ការបណ្តុះបណ្តាលធនធានមនុស្ស**

- បន្តការអភិវឌ្ឍធនធានមនុស្ស ដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានលឿន និងប្រសិទ្ធភាព។

**៥. ការអភិវឌ្ឍសហគមន៍**

- បន្តការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ.)
- បន្តការអភិវឌ្ឍភូមិចម្រុះ

- បន្តបញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍
- បន្តការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- បន្តពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ កំពង់ស្ពឺ និងកម្ពុជា-កូរ៉េ

**៦. ការអភិវឌ្ឍជនជាតិដើមភាគតិច**

ការងារអភិឌ្ឍជនជាតិដើមភាគតិច ដើម្បីឲ្យជនជាតិដើមភាគតិចមាន ជីវភាពរស់នៅសមរម្យ និងចាកផុតពីភាពក្រីក្រ អភិរក្ស និងការពារវប្បធម៌របស់ជនជាតិដើមភាគតិចឲ្យបានគង់វង្ស ដែលមានគោលដៅចំបងៗ ៖

- អភិឌ្ឍជនជាតិដើមភាគតិច មានជីវភាពរស់នៅចាកផុតពីភាពអត់ឃ្លាន និងភាពក្រីក្រធ្ងន់ធ្ងរ។
- ការពារវប្បធម៌របស់ជនជាតិដើមភាគតិច និង ឲ្យមានភាពល្អប្រសើរ
- ថែរក្សាសុខភាពរបស់ជនជាតិដើមភាគតិចឲ្យបានល្អប្រសើរ
- ផ្តល់ការអប់រំជនជាតិដើមភាគតិចទាំងអស់ យ៉ាងតិចកម្រិតមូលដ្ឋានប្រាំបួនឆ្នាំ និង ត្រូវផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសមស្របនឹងតម្រូវការ និងផ្អែកលើទីតាំងភូមិសាស្ត្ររស់នៅរបស់ជនជាតិ។

## ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

៤.១៧៣- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការអនុវត្តគោលនយោបាយទឹកស្អាតដើម្បីឲ្យប្រជាពលរដ្ឋនៅទីប្រជុំជន១០០% ទទួលបានសេវាទឹកស្អាតនៅឆ្នាំ២០២៥ និងធានាបាននូវបុរេលក្ខខណ្ឌ ៤គឺ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ***ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*** មានសកម្មភាពអាទិភាព ដូចខាងក្រោម៖

***ជំរុញ និងលើកម្ពស់ គ្រប់គ្រង បច្ចេកទេស និង ហិរញ្ញវត្ថុ***

- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ រួមមានផែនការហិរញ្ញប្បទាននិងវិនិយោគរយៈពេលវែង
- គ្រប់អង្គភាពសាធារណៈទាំងអស់ត្រូវរៀបចំផែនការអាជីវកម្ម ៥ឆ្នាំ របស់ខ្លួនឲ្យបានល្អត្រឹមឆ្នាំ២០២៣
- ស្តារឡើងវិញនូវមធ្យោបាយផលិតកម្ម និងបណ្តាញចែកចាយដែលមានស្រាប់ដោយប្រើប្រាស់ធនធានរបស់រាជរដ្ឋាភិបាល ធនធានរបស់អង្គភាព និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានា។
- សិក្សាស្វែងយល់អំពីមូលហេតុតាមអង្គភាពនីមួយៗអំពីឫសគល់នៃបញ្ហាដែលបណ្តាលឲ្យរដ្ឋាករទឹកសាធារណៈមិនទាន់មានចំណូលធានាគ្រប់ចំណាយ និងរិះរកវិធានការកែលម្អ និងលើកម្ពស់ប្រសិទ្ធភាព និងផលិតភាពរបស់អង្គភាព។

- ការផ្តល់ស្វ័យភាពពេញលេញដល់អង្គភាពសាធារណៈ តាមរយៈការកសាងសមត្ថភាពរដ្ឋាករទឹកសាធារណៈតាមបណ្តាខេត្ត ដើម្បីបជំរុញការផ្តល់ស្វ័យភាពជាសហគ្រាសមានលក្ខណៈសេដ្ឋកិច្ចតាមស្ថានភាពជាក់ស្តែង។
- យកតាមគំរូ និងបទពិសោធរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អង្គភាពទាំងអស់នឹងត្រូវផ្តល់ស្វយ័ភាពជាអង្គភាពសាធារណៈមានលក្ខណៈសេដ្ឋកិច្ចត្រឹមឆ្នាំ២០២៣។
- ខិតខំជំរុញឲ្យរដ្ឋាករទឹកសាធារណៈ ផ្តល់សេវាប្រកបទៅដោយគុណភាព តម្លៃសមរម្យធានាការទូទាត់សោហ៊ុយចំណាយបានទាំងស្រុង និងធនធានសម្រាប់ការវិនិយោគឡើងវិញ។
- អភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកឱ្យមានប្រសិទ្ធភាព ដើម្បីធានាថាការផ្គត់ផ្គង់ទឹកស្អាតត្រូវអនុលោមតាមបទដ្ឋានគុណភាពទឹកផឹកជាតិ។

***លើកម្ពស់ប្រសិទ្ធិភាព កិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជំនួយ អន្តរជាតិ***

- បន្តកិច្ចសហប្រតិបត្តិការស្មើភាពល្អជាមួយដៃគូអភិវឌ្ឍនានា ដើម្បីរកហិរញ្ញប្បទានសម្រាប់ការស្តារ និងពង្រីកសមត្ថភាពផ្គត់ផ្គង់ស្របតាមផែនការអភិវឌ្ឍ។
- សិក្សា និងជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ផ្នែកឯកជនតាមរយៈការសហការជាមួយបណ្តាស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងធនាគារក្នុង និងក្រៅស្រុក ដើម្បីជួយគាំទ្រផ្នែកឯកជនក្នុងការទទួលបានប្រាក់កម្ចីដែលមានលក្ខណៈអនុគ្រោះដល់វិស័យឯកជន។
- ជំរុញលើកទឹកចិត្តឲ្យមានការចូលរួមវិនិយោគពីវិស័យឯកជន ដោយការបង្កើតនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ សម្រួលដល់បរិយាកាសវិនិយោគក្នុងការទាក់ទងភាពជាដៃគូសាធារណៈ ឯកជន ព្រមទាំងការលើកទឹកចិត្តដល់ការវិនិយោគឯកជន។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធានាការសម្រេចគោលដៅអភិវឌ្ឍន៍វិស័យទឹកស្អាតឲ្យកាន់តែប្រសើរឡើង។
- បង្កើនភាពជាដៃគូជាមួយ “សមាគមអ្នកផ្តល់សេវាទឹកស្អាតកម្ពុជា” ដើម្បីរួមគ្នាសម្រេចគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទឹកស្អាតកម្ពុជា។
- សហការជាមួយគណៈកម្មការធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងត្រៀមចំពោះការប្រែប្រួលអាកាសធាតុ ព្រមទាំងការចូលរួមរាល់សកម្មភាពដើម្បីកាត់បន្ថយផលប៉ះពាល់ដល់វិស័យទឹកស្អាត។

***លើកកម្ពស់ក្របខ័ណ្ឌគោលនយោបាយ និងបញ្ញត្តិកម្ម***

- ការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន។
- ការជំរុញវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតតំបន់ទីប្រជុំជន។
- ការបង្កើនការការពារប្រភពទឹក និងពង្រឹងបញ្ញត្តិកម្ម។

***លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស***

- កសាងធនធានមនុស្សឲ្យមានបរិមាណ និងគុណភាព ឆ្លើយតបទៅនឹងតម្រូវការទាំងក្នុងអគ្គនាយកដ្ឋានទឹកស្អាត និងវិស័យឯកជនឲ្យមានលក្ខណៈជាប្រព័ន្ធ និងមានចីរភាព។

- បង្កើនវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីតាមបណ្តា អង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជន លើការងារដំណើរការប្រព័ន្ធផលិតកម្ម ការថែទាំប្រព័ន្ធបរិក្ខារអគ្គិសនី និងមេកានិកនិងជំនាញផ្សេងៗបន្ថែមទៀតសម្រាប់ដំណាក់កាលបន្ទាន់
- ស្វែងរកប្រភពជំនួយ ដើម្បីកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវលើវិស័យទឹកស្អាតសម្រាប់រយៈពេលវែង។

***លើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទឹកស្អាត និងការចូលរួម***

- អនុវត្តកម្មវិធី "ទឹកស្អាតសម្រាប់ទាំងអស់គ្នា" ដោយផ្តោតលើការផ្តល់ឧបត្ថម្ភធនថ្លៃតភ្ជាប់បណ្តាញដល់គ្រួសារដែលក្រីក្របំផុត និងគ្រួសារដែលងាយរងគ្រោះបំផុត។
- បង្កើតបរិយាកាសប្រទ្បងប្រណាំង ដោយដាក់ចេញនូវសូចនាករគុណភាព សេវាផ្គត់ផ្គង់ទឹកស្អាត សំខាន់ៗ សម្រាប់ធ្វើជាខ្នាតវាស់សមត្ថភាពរបស់អង្គភាពផ្តល់សេវា និងប្រព័ន្ធត្រួតពិនិត្យ ប្រកបដោយតម្លាភាព។
- រៀបចំកម្មវិធីអប់រំនិងផ្សព្វផ្សាយពីការងារទឹកស្អាតដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈដើម្បីសហការអភិវឌ្ឍ។

## ភូមិមួយផលិតផលមួយ

៤.១៧៤- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និង ជនបទ*** នឹងបន្តសកម្មភាពជាអាទិភាព ដោយបន្តជំរុញការអនុវត្ត**គោលលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦** បានផ្តោតលើយុទ្ធសាស្ត្រជាអាទិភាពចំនួន១៥ គឺ៖

- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ
- រៀបចំផែនទីផលិតផលភូមិមួយផលិតផលមួយ
- ជំរុញការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដែលពាក់ព័ន្ធដល់ការងារជំរុញចលនាភូមិមួយ ផលិតផលមួយ
- ជំរុញការផ្លាស់ប្តូរផ្នត់គំនិតឲ្យកាន់តែល្អប្រសើរឡើង
- លើកកម្ពស់ការយល់ដឹងពីបទពិសោធនានានៃការជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ
- អភិវឌ្ឍសមត្ថភាពក្នុងការផលិតនូវផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម
- លើកកម្ពស់គុណភាពផលិតផលតាមស្តង់ដាផលិតផលភូមិមួយផលិតផលមួយ
- ស្វែងរកប្រភពហិរញ្ញប្បទានសម្បទាន ឬឥណទាន
- លើកកម្ពស់ការអភិវឌ្ឍទីផ្សារ និងការគ្រប់គ្រងអាជីវកម្ម

- បង្កើត ចងក្រង ឬពង្រឹងនិងពង្រីកសមាគម សហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការចូលរួមរបស់យុវជន និងស្ត្រីក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការចូលរួមពីបុគ្គលដែលមានជំនាញ មានបទពិសោធ និងប្រជាជនតាមមូលដ្ឋានក្នុងសកម្មភាពជំរុញចលនាភូមិមួយផលិតផលមួយ
- ជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាព

**តារាងទី ៤.១៦ សូចនាករសម្រាប់វាស់វែងចលនាភូមិមួយ ផលិតផលមួយ**

| ល.រ | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ១ | ផលិតផលខ្មែរត្រូវបានបញ្ចូលជាផលិតផលភូមិមួយផលិតផលមួយ (២៥រាជធានី ខេត្ត) | ចំនួន | ១២៥ | ២០០ | ២៧៥ | ៣៥០ | ៤២៥ |
| ២ | ផលិតផលភូមិមួយផលិតផលមួយត្រូវបានលើកកម្ពស់គុណភាពតាមកម្រិតស្តង់ដាពីទាបទៅខ្ពស់ (២៥រាជធានី ខេត្ត) | ចំនួន | ០ | ៧៥ | ១៥០ | ២០០ | ២៥០ |
| ៣ | មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍ និងបណ្តុះបណ្តាលផលិតផលភូមិមួយផលិតផលមួយត្រូវបង្កើតតាមរាជធានី ខេត្ត | ចំនួន | ៥ | ១០ | ១៥ | ២០ | ២៥ |
| ៤ | ពិព័រណ៍ផលិតផលភូមិមួយផលិតផលមួយ (២ដងក្នុងមួយឆ្នាំ ទាំង២៥រាជធានី ខេត្ត) | ចំនួន | ៥០ | ១០០ | ១៥០ | ២០០ | ២៥០ |
| ៥ | សមាគម និងសហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយត្រូវបានបង្កើតនៅថ្នាក់រាជធានីខេត្ត | ចំនួន | ០ | ០ | ២៥ | ៥០ | ១០០ |

## ៦.២- ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ ប្រកបដោយចីរភាព

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៧៥- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺរក្សាតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សសំដៅលើកកម្ពស់វិភាគទានកិច្ចការនេះ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និង ទេសចរណ៍ ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ ការធានាចីរភាពធនធានព្រៃឈើ ជលផល និង ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងការការពារ និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ។

៤.១៧៦- ជាលទ្ធផល គម្របព្រៃឈើត្រូវបានរក្សាក្នុងរង្វង់៦០%នៃផ្ទៃប្រទេស ដីសម្បទានសេដ្ឋកិច្ចជាង៤១ម៉ឺនហ.ត. ត្រូវបានដកហូត ដើម្បីយកមកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ឬ ធ្វើប្រទានកម្ម ឬ ដាំដើមឈើឡើងវិញ កន្លែងអភិរក្សជលផលជាង៩៧ម៉ឺនហ.ត. ត្រូវបានអភិរក្សក្រោយការរំសាយឡូត៍នេសាទ សហគមន៍ព្រៃឈើចំនួន៦១០ និង សហគមន៍នេសាទចំនួន៥១៦ ត្រូវបានបង្កើត បេតិកភណ្ឌវប្បធម៌រូបី និង អរូបី រួមមាន ប្រាសាទសំបូរព្រៃគុក ចាប៉ីដងវែង ល្បែងទាញព្រ័ត្រ និង ប្រពៃណីទាញព្រ័ត្រ និង ប្រពៃណីនិទានរឿងរាមកេរ្តិ៍ តាគ្រុឌ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌនៃអង្គការយូណេស្កូ។

៤.១៧៧- បញ្ហាប្រឈមពាក់ព័ន្ធនឹងវិស័យនេះ រួមមាន អភិបាលកិច្ច និង ប្រព័ន្ធគ្រប់គ្រងធនធាន រ៉ែ នៅមិនទាន់រឹងមាំ និង ការធ្វើអាជីវកម្មរ៉ែនៅមានអនាធិបតេយ្យ សម្ពាធនៃតម្រូវការដីសម្រាប់ប្រើប្រាស់ទល់នឹងការចាំបាច់ក្នុងការការពារគម្របព្រៃឈើ ការហ៊ុមព័ទ្ធ និង ការឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ ការទន្ទ្រានដីព្រៃលិចទឹក និង ដែននេសាទ បទល្មើសព្រៃឈើ សត្វព្រៃ និង ជលផលនៅបន្តជាក្តីកង្វល់ ព្រមទាំងការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ក៏នៅមិនអស់សក្តានុពល។

៤.១៧៨- ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១-ការជំរុញអនុវត្ត “***គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨***” ដោយពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងធនធាន និង អាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានសង្គម និង ពង្រឹងការប្រមូលចំណូលថវិកាជាតិ។
- ទី២-ការពង្រឹងយន្តការគ្រប់គ្រងធនធាន និង អាជីវកម្មខ្សាច់ ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែក សង្គម និង បរិស្ថាន។
- ទី៣-ការបន្តគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ដោយថែរក្សាគម្របព្រៃឈើឲ្យលើស ៦០% នៃផ្ទៃប្រទេស ការលើកកម្ពស់ការអភិរក្សព្រៃឈើ និង សត្វព្រៃ ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ និង ឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការការពារ និង ស្តារព្រៃឈើឡើងវិញ ព្រមទាំងការបង្ក្រាបបទល្មើស ព្រៃឈើ និង ការជួញដូរសត្វព្រៃ។
- ទី៤-ការបន្តជំរុញការអភិរក្ស និង គ្រប់គ្រងធនធានជលផល តាមរយៈ ការបង្ក្រាបបទល្មើសជលផល ការធ្វើឲ្យប្រសើរឡើងនូវសហគមន៍នេសាទ និង ការបង្កើនវារីវប្បកម្ម។
- ទី៥-ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និង ការការពារតំបន់ធម្មជាតិ ដោយផ្តោតលើការការពារជីវៈចម្រុះ តំបន់ដីសើម និង តំបន់ឆ្នេរ ដើម្បីធានាគុណភាពដី និង ចីរភាពប្រភពទឹក។

ទី៦-ការបន្តអភិរក្ស និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ដោយជំរុញការចុះបញ្ជី ពង្រឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ និង ចងក្រង ព្រមទាំងការបង្កើត តម្លៃពីបេតិកភណ្ឌវប្បធម៌។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព ធនធានរ៉ែ

៤.១៧៩- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** នឹងបន្តអនុវត្ត ***គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨*** ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថានសង្គមនិងពង្រីកការប្រមូលចំណូលថវិកាជាតិ ពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថាន។ ក្រសួងបានបន្តដាក់ចេញនូវយុទ្ធសាស្ត្រ ដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដូចខាងក្រោម៖

- ពង្រឹងតួនាទីស្ថាប័នក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានរ៉ែ ដោយផ្តោតសំខាន់លើការលុបបំបាត់អាជីវកម្មរ៉ែខុសច្បាប់ និងការប្រមូលចំណូលមិនមែនសារពើពន្ធជូនរដ្ឋ
- ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាព និងការទទួលខុសត្រូវសង្គម បរិស្ថាន និងសេដ្ឋកិច្ច
- គ្រប់គ្រងនិងអភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចតាមរយៈប្រតិភូកម្មអំណាចជូនថ្នាក់ក្រោមជាតិក្នុងការចេញអាជ្ញាបណ្ណ និងគ្រប់គ្រងអាជីវកម្មរ៉ែក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- គ្រប់គ្រងនិងដំណើរការការនាំចេញផលិតផលរ៉ែ។

## ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម និង ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

### *ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម*

៤.១៨០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាព រួមមាន៖

- បន្តពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផលប្រកបដោយចីរភាពស្របតាម ***ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល២០១៥-២០២៤*** និងសេចក្តីថ្លែងការណ៍ ស្តីពីគោលនយោបាយវិស័យជលផលជាតិ ពិសេសតាមរយៈការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ

- បង្កើនវារីវប្បកម្មដើម្បីបង្កើនការផ្គត់ផ្គង់ ដែលនឹងត្រូវផ្ដល់នូវការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី រួមទាំងបច្ចេកទេស ពូជត្រី ឥណទាន ទីផ្សារ និងការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់បន្តនូវយន្តការដែលមានស្រាប់ គឺជាអាទិភាពក្នុងការការពារធនធានជលផល។

### *ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ*

- គ្រប់គ្រង និងអភិវឌ្ឍព្រៃឈើ
- ពង្រឹងការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ
- គ្រប់គ្រងឧទ្យានសួនសត្វនិងសង្គ្រោះថែរក្សាសត្វព្រៃ
- ពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ
- ពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រអង្គភាព

## គ្រប់គ្រងធនធានធម្មជាតិ

៤.១៨១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងបរិស្ថាន*** នឹងបន្តអនុវត្តសកម្មភាពជាអាទីភាព រួមមាន៖

### *ការគ្រប់គ្រងតំបន់ការពារធម្មជាតិ*

- ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ តាមរយៈការពង្រឹងសមត្ថភាព គ្រប់គ្រងរបស់អង្គភាពត្រូវបានពង្រឹងតាមរយៈការធ្វើអភិបាលកិច្ចល្អ
- កំណត់ព្រំប្រទល់ កំណត់តំបន់គ្រប់គ្រង ចុះបញ្ជីកាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋតំបន់ការពារធម្មជាតិ និងមានផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិឲ្យបានច្បាស់លាស់
- បង្កើនប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង ដោយបំពាក់ឧបករណ៍ ទំនើប និងការបណ្ដុះបណ្ដាលស្ដីពីពង្រឹងការអនុវត្តច្បាប់ និងជំនាញពាក់ព័ន្ធតាមការចាំបាច់នៃតំបន់នីមួយៗ
- ជំរុញការធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- កំណត់សិទ្ធិដីអាស្រ័យផល ក្នុងតំបន់ការពារធម្មជាតិ និងដោះស្រាយទំនាស់ដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ រួមទាំងនៅក្នុងតំបន់គម្រោងសម្បទានដីសេដ្ឋកិច្ច
- រៀបចំបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត
- រៀបចំយុទ្ធសាស្ត្របង្កើនគម្របព្រៃឈើឡើងវិញតាមរយៈការដាំឈើឡើងវិញ និងលើកកម្ពស់ ការអភិរក្សនិង ស្ដារឡើងវិញនូវប្រភពដើមធនធានសេនេទិករុក្ខជាតិព្រៃឈើ និងសត្វព្រៃ ក្នុង តំបន់ការពារធម្មជាតិ
- លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីរេដបូក តាមការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរិលព្រៃឈើ ការអភិរក្សស្តុកកាបូនព្រៃឈើ ការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព និងការបង្កើនសន្និធិកាបូនព្រៃឈើ

- អភិវឌ្ឍគំនិតច្នៃប្រឌិតថ្មីៗក្នុងការអភិរក្ស និងការអភិវឌ្ឍ រួមទាំងបង្កើតឱកាសសម្រាប់ចីរភាពអេកូទេសចរណ៍ និងយន្តការហិរញ្ញប្បទាន។

### ការអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន

- ជំរុញការប្រែក្លាយចំណេះដឹងបរិស្ថានឱ្យទៅជាការប្រតិបត្តិបរិស្ថាន តាមរយៈការរៀបចំគោលនយោបាយអប់រំបរិស្ថាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំបរិស្ថាន ព្រឹត្តិការណ៍បរិស្ថាន និងសកម្មភាពអប់រំបរិស្ថាននានា មានជាអាទិ៍៖ ការកែលម្អកម្មវិធីសិក្សាអប់រំបរិស្ថានជាតិ ការបន្តអនុវត្តកម្មវិធីសាលាមេត្រីភាពបរិស្ថាន ការអនុវត្តកម្មវិធីអារាមមេត្រីបរិស្ថាន ការបំផុសចលនាភូមិដ្ឋានបៃតង ផ្ទះមេត្រីភាពបរិស្ថាន
- ជំរុញសកម្មផ្សព្វផ្សាយព័ត៌មានបរិស្ថានតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដោយបន្តបង្កើននូវកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធនានា ដើម្បីកែប្រែផ្នត់គំនិតប្រជាពលរដ្ឋឱ្យមានឥរិយាបថល្អចំពោះបរិស្ថាន
- រៀបចំទិន្នន័យបរិស្ថានផ្តល់សេវារៀបចំផែនទីបរិស្ថាន មានជាអាទិ៍៖ ផែនទីអភិរក្សជីវៈចម្រុះ ផែនទីគោលប្រើប្រាស់ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ផែនទីកំណត់តំបន់គ្រប់គ្រងក្នុង តំបន់ការពារធម្មជាតិ ផែនទីសហគមន៍តំបន់ការពារធម្មជាតិ ផែនទីរបៀងអេកូទេសចរណ៍។
- បំផុសចលនាប្រឡងប្រណាំងសកម្មភាពមេត្រីភាពបរិស្ថាន តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្ត ការផ្តល់វិញ្ញាបនបត្របៃតងចំពោះអ្នកប្រតិបត្តិល្អមេត្រីភាពបរិស្ថាន អ្នកផ្តល់សេវាកម្ម របកគំហើញបច្ចេកវិទ្យា និងអ្នកផលិតផលិតផលបៃតង។

### ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគ្រប់គ្រងតំបន់បេតិកភណ្ឌ

- បន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីសហគមន៍តំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រង
- សហគមន៍ និងបន្តធ្វើការសិក្សាសហគមន៍ព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ ទើបបង្កើតថ្មី ដើម្បីរៀបចំបង្កើតទៅជាសហគមន៍តំបន់ការពារធម្មជាតិបន្ថែមទៀត
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បន្តការងារទាក់ទងនឹងការរៀបចំបង្កើតបណ្តាញសហគមន៍តំបន់ការពារធម្មជាតិដែលរួមមានថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់គណៈកម្មការតំបន់ការពារធម្មជាតិ
- ពង្រីក/បង្កើនឱកាសមុខរបរសម្រាប់សហគមន៍មូលដ្ឋាន ដោយផ្តល់ឱកាសឱ្យមានការអនុវត្តដោយផ្ទាល់ និងមានផលប្រយោជន៍ដល់ការបង្កើតជម្រើសមុខរបរ និងជំរុញលើកទឹកចិត្តឱ្យធ្វើសមាហរណកម្ម រាល់សកម្មភាពនៅក្នុងផែនការគ្រប់គ្រងសហគមន៍ទៅក្នុងផែនការវិនិយោគឃុំសង្កាត់នីមួយៗ

- ជ្រើសរើស និងអនុវត្តសាកល្បងនូវទស្សនៈទានស្តីពី "សហគ្រប់គ្រង និងការចូលរួមរបស់សហគមន៍" នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិមួយចំនួនស្ថិតនៅក្នុងតំបន់ខាងកើតទន្លេ មេគង្គខាងជើង និងខាងត្បូងបឹងទន្លេសាប
- គៀរគរការគាំទ្រ និងធនធានសម្រាប់បង្កើតនិងពង្រីកផលិតកម្ម ដែលរួមចំណែកដល់ការ កែលម្អជីវភាពសហគមន៍ សម្រាប់សហគមន៍តំបន់ការពារធម្មជាតិស្ថិតនៅក្នុងតំបន់ខាងកើតទន្លេមេគង្គ ខាងជើង និងខាងត្បូង បឹងទន្លេសាប
- ការរៀបចំទេសចរណ៍ធម្មជាតិ និងអភិរក្សធនធានធម្មជាតិ
- សហគមន៍មូលដ្ឋានទទួលបានផលប្រយោជន៍ពីការចូលរួមទៅក្នុងការគ្រប់គ្រងតំបន់ការពារ ធម្មជាតិតាមរយៈការរៀបចំទេសចរណ៍ធម្មជាតិ
- ទេសចរណ៍ធម្មជាតិ និងទេសចរណ៍វប្បធម៌ បានបង្ហាញឲ្យឃើញថាជាមធ្យោបាយដ៏ជោគជ័យសម្រាប់ការការពារ និង អភិរក្សតំបន់ការពារធម្មជាតិព្រមទាំងរក្សាបាននូវចីរភាព និងសុខុមាលភាពរបស់សហគមន៍មូលដ្ឋានក្នុងពេលដំណាលគ្នាផងដែរ
- ពង្រឹងកិច្ចសហការ និងភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយក្រុមហ៊ុនទេសចរណ៍ និងទេសចរណ៍ធម្មជាតិ និងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងសេវាកម្មទេសចរណ៍ធម្មជាតិ ត្រូវបានកែលម្អ និងបង្កើនចំនួនភ្ញៀវទេស-ចរណ៍ទៅទស្សនាក្នុងតំបន់ការពារធម្មជាតិ
- ពង្រឹងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយស្ថាប័នទទួលបន្ទុកការងារវប្បធម៌ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ និង
- ពង្រឹងសមត្ថភាពរបស់អង្គភាព និងផ្សព្វផ្សាយព័ត៌មាន និងការអប់រំអំពីតម្លៃបេតិកភណ្ឌធម្មជាតិ-វប្បធម៌ទូលំទូលាយដល់សាធារណជន។

៤.១៨២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាព រួមមាន៖

**១- ការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ**

- ប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ ភាពងាយរងគ្រោះ សមត្ថភាព ការប្រឈមនឹងភយន្តរាយ លក្ខណៈរបស់មុខសញ្ញាគ្រោះថ្នាក់ និងផលប៉ះពាល់ដែលអាចកើតមាន។
- លើកកម្ពស់ការប្រមូល ការវិភាគ ការគ្រប់គ្រង ការប្រើប្រាស់ និងការផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធដោយប្រើប្រាស់ ព័ត៌មានប្រភពដើម រួមមានប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ និងរបកគំហើញថ្មីៗ។
- ជំរុញការអនុវត្តធុរកិច្ច លើការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយនៅតាមទីតាំងជាក់លាក់នៃបរិយាកាសប្រតិបត្តិការ និងមានខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួនដោយមានការ

យល់ដឹងច្បាស់លាស់ អំពីការប្រឈមនឹងហានិភ័យដោយមុខសញ្ញាគ្រោះថ្នាក់ និង ភាពងាយរងគ្រោះ។

- សមាហរណកម្មព័ត៌មានហានិភ័យគ្រោះមហន្តរាយ ទៅក្នុងផែនការវិនិយោគធុរកិច្ច និងការគ្រប់គ្រងអង្គភាពវិស័យឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម តាមរយៈសមាគមសហគ្រាសធុរកិច្ច សភាពាណិជ្ជកម្ម និងវេទិកាជាតិ និងវេទិកាតំបន់ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- បំផុសគំនិតផ្តួចផ្តើមភាពជាដៃគូរវាងវិស័យសាធារណៈ ឯកជន សម្រាប់លើកកម្ពស់ការយល់ដឹង ការគាំទ្រ និងការអប់រំ ដើម្បីពង្រឹងឥរិយាបថរបស់វិស័យឯកជនចំពោះការអភិវឌ្ឍដែលមានហានិភ័យគួរឲ្យភ័យខ្លាច ។
- រៀបចំគោលការណ៍ណែនាំ សម្រាប់ការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ទៅនឹងការប្រើប្រាស់ផែនការអភិវឌ្ឍនៅមូលដ្ឋានសហគមន៍របស់ខ្លួនជានាដល់ការបំពេញបន្ថែមនូវចំណេះដឹងនិងការអនុវត្តដែលមានតាមប្រពៃណី ជនជាតិដើមភាគតិច និងមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។
- កសាងចំណេះដឹង និងសមត្ថភាពរបស់មន្ត្រីរាជការ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបុគ្គលិកសង្គមស៊ីវិល សហគមន៍ និងអ្នកស្ម័គ្រចិត្ត ដើម្បីតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ ការប្រឈមនឹងហានិភ័យ និងភាពងាយរងគ្រោះក្នុងសង្គម ។
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះមហន្តរាយជាទៀងទាត់តាមរយៈការប្រារព្ធទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ ទិវាអន្តរជាតិការកាត់បន្ថយគ្រោះមហន្តរាយ និងទិវាពិភពលោកស្តីពីរលកយក្សស៊ូណាមី ។

**២-ពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ**

- កែលម្អយុទ្ធសាស្ត្រ/ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងមូលដ្ឋានដែលមានស្រាប់ឲ្យស្របតាមក្របខ័ណ្ឌការងារសេនដាយ និង គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។
- រៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្ត ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។
- ជំរុញការអនុវត្តលើទិដ្ឋភាពសុខាភិបាល នៃក្របខ័ណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ក្នុងន័យធានាដល់កិច្ចសហប្រតិបត្តិការជាប្រព័ន្ធ និងសមាហរណកម្មរវាងការគ្រប់គ្រងគ្រោះមហន្តរាយ និងហា-និភ័យសុខាភិបាល។
- រៀបចំធ្វើសារពើភណ្ឌលើយុទ្ធសាស្ត្រ/ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមាននៅមូលដ្ឋាន ឆ្ពោះទៅសម្រេចបាននូវគោលដៅ (ង) របស់ក្របខ័ណ្ឌការងារសេនដាយ "ស្តីពីយុទ្ធសាស្ត្រ/ផែនការ ការគិតគូពីហានិភ័យនៅមូលដ្ឋានសហគមន៍សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ" នៅត្រឹមឆ្នាំ២០២០។

- ធានាដល់ការចូលរួមរបស់ស្ត្រីបានពេញលេញ ប្រកបដោយប្រសិទ្ធភាព និងមានឱកាសស្មើភាពសម្រាប់ភាពជាអ្នកដឹកនាំ នៅគ្រប់លំដាប់ថ្នាក់នៃការធ្វើសេចក្តីសម្រេចចិត្តក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

**៣-ការវិនិយោគលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់ភាពធន់**

- ជំរុញយន្តការជាតិ សម្រាប់ការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ និងការធានារ៉ាប់រងឲ្យបានសមស្រប ។
- បង្កើនភាពធន់ និងធ្វើសមាហរណកម្ម ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការអនុវត្តជារួម តាមរយៈការបង្កើនភាពជាដៃគូរវាងរដ្ឋបាលមូលដ្ឋាន វិស័យឯកជន ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត។
- ជំរុញយន្តការហិរញ្ញវត្ថុឲ្យបានសមស្រប ក្នុងការធ្វើសមាហរណកម្ម ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងវិធានការនានា ដើម្បីគាំទ្រដល់ការកសាងសហគមន៍ធន់នឹងគ្រោះមហន្តរាយ ដោយមានការចូលរួមពីមូលនិធិអភិវឌ្ឍ ធនាគារ មូលនិធិឯកជន និងភាគីពាក់ព័ន្ធ។
- ចលនាឲ្យមានការចូលរួមគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ដើម្បីពង្រឹងភាពធន់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលកើតមាននៅតាមគ្រួសារ និងសហគមន៍។
- ពង្រឹងការអប់រំស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងពន្លឿនការអនុវត្ត យ៉ាងទូលំទូលាយនូវសុវត្ថិភាពសាលារៀន។

**៤- លើកកម្ពស់ការត្រៀមរៀបចំគ្រោះមហន្តរាយ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងដើម្បី "ស្ថាបនាឱ្យប្រសើរជាងមុន" ក្នុងការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការស្ថាបនា ឡើងវិញ**

- ធ្វើបច្ចុប្បន្នភាព ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅមូលដ្ឋាន និងថ្នាក់ជាតិ វិធីសាស្ត្រដែលមានការចូលរួមពីពហុភាគីពាក់ព័ន្ធ និងពហុវិស័យ ធានាដល់ការទទួលបាននូវសេវាកម្មទូលំទូលាយ និងយន្តការបង្អែក ដើម្បីជំរុញតម្រូវការជាក់លាក់របស់ស្ត្រី និងកុមារ មនុស្សចាស់ ជនពិការនិងប្រជាពលរដ្ឋ ដែលប្រឈមនឹងហានិភ័យ។
- ពង្រឹងប្រព័ន្ធប្រកាសឲ្យដឹងមុន សម្រាប់ពហុមុខសញ្ញាគ្រោះថ្នាក់ ដើម្បីធានាដល់ការទទួលបាននៅរយៈចម្ងាយឆ្ងាយ។
- ពង្រីកការចូលរួមរបស់វិស័យឯកជន ក្នុងការត្រៀមរៀបចំសម្រាប់ការឆ្លើយតប ការស្តារឡើងវិញ និង "ការស្ថាបនាឲ្យប្រសើរជាងមុន" តាមរយៈកិច្ចសហប្រតិបត្តិការជាប្រព័ន្ធរវាងវិស័យសាធារណៈ និងវិស័យឯកជន។
- កសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន រួមទាំងការពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី ជនពិការ និងយុវជន ដើម្បីរៀបចំបង្កើតផែនការស្តារឡើងវិញនូវគ្រោះមហន្តរាយនៅ

មូលដ្ឋានសហគមន៍ រួមមានការជួសជុលសំណង់ឲ្យរឹងមាំ ការកសាងឡើងវិញ ពង្រឹងនូវក្រមសាងសង់ កម្មវិធីក្រោយមានរបួសស្នាម ជីវភាពរស់នៅប្រកបដោយភាពធន់ ការផ្ដល់ទីជម្រកសម្រាប់ប្រជាជនផ្លាស់ទីលំនៅជាដើម ។
- បញ្ជ្រាបវិធីសាស្ត្រ មូលដ្ឋានប្រព័ន្ធអេកូឡូស៊ី តាមរយៈកិច្ចសហប្រតិបត្តិការឆ្លងដែនដើម្បី កសាងភាពធន់។

៤.១៨៣- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ*** នឹងបន្តអនុវត្តសកម្មភាពជាអាទិភាព រួមមាន៖

**១.ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបីនិងអរូបី ៖**
- ការធ្វើបច្ចុប្បន្នកម្មបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ជាតិដោយបង្កើតឲ្យមាននូវ "មូលដ្ឋានទិន្នន័យ" ជាតិមួយ ដែលងាយស្រួលក្នុងការកំណត់ហានិភ័យបេតិកភណ្ឌវប្បធម៌ជាប្រចាំ
- រៀបចំយន្តការ បទដ្ឋានគតិយុត្តនិងផែនការការងារដែលឆ្លើយតបនឹងស្ថានភាពជាក់ស្តែងក្នុងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
- រៀបចំវិធាននិងចំណាត់ការសមស្របទាន់ពេលវេលាក្នុងការការពារទប់ស្កាត់ ថែទាំនិងជួសជុលសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិដែលប្រឈមនឹងគ្រោះថ្នាក់ឬឈានទៅរកការបាត់បង់
- ពង្រឹងយន្តការទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួចនិងកាន់កាប់ដោយខុសច្បាប់ទាំងនៅក្នុងនិងក្រៅប្រទេស
- លើកកម្ពស់ការយល់ដឹងនិងបង្កឲ្យមានការចូលរួមពីសាធារណជនក្នុងការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ
- ជំរុញការអភិរក្សបេតិកភណ្ឌក្នុងសហគមន៍
- ពង្រឹងនិងពង្រីកការអភិវឌ្ឍចំណេះដឹងនិងជំនាញវិជ្ជាជីវៈលើវិស័យវប្បធម៌
- ថែរក្សានិងជំរុញឲ្យកាន់តែខ្លាំងចំពោះការផ្ទេរចំណេះដឹងប្រពៃណី
- បង្កើនការយល់ដឹងការយកចិត្តទុកដាក់និងការចូលរួមពីមហាជន ពិសេសយុវជននិងកុមារដោយធ្វើការបណ្ដុះបណ្ដាលដោយឈរលើគោលការណ៍ "អប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីអប់រំ"
- ថែរក្សានិងលើកកម្ពស់ការការពារវប្បធម៌ជនជាតិដើមភាគតិច
- បង្កលក្ខណៈឲ្យស្ត្រី កុមារនិងជនពិការចូលរួមកាន់តែច្រើនក្នុងវិស័យវប្បធម៌

**២.ការលើកតម្លៃវប្បធម៌ជាតិ៖**

- ពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវប្បធម៌ជាតិឲ្យកាន់តែទូលំទូលាយតាមរយៈការសម្តែងមហោស្រព ការតាំងពិព័រណ៍។ល។
- ពង្រឹងនិងពង្រីកតួនាទីរបស់សារមន្ទីរ និងមណ្ឌលវប្បធម៌
- ស្រាវជ្រាវនិងផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ជាតិ
- រៀបចំចងក្រងឯកសារបេតិកភណ្ឌប្រណិត និងមានតម្លៃលេចធ្លោរបស់កម្ពុជាដាក់បញ្ចូលក្នុងបញ្ជីរបស់អង្គការយូណេស្កូ

**៣.ការអភិវឌ្ឍវប្បធម៌៖**

- រៀបចំបទដ្ឋានគតិយុត្តនិងយន្តការអនុវត្តសម្រាប់ជួយទ្រទ្រង់ដល់សិល្បករផលិតករ អង្គការ សមាគម និងសហគ្រិនដែលប្រកបអាជីពក្នុងវិស័យវប្បធម៌
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញដល់ការបង្កើតទីផ្សារផលិតផលវប្បធម៌និងទីផ្សារការងារក្នុងវិស័យវប្បធម៌ និងសិល្បៈ
- ពង្រីកទីផ្សារផលិតផលនិងសេវាកម្មវប្បធម៌ ដោយផ្តល់ឱកាសឲ្យបានទូលំទូលាយជូនដល់សិល្បករ ផលិតករ និងអ្នកប្រកបអាជីពក្នុងវិស័យវប្បធម៌ និងសិល្បៈ
- បង្កលក្ខណៈលើកទឹកចិត្តនិងជំរុញដល់ការច្នៃប្រឌិតបង្កើតថ្មីស្នាដៃដើម ហើយថ្មីក្នុងផ្នែកតន្ត្រី សោទស្សន៍ ភាពយន្ត សិល្បៈទស្សនីយភាព សិប្បកម្ម វិចិត្រកម្ម តម្បាញប្រពៃណី និងការរចនាម៉ូដ
- ជំរុញការរៀបចំពិព័រណ៍ស្នាដៃច្នៃប្រឌិតបង្កើតថ្មីក្នុងវិស័យសិល្បៈវប្បធម៌ និងឧស្សាហកម្មច្នៃប្រឌិត
- លើកកម្ពស់វិស័យភាពយន្តនៅកម្ពុជា
- ជំរុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌
- បង្កើតប្រព័ន្ធទិន្នន័យស្តីពីអង្គការ សមាគម និងសហគ្រាសវប្បធម៌
- ធ្វើអត្តសញ្ញាណកម្មវប្បធម៌ និងភូមិមួយផលិតផលមួយ
- រៀបចំយន្តការសម្រួលការនាំចូលសម្ភារៈបច្ចេកវិទ្យាស្តង់ដានិងស្របច្បាប់ជូនដល់សហគ្រិនប្រកបមុខរបរលើវិស័យវប្បធម៌។

## ៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៨៤- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍទីក្រុងដើម្បីឲ្យមានបរិស្ថានល្អសម្រាប់ការរស់នៅ និង មានសោភ័ណភាព ព្រមទាំងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និង ប្រសិទ្ធភាពសង្គម-សេដ្ឋកិច្ច។

៤.១៨៥- ទន្ទឹមនេះ រាជរដ្ឋាភិបាលនៅជួបបញ្ហាប្រឈមមួយចំនួន រួមមាន ប្លង់គោលប្រើប្រាស់ដី និង យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍនៅមិនទាន់ត្រូវបានសិក្សាចប់ និង អនុម័តសម្រាប់ខេត្ត ក្រុងភាគច្រើន ការតាំងទីលំនៅមិនទាន់មានសណ្តាប់ធ្នាប់ល្អនៅឡើយ ការរំលោភយកចំណីផ្លូវ ការរំលោភបំពានលើបឹងធម្មជាតិ ដីគម្របព្រៃ និង ការចាប់យកដីសាធារណៈនៅមិនទាន់ត្រូវបានដោះស្រាយបានល្អនៅឡើយ ផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តទីក្រុង មិនទាន់ត្រូវបានរៀបចំឲ្យមានភាពប្រទាក់ក្រឡា ការដឹកជញ្ជូន និង ចរាចរណ៍នៅក្នុងក្រុងមិនទាន់មានសណ្តាប់ធ្នាប់ល្អដែលធ្វើឲ្យមានការខាតបង់ខាងសង្គម និង សេដ្ឋកិច្ច និង ការមិនទាន់រៀបចំបាននូវក្របខ័ណ្ឌច្បាស់លាស់ សម្រាប់លើកកម្ពស់សោភ័ណភាពនិង អភិរក្សសំណង់ប្រវត្តិសាស្ត្រនៅក្នុងក្រុង។

៤.១៨៦- ក្នុងនីតិកាលទី៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖

ទី១-ការបន្តជំរុញដំណើរការកែទម្រង់ដីធ្លី និង ការបង្កើនល្បឿននៃការកសាងផែនការមេ និង ប្លង់គោលនៃការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក្នុងគោលដៅគ្រប់គ្រង និង អភិវឌ្ឍវិស័យដីធ្លីឲ្យកាន់តែមានប្រសិទ្ធភាព។

ទី២-ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម ការងារប្លង់គោលប្រើប្រាស់ដីរាជធានី ការកសាងប្លង់គោល ប្រើប្រាស់ដីក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ នៅទូទាំងរាជធានី-ខេត្ត ការរៀបចំយុទ្ធសាស្ត្រតម្រង់ទិសក្នុងការកំណត់ បែងចែកតំបន់ប្រើប្រាស់ និង ការគ្រប់គ្រងលំនៅឋានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

ទី៣-ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង ទីប្រជុំជនសំខាន់ៗ សម្រាប់គាំទ្រការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និង ផ្លូវទឹក ក៏ដូចជាប្រព័ន្ធ ផ្គត់ផ្គង់អគ្គិសនី និង ទឹកស្អាត និងជាពិសេសប្រព័ន្ធលូ និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

ទី៤-ការជំរុញការអភិវឌ្ឍវិស័យសំណង់ និង ការរៀបចំទីក្រុង ទីប្រជុំជន ពិសេសក្រុងប៉ោយប៉ែត និង ក្រុងបាវិត ដោយជំរុញការអភិវឌ្ឍ និង ពង្រឹងការអនុវត្តតាមច្បាប់ បទដ្ឋានគតិយុត្ត បច្ចេកទេស និង ស្តង់ដាសំណង់ ដែលធានា គុណភាព សុវត្ថិភាព សោភ័ណភាព ប្រសិទ្ធភាពខ្ពស់ និង គោលការណ៍ទីក្រុងឆ្លាតវៃ ព្រមទាំងជំរុញអនុវត្តកម្មវិធីអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ។

ទី៥-ការបន្តពង្រឹងសោភ័ណភាព និង សេវាទីក្រុង ទីប្រជុំជនសំខាន់ៗ តាមរយៈការគ្រប់គ្រងការប្រមូលសំរាម និង អនាម័យ ការរៀបចំផ្លូវថ្មើរជើង ទីធ្លាចំណត ការរៀបចំសួនច្បារសាធារណៈ ការកសាង និង ការពារច្រាំងទន្លេ និង ទំនប់ ការរៀបចំសណ្តាប់ធ្នាប់ និង

ភ្លើងបំភ្លឺនៅក្នុងក្រុង ការអភិរក្សសំណង់ ដែលមានតម្លៃប្រវត្តិសាស្ត្រ ព្រមទាំងការបន្តរៀបចំពង្រីក និង ពង្រឹងគុណភាព ក៏ដូចជាជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងទីក្រុង។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៨៧- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*** នឹងបន្ត សកម្មភាពជាអាទិភាព រួមមានដូចខាងក្រោម៖

### ១. ការងាររដ្ឋបាលដីធ្លី:

- អនុវត្តផែនការចុះបញ្ជីអចលនវត្ថុឲ្យបាន៧៨% នៅឆ្នាំ២០១៩ ៨៤% នៅឆ្នាំ២០២០ ៩០% នៅឆ្នាំ២០២១ ៩៦% នៅឆ្នាំ២០២២ និងឈានទៅសម្រេច១០០% នៅឆ្នាំ២០២៣ នៃចំនួនក្បាលដីប៉ាន់ស្មានសរុប៧លានក្បាលដី
- ចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព ឲ្យបានចំនួន១០ សហគមន៍ ក្នុងមួយឆ្នាំ
- ពន្លឿនការចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ចដែលនៅសេសសល់ចំនួន ១១៩ក្រុមហ៊ុន និងដីរដ្ឋផ្សេងទៀត
- សិក្សាបទដ្ឋានគតិយុត្តដើម្បីបញ្ចូលព័ត៌មានស្តីពីសំណង់នៅលើបណ្ណកម្មសិទ្ធិ
- ពន្លឿនការដោះស្រាយវិវាទដីធ្លីតាមគ្រប់យន្តការ រួមមាន យន្តការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គណៈកម្មការសុរិយោដី ក្រុមដោះស្រាយវិវាទចល័ត និងយន្តការដែលបង្កើតបន្ថែមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីភាពសុខដុមរមនាក្នុងសង្គម
- ទប់ស្កាត់ការចូលរំលោភកាន់កាប់ដីរដ្ឋគ្រប់ប្រភេទដើម្បីធ្វើជាកម្មសិទ្ធ មានជាអាទិ៍៖ ដីព្រៃឈើ ដីក្នុងដែននេសាទដែលត្រូវការពារ ដីក្នុងតំបន់ការពារធនធានធម្មជាតិ និងបរិស្ថាន ដីចំណីផ្លូវថ្នល់ និងផ្លូវរថភ្លើង
- ពង្រីកបណ្តាញបង្គោលប្រឹថពីវិភាគលំដាប់ទី២ លំដាប់ទី៣ និងលំដាប់ទី៤ ដើម្បីគាំទ្រដល់ការកសាងផែនទី និងការចុះបញ្ជីអចលនវត្ថុនៅទូទាំងប្រទេស
- ធ្វើបច្ចុប្បន្នភាពបញ្ជីវាយនាមភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ភូមិ ឃុំ សង្កាត់ដែលបង្កើតថ្មី។

### ២.ការងាររៀបចំដែនដី និងនគរូបនីយកម្ម:

- ជំរុញ និងអនុម័តផែនការរូបវន្ត ដូចខាងក្រោម៖
  - ▪ផែនការរៀបចំដែនដីថ្នាក់ជាតិ

▪ ផែនការរៀបចំដែនដីតាមតំបន់ចំនួន៣ គឺ តំបន់ឆ្នេរសមុទ្រ តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ជុំវិញរាជធានីភ្នំពេញ
▪ ផែនការរៀបចំដែនដីថ្នាក់ខេត្តចំនួន១២
▪ ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជនចំនួន២២
▪ ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ចំនួន៣៨
▪ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន១៧៩។

- ជំរុញនិងអនុម័តផែនទីព្រំប្រទល់រដ្ឋបាល ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងផែនទីប្រើប្រាស់ដីបច្ចុប្បន្ន នៃក្រុង ស្រុក ខណ្ឌ តាមបណ្តារាជធានី ខេត្ត ទាំងអស់ចំនួន១៩៧ ត្រឹមឆ្នាំ២០១៩។

### ៣.ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា:

- រៀបចំ និងអនុម័តផែនការរូបវន្តតំបន់ឆ្នេរសមុទ្រកម្ពុជា៖ ១. ប្លង់គោលប្រើប្រាស់ដីកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន ៧កោះ ២. ប្លង់គោលប្រើប្រាស់ដីក្រុងកោះរ៉ុង ៣. ប្លង់គោល និងប្លង់លម្អិតដីចំណីឆ្នេរសមុទ្រ ដៃសមុទ្រ ស្ទឹង ព្រែក បឹង ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- សាងសង់ និងបោះបង្គោលព្រំប្រទល់ដីចំណីឆ្នេរសមុទ្រ ព្រែក ស្ទឹង អូរ បឹង និងបណ្តាញផ្លូវទឹកដែលភ្ជាប់ទៅនឹងសមុទ្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- បោះបង្គោលប្រឹថពីភិភាគ និងរៀបចំផែនទីរូបថតពីលើអាកាស នៅតាមកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា។

### ៤. ការងារលំនៅឋាន និងសម្បទានដីសង្គមកិច្ច:

- ដាក់ឲ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងទិន្នន័យលំនៅឋានទូទាំងប្រទេស
- កសាងផែនទីទីតាំងសំណង់បណ្តោះអាសន្ន និងសហគមន៍ប្រជាពលរដ្ឋក្រីក្រ និងព័ត៌មានសេវាកម្មឥណទានលំនៅឋាននៅតាមបណ្តារាជធានី ខេត្ត
- បន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ដើម្បីចែកដីជូនប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដីចំនួន៥០០គ្រួសារ ក្នុងមួយឆ្នាំ និងបន្តអនុវត្តចែកដី និង/ឬផ្ទះ ជូនកងកម្លាំងកំពុងឈរជើងនៅតាមព្រំដែន ចំនួន៥០០ខ្នង ក្នុងមួយឆ្នាំ
- ចងក្រងបង្កើតជាភូមិផ្លូវការសម្រាប់ទីតាំងសម្បទានសង្គមកិច្ចដែលបានរៀបចំ និងសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ជំរុញដោះស្រាយសំណង់មិនរៀបរយតាមទីក្រុង និងទីប្រជុំជន តាមរូបភាពអភិវឌ្ឍនៅនឹងកន្លែង ឬតាំងទីលំនៅថ្មី ស្របតាមសារាចរណែនាំលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

- ជំរុញការសាងសង់លំនៅឋានសម្រាប់ជួល និងលក់ជូនប្រជាពលរដ្ឋ ដែលមានចំណូលទាប មធ្យម និងជនងាយរងគ្រោះ ដោយអនុវត្តស្របតាមគោលនយោបាយជាតិស្តីពីលំនៅឋាន និងគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានមានតម្លៃសមរម្យ។

### ៥. ការគ្រប់គ្រង និងអភិវឌ្ឍវិស័យសំណង់:

- ពង្រឹងការគ្រប់គ្រងវិស័យសំណង់ ដោយចាត់វិធានការតឹងរឹងក្នុងការត្រួតពិនិត្យ និងទប់ស្កាត់ការសាងសង់រំលោភលើដីសាធារណៈរបស់រដ្ឋ និង ការសាងសង់គ្មានលិខិតអនុញ្ញាត ការសាងសង់ខុសលិខិតអនុញ្ញាត ដើម្បីជៀសវាងការប៉ះពាល់ដល់សោភ័ណភាព សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និងឆ្នេរសមុទ្រកម្ពុជា
- ដាក់ឲ្យប្រើប្រាស់ការផ្តល់សេវាសាធារណៈលើការចុះបញ្ជីប្រកបអាជីវកម្មវិស័យសំណង់តាមប្រព័ន្ធអេឡិចត្រូនិក និងឈានទៅពង្រីកបន្ថែមសេវាផ្សេងៗទៀតឲ្យបានទូលំទូលាយ
- ដាក់ឲ្យប្រើប្រាស់នូវការគ្រប់គ្រងទិន្នន័យសំណង់តាមប្រព័ន្ធព័ត៌មានវិទ្យាដែលភ្ជាប់នឹងព័ត៌មានភូមិសាស្ត្រ GIS របស់កម្មវិធី Google Map
- ជំរុញការដោះស្រាយវិវាទក្នុងវិស័យសំណង់ឲ្យមានតម្លាភាព
- ពង្រឹងការគ្រប់គ្រងរូបវន្តបុគ្គល និងនីតិបុគ្គលប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់។

### ៦. ការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត:

- រៀបចំច្បាប់៖ ១. ច្បាប់ស្តីពីសំណង់ ២. ច្បាប់ភូមិបាលថ្មី ៣. ច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម ៤. ច្បាប់ស្តីពីលំនៅឋាន និង ៥. ច្បាប់ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រ៖ គោលនយោបាយជាតិស្តីពីភាពជាដៃគូរវាងវិស័យឯកជននិងវិស័យសាធារណៈលើការងារដីធ្លី និង យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍទីក្រុង ទីប្រជុំជន
- រៀបចំព្រះរាជក្រឹត្យ និងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត៖ ១. ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិបទដ្ឋានបច្ចេកទេសសំណង់ ២. ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈពាក់ព័ន្ធនឹងវិស័យសំណង់ ៣. អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ៤. អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ ៥. អនុក្រឹត្យស្តីពីការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ដែលមិនទាន់មានគណៈវិជ្ជាជីវៈ ៦. អនុក្រឹត្យស្តីពីអាជ្ញាបណ្ណក្នុងវិស័យសំណង់ ៧. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិវិស័យសំណង់ ៨. អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើសំណង់ ៩. អនុក្រឹត្យស្តីពីលក្ខខណ្ឌ

និងនីតិវិធីនៃការផ្តល់និយ័តភាពសំណង់ ១០. អនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ ១១. អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការសម្រេចលើបណ្តឹងឧបាស្រ័យក្នុងវិស័យសំណង់ ១២. អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ១៣. អនុក្រឹត្យស្តីពីប្រភេទសំណង់ដែលតម្រូវឲ្យមានការធានារ៉ាប់រងចំពោះប្រតិបត្តិការសាងសង់ ឬរុះរើ ១៤. អនុក្រឹត្យស្តីពីការបង្កើតមូលនិធិអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា ១៥. លិខិតបទដ្ឋានគតិយុត្តនានា គាំទ្រការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងលំនៅឋាន ។

**តារាងទី ៤.១៧ សូចនាករ ផែនការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២០១៩-២០២៣**

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| ១ | អត្រាចុះបញ្ជីអចលនវត្ថុ (ចេញបណ្ណកម្មសិទ្ធិ) | % | ៧២,៥ | ៧៨ | ៨៤ | ៩០ | ៩៦ | ១០០ |
| ២ | ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | សហគមន៍ | ២៤ | ៣៤ | ៤៤ | ៥៤ | - | - |
| ៣ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ផែនការ | ៨០ | ១៧៩ | ១៩៩ | ២១៩ | ២៣៩ | ២៥៩ |
| ៤ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ | ប្លង់គោល | - | ១៩ | ២៥ | ២៩ | ៣៤ | ៣៨ |
| ៥ | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជន | ប្លង់គោល | ៩ | ២៣ | ២៥ | ២៧ | ២៩ | ៣១ |
| ៦ | ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ផែនការ | ៣ | ៧ | ៩ | ១១ | ១៣ | ១៥ |
| ៧ | ផែនការរៀបចំដែនដីតាមតំបន់ | ផែនការ | - | ១ | ១ | ២ | ២ | ៣ |
| ៨ | ផែនការរៀបចំដែនដីថ្នាក់ជាតិ | ផែនការ | - | ០ | ០ | ០ | ០ | ១ |
| ៩ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | គ្រួសារ | ៧៨ ៥៤៥ | ៧៩ ០៤៥ | ៧៩ ៥៤៥ | ៨០ ០៤៥ | ៨០ ៥៤៥ | ៨១ ០៤៥ |
| ១០ | សាងសង់ផ្ទះជូនគ្រួសារកងទ័ព នគរបាលជាតិ និងអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ | ខ្នងផ្ទះ | **៦ ៦៩៩** | ៧ ១៩៩ | ៧ ៦៩៩ | ៨ ១៩៩ | ៨ ៦៩៩ | ៩ ១៩៩ |

*ប្រភព:* ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៦.៤- ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១៨៨- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមា ពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។

៤.១៨៩- បញ្ហាប្រឈមសំខាន់ៗ រួមមាន ការកើនឡើងនៃការប្រើប្រាស់ធនធានធម្មជាតិ ការថយចុះគុណភាពបរិស្ថាន ទាំងទឹក ដី និង ខ្យល់ សមត្ថភាពយល់ដឹង ក្នុងការបញ្ជ្រាបបច្ចេកវិទ្យាដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងកិច្ចសហប្រតិបត្តិការ និង ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត និង មានតម្រូវការធានាសន្តិសុខ ទឹក និង សន្តិសុខថាមពលស្អាតក្នុងរយៈពេលវែង។

៤.១៩០- ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- ទី១-ការបន្តអនុវត្ត "**ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០**" "**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣**" "**យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣**" "**ផែនការយុទ្ធសាស្ត្ររេដបូកជាតិ**" និង ការប្រើប្រាស់មូលនិធិបរិស្ថានសង្គមឲ្យមានប្រសិទ្ធភាព ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ចបំភាយកាបូនទាប និង ធន់នឹងការប្រែប្រួលអាកាសធាតុ។
- ទី២-ការបន្តពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ អភិរក្សជីវៈចម្រុះ អភិរក្សសម្បត្តិធម្មជាតិ ពិសេសប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ទន្លេមេគង្គ និង តំបន់ឆ្នេរ។
- ទី៣-ការបន្តពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និង សារធាតុគ្រោះថ្នាក់ តាមរយៈការអនុវត្តគោលការណ៍ កាត់បន្ថយការប្រើប្រាស់ឡើងវិញការកែច្នៃឡើងវិញ និង ការបដិសេធ ព្រមទាំងការពង្រឹងយន្តការតាមដាន និង ត្រួតពិនិត្យការបំពុល។
- ទី៤-ការលើកកម្ពស់ការរស់នៅ ដោយមានប្រសិទ្ធភាព និង ចីរភាពធនធាន តាមរយៈការអនុវត្តគោលការណ៍នៃការប្រើប្រាស់ និង ផលិតកម្មប្រកបដោយចីរភាព។
- ទី៥-ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាភាគបរិស្ថាន និង ភាគអាកាសធាតុ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។
- ទី៦-ការបន្តជំរុញការអនុវត្តយន្តការពាណិជ្ជកម្មកាបូន និង ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធការពង្រឹងសមត្ថភាពរៀបចំ និង អនុវត្តវិធានការ ដើម្បីបន្សាំ និង ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការពិនិត្យលទ្ធភាពសិក្សាពីភាពធន់ផ្នែកហិរញ្ញវត្ថុ ក្នុងការឆ្លើយតបទៅគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
- ទី៧-ការបន្តជំរុញការអភិវឌ្ឍ និង អនុវត្តផែនការគ្រប់គ្រងទឹកចម្រុះដើម្បីពង្រីកការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់តាមតម្រូវការ កាត់បន្ថយជាអតិបរមានូវហានិភ័យបណ្តាលមកពីគ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ព្រមទាំងធានាសន្តិសុខទឹករយៈពេលវែង។

ទី៨-ការបន្តការលើកទឹកចិត្ត និង បង្កើនការវិនិយោគលើថាមពលស្អាត និង ថាមពលកកើតឡើងវិញ ពិសេសថាមពលពន្លឺព្រះអាទិត្យ ទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលពីប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈ ពេលវែង។

ទី៩-ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត ព្រមទាំងការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពជំនាញ និង ចំណេះដឹងដល់មន្ត្រីថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ លើផ្នែកបរិស្ថានការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព

៤.១៩១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព*** នឹងបន្តខិតខំអនុវត្តសកម្មភាពការងារជាអាទិភាព រួមមាន៖

**ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

- ធានាសង្គតិភាពលើការរៀបចំអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធីនិរន្តរភាពរបស់ជាតិ និងការបន្សុំអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធី ជាមួយលិខិតូបករណ៍ គោលនយោបាយថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដែលកម្ពុជាបានចូលជាភាគីសមាជិក
- ជំរុញការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ការកសាងធនធានមនុស្ស ការលើកកម្ពស់ការយល់ដឹង ការប្រើប្រាស់បច្ចេកវិទ្យាបៃតង និងបច្ចេកវិទ្យានុយក្លេអ៊ែរ សម្រាប់បម្រើឲ្យគោលបំណងសន្តិភាព ដើម្បីគាំទ្រការអភិវឌ្ឍដោយចីរភាព
- ពង្រឹង និងកែលម្អគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីបង្កើនការចូលរួមចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះ និងប្រសិទ្ធភាពថាមពលរបស់កម្ពុជា
- រៀបចំនិងគាំទ្រការអនុវត្តរបៀបវារៈនៃការស្រាវជ្រាវជាតិដើម្បីធានាការអភិវឌ្ឍដោយចីរភាព។
- ជំរុញការដាក់បញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានិរន្តរភាពបរិស្ថាន និង ធនធានធម្មជាតិក្នុងវិស័យរ៉ែ (ខ្សាច់) និងថាមពល
- ជំរុញនិរន្តរភាពក្នុងការអភិវឌ្ឍ ដែលធានាបាននូវវិបុលភាពសេដ្ឋកិច្ច ទន្ទឹមនឹងរក្សាការពារគុណភាពបរិស្ថាន ការរស់នៅដោយចីរភាព និងភាពពេញលេញនៃធនធានធម្មជាតិ
- ធ្វើទំនើបកម្មក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពក្នុងការបំពេញតួនាទី និងភារកិច្ចពេញលេញដើម្បីធានាអភិបាលកិច្ចល្អនិងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា
- រៀបចំ និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនិរន្តរភាព។

**ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**

- ធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការទទួលខុសត្រូវភាពម្ចាស់ការ សំដៅធានានិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន
- ជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងបង្កលក្ខណៈងាយស្រួលសម្រាប់វឌ្ឍនភាពនៃការកសាងសង្គមមួយ ដែលបញ្ចេញកាបូនតិច រួមទាំងទាក់ទាញវិស័យឯកជនក្នុងការវិនិយោគដែលវៃឆ្លាតខាងអាកាសធាតុ
- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តន៍ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បង្កើនការវិភាជថវិកាជាតិសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- បង្ហាញគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដល់វិស័យឯកជនដើម្បីអនុវត្តការវិនិយោគដែលវៃឆ្លាតខាងអាកាសធាតុ។

**ជីវៈចម្រុះ និងជីវសុវត្ថិភាព**

- ធានានិរន្តរភាពមុខងារ និងតួនាទីពេញលេញរបស់ធនធានជីវៈចម្រុះ ជីវសុវត្ថិភាព និងប្រព័ន្ធអេកូឡូស៊ី រួមទាំងអនុវត្តយន្តការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី
- រៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី
- ជំរុញការអភិរក្សព្រៃដែនធម្មជាតិ ។

## តារាងទី ៤.១៨ សូចនាករសំខាន់ៗ ការងារប្រែប្រួលអាកាសធាតុ ២០១៩-២០២៣

| ល.រ | សូចនាករ | ឯកតា | ទិន្នន័យ មូលដ្ឋាន ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|---|
| ១ | ចំនួនគោលនយោបាយ បទប្បញ្ញត្តិ គោលការណ៍ណែនាំ អនុស្សារណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ចំនួន | ៥ | ០ | ២ | ២ | ២ | ២ | ១ |
| ២ | ចំនួនទីប្រជុំជនក្រុងដែលបានអនុម័ត និងអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ២០១៨-២០៣០ | ចំនួន | ១ | ៨ | ៨ | ១២ | ១២ | ១២ | ០ |
| ៣ | ចំនួនផែនការតាមវិស័យដែលបានវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ | ចំនួន | ០ | ០ | ១ | ១ | ១ | ១ | ០ |
| ៤ | សមាមាត្រនៃថាមពលកកើតឡើងវិញក្នុងថាមពលដែលប្រើប្រាស់សរុប | % | ០,៧៥ | ០,៨៥ | ១ | ១,២ | ១,៤ | ១,៦ | ១,៦៦ |
| ៥ | បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយធៀបទិន្នន័យឆ្នាំគោល | Gg $CO_2$ សមមូល | ២ ៤៤៣ ០៤០ | ២ ៤៩៧ ២៧៥ | ២ ៧៩ ៨៥២ | ២ ៨៣៥ ៧៨១ | ២ ៨៨៧ ១៨១ | ២ ៩១៧ ៣៥២ | ៣ ០១៨ ៣៧ |
| ៦ | ភាគរយនៃឃុំ/សង្កាត់ងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ | % | ៤២ | ៤០ | ៣៩ | ៣៨ | ៣៧ | ៣៦ | ៣៥ |
| ៧ | កម្រិតត្រៀមរបស់ស្ថាប័នក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | % | ៤៥ | ៤៩ | ៥៣ | ៥៧ | ៦០ | ៦៣ | ៦៥ |
| ៨ | ក្រសួង/ស្ថាប័នដែលបានបញ្ជ្រាបបញ្ហាជីវៈចម្រុះក្នុងផែនការនៃវិស័យពាក់ព័ន្ធ | ចំនួន | ២ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
| ៩ | ទីតាំងនៃតំបន់អភិរក្សក្រៅដែនធម្មជាតិ | ចំនួន | ០ | ១ | ៣ | ៥ | ៧ | ៨ | ៨ |
| ១០ | ទីតាំងអនុវត្តការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី | ចំនួន | ០ | ១ | ២ | ៣ | ៤ | ៦ | ៨ |

***ប្រភព:*** ក្រសួងបរិស្ថាន

# ជំពូកទី៥
# តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ

# ជំពូកទី ៥

## តម្លៃដែលត្រូវចំណាយ ធនធាននិងការកំណត់កម្មវិធីចំណាយ

៥.១- ជំពូកនេះបង្ហាញអំពីតម្រូវការធនធានសម្រាប់ការវិនិយោគ ដើម្បីសម្រេចបានទិសដៅនិងចំណុចដៅរបស់ **ផ.យ.អ.ជ. ២០១៩-២០២៣**។ ខណៈដែលទំហំនៃការវិភាគផ្តោតទៅលើសេដ្ឋកិច្ចទាំងមូល ការផ្តោតចំបងរបស់យើង គឺវិនិយោគសាធារណៈដែលអាចរកបានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយដែលបានកំណត់នៅក្នុង **ផ.យ.អ.ជ. ២០១៩-២០២៣** និងបញ្ហាប្រឈមកម្មវិធីជាប់ពាក់ព័ន្ធទាំងឡាយ។ ជំពូកនេះ មានបួនផ្នែក ដោយ *ផ្នែកទី១* បង្ហាញអំពីការកំណត់តម្រូវការហិរញ្ញវត្ថុពីវិស័យឯកជននិងវិស័យសាធារណៈ សម្រាប់កសាងទិន្នន័យដូចដែលបានកំណត់នៅក្នុងជំពូកមុនៗ ក៏ដូចជាកំណត់នៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល *ផ្នែកទី២* វិភាគទៅលើតម្រូវការសរុបនៃវិនិយោគសាធារណៈ ដូចដែលបានដាក់ចេញជាតម្រូវការដែលស្នើឡើងនៅក្នុងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) *ផ្នែកទី៣* ពិនិត្យទៅលើប្រភពធនធាននិងគម្លាត រវាងតម្រូវការនិងធនធានដែលមានស្រាប់ ដែលទាមទារឲ្យមានការបំពេញហិរញ្ញប្បទានបន្ថែម ដូចបានគូសបញ្ជាក់នៅក្នុងការវាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ដែលបោះពុម្ពផ្សាយនៅឆ្នាំ២០១៨ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមនឹងយុទ្ធសាស្ត្រគៀរគរធនធានដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង*ផ្នែកទី៤* ពិភាក្សាអំពីជម្រើសក្នុងការពង្រីកការបន្សុីគ្នារវាងការរៀបចំផែនការវិនិយោគសាធារណៈ។

៥.២- រាជរដ្ឋាភិបាលទទួលស្គាល់អាទិភាពនៃហិរញ្ញប្បទានគ្រប់ទម្រង់ដែលជាតម្រូវការវិនិយោគនៃប្រទេសមានចំណូលមធ្យមនិងមានការរីកចម្រើនឆាប់រហ័ស។ ចំពោះវិស័យសាធារណៈ មានតម្រូវការហិរញ្ញប្បទានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ សាលារៀននិងមន្ទីរពេទ្យថ្មី និងប្រព័ន្ធគាំទ្រថ្មីៗទៀត ដែលចាំបាច់ដូចជាកម្មវិធីគាំពារសង្គមជាដើម។ ក្នុងកំឡុងពេលនៃវដ្តរៀបចំផែនការថ្មី វិនិយោគសាធារណៈនឹងនៅតែបន្តផ្តល់អាទិភាពទៅលើវិស័យសង្គមកិច្ច ក៏ដូចជាតម្រូវការក្នុងការដាក់គោលដៅវិនិយោគទៅលើក្រុមជនងាយរងគ្រោះ។ នៅក្នុងវិស័យឯកជន ការវិនិយោគទាមទារឲ្យបង្កើតការផ្លាស់ប្តូរជាជំហានៗ ទៅលើផលិតភាពផលិតកម្ម និងការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីៗ ដើម្បីរក្សាឲ្យមានភាពប្រកួតប្រជែង និងបរិមាណការងារមួយក្នុងកម្រិតខ្ពស់។

៥.៣- លើសពីនេះទៀត រាជរដ្ឋាភិបាលនឹងបន្តការពង្រឹងនិងពង្រីកប្រភេទនិងទំហំប្រតិបត្តិការរវាងក្រសួង ស្ថាប័នជាមួយនឹងដៃគូអភិវឌ្ឍ ប៉ុន្តែទាមទារឲ្យមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើដៃគូដែលផ្តល់កិច្ចគាំទ្រទាក់ទងនឹងធនធានហិរញ្ញវត្ថុ។ ដោយសារការធ្លាក់ចុះនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ជាពិសេស ជំនួយឥតសំណង តួនាទីរបស់វិស័យឯកជនត្រូវបានទទួល

ស្គាល់កាន់តែទូលាយ និងដើរតួនាទីជាហិរញ្ញប្បទានសាធារណៈក្នុងស្រុក។ កិច្ចប្រឹងប្រែងនឹងត្រូវធ្វើឡើងតាមរយៈការពង្រឹងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាលក្នុងការកៀរគរ គ្រប់គ្រង និងវិនិយោគ។

**៥.៤-** ជាចុងក្រោយ ដូចដែលបានពិភាក្សានៅជំពូកមុនៗ រាជរដ្ឋាភិបាលនឹងរក្សាសកម្មភាពប្រាកដនិយមក្នុងកិច្ចបន្តការពង្រឹង និងការធ្វើឲ្យប្រសើរឡើងនូវភាពស៊ីចង្វាក់គ្នារវាងការរៀបចំផែនការ រួមទាំងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាមួយនឹងការអនុវត្តចំណាយវិនិយោគសាធារណៈក៏ដូចជាហិរញ្ញប្បទានសហប្រតិបត្តិនានា តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាឲ្យមានការបន្សុីគ្នា ការផ្សារភ្ជាប់រវាងផែនការនិងថវិកា នឹងត្រូវធ្វើឡើងរវាងការរៀបចំផែនការ(ដាក់ចេញនៅក្នុងផ.យ.អ.ជ. និងកម្មវិធីវិនិយោគសាធារណៈ ដែលទទួលខុសត្រូវដោយក្រសួងផែនការ) ជាមួយនឹងចំណូលនិងការរៀបចំថវិកាវិនិយោគ(ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា ដែលធ្វើឡើងដោយក្រសួង ស្ថាប័ននិងទទួលខុសត្រូវដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ)។

## តម្រូវការវិនិយោគសរុប

**៥.៥-** រាជរដ្ឋាភិបាលបានកំណត់យកដំណើរការពីរក្នុងការបង្កើតតម្រូវការវិនិយោគ។ *ទី១* ពិនិត្យមើលទៅលើសេដ្ឋកិច្ចទាំងមូល(ឧទាហរណ៍ វិស័យសាធារណៈនិងវិស័យឯកជន) ដែលមាននៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទិន្នន័យនៅទីនេះគឺជាការប៉ាន់ប្រមាណពីលើចុះក្រោម ដែលបានធ្វើឡើងស្របទៅនឹងព្យាករកំណើនដែលកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងទិសដៅសេដ្ឋកិច្ចរយៈពេលវែង(នៅក្នុងកិច្ចប្រឹងប្រែងរក្សាកំណើនពិតនៃផ.ស.ស. ឲ្យលើស៧%ក្នុងមួយឆ្នាំ)។ ជាលទ្ធផល ការប៉ាន់ប្រមាណសម្រាប់វិនិយោគសាធារណៈ គឺមានសង្គតិភាពជាមួយដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលផ្តល់នូវនីតិវិធីសម្រាប់ថវិកាមូលធន និងថវិកាចរន្ត។ *ទី២* ចំហាកម៉ាក្រូសេដ្ឋកិច្ចត្រូវបានពិភាក្សាជាហូរហែក្នុងជំពូកទី៣ ហើយដែលផ្តល់នូវចំណោលវិនិយោគសរុបរបស់វិស័យឯកជន និងវិនិយោគសាធារណៈ ដែលបានប្រើនៅក្នុងផ.យ.អ.ជ.។ ចំណុចទាំងនេះត្រូវបានរំលេចម្តងទៀតនៅក្នុងតារាង ៥.១ ខាងក្រោម (ជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល)។

## តារាងទី ៥.១ : វិនិយោគមូលធនដែលត្រូវការចាំបាច់ដើម្បីសម្រេចបានកំណើន ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ហិរញ្ញប្បទានឆ្នាំ២០១៩-២០២៣

| ប្រភពហិរញ្ញប្បទាន | ២០១៩ (ចំណោល) | ២០២០ (ចំណោល) | ២០២១ (ចំណោល) | ២០២២ (ចំណោល) | ២០២៣ (ចំណោល) | សរុប |
|---|---|---|---|---|---|---|
| | គិតជាលានដុល្លារអាមេរិក | | | | | |
| **វិនិយោគសាធារណៈសរុប** | **២ ២៥៧** | **៣ ៣៨២** | **៣ ៣៧៦** | **៣ ៥២៧** | **៣ ៩១២** | **១៦ ៤៥៤** |
| ហិរញ្ញប្បទានក្នុងស្រុក | ៧៣៨ | ១ ៦៣៦ | ១ ៥១៩ | ១ ៥៣៩ | ១ ៥៦៦ | ៧ ០០០ |
| ហិរញ្ញប្បទានក្រៅប្រទេស | ១ ២៩៨ | ១ ៤៧៦ | ១ ៥៦១ | ១ ៦៣៤ | ១ ៩៣៤ | ៨ ១៥៤ |
| **វិនិយោគឯកជនសរុប** | **៦ ៥១៩** | **៧ ៤៤៧** | **៨ ៥២៤** | **៩ ៧៧៤** | **១១ ១៧៤** | **៤៣ ៤៣៨** |
| ហិរញ្ញប្បទានក្នុងស្រុក | ២ ៨៥៣ | ៣ ១១៨ | ៣ ៤០៥ | ៣ ៧១៩ | ៤ ០១២ | ១៧ ១០៧ |
| ហិរញ្ញប្បទានក្រៅប្រទេស | ៣ ៦៦៦ | ៤ ៣២៨ | ៥ ១១៩ | ៦ ០៥៥ | ៧ ១៦២ | ២៦ ៣៣១ |
| **វិនិយោគសរុប** | **៨ ៧៧៦** | **១០ ៨៣០** | **១១ ៩០១** | **១៣ ៣០១** | **១៥ ០៨៦** | **៥៩ ៨៩០** |
| | គិតជាប៊ីលានរៀល | | | | | |
| **វិនិយោគសាធារណៈសរុប** | **៩ ២៥៧** | **១៣ ៨៧០** | **១៣ ៨៤៥** | **១៤ ៤៦៣** | **១៦ ០៤៣** | **៦៧ ៤៧៩** |
| ហិរញ្ញប្បទានក្នុងស្រុក | ៣ ០២៨ | ៦ ៧១១ | ៦ ២៣០ | ៦ ៣១០ | ៦ ៤២១ | ២៨ ៧០០ |
| ហិរញ្ញប្បទានក្រៅប្រទេស | ៥ ៣២៤ | ៦ ០៥៣ | ៦ ៤០៤ | ៦ ៧៣៨ | ៨ ០៩៦ | ៣២ ៦១៥ |
| **វិនិយោគឯកជនសរុប** | **២៦ ៧២៧** | **៣០ ៥៣២** | **៣៤ ៩៥០** | **៤០ ០៧៣** | **៤៥ ៨១២** | **១៧៨ ០៩៦** |
| ហិរញ្ញប្បទានក្នុងស្រុក | ១១ ៦៩៧ | ១២ ៧៨៦ | ១៣ ៩៦០ | ១៥ ២៤៦ | ១៦ ៤៤៧ | ៧០ ១៣៨ |
| ហិរញ្ញប្បទានក្រៅប្រទេស | ១៥ ០២៩ | ១៧ ៧៤៦ | ២០ ៩៩០ | ២៤ ៨២៦ | ២៩ ៣៦៤ | ១០៧ ៩៥៧ |
| **វិនិយោគសរុប** | **៣៥ ៩៨៤** | **៤៤ ៤០២** | **៤៨ ៧៩៥** | **៥៤ ៥៣៦** | **៦១ ៨៥៥** | **២៤៥ ៥៧៤** |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

(ចំណាំ៖ អត្រាប្តូរប្រាក់ ១ដុល្លារអាមេរិក ស្មើនឹង៤ ១០០រៀល, (*)គម្លាតនៃលេខសរុប គឺជាការទូទាត់ប្រាក់កម្ចីរបស់រាជរដ្ឋាភិបាលកម្ពុជា។

**៥.៦-** ទោះជាយ៉ាងណា ជាការសំខាន់ណាស់ដោយត្រូវបញ្ជាក់ថាតួលេខទាំងនេះ គឺជាទំហំនៃការព្យាករ ហើយក៏មិនបានដាក់បញ្ចូលនូវវិស័យសាធារណៈ ជម្រើសគោលនយោបាយថ្មីៗសម្រាប់វិស័យឯកជននិងសាធារណៈ ក៏ដូចជាព្រឹត្តិការណ៍ធំៗដែលអាចប៉ះពាល់លើការវិនិយោគ និងការប្រែប្រួលអញ្ញត្តិនៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនោះដែរ។ ជាថ្មីម្តងទៀត នេះជាចំណុចចាប់ផ្តើមដ៏មានសារៈសំខាន់មួយ និងដែលបានដាក់ចេញជាតម្រូវការវិនិយោគសម្រាប់ **ផ.យ.អ.ជ. ២០១៩-២០២៣** ដែលរួមមានដូចជា៖

- វិនិយោគមូលធនសរុប មានចំនួន៥៩,៨ប៊ីលានដុល្លារអាមេរិក សមមាត្រ ២៤៥ ៥៧៤ ប៊ីលានរៀល សម្រាប់ ២០១៩-២០២៣
  - វិនិយោគមូលធនរបស់វិស័យឯកជន មានចំនួន៤៣,៤ប៊ីលានដុល្លារអាមេរិក សមមាត្រ ១៧៨ ០៩៦ប៊ីលានរៀល ស្មើនឹង ៧២,៥% នៃទុនវិនិយោគសរុប

- វិនិយោគមូលធននៃវិស័យសាធារណៈ មានចំនួន១៦,៤ប៊ីលានដុល្លារអាមេរិក សមមាត្រ ៦៧ ៤៧៩ប៊ីលានរៀល ស្មើនឹង ២៧,៥% នៃទុនវិនិយោគសរុប។

**៥.៧-** ការព្យាករសម្រាប់ពេលកន្លងទៅថ្មីៗ និងនាពេលអនាគត ត្រូវបានបង្ហាញជាបន្តបន្ទាប់នៅក្នុងរូបភាព ៥.១ និង ៥.២។ ចំណុចពិសេសៗដែលបានបង្ហាញឡើង គឺ *ទី១* ភាពលើសលប់នៃកម្រិតវិនិយោគឯកជនទៅលើកម្រិតវិនិយោគសាធារណៈនិងការកត់សម្គាល់ថាហិរញ្ញប្បទានឯកជនមានតួនាទីសំខាន់ក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជា *ទី២* ភាពផ្សេងគ្នារវាងប្រភពធនធានខាងក្នុងនិងខាងក្រៅ ស្របពេលដែលវិនិយោគឯកជនត្រូវបានទ្រទ្រង់ដោយថវិកាវិនិយោគរួមគ្នានៃធនធានក្នុងស្រុកនិងបរទេស ហើយវិនិយោគសាធារណៈមានប្រភពពីហិរញ្ញប្បទានក្រៅប្រទេសនិងដែលមាននិន្នាការកើនឡើងជាលំដាប់ និង *ទី៣* វិស័យសាធារណៈឃើញថាការរំលស់បំណុលកាន់តែមានសារៈសំខាន់ដោយសារតែបំណុលកាន់តែកើនឡើង។ ការព្យាករទាំងនេះបានសន្មតថាហិរញ្ញប្បទានសាធារណៈក្នុងស្រុកត្រូវបានបំពេញដោយថវិកាចរន្ត (ឧទាហរណ៍ ប្រភពចំណូល) នៅក្នុងរយៈពេលមធ្យម។ លើសពីនេះទៀត រាជរដ្ឋាភិបាលនឹងនៅតែបន្តពឹងផ្អែកទៅលើកម្ចីសម្បទានដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុសាធារណៈសម្រាប់អំឡុងពេលនៃវដ្តផែនការ។

## រូបភាពទី ៥.១ : សមាសភាគនៃវិនិយោគវិស័យឯកជន (គិតជាដុល្លារអាមេរិក)




*ប្រភព :* ការគណនារបស់ក្រសួងផែនការដោយផ្អែកលើទិន្នន័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រូបភាពទី ៥.២ : សមាសភាគនៃវិនិយោគវិស័យសាធារណៈ (គិតជាដុល្លារអាមេរិក)**




*ប្រភព :* ការគណនារបស់ក្រសួងផែនការដោយផ្អែកទៅលើទិន្នន័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## តម្រូវការវិនិយោគសាធារណៈ

**៥.៨-** ជំពូកនេះបង្ហាញអំពីការវិនិយោគសាធារណៈ ដើម្បីគាំទ្រតម្រូវការដែលបានដាក់ចេញនៅក្នុង **ផ.យ.អ.ជ. ២០១៩-២០២៣**។ ដោយពិនិត្យឡើងវិញទៅលើការពិភាក្សាខាងលើ យើងសង្កេតឃើញថាតួលេខវិនិយោគសាធារណៈដែលបានបង្ហាញខាងលើ នៅមានកម្រិតមូលដ្ឋាននៅឡើយដោយសារតែគេមិនបានរួមបញ្ចូលតម្រូវការទាំងអស់នៃចំណាយវិនិយោគសាធារណៈដែលបានគ្រោងទុកដោយរាជរដ្ឋាភិបាល ដូចដែលបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងការប្តេជ្ញាចិត្តគោលនយោបាយដ៏ទៃទៀត រួមទាំងផែនការអភិវឌ្ឍន៍តាមវិស័យ ដែលចាំបាច់ត្រូវពិចារណាសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៦នេះ។ ត្រង់នេះយើងត្រូវពិនិត្យមើលឡើងវិញវិធីសាស្ត្រពីក្រោមទៅលើ ដែលបានដាក់ស្នើដោយក្រសួង ស្ថាប័នសម្រាប់កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ដែលដាក់ចេញពេញលេញនូវកញ្ចប់គម្រោងអាទិភាពរំពឹងទុក។ ខណៈពេលដែលយន្តការនេះ នៅកំពុងដំណើរការនៅឡើយ យើងនៅតែអាចធ្វើការប៉ាន់ស្មានបានពីកម្រិតនៃការចំណាយបន្ថែម ដែលនឹងត្រូវស្វែងរកដោយក្រសួង ស្ថាប័នតាមរយៈការពិនិត្យមើលវដ្តមុនៗនៃផ.យ.អ.ជ.កន្លងមក។ សំណើរនេះអាចមានប្រមាណ ៤៩% លើសពីលើចំនួនដែលបានផ្តល់ដោយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច។

**៥.៩-** ទាំងនេះឆ្លុះបញ្ចាំងជាពិសេសអំពីការប្តេជ្ញាចិត្តថ្មីៗផ្នែកគោលនយោបាយសម្រាប់ការផ្លាស់ប្តូរគោលនយោបាយនិងអាទិភាពសំខាន់ៗ ឧទាហរណ៍ ការលើកកម្ពស់វិស័យអប់រំ និងការបង្កើតប្រព័ន្ធគាំពារសង្គមជាមូលដ្ឋានមួយ រួមទាំងការចំណាយថ្មីៗ ដើម្បីគាំទ្រលើកកម្ពស់សមត្ថភាពបច្ចេកទេសរដ្ឋបាលនៃស្ថាប័នរាជរដ្ឋាភិបាល។ ប្រសិនបើយើងដាក់បញ្ចូលប្រភេទ

ចំណាយទាំងនេះទៅក្នុងការធ្វើចំណោលកំណើនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នោះយើងឃើញថា តម្រូវការវិនិយោគមូលធនប្រមាណ៧,០ពាន់លានដុល្លារអាមេរិក សមមូល២៨ ៩៣១ ប៊ីលានរៀល បន្ថែមទៀត សម្រាប់វដ្តផែនការ ដូចមាននៅក្នុងតារាង៥.២។

**៥.១០-** ចំណោលកំណើននេះ ផ្តល់នូវភាពប្រាកដជាងមុននៃតម្រូវការថវិកាសរុប សម្រាប់រាជរដ្ឋាភិបាលក្នុងសម្រេចបានគោលបំណងគោលនយោបាយ ផ.យ.អ.ជ. ថ្មីនេះ។ ផ្នែកដែលបានអនុម័តទាំងនេះតំណាងឲ្យភាពទូលំទូលាយនៃគម្រោង និងអាទិភាពកម្មវិធីវិនិយោគសាធារណៈទាំងឡាយរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយវានឹងពុំមានន័យទេប្រសិនបើក្រសួងស្ថាប័នទាំងអស់មិនអាចបំពេញធាតុចូលសម្រាប់កម្មវិធីវិនិយោគសាធារណៈ ដែលនាំឲ្យចំនួនសរុបនេះអាចនឹងត្រូវបានប៉ាន់ស្មានទាបពេកធៀបទៅនឹងតម្រូវការជាក់ស្តែងទាំងមូល។ ជាក់ស្តែងកម្មវិធីវិនិយោគសាធារណៈផ្អែកទៅលើវដ្ត៣ឆ្នាំ។ ក្រសួងផែនការនឹងរក្សាចំនួនសរុបនេះឲ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យបន្ថែម រួចនឹងធ្វើការកែតម្រូវនៅពេលមានទិន្នន័យថ្មី។ រាជរដ្ឋាភិបាលនឹងពង្រឹងបន្ថែម រួមទាំងធ្វើឲ្យប្រសើរឡើងផងដែរនូវដំណើរការរៀបចំផែនការ និងការធ្វើវិភាជថវិកា ក៏ដូចជាកសាងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាល។ កិច្ចការនេះនឹងពង្រឹងសុខដុមនីយកម្មនៃកម្មវិធីវិនិយោគសាធារណៈ ជាមួយនឹងហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍ និង កាលវិភាគសម្រាប់រៀបចំថវិកាជាតិ។

**តារាងទី ៥.២ ចំណុចដៅក្នុងការកៀរគរធនធានសម្រាប់វិនិយោគវិស័យសាធារណៈ ២០១៩-២០២៣**

| ចំណុចដៅវិនិយោគសាធារណៈ | ២០១៩-២០២៣ | |
|---|---|---|
| | ពាន់លានរៀល | ពាន់លានដុល្លារអាមេរិក |
| វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ៦៧ ៤៧៩ | ១៦,៥ |
| ការចំណាយមូលធនដ៏ទៃទៀតដែលនឹងត្រូវកំណត់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ | ២៨ ៩៣១ | ៧,០ |
| **សរុប** | **៩៦ ៤១០** | **២៣,៥** |

*ប្រភព :* ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងសំណើក្នុងក.វ.ស. បីឆ្នាំរំកិល ដោយក្រសួង ស្ថាប័ន

## ប្រភពហិរញ្ញប្បទានសក្តានុពលសម្រាប់ចំណាយវិនិយោគសាធារណៈ

**៥.១១-** នៅវដ្តផែនការមុន រាជរដ្ឋាភិបាលជួបបញ្ហាប្រឈមមួយចំនួនក្នុងការសម្រេចបាននូវតម្រូវការវិនិយោគមូលធនរបស់វិស័យសាធារណៈដ៏មានមហិច្ឆតារបស់ខ្លួន ធៀបទៅនឹងលទ្ធភាពជាក់ស្តែងដែលអាចកៀរគរបានពីប្រភពក្នុងស្រុកនិងកម្ចីបរទេស។ នៅពេលអនាគត មានវិធីច្រើនសម្រាប់បំពេញគម្លាតហិរញ្ញប្បទានដែលជាតម្រូវការ។ លើសពីនេះទៀត ការវិភាជថវិកា

របស់រាជរដ្ឋាភិបាលកម្ពុជា និងការប្ដេជ្ញាចិត្តក្នុងការផ្ដល់ហិរញ្ញប្បទានពីប្រភពខាងក្រៅផ្ដល់នូវមូលដ្ឋានដ៏រឹងមាំដែលជួយដល់ការទាក់ទាញហិរញ្ញប្បទានថ្មីៗបន្ថែមទៀត។

**៥.១២-** រាជរដ្ឋាភិបាលបានពិនិត្យមើលច្រកលំហូរហិរញ្ញប្បទានចំនួន៥ គឺ (១)ការគ្រប់គ្រង/ការសម្របសម្រួលប្រសើរជាងមុននៃជំនួយឥតសំណងពីដៃគូអភិវឌ្ឍនានា និងលទ្ធភាពដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍថ្មី (២)ហិរញ្ញប្បទានឥណទានសម្បទានបន្ថែមពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងដៃគូទ្វេភាគី (៣)ប្រភពចំណូលថ្មីៗ ដូចជាថ្លៃឈ្នួល ចំណូលពន្ធបន្ថែម ឬភាពប្រសើរឡើងនូវការប្រមូលចំណូលជាដើម (៤)ប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន និង (៥)កម្ចីថ្មីៗពីប្រភពក្នុងស្រុក។

**៥.១៣-** ផ្អែកលើការវិភាគអំពីតម្រូវការចំណាយសម្រាប់ការអភិវឌ្ឍ ជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍក្នុងរយៈពេលវែងមានការធ្លាក់ចុះពីកម្រិតជាង១០% នាដើមទសវត្សរ៍ឆ្នាំ២០០០ មកត្រឹមរង្វង់៣% នៃផ.ស.ស. នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ(សូមមើលរូបភាព ៥.៣)។ លើសពីនេះទៀត ការប្រែប្រួលនូវសមាសធាតុ កំពុងតែកើតមានឡើងដោយប្ដូរពីជំនួយឥតសំណងមកជាហិរញ្ញប្បទានសម្បទាន ហើយហិរញ្ញប្បទានឥណទានទាំងឡាយក៏កាន់តែមានលក្ខណៈមិនសម្បទានបន្តិចម្ដងៗ។ នេះផ្ទុយទៅនឹងកំណើននៃធនធានសាធារណៈក្នុងស្រុក (ចរន្ត) និងលំហូរនៃមូលធនវិស័យឯកជនក្នុងស្រុកនិងក្រៅស្រុក។

## រូបភាពទី ៥.៣ : ការព្យាករលំហូរនៃហិរញ្ញប្បទាននាពេលអនាគត ឆ្នាំ២០២៥




*ប្រភព :* ការប៉ាន់ស្មានតម្រូវការធនធានសម្រាប់ការអភិវឌ្ឍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៨

៥.១៤- ក្នុងបរិបទនេះ កម្ពុជានឹងពង្រីកនូវកិច្ចប្រឹងប្រែងកៀរគរការវិនិយោគមូលធនបន្ថែមទៀត ដោយឈោងចាប់នូវកាលានុវត្តភាពថ្មីៗ ប៉ុន្តែនៅក្នុងរង្វង់ជំនួយអភិវឌ្ឍន៍ផ្លូវការ រាជរដ្ឋាភិបាលនឹងត្រូវខិតខំ (១)បង្កើនគុណភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការជាអតិបរមា តាមរយៈការសម្របសម្រួល និងការគ្រប់គ្រងដែលប្រសើរជាងមុន (២)បង្កើនជំនួយឥតសំណង ដោយលើកទឹកចិត្តម្ចាស់ជំនួយឲ្យងាកទៅរកការរៀបចំថវិកាគាំទ្រវិញ និង (៣)ស្វែងរកការបង្កើននូវឥណទានសម្បទាន ដោយពង្រីកនូវប្រាក់កម្ចីតាមរយៈការចូលរួមពីដៃគូអភិវឌ្ឍដែលផ្តល់សេវាផ្តល់ឥណទានសម្បទាន និងការផ្តល់អាទិភាពដល់ការវិនិយោគណាដែលផ្តល់ផលចំណេញខ្ពស់ ដូចជានៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធជាដើម ។

៥.១៥- ដើម្បីពង្រឹងនូវការបន្សីគ្នានិងសុខដុមនីយកម្ម កម្ពុជានឹងជំរុញដៃគូអភិវឌ្ឍ ក្នុងការគាំទ្រដល់ការអភិវឌ្ឍដែលមានលក្ខណៈអភិក្រមទូទាំងវិស័យ និងគោលការណ៍ដោយផ្អែកលើកម្មវិធីសម្រាប់វិស័យសំខាន់ៗ ដែលជាគន្លឹះក្នុងការសម្រេចបាននូវសមិទ្ធផលរួម និងជៀសវាងការត្រួតស៊ីគ្នា។ រាជរដ្ឋាភិបាល ទទួលស្គាល់ថាប្រតិបត្តិការនៃក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យត្រូវតែពង្រឹងបន្ថែមទៀត និងអាចត្រូវកែសម្រួលឡើងវិញ ដើម្បីផ្សារភ្ជាប់ជាមួយនឹងលំហូរនៃធនធានអភិវឌ្ឍផ្សេងៗទៀត និងធ្វើការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដែលទើបនឹងអនុមតិថ្មីៗនេះ។ ដូច្នេះ កម្ពុជានឹងធ្វើការជាមួយនឹងដៃគូអភិវឌ្ឍក្នុងការពង្រឹងយន្តការក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពង្រីកនូវប្រសិទ្ធភាព កសាងកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន។ ជម្រើសនានា មានដូចខាងក្រោម៖

- រៀបចំឡើងវិញនូវក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការទទួលខុសត្រូវលើវិស័យ ឬបញ្ហាជាក់លាក់ណាមួយ (ដែលមានសក្តានុពលក្នុងការបំពេញបន្ថែមក្នុងការផ្តល់ការណែនាំដូចបានកំណត់នៅក្នុងរបាយការណ៍ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា)
- ទទួលយកនូវការយកចិត្តទុកដាក់ក្នុងក្រុមការងារបច្ចេកទេសចម្រុះ លើការគាំទ្របច្ចេកទេសនិងគោលនយោបាយ។ កិច្ចការនេះអាចសម្រេចបានតាមរយៈការកំណត់សមាជិកពេញលេញរបស់ដៃគូអភិវឌ្ឍ ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់វិស័យ ហើយធានាឲ្យមានការចូលរួមពីបុគ្គលិកជំនាញរបស់ដៃគូអភិវឌ្ឍ និងមន្ត្រីបច្ចេកទេសរបស់រាជរដ្ឋាភិបាល។
- អភិវឌ្ឍបន្ថែមនូវកិច្ចការរដ្ឋបាលរបស់ក្រុមការងារបច្ចេកទេសចម្រុះ រួមមានការរៀបចំរបៀបវារៈ ការជូនដំណឹងគ្នាទៅវិញទៅមក និងការរក្សាទុកនិងចែករំលែកកំណត់ហេតុរបស់កិច្ចប្រជុំក្រុមការងារ។

៥.១៦- ស្របទៅនឹងកិច្ចព្រមព្រៀងក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍ រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តផងដែរដល់ដៃគូអភិវឌ្ឍក្នុងការអនុមតិនូវបែបបទនៃផ្តល់ហិរញ្ញប្បទាន តាមរយៈ **“ការគាំទ្រថវិកា”** សម្រាប់លំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលនៅសល់ ជាពិសេសថវិកាវិនិយោគមូលធន។ នេះនឹងជួយជំរុញដល់ភាពជាម្ចាស់ កាត់បន្ថយចំណាយប្រតិបត្តិការ និងផ្តល់នូវភាពប្រាកដប្រជាក្នុងដំណាក់កាលដែលធនធានទាំងនេះកាន់តែមានភាពខ្សត់ទៅៗ។ រាជរដ្ឋាភិបាលទទួលស្គាល់កិច្ចការនេះមានទំនាក់ទំនងទៅនឹងការអនុមតិលើកិច្ចព្រមព្រៀងលើក្របខ័ណ្ឌនានាដែលមានចំណុចដៅដែលអាចវាស់វែងបាន និងត្រូវរៀបចំឲ្យមានថវិកាគ្រប់គ្រាន់សម្រាប់ការអនុវត្ត។

៥.១៧- ដោយឡែក រាជរដ្ឋាភិបាល នឹងស្វែងរកនូវដៃគូផ្តល់ហិរញ្ញប្បទានឥណទានបន្ថែមទៀតក្នុងការគាំទ្រនូវការចំណាយលើការវិនិយោគមូលធនសាធារណៈ ជាពិសេសលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយរួមបញ្ចូលទាំងស្ថាប័នផ្តល់ហិរញ្ញប្បទានឥណទានទ្វេភាគីនិងពហុភាគីថ្មីៗ។ ប៉ុន្តែ វាត្រូវបានគូសបញ្ជាក់ថា រាល់ហិរញ្ញប្បទានឥណទានទាំងអស់ នឹងត្រូវអនុលោមទៅតាមការពិនិត្យពិច័យកម្រិតខ្ពស់លើសំណើរហិរញ្ញប្បទាន ស្របទៅនឹងការពិនិត្យវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច សង្គមកិច្ចយ៉ាងល្អិតល្អន់នៃគម្រោង ដែលនឹងត្រូវរួមផ្សំជាមួយនឹងការកំណត់អាទិភាពទៅលើអត្រាចំណេញពីការវិនិយោគ។ កត្តាទាំងនេះនឹងត្រូវបានសម្រួលដោយនីតិវិធីថ្មីៗនៅក្នុងក.វ.ស. ៣ឆ្នាំរំកិល និងផែនការថវិកាមូលធននៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា។

៥.១៨- ចំពោះផ្នែកចំណូលវិញ រាជរដ្ឋាភិបាលនឹងបន្តគាំទ្រដល់ការស្វែងរកប្រភពចំណូលថ្មីៗទៀត ហើយតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ នឹងជំរុញការរកចំណូលមិនមែនពន្ធបន្ថែមនៅក្នុងវិស័យគន្លឹះៗ រួមមាន វិធានការក្នុងការដាក់ចេញនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងចំណូលជាតិ ការកសាងសមត្ថភាពនៅតាមក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលទទួលខុសត្រូវក្នុងការកំណត់និងការប្រមូលប្រាក់ឈ្នួល ការចេញអាជ្ញាបណ្ណ និងការដាក់ចេញនូវបទប្បញ្ញត្តិនិងច្បាប់បន្ថែមទៀត ដែលមានសារៈសំខាន់និងពាក់ព័ន្ធដល់ការប្រមូលនូវចំណូលពីធនធានធម្មជាតិ ដូចជាប្រេងនិងឧស្ម័ន និងដល់កំណើនថាមពលកកើតឡើងវិញ។

៥.១៩- លើសពីនេះទៀត ដូចបានចែងនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល រាជរដ្ឋាភិបាលនឹងបន្តគាំទ្រដល់កំណើនដែលមានប្រភពពីពន្ធទូទៅ។ ចំណូលសរុបមានការកើនឡើងជារៀងរាល់ឆ្នាំរហូតដល់២០%នៃផ.ស.ស. ដែលធ្វើឲ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនចំណូលពីពន្ធខ្ពស់ក្នុងចំណោមប្រទេសអាស៊ាន ហើយលើសពីចំណុចដៅរបស់រាជរដ្ឋាភិបាលកំណត់នៅក្នុងយុទ្ធសាស្ត្រមុន ដែលមានកម្រិតកំណើន០,៥% នៃផ.ស.ស.ក្នុងមួយឆ្នាំ។

៥.២០- ចំណូលពន្ធបានចូលរួមវិភាគទានយ៉ាងធំធេង ដែលក្នុងនោះមួយភាគធំទទួលបានមកពីពន្ធក្នុងប្រទេស ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ដែលមានការកើនឡើងរហូតដល់ ៥០% ធៀបទៅនឹងផ.ស.ស. ក្នុងចន្លោះឆ្នាំ២០១៣ និង ២០១៧។ ការកើនឡើងនេះបានផ្តល់នូវវិសាលភាពសម្រាប់ចំណូលបន្ថែមដល់មូលធន ហើយមានការកើនឡើងជាលំដាប់នូវប្រភពចំណូលសម្រាប់ចំណាយលើការវិនិយោគផងដែរ[1]។

៥.២១- ក្នុងការធ្វើដំណើរឆ្ពោះទៅមុខ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ មានទស្សនវិស័យក្នុងការទទួលបាននូវកំណើនបន្ថែមទៀតនៃចំណូលទោះបីជាស្ថិតក្នុងអត្រាយឺតក៏ដោយ ដែលចំណុចដៅនៃកំណើនត្រូវបានកំណត់០,៣%នៃផ.ស.ស.ក្នុង១ឆ្នាំ។ លើសពីនេះទៀត កត្តាជំរុញនៃការពង្រីកបន្ថែមទៀត ត្រូវពាក់ព័ន្ធទៅនឹងការប្រមូលចំណូលបានប្រសើរជាងមុននៃចំណូលពន្ធដែលមានស្រាប់ និង/ឬពន្ធដែលបានកំណត់បន្ថែម។ សំណើរនៃការកសាងសមត្ថភាព និងការគាំទ្របែបរដ្ឋបាល នឹងត្រូវបានស្នើឡើងនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល។ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែខិតខំផងដែរក្នុងការប្រើប្រាស់ពន្ធជាឧបករណ៍គោលនយោបាយក្នុងគោលបំណងជំរុញឥទ្ធិពលទៅលើអ្នកផលិតនិងឥរិយាបទអ្នកប្រើប្រាស់។ ឧទាហរណ៍រួមមានការតម្លើងថ្លៃនិងការកាត់បន្ថយតម្រូវការឬការប្រើប្រាស់ថ្នាំជក់និងផលិតផល ដែលអាចនាំឲ្យគ្រោះថ្នាក់ ហើយផ្ទុយទៅវិញ ជំរុញនូវការទទួលយកនូវបច្ចេកវិទ្យាថ្មីៗ ដោយកាត់បន្ថយនូវអត្រាពន្ធតម្លៃបន្ថែម និង/ឬពន្ធអាករទៅលើផលិតផលដែលត្រូវបានអនុញ្ញាត។ ជារួមកិច្ចប្រឹងប្រែងនេះ នឹងចូលរួមចំណែកវិជ្ជមានចំពោះធនធានសាធារណៈ។

៥.២២- រាជរដ្ឋាភិបាលនឹងបន្តពង្រីកនូវវិសាលភាពនិងការប្រើប្រាស់នូវភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ក្នុងការផ្តល់នូវតម្រូវការវិនិយោគ ដោយមានការយកចិត្តទុកដាក់ទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធជាគន្លឹះ។ ក្នុងនោះរួមបញ្ចូលនូវគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន នៅពេលបច្ចុប្បន្ន ប៉ុន្តែនៅពេលអនាគតនឹងត្រូវពង្រីកទៅដល់គម្រោងនីមួយៗ។ ការប្រើប្រាស់នូវគំរូភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនចូលរួមចំណែកក្នុងការកាត់បន្ថយនូវសម្ពាធលើធនធានមូលធន និងអាចទទួលបានការចូលរួមពីវិស័យឯកជនក្នុងការផ្តល់នូវសេវាសាធារណៈ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍ។

---

[1] គួរកត់សម្គាល់ថា ការទទួលស្គាល់លើនិយមន័យនៃចំណូល និងមូលធន កាន់តែមានភាពមិនច្បាស់លាស់ឡើងៗ ដោយសារតែការចំណាយចរន្តជាច្រើន ដូចជានៅក្នុងវិស័យអប់រំ និងសុខាភិបាល ដើម្បីបម្រើបំពេញតម្រូវការកើនឡើងមូលធនមនុស្ស ។

៥.២៣- ក្នុងស្ថានភាពដែលលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការមានការថយចុះ និងសម្បទាននៃហិរញ្ញប្បទានឥណទានផ្លូវការមានការកាត់បន្ថយ រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្នកំពុងតែធ្វើការស្រាវជ្រាវយ៉ាងសកម្ម និងដាក់ចេញនូវសំណើក្នុងការអភិវឌ្ឍ ស្វែងរកប្រភពប្រាក់កម្ចីក្នុងស្រុកតាមរយៈការដាក់ចេញនូវសញ្ញាបណ្ណជាប្រាក់រៀល។ ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះមិនមានការពឹងផ្អែកទៅលើឧបករណ៍បំណុលសាធារណៈទេ ប៉ុន្តែឧបករណ៍ទាំងនេះ គឺជាសមាសភាគយ៉ាងចាំបាច់នៃហិរញ្ញប្បទានសាធារណៈ នៅក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងប្រទេសដែលមានចំណូលខ្ពស់។ សញ្ញាបណ្ណក្នុងស្រុក ផ្តល់នូវគុណសម្បត្តិដោយលើកកម្ពស់ការអភិវឌ្ឍនៃទីផ្សារមូលធនយ៉ាងទូលំទូលាយ និងផ្តល់នូវឧបករណ៍លុបបំបាត់នូវដុល្លារូបនីយកម្មក្នុងរយៈពេលវែងនៃសេដ្ឋកិច្ចកម្ពុជា។ ព្រះរាជាណាចក្រកម្ពុជាទោះបីជាយ៉ាងណានឹងអនុវត្តនូវភាពប្រុងប្រយ័ត្ន ដោយយកចិត្តទុកដាក់ រក្សាកម្រិតប្រុងប្រយ័ត្នខ្ពស់បំផុតនៃការខ្ចីបំណុលនិងការចំណាយលើការសងបំណុល។

## ការអភិវឌ្ឍនូវសំយោគថ្មី សម្រាប់ការវិនិយោគមូលធន រវាងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និង ថវិកា

៥.២៤- បន្ថែមទៅលើកិច្ចការដែលផ្តួចផ្តើមក្នុងវដ្តផែនការមុន រាជរដ្ឋាភិបាលនឹងបង្កើនល្បឿននៃកិច្ចប្រឹងប្រែងក្នុងការរួមបញ្ចូលគ្នានៃដំណើរការក.វ.ស. និងការអភិវឌ្ឍនៃថវិកាមូលធននៅក្នុងរង្វង់នៃផែនការយុទ្ធសាស្ត្រថវិកា(ស្ថិតក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)។ ស្ថិតក្រោមផែនការសកម្មភាពនៃសុខដុមនីយកម្មនិងការបន្សុីគ្នា កិច្ចការទាំងនេះមានគោលបំណងផ្តល់នូវវិធីសាស្ត្រដែលសង្គតិភាពទៅនឹងការរៀបចំផែនការនិងថវិកា ដែលផ្សារភ្ជាប់ទិសដៅកម្រិតខ្ពស់ទៅនឹងការផ្តល់សេវានិងការអនុវត្ត។

៥.២៥- ក្រសួងផែនការ នឹងពង្រឹងគុណភាពរបស់ក.វ.ស. ក្នុងការផ្តល់នូវគ្រោងធនធានវិនិយោគហើយដែលមានតួនាទីជាឧបករណ៍ក្នុងការអនុវត្តអាទិភាពគោលនយោបាយក្នុងផ.យ.អ.ជ.។ កិច្ចការនេះនឹងជួយធានាថា តម្រូវការចំណាយចរន្តបន្ថែមនៃគម្រោងដែលបានស្នើឡើង ត្រូវបានយកចិត្តទុកដាក់ទៅលើថវិកាប្រចាំឆ្នាំ ហើយគម្រោងដែលបានបញ្ចូលទៅក្នុងក.វ.ស. ត្រូវចាត់ទុកជាគម្រោងអាទិភាពយ៉ាងច្បាស់លាស់។ ធ្វើដូច្នេះនឹងត្រូវឆ្លងកាត់ការណែនាំដ៏ជាក់លាក់ស្តីអំពីលំដាប់លំដោយ ដោយយកចិត្តទុកដាក់លើបរិយាកាសម៉ាក្រូសេដ្ឋកិច្ចនិងសមត្ថភាពក្នុងការកៀរគរធនធានខាងក្រៅ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ត្រូវធានាថាកម្មវិធីនិងគម្រោងទាំងអស់នឹងត្រូវដាក់បញ្ចូលនៅក្នុង ក.វ.ស. ហើយត្រូវបានយកមកពិចារណាក្នុងការផ្តល់ហិរញ្ញប្បទាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

និងក្រសួង ស្ថាប័នត្រូវធានាថាសកម្មភាពកៀរគរធនធាន ត្រូវផ្តោតទៅលើការស្វែងរកហិរញ្ញប្បទានសម្រាប់គាំទ្រដល់កម្មវិធីនិងគម្រោងទាំងនោះ។

៥.២៦- សម្រាប់ផ.យ.អ.ជ.២០១៩-២០២៣ ការវិភាជចំណាយមូលធនតាមវិស័យនិងអនុវិស័យមានបង្ហាញក្នុងតារាង ៥.៣ខាងក្រោម៖

## តារាងទី ៥.៣ : ការវិភាជតាមវិស័យនិងអនុវិស័យនៃវិនិយោគវិស័យសាធារណៈក្នុង ផ.យ.អ.ជ. ២០១៩-២០២៣

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០១៩-២០២៣ | |
|---|---|---|---|
| | | ប៊ីលានរៀល | ប៊ីលានដុល្លារអាមេរិក |
| **វិស័យសង្គមកិច្ច** | **៣២** | **៣០,៨** | **៧,៥** |
| អប់រំ | ១០ | ៩,៦ | ២,៣ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៨ | ៧,៨ | ១,៨ |
| សុខាភិបាល | ១០ | ៩,៦ | ២,៤ |
| កិច្ចគាំពារសង្គម/ការកាត់បន្ថយភាពក្រីក្រ | ៤ | ៣,៨ | ១,០ |
| | | | |
| **វិស័យសេដ្ឋកិច្ច** | **២៤** | **២៣,០** | **៥,៦** |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ៣,៨ | ១,០ |
| ដំណាំតាមរដូវ៖ ស្រូវនិងផ្សេងៗ | ៤ | ៣,៨ | ១,០ |
| អភិវឌ្ឍន៍ជនបទ | ១២ | ១១,៦ | ២,៧ |
| កម្មមន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ៣,៨ | ១,០ |
| | | | |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | **២១** | **២០,២** | **៥,០** |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ១១,៦ | ២,៧ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ៣,៨ | ១,០ |
| ថាមពល និងអគ្គិសនី | ៤ | ៣,៨ | ១,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ១,០ | ០,២ |
| | | | |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | **២១** | **២០,២** | **៥,០** |
| ការបញ្ច្រាបយេនឌ័រ | ១,៥ | ១,៤ | ០,៤ |
| ទេសចរណ៍ | ២ | ២,០ | ០,៥ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ៣,៨ | ១,០ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ៣,៨ | ១,០ |
| វប្បធម៌និងសិល្បៈ | ១,៥ | ១,៤ | ០,៤ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ៧,៨ | ១,៨ |
| | | | |
| **មិនទាន់បែងចែក** | **២** | **២,០** | **០,៥** |
| **សរុបរួម** | **១០០** | **៩៦,៤** | **២៣,៥** |

## ជំពូកទី៦

# ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

# ជំពូកទី ៦

# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ១. សេចក្តីផ្តើម

**៦.១-** ជំពូកទី៦ នេះបង្ហាញអំពីក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់**ផ.អ.យ.ជ. ២០១៩-២០២៣**។ ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃគឺជាស្នូលនៃការអនុវត្តផ.យ.អ.ជ. ដែលជំរុញដល់ការប្រតិបត្តិគោលយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព។ ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ នឹងផ្តល់ឲ្យអ្នករៀបចំផែនការ និង អ្នកអនុវត្តនូវការវាយតម្លៃវឌ្ឍនភាពដែលទទួលបាននៅតាមគម្រោង កម្មវិធី វិស័យ ឬដំណើរការអភិវឌ្ឍទាំងមូល ដែលនឹងត្រូវរៀបចំឲ្យមានជាក្របខ័ណ្ឌលទ្ធផលនិងប្រព័ន្ធការងារ។ ការរៀបចំកិច្ចការទាំងនេះ ក្រសួងផែនការបានផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការសម្រេចបានលទ្ធផលនានាដែលមានចែងក្នុងផ.យ.អ.ជ. និងសម្រេចបានគោលដៅអភិវឌ្ឍន៍។
- ការពង្រឹងសមត្ថភាពនៅក្នុងក្រសួង ស្ថាប័ន ជាពិសេសមន្ត្រីបង្គោលដែលទទួលបន្ទុកការងាររៀបចំផែនការ។
- ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍ វិស័យឯកជន ស្ថាប័នថ្នាក់ក្រោមជាតិ ជាដើម ក្នុងភាពជាដៃគូដែលមានប្រសិទ្ធភាព ដើម្បីជានាសម្រេចបានគោលដៅជាតិ។

**៦.២-** ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ មានគោលបំណងពិពណ៌នាអំពីវឌ្ឍនភាពធៀបនឹងផែនការ ដោយពិនិត្យមើលពីចង្វាក់លទ្ធផល បរិបទ និងមូលហេតុនានា។ ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវមានភស្តុតាងជាចាំបាច់ និងបម្រើជាប្រភពទិន្នន័យសំខាន់ដែលចាំបាច់សម្រាប់ការរៀបចំផែនការនិងកម្មវិធី។

**៦.៣-** ជំពូកនេះមានចំនួន៤ផ្នែក ដោយ*ផ្នែកទី១* បង្ហាញអំពីតួនាទីរបស់ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងសារៈសំខាន់របស់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃក្នុងការរៀបចំគោលនយោបាយនិងការអនុវត្ត *ផ្នែកទី២* បង្ហាញអំពីការរៀបចំនិងក្របខ័ណ្ឌការតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់វដ្តរៀបចំផ.យ.អ.ជ. *ផ្នែកទី៣* បង្ហាញអំពីការតាមដានត្រួត

ពិនិត្យនិងវាយតម្លៃនៅកម្រិតវិស័យនិងថ្នាក់ក្រោមជាតិ និង *ផ្នែកទី៤* បង្ហាញអំពីភាពប្រឈមទាក់ទងនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃនិងការដោះស្រាយបញ្ហាប្រឈមទាំងនេះ។

## ២. តួនាទីនិងសារៈសំខាន់នៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងរៀបចំគោលនយោបាយនិងការរៀបចំផែនការ

**៦.៤-** ការតាមដានត្រួតពិនិត្យ និងវាយតម្លៃជំរុញឲ្យមានការផ្តល់ព័ត៌មានសំខាន់ៗដល់អ្នកអ្នករៀបចំគោលនយោបាយ ឬសម្រេចចិត្តនៅគ្រប់កម្រិតនិងបង្កើតទំនាក់ទំនងនៅក្នុងវដ្តគោលនយោបាយ ដូចក្នុងរូបភាព ៦.១ ខាងក្រោម។ ក្នុងការរៀបចំផ.យ.អ.ជ. ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃនិងប្រព័ន្ធគាំទ្រផ្តល់នូវព័ត៌មានគ្រឡប់ស្តីពីការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្តល់ព័ត៌មាននិងជំរុញការសម្រេចចិត្តផ្នែកប្រតិបត្តិនិងគ្រប់គ្រង ដើម្បីកែលម្អលទ្ធផល និងនៅកម្រិតខ្ពស់ ដើម្បីកែលម្អគោលនយោបាយ។ សម្រាប់ការកែលម្អគោលនយោបាយតម្រូវឲ្យមានការពិនិត្យឡើងវិញយ៉ាងល្អិតល្អន់នូវជំហរគោលនយោបាយ និងការកែសម្រួលបន្តបន្ទាប់នូវគោលដៅចុងក្រោយនានា។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ បម្រើជាការត្រួតពិនិត្យគណនេយ្យភាពនៅគ្រប់កម្រិត ដូចជាក្រសួង ស្ថាប័ន នាយកដ្ឋាន ផ្នែក និងអង្គភាព។ ដូចនេះ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃអាចបម្រើនៅក្នុងប្រព័ន្ធគ្រប់គ្រងសមិទ្ធផល ដែលផ្តល់នូវលក្ខណៈវិនិច្ឆ័យលទ្ធផល ដែលត្រូវគ្នាជាមួយទិន្នន័យធនធានមនុស្សនិងហិរញ្ញវត្ថុ។

**រូបភាពទី ៦.១ : ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងវដ្តគោលនយោបាយ**




**៦.៥-** ការអនុវត្តល្អ គឺក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុលោមតាមតក្កនៃដំណើរការរៀបចំផែនការនិងដំណើរការអនុវត្ត ដែលមានឈ្មោះថាទ្រឹស្តីបទនៃការផ្លាស់ប្តូរ។ ទ្រឹស្តីបទនេះត្រូវបានបង្ហាញជាចង្វាក់លទ្ធផល ដែលជាជំហាននីមួយៗដែលផ្សារភ្ជាប់ស្ថានភាពបច្ចុប្បន្នទៅនឹងលទ្ធផលចុងក្រោយ។ ទ្រឹស្តីបទនេះកំណត់សកម្មភាពនិងលទ្ធផលនៅតាម

កម្រិតផ្សេងៗ និងកំណត់អំពីធាតុចូលនិងដំណើរការនានា ដែលចូលរួមចំណែកក្នុងការសម្រេចបានធាតុចេញ និងឆ្ពោះទៅសម្រេចបានលទ្ធផលនិងឥទ្ធិពល។ ទ្រឹស្តីបទនេះពិពណ៌នាអំពីទំនាក់ទំនងរវាងស្ថានភាពបច្ចុប្បន្ននិងស្ថានភាពចុងក្រោយដែលរំពឹងទុក។ ទ្រឹស្តីបទនៃការផ្លាស់ប្តូរនិងទំនាក់ទំនងជាមួយការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មានបង្ហាញនៅក្នុងរូបភាព ៦.២ ខាងក្រោម៖

## រូបភាពទី ៦.២ : ទ្រឹស្តីបទនៃការផ្លាស់ប្តូរនិងចង្វាក់លទ្ធផល




៦.៦- ចង្វាក់លទ្ធផលអាចត្រូវបានរៀបចំនៅគ្រប់កម្រិត និងមានគោលការណ៍ដូចគ្នាសម្រាប់គ្រប់វិស័យ រដ្ឋបាលថ្នាក់ក្រោមជាតិ កម្មវិធី និងគម្រោង ឬផ.យ.អ.ជ.។ **ធាតុចូល** គឺជាធនធានដែលត្រូវការសម្រាប់អនុវត្តសកម្មភាព ដូចជា ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត ឬចំណេះដឹងជាដើម (ឧទាហរណ៍ សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ ធាតុចូលអាចជាស៊ីម៉ងត៍ វិស្វករជំនាញ ជាដើម)។ **ធាតុចេញ** កើតចេញពីការប្រើប្រាស់ធាតុចូល ដូចជារបាយការណ៍បច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ សមត្ថភាពបច្ចេកទេស ផ្លូវថ្នល់ ផ្លូវដែកដែលត្រូវបានសាងសង់)។ ធាតុចេញទាំងនេះត្រូវបានរំពឹងថានឹងជួយដល់វឌ្ឍនភាពសេដ្ឋកិច្ច ដូចបានរៀបនៅក្នុងផែនការ ដែលឲ្យឈ្មោះថា “**លទ្ធផល**” (ឧទាហរណ៍ ការតភ្ជាប់ប្រសើរជាមុន តម្លៃឡជីស្ទីកទាបជាងមុន។ ចុងក្រោយ លទ្ធផលទាំងនេះត្រូវបានរំពឹងថានឹងជួយលើក

កម្ពស់សុខុមាលភាពប្រជាជន និងធានាក្នុងការសម្រេចបានគោលដៅគោលនយោបាយចុងក្រោយ ឬ “**ឥទ្ធិពល**” (ឧទាហរណ៍ ភាពរុងរឿង និងវិសមភាពធ្លាក់ចុះ)។

**៦.៧-** តាមទ្រឹស្តីបទនៃការផ្លាស់ប្តូរនិងចង្វាក់លទ្ធផល មានការសន្មតមួយចំនួនត្រូវបានបង្កើតឡើងអំពីភាពទាក់ទងគ្នារវាងទំនាក់ទំនងនៅក្នុងចង្វាក់លទ្ធផល ដែលតម្រូវឲ្យមានការកំណត់ឲ្យបានច្បាស់លាស់ និងការបញ្ជាក់ឡើងវិញ ដែលជាផ្នែកមួយនៃដំណើរការការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ជាពិសេស ត្រូវធានាថាធាតុចេញអាចសម្រេចបានដោយប្រើប្រាស់ធាតុចូលដែលបានកំណត់ និងធានាថាលទ្ធផលនឹងត្រូវសម្រេចបានប្រសិនបើសម្រេចបានធាតុចេញ។ ឧទាហរណ៍ ការថែទាំហេដ្ឋារចនាសម្ព័ន្ធ តើការសាងសង់ស្ពានឆ្លងកាត់ទន្លេជាការងារចាំបាច់និងជួយជំរុញពាណិជ្ជកម្ម និងតម្លៃបន្ថែមខ្ពស់ឬទេ និងសម្រេចបានភាពរុងរឿងរបស់ប្រទេសឬទេ? ការសាកល្បងការសន្មត និងសម្រេចបាននិងសង្គតិភាពរបស់ទ្រឹស្តីបទនៃការផ្លាស់ប្តូរពាក់ព័ន្ធនឹងការកំណត់បញ្ហាប្រឈម និងតម្រូវការបច្ចេកទេសវាយតម្លៃ តាមរយៈការវិភាគអំពីជម្រើស និងការវិភាគអំពីបញ្ហានិងដំណោះស្រាយជាដើម។

## ៣. ក្របខ័ណ្ឌការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនិងការរៀបចំសម្រាប់ ផ.យ.អ.ជ. ២០១៩-២០២៣

**៦.៨-** ចង្វាក់លទ្ធផលសម្រាប់ផ.យ.អ.ជ. ត្រូវបានរៀបចំឡើងនៅក្នុងក្របខ័ណ្ឌលទ្ធផលនៅក្នុងជំពូកទី៣ (តារាង ៣.៤) និងត្រូវបានសង្ខេបនៅក្នុងតារាង ៦.១ ខាងក្រោម និងបង្ហាញអំពីទិដ្ឋភាពរួមនៃចង្វាក់លទ្ធផលដែលគាំទ្រផ.យ.អ.ជ.។ ឋានានុក្រមរបស់សូចនាករ ត្រូវបានផ្សារភ្ជាប់ទៅនឹងចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និងឆ្នាំ២០៥០ កម្រិតឥទ្ធិពល និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ កម្រិតលទ្ធផល។ ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ បានផ្សារភ្ជាប់ទំនាក់ទំនងលទ្ធផលកម្រិតខ្ពស់ទាំងនេះទៅនឹងលទ្ធផលកម្រិតទាបនិងធាតុចេញ ដែលទទួលរងឥទ្ធិពលពីសកម្មភាពនិងជម្រើសគោលនយោបាយ ដូចនេះ បានផ្តល់ជាយន្តការសម្រាប់តាមដាននិងតម្រង់ទិសការអនុវត្តគោលនយោបាយនៅកម្រិតផែនការ។ ដោយផ្អែកតាមចង្វាក់លទ្ធផល សូចនាករធាតុចូលនិងដំណើរការនឹងត្រូវរៀបចំឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនៅតាមក្រសួង ស្ថាប័ន និងក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

## តារាងទី ៦.១ : ក្របខ័ណ្ឌលទ្ធផលសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផ.យ.អ.ជ.

| | | | | |
|---|---|---|---|---|
| **ឥទ្ធិពលរយៈពេលវែង៖** ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ និងឆ្នាំ២០៥០ | **ការសម្រេចបានជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០** | | | |
| **លទ្ធផលកម្រិតខ្ពស់៖** គោលដៅរបស់យុទ្ធសាស្ត្រចតុកោណ | **កំណើន៖** សេដ្ឋកិច្ចដែលមានភាពធន់ | **ការងារ៖** ការងារពេញលេញ រួមទាំងការងារដែលមានគុណភាពខ្ពស់ | **សមធម៌៖** ភាពក្រីក្រនិងភាពងាយរងគ្រោះកាន់តែទាប | **ប្រសិទ្ធភាព៖** សមត្ថភាពស្ថាប័នកាន់តែខ្ពស់ និងអភិបាលកិច្ចល្អ |
| | **គុណភាពនៃបរិស្ថានប្រតិបត្តិ** | | | |
| **លទ្ធផល៖** ស្នូលនិងមុំរបស់យុទ្ធសាស្ត្រចតុកោណ | **ស្នូល៖** ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច<br>**អាទិភាពទី១៖** ការអភិវឌ្ឍធនធានមនុស្ស<br>**អាទិភាពទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច<br>**អាទិភាពទី៣៖** ការអភិវឌ្ឍវិស័យឯកជននិងការងារ<br>**អាទិភាពទី៤៖** ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន | | | |
| **ធាតុចេញរបស់គោលនយោបាយនិងសកម្មភាព** | **មាននៅក្នុងបញ្ជីសូចនាករស្នូល** | | | |
| **សកម្មភាព ដំណើរការ និងធាតុចូល** | **មាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យនិងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងបញ្ជីសូចនាករបន្ថែម** | | | |

**៦.៩-** ដូចមានក្នុងវដ្តនៃការរៀបចំ ផ.យ.អ.ជ. មុនៗ យន្តការសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងតាមដានវឌ្ឍនភាពរបស់ផែនការ គឺសូចនាករ។ ដោយអនុលោមតាមចង្វាក់លទ្ធផល សូចនាករត្រូវបានរៀបចំទៅតាមអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងមានសង្គតិភាពជាមួយកម្មវិធីនិងសកម្មភាពរបស់ក្រសួង ស្ថាប័ន។ វាក៏បានផ្តល់ជាមូលដ្ឋានរបស់ចង្វាក់លទ្ធផលនិងផែនការរបស់វិស័យនិងថ្នាក់ក្រោមជាតិ ដោយភ្ជាប់លទ្ធផលទៅការផ្តល់ សេវា ការសម្រេចចិត្ត និងសកម្មភាព។ សូចនាករស្នូលមានចំនួន២ផ្នែក ដូចខាងក្រោម៖

ទី១ លទ្ធផលកម្រិតខ្ពស់មិនស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល (អាស្រ័យលើគោលដៅកម្រិតខ្ពស់របស់យុទ្ធសាស្ត្រចតុកោណ)៖

- គោលដៅចំនួន៤៖ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព
- គោលដៅគ្រប់ដណ្តប់នៃការសម្រេចបានផែនការ

ទី២ លទ្ធផលនិងធាតុចេញ ដែលអាចទទួលរងឥទ្ធិពលពីសកម្មភាពនិងជម្រើសគោលនយោបាយរបស់រាជរដ្ឋាភិបាល។ លទ្ធផលនិងធាតុចេញ ផ្អែកលើស្នូល និងគោលដៅអាទិភាពទាំង៤របស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

- **ស្នូល៖** ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច
- **អាទិភាពទី១៖** ការអភិវឌ្ឍធនធានមនុស្ស
- **អាទិភាពទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច
- **អាទិភាពទី៣៖** ការអភិវឌ្ឍវិស័យឯកជននិងការងារ
- **អាទិភាពទី៤៖** ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន

៦.១០- ដូចមានបង្ហាញក្នុងតារាងសូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣ សូចនាករទាំងអស់មានចំនួន១០៧ ក្នុងក្រុមចំនួន៧ ។ ប៉ុន្តែ ការបែងចែកមានលក្ខណៈខុសគ្នាអាស្រ័យទៅលើលទ្ធភាពនៃប្រភពទិន្នន័យ។ នេះប្រៀបធៀបទៅនឹងសូចនាករចំនួន៨០ នៅក្នុងផ.យ.អ.ជ.មុន។

## រូបភាពទី ៦.៣ : សូចនាករ ផ.យ.អ.ជ. តាមអាទិភាពគោលនយោបាយ




៦.១១- សូចនាករត្រូវបានដកចេញពី៤ប្រភព (១) ក្របខ័ណ្ឌគ.អ.ច.ក. ដែលទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រីកាលពីខែវិច្ឆិកា ឆ្នាំ២០១៨ (២) ក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្រ ដែលបានស្នើឡើងសម្រាប់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៣) សូចនាករដែលមាននៅក្នុងផ.យ.អ.ជ.មុន និង(៤) សូចនាករថ្មី ដែលត្រូវបានរៀបចំឡើងតាមតម្រូវការរបស់ផែនការ។ ការជ្រើសរើសសូចនាករផ្តោតលើអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសសូចនាករដែលមានប្រភពពីក្របខ័ណ្ឌគ.អ.ច.ក. ប្រភពទិន្នន័យ និង

លក្ខណៈវិនិច្ឆ័យ SMART (ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ទាក់ទងនឹងគោលនយោបាយ និងមានពេលវេលាកំណត់)។

**រូបភាពទី ៦.៤ : សូចនាករ ផ.យ.អ.ជ. តាមប្រភេទ**




**៦.១២-** សម្រាប់ការរៀបចំបញ្ជីសូចនាករ ក្រសួងផែនការដោយមានកិច្ចពិគ្រោះយោបល់ក្នុងក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ផ.យ.អ.ជ. និង ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធបានពិនិត្យនិងកែសម្រួលឡើងវិញនូវបញ្ជីសូចនាករ។ ដូចនេះ ការកំណត់ចំណុចដៅត្រូវបានធ្វើឡើងដោយផ្អែកលើគោលដៅគោលនយោបាយរយៈពេលវែងនិងមធ្យមរបស់រាជរដ្ឋាភិបាល និងការពិចារណាអំពីលក្ខខណ្ឌប្រតិបត្តិមួយចំនួនដែលអាចនឹងកើតឡើង។

**៦.១៣-** ដំណើរការជ្រើសរើសនិងកែសម្រួលសូចនាករ គឺជាបញ្ហាប្រឈម និងតម្រូវឲ្យមានការវិនិច្ឆ័យដោយប្រុងប្រយ័ត្ន និងការវិភាគអំពីកត្តាខាងក្នុងនិងខាងក្រៅដែលអាចមានឥទ្ធិពលលើសូចនាករ។ ដូចក្នុងវដ្តផែនការមុនៗ ដំណើរការត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំ នឹងរួមបញ្ចូលការត្រួតពិនិត្យសូចនាករឡើងវិញ ប្រសិនបើតម្រូវឲ្យមានការកែសម្រួលចំណុចដៅរបស់សូចនាករ។

**៦.១៤-** ការជ្រើសរើសនិងកំណត់សូចនាករសម្រាប់គោលដៅអរូបីមានការលំបាក ឧទាហរណ៍ នៅក្នុងអាទិភាពស្តីពីអភិបាលកិច្ច និងសម្រាប់សូចនាករដែលឆ្លុះបញ្ចាំងពីគុណភាពរបស់បរិស្ថានប្រតិបត្តិ។ បញ្ហាប្រឈមទាំងនេះ ត្រូវបានដោះស្រាយដោយប្រើប្រាស់វិធានការជំនួសដូចជាសមត្ថភាពស្ថាប័ននិងការគ្រប់គ្រង (ឧទាហរណ៍ ការអនុវត្តថវិកា) និងដោយពឹងផ្អែកលើយោបល់និងទិន្នន័យដោយផ្អែកលើការវិនិច្ឆ័យ (ឧទាហរណ៍ ការវាយតម្លៃរបស់ធនាគារពិភពលោកលើការអនុវត្តរបស់កម្ពុជា)។

៦.១៥- លើសពីនេះទៀត ដូចក្នុងវដ្តផែនការមុន បញ្ជីសូចនាករបន្ថែមត្រូវបានរៀបចំឡើងដែលបានមកពីសូចនាករគ.អ.ច.ក.និងផ.យ.អ.ជ.ដែលនៅសល់ បន្ថែមជាមួយសំណើរបស់ក្រសួង ស្ថាប័ន។ សូចនាករទាំងនេះ នឹងមិនតម្រូវឲ្យធ្វើការប្រមូលទិន្នន័យនៅក្នុងដំណើរការការតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់ផ.យ.អ.ជ.ឡើយ ប៉ុន្តែត្រូវមានទិន្នន័យសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនិងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងដើម្បីគាំទ្រការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃឲ្យបានទូលំទូលាយ។

៦.១៦- ការពិនិត្យមើលបញ្ជីសូចនាករស្នូលចុងក្រោយបង្ហាញថាក្រសួង ស្ថាប័នភាគច្រើនមានលទ្ធភាពផលិតទិន្នន័យ។ សូចនាករភាគច្រើនមានលក្ខណៈពេញលេញដោយមានទិន្នន័យមូលដ្ឋាន និងចំណុចដៅតាមឆ្នាំ។ លទ្ធភាពទិន្នន័យគឺជាការងារដែលត្រូវយកចិត្តទុកដាក់ជាសំខាន់ ប៉ុន្តែនៅមានសូចនាករមួយចំនួនមិនទាន់មានលក្ខណៈពេញលេញ ប៉ុន្តែសូចនាករទាំងនោះមានសារៈសំខាន់នៅក្នុងផែនការ ហើយមិនមានសូចនាករជំនួស។ ការងារចាំបាច់ដែលត្រូវធ្វើគឺការកំណត់ប្រភពទិន្នន័យនិងការប្រមូលទិន្នន័យ។ ការងារនេះនឹងត្រូវធ្វើក្នុងរយៈពេល៦ខែដំបូងក្នុងឆ្នាំ២០១៩ ហើយប្រសិនបើមិនអាចធ្វើកើត សូចនាករទាំងនោះនឹងត្រូវលុប ហើយជំនួសមកវិញជាផ្នែកមួយនៃការត្រួតពិនិត្យប្រចាំឆ្នាំ។

៦.១៧- ដូចក្នុងវដ្តផែនការមុនៗ ដំណើរត្រួតពិនិត្យឡើងវិញត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ដឹកនាំដោយក្រសួងផែនការនិងមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងដំណើរការនេះ សមិទ្ធផលជាក់ស្តែងនឹងត្រូវប្រៀបធៀបជាមួយចំណុចដៅដែលបានកំណត់សម្រាប់សូចនាករនីមួយៗ។ ភាពខុសគ្នានឹងត្រូវវិភាគ និងផ្តល់ព័ត៌មានត្រឡប់ទៅអ្នករៀបចំគោលនយោបាយនិងថ្នាក់ដឹកនាំ។ ការរកឃើញនិងអនុសាសន៍នានានឹងត្រូវរៀបចំដាក់ចេញជាសកម្មភាពកែតម្រូវ ដូចបានពិពណ៌នាពីខាងដើមនៃជំពូកនេះ។

៦.១៨- ការវាយតម្លៃប្រចាំឆ្នាំត្រូវរួមបញ្ចូលការវាយតម្លៃគុណភាពរបស់សូចនាករនិងទិន្នន័យគាំទ្រ។ ដូចនេះ ទិន្នន័យនិងជម្រើសសូចនាករអាចត្រូវបានកែសម្រួល ហើយក្នុងករណីខ្លះ អាចមានការកែសម្រួលការព្យាករចំណុចដៅសម្រាប់រយៈពេលដែលនៅសល់របស់ផែនការ។ ដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវមានលក្ខណៈបត់បែន និងអាចទទួលយកសូចនាករថ្មីៗ។ ការផ្លាស់ប្តូរសូចនាករអាចត្រូវបានធ្វើឡើងតាមតម្រូវការរបស់អ្នកធ្វើគោលនយោបាយនៅតាមក្រសួង ស្ថាប័ន។ សំណើរសម្រាប់ការផ្លាស់ប្តូរនឹងត្រូវត្រួតពិនិត្យដោយក្រសួងផែនការ សម្រាប់ការបន្ថែមទៅលើចំណុចដៅនិងទិន្នន័យរបស់ផ.យ.អ.ជ.។

## ៤. ការរៀបចំផែនការនិងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅតាមកម្រិត

៦.១៩- ដូចក្នុងវដ្តផែនការមុនៗ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តរៀបចំក្របខ័ណ្ឌលទ្ធផល ដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍន៍របស់ខ្លួន។ ផែនការទាំងនេះមានឋានានុក្រមចំនួន២ក្រុម គឺថ្នាក់ជាតិ/វិស័យ/កម្មវិធី និងថ្នាក់ក្រោមជាតិ/ថ្នាក់ខេត្ត/ឃុំ សង្កាត់ ប៉ុន្តែតម្រូវឲ្យមានសង្គតិភាពគ្រប់កម្រិតទៅតាមឋានានុក្រមនៃផែនការ ដោយតម្រូវឲ្យស្របតាមផែនការមេក្នុងការកំណត់ទំហំការងារនិងការផ្សារភ្ជាប់គោលនយោបាយទៅនឹងលទ្ធផល។ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវបន្ស៊ីគ្នាឲ្យបានពេញលេញ និងមានតារាងសូចនាករ ដែលបង្ហាញនៅចុងជំពូកនេះ។

៦.២០- ក្រសួង ស្ថាប័នមានតួនាទីអនុវត្តការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅកម្រិតធាតុចេញនិងធាតុចូល គឺសម្រាប់គម្រោងនិងសេវា និងចំណាយនិងសកម្មភាពដើម្បីសម្រេចបានលទ្ធផលតាមវិស័យ។ លទ្ធផលចុងក្រោយរបស់ផែនការគឺកំណត់ដោយលទ្ធផលនៅក្នុង ផ.យ.អ.ជ. និងក្នុងចង្វាក់លទ្ធផល ដូចនេះ ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ឆ្លុះបញ្ចាំងពីផ្នែកខាងក្រោមនៃរូបភាពទី ៦.២ ខាងលើ។ ចង្វាក់លទ្ធផលទាំងអស់ត្រូវកំណត់ការសន្មតនានានិងអនុលោមតាមទ្រឹស្តីបទនៃការផ្លាស់ប្តូរនិងគាំទ្រដោយការវិភាគអំពីជម្រើសនិងបញ្ហាប្រឈម សម្រាប់ ផ.យ.អ.ជ. ដែលមានបរិយាយក្នុងជំពូកទី៣ និង ទី៤។

៦.២១- ដោយបន្ស៊ីជាមួយការអនុវត្តថវិកាដោយផ្អែកលើសមិទ្ធកម្ម ដូចមានក្នុងកថាខណ្ឌទី៣ និងទី៤ នៃឯកសារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នត្រូវរៀបចំផែនការនិងអនុវត្តគម្រោងនិងកម្មវិធីដោយគោរពតាមរចនាសម្ព័ន្ធកម្មវិធីស្តង់ដា។ រចនាសម្ព័ន្ធកម្មវិធី ថវិកា និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវបន្ស៊ីគ្នា ដើម្បីជានាសុខដុមនីយកម្មជាមួយគ្នា។ រូបភាពទី ៦.៥ ខាងក្រោមបង្ហាញអំពីការបន្ស៊ីគ្នារវាងរចនាសម្ព័ន្ធកម្មវិធី ថវិកា និងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់សកម្មភាពនៅថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ និងបង្ហាញអំពីការប្រែក្លាយគោលនយោបាយទៅយុទ្ធសាស្ត្រ ដែលឆ្លុះបញ្ចាំងក្នុងថវិកាតាមរយៈកម្មវិធីនិងអនុកម្មវិធី។ រចនាសម្ព័ន្ធកម្មវិធីនៅកណ្តាល ថវិកានៅខាងស្តាំដៃ និងត្រូវស៊ីគ្នាជាមួយសូចនាករសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅខាងឆ្វេងដៃ។

## រូបភាពទី ៦.៥ : ទំនាក់ទំនងរវាងរចនាសម្ព័ន្ធកម្មវិធី ថវិកា និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ




**៦.២២-** ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃតម្រូវឲ្យមានការយកចិត្តទុកដាក់ខ្ពស់ដោយសារវាមានការលំបាកជាងកម្រិតវិស័យ ទិន្នន័យមានកំណត់ សមត្ថភាពស្ថាប័ន សមត្ថភាពវិភាគ និងធនធាន។ ប៉ុន្តែ ដោយមានការកែលម្អជាបន្តបន្ទាប់លើការប្រមូលទិន្នន័យ បច្ចុប្បន្នមានការបំបែកទិន្នន័យរដ្ឋបាលនិងទិន្នន័យស្ថិតិច្រើន ដែលអាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិផលិតទិន្នន័យទៅតាមការចាំបាច់។ ទិន្នន័យស្ថិតិ ដែលអាចផ្តល់បានដល់កម្រិតខេត្ត រួមមាន អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា ដែលជាប្រភពទិន្នន័យមួយសំខាន់។ លើសពីនេះទៀត វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានផ្តល់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា សម្រាប់គណនាអត្រាភាពក្រីក្រ និងបន្តសាកល្បងការផលិតការព្យាករជ.ស.ស. នៅថ្នាក់ខេត្ត។

**៦.២៣-** សម្រាប់ទិន្នន័យរដ្ឋបាល ទិន្នន័យស្តីពីសូចនាករសេដ្ឋកិច្ច សង្គមកិច្ចអាចត្រូវបានបង្កើតឡើងដោយប្រើប្រាស់ទិន្នន័យដែលក្រសួង ស្ថាប័នផលិតឡើង ដូចជា ដំណាំ អត្រានៃការសិក្សា និងការគ្រប់ដណ្តប់វិស័យសុខាភិបាល ជាដើម។ ដូចគ្នានេះដែរ មូលដ្ឋានទិន្នន័យឃុំ សង្កាត់ផ្តល់កាលានុវត្តភាពក្នុងការផលិតទិន្នន័យនៅកម្រិតខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ប៉ុន្តែមូល

ដ្ឋានទិន្នន័យឃុំ សង្កាត់ ត្រូវបានប្រើប្រាស់ទៅតាមជម្រើស ដោយមានការវិនិច្ឆ័យត្រឹមត្រូវក្នុងការផលិតទិន្នន័យនិងមានការត្រួតពិនិត្យតិចតួចពីស្ថាប័នស្ថិតិ ដោយសារមូលដ្ឋានទិន្នន័យឃុំ សង្កាត់មិនស្ថិតក្នុងចំណោមស្ថិតិផ្លូវការ។

## ៥. បញ្ហាប្រឈមទាក់ទងនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

៦.២៤- ការបង្កើតក្របខ័ណ្ឌសូចនាករនិងការសម្រេចបានការតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលពេញលេញនិងមានប្រសិទ្ធភាពជួបប្រទះបញ្ហាប្រឈមជាច្រើន ហើយក្រសួងផែនការត្រូវប្រឹងប្រែងកាត់បន្ថយបញ្ហាទាំងនេះក្នុងរយៈពេលនៃវដ្តផ.យ.អ.ជ.។ ក្រសួងផែនការត្រូវផ្តល់ជាជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបញ្ហានានាដែលជួបប្រទះក្នុងការរៀបចំនិងអនុវត្តការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ពួកគេ។ បញ្ហាប្រឈមចំនួន៣ត្រូវបានកំណត់ ដូចខាងក្រោម៖

៦.២៥- *បញ្ហាទី១* គឺការធានាជម្រើសសូចនាករនិងដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃមានទំនាក់ទំនងជាមួយគោលនយោបាយឬតម្រូវការរបស់ថ្នាក់ដឹកនាំ។ ការងារនេះមានសារៈសំខាន់ក្នុងកែសម្រួលបរិបទគោលនយោបាយរបស់កម្ពុជា ហើយយោងតាមផ.យ.អ.ជ. បានបង្ហាញអំពីការវិវត្តពីយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ទៅដំណាក់កាលទី៤ និងការអនុម័តក្របខ័ណ្ឌគ.អ.ច.ក. ដែលជាក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃរយៈពេលវែង។ ការងារនេះសម្រេចបាននៅក្នុងផ.យ.អ.ជ. តាមរយៈការរៀបចំឡើងវិញដើម្បីឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធថ្មីនៃអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងការកែសម្រួលសូចនាករស្នូល ដើម្បីគ្របដណ្តប់ឲ្យបានច្រើនលើទិន្នន័យរបស់គ.អ.ច.ក.។ លើសពីនេះទៀត ការងារនេះតម្រូវឲ្យមានការជ្រើសរើសទិន្នន័យពីក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្ររបស់យុទ្ធសាស្ត្រ ចតុកោណដោយប្រុងប្រយ័ត្ន និងការបង្កើតសូចនាករថ្មីដោយផ្អែកលើតម្រូវការរបស់អ្នកសម្រេចចិត្ត។ សូចនាករទាំងអស់ត្រូវត្រួតពិនិត្យឡើងវិញក្នុងពេលធ្វើការវាយតម្លៃប្រចាំឆ្នាំ ហើយត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាថាសូចនាករនិងក្របខ័ណ្ឌផ.យ.អ.ជ. គ.អ.ច.ក. និងយុទ្ធសាស្ត្រចតុកោណត្រូវដាក់បញ្ចូលគ្នានិងធ្វើបច្ចុប្បន្នភាព។

៦.២៦- ក្រសួងផែនការ ត្រូវប្រឹងប្រែងក្នុងការសម្របសម្រួលរវាងអ្នកផលិតទិន្នន័យនិងអ្នកប្រើប្រាស់ទិន្នន័យសូចនាករ ដើម្បីបំពេញតាមតម្រូវការនៃប្រើប្រាស់។ ស្ថាប័នជាច្រើនត្រូវការទិន្នន័យស្តីពីបញ្ហាផ្សេងៗគ្នា ដូចជាហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្ម ពលកម្ម ជាដើម ដូចនេះសម្រាប់ការផ្តល់ទិន្នន័យអាចមានស្ថាប័នច្រើនប្រមូលនិងចងក្រងទាំងទិន្នន័យស្ថិតិនិងទិន្នន័យរដ្ឋបាល ដោយសារស្ថាប័នតែមួយមិនអាចអនុវត្តការងារទាំងអស់នេះបានឡើយ ហើយទិន្នន័យ

មួយចំនួនមានលក្ខណៈបច្ចេកទេសខ្ពស់។ នេះបង្ហាញឲ្យឃើញថាមានទីផ្សារសម្រាប់ទិន្នន័យនៅក្នុងការគ្រប់គ្រងគោលនយោបាយសាធារណៈ ប៉ុន្តែត្រូវមានការគ្រប់គ្រងឲ្យបានត្រឹមត្រូវ។ ក្រសួងផែនការ ត្រូវអនុវត្តកិច្ចការនេះ តាមរយៈការសម្របសម្រួលការងាររវាងអគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ដែលជាអ្នកផលិតទិន្នន័យស្ថិតិ។

**៦.២៧-** *បញ្ហាទី២* គឺភាពពេញលេញនិងគុណភាពរបស់ទិន្នន័យ ដូចជាការធានាថាមានទិន្នន័យគ្រប់គ្រាន់តាមពេលកំណត់ មានទំនុកចិត្តខ្ពស់ ភាពទាក់ទងគ្នា និងការបំបែកទិន្នន័យ។ ការពិចារណាមួយចំនួនរួមមានការធានាថាមានការប្រមូលទិន្នន័យសម្រាប់សូចនាករទាំងអស់ដែលបានជ្រើសរើស មានព័ត៌មានលម្អិតអំពីប្រភពទិន្នន័យនិងមេតាទិន្នន័យ និងមានទិន្នន័យមូលដ្ឋាននិងចំណុចដៅ។ លើសពីនេះទៀត ការធ្វើសាកល្បងត្រូវការជាចាំបាច់ក្នុងការធានាថាសូចនាករទាំងអស់បំពេញតាមលក្ខណៈវិនិច្ឆ័យSMART។ បញ្ហាផ្សេងៗអាចត្រូវបានកំណត់តាមរយៈការធ្វើសាកល្បងទិន្នន័យនិងការធ្វើទំនាក់ទំនងសូចនាករទៅនឹងគោលបំណងរបស់គោលនយោបាយនិងថ្នាក់ដឹកនាំដែលមានបំណងធ្វើការតាមដាន។

**៦.២៨-** ប៉ុន្តែការដោះស្រាយបញ្ហាទាំងនេះ លើសពីការរៀបចំក្របខ័ណ្ឌរហូតដល់ការគ្រប់គ្រងនិងអភិបាលកិច្ចដំណើរការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ដូចបានរៀបរាប់ខាងលើ មានស្ថាប័នច្រើនប្រមូលនិងចងក្រងទិន្នន័យ ចំណែកការសម្របសម្រួលនៅមានកម្រិតនៅឡើយដែលតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាថានិយមន័យនិងដំណើរការផលិតទិន្នន័យអាចប្រៀបធៀបគ្នាបាន ហើយនៅក្នុងលក្ខខណ្ឌចាំបាច់ ក្រសួង ស្ថាប័នត្រូវគោរពតាមនិយមន័យនិងការអនុវត្តរបស់អន្តរជាតិ ឬយ៉ាងហោចណាស់និយមន័យនិងការអនុវត្តដែលទទួលស្គាល់នៅថ្នាក់ជាតិ។

**៦.២៩-** ដូចក្នុងវដ្តផែនការមុនៗ យុទ្ធសាស្ត្រចំនួន៣នឹងត្រូវបន្តអនុវត្តដោយក្រសួងផែនការដើម្បីសម្រេចបាន (១) ការបង្កើនស្តង់ដាទិន្នន័យ ការកសាងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ដែលផ្តល់ស្តង់ដាគុណភាពសម្រាប់ទិន្នន័យស្ថិតិ ក្រសួងផែនការនឹងពង្រីកការងារនេះរហូតដល់ទិន្នន័យរដ្ឋបាលនិងដំណើរការចងក្រងទិន្នន័យ (២) ការកំណត់ប្រភពនិងនិយមន័យក្នុងក្របខ័ណ្ឌទិន្នន័យជាតិ ផ.យ.អ.ជ. និង គ.អ.ច.ក. និងក្របខ័ណ្ឌលទ្ធផលរបស់យុទ្ធសាស្ត្រចតុកោណ ដែលកំពុងរៀបចំសម្រាប់យុទ្ធសាស្ត្រ ចតុកោណដំណាក់ទី៤ ដើម្បីប្រមូលផ្តុំរួមគ្នា និង (៣) ការទទួលស្គាល់ស្តង់ដា ដោយជូនដំណឹងដល់អ្នកប្រើប្រាស់ទិន្នន័យអំពីភាពផ្សេងគ្នានេះ។

**៦.៣០-** ការពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់វិទ្យាស្ថានជាតិស្ថិតិ តាមរយៈយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិក្នុងការរៀបចំប្រព័ន្ធស្ថិតិឡើងវិញ រួមទាំងទិន្នន័យរដ្ឋបាល គឺជាការងារអាទិភាពមួយ។ ក្រសួងផែនការកំពុងបន្តភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងធ្វើការកែលម្អ

ប្រព័ន្ធទិន្នន័យសំខាន់ៗ ចំនួន២ដែលមានស្រាប់ គឺប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ និងប្រព័ន្ធព័ត៌មានសុខាភិបាល។

៦.៣១- *បញ្ហាទី៣* គឺគម្លាតសមត្ថភាពវិភាគនិងបច្ចេកទេស។ មន្ត្រីមួយចំនួនមិនទាន់មានលទ្ធភាពបង្កើតសូចនាករដែលគោរពតាមលក្ខណៈវិនិច្ឆ័យSMART និងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រមូលនិងវិភាគទិន្នន័យសម្រាប់ការរៀបចំគោលនយោបាយនិងការសម្រេចចិត្ត។ គម្លាតមួយចំនួនគឺកម្រិតស្ថាប័ន ដោយសារស្ថាប័នមួយចំនួនមិនប្រើប្រាស់គោលការណ៍ដោយផ្អែតលើភស្តុតាង។ លើសពីនេះទៀត កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងសមិទ្ធិកម្មតាមរយៈ ការប្រើប្រាស់សូចនាករជាតុចេញដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកានឹងបង្ហាញកាន់តែច្បាស់អំពីសារៈសំខាន់នៃភាពប្រឈមទាំងនេះ។

៦.៣២- ជាការឆ្លើយតបនិងការបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្រសួងផែនការដោយសហការជាមួយក្រសួង ស្ថាប័ននឹងដំណើរការវិធានការមួយចំនួនដើម្បីកសាងសមត្ថភាព៖

- រៀបចំប្រព័ន្ធជាតិមួយសម្រាប់ការត្រួតពិនិត្យតាមដាននិងវាយតម្លៃសមិទ្ធផលនៃការអនុវត្តផ.យ.អ.ជ.និងគ.អ.ច.ក.។
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិនៃការអនុវត្ត ផ.យ.អ.ជ. និងរបាយការណ៍ស្តីពីការសម្រេចបានគ.អ.ច.ក. ដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់។
- រៀបចំគោលការណ៍ណែនាំលក្ខណៈបច្ចេកទេស និង យុទ្ធសាស្ត្រជាតិតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងផ្សព្វផ្សាយឯកសារទាំងនេះ រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលក្នុងការប្រើប្រាស់ឯកសារទាំងនេះ។
- ពង្រឹងប្រព័ន្ធសម្រាប់ការតាមដានការអនុវត្តគម្រោងដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល។
- ផ្សារភ្ជាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាមួយសូចនាករនិងទិន្នន័យដែលប្រើប្រាស់សម្រាប់តាមដានការរៀបចំថវិកាតាមរយៈដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។
- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីទទួលបបន្ទុកផែនការនិងស្ថិតិ និង ការបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការប្រមូលទិន្នន័យ ការវិភាគសម្រាប់មន្ត្រីបង្គោលនៅតាមក្រសួង ស្ថាប័ន។ និង
- បង្កើតឲ្យមានសេវាផ្តល់ជំនួយសម្រាប់ក្រសួង ស្ថាប័នស្តីពីការជ្រើសរើសសូចនាករ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ការបកស្រាយទិន្នន័យ និងការរៀបចំក្របខ័ណ្ឌលទ្ធផលជាដើម។

៦.៣៣- ក្រសួង ស្ថាប័នត្រូវផ្តល់ធាតុចូលនិងកិច្ចសហការតាមការស្នើសុំរបស់ក្រសួងផែនការ សម្រាប់ចូលរួមចំណែកដល់ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និង បញ្ចប់អាណត្តិនៃការអនុវត្តផ.យ.អ.ជ. និងរបាយការណ៍ស្តីពីការសម្រេចបានគ.អ.ច.ក។

៦.៣៤- យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិកម្ពុជានឹងផ្តល់ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការ គាំទ្រផលិតទិន្នន័យសំខាន់ៗទាំងឡាយប្រកបដោយចីរភាព។ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍស្ថិតិ ក៏បង្ហាញផងដែរនូវការគាំទ្រជួយឧបត្ថម្ភដល់តម្រូវការផលិតបន្ថែមទៀតនូវស្ថិតិ ដើម្បីជានានូវគោលដៅរបស់ប្រព័ន្ធស្ថិតិជាតិសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ និងការតាមដានគោលនយោបាយ និងកម្មវិធីស្ថិតិ។

៦.៣៥- យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិកម្ពុជា ក៏ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការស្វែងយល់ពីស្ថានភាពនៃបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាលក្នុងការអនុវត្តប្រតិបត្តិការស្ថិតិ ការអភិវឌ្ឍសមត្ថភាព និងការបង្កើនគុណភាពទិន្នន័យរបស់ខ្លួនក្នុងដំណើរការនៃការផ្តល់ស្ថិតិមានគុណភាព សម្រាប់ការធ្វើផែនការ គោលនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។

៦.៣៦- លើសពីនេះទៀត វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការនឹងបន្តអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិឆ្នាំ២០១៩-២០២៣ ដែលមានគោលដៅយុទ្ធសាស្ត្រចំនួន៨ ដូចខាងក្រោម៖

- **គោលដៅយុទ្ធសាស្ត្រទី១៖** អភិវឌ្ឍ និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់ ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិ ក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។ ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពរួមមាន (១) ភ្ជាប់ប្រតិបត្តិការប្រព័ន្ធស្ថិតិជាតិ ទៅនឹងគោលនយោបាយអភិវឌ្ឍន៍ (២) កែលម្អគោលនយោបាយទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ (៣) គាំទ្រការចងក្រងនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និង (៤) បន្តកែលម្អស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច។
- **គោលដៅយុទ្ធសាស្ត្រទី២៖** បន្តពង្រឹងច្បាប់ស្ថិតិ ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ ដោយផ្តោតលើសកម្មភាពអាទិភាព ដូចជា (១) រៀបចំប្រព័ន្ធស្ថិតិជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ (២) ផ្តល់នូវស្វ័យភាព និងការទទួលខុសត្រូវបន្ថែមទៀត

ក្នុងការគ្រប់គ្រងវិទ្យាស្ថានជាតិស្ថិតិ និង (៣) បង្កើតអាណត្តិរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

- **គោលដៅយុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍនិងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។ ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពរួមមាន (១) ធ្វើការផ្លាស់ប្តូរថ្មីនូវគោលនយោបាយនិងការគ្រប់គ្រងធនធានមនុស្ស និង(២) អភិវឌ្ឍនិងបន្តកម្មវិធីបណ្តុះបណ្តាលទូលំទូលាយក្នុងប្រព័ន្ធស្ថិតិជាតិ។
- **គោលដៅយុទ្ធសាស្ត្រទី៤៖** អភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីផ្តល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ ដោយផ្តោតជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យាជាយុទ្ធសាស្ត្រ ជាមួយការកាត់បន្ថយជាអប្បបរមានៃកម្លាំងពលកម្ម។
- **គោលដៅយុទ្ធសាស្ត្រទី៥៖** អភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ និងយុទ្ធសាស្ត្រគាំទ្រ និងអន្តរកម្ម ដើម្បីផ្តល់ការទទួលបានឲ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្តីត្រូវការសម្រាប់ស្ថិតិ តាមរយៈសកម្មភាពស្នូល (១) ការគាំទ្រដល់ការប្រើប្រាស់ស្ថិតិតាមគោលនយោបាយនិងផែនការ និង(២) ផ្សព្វផ្សាយនិងធ្វើអន្តរកម្មប្រកបដោយប្រសិទ្ធភាពទៅអ្នកប្រើប្រាស់ដ៏ទូលំទូលាយ។
- **គោលដៅយុទ្ធសាស្ត្រទី៦៖** ធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិដើម្បីលុបបំបាត់ជម្លោះទិន្នន័យនិងផលិតស្ថិតិអាចប្រៀបធៀបបានទាន់ពេលវេលាក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន ដោយផ្តោតលើការពង្រីកវិសាលភាព និងយន្តការនៃការសម្របសម្រួលនៅក្នុងប្រព័ន្ធស្ថិតិជាតិ។
- **គោលដៅយុទ្ធសាស្ត្រទី៧៖** ធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងការងារនិងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ ដើម្បីធានានូវការគាំទ្រការព្យាករ ការបន្តនិងការរួមបញ្ចូលគ្នាទៅនឹងសកម្មភាពអាទិភាពរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាការផ្ទេរជំនាញពេញលេញនិងចំណេះធ្វើ ដោយធ្វើឲ្យស្របគ្នានូវតម្រូវការរបស់ប្រទេសជាមួយដៃគូអភិវឌ្ឍ។
- **គោលដៅយុទ្ធសាស្ត្រទី៨៖** ជំរុញចីរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តកម្មវិធីស្ថិតិអាទិភាពប្រកបដោយប្រសិទ្ធភាព តាមរយៈការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិទាក់ទងនឹងនីតិវិធីកែលម្អសម្រាប់ហិរញ្ញប្បទាន។

## តារាងសូចនាករ សម្រាប់តាមដានត្រួតពិនិត្យ និង វាយតម្លៃ ផ.យ.អ.ជ ២០១៩-២០២៣

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| | **កម្រិតឥទ្ធិពល៖ គោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល** | | | | | | | | | |
| | **យុទ្ធសាស្ត្រ៖ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** | | | | | | | | | |
| | កំណើនលើសពី ៧% មូលដ្ឋានសេដ្ឋកិច្ចដែលធំទូលាយជាងមុន ភាពប្រកួតប្រជែង និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច | | | | | | | | | |
| ១ | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) តម្លៃបច្ចុប្បន្ន | លានដុល្លារអាមេរិក | ២៤ ៣៧៤ | ២៦ ៧៨៦ | ២៩ ៣៦២ | ៣២ ២៩៣ | ៣៥ ៥៦២ | ៣៩ ១៩២ | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| ២ | ផ.ស.ស. សម្រាប់មនុស្សម្នាក់ | ដុល្លារអាមេរិក /ម្នាក់ | ១ ៥៤៨ | ១ ៦៧៩ | ១ ៨១៦ | ១ ៩៧២ | ២ ១៤៤ | ២ ៣៣៥ | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| ៣ | អត្រាកំណើននៃ ផ.ស.ស ពិត | % | ៧,៥ | ៧,១ | ៦,៥ | ៧,០ | ៧,០ | ៧,០ | ផ.យ.អ.ជ ២០១៤/១៨ និង ក.យ.ច. | ក.ស.ហ. |
| ៤ | ចំណែក ផ.ស.ស តាមវិស័យ | | | | | | | | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| | កសិកម្ម | % | ១៨,០ | ១៧,១ | ១៦,៤ | ១៥,៦ | ១៤,៨ | ១៤,១ | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| | ឧស្សាហកម្ម | % | ៣៥,៦ | ៣៦,៨ | ៣៧,៦ | ៣៨,៧ | ៣៩,៩ | ៤១,០ | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| | សេវាកម្ម | % | ៣៩,១ | ៣៩,០ | ៣៨,៩ | ៣៨,៧ | ៣៨,៤ | ៣៨,១ | ផ.យអ.ជ.២០១៤/១៨ | ក.ស.ហ. |
| ៥ | អត្រាអតិផរណាប្រចាំឆ្នាំ (ខែធ្នូ) | % | ២,៥ | ២,៨ | ២,៩ | ៣,០ | ៣,០ | ៣,១ | ផ.យ.អ.ជ ២០១៤/១៨ និង ក.យ.ច. | ក.ស.ហ. |
| | **ភាពមានការងារធ្វើ៖ ការងារ, យុវជន, ជំនាញ ព័ត៌មានទីផ្សារ និងលក្ខខណ្ឌការងារ** | | | | | | | | | |
| ៦ | អត្រាភាពមានការងារធ្វើ | % | ៨៤,២ (២០១៧) | ៨៦,០ | ៨៨,០ | ៩០,០ | ៩២០ | ៩៤,០ | ក.យ.ច. | ក.ស.ហ./អ.ស.ស.ក./ LFS |
| ៧ | ចំណែកមានការងារធ្វើតាមវិស័យ | | | | | | | | ផ.យ.អ.ជ ២០១៤/១៨ | ក.ស.ហ./អ.ស.ស.ក./ LFS |
| | កសិកម្ម | % | ៣៧,០ (២០១៧) | ៣៧,០ | ៣៧,០ | ៣៨,០ | ៣៨,០ | ៣៨,០ | ផ.យ.អ.ជ ២០១៤/១៨ | ក.ស.ហ./អ.ស.ស.ក./ LFS |
| | ឧស្សាហកម្ម | % | ២៦,២ (២០១៧) | ២៧,២ | ២៧,២ | ២៧,២ | ២៧,២ | ២៧,២ | ផ.យ.អ.ជ ២០១៤/១៨ | ក.ស.ហ./អ.ស.ស.ក./ LFS |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សេវាកម្ម | % | ៣៦,៨ (២០១៧) | ៣៦,០ | ៣៦,០ | ៣៥,០ | ៣៥,០ | ៣៥,០ | ផ.យ.អ.ជ. ២០១៤/១៨ | ក.ស.ហ./អ.ស.ស.ក./ LFS |
| | **សមធម៌៖ ភាពក្រីក្រស្ថិតក្រោម ១០% កាត់បន្ថយភាពងាយរងគ្រោះ (តាមរយៈការបង្កើតការងារ កិច្ចគាំពារសង្គមនិងគុណភាពសេវាសាធារណៈ)** | | | | | | | | | |
| ៨ | សមាមាត្រនៃប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រជាតិ (ផ្អែកលើការប្រើប្រាស់) | % | ១៣,៥ (២០១៤) | ៩,៥ | | ៧,៥ | | ៥,៥ | គ.អ.ច.ក., ផ.យ.អ.ជ. ២០១៤/១៨ និង ក.យ.ច. | ក.ស.ហ./អ.ស.ស.ក./ LFS |
| ៩ | សមាមាត្រនៃប្រជាជននៅតំបន់ជនបទ ដែលរស់នៅក្រោមបន្ទាត់ក្រីក្រ (ផ្អែកលើការប្រើប្រាស់) | % | ១២,៥ (២០១៤) | ១១,៥ | | ១០,៥ | | ៩,៦ | គ.អ.ច.ក., ផ.យ.អ.ជ. ២០១៤/១៨ និង ក.យ.ច. | ក.ស.ហ./អ.ស.ស.ក./ LFS |
| ១០ | សមាមាត្រនៃកុមាររស់នៅក្រោមបន្ទាត់ក្រីក្រជាតិ (ផ្អែកលើការប្រើប្រាស់) | % | ១៦,០ | ១២,០ | | ១១,០ | | ១០,០ | គ.អ.ច.ក. | រ.ជ.ស./អ.ប.ស.ក. |
| ១១ | សមាមាត្រនៃកុមាររស់នៅក្រោមបន្ទាត់ក្រីក្រជាតិ (ផ្អែកលើពហុសមាសភាគ) | % | ៤៩,០ | ៤១,០ | | ៣៣,០ | | ២៥,០ | គ.អ.ច.ក. | រ.ជ.ស./អ.ប.ស.ក. |
| ១២ | អាយុរំពឹងរស់ពីកំណើត | ឆ្នាំ | ៧០,៦ | ៧១,០ | ៧២,០ | ៧៣,០ | ៧៣,០ | ៧៤,០ | ផ.យ.អ.ជ. ២០១៤/១៨ និង ក.យ.ច. | រ.ជ.ស. |
| | ប្រុស | ឆ្នាំ | ៦៨,១ | ៦៩,០ | ៧០,០ | ៧១,០ | ៧១,០ | ៧២,០ | ផ.យ.អ.ជ. ២០១៤/១៨ និង ក.យ.ច. | រ.ជ.ស. |
| | ស្រី | ឆ្នាំ | ៧១,៩ | ៧៣,០ | ៧៤,០ | ៧៥,០ | ៧៦,០ | ៧៦,០ | ផ.យ.អ.ជ. ២០១៤/១៨ និង ក.យ.ច. | រ.ជ.ស. |
| ១៣ | អត្រាអក្ខរកម្ម (មនុស្សពេញវ័យចាប់ពី ១៥ឆ្នាំឡើង) | % | ៨២,៥ | ៨៣,០ | ៨៥,០ | ៨៦,០ | ៨៨,០ | ៩០,០ | **គ.អ.ច.ក.** | **អ.ស.ស.ក. រ.ជ.ស.** |
| | **សមត្ថភាពខ្ពស់ជាងមុន និងអភិបាលកិច្ច និងស្ថាប័នសាធារណៈ** | | | | | | | | | |
| ១៤ | គុល្យភាពថវិការរដ្ឋ (អតិរេក/ឱនភាព) ធៀបនឹង ផ.ស.ស. | % | -៥,៤ | -៥,២ | -៤,៩ | -៤,៦ | -៤,៣ | -៤,០ | **ក.យ.ច.** | **ក.ស.ហ.** |
| | **ភាពគ្រប់ជ្រុងជ្រោយ៖ បរិយាកាសប្រតិបត្តិការដែលអំណោយផល** | | | | | | | | | |
| | **សន្តិភាព នយោបាយ និងរបៀបរៀបរយសង្គម** | | | | | | | | | |
| ១៥ | អារម្មណ៍សុវត្ថិភាពពីបទឧក្រិដ្ឋនិងអំពើហិង្សា | % | ៨៤,២ (២០១៧) | ៨៦,០ | ៩០,០ | ៩២,០ | ៩៤,០ | ៩៥,០ | ផ.យ.អ.ជ. ២០១៤/១៨ | អ.ស.ស.ក. រ.ជ.ស. |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **បរិយាកាសអំណោយផលដល់អាជីវកម្ម ការវិនិយោគ និងការអភិវឌ្ឍ** | | | | | | | | | |
| | **ការពង្រឹងភាពជាម្ចាស់ និងដៃគូក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ** | | | | | | | | | |
| ១៦ | ទំហំហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ | % | ៨៣ | | | | | ៩៥ | ថ្មី | ក.អ.ក. |
| ១៧ | ការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍ | % | ៦១,០ | | | | | ៧២,៥ | ថ្មី | ក.អ.ក. |
| ១៨ | ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផល ដោយដៃគូអភិវឌ្ឍ | % | ៦៤ | | | | | ៨០ | ថ្មី | ក.អ.ក. |
| ១៩ | ចំនួនកិច្ចសន្យាពាណិជ្ជកម្ម ជាមួយនឹងប្រទេសដទៃទៀត | ចំនួន | ២១ | ២២ | ២៣ | ២៤ | ២៤ | ២៥ | គ.អ.ថ.ក. | ក.ព.ក. |
| | **ក្រុមិតលទ្ធផល-អាទិភាពនៃគោលនយោបាយរដ្ឋាភិបាល** | | | | | | | | | |
| | **ចំណុចស្នូលៈ ពន្លឿនកំណែទម្រង់** | | | | | | | | | |
| | **កំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព** | | | | | | | | | |
| ២០ | ភាគរយនៃស្ថាប័នសាធារណៈ ដែលកំពុងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ( Budget Strategic Plan ) | % | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ក.យ.ថ. | ក.ស.ហ. |
| ២១ | ចំនួនស្ថាប័នដែលបានកែសម្រួលរចនាសម្ព័ន្ធស្របជាមួយវិមជ្ឈការ | ស្ថាប័ន | ១ | ២ | ៣ | ៤ | ៥ | ៦ | ថ្មី | ក.ម.ផ. / គ.ជ.អ.ប. |
| ២២ | ចំនួនថវិការដ្ឋប្រចាំឆ្នាំសម្រាប់គាំទ្រសកម្មភាពកំណែទម្រង់ស្នូល( លានដុល្លារ ) | លានដុល្លា | ៩,០ | ៩,៥ | ១០,០ | ១០,៥ | ១១,០ | ១១,០ | ថ្មី | ក.ម.ផ. / គ.ជ.អ.ប. |
| | **ភាពស្អាតស្អំ និងសុចរិតភាពនៃរដ្ឋបាលសាធារណៈ** | | | | | | | | | |
| ២៣ | ភាគរយនៃក្រុង ស្រុក ខណ្ឌគោលដៅដែលប្រើប្រាស់ប្រព័ន្ធព័ត៌មានក្នុងការគ្រប់គ្រង | % | ៦០ | ៧០ | ៨០ | ៩០ | ១០០ | ១០០ | ថ្មី | ក.ម.ផ. / គ.ជ.អ.ប. |
| ២៤ | ភាគរយស្ត្រីក្រុង ស្រុក ខណ្ឌកាន់មុខតំណែងគ្រប់គ្រង | % | ២៥ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ថ្មី | ក.ម.ផ. / គ.ជ.អ.ប. |
| ២៥ | ភាគរយផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តនៃថវិកាជាតិ | % | ០,៣៧ | ០,៥០ | ០,៥០ | ១,០០ | ១,០០ | ១,០០ | ថ្មី | ក.ម.ផ. / គ.ជ.អ.ប. |
| | **ប្រសិទ្ធភាពនៃការងារ** | | | | | | | | | |
| ២៦ | ចំណូលក្នុងស្រុក ធៀបនឹង ផ.ស.ស. | % | ១៩,៣ | ១៩,៦ | ២០,២ | ២០,៧ | ២១,០ | ២១,៣ | ក.យ.ថ. | ក.ស.ហ. |
| | **អភិបាលកិច្ចផ្នែកឯកជន** | | | | | | | | | |

| | អាទិភាពទី១ របស់រាជរដ្ឋាភិបាលកម្ពុជា: ការអភិវឌ្ឍធនធានមនុស្ស | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **ការអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** | | | | | | | | | |
| ២៧ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | % | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,២ | ៩៨,៤ | ៩៨,៥ | ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ២៨ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា(តួលេខកែសម្រួល) | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ | ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ២៩ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៥៩,២ | ៦០,៧ | ៦២,២ | ៦៣,៧ | ៦៥,២ | ៦៦,៧ | ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ៣០ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(តួលេខកែសម្រួល) | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ | គ.អ.ច.ក. និង ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ៣១ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ២៨,៥ | ៣០,៤ | ៣២,៣ | ៣៤,២ | ៣៦,១ | ៣៨,០ | ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ៣២ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ២៣,៦ | ២៥,២ | ២៦,៤ | ២៧,៣ | ២៨,០ | ៣០,០ | ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ៣៣ | យុគភាពយេនឌ័រ(GPI) នៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ(តួលេខកែសម្រួល) | សន្ទស្សន៍ | ១,១៨ | ១,១៤ | ១,១១ | ១,០៩ | ១,០៨ | ១,០៣ | គ.អ.ច.ក. | ក.អ.យ.ក./ក.ក.ន |
| ៣៤ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ)-សរុប | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ | គ.អ.ច.ក. និង ផយអេជ ២០១៩/២៣ | ក.អ.យ.ក. |
| ៣៥ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ)-ស្ត្រី | % | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ | គ.អ.ច.ក. | ក.អ.យ.ក. |
| ៣៦ | ភាគរយនិស្សិតរៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) កម្រិតបរិញ្ញាបត្រ | % | ២៧,១ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | ៣២,០ | ប.ព.វ.ក.ស. | ក.អ.យ.ក. |
| ៣៧ | អត្រាចុះឈ្មោះចូលរៀនរបស់និស្សិតជាស្ត្រី ផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEAM) | % | ១៧,៤ | ១៨,៤ | ១៩,៤ | ២០,៥ | ២១,៥ | ២២,៥ | ប.ព.វ.ក.ស. | ក.អ.យ.ក. |
| | **ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ** | | | | | | | | | |
| ៣៨ | អត្រាចុះឈ្មោះចូលរៀនសរុបនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ (អាយុ១៥-២៤ឆ្នាំ) (តួលេខកែសម្រួល) | % | ៤៤ | ៥០ | ៥០ | ៦០ | ៦០ | ៦០ | គ.អ.ច.ក. | ក.ក.ប.វ./អ.ស.ស.ក. |
| | **ការថែទាំសុខភាពសាធារណៈ និងអាហារូបត្ថម្ភ** | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣៩ | សមាមាត្រនៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលមានជំនាញ | % | ៨៩ | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ | ផយអេជ ២០១៧/១៨ | ក.ស.ភ. |
| ៤០ | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | លើប្រ/ជ ១០០ ពាន់នាក់ | ០.៣៥ | ០,១៥ | 0,00 | 0,00 | 0,00 | 0,00 | ផយអេជ ២០១៧/១៨ | ក.ស.ភ. |
| ៤១ | អត្រាមរណភាពមាតា | ក្នុង១០០ពាន់ទារកកើតរស់ | ៧៥ (២០១៤) | | ៦៥ | | | ៥៥ | ផយអេជ ២០១៧/១៨ | អ.ប.ស.ក./វ.ជ.ស./ក.ស.ភ. |
| ៤២ | អត្រាមរណភាពទារកទើបកើត | ១០០០ទារកកើតរស់ | ២៨ (២០១៤) | | ២០ | | | ១៥ | ផយអេជ ២០១៧/១៨ | អ.ប.ស.ក./វ.ជ.ស./ក.ស.ភ. |
| ៤៣ | អត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ | ១០០០ទារកកើតរស់ | ៣៥ (២០១៤) | | ២៥ | | | ១០ | ផយអេជ ២០១៧/១៨ | អ.ប.ស.ក./វ.ជ.ស./ក.ស.ភ. |
| ៤៤ | ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់ | ក្នុងប្រ/ជគ្មានផ្ទុកមេរោគអេដស៍១០០០នាក់ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ០,០៣ | ផយអេជ ២០១៧/១៨ | ក.ស.ភ. |
| ៤៥ | អាំងស៊ីដង់នៃជំងឺរបេង(តួលេខកែសម្រួល) | ក្នុងប្រ/ជ ១០០ ពាន់នាក់ | ៣២៦ | ៣២៣ | ៣១០ | ២៦១ | ២៤៣ | ២២៦ | គ.អ.ច.ក. | ក.ស.ភ. |
| ៤៦ | ពិនិត្យពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ០,៧២ | ០,៨០ | ០,៨៥ | ០,៨៦ | ០,៨៧ | ០,៨៩ | ប.ព.វ.ក.ស. | ក.ស.ភ. |
| | **សមភាពយេនឌ័រ និងការគាំពារសង្គម** | | | | | | | | | |
| ៤៧ | ចំនួនមណ្ឌលសេវាចម្រុះសម្រាប់ស្ត្រី និងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្តល់សេវា ផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗទៀតជូនជនរងគ្រោះ | ចំនួនមណ្ឌល | ០ | ១ | ២ | ៣ | ៤ | ៥ | ប.ព.វ.ក.ស. | ក.ស.ភ./ក.ក.ន |
| ៤៨ | សមាមាត្រស្ត្រីដែលមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈ ទាំងថ្នាក់ជាតិនិងក្រោមជាតិ (អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងប្រធានមន្ទីរ) | % | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ប.ព.វ.ក.ស. | ក.ម.ស./ក.ក.ន |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤៩ | អត្រាស្ត្រីដែលមានការងារធ្វើ អាយុពី១៥-៦៤ ឆ្នាំ | % | ៧៩.៩ (២០១៧) | ៨២,០ | ៨៤,០ | ៨៥,០ | ៨៧,០ | ៩០,០ | អ.ស.ស.ក. | អ.ស.ស.ក./វ.ជ.ស./ ក.ផ.ក. |
| ៥០ | ចំណែករបស់ស្ត្រីចូលរួមក្នុងការងារមានប្រាក់កម្រៃ អាយុពី ១៥-៦៤ ឆ្នាំ | | | | | | | | អ.ស.ស.ក. | អ.ស.ស.ក./វ.ជ.ស./ ក.ផ.ក. |
| | កសិកម្ម | % | ៣៥,០ (២០១៧) | ៣៧,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | អ.ស.ស.ក. | អ.ស.ស.ក./វ.ជ.ស./ ក.ផ.ក. |
| | ឧស្សាហកម្ម | % | ២៧,៣ (២០១៧) | ២៩,០ | ៣០,០ | ៣១,០ | ៣៣,០ | ៣៥,០ | អ.ស.ស.ក. | អ.ស.ស.ក./វ.ជ.ស./ ក.ផ.ក. |
| | សេវាកម្ម | % | ៣៧,៦ (២០១៧) | ៣៨,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | អ.ស.ស.ក. | អ.ស.ស.ក./វ.ជ.ស./ ក.ផ.ក. |
| | **អាទិភាពទី២ របស់ព្រះរាជាណាចក្រកម្ពុជា៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច** | | | | | | | | | |
| | **ឡូជីស្ទីក ការដឹកជញ្ជូន ថាមពល និងការតភ្ជាប់បែបឌីជីថល** | | | | | | | | | |
| ៥១ | បរិមាណដឹកជញ្ជូន នៅផែក្រុងព្រះសីហនុ និងក្រុងភ្នំពេញ ប្រចាំឆ្នាំ (តួលេខកែសម្រួល) | ១០០០តោន | ៨ ០៩៥ | ៩ ០២៦ | ១០ ២៦២ | ១១ ១០៦ | ១២ ១២៤ | ១៣ ២០៥ | គ.អ.ច.ក. | ក.ស.ជ. |
| | | ១០០០ TEU | ៧៤២ | ៨២៤ | ៩១៨ | ១ ០១៥ | ១ ១១០ | ១ ២៨៤ | ថ្មី | ក.ស.ជ. |
| ៥២ | ចំនួនអ្នកដំណើរតាមជើងយន្តហោះក្នុងស្រុក | នាក់ | ៤៤២ ៣១៦ | ៤៥២ ០៤៧ | ៤៦១ ៩៩២ | ៤៧២ ១៥៦ | ៤៨៣ ៥៤៣ | ៤៩៣ ១៥៩ | គ.អ.ច.ក. | រ.ល.អ.ស. |
| ៥៣ | ចំនួនអ្នកដំណើរតាមជើងយន្តហោះអន្តរជាតិ | ពាន់នាក់ | ៧ ៦២៧ | ៨ ៤៥៨ | ៩ ៣៨០ | ១០ ៤០៣ | ១១ ៥៣៧ | ១២ ៧៩៤ | គ.អ.ច.ក. | រ.ល.អ.ស. |
| ៥៤ | ប្រវែងផ្លូវជាតិដែលក្រាលកៅស៊ូនិងចាក់បេតុង (ក្នុងប្រវែងផ្លូវជាតិសរុប ១៦ ២៩២គ.ម.) | គ.ម. | ៥៧៩,៣៥ | ៥៥៥,៥៧ | ៤៧៤,៥៥ | ៦២៧,៩៩ | ៦៩៤,៩៣ | ៦៧៥,៥៨ | ថ្មី | ក.ស.ជ. |
| ៥៥ | ភាគរយនៃផ្លូវជាតិនិងខេត្តដែលធន់នឹងការប្រែប្រួលអាកាសធាតុ | % | ៥២,៦៧ | ៥៥,៣០ | ៥៨,០៧ | ៦០,៩៧ | ៦៤,០២ | ៦៧,២២ | ថ្មី | ក.ស.ជ. |
| ៥៦ | ប្រវែងផ្លូវជនបទ(ក្នុងប្រវែងផ្លូវជនបទសរុប៤៥ ០០០គ.ម.) | គ.ម. | ២៩ ១៧២ | ៣០ ៧៤០ | ៣២ ៩៣៥ | ៣៦ ០០៨ | ៣៩ ៦០៩ | ៤៣ ៥៧០ | ថ្មី | ក.អ.ជ. |
| ៥៧ | ប្រវែងផ្លូវជនបទសរុប ដែលធន់នឹងការប្រែប្រួលអាកាសធាតុ(ក្នុងប្រវែងផ្លូវជនបទសរុប ២ ២៥១ គ.ម.) | គ.ម. | ៣១០ | ៦៤០ | ៩៩១ | ១ ៣៧៣ | ១ ៧៩០ | ២ ២៥១ | ថ្មី | ក.អ.ជ. |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥៨ | ការស្តារ និងសាងសងផ្លូវដែក | គ.ម | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ផយអេជ ២០១៤/១៨ | ក.ស.ដ. |
| ៥៩ | ទេសចរណ៍(ចំនួននៃការមកដល់នៃភ្ញៀវអន្តរជាតិ) | នាក់ | ៦,២០ | ៦,៦៤ | ៧,១៥ | ៧,៨៧ | ៨,៦៥ | ៩,៣០ | ផយអេជ ២០១៤/១៨ | ក.ទ.ច. |
| ៦០ | ការផ្គត់ផ្គង់ថាមពលអគ្គិសនី | លានkWh | ៩ ៣០៧ | ១០ ៨០៨ | ១២ ៩៦៩ | ១៥ ៣០៤ | ១៧ ៥៩៩ | ២០ ០៦៣ | ថ្មី | ក.រ.ថ. |
| ៦១ | សមាមាត្រ នៃប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន ដែលទទួលបានសេវាទឹកស្អាត និងមានសុវត្ថិភាព (តួលេខកែសម្រួល) | % | ៤៥,៧១ | ៥៣,៧១ | ៦១,៧១ | ៦៩,៧១ | ៧៧,៧១ | ៩០,០០ | ផយអេជ ២០១៤/១៨ | ក.ឧ.ស. |
| ៦២ | សមាមាត្រ នៃប្រជាជនកម្ពុជា នៅតំបន់ជនបទ ដែលទទួលបាននូវសេវាទឹកស្អាត និងមានសុវត្ថិភាព | % | ៦០ | ៦៥ | ៧២ | ៧៩ | ៨៤ | ៩០ | ផយអេជ ២០១៤/១៨ | ក.អ.ជ. |
| ៦៣ | សមាមាត្រនៃប្រជាជនកម្ពុជា នៅតំបន់ជនបទ ដែលទទួលបាននូវសេវាអនាម័យ | % | ៦០ | ៧០ | ៧៥ | ៨០ | ៨៥ | ៩០ | ប.ព.រ.ក.ស. | ក.អ.ជ. |
| | **ប្រភពថ្មីៗនៃកំណើនសេដ្ឋកិច្ច** | | | | | | | | | |
| ៦៤ | ប្រជាជនកម្ពុជាដែលទទួលបានការងារក្នុងវិស័យកម្មន្តសាល គិតជាភាគរយនៃអ្នកមានការងារធ្វើសរុប(កែសម្រួល) | % | ២៣,៩១ | ២៤,៤០ | ២៥,៤៨ | ២៦,៣៦ | ២៧,១០ | ២៨,០៧ | គ.អ.ថ.ក. | ក.ឧ.ស./វ.ជ.ស. |
| ៦៥ | ចំណូលមិនមែនសារពើពន្ធដែលប្រមូលបាន និងប៉ាន់ស្មានសម្រាប់ឆ្នាំបន្តក្នុងវិស័យរ៉ែនិងថាមពល | លានដុល្លារ | ១៨,០ | ១៨,៩ | ២២,០ | ២៣,០ | ២៣,០ | ២៣,០ | ថ្មី | ក.រ.ថ. |
| ៦៦ | ផលិតកម្មប្រេងកាតពីប្លុក A | ពាន់បារ៉ែល | - | - | ២ ៣៦៥,៥២ | ២ ៣៦៥,២ | ៦ ៨៧៣,៣២ | ៦ ៨៦៧,៤៨ | ថ្មី | ក.រ.ថ. |
| | **សេដ្ឋកិច្ចឌីជីថល បដិវត្តឧស្សាហកម្ម ជំនាន់ទី៤ (៤.0)** | | | | | | | | | |
| ៦៧ | អត្រាកំណើន នៃការចុះបញ្ជីក្រុមហ៊ុនតាមអនឡាញ | % | ៣២ | ៣៣ | ៣៦ | ៤០ | ៥០ | ៧៨ | គ.អ.ថ.ក. | ក.ព.ក. |
| ៦៨ | អត្រាកំណើននៃការចុះបញ្ជី ម៉ាក តាមអនឡាញ | % | ១២ | ១៣ | ១៥ | ១៧ | ២០ | ២១ | គ.អ.ថ.ក. | ក.ព.ក. |
| ៦៩ | អត្រាកំណើននៃការចេញលិខិតបញ្ជាក់ប្រភពដើមទំនិញ (C/O) | % | ២៤ | ២៥ | ២៧ | ២៩ | ៣២ | ៣៦ | គ.អ.ថ.ក. | ក.ព.ក. |
| ៧០ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទសរុប | | | | | | | | ក.យ.ថ. | ក.ប.ទ. |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ទូរស័ព្ទចល័ត | ក្នុងប្រ/ជ១០០ នាក់ | ១២០,១១ | ១២១,១៥ | ១២៤,២០ | ១២៧,៧០ | ១៣០,៧០ | ១៣៤,១៧ | ក.យ.ច. | ក.ប.ទ. |
| | ទូរស័ព្ទអចល័ត | ក្នុងប្រ/ជ១០០ នាក់ | ០,៥៧ | ០,៥៥ | ០,៥៣ | ០,៥២ | ០,៥១ | ០,៥០ | ក.យ.ច. | ក.ប.ទ. |
| ៧១ | អត្រាអ្នកប្រើប្រាស់សេវាអ៊ិនធឺណិតសរុប (តួលេខកែសម្រួល) | | | | | | | | គ.អ.ច.ក. និងក.យ.ច. | ក.ប.ទ. |
| | អ៊ិនធឺណិតចល័ត | ក្នុងប្រ/ជ១០០ នាក់ | ៨០,៧០ | ៨៤,៥៧ | ៩០,០៣ | ៩៥,៨៩ | ១០២,១៧ | ១០៨,៩២ | គ.អ.ច.ក. និងក.យ.ច. | ក.ប.ទ. |
| | អ៊ិនធឺណិតអចល័ត | ក្នុងប្រ/ជ១០០ នាក់ | ០,៩២ | ១,១០ | ១,៣៥ | ១,៦៥ | ២,០២ | ២,៤៧ | គ.អ.ច.ក. និង ក.យ.ច. | ក.ប.ទ. |
| | **វិស័យធនាគារ និងហិរញ្ញវត្ថុ** | | | | | | | | | |
| ៧២ | ភាគរយ នៃមនុស្សពេញវ័យដែលប្រើប្រាស់គណនីធនាគារ គិតទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | % | ៦៩,០០ | ៧៤,០០ | ៧៩,០០ | ៨៣,០០ | ៨៦,០០ | ៨៩,០០ | សូចនាករកំណត់ថ្មី | ធ.ជ.ក. |
| ៧៣ | ការដាក់ប្រាក់បញ្ញើជាប្រាក់រៀល ធៀបនឹងនៃការផ្គត់ផ្គង់សាច់ប្រាក់ (M2) | % | ៥,០០ | ៧,០០ | ១០,០០ | ១១,០០ | ១២,០០ | ១៣,០០ | សូចនាករកំណត់ថ្មី | ធ.ជ.ក. |
| ៧៤ | ឥណទានមិនដំណើរការ(ធៀបនឹងឥណទានសរុប) | | | | | | | | ក.យ.ច. | ធ.ជ.ក. |
| | គ្រឹះស្ថានធនាគារ | % | ២,៦៧ | ២,៨០ | ២,៨០ | ២,៩០ | ២,៩០ | ៣,០០ | ក.យ.ច. | ធ.ជ.ក. |
| | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | % | ១,៥៨ | ១,៣៥ | ១,២៥ | ១,២០ | ១,២២ | ១,២៣ | ក.យ.ច. | ធ.ជ.ក. |
| | **អាទិភាពទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា៖ ការអភិវឌ្ឍផ្នែកឯកជន និងការងារ** | | | | | | | | | |
| | **ការអភិវឌ្ឍទីផ្សារការងារ** | | | | | | | | | |
| ៧៥ | តម្លៃប្រាក់ឈ្នួលអប្បបរមាប្រចាំខែ (ប្រាក់ឈ្នួលអប្បបរមាវិស័យវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង) | ដុល្លារ | ១៧០ | ១៨២ | | | | | សូចនាករកំណត់ថ្មី | ក.ក.ប.វ. |
| ៧៦ | ភាគរយនៃការងារផ្លូវការ (ឧ.ស្ថានភាពរបស់និយោជិត) | % | ៦៥ | ៦៥ | ៧០ | ៧៥ | ៧៥ | ៨០ | សូចនាករកំណត់ថ្មី | ក.ក.ប.វ. |
| ៧៧ | ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ | % | ៤៥ | ៥០ | ៥៥ | ៥៥ | ៥៥ | ៥០ | ក.យ.ច. | ក.ក.ប.វ. |
| | **សហគ្រាសខ្នាតតូច និងមធ្យម និងសហគ្រិនភាព** | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៧៨ | ប្រាក់បៀវត្សសរុប | លានដុល្លារ | ២,១៩៤ | ២,៣០២ | ២,៥១៦ | ២,៧២៩ | ២,៩៤២ | ៣,១៥៦ | ផយអជ ២០១៤/១៨ | |
| | **ភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ** | | | | | | | | | |
| | **ការលើកកម្ពស់ការប្រកួតប្រជែង** | | | | | | | | | |
| ៧៩ | ការវិនិយោគលើការស្រាវជ្រាវ និងការអភិវឌ្ឍសរុប (សាធារណៈនិងឯកជន) គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) | % | ០,១៤ | ០,១៧ | ០,២០ | ០,២៣ | ០,៣០ | ០,៤៤ | គ.អ.ច.ក. | អ.ល.-ក.ជ.វ.ប./ក.ផ.ក. |
| ៨០ | ចំនួនអ្នកស្រាវជ្រាវគិតជាសមមូលនៃរយៈពេលធ្វើការពេញម៉ោង(FTE) ក្នុងប្រជាជន ១លាននាក់ | ក្នុងប្រជាជន ១លាននាក់ | ៧៥ | ១០៨ | ១៥២ | ២២០ | ២៨៧ | ៣៧៧ | គ.អ.ច.ក. | អ.ល.-ក.ជ.វ.ប./ក.ផ.ក. |
| | **អាទិភាពទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា៖ ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន** | | | | | | | | | |
| | **ការអភិវឌ្ឍជនបទ កសិកម្ម និងធនធានទឹក** | | | | | | | | | |
| ៨១ | ទិន្នផលស្រូវ | តោន/ហិកតា | ៣,៣៣ | ៣,៣៥ | ៣,៣៧ | ៣,៣៩ | ៣,៤១ | ៣,៤៤ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨២ | តម្លៃបន្ថែមក្នុងវិស័យកសិកម្ម ប្រចាំឆ្នាំ | ពាន់លានរៀល | ២១,៧១ | ២២,៦១ | ២៣,៥២ | ២៤,២២ | ២៤,៩៤ | ២៥,៦៩ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៣ | បរិមាណផលិតផលកសិកម្មសរុប ប្រចាំឆ្នាំ | លានតោន | ២៨,៤៧ | ២៩,៩៣ | ៣១,៤៨ | ៣៣,១៤ | ៣៤,៩០ | ៣៦,៧៧ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៤ | បរិមាណផលិតផលកសិកម្មនាំចេញប្រចាំឆ្នាំ | លានតោន | ៥,៤៩ | ៥,៨៧ | ៦,២៩ | ៦,៧៣ | ៧,២០ | ៧,៧០ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៥ | ផលិតផលសាច់សត្វសរុបកើន៣%/ឆ្នាំ | ពាន់តោន | ២៣២ | ២៤០ | ២៤៧ | ២៥៤ | ២៦២ | ២៧០ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៦ | ផលិតកម្មកៅស៊ូប្រចាំឆ្នាំ | ពាន់តោន | ២០៧,០០ | ២៩២,០០ | ៣៥៣,០០ | ៣៩៥,០០ | ៤១២,០០ | ៤១៧,០០ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៧ | បរិមាណផលនេសាទ (ចាប់ពីធម្មជាតិនិងវារីវប្បកម្ម) ប្រចាំឆ្នាំ | ពាន់តោន | ៨៤៨,០ | ៨៩៨,៧ | ៩៥៨,៥ | ១ ០៣០,១ | ១ ១១៦,២ | ១ ២១៩,៤ | ផយអជ ២០១៤/១៨ | ក.ក.រ.ន. |
| ៨៨ | បរិមាណផលឈើដាំត្រូវបានប្រមូល | ពាន់ម៉ែត្រគូប/ឆ្នាំ | ១៧៥ | ២០០ | ២២៥ | ២៥០ | ២៧៥ | ៣០០ | | ក.ក.រ.ន. |
| ៨៩ | ផ្ទៃដីសរុបដែលបានបោសសម្អាតមីននិងសំណល់ផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (តួលេខកែសម្រួល) | ហិកតា | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | ២១ ៤០០ | គ.អ.ច.ក. | អ.ក.គ.ស. |
| | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក រួមទាំងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ** | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៩០ | លទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវ(ប្រាំងនិងវស្សា) ប្រចាំឆ្នាំនីមួយៗ | ពាន់ហិកតា | ១ ៨០២,៣៦ | ៣០,០០ | ១ ៨៦២,៣៦ | ១ ៨៩២,៣៦ | ១ ៩២២,៣៦ | ១ ៩៥,៣៦ | ផយអជ ២០១៩/២៣ | ក.ធ.ទ.ឧ. |
| | **ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត** | | | | | | | | | |
| ៩១ | ផ្ទៃដីដំណាំស្រូវដែលត្រូវបានសង្គ្រោះពីភាពរាំងស្ងួតនិងខ្វះទឹក ប្រចាំឆ្នាំ | ហិកតា | ៩៣ ២៨៧ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ | ៩០ ០០០ | ផយអជ ២០១៩/២៣ | ក.ធ.ទ.ឧ. |
| | ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម | | | | | | | | | |
| ៩២ | ចំនួនស្ថានីយជលសាស្ត្រពិនិត្យគុណភាពទឹក ដែលបានដំឡើង | ស្ថានីយ ជលសាស្ត្រ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ផយអជ ២០១៩/២៣ | ក.ធ.ទ.ឧ. |
| ៩៣ | ចំនួនស្ថានីយឧតុនិយម ដែលបានដំឡើង | ស្ថានីយឧតុនិយម | ៦៥ | ៧០ | ៧៥ | ៨០ | ៨៥ | ៩០ | ផយអជ ២០១៩/២៣ | ក.ធ.ទ.ឧ. |
| | **អភិរក្សធនធានធម្មជាតិនិងវប្បធ៌មប្រកបដោយចីរភាព** | | | | | | | | | |
| ៩៤ | ចំនួនតំបន់ការពារធម្មជាតិត្រូវបានកំណត់ព្រំប្រទល់ កំណត់តំបន់គ្រប់គ្រង ចុះបញ្ជីកាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងមានផែនការគ្រប់គ្រងច្បាស់លាស់ | តំបន់ការពារធម្មជាតិ | ៣ | ៧ | ៧ | ៧ | ៧ | ៦ | ប.ព.វ.ក.ស. | ក.ប.ស. |
| ៩៥ | កម្មវិធីប្រតិបត្តិមេត្រីភាពបរិស្ថាន | នាក់ | ០ | ១០០ | ១០០ | ១៥០ | ២០០ | ៣០០ | ប.ព.វ.ក.ស. | ក.ប.ស. |
| | **ការគ្រប់គ្រងនគរូបនីយកម្ម** | | | | | | | | | |
| ៩៦ | អត្រាចុះបញ្ជីអចលនវត្ថុ (ចេញបណ្ណកម្មសិទ្ធិ) | % | ៧២,៥ | ៧៨,០ | ៨៤,០ | ៩០,០ | ៩៦,០ | ១០០ | ផយអជ ២០១៩/២៣ | ក.រ.ដ.ន.ស. |
| ៩៧ | ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | សហគមន៍ | ២៤ | ៣៤ | ៤៤ | ៥៤ | - | - | ផយអជ ២០១៩/២៣ | ក.រ.ដ.ន.ស. |
| ៩៨ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | គ្រួសារ | ៧៨ ៥៤៥ | ៧៩ ០៤៥ | ៧៩ ៥៤៥ | ៨០ ០៤៥ | ៨០ ៥៤៥ | ៨១ ០៤៥ | ផយអជ ២០១៩/២៣ | ក.រ.ដ.ន.ស. |
| ៩៩ | ផ្ទះដែលបានសាងសង់ជូនគ្រួសារកងទ័ព នគរបាលជាតិ និងអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ | ខ្នង | ៦ ៦៩៩ | ៧ ១៩៩ | ៧ ៦៩៩ | ៨ ១៩៩ | ៨ ៦៩៩ | ៩ ១៩៩ | ផយអជ ២០១៩/២៣ | ក.រ.ដ.ន.ស. |
| ១០០ | បរិមាណសំណល់រឹងពីទីក្រុង ដែលត្រូវបានប្រមូលទៀងទាត់ ដោយមានទីកន្លែងចាក់ (តួលេខកែសម្រួល) | ពាន់តោន | ១ ០៧៩ | ១ ២៣០ | ២ ១៨២ | ២ ៤៦៦ | ២ ៧៨៧ | ៣ ១៥០ | គ.អ.ច.ក. | ក.ប.ស. |

| | ចីរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១០១ | បម្រែបម្រួលប្រចាំឆ្នាំជាមធ្យមនៃប៉ារ៉ាម៉ែត្រ នៃសារធាតុ CO NO2 SO2 TSP PM2.5 និង PM10 | % | ៤,០ | ៤,០ | ៥,០ | ៥,០ | ៥,០ | ៥,០ | គ.អ.ច.ក. | ក.ប.ស. |
| ១០២ | ភាគរយ នៃការកាត់បន្ថយនៃការបញ្ចេញសារធាតុបំពុលសរីរាង្គ (POPs) ដល់បរិស្ថាន | % | ១,០ | ២,០ | ៤,០ | ៨,០ | ១០,០ | ១៤,០ | ប.ព.វ.ក.ស. | ក.ប.ស. |
| ១០៣ | ចំនួនគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានចុះបញ្ជី | ចំនួន | ១ | ២ | ៤ | ៧ | ១០ | ១៤ | គ.អ.ច.ក. | ក.ប.ស./អ.គ.អ.ច. |
| ១០៤ | % នៃថវិកាចំណាយលើអាកាសធាតុក្នុង ផ.ស.ស. | % | ១,២ | ១,៤ | ១,៥ | ១,៥ | ១,៥ | ១,៦ | គ.អ.ច.ក. | ក.ប.ស./អ.គ.អ.ច. |
| ១០៥ | បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយធៀបទិន្នន័យឆ្នាំគោល | ពាន់ Gg CO2 equivalent | ២ ៤៩៧ | ២ ៧៩៩ | ២ ៨៣៦ | ២ ៨៨៧ | ២ ៩១៧ | ៣ ០១៨ | គ.អ.ច.ក. | ក.ប.ស./អ.គ.អ.ច. |
| ១០៦ | កម្រិតត្រៀមរបស់ស្ថាប័នក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (តួលេខកែសម្រួល) | % | ៤៩ | ៥៣ | ៥៧ | ៦០ | ៦៣ | ៦៥ | គ.អ.ច.ក. | ក.ប.ស./អ.គ.អ.ច. |
| ១០៧ | ចំនួនក្រសួង ស្ថាប័នដែលបានបញ្ជ្រាបបញ្ហាជីវៈចម្រុះក្នុងផែនការនៃវិស័យពាក់ព័ន្ធ | ចំនួនផែនការ | ២ | ៣ | ៤ | ៥ | ៦ | ៧ | គ.អ.ច.ក. | ក.ប.ស./អ.គ.អ.ច. |
| ១០៨ | សមាមាត្រនៃថាមពលកកើតឡើងវិញ ក្នុងថាមពលដែលប្រើប្រាស់សរុប | Mtoe | ២ ៧៥០,១ | ២ ៨៨៥,៥ | ៣០៣១,២ | ៣ ១៨៤,៥ | ៣ ៣៤៦,១ | ៣ ៥១៦,៣ | គ.អ.ច.ក. | ក.រ.ថ. |
| ១០៩ | ភាគរយនៃប្រភពថាមពលអគ្គិសនីកកើតឡើងវិញ (អានុភាពតម្លើង) | % | ៥២,៦៣ | ៥១,១៣ | ៥២,១៤ | ៥៤,០៤ | ៥៥,២២ | ៤៩,២៣ | ថ្មី | ក.រ.ថ |

**សម្គាល់៖**

១. អាទិភាពនៃប្រភព ត្រូវបានកំណត់តាមលំដាប់ ផ.យ.អ.ជ. ២០១៤-២០១៨ គ.អ.ច.ក. ក្រសួង ស្ថាប័ន និង ចុងក្រោយ គឺ បង្កើតថ្មី (ឧ. សូចនាករណាដែលមានកំណត់ប្រភពច្រើន ដូចជា ផ.យ.អ.ជ. ២០១៤-២០១៨ និង គ.អ.ច.ក. ត្រូវកំណត់យក ប្រភពមកពី ផ.យ.អ.ជ. ២០១៤-២០១៨)

២. សូចនាករកំណាំថ្មីគឺជាសូចនាករ ក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ (ក.យ.ច.) សូចនាករ ផ.យ.អ.ជ. ២០១៩-២០២៣ និង សូចនាករ ថ្មី

# តារាងសូចនាករ បន្ថែមសម្រាប់តាមដានត្រួតពិនិត្យ និង វាយតម្លៃ ផ.យ.អ.ជ ២០១៩-២០២៣

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើសបុគ្គលិក ស្របតាមគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | % | ០ | ៤០ | ៦០ | ៨០ | ១០០ | ១០០ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ២ | ភាគរយនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ វាយតម្លៃដោយគណៈអភិបាលរបស់ខ្លួន | % | ០ | ២០ | ៤០ | ៦០ | ៨០ | ១០០ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ៣ | ចំនួនសរុបនៃក្រសួង/ ស្ថាប័ន ដែលបានបញ្ចប់លិខិតបទដ្ឋានផ្ទេរមុខងារ | ក្រសួង/ ស្ថាប័ន | ៥ | ៧ | ៩ | ១១ | ១៣ | ១៤ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ៤ | ចំនួនសរុបនៃផែនការផ្ទេរមុខងារដែលបានអនុវត្ត | ផែនការ | ២ | ៤ | ៦ | ៨ | ១០ | ១២ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ៥ | ចំនួនក្រុង ស្រុក ខណ្ឌ ដែលទទួលបានមូលនិធិមានភ្ជាប់លក្ខខណ្ឌ | % | ០ | ១៥ | ៤០ | ៥០ | ៦០ | ៧០ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ៦ | ភាគរយចំណូលសារពើពន្ធនៃគុណប្រយោជន៍ថវិកា ខេត្តចែករំលែកទៅឱ្យក្រុង ស្រុក | % | ៣ | ៣ | ៣ | ៥ | ៥ | ៥ | ថ្មី | ក.ម.ជ./គ.ជ.អ.ប. |
| ៧ | អត្រាស្លាប់ដែលបណ្តាលមកពីសរសៃឈាមបេះដូងមហារីក ទឹកនោមផ្អែម ឬប្រព័ន្ធដង្ហើមរ៉ាំរ៉ៃក្នុងចំណោមប្រជាជនដែលមានអាយុពី៣០ ទៅ៧០ ឆ្នាំ | % | | | ៣៤ | | | | គ.អ.ច.ក. | ក.ស.ភ. |
| ៨ | ភាគរយនៃស្ត្រីវ័យជំទង់អាយុ១៥-១៩ឆ្នាំមានគភ៌ | % | | | ៨ | | | | គ.អ.ច.ក. | ក.ស.ភ. |
| ៩ | ពិនិត្យពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ០,៧២ | ០,៨០ | ០,៨៥ | ០,៨៦ | ០,៨៣ | ០,៨៩ | | ក.ស.ភ. |
| ១០ | អត្រាគ្របដណ្តប់នៃការផ្តល់វ៉ាក់សាំងបង្ការជាប្រចាំលើកុមារអាយុក្រោមមួយឆ្នាំ តាមប្រភេទវ៉ាក់សាំង | | | | | | | | | |
| | - វ៉ាក់សាំងបង្ការជំងឺតេតាណូស-ខាន់ស្លាក់-ក្អកមាន់-រលាកថ្លើមប្រភេទបេ-រលាកសួត៣លើក | % | ៩៨ | > ៩៥ | > ៩៥ | > ៩៥ | > ៩៥ | > ៩៥ | | ក.ស.ភ. |

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| | - ជំងឺកញ្ច្រឹល -ស្អូច នៅខែទី៩ | | ១០៣ | > ៩៥ | > ៩៥ | > ៩៥ | > ៩៥ | > ៩៥ | | ក.ស.ភ. |
| ១១ | ភាគរយនៃសមាជិកដែលបានចុះបញ្ជី ក្នុងសហគមន៍នេសាទ និងរុក្ខាប្រមាញ់ ដែលទទួលបានសិទ្ធិស្របច្បាប់ ក្នុងការទាញផលនេសាទ និងអនុផលព្រៃឈើ តាមរយៈការចុះបញ្ជី និងការអភិវឌ្ឍមានប្រសិទ្ធភាព | % | ៤៥,០ | ៤៨,០ | ៥០,០ | ៥៣,០ | ៥៥,០ | ៥៨,០ | គ.អ.ច.ក. | ក.ក.រ.ន. |
| ១២ | បរិមាណដឹកជញ្ជូននៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ១000តោន | ៥ ១៩៦ | ៥ ៩០៨ | ៦ ៧៤៧ | ៧ ៤២១ | ៨ ១៦៤ | ៨ ៩៨០ | | ក.ប.ទ. |
| | | ១000 TEU | ៥៣៧ | ៥៩០ | ៦៦៨ | ៧៤៥ | ៨១០ | ៩៥៤ | | ក.ប.ទ. |
| ១៣ | បរិមាណដឹកជញ្ជូននៅកំពង់ផែស្វយ័តភ្នំពេញ | ១000តោន | ២ ៨៩៩ | ៣ ១១៨ | ៣ ៥១៥ | ៣ ៦៨៥ | ៣ ៩៦០ | ៤ ២២៥ | | ក.ប.ទ. |
| | | ១000 TEU | ២០៥ | ២៣៤ | ២៥០ | ២៧០ | ៣០០ | ៣៣០ | | ក.ប.ទ. |
| ១៤ | ចំនួននៃភ្ញៀវជាតិ | នាក់ | ១១,០ | ១១,៣០ | ១១,៥០ | ១១,៨៥ | ១២,១៣ | ១២,៥០ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ទ.ច. |
| ១៥ | សេវាស្នាក់នៅ | បន្ទប់ | ៨១ ៥៣៦ | ៨៨ ៧០០ | ៩៧ ៩០០ | ១០៦ ៥០០ | ១១៥ ៤០០ | ១២៥ ០០០ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ទ.ច. |
| ១៦ | កម្លាំងពលកម្មបម្រើឱ្យវិស័យ ទេសចរណ៍ | ពាន់នាក់ | ៦២០ | ៦៣៥ | ៦៥០ | ៦៨០ | ៧២០ | ៧៥០ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ទ.ច. |
| ១៧ | ចំណូលពីទេសចរណ៍អន្តរជាតិ | លានដុល្លារ | ៤ ៣៧៥ | ៤ ៦០០ | ៥ ០០០ | ៥ ៥០០ | ៦ ១០០ | ៦ ៧០០ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ទ.ច. |
| ១៨ | សមាមាត្រនៃចំនួនប្រជាជន ដែលមានអគ្គិសនីប្រើប្រាស់ | % | ៩,៧៧ | ១០,០៦ | ១០,៣៤ | ១០,៦៣ | ១០,៩២ | ១១,២១ | អ.ស.ស.ក. | អ.ស.ស.ក./ជំរឿន |
| ១៩ | បរិមាណអគ្គិសនីដែលបានប្រើប្រាស់ដោយប្រជាជនម្នាក់ក្នុង ១ឆ្នាំ | KWh\១នាក់ | ៥៧៩ | ៦៦៤ | ៧៨៦ | ៩១៥១ | ១ ០៣៧ | ១ ១៦៥ | ថ្មី | ក.រ.ថ. |
| ២០ | ចំនួនសហគ្រាសខ្នាតតូច និងមធ្យមដែលបានចុះបញ្ជី | សហគ្រាស | ១៥៦ ៨៥៣ | ១៦០ ៧៥៥ | ១៧២ ០០០ | ១៨០ ៦០៥ | ១៨៧ ៥៣០ | ១៩៧ ២២១ | ក.យ.ច. | ក.ឧ.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ២១ | ចំនួននៃចង្កោមសហគ្រាសធុនតូចនិងមធ្យមថ្មីៗដែលទើបតែនឹងបង្កើតឡើង | ចង្កោម | ០០ | ០២ | ០៧ | ១៣ | ១៧ | ២៧ | ក.យ.ច. | ក.ឧ.ស./ក.អ.ក. |
| ២២ | ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ១,៤៤៥ | ១,៦៣២ | ១,៧៤៦ | ១,៨៦០ | ១,៩៧៤ | ២,០៨៩ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ព.ក. |
| ២៣ | ចំនួនកម្មករ (ប្រុស-ស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ៩៨៨,៨៥៦ | ១,១០០,៤៩៨ | ១,១៦២,៥៦៥ | ១,២២៤,៦៣២ | ១,២៨៦,៦៩៩ | ១,៣៤៨,៧៦៦ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ព.ក. |
| ២៤ | ចំនួនសមាគមអាជីវកម្ម | ចំនួន | ៣២ | ៣៧ | ៤១ | ៤៥ | ៤៩ | ៥២ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ព.ក. |
| ២៥ | ចំនួនសភាពាណិជ្ជកម្ម | ចំនួន | ១៥ | ២០ | ២៤ | ២៤ | ២៩ | ៣៣ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ព.ក. |
| ២៦ | អនុបាត % ពិពិធកម្មដំណាំ ធៀបទៅនឹងផ្ទៃដីស្រូវ | % | ៦២,៣២ | ៦៣,៤៤ | ៦៤,៥៥ | ៦៥,៦៥ | ៦៦,៧៣ | ៦៧,៧៩ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ក.រ.ន. |
| ២៧ | បរិមាណផលនេសាទចាប់ពីធម្មជាតិ ប្រចាំឆ្នាំ | ពាន់តោន | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ក.រ.ន. |
| ២៨ | បរិមាណផលិតផលវារីវប្បកម្ម ប្រចាំឆ្នាំ | ពាន់តោន | ២៤៨ | ២៩៨,៧ | ៣៥៨,៥ | ៤៣០,១ | ៥១៦,២ | ៦១៩,៤ | ផ.យ.អ.ជ. ២០១៤/២០១៨ | ក.ក.រ.ន. |
| ២៩ | ផលនេសាទនិងផលិតផលវារីវប្បកម្មនាំចេញប្រចាំឆ្នាំ | ពាន់តោន | ២០ | ២០ | ២០ | ៣០ | ៥០ | ៥០ | ផ.យ.អ.ជ. ២០១៤/២០១៨ | |
| ៣០ | ផ្ទៃដីដំណាំស្រូវដែលធន់នឹងអាកាសធាតុ | ហិកតា | ១,១ | ១,២ | ១,២៣ | ១,២៦ | ១,២៩ | ១,៣២ | | ក.ក.រ.ន. |
| ៣១ | លទ្ធភាពស្រោចស្រពដំណាំរួមផ្សំ (ក្នុងឆ្នាំនីមួយៗ) | ហិកតា | ៤ ៤១៣ | ៤ ៩១៣ | ៥ ៤១៣ | ៥ ៩១៣ | ៦ ៤១៣ | ៦ ៩១៣ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៣២ | ចំនួនសហគមន៍កសិករប្រើប្រាស់ទឹក(ក្នុងឆ្នាំនីមួយៗ) | សហគមន៍ | ៥៤៤ | ៥៥១ | ៥៥៨ | ៥៦៥ | ៥៧២ | ៥៧៩ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៣ | ចំនួនស្ថានីយបូមទឹកដែលបានសាងសង់ | ស្ថានីយ បូមទឹក | ៣១ | ៣៦ | ៤១ | ៤៦ | ៥១ | ៥៦ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៤ | ចំនួនស្ថានីយបូមទឹកដែលបានជួសជុល | ស្ថានីយ បូមទឹក | ០ | ៩ | ១៨ | ២៧ | ៣៦ | ៤០ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៥ | ចំនួនម៉ាស៊ីនបូមទឹក ដែលបានជួសជុល | កន្លែង | ០ | ១៨ | ៣៦ | ៥៤ | ៧២ | ៩០ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៦ | ចំនួនស្ថានីយជលសាស្ត្រវាស់កម្ពស់ទឹក ដែលបានដំឡើង | ស្ថានីយ ជលសាស្ត្រ | ៤៤ | ៦១ | ៧៨ | ៩៥ | ១១២ | ១២៩ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៧ | ចំនួនស្ថានីយជលសាស្ត្រ ដែលបានជួសជុល | ស្ថានីយ ជលសាស្ត្រ | ០ | ១២ | ១២ | ១២ | ១២ | ១២ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៨ | ចំនួនស្ថានីយឧតុនិយម ដែលបានជួសជុល | ស្ថានីយឧតុ និយម | ០ | ១២ | ២៤ | ៣៦ | ៤៨ | ៦០ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.ធ.ទ.ឧ. |
| ៣៩ | ចំនួនសហគមន៍តំបន់ការពារធម្មជាតិដែលបានសិក្សា និងរៀបចំបង្កើត | សហគមន៍ | ១៥៣ | ១២ | ១២ | ១២ | ១២ | ១២ | ក.ប.ស. | ក.ប.ស. |
| ៤០ | កម្មវិធីសាលាមេត្រីបរិស្ថាន | សាលារៀន | ០ | ១០០ | ១៥០ | ២០០ | ២៥០ | ៣០០ | ក.ប.ស. | ក.ប.ស. |
| ៤១ | កម្មវិធីអារាមមេត្រីបរិស្ថាន | វត្ត | ០ | ០ | ៥០ | ១០០ | ១៥០ | ២០០ | ក.ប.ស. | ក.ប.ស. |
| ៤២ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ផែនការ | ៨០ | ១៧៩ | ១៩៩ | ២១៩ | ២៣៩ | ២៥៩ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៤៣ | ប្លង់គោលប្រើប្រាស់ដី | ប្លង់គោល | ៩ | ៤២ | ៥០ | ៥៦ | ៦១ | ៦៩ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| | ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ | ប្លង់គោល | - | ១៩ | ២៥ | ២៩ | ៣៤ | ៣៨ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជន | ប្លង់គោល | ៩ | ២៣ | ២៥ | ២៧ | ២៩ | ៣១ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| ៤៤ | ផែនការរៀបចំដែនដី | ផែនការ | ៣ | ៨ | ១០ | ១៣ | ១៥ | ១៨ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| | ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ផែនការ | ៣ | ៧ | ៩ | ១១ | ១៣ | ១៥ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| | ផែនការរៀបចំដែនដីតាមតំបន់ | ផែនការ | - | ១ | ១ | ២ | ២ | ៣ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| | ផែនការរៀបចំដែនដីថ្នាក់ជាតិ | ផែនការ | - | ០ | ០ | ០ | ០ | ១ | ផ.យ.អ.ជ. ២០១៩/២០២៣ | ក.រ.ដ.ន.ស. |
| ៤៥ | ភាគរយនៃឃុំ/សង្កាត់ ដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ | % | ៤០ | ៣៩ | ៣៨ | ៣៧ | ៣៦ | ៣៥ | គ.អ.ច.ក. | ក.ប.ស./គ.អ.ច.ក. |
| ៤៦ | ចំនួនគោលនយោបាយ បទបញ្ញត្តិ គោលការណ៍ណែនាំ ផែនការយុទ្ធសាស្រ្ត អនុស្សារណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងពាក់ព័ន្ធការអភិវឌ្ឍន៍ដោយចីរភាព ( ជីវៈចម្រុះ និងជីវៈសុវត្ថិភាពការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចបៃតង វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ) | ចំនួន | ២៥ | ៥ | ៥ | ៥ | ៥ | ៥ | | គ.អ.ច.ក./ក.ប.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៤៧ | ចំនួនតំបន់ទីប្រជុំជន ក្រុងដែលបានអនុម័ត និងអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ២០១៨-២០៣០ | ចំនួនទីប្រជុំជនក្រុង | ៨ | ៨ | ១២ | ១២ | ១២ | ១២ | | គ.អ.ច.ក./ក.ប.ស. |
| ៤៨ | ចំនួនទីតាំងតាមដានគុណភាពទឹកសាធារណៈ និងទឹកកខ្វក់ ផ្អែកលើប៉ារ៉ាម៉ែត្រ pH DO BOD COD TSS TN TP NH3 Oil and Grease Coliform តាមគោលដៅកំណត់ក្នុងឆ្នាំ | ទីតាំង | ៤៥ | ៥២ | ៦១ | ៧១ | ៨១ | ៩១ | ក.ប.ស. | ក.ប.ស. |
| ៤៩ | ចំនួនទីតាំងចុះតាមដានគុណភាពខ្យល់សាធារណៈ ផ្អែកលើប៉ារ៉ាម៉ែត្រ CO NO2  SO2 O3  PM2.5 and PM10 នៅតាមគោលដៅក្នុងឆ្នាំ | ទីតាំង | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ក.ប.ស. | ក.ប.ស. |

# ជំពូកទី៧

# សេចក្តីសន្និដ្ឋាន

# ជំពូកទី ៧

# សេចក្តីសន្និដ្ឋាន

**៧.១.** តាមរយៈការរៀបចំផែនការ និងការវិនិយោគដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ លើវិស័យដើម្បីលើកកម្ពស់មូលធនមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និង វិស័យអាទិភាពសំខាន់ៗ ដែលជាកត្តាចម្បងសម្រាប់*ព្រះរាជាណាចក្រកម្ពុជា* បានវិវត្តខ្លួនពីប្រទេសដែលខ្ទេចខ្ទាំដោយសង្គ្រាមស៊ីវិលទៅជាប្រទេសមួយ ដែលមានសក្តានុពលសេដ្ឋកិច្ច និងជាប្រទេសគោលដៅនៃការវិនិយោគពីបរទេស របូតឈានជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ សមិទ្ធផលទាំងអស់នេះ ស្តែងចេញតាមរយៈ សហគ្រិនភាព និងការវិនិយោគឯកជន បានកើនឡើងជាបន្តបន្ទាប់ ដែលរួមចំណែកដល់កំណើន*ផ.ស.ស.* មធ្យមប្រចាំឆ្នាំវង្វង់៧% ក្នុងរយៈពេលវែង ដែល *ផ.ស.ស.* សម្រាប់មនុស្សម្នាក់ បានកើនលើសពី ១ ៥០០ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១៨ ហើយអត្រាភាពក្រីក្របានថយចុះមកកម្រិតទាបជាង១០% ក្នុងអាណត្តិនៃការអនុវត្ត*ផ.យ.អ.ជ. ២០១៤-២០១៨*។ ក្នុងន័យនេះដែរ ទំហំវិនិយោគឯកជននាពេលបច្ចុប្បន្នមានសមាមាត្រខ្ពស់ជាងទំហំវិនិយោគសាធារណៈ។ ការអនុវត្តប្រកបដោយជោគជ័យនូវបណ្តាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះបាននាំកម្ពុជាឲ្យចាកចេញពីប្រទេសនាំចូលស្បៀង ឈានឡើងទៅជាប្រទេសមួយក្នុងចំណោមប្រទេសទាំង១០ ដែលបាននាំចេញអង្ករទៅក្រៅប្រទេស និងក្នុងចំណោមប្រទេសទាំង១៥ ដែលបានផលិតអង្ករច្រើនជាងគេនៅក្នុងពិភពលោក។ វឌ្ឍនភាពសំខាន់ៗ ក៏បានបន្តមាននៅក្នុងវិស័យនិងកិច្ចសហប្រតិបត្តិការមួយចំនួន រួមមាន៖ ឧស្សាហកម្មវាយនភ័ណ្ឌ ដែលបានអនុញ្ញាតឲ្យកម្ពុជាក្លាយជាអ្នកផលិត និងនាំចេញផលិតផលវាយនភ័ណ្ឌ។ប្រទេសកម្ពុជាបានក្លាយទៅជាគោលដៅទេសចរណ៍ និងជាសមាជិកភាពនៃសហគមន៍អាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហគមន៍តំបន់ និងអន្តរជាតិ។ កម្ពុជា ក៏បានជំរុញកំណើនបរិមាណគ្រឹះស្ថាន អប់រំនៅទូទាំងប្រទេស ដែលក្នុងនោះ បឋមសិក្សាបានចំនួនជិត៧ ២០០ និងគ្រឹះស្ថានឧត្តមសិក្សាបានច្រើនជាង១២០ កន្លែង ជាពិសេស យើងបាននឹងកំពុងពង្រឹងគុណភាពអប់រំបន្ថែមទៀត។

**៧.២.** សម្រាប់ការអភិវឌ្ឍប្រទេសក្នុងដំណាក់កាល *ផ.យ.អ.ជ. ២០១៩-២០២៣* រាជរដ្ឋាភិបាលកម្ពុជានឹងបន្តប្តេជ្ញាអនុវត្តការងារ ដើម្បីឈានទៅសម្រេចបាននូវវឌ្ឍនភាពថ្មីៗបន្ថែមទៀត ក៏ដូចជា បញ្ចប់ឲ្យរួចរាល់នូវគោលនយោបាយ កម្មវិធី និងផែនការសកម្មភាព ដែលមិនទាន់បានដោះស្រាយនាអាណត្តិកន្លងមក និងត្រៀមទប់ទល់និងកាត់បន្ថយបញ្ហាប្រឈមទាំងឡាយ

នាពេលអនាគត រួមបញ្ចូលទាំងបញ្ហាប្រឈមនៅក្នុងតំបន់និងពិភពលោក និងការកាត់បន្ថយជំនួយសម្បទានពីខាងក្រៅ។ នៅក្នុងវដ្តបន្ទាប់នៃការដំណើរការរៀបចំ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងសកម្មភាព* តម្រូវឲ្យមានការគិតគូរច្បាស់លាស់ និងជំរុញអនុវត្តនូវដំណើរការចំនួនបី គឺ៖

- ការបង្កើនចំណូលថវិកាជាតិ ពីប្រភពពន្ធ-គយ និងមិនមែន-ពន្ធគយ ប្រកបដោយចីរភាព និងស៊ីជម្រៅ ។
- ការពង្រីកគុណភាពមូលធនមនុស្ស ផ្ទេកឧស្សាហូបនីយកម្ម និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជន។
- ការលើកកម្ពស់សមត្ថភាព ក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ សំដៅផ្តល់សេវាសាធារណៈ ដល់ប្រជាជន វិស័យឯកជន និងដៃគូនានា តាមរយៈ ការធ្វើទំនាក់ទំនង និងការបែងចែកព័ត៌មាន រវាងក្រសួង ស្ថាប័ន ការធ្វើសមាហរណកម្មការងាររវាងថ្នាក់ជាតិ និងបណ្តាក្រសួងនៅថ្នាក់ជាតិឲ្យកាន់តែប្រសើរឡើង និងការជំរុញអភិបាលកិច្ចអេឡិកត្រូនិក ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤។

**៧.៣.** *ផ.យ.អ.ជ. ២០១៩-២០២៣* គឺជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពរបស់*រាជរដ្ឋាភិបាលកម្ពុជា* សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ដូចមានចែងក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។ គោលបំណងរបស់ *ផ.យ.អ.ជ. ២០១៩-២០២៣* គឺដើម្បីធានាដល់ការបន្សុីគ្នារវាងផែនការសកម្មភាព កម្មវិធី និងគម្រោងរបស់បណ្តាក្រសួង ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលបានកំណត់ក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។ ក្នុងន័យនេះ *ផ.យ.អ.ជ. ២០១៩-២០២៣* ក៏ធានាផងដែរថា បណ្តាយុទ្ធសាស្ត្រដែលបានលើកឡើងដោយក្រសួង ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់នានាមកលើប្រទេសកម្ពុជា ដែលរួមមាន ការបន្តចាកចេញពីឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងការកាត់បន្ថយនូវជំនួយឥតសំណងនិងជំនួយបច្ចេកទេស។ ទន្ទឹមនឹងនេះ *ផ.យ.អ.ជ. ២០១៩-២០២៣* ក៏មានគោលបំណងធានាថា រាល់បណ្តាគោលនយោបាយ ដែលបានរៀបចំឡើង គឺធ្វើយ៉ាងណាដើម្បីគ្រប់គ្រង និង ប្រកួតប្រជែងទាំងក្នុងតំបន់ និង ពិភពលោក។ *រាជរដ្ឋាភិបាលកម្ពុជា* បាននិងកំពុងរៀបចំជាប្រព័ន្ធនិងជាលំដាប់លំដោយ នូវវិធានការជាច្រើន សំដៅកាត់បន្ថយឥទ្ធិពលអវិជ្ជមាននានាពីក្រៅប្រទេស និងកត្តាសេដ្ឋកិច្ចថ្មីៗផ្សេងទៀត មកលើប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ច

របស់កម្ពុជា ព្រមទាំងសំដៅការពារនូវសមិទ្ធផលនានា ដែលសម្រេចបាន ដោយកិច្ចខិតខំយ៉ាងលំបាកកន្លងមក។ សូចនាករម៉ាក្រូសេដ្ឋកិច្ច បានឆ្លុះបញ្ចាំងឲ្យឃើញនូវគោលបំណងការពារសមិទ្ធផលចម្បងៗកន្លងមករបស់ *ផ.យ.អ.ជ.* ដែលរួមមាន ការសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងអត្រាយ៉ាងហោចណាស់ប្រមាណ៧% ជាមធ្យមក្នុងមួយឆ្នាំ និងការកាត់បន្ថយអត្រានៃភាពក្រីក្រលើសពី១% ក្នុងមួយឆ្នាំ។

**៧.៤.** *ផ.យ.អ.ជ. ២០១៩-២០២៣* ក៏បានលើកឡើងពីតម្រូវការធនធានហិរញ្ញប្បទានដែលមានចំនួនច្រើនជាងការអនុវត្ត *ផ.យ.អ.ជ.* មុនៗ។ ទោះជាដូចនេះក្តី *រាជរដ្ឋាភិបាលកម្ពុជា* ជឿជាក់ថា ធនធានហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍ គឺជាចលករជំរុញមួយដ៏សំខាន់សម្រាប់ពន្លឿនការវិនិយោគ សកម្មភាព សមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ឲ្យបានសម្រេចរួមគ្នាក្នុងពេលតែមួយ។ ចលករនេះ មានសារសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ដែលកំពុងយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័នរបស់រដ្ឋាភិបាល។

**៧.៥.** ដំណើរការនៃការរៀបចំ*ផ.យ.អ.ជ.* នេះ បានបង្ហាញពីវិធីសាស្ត្រច្នៃប្រឌិត ដែលរួមមាន៖ ការប្រមែប្រមូលព័ត៌មានតាមនីតិវិធី *ពីក្រោមឡើងលើ* សំដៅធ្វើការកំណត់នូវ*អ្នកទទួលខុសត្រូវនិងអនុវត្តសកម្មភាពសំខាន់ៗ* និង *ថវិកា* ដែលត្រូវចំណាយក្នុងការអនុវត្តផែនការសកម្មភាពដែលបានស្នើឡើង។ ជាមួយគ្នានេះ នីតិវិធី*ពីលើចុះក្រោម* ពឹងផ្អែកលើការវិភាគបែបបរិមាណអំពីនិន្នាការនៃការវិវត្តរបស់ស្ថានភាពរួមនៃសេដ្ឋកិច្ច។ បន្ថែមលើវិធីសាស្ត្រខាងលើនេះ*ក្រសួងផែនការ* បានអនុវត្តការងារជាក់លាក់មួយចំនួន ដើម្បីធានាឲ្យមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ព្រមជាមួយគ្នានឹងការធានាផងដែរថា បណ្តាដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលដទៃទៀតត្រូវបានផ្តល់នូវកាលានុវត្តភាពដើម្បីចូលរួមយ៉ាងសកម្មក្នុងការកំណត់ពីលទ្ធផល (ដូចជា ផលប៉ះពាល់របស់គោលនយោបាយ កម្មវិធី និងគម្រោងសកម្មភាព) ក្នុងដំណើរការនៃការរៀបចំធាតុចូលនិងចំណុចដៅទាំងឡាយ។

**៧.៦.** ដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៅក្នុង*ផ.យ.អ.ជ.* នេះ ក៏បានលើកឡើងផងដែរពី*ក្របខ័ណ្ឌលទ្ធផល* ដើម្បីធានាថា រាល់ធាតុចូលទាំងអស់ ត្រូវឆ្លើយតបនឹងសកម្មភាព ធាតុចេញ លទ្ធផល និងឥទ្ធពល យ៉ាងត្រឹមត្រូវ។ ដើម្បីបន្តដំណើរការរៀបចំកែលម្អសូចនាករ និងចំណុចដៅសំខាន់ៗ សម្រាប់ការតាមដានត្រួតពិនិត្យ *ផ.យ.អ.ជ. ២០១៩-២០២៣* និងការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត *ផ.យ.អ.ជ. ២០១៩-២០២៣ ក្រសួងផែនការ* បានកំណត់បន្តតួនាទីរបស់*ក្រុមការងារជាតិសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ.* ដែលដឹកនាំដោយ *ក្រសួងផែនការ*។ ដូចដែលបានលើកឡើងក្នុងជំពូកទី ៦ ក្រុមការងារជាតិបានយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញភារកិច្ចរៀបចំឲ្យមាន និយាមនិយមន័យរបស់បណ្តា

សូចនាករ និងការកំណត់និយមន័យសូចនាករថ្មីៗផ្សេងទៀត ដើម្បីបង្កបរិយាកាសងាយស្រួលក្នុងការតាមដានត្រួតពិនិត្យនូវលទ្ធផល ដែលបានពីការចំណាយសម្រាប់ការអនុវត្តផែនការ។ ក្រុមការងារជាតិ គឺជា*គណៈកម្មាធិការកណ្តាល*និងមានតួនាទីតាមដានរាល់វឌ្ឍនភាពក្នុងអំឡុងពេលនៃការអនុវត្ត*ផ.យ.អ.ជ. ២០១៩-២០២៣*។ ជាមួយគ្នានេះ កិច្ចការរបស់ក្រុមការងារជាតិក៏រួមមាន ការលើកកម្ពស់ដំណើរនៃតាមដានត្រួតពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការ ប្រសិនបើមានការចាំបាច់។ ដូច្នេះ *ផ.យ.អ.ជ.* ធានាបាននូវភាពទន់ភ្លន់ក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ក្រុមការងារជាតិ ក៏បានរៀបចំឲ្យមានឋានានុក្រមនៃសូចនាករទាំងឡាយ ដោយបានរៀបចំពីកម្រិតខ្ពស់ (ចាប់ពីកម្រិតសេដ្ឋកិច្ច កម្រិតអន្តរវិស័យ។ល។) កម្រិតបន្ទាប់(ធាតុចេញ/លទ្ធផលតាមវិស័យ) និងកម្រិតក្រោមបន្ទាប់ គឺធាតុចេញ/លទ្ធផល តាមអនុវិស័យ និងកម្រិតក្រោមបង្អស់ គឺធាតុចូល។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

# ពាក្យបំប្រួញ

| | |
|---|---|
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ក.រ.ន. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ក.ប.វ. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ជ.ត.វ.ប.អ. | ក្របខ័ណ្ឌជាតិនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីការប្រែប្រួលអាកាសធាតុ |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ក.ប.ស. | ក្រសួងបរិស្ថាន |
| ក.ផ.ក. | ក្រសួងផែនការ |
| ក.ព.ក. | ក្រសួងពាណិជ្ជកម្ម |
| ក.រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| ក.រ.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ធ.ទ.ឧ. | ក្រសួងធនធានទឹកនិងឧតុនិយម |
| ក.ម.ផ. | ក្រសួងមហាផ្ទៃ |
| ក.ម.ស. | ក្រសួងមុខងារសាធារណៈ |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.យ.ច. | ក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ |
| ក.ស.ដ. | ក្រសួងសាធារណៈការនិងដឹកជញ្ជូន |
| ក.ស.ហ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ស.ភ. | ក្រសួងសុខាភិបាល |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ក.អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ក.ឧ.ស. | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម |
| គ.ម. | គីឡូម៉ែត្រ |
| គ.ម.$^2$ | គីឡូម៉ែត្រការ៉េ |
| គ.វ.ម៉. | គីឡូវ៉ាត់ម៉ោង |
| គ.អ.ច.ក. | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ទ.ឃ.ស. | ទិន្នន័យឃុំ សង្កាត់ |
| ប.ព.រ.ក.ស. | ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់ក្រសួង ស្ថាប័ន |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |

| | |
|---|---|
| ព.ច.ស.ប.អ. | ការពិនិត្យមើលឡើងវិញពីការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ |
| ភ១.ផ១. | ភូមិមួយផលិតផលមួយ |
| ម. | ម៉ែត្រ |
| ម.³ | ម៉ែត្រត្រីគុណ |
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| រ.ល.អ.ស. | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| វ.ជ.ស. | វិទ្យាស្ថានជាតិស្ថិតិ |
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ហ.ត. | ហិកតា |
| អ.ក.គ.ស. | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីនិងសង្គ្រោះជនពិការដោយសារមីន |
| អ.ប.ស.ក. | អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| អ.ល.-ក.ជ.វ.ប. | អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា |
| អ.ស.ស.ក. | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |

**ឧបសម្ព័ន្ធទី២**

# គេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា

| ល.រ. | ក្រសួង ស្ថាប័ន | គេហទំព័រ(www) |
|---|---|---|
| ១ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cdc- crdb.gov.kh |
| ២ | គណៈកម្មាធិការវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cib-cdc.gov.kh |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | civilaviation.gov.kh |
| ៤ | អាជ្ញាធរជាតិកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | cmaa.gov.kh |
| ៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | mih.gov.kh |
| ៦ | សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា | card.gov.khf |
| ៧ | ក្រសួងព័ត៌មាន | information.gov.kh |
| ៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | maff.gov.kh |
| ៩ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | mcfa.gov.kh |
| ១០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | mef.gov.kh |
| ១១ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | mfaic.gov.kh |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | mlmupc.gov.kh |
| ១៣ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | mlvt.gov.kh |
| ១៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | mnasrl.gov.kh |
| ១៥ | ក្រសួងពាណិជ្ជកម្ម | moc.gov.kh |
| ១៦ | ក្រសួងធម្មការនិងសាសនា | mocar.gov.kh |
| ១៧ | ក្រសួងការពារជាតិ | mod.gov.kh |
| ១៨ | ក្រសួងបរិស្ថាន | moe.gov.kh |
| ១៩ | ក្រសួងអប់រំ យុវជន និងកីឡា | moeys.gov.kh |
| ២០ | ក្រសួងសុខាភិបាល | moh.gov.kh |
| ២១ | ក្រសួងមហាផ្ទៃ | moi.gov.kh |
| ២២ | ក្រសួងយុត្តិធម៌ | moj.gov.kh |
| ២៣ | ក្រសួងផែនការ | mop.gov.kh |
| ២៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | mosvy.gov.kh |
| ២៥ | ក្រសួងទេសចរណ៍ | mot.gov.org |
| ២៦ | ក្រសួងកិច្ចការនារី | mowa.gov.kh |
| ២៧ | ក្រសួងធនធានទឹកនិងឧតុនិយម | mowram.gov.kh |
| ២៨ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | mptc.gov.kh |
| ២៩ | ក្រសួងសាធារណការនិងដឹកជញ្ជូន | mpwt.gov.kh |
| ៣០ | ក្រសួងអភិវឌ្ឍន៍ជនបទ | mrd.gov.kh |
| ៣១ | ក្រសួងមុខងារសាធារណៈ | mcs.gov.kh |

| | | |
|---|---|---|
| ៣២ | ក្រសួងរ៉ែ និង ថាមពល | mme.gov.kh |
| ៣៣ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | naa.org.kh |
| ៣៤ | ធនាគារជាតិនៃកម្ពុជា | nbc.org.kh |
| ៣៥ | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ncdd.gov.kh |
| ៣៦ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ncdm.gov.kh |
| ៣៧ | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | cnmc.gov.h |
| ៣៨ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ | cnm.gov.kh |
| ៣៩ | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | nacd.gov.kh |
| ៤០ | វិទ្យាស្ថានជាតិស្ថិតិ | nis.gov.kh |
| ៤១ | សាលារាជធានីភ្នំពេញ | phnompenh.gov.kh |
| ៤២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | pressocm.gov.kh |
| ៤៣ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | snec.gov.kh |